ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៣-១៤
13 – 14

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

BIBLIOTHÈQUE ROYALE DU CAMBODGE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

1942

សេចក្ដីជូនដំណឹង

ព្រះរាជបណ្ណាល័យសូមជូនដំណឹងដល់លោក-អ្នកទាំងឡាយ.

ដ្បិតព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរឿងថ្មីៗ នឹងបោះពុម្ពសៀវភៅចាស់ដែលចំណាយអស់ទៅ រួមជាច្រើនរឿងដូចមានរាយឈ្មោះខាងក្រោមនេះ:

ចំពោះរឿងដែលបោះពុម្ពថ្មី:

១) ក្រុងសុភមិត្រពាក្យកាព្យភាគទី ២ និងទី ៣ តសេចក្ដីពីភាគទី ១ មក ដែលព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរួចមកហើយកាលពីឆ្នាំមុននេះ ដូច្នេះ អស់លោកដែលបានជាវភាគទី ១ រួចហើយ សូមអញ្ជើញទៅជាវភាគទី ២-៣ ទៀតទើបចប់រឿង ភាគទី ២ នោះដំថ្លៃជាវ ១ ក្បាល ០រ.៤០ ភាគទី ៣ ដំថ្លៃ ១ ក្បាល ០រ.៣៥ ។

២) ច្បាប់ផ្សេងៗគឺ: វិធូរបណ្ឌិត ១ ច្បាប់ទូន្មានខ្លួន ១ ច្បាប់ពាក្យចាស់ ១ រួមគ្នាជាមួយក្បាល ស្រង់ចេញពីច្បាប់សាស្ត្រស្លឹករឹត ច្បាប់ផ្សេងៗនេះ ១ ក្បាលដំថ្លៃ ០រ.២០ ។

៣) សុក្កិសូត្រ មានទាំងបាលីទាំងសម្រាយ ជាធម៌សម្រាប់សូត្រសុំទឹកភ្លៀងតាមទំនៀមស្រុក ៗ តាមទំនៀមស្រុកខ្មែរពីដើមនោះតែកាលណាស្រុកទេសកើតរាំងភ្លៀងគ្មានទឹកនឹងធ្វើស្រែចំការច្បារដំណាំ អ្នកស្រុកច្រើនតែនិមន្តព្រះសង្ឃឲ្យសូត្រសុក្កិសូត្រនេះ ប៉ុន្តែទំលាប់មាត់អ្នកស្រុកច្រើននិយាយថា "សូត្រសុកោត្ត" ។ សៀវភៅនេះដំថ្លៃ ១ ក្បាល ០រ.២០ ។

៤) ច្បាប់សុភាសិត ពាក្យកាព្យ មានទាំងបាលីទាំងសម្រាយ ជាពាក្យទូន្មានជនប្រុស-ស្រី ជាស្នាដៃរបស់លោកឧកញ៉ាវង្សាសរពេជ្ញ នង ជាចិត្តករដ៏ជាន់ចាស់ ក្នុងរជ្យព្រះករុណាព្រះបរមកោដ្ឋព្រះអង្គដួង សៀវភៅនេះ ១ ក្បាលដំឡៃ ០រ.២៥ ។

ចំពោះរឿងដែលបោះពុម្ពឡើងវិញ :

១) អត្តានុសាសនិ៍ ជាសេចក្ដីទូន្មានខ្លួនឲ្យតាំងនៅក្នុងសម្មាបដិបត្តិតាមព្រះពុទ្ធឱវាទ ដំឡៃថ្មី ១ ក្បាល ០រ.៣៥ ។

២) គតិលោក ភាគទី១ ជាស្នាដៃរបស់លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ជាចិត្តករឯក ក្នុងរជ្យព្រះករុណាស៊ីសុវត្ថិព្រះបរមរតនកោដ្ឋ ដំឡៃថ្មី ១ ក្បាល ០រ.២០ ។

៣) បញ្ចអភិណ្ហប្បច្ចវេក្ខណៈ ជាធម៌សម្រាប់ឲ្យពុទ្ធសាសនិកជនពិចារណាឲ្យរឿយៗ មាន ៥ ប្រការ ជាស្នាព្រះហស្តសម្ដេចព្រះរាជអយ្យកោ វរចក្រណាបុទ្ធ ដំឡៃថ្មី ១ ក្បាល ០រ.១២ ។

៤) គិហិបដិបត្តិពិស្ដារ សំដែងពីវិធីបដិបត្តិរបស់ពួកឧបាសកឧបាសិកាតាមច្បាប់ព្រះពុទ្ធសាសនា សៀវភៅនេះបោះពុម្ពច្រើនលើកមកហើយ ដំឡៃថ្មី ១ ក្បាល ០រ.៥៥ ។

សៀវភៅអស់នេះ មានចំណាយនៅព្រះរាជបណ្ណាល័យកម្ពុជា និងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅទាំងក្នុងក្រុងនិងខេត្តក្រៅ ។

បញ្ជីរឿង

ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៦ លោកគ្រូអាចារ្យ សា-ឌុម ក្រុមជំនុំព្រះត្រៃបិដក សំដែង ១

២ — អំពីមហាចិន្តកវីកាលីទាសៈ និងកិច្ចការដ៏ថ្លៃថ្នូររបស់លោក ១១

៣ — ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់ៈ ១ — ប្រវត្តិនាងសុជាតា-សេនិយធីតា ២១

៤ — លោកនេយ្យ ពាក្យកាព្យ របស់អ្នកឧកញ៉ាវង្សាសព្វេជ្ញ ឌង (តមក) . . ២៤

៥ — ពិធីទ្វាទសមាស តាមទំនៀមព្រាហ្មណ៍ក្នុងនគរពារាណសី (តទៅ) . . . ៣២

៦ — ភូមិសាស្ត្រសង្ខេបនៃនានាប្រទេសៈ អំពីភូមិសាស្ត្រនៃប្រទេសអាមេរិកកណ្ដាល. ៣៩

៧ — ពង្សាវតារក្រុងរោម ស្រង់យកអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) ៤១

៨ — រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គឹម-អាន ប្រែចេញពីភាសាបារាំង-សែសមកជាខេមរភាសា (តមក) ៤៤

៩ — ប្រស្នាចំរើនសតិបញ្ញាៈ

១) សួរនិងឆ្លើយអំពីខ្លាក់និងខ្ទិន (តមកនិងចប់). ៥៣

២) សួរនិងឆ្លើយអំពីសក់ ៥៥

៣) សួរនិងឆ្លើយអំពីស្វានិងជារី ៥៧

៤) សួរនិងឆ្លើយអំពីពុកមាត់ ៥៩

១ — រឿងព្រេងខ្មែរៈ "រឿងបុរសបាញ់ទុង" ៦១

TABLE DES MATIÈRES

Pages

1. Vidyudesanā (Conférence faite à la Radio Phnom-Penh) par le vénérable Sa-Doum, membre de la Commission du Tripitaka 1

2. Kalidāsā, grand poète de l'Inde, et ses œuvres 11

3. Vies des disciples du Bouddha: I. Vie du Sujatā-Seniyadhitā. 21

4. Lokaneyya, poème par feu l'Oknha Vongsāsarpejña Nong (suite) 24

5. Cérémonies brahmaniques des douze mois à Bénarès (Inde) .. 32

6. Géographie sommaire de divers pays: l'Amérique centrale ... 35

7. Histoire de Rome, extraits de divers documents de l'histoires universelle (suite) 41

8. Légende de l'Empereur Açoka de l'Inde antique, par feu l'Achar Kim-Ann (suite) 44

9. Réflexions sur les phénomènes naturels:

I. Dialogue sur l'aveugle et le paralytique (suite et fin) ... 53

II. Dialogue sur les cheveux 55

III. Dialogue sur la fumée de cigarette et la chique de bétel 57

IV. Dialogue sur les barbes 59

10. Conte populaire cambodgien inédit: "Un chasseur de péli-

វិទ្យុធម្មទេសនា កណ្ឌទី ៦

លោកគ្រូអាចារ្យ សា-ឌុម ក្រុមជំនុំព្រះត្រៃបិដក សំដែង

នៅថ្ងៃពុធ ៨ រោច ខែចេត្រ ឆ្នាំម្សាញ់ត្រីស័ក ពុទ្ធសករាជ ២៤៨៤ ។

សន្តិកថា

សន្តមគ្គមេរ ព្រហាយ ។

វេលានេះ នឹងពណ៌នាអំពីសន្តិភាព (សេចក្តីស្ងប់) ដែលរាប់ថាជាកំពូលនៃសេចក្តីសុខយ៉ាងសំខាន់ ដើម្បីឲ្យត្រូវតាមបំណងពុទ្ធសាសនា ។ ឥឡូវនេះ នៅសេសចំនួន ៤-៥ ថ្ងៃទៀតទេ នឹងដល់ការលះឆ្នាំចាស់ ចូលឆ្នាំថ្មី ។

សម័យនេះហើយ ដែលពួកយើងគួរប្រែគំនិតដែលធ្លាប់ពុលដោយល្បែងស្រី ល្បែងស្រា និងល្បែងបៀជាដើមពីឆ្នាំចាស់ ផ្លាស់ឲ្យបានជាគំនិតថ្មីជាល្អវិញ ។ សម័យនេះហើយ ដែលពួកយើងត្រូវស្វែងរកសេចក្តីស្ងប់ ដោយការពួតដៃវេញចូលធ្លុងគ្នាជាពួក ។ សម័យនេះហើយ ដែលពួកយើងត្រូវតាំងចិត្តមេត្តាក្រឡេកមើលគ្នាដោយនេត្រាដ៏ស្រទន់ មិនរិះគន់រកទោសគ្នាទៅវិញទៅមក ។ សម័យនេះហើយដែលពួកយើងត្រូវរឭកដល់គុណនៃគ្នានិងគ្នា ជាគ្រឿងបង្កឲ្យកើតសាមគ្គីស្មោះស័គ្រ ប្រឹងស្វែងរកសេចក្តីស្ងប់ ។

ជនជាតិណាក៏ដោយ ឲ្យតែមានកំណើតកើតឡើងអាស្រ័យធាតុបួន គឺ ដី ទឹក ភ្លើង ខ្យល់ហើយ សុទ្ធតែមានអធ្យាស្រ័យស្រឡាញ់សេចក្តីសុខ ស្អប់ខ្ពើមទុក្ខទាំងអស់ ។ សេចក្តីទុក្ខជាគ្រឿងបង្អើលឲ្យស្វែងរកសុខ ស្អប់ខ្ពើមទុក្ខទាំងអស់ ។ សេចក្តីសុខជាគ្រឿងបង្អើលឲ្យស្វែងរកព្រះនិព្វាន ។ បើទុកជាមានលំនាំយ៉ាងនេះក្តី ក៏គង់នៅមានជនជាច្រើនស្ទើរតែពេញលោក ប្រែត្រឡប់ជាខ្វះខ្វែងស្វែងរកសេចក្តីសុខមិនបានបេះតែឃ្វាងផ្លូវផ្កាប់ទៅវិញ ។ ទាំងនេះ មកពីមិនមានគំនិតឆ្ពុះមុតយល់ដល់មូលហេតុ ដែលជាដើមចមនៃសេចក្តីសុខ មានជនខ្លះថែមទាំងមិនស្គាល់សេចក្តីសុខទៅទៀតផង ។ យ៉ាងនេះតើកាលណា នឹងស្វែងរកសេចក្តីសុខបាន ព្រោះសេចក្តីសុខចាត់ដោយប្រភេទមាន ២ យ៉ាងគឺសេចក្តីសុខបឋម ដែលហៅថា សាមិសសុខ (សុខអាស្រ័យនុយ) មួយយ៉ាង សេចក្តីសុខពិត ដែលហៅថា និរាមិសសុខ (សុខមិនអាស្រ័យនុយ) មួយយ៉ាង ។

ចុះនុយបានដល់អ្វី ? នុយបានដល់លាភ យស សរសើរ សុខ ឬ រូប សំឡេង ក្លិន រស ផ្សព្វ ដែលជាទីប្រាថ្នា ។ សេចក្តីត្រេកត្រអាលជក់ចិត្តក្នុងនុយទាំងនោះ ចាត់ជាសេចក្តីសុខបឋម ព្រោះរមែងប្រែក្លាយទៅជាសេចក្តីទុក្ខចិត្តទោមនស្សអាក់អន់ក្នុងខ្លួនវិញ ។

វិញ្ញូជនគួរឃើញថា ដូចសេចក្តីសុខរបស់ត្រី ដែលត្រេកត្រអាលប្រឹងលេបនុយដោយទាំងសន្ធូច លួមយល់ថាឲ្យសុខមែន តែក្នុងវេលា

ដែលប្រឹងផញ្ចក់ផញ្ចាបលេបមនុស្ស រួចហើយគង់ប្រែក្រឡាប់ទៅជាសេចក្ដីទុក្ខវិញ ក្នុងវេលាដែលសន្ធប់ជាប់ក ៗ ដំណើរនេះ នាំឲ្យឃើញច្បាស់ដល់ព្រះបាលីថា . សុខស្សានន្តរំ ទុក្ខំ សេចក្ដីទុក្ខកើតជាលំដាប់នៃសេចក្ដីសុខ គឺថាសេចក្ដីសុខកើតមានហើយ គង់ប្រែខ្វទៅជាសេចក្ដីទុក្ខវិញ ៗ សេចក្ដីសុខបួមបែបនេះ អ្នកប្រាជ្ញខាងពុទ្ធសាសនាមិនត្រូវការ គឺមិនបណ្ដោយចិត្តឲ្យទទួលរីករាយ ដោយសំគាល់ថា ជាសេចក្ដីសុខមែន លោកតែងនាំគ្នាបោះបង់ចោល ហើយប្រឹងស្វះស្វែងរកតែសេចក្ដីសុខពិតឥតប្រែក្លាយ ដែលជាតួនិរាមិសសុខ (សុខមិនអាស្រ័យនុយ) គឺជាមិនបាច់ដើរមើលល្បែងក៏សុខ មិនបាច់លេងបៀ ផឹកស្រា ជក់អាភៀនក៏សុខ មិនបាច់ដើរលេងស្រីឬមានប្រពន្ធច្រើនក៏សុខ ដរាបដល់មិនបាច់មានប្រពន្ធមានកូនសោះក៏សុខ ៗ មួយទៀត សេចក្ដីសុខនេះ កើតមានឡើងអាស្រ័យសេចក្ដីស្ងប់ៗកប់ថាជាកំពូលឬជាមូលហេតុនៃសេចក្ដីសុខៗ ដំណើរនេះ អាចឃើញបានដោយផ្ទុំលោក . ចំណោមជនដែលនៅរួមរួមគ្នាជាពួកៗ តាំងអំពីនៅរួមរួមគ្នាជាប្ដីប្រពន្ធឡើងទៅ ដរាបដល់ការនៅរួមឃុំ រួមខេត្ត រួមក្រុង រួមដែន និងរួមកិច្ចការផ្ទញ្ញប្រែ ដែលត្រូវអាស្រ័យគ្នា និងទាក់ទិនគ្នាទៅវិញទៅមក បើប្រសិនជាគ្មានសេចក្ដីស្ងប់ គឺថាបេះតែច្រលច្រើមដោយវិវាទបែកសាមគ្គី រករឿងចាប់ទោសអួសដំណើរគ្នាជារឿយៗហើយ មុខជានឹងមានតែសេចក្ដីទុក្ខ រកសេចក្ដីសុខគ្មាន ៗ

ហេតុនេះ បានជាអ្នកប្រាជ្ញមានព្រះសព្វញ្ញុពុទ្ធជាដើម តែងនាំគ្នាស្វែងរកឧបាយធ្វើឱ្យកើតសេចក្តីស្ងប់ គឺប្រដៅឱ្យធ្វើទានចែកសេចក្តីសុខដល់គ្នានឹងគ្នា ធ្វើសមាធិហាត់ចិត្តឱ្យស្ងប់ មិនឱ្យពុះក្តៅដោយសេចក្តីលោភ ក្រោធ វង្វេង ធ្វើបញ្ញាពិចារណាកងសង្ខារដាក់បញ្ចុះចិត្តស៊ប់ថា មិនទៀងជាទុក្ខនឹងអនត្តា ត្រាតែពុះបំបែកនូវឧបាទាន (សេចក្តីប្រកាន់មាំ) ថារបស់អញ ជាអញ ជាខ្លួនប្រាណនៃអញ ដែលជាមេបង្កឱ្យទួលនេះក្តៅក្រហាយចេញ ៗ ព្រោះ ទាន សីល ភាវនានេះ មានគុណយ៉ាងសំខាន់ នាំនាំបណ្តាលឱ្យកើតសេចក្តីស្ងប់ល្អ បានជាព្រះសាស្តាទ្រង់ប្រោសប្រទានទុកឲ្យថា សន្តិមគ្គមេវ ព្រូហយ អ្នកចូរប្រឹងចំរើនឧបាយនៃសេចក្តីស្ងប់ គឺ ទាន សីល ភាវនា ចុះ នត្ថិ សន្តិ-បរំ សុខំ (ព្រោះ) សេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់មិនមាន គឺជាមានសេចក្តីស្ងប់ជាកំពូល ឬជាមូលហេតុទាំងអស់ ៗ ពួកយើងគួរខ្មីឃ្មាតរកឧបាយសាងសេចក្តីស្ងប់ ដោយការព្រមព្រៀងប្រកបកិច្ចល្អគ្រប់គ្នាទៅ កុំដេកដ៏អក់ចាំទទួលយកសេចក្តីសុខតែម្តងនោះ មិនបានទេ ៗ

មួយទៀត ឧបាយនៃសេចក្តីស្ងប់ដទៃ ក្រៅអំពី ទាន សីល ភាវនា មិនមាន គួរយើងធ្វើទាន ធ្វើសីល ធ្វើភាវនា ទើបបានស្ងប់ ៗ ហេតុអ្វី? ហេតុថា ទានជាគូប្រតិបក្ខនូវមច្ឆរិយៈ ៗ មានលក្ខណៈហួងទុកនូវទ្រព្យរបស់ខ្លួន ៗ ទានមានលក្ខណៈចែកចាយទ្រព្យទុកបម្រុងខ្លួន ទាំងចែក

ចាយដល់អ្នកដទៃ ដោយប្រាថ្នាបូជាគុណ ឬអនុគ្រោះ ។ មច្ឆរិយៈជាកិលេសមួយយ៉ាងអាក្រក់ បណ្ដាលឲ្យពុះក្ដៅ ឲ្យមានអធ្យាស្រ័យចង្អៀតដកពុដល់ប្រៀតរកសេចក្ដីសុខខ្លួនឯងមិនបាន នាំឲ្យរក្សាតែទ្រព្យទុកដូចពស់ថ្លាន់វណ្ឌដំបូក ក្អែបានដូងនឹងការក្រទឹករក្សាស្រះ មិនសម្រេចប្រយោជន៍ខ្លួននឹងអ្នកដទៃ មានតែសេចក្ដីពុះក្ដៅភ័យរន្ធត់ក្រែងទ្រព្យវិនាស នាំឲ្យបែកបាក់បាកមិត្រ បង្កលោភឲ្យកាន់តែក្រាស់ឡើងៗ បើឃើញស្មូមយាចក ញាតិ មិត្រ ត្រឡប់មកដល់ រមែងញ័ររន្ធត់ មិនអាចសំដែងទឹកមុខឲ្យស្រស់ញញឹមបាន ធ្វើឲ្យមានដំណើរចង្អៀត ដកចប្រែកប្រៀតរកៈ បាយសេចក្ដីសុខមិនកើត រវល់តែសំកុកចាំទ្រព្យដែលខ្លួនហួងទល់ស្លាប់ ។ មច្ឆរិយៈនេះមានក្រាស់ក្រួនៅក្នុងចិត្តបុគ្គលណា បុគ្គលនោះលោកហៅថា អសប្បុរស ទ្រព្យអសប្បុរសមិនសម្រេចប្រយោជន៍ដល់ជនដទៃ ព្រោះគ្មានមេត្តាប្រាថ្នាឲ្យអ្នកដទៃបានសុខទេ គិតឲ្យបានតែសុខខ្លួន ទោះបីប្រថុយចែកចាយទ្រព្យដល់អ្នកដទៃ ទាល់តែឃើញកម្រៃវិលត្រឡប់មកវិញមួយជាពីរឡើងទៅ ដូចជនខ្លះគ្រាន់តែឲ្យចេកអំបូងត្រឹមមួយកំណាត់ត្អូញចង់បានសម្បត្តិសេដ្ឋី ។ យ៉ាងនេះតើ ទីងទាក់ថាជាអ្នកមានអធ្យាស្រ័យស្ងប់ល្អដូចម្ដេចបាន ។ ហេតុហ្នឹង បានជាព្រះទ្រង់ញាណត្រាស់ទុកថា មច្ឆេរំ ធនតោ មលំ សេចក្ដីកំណាញ់ជាមន្ទិលនៃអ្នកឲ្យ គឺថាសួះចិត្តសួះគំនិតឲ្យមានអធ្យាស្រ័យចង្អៀត ។

ឧបាយដែលនឹងផ្ចាញ់សេចក្ដីកំណាញ់ឲ្យខ្ចាត់ចេញបាននោះ ទាល់តែធ្វើទាន តាំងចិត្តផ្សាយមេត្តាករុណា ប្រាថ្នាឲ្យជាប្រយោជន៍ដល់ជនដទៃ ដោយបំណងបូជាគុណឬអនុគ្រោះ ហេតុនេះបានជាព្រះទ្រង់យសត្រាស់ប្រដៅទុកថា ជិនេ កទរិយំ ទានេន ត្រូវផ្ចាញ់សេចក្ដីកំណាញ់ដោយទាន ៗ ទានមានគុណជាអនេក គឺអាចកំចាត់សេចក្ដីកំណាញ់ ជាសំគសត្រូវជាប់តាស្ងប់ ធ្វើអធ្យាស្រ័យនឹងដំណើរឲ្យធំទូលាយល្អ ចងបាច់អ្នកដទៃដែលជាមិត្រស្រាប់ ឲ្យរឹងរឹតតែមានសេចក្ដីស្និទ្ធមេត្រីខ្ជាំងឡើង ដែលមិនមែនជាមិត្រឲ្យជាមិត្រថែមឡើងទៀត ទើបព្រះបរមនាថត្រាស់ទុកថា ទទំ មិត្តានិ គន្ថតិ ចងអ្នកដទៃមកជាមិត្របានអាស្រ័យការឲ្យ គឺជាគ្រូឲ្យធម៌ ក៏ឲ្យធម៌ គ្រូឲ្យអាមិស ក៏ឲ្យអាមិស ៗ ទាន មានគុណសម្បត្តិឲ្យកើតស្ងប់ត្រជាក់ស្រួលក្នុងចិត្តខ្លួននិងអ្នកដទៃជាដើមដូច្នេះ បានជាព្រះសាស្ដាត្រាស់ប្រដៅឲ្យធ្វើ មិនតែប៉ុណ្ណោះ ថែមតាំងរៀងទុកទានដើមនៃបារមីធម៌តាំង ១០ ផង ៗ ពួកយើងគួររំពឹងរកគុណនៃទានឲ្យឃើញជាក់លាក់ដោយខ្លួនឯង ៗ

ចំណែកខាងសីល ជាគូប្រឆាំងនូវវីតិក្កមកិលេស គឺលោភ ក្រោធ វង្វេង ដ៏គ្រៀវក្រា ដែលអាចញ៉ាំងកាយនិងវាចាឲ្យបៀតបៀនខ្លួននិងអ្នកដទៃ គឺឲ្យប្រព្រឹត្តបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងក្រេបផឹកនូវសុរានឹងមេរយជាទីតាំងនៃសេចក្ដីប្រមាទ ដែលហៅថា បញ្ចវេរ (អំពើ

លាមក ៥ យ៉ាង) ។ បញ្ចវេរនេះ ជាអំពើថោកអាក្រក់ពន់ពេក បណ្តាលឲ្យកើតមានភ័យរន្ធត់ក្តៅក្រហាយដល់ខ្លួនទាំងជនដទៃ ហើយជាគ្រឿងគាស់បំផ្លាញឫសគល់របស់មនុស្សថែមទៀតផង នាំឲ្យបែកសាមគ្គីបងពៀរវេរាដល់គ្នានឹងគ្នា មិនមែនមានគុណប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់បានឡើយ ព្រោះចំហាយភ្លើងគឺបញ្ចវេរនេះ ចេញមកអំពីភ្លើង ៣ គំនរ គឺភ្លើង រាគៈ ទោសៈ មោហៈ ដែលក្តៅបំផុតរកភ្លើងអ្វីដូចគ្មាន មនុស្សអ្នកប្រកបបញ្ចវេរ រមែងបែរមុខទៅរកអបាយ ដែលមានសេចក្តីក្តៅក្រហាយចិត្តជាវិបាក ។ បុគ្គលឯណាស្វែងរកសេចក្តីសុខខ្លួនដោយការប្រព្រឹត្តបញ្ចវេរ បុគ្គលនោះឥតបានសេចក្តីសុខក្សេមឡើយ មានតែរងទុក្ខក្តៅក្រហាយដរាប បើទុកជាមានសេចក្តីពេញចិត្តប្រព្រឹត្តបញ្ចវេរដោយវង្វេងថាបានសុខ ក៏គង់ប្រែក្លាយជាទុក្ខធំវិញ ដូចលេបថ្នាំពិសលាយទឹកឃ្មុំ ឲ្យសុខស្រួលបានខ្លះ តែក្នុងរវាងលេបរួចហើយ ក៏នឹងក្លាយទៅជាទុក្ខលំបាកជាយ៉ាងពន្លឹកវិញ ។ ហេតុនេះហើយបានជាព្រះសាស្តាត្រាស់ប្រដៅឲ្យលះមិនឲ្យប្រព្រឹត្តឡើយ ។ ការដែលលះបញ្ចវេរនេះបាន ត្រូវអាស្រ័យចំរើនសីល គឺប្រព្រឹត្តត្រឹមត្រូវមិនល្មើសមាត្រាច្បាប់ បានដល់សិក្ខាបទដែលព្រះសាស្តាទ្រង់បញ្ញត្តហាមឃាត់ទុក ពោលដោយជាន់តាម បានដល់សិក្ខាបទទាំង ៥ គឺ ការវៀរចាកសម្លាប់សត្វ ១ វៀរចាកកាន់

យកទ្រព្យដែលម្ចាស់ គេមិនបានឲ្យ ១ វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ១ វៀរចាកនិយាយពាក្យមិនពិត ១ វៀរចាកហេតុជាទីតាំងនៃសេចក្តីធ្វេស គឺគ្រឿងផឹកគ្រឿងស្រវឹងគឺសុរានិងមេរ័យ ១ ។ ការលះវៀរចាកពៀរទាំង ៥ នេះ ហៅថានិច្ចសីល ជាសីលដែលត្រូវរក្សាជានិច្ច មិនគ្រាអាក់ខាន ។ និច្ចសីលមានគុណភាពកំចាត់នូវវីតិក្កមកិលេសដែលនាំឲ្យប្រព្រឹត្តបញ្ចវេរ ជាដើមផ្លូវសម្រាប់ឈានទៅរកគុណដ៏ខ្ពង់ខ្ពស់ ប្រៀបដូចផែនដីសម្រាប់បណ្តុះពូជដែលមានផលប្រយោជន៍ និងសង់លំនៅឲ្យបានល្អ និងនាំមកនូវសេចក្តីត្រជាក់ចិត្ត មិនក្តៅក្រហាយស្តាយក្រោយជាអានិសង្ស ។ ពួកជនអ្នកមានសីល អាស្រ័យនៅក្នុងទីណា សេចក្តីស្ងប់ដែលជាកំពូលនៃសេចក្តីសុខ រមែងកើតមានឡើងក្នុងទីនោះ ។ វិញ្ញូ-ជន គួរពិចារណាឲ្យឃើញច្បាស់ដោយខ្លួនឯងចុះ ថាសីលនេះពិតជាទីពឹងរបស់ខ្លួននិងពួកជនដែលនៅរួមគ្នាជាប្រាកដ ព្រោះឧបទ្រពនិងទុក្ខភ័យទាំងឡាយ មិនដែលកើតមានអំពីពួកជនអ្នកមានសីលទេ ។ ហេតុនេះ បានជាព្រះមហាមុនីត្រាស់ឲ្យសាងសីល ដើម្បីធ្វើសេចក្តីស្ងប់ឲ្យកើតមាន ។

ចំណែកភាវនា ជាគ្រឿងបង្ក្រាបនូវកិលេសយ៉ាងកណ្តាល និងកិលេសយ៉ាងល្អិត ។ កិលេសយ៉ាងកណ្តាល បានដល់នីវរណូបក្កិលេសទាំង ៥ មានកាមច្ឆន្ទៈ (សេចក្តីចូលចិត្តក្នុងកាម) ជាដើម ដែលហៅថា បរិយុដ្ឋាន-

កិលេស សម្រាប់ចំពាស់ចិត្តឲ្យខូចពាក់សេចក្ដីស្ងប់ ញ៉ាំងសេចក្ដីទុក្ខ ឆេះឆួលពុះក្ដៅឲ្យកើតឡើងក្នុងចិត្ត ធ្វើចិត្តឲ្យមានទុក្ខទ្រព្រួយក្រសាប់ក្រសល់ ខ្វល់ខ្វក់វិនាសពាក់សេចក្ដីសុខ ។

កិច្ចដែលទប់ទល់កំចាត់បង់នូវកិលេសនេះ ត្រូវប្រើសមថភាវនា រកឧបាយធ្វើចិត្តឲ្យស្ងប់ជាសមាធិ ដោយណោងយកអារម្មណ៍ដែលជាគូទំនាស់នឹងកិលេសនោះ ដូចពួកយើងដែលធ្លាប់នាំគ្នាធ្វើកិច្ចថ្វាយបង្គំព្រះ នឹករំពឹងដល់គុណព្រះរតនត្រ័យ នឹងនឹករំពឹងមើលនូវគុណសេចក្ដីល្អ ដែលមាននៅក្នុងខ្លួនជាដើម ។ នេះហើយ ដែលជាឧបាយសាងសេចក្ដីស្ងប់ធ្វើចិត្តឲ្យស្រួល ធ្វើចិត្តឲ្យរងថ្លាមានពន្លឺមិនកករល្អក់ ។

កិលេសយ៉ាងល្អិត បានដល់អនុសយកិលេសទាំង ៧ មានកាមរាគៈ (គ្រឿងដែលក់ចិត្តជាប់ក្នុងកាម) ជាដើម ជាកិលេសមួយពួកសម្ងំស្ងៀមនៅក្នុងសន្ដានចិត្ត ដូចអាសិរពិសដែលពេនសម្ងំលាក់ខ្លួនក្នុងដំបូក មិនទាន់ចេញស្វែងរកអាហារ ដកពពាព្រួសពិសសំដែងឫទ្ធិឲ្យប្រាកដ កិលេសនេះក៏ដូចគ្នា តែងសម្ងំនៅក្នុងដំបូកគឺមហាភូតទាំង ៤ ដែលមានទ្វារ ៦ គឺអាយតនៈ លុះត្រូវអារម្មណ៍ប៉ះពាល់ត្រាណា ទើបចេញសំដែងឫទ្ធិព្រួសពិសឲ្យប្រាកដ នាំឲ្យក្រហល់ក្រហាយក្នុងចិត្ត នាំឲ្យបៀតបៀនខ្លួននឹងអ្នកដទៃ ។

កិច្ចដែលលះកិលេសឥឡូវនេះ ត្រូវអាស្រ័យវិបស្សនាការនោះ ។ ជាគួបផ្ដាចឡូវកិលេសនេះ គឺត្រូវចំរើនប្រាជ្ញាពិចារណាគង់សង្ខារឲ្យ ឃើញច្បាស់តាមយថាភូត គឺជារបស់មិនទៀង ជាទុក្ខ ទឹងអនត្តា ដើម្បីធ្វើចិត្តឲ្យដាច់អាល័យអំពីគង់សង្ខារ ដែលធ្លាក់នៅក្នុងអំណាចទុក្ខសច្ចធាតុ ហើយធ្វើចិត្តឲ្យស៊ប់មាំក្នុងវិសង្ខារ គឺព្រះនិព្វានដែលផុតចាកបំណោមនៃទុក្ខសច្ចធាតុ ដកចង់សម្លាប់អនុសយកិលេសនោះអស់ឥតមានសេសសល់ ធ្វើកាយឲ្យបរិសុទ្ធស្អាតចាកឧបក្កិលេស ដូចជាដំបូកដែលស្អាត មិនមានគរសើរពីសត្វមួយចុះនៅទាំងក្នុង ។ ការផ្ដាច់កិលេសទាំង ៣ ជាន់ ត្រូវអាស្រ័យសីល សមាធិ បញ្ញា ដូចពណ៌នាមកនេះ សមនឹងព្រះបាលីថា សីលេន វីតិក្កមក្កំ បរិយុដ្ឋំ សមាធិនា បញ្ញាយ អនុសយំ ជិន្នំ ពេត្ថា ជិរ្ឃាតមុត្តំ កាលបើបុគ្គលផ្ដាច់បង់វីតិក្កមកិលេសដោយសីល បរិយុដ្ឋានកិលេសដោយសមាធិ អនុសយកិលេសដោយបញ្ញា រមែងបាននូវព្រះនិព្វានដ៏ខ្ពង់ខ្ពស់ ។

សំដែងមកក្នុងសច្ចកថា ពណ៌នាអំពីគុណនៃសេចក្ដីស្ងប់នឹងឧបាយដែលជាផ្លូវនៃសេចក្ដីស្ងប់ ឯវំ គឺបាប់លម្អមសមគួរដោយនូវប្រការ ៗ ៩ គឺជា ជម្មទានេន សទ្ធំ បោកត្ថុ សព្វទា ដោយគុណានុភាពនៃធម្មទាននេះ សូមសួស្ដីជ័យមង្គលសំរេចដល់ពួកយើងដែលជាពុទ្ធសាសនិកៈគ្រប់ៗកាលតទៅហោង ។

ចប់វិជ្ជាធម្មទេសនា កណ្ឌទី ៦ តែប៉ុណ្ណេះ ។

អំពីកាលីទាសៈ

និងកិច្ចការស្នាថ្វីដៃរបស់លោក

កាលីទាសៈនេះ ជាឈ្មោះចិន្តកវីម្នាក់នៅប្រទេសឥណ្ឌា កាលពីសម័យពុទ្ធសករាជ ៩៤៣ លោកចិន្តកវីនេះមានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ក្នុងប្រទេសឥណ្ឌាសម័យបុរាណ ។ ឯរឿងរ៉ាវជាថ្វីដៃរបស់លោក គេបានប្រែចេញពីភាសាសំស្ក្រឹតមកជាភាសាផ្សេងៗក្នុងប្រទេសឥណ្ឌាទាំងក្នុងទ្វីបអឺរ៉ុប ព្រោះរឿងរ៉ាវអស់នោះ មិនមែនប្រើការបានគ្រប់គ្រាន់ត្រឹមតែជាភាសាកាព្យប៉ុណ្ណោះទេ គេអាចយកទៅប្រើលេងល្ខោនបានទៀតផង សឹងជាទីចាប់ចិត្តគំនិតរបស់ពួកអ្នកមើលល្ខោនទូទៅ ។ លោកអ្នកប្រាជ្ញនេះហើយ ដែលយល់ច្បាស់នូវអាការៈនៃចិត្តគំនិតមនុស្ស ហើយអាចយឹតយោងចិត្តអ្នកមើលឲ្យជាប់ចិត្តនឹងរឿងរ៉ាវរបស់លោក ។

ក្នុងចំណោមរឿងរ៉ាវដែលល្បីល្បាញនោះ គួរស្រង់យករឿងមួយមកពោល ដែលហៅថា ឫតុសំហារៈ ជារឿងអនុលោមទៅតាមរដូវកាលជារឿងដែលលោកអ្នកប្រាជ្ញនេះចង្អុលបង្ហាញឲ្យឃើញចិត្តគំនិតរបស់មនុស្សយើងដែលជាប់ទាក់ទងនឹងធម្មជាតិ ហើយតែងប្រែប្រួលទៅតាមរដូវកាល ទើបរឿងរបស់លោកពីរោះចាប់ចិត្តគ្រប់ៗរដូវរៀងមក ។

ក្នុងរដូវក្ដៅ ទុកជាក្ដៅស្ទើរឆេះក្នុងវេលាថ្ងៃ តែដល់វេលាយប់អាកាសប្រែត្រជាក់ជាមួយនឹងផ្ទៃផែនដី ទើបនាំឲ្យចិត្តគំនិតរីករាយឡើងវិញ

នៅឱកាសនោះ ព្រះចន្ទចុះពន្លឺស្មើដីត្រជាក់មកកាន់ផ្ទៃផែនដីនេះ រឿងនេះមានទំនងដូចជាចិត្តរបស់មនុស្សយើង ដែលពុះក្តៅហើយគេអាចបន្ទោបង់សេចក្តីក្រហល់ក្រហាយចេញទៅបានដោយសេចក្តីមេត្រីស្នេហា ។ សេចក្តីស្នេហានេះ អាចកើតឡើងបានដោយត្រូវខ្យល់បក់ឲ្យរហើយយ៉ាងរំភើយ ។ ឯព្រះចន្ទរះឡើងក្នុងវេលាយប់ បែរមុខមើលមកគូស្នេហា ដែលនៅក្រោមពន្លឺដួងចន្ទ ទ្រង់សំឡឹងមើលដោយអាការៈខ្មាសទឹងស្នេហា ។ ពួកនាគក៏ធុរជេះឡើងដោយកំដៅថ្ងៃ ហើយលូនទៅក្នុងធូលីទាល់តែឆេះផ្ទៃ សត្វក្របីងើយចំមុះដកដង្ហើមឡើងពីស្មើតហើយលៀនអណ្តាតធ្លាក់ស្តោកដើរត្រាច់ផ្គាត់រេរកទឹក ។

ស្បៀនរដូវចូលមក ហាក់ដូចជាស្នូនហារបស់ព្រះរាជានៅក្នុងចំណោមកងទ័ពដែលមានការុងប្រចន្ត្រាង, ផ្គរលាន់ទុកជាស្គរ ហើយពពកក៏ក្រាស់ទៅដោយទឹកភ្លៀងទុកដូចជាដំរី ឥន្ទធនូនឹងភ្លកទុកដូចជាផ្ទេកបន្ទោរ ហើយផែនដីទុកដូចជាស្ពានបង្ហាប់តាក់តែងដោយគ្រឿងមាសពេជ្រដ៏រុងរឿងគឺស្មៅខ្ចី ក្អែកក្ងាយកន្ទុយទុកដូចជាបាច់ផ្កា ។ ពួកស្រីតែងមានសេចក្តីស្នេហា នៅក្នុងដៃសហាយរបស់នាង ។ ក្តុចខ្ទាចស្ទូរស្ទាវទ្ធន ។ ខណៈនោះមើលឃើញមេឃឃើញដីទាំងអស់ឥតកំបាំង ទឹកទន្លេតែងហូរទៅ, ក្នុងសង្ស្រាតែងយល់សប្តិល្អ, ភ្លៀងតែងធ្លាក់ចុះមក,

ក្រោកក៏ពន់ពាំកាយកន្ទុយ, ដំរីកំស្រែកកងរំពង, ប្រពន្ធដែលលែងប្តីទៅតែងយល់សប្តិអាក្រក់ ពពកចុះមកទាបព្រិនហើយធ្ងន់ដោយទឹកភ្លៀង... ។

រដូវដើមឈើជ្រុះសន្លឹកចូលមក ទុកដូចជាថ្ងៃអាពាហ៍ពិពាហ៍ផ្កាឈូកដែលក្រពុំរីកឡើង; វេលាយប់តែងតែប្រាសចាកពពកដែលអណ្តែតទៅបាំងពីមុខដួងចន្ទ្រ; ខ្យល់បក់ផាត់ដើមស្វាយកំពុងផ្កា; ប្រឡាយទឹកតែងបែកទឹកខ្វាត់ខ្វាយ; ផែនដីក៏ប្រកបដោយសេចក្តីរីករាយ; ទេពធីតាឈ្មោះស្រីបានផ្សាយសេចក្តីសុខនិងលំអចុះមក ។

ដល់រដូវត្រជាក់ គូស្នេហាតែងបិទបន្ទប់ហើយបានសេចក្តីកក់ក្តៅដោយស្មោះនៃដួងចិត្ត; ឯផ្ទៃផែនដីដេរដាសដោយស្រូវចំរូត; បុរសស្នេហាតែងឱបក្រសោបស្ត្រីជាទីស្នេហារបស់ខ្លួន ។

ដល់រដូវទឹកសន្សើមធ្លាក់ ជាពេលប្រកបដោយសេចក្តីស្នេហា; ស្រីៗតែងសៀតចង្កាផ្កានៅលើសក់របស់ខ្លួន ។ រដូវនេះហើយដែលប្រកបដោយសេចក្តីស្នេហា; សេចក្តីរីករាយ ។

ដល់រដូវដើមឈើលាស់សន្លឹក ជារដូវដែលសេចក្តីស្នេហា ឬព្រះកាមទេពទ្រង់ដំឡើងសរកាម ត្រៀមបាញ់ទម្លុះបេះដូងក្រមុំកំលោះ ។ វត្ថុទាំងអស់សុទ្ធតែតាក់តែងឲ្យល្អឡើង ទឹកមានពណ៌ខៀវក៏ដេរដាសដោយផ្កាឈូក ហើយដើមព្រឹក្សាក៏ទោរទន់ចុះទៅដោយទម្ងន់ផ្កា ។. នេះហើយជាខែមធុរស ស្គរមេឃយំទ្រហឹង; ពួកបក្សាបក្សីក៏យំឮសូរសាន;

កូនភ្នំទាំងឡាយក៏ដេរដាសដោយផ្កា; ខ្យល់បក់រំភើយៗនាំក្លិនក្រអូបនៃផ្កាស្វាយសាយចេញទៅ; វេលាយប់ក៏សប្បាយពន់ពេក ពន្លឺដួងចន្ទក៏ភ្លឺថ្លាត្រចះ ។ មេឃទូតឬពពកនាំសារ ជាក់ដូចជាដំណាលពង្សាវតារនិយាយពីយក្ស ១ ដែលត្រូវទោសនិរទេស ហើយបានផ្ញើសារមួយតាមពពកទៅដល់ភរិយាខ្លួន ដ្បិតខ្លួននៅឆ្ងាយដាច់ស្រយាលពីភរិយា យក្សនោះក៏ពន្យល់ផ្លូវប្រាប់ពពកតាមដំណើរសព្វគ្រប់ ។ កាលពពកធ្វើដំ-ណើរមកដល់ទាំងមុខភ្នំហិម៉ាលយ៉ា ក៏ត្រូវឡើងទៅឃើញក្រុងយក្ស ព-ពកក៏ស្គាល់ច្បាស់ជាផ្ទះយក្ស នៅជិតស្រះមួយដ៏ដេរដាសដោយផ្កាឈូកមាស ហើយមានភ្នំមួយដែលមានកំពូលសុទ្ធតែជាពេជ្រនិលចិន្ដា មុននឹងបញ្ចប់សារយក្សនោះពោលថា " ឱ ! ពពកអើយ អ្នកនេះហើយដែលជាបក្ខពួកនៅក្នុងរដូវភ្លៀង សូមឲ្យអ្នកកុំបីព្រាត់ប្រាសឃ្លាតឃ្លាពីផ្លេកបន្ទោរដែលជាប្រពន្ធដ៏ជាទីស្នេហារបស់អ្នកឡើយ ។

*

* *

រឿងសកុន្ដលា ក៏ជាថ្វីដៃដ៏ចំណាប់ ១ របស់ចិត្តកវីកាលីទាសៈនេះដែរ ហើយគេបានប្រែមកជាពាក្យកាព្យដែរ បណ្ដាអ្នកដែលបានមើលសេចក្ដីប្រែជាពាក្យកាព្យនោះ ក៏មានសេចក្ដីសរសើរទាំងអស់ ដូចមានមហាកវីរបស់អឺរ៉ុបម្នាក់មានអាយុ ៨០ ឆ្នាំហើយ លុះលោកបានមើលសេចក្ដីប្រែ

ជាភាសារបស់លោកចប់ហើយក៏លុតជង្គង់ចុះពោលថា "ខ្ញុំសូមអរគុណព្រះដ៏ជាម្ចាស់សួគ៌ ដែលទ្រង់ប្រោសឲ្យខ្ញុំមានជីវិតរស់នៅរហូតដល់សព្វថ្ងៃនេះ" ហើយលោកតែងជាពាក្យកាព្យមួយដូចមានសេចក្ដីខាងក្រោមនេះ:

"វត្ថុទាំងអស់ ពោះមេឃក្ដី ដីក្ដី ផ្កាឈើនៅរដូវលាស់សន្លឹកក្ដី ផ្លែឈើនៅរដូវជ្រុះស្លឹកក្ដី សុទ្ធតែធ្វើឲ្យអ្នកសប្បាយចិត្ត ឲ្យអ្នកបានបរិភោគ ឲ្យអ្នកឆ្អែត ហើយធ្វើឲ្យមានលំអផង តែបើអ្នករឭកដល់ឲ្យស្របព្រមគ្នាតែម្ដងនោះ មានតែពាក្យ ១ ម៉ាត់ទេដែលហៅថា "គកុត្តណា ឈ្មោះនេះហើយ ទើបប្រាប់អ្នកឲ្យយល់សព្វគ្រប់ទាំងអស់" ។

លោកចិន្តកវីកាលីទាសៈ ដែលបានតែងពាក្យកាព្យនេះលោកបានចាប់យកដំណើរទំនងជាទបាស់ តាមដែលមានក្នុងរឿងមហាភារតៈ ។ ឯរឿងការនោះដូច្នេះ :

លោកមហាឥសីមួយរូបឈ្មោះកាមទេវៈ បានសាងអាស្រមបទនៅនាកណ្ដាលព្រៃ ជាទីសំណាក់នៅជាមួយនឹងភរិយាឈ្មោះនាងគោតមី ហើយនឹងពួកឥសីក្មេងៗ សុទ្ធតែស្លៀកសំបកឈើទាំងអស់ ។ ឥសីកាមទេវៈនឹងនាងគោតមីមានសេចក្ដីព្រួយចិត្តណាស់ ដ្បិតគ្មានកូនមួយសោះ ។

មានថ្ងៃមួយនោះមាននាងទារិកាតូចម្នាក់មកកើតនាទីព្រៃនោះ ម្ដាយជាទេពតាឈ្មោះនាងមេនកា មកប្រសូតកូនស្រី ១ ចោលក្នុងព្រៃនោះ ។

អស់សត្វបក្សាបក្សីមកចោមរោមការពារអន្តរាយនាងទារិកានោះ ៗ ដល់ព្រឹកឡើង ពួកឥសីក្មេងៗ នាំគ្នាមករើសបេះផ្លែឈើ ក៏បានឃើញនាងទារិកាកុន្ទលា ហើយយកទៅថ្វាយឥសីជាគ្រូ ៗ នាងកុន្ទលាបានធាត់ធំចំរើនឡើងក្នុងអាស្រមបទ ហើយនាងមានស្រីកំលៀង ២ នាក់ ឈ្មោះអនសូយៈ ១ ប្រិយម្ពទៈ ១ នឹងកូនម្រឹគមួយ តែងដើរតាមនាងទៅគ្រប់ៗអន្លើ ៗ ស្រីសំឡាញ់ទាំង ៣ នាក់នាំគ្នាជួយរក្សាសំអាតអាស្រម នាងទាំង ៣ តែងលេងសើចរីករាយកំសាន្តចិត្តជាមួយគ្នាជាដរាប ៗ

ក្នុងថ្ងៃមួយនោះ ស្តេចទុស្សន្តៈជាមហាក្សត្រមានឫទ្ធានុភាពមួយ ឯអាស្រមបទរបស់ឥសីកាមៈទ្វៈក៏នៅក្នុងអាណាចក្រទ្រង់នេះដែរ ថ្ងៃមួយស្តេចចេញទៅបរបាញ់នឹងក្លុកប្បួន ម្នាក់ឈ្មោះមាធវ្យៈ ៗ សូរត្រែរបស់ស្តេចលាន់ឮក្នុងរំពងទៅទាំងព្រៃ ស្តេចគង់លើរាជរថមាសដេញបាញ់ក្តាន់មួយចូលទៅក្នុងព្រៃជ្រៅរហូតមកដល់អាស្រមរបស់ឥសី ៗ ស្តេចក៏លែងដេញបាញ់សត្វនោះ ហើយយាងចុះទៅកាន់បណ្ណសាលា ស្រាប់តែទ្រង់ទតឃើញនាងកុន្ទលា ៗ តាំងពីពេលនោះមក ទ្រង់មិនព្រមចេញពីអាស្រមបទ ហើយទ្រង់មិនព្រមត្រឡប់ទៅព្រះនគរវិញផង ៗ

នៅថ្ងៃមួយនោះ ស្តេចទ្រង់នាងកុន្ទលាទ្រង់កម្រងផ្កាអាពាហ៍ពិពាហ៍ជាមួយគ្នា ។ តមកក្នុងថ្ងៃមួយ ស្តេចទ្រង់ឡើងគង់រាជរថមាសត្រឡប់ចូលទៅកាន់ព្រះរាជវាំងវិញ ឯនាងកុន្ទលាក៏ត្រឡប់ទៅកាន់អាស្រម

ដែរ ប៉ុន្តែមុនស្តេចយាងត្រឡប់ទៅកាន់ព្រះរាជវាំងនោះ ទ្រង់បានប្រទានព្រះទំរង់១វង់ទៅនាងគក្តុទលា ហើយទ្រង់សញ្ញាថានឹងមកទទួលនាង ។ តែតមក ស្តេចមិនបានត្រឡប់ទៅវិញឡើយ ។ ឯនាងគក្តុទលាក៏សោយសោកទង្គឹះខ្សឹកខ្សួលនៅតែក្នុងអាស្រមមិនបានសង្កេតគន់មើល មហាឥសីទូវិសៈ ចូលមកក្នុងអាស្រម ហើយខឹងនឹងនាងជាខ្លាំង ទើបដាក់បណ្ដាសានាងថា កុំឲ្យស្តេចនោះចាំនាងបានឡើយ ។ ឯស្រីសំឡាញ់ចាំងពីរបានឮមហាឥសីដាក់បណ្ដាសាដូច្នោះក៏ភិតភ័យ ទើបនាំគ្នាអង្វរសូមឲ្យមហាឥសីដកពាក្យបណ្ដាសានុះចេញ ទើបមហាឥសីតែបន្ទូរថា បើស្តេចបានឃើញព្រះទំរង់ដែលពាក់នៅនឹងដៃនាង សូមឲ្យស្គាល់ថាជានាងគក្តុទលា ។ ក្នុងសម័យនោះ ស្តេចគង់ក្នុងព្រះរាជវាំង ទ្រង់ភ្លេចភ្លាំងអាស្រមចំនឹងនាងគក្តុទលាសូន្យឈឹង (ដោយត្រូវបណ្ដាសាឥសី) ។

ឯកាមទេវៈក៏ទូន្មាននាងគក្តុទលា អំពីច្បាប់ដែលនាងទៅនៅនឹងព្រះរាជស្វាមី ។ ឯស្រីសំឡាញ់ចាំងពីរនាក់ក៏កាត់តែងរៀបចំខ្លួនប្រាណឲ្យនាងទើបនាំនាងចេញដំណើរទៅ លុះនាំគ្នាដើរទៅបានពាក់កណ្ដាលផ្លូវ នាងក៏ចុះទៅងូតទឹកក្នុងគង្គាមិនបានប្រយ័ត្ន ចិញ្ចៀនដែលពាក់នឹងម្រាមដៃក៏របូតជ្រុះទៅក្នុងស្ទឹងទៅ ។ លុះនាងដល់ទៅព្រះរាជវាំង ស្តេចក៏ឥតស្គាល់នាងបន្តិចទើបទ្រង់ដណ្ដឹងសួរ ។ នាងគក្តុទលាទូលរៀបរាប់កាលទ្រង់ទៅសំណាក់នៅក្នុងអាស្រមសាលា ហើយទ្រង់ប្រទានចិញ្ចៀន

១ ឆ្នាំ តែមហាក្សត្រទ្រង់នឹកមិនឃើញសោះ ឯនាងគក្កុន្ដលា ក៏ទ្រង់ព្រះកន្សែងសោកជាខ្លាំង ទើបនាងទេពធីតាឈ្មោះមនោគាដែលជាម្ដាយនាង បានឮស្នូរសព្ទសោករបស់កូនក៏ចុះពីស្ថានសួគ៌មក ហើយនាំនាងគក្កុន្ដលាទៅកាន់អាស្រមរបស់តាសក្កស្សបៈ នៅទីនោះនាងគក្កុន្ដលាប្រសូតបានកូនប្រុសមួយ ហើយជួយប្រឡោមលោមចិត្តនាងឲ្យបន្ទោបង់សេចក្ដីទុក្ខព្រួយបានខ្លះ ៗ

ក្នុងសម័យថ្ងៃមួយនោះ មានអ្នកនេសាទត្រីម្នាក់ទៅបង់សំណាញ់នៅអាត់ស្ទឹងបានត្រី ១ ធំ ហើយយកមកវះពោះចេញ ក៏ស្រាប់តែឃើញព្រះទំរង់ស្ដេចនៅក្នុងក្រពះត្រីនោះ ដែលរបូតពីដៃនាងគក្កុន្ដលាពេលចុះទៅងូតទឹក ហើយត្រីនោះលេបបាត់ទៅ ៗ ឯអ្នកនេសាទក៏យកចិញ្ចៀននោះទៅលក់ឲ្យជួរជាងទង ឯជាងទងឃើញក៏ស្គាល់ជាចិញ្ចៀនរបស់ស្ដេច ព្រោះមានព្រះសញ្ញាស្ដេចប្រថាប់ទៅទីក្បាលចិញ្ចៀន ទើបនាំអ្នកនេសាទនោះទៅកាន់ព្រះរាជវាំង ហើយក្រាបទូលរៀបរាប់ពីដំណើរដែលខ្លួនរើសបានចិញ្ចៀននេះ ៗ ឯព្រះមហាក្សត្រកាលទ្រង់ទតឃើញព្រះទំរង់នេះ ក៏ទ្រង់នឹកឃើញនាងគក្កុន្ដលាមួយរំពេច ទើបទ្រង់ឲ្យដើររកនាងសព្វអន្លើ (តែមិនប្រទះ) លុះទ្រង់រុករកចូលទៅក្នុងព្រៃធំ ទើបទ្រង់ទតឃើញព្រះរាជបុត្រកំពុងលេងកំសាន្តជាមួយនឹងកូនរាជសីហ៍ តែទ្រង់ឥតស្គាល់ជាព្រះរាជបុត្រទេ ហើយទ្រង់យកព្រះហស្តឧបកុមារ

នោះ ៗ ទើបនាងគុន្តលាចូលទៅជិតទ្រង់ ព្រះមហាក្សត្រក៏ស្គាល់ព្រះនាងជាក់ច្បាស់ ៗ ឯពាក្យបណ្ដាសារបស់ឥសីទូវិសៈក៏សាបរលាបអស់ទៅ ទើបមហាក្សត្រនាំនាងគុន្តលា និងព្រះរាជបុត្រត្រឡប់ចូលទៅក្នុងព្រះនគរវិញ ហើយក៏មានសេចក្ដីសុខក្សេមក្សាន្តជាមួយគ្នាតរៀងទៅ ៗ

*

* *

មានកំណាព្យមួយទៀត ជាកំណាព្យល្បីល្បាញណាស់ដែរ ជារបស់លោកកាលិទាសៈ ហៅថា រឃុវង្សៈ ប្រែថា វង្សព្រះអាទិត្យ ៗ រឿងនេះជាថ្វីដៃដ៏ថ្លៃថ្លាមួយ ដែលគេទុកជាគំរូបែបផែនក្នុងការតែងសេចក្ដី ៗ លោកបិន្តក៏បានពោលអំពីការធំៗរបស់ពួកទេសព្រះអាទិត្យដែលហៅថា ឥក្សាកុ មានក្សត្ររឃុជាបឋមវង្ស ហើយមានព្រះរាមដែលជាក្សត្រ ១ អង្គមានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុត ៗ មានទំនុកកាព្យ ៩ ទំនុកដំបូងនោះ សុទ្ធតែពោលអំពីបុព្វបុរសរបស់ព្រះរាម ហើយទំនុកកាព្យឯទៀតពោលពីព្រះរាមនិងព្រះរាជវង្សព្រះរាមតៗមក ៗ ទំនុកអស់នេះទុកដូចជាសេចក្ដីសង្ខេបមួយក្នុងរឿងរាមាយនៈ ៗ

*

* *

ក្នុងរឿងកុមារសម្ភវៈ ឬកំណើតរបស់កុមារនោះ លោកកាលីទាសៈ សរសើរកំភ្លុកដល់កាត៌កេយៈ ជាព្រះវ៉ែកខាងចម្បាំង ជាបុត្រព្រះសិវៈ ។ វិក្រមូវ៌សី "ចរិតៈស្ដោះនៃសេចក្តីក្លាហាន" ក៏ជាស្នាដៃរបស់លោកកាលី-ទាសៈតែងដែរ ឃើញមានរឿងការនៅក្នុងចំនុក ១ ក្នុងឫគវេទៈ ។ លោកកាលីទាសៈ ដំណាលអំពីសេចក្តីស្នេហារបស់ទេពធីតា ១ និងនឹងខ្មោច ១ ហើយពោលអំពីសេចក្តីលំបាកនៃគូស្នេហា ក្នុងកាលដែលទេពធីតាស្វែងរកខ្មោចនោះ ។ ប៉ុន្តែព្រះឥន្ទ្រអនុញ្ញាតឲ្យខ្មោចនោះថែរក្សាទេពធីតា ទ វិភិះនៅក្បែរទ្រង់ ។

*

* *

មាលវិកាគ្និមិត្រៈក៏ជាពាក្យកាព្យមួយ និយាយពីសេចក្តីស្នេហា ដែលលោកកាលីទាសៈដំណាលពីសេចក្តីស្នេហារបស់ស្តេចអគ្និមិត្រៈ ។ ស្តេចនេះលុះអំណាចស្នេហានឹងស្រីបម្រើម្នាក់ របស់ព្រះអគ្គមហេសី មាលវិកាអគ្គមហេសីទី ១ ខំទប់ទល់គាំងពីដំបូងមិនឲ្យស្រីបំរើរួមភិរម្យជា-មួយនឹងស្តេច ។ នាងឥរាវតីក៏នាងមិនព្រមឲ្យស្តេចជួបជុំដែរ ហើយនាងទាំងពីរប្រចណ្ឌជាខ្លាំង តែតមកនាងនេះតែងគត់ទ្រាំទៅ ទើបនាងបំរើមាលវិកាបានជាព្រះជាយា ១ របស់ស្តេចនោះ ។

ប្រវត្តិពួកឧបាសិកា

១ សុជាតា- សេនិយធីតា- ជាបុត្រីរបស់សេនិយកុដុម្ពិក កើតនៅតំបន់សេនានិគម ដែនឧរុវេលប្រទេស លុះបានចំរើនវ័យឡើងហើយ បានទៅកាន់ដើមជ្រៃធំមួយដើម តាំងសេចក្តីប្រាថ្នាថា បើខ្ញុំបានស្វាមីដែលមានជាតិត្រកូលស្មើគ្នា ហើយបានកូនប្រុសដំបូង ខ្ញុំនឹងមកធ្វើការបួងសួងលោករាល់ៗ ឆ្នាំ ។

លុះចំណេរកាលតមកនាងក៏បានសម្រេចសមតាមប្រាថ្នាគ្រប់ប្រការ ហើយចួនជាព្រះសិទ្ធត្ថរាជកុមារ ធ្វើទុក្ករកិរិយាកន្លងមក ៦ ឆ្នាំហើយ ដល់ថ្ងៃវិសាខបុណ្ណមីក៏បានសម្រេចព្រះពោធិញាណ ស្តេចមកគង់នៅក្រោមដើមឈើនោះ ។ ឯនាងសុជាតា បានក្រោកឡើងអំពីព្រឹក មានបំណងនឹងទៅធ្វើពិធីបួងសួងទេវតា ហើយបានចាត់ចែងរីតយកទឹកដោះពីមេគោ ក៏រីតបានដោយងាយស្រួល គង់វេលានោះ កូនគោទាំងឡាយមិនបានបៅដោះមេគោឡើយ គ្រាន់តែយកភាជន៍ទៅរងពីក្រោមដោះ ទឹកដោះក៏ហូរចេញមកឯង ។ នាងយកទឹកដោះនោះទៅដាំធ្វើជាមធុបាយាស លុះរួចស្រេចហើយក៏នាំយកទៅឯដើមជ្រៃធំនោះ ដើម្បីនឹងធ្វើពិធីបួងសួងលាបំណន់ដែលខ្លួនបានបន់ទុកនោះ ។ ថ្ងៃនោះ ព្រះពោធិសត្វស្តេចត្រេចទៅបិណ្ឌបាតត្រឡប់មកពីព្រឹកហើយគង់នៅក្រោមដើមជ្រៃនោះ នាងសុជាតាមកជួបសំគាល់ថាជាទេវតា ក៏

នាំមធុបាយាសទៅថ្វាយ ទមស្សការហើយពោលពាក្យថា សេចក្ដីប្រាថ្នារបស់ខ្ញុំម្ចាស់បានសម្រេចយ៉ាងណា ក៏សូមឲ្យសេចក្ដីប្រាថ្នារបស់លោកម្ចាស់បានសម្រេចយ៉ាងនោះចុះ ។

ឯព្រះបរមពោធិសត្វទ្រង់ទទួលបាយមធុបាយាសហើយ ស្ដេចយាងទៅកាន់មាត់ស្ទឹងនេរញ្ជរា ទ្រង់ដាក់ថាសមាសទីមាត់ច្រាំង រួចស្ដេចចុះស្រង់ក្នុងគង្គាដម្រះព្រះកាយរួចស្រេចហើយស្ដេចឡើង ទ្រង់ពូតបាយមធុបាយាសបាន ៤៩ ដុំ លុះសោយស្រេចស្ដេចបណ្ដែតថាសមាសទៅក្នុងស្ទឹង ស្ដេចវិលមកកាន់ពោធិមណ្ឌល ក្រោមដើមមហាពោធិព្រឹក្សវិញ ហើយទ្រង់ចំរើនធម៌បានសម្រេចអនុត្តរសម្មាសម្ពោធិញាណ ស្ដេចប្រថាប់នៅទីនេះជាវេលា ៧ សប្ដាហ៍ ។ តអំពីនោះស្ដេចទៅសំដែងព្រះធម្មចក្រនៅព្រៃឥសិបតនម្រឹគទាយវ័ន ទ្រង់ទតឃើញឧបនិស្ស័យរបស់យសកុលបុត្រ ជាបុត្រនាងសុជាតា ទើបស្ដេចទៅប្រថាប់ក្បែរគល់ឈើមួយដើម ។ ឯយសកុលបុត្រមានចិត្តនឿយណាយ ក្នុងការគ្រងឃរាវាស ទើបចេញពីគេហដ្ឋានទៅ ស្រាប់តែបានជួបប្រទះនឹងព្រះបរមសាស្ដានៅទីនោះ បានស្ដាប់ព្រះធម្មទេសនាហើយ បានសម្រេចមគ្គផលដល់ថ្នាក់អនាគាមី ។ ឯបិតារបស់យសកុលបុត្រទៅតាមជួបនឹងព្រះបរមសាស្ដា បានស្ដាប់ព្រះធម្មទេសនាសម្រេចសោតាបត្តិផល

យសកុលបុត្របានសម្រេចព្រះអរហត្តផល ព្រះអង្គទ្រង់អនុញ្ញាតឲ្យបួស ដោយវិធី "ឯហិភិក្ខុឧបសម្បទា" ។ ឯបិតារបស់ព្រះយស បានទូលនិមន្តព្រះបរមសាស្តាឲ្យស្តេចទទួលបិណ្ឌបាតឯផ្ទះរបស់ខ្លួន ។ សម្តេចព្រះបរមសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់សំដែងព្រះធម្មទេសនា វេលាចប់ទេសនា នាងសុជាតាជាមាតា ព្រមទាំងភរិយារបស់ព្រះយស បានសម្រេចសោតាបត្តិផលទាំងពីរនាក់ ។ នាងសុជាតានឹងកូនប្រសាបាន តាំងនៅក្នុងតេវាចិកសរណគមន៍ជាដំបូងក្នុងថ្ងៃនោះ អាស្រ័យហេតុនេះ ទើបព្រះសាស្តាទ្រង់តាំងក្នុងឯតទគ្គៈ ប្រសើរលើសលែងពួកឧបាសិកា ដែលបានដល់សរណៈមុនឧបាសិកាទាំងពួង ។

ចប់ប្រវត្តិសង្ខេបរបស់ នាងសុជាតា-សេនីយធីតា តែប៉ុណ្ណេះ ។

លោកនេយ្យ ពាក្យកាព្យ

(តមក)

អស់ទេពសួគ៌សុខ ទាំងបពមុខ ទាំងអ្នកពាលា នៅនាលោកិយ អប្រិយយសា លុះដល់មរណា សោយទុក្ខធ្ងន់ក្រៃ ៗ នៅស្ថាននរក រៀនតែទល់ទុក្ខ ពិតពុំប្រពៃ ទើបសុន្ទរ- ល័យរាកាចក្រៃ រកកលថាហៃ ធនញ្ជ័យបណ្ឌិត ៗ អញផ្ដាំងទៅ ចូរប្រាប់ដោយនូវ ពាក្យទៀងពុំខិត ឲ្យយើងបានដឹង ដំណាំងពាក្យពិត ឲ្យដឹងគំនិត អ្នកកុំសង្កា ៗ ទៅបានធ្វើគុណ ទាំងស្ដេចលើសលន់ ប្ដូមួយក្សត្រា ធ្វើគុណទាំងទៅ ច្រើននៅអាត្មា ទៅប្រាប់យើងពី ឲ្យដឹងសេចក្ដី ៗ ពោធិសត្វឆ្លើយ ថាអា- ចារ្យអើយ ព្រះបាទចក្រី ព្រះអគ្គសីងធ្វើ គុណលើសិរសី អញច្រើនគគប៍ ឥតបើគណនា ៗ អញសោតសីងធ្វើ គុណតាប់ទៅលើ ក្សត្រក្សត្ត្រថ្លៃថ្លា សុន្ទរាល័យ ស្រដីទៅថា ឥឡូវនេះណា ចិត្តទៅសព្វថ្ងៃ ៗ ទៅដឹងព្រះគុណ ក្សត្រថ្លៃលើសលន់ ប្ដូមួយក្សត្រថ្លៃ, ព្រះអគ្គដីធំគុណទៅគន់ពេកក្រៃ ថ្លៃក៏កុំសង្ស័យ អស់យើងនេះណា ៗ អ្នកថាខ្ញុំទឹកគុណក្សត្រយប់ព្រឹក សព្វទិនទិវា ឯក្សត្រឧត្ដម អញដឹងហើយណា កុំព្រះទ័យា ពុំហានថាឡើយ ៗ អាចារ្យទាំងបី ស្ដាប់ព្រះពោធិ- សត្វថ្លែងហើយ មានចិត្តត្រេកអរ សាធុះឆ្លើយ ថាធនញ្ជ័យអើយ យើងសួរទៅទៅ ៗ ទើបបបួលគ្នា ចុះចាកសាលា ដើរដល់ផ្លូវក្រៅ

សុទ្ធពល័យ ស្រដីទៅពៅ អួតថាយើងទៅ លួងលោមបានការ ។
អស់គ្នាយើងកុំ ធុញថប់បារម្ភ គន់គិតសោក អត្តឲ្យអញឯង សំដែង
កិច្ចការ កិច្ចវាឲ្យបាន ចុះចាញ់ចំណេះ ។ យើងទៅទូលកិច្ច ញុះញង់
ឲ្យស្ដេច សម្លាប់វានេះ កុំឲ្យវាច្រើន លើយើងដូច្នេះ គិតហើយវាង
វេះ ទៅផ្ទះគ្រប់ប្រាណ ។ ព្រះពោធិសត្វ មហាបុរសរ័តន៍ ក្រោយ
ដោះអ្នកមាន ព្រះទ័យគន់គិត ក្នុងចិត្តពុំក្សាន្ត ថាវាលួងបាន ពាក្យ
អញនេះណា ។ វាទៅពាពាំ ពាក្យពីនេះនាំ ឲ្យខុសអាត្មា លង់
លុះត្រឹកព្រាង ស្រេចស្រាងអស់អា- ចារ្យនូវព្រះមហា- បុរសរ័តន៍
ថ្ងៃ ។ ទៀងគាល់មហាក្សត្រ ទុនអន្តប្រណិប័តន៍ គ្រប់គ្នូទិវៃ អង្គុយ
គ្រប់ប្រាណ នៅស្ថានប្រពៃ សុទ្ធពល័យ ក្រាបទូលក្សត្រា ។
បពិត្រភូមិន្ទ នាកយណ៍នរិន្ទ- ធិបតីពជា ឲ្យទៅធនញ្ជ័យ គាប់ត្រែ
សោះសា ល្មើសគុណក្សត្រា អម្ចាស់សរសើ ។ កាលនោះមហាក្សត្រ
បើកបន្ទូលថ្កាត់ ថាហេតុដ្បិតអ្វី ព្រះស្ដែងតើជន ដំណឹងអំពី ដំណើរ
ដូចម្ដេច ចូរទៅចរចា ។ អាចារ្យទាំងបី ក្រាបទូលវិញ កាលខ្ញុំករុណា
ទាំង ៣ ដើរទៅ លំនៅសាលា ធនញ្ជ័យបាចា ពីម្សិលនោះនៃ ។ ថា
គាត់ធ្វើគុណ ទឹងម្ចាស់ច្រើនលន់ ហើយអម្ចាស់ថ្លៃ មានគុណទឹងគាត់
ច្រើនគ្នាក់ពេកក្រៃ គាត់ឯងសព្វថ្ងៃ គិតគុណក្សត្រា ។ ឯព្រះអង្គក្សត្រ
ពុំគិតគុណគាត់ ផល់តិចឡើយណា មួយសោកគាត់ថ្លែង សំដែងចរចា

ថាបើនរណា កាត់គុណគេហើយ ៗ វែរស់ទៅតា លោកនៃឯបរ មុខមិនលែងឡើយ ឲ្យជាការក្រក់ ជាទុក្ខពុំស្បើយ ដ៏លោកឥតត្រើយ ដល់បរលោកឆាយ ៗ ទីនេះទៅសោយទុក្ខ នៅនានរក ចតុរាបាយ ពាក្យ កាត់នេះដៀល បញ្ចៀសពីឆាយ ឲ្យក្សត្រពណ្ណរាយ ពុំជាទៅឡើយ ៗ ស្តេចប្រាបព្រះទ័យ សុទ្ធកល័យ ទូលដូច្នោះហើយ ទ្រង់ព្រះក្រោធ ក្រៃ ព្រះទ័យពុំស្បើយ ថាធនញ្ជ័យអើយ មែនពិតឬអ្វី ៗ ពង្ស ពោធិសត្វ ទៀងទូលទៅថ្វាត់ ថាខ្ញុំស្រដី ពិតពាក្យពុំកៀស បញ្ចៀស ចក្រ កាចាវ្យទាំងបី គេមកទូលគាត់ ៗ ខ្ញុំជាមិនដឹង មិនមានដំណឹង គុណព្រះទ័យស្តេច ដ្បិតខ្ញុំមិនបាន ដល់ស្ថានសម្រេច អរហត្តផលផ្តាច់ វដ្តសង្សារសោះ ៗ យន់យល់សព្វសា- រពើពីបា- ទ័យទៀងចំពោះ មួយសោតខ្ញុំថា អ្នកណាមួយនោះ ភ្លេចគុណគេសោះ អស់ទាំងទេ- ពតា ៗ តែងបកមុខ ពិតពុំមានសុខ ក្នុងអន្តកាយា ពិតពីមុខមាន ទំពាំងបង់ជា ច្បាប់ច្បាស់ប្រុះប្រៀ- កជកុំសង្ស័យ ៗ សម្តេចក្សត្រា បើកបន្ទូលថា ម្តេចចៅធនញ្ជ័យ បូរចៅតាវែង ថ្វាថ្លែងប្រែស្រាយ ឲ្យ ដឹងសាចនៃ ដើមទងនិទាន ៗ

ពោធិសត្វទឹក គន់គិតវៀក ជាតិសវញ្ញាណ អ្នកនាំនិយាយ តែងតាយនិទាន បុរសមួយមាន ចិត្តល្មិលគុណគ្រូ ៗ ទៀងទើប ទូលថា បពិត្រក្សត្រា ជាមកុដឥតគូ កាលកន្លងលង់ ព្រះអង្គឯងកូ

គបកើតទិត្យនៅ ជាតិជាក្សត្រា ៗ នាមព្រះព្រហ្មទត្ត សោយរាជ-
សម្បត្តិ គ្រប់គ្រងសីមា ពារាណសី សេនីយសេនា សម្រាប់ព្រះ
មហា- ក្សត្រក្សាន្តឥស្សូរ ៗ ឯអគ្គពុជព្រាហ្មណ៍ អន្ទោលទៅតាម
កើតកបមួយមូល យោនយកជាតិជា វង្សត្រកូល ព្រាហ្មណ៍ព្រឹទ្ធ
អំបូរ បុរោហិតា ៗ គាត់បង្កើតបុត្រ កូនប្រុសបរិសុទ្ធ មួយមានរូបា
ទើបមកសន្ធត ប្រាកដនាមា ឲ្យហៅឈ្មោះជា ទិព្វសរកុមារ ៗ គឺ
អគ្គសេនា- បតីកើតជា កូនគាត់គាប់កាល នោះនៃហេតុកម្ម នោះ
នាំបណ្តាល រំលល់រំបាល បៀតបៀនឲ្យស្លាប់ ៗ វង្សកទាំងផ្ទុះ ស្ងប់
ស្ងាត់វង្គះ សោះសូន្យធុតធាប់ ទិព្វសរកុមារ ម្ហ៊ូមា ប្រញាប់ រួតរត់
ក្រឡាប់ បរបោលត្រឹហា ៗ ស្វែងស្វះរករៀន សិល្បសាស្ត្រ
រៀន ទាល់តក្កសិលា ចូលទៅសំណាក់ អាស្រ័យទិសា- បាមោក្ខ
ជាអា- ចារ្យចែងប្រដៅ ៗ លុះកាលបើរៀន សិល្បសាស្ត្ររៀន
ចេះចប់ជ្រះជ្រៅ សំពះក្រាបលា គ្រូថានឹងទៅ ទីស្ថានលំនៅ តំបន់
ត្រឹហា ៗ គ្រូបើកស្នានស្មោះ ដើរដល់ស្រុកឈ្មោះ បច្ចន្តគ្រាមា
កាលនោះខ្ញុំឯង ពីព្រេងនាយណា យោនយកជាតិជា ចណ្ឌាល
មាណព ៗ ឥតញាតិពង្សា មោះមានប្រាជ្ញា ចេះមន្តសព្វគ្រប់ មន្ត
មួយពិស្តារ ត្រកាលតែងជប្ប សារពើឈើសព្វ ឥតផ្លែជប្បបាន ៗ
មន្តនោះទិមិល ស្មោះអកាលផល បើចិត្តគិតធ្យាន ប្រាថ្នាផ្លែឈើ

សារពើសឹងបាន បៀមទឹកព្រៃសន្តាន កើតផ្លែច្រើនក្រៃ ៗ បណ្ដាល
មាណព ចិត្តគិតបង់ផ្ទុយ មានកាលមួយថ្ងៃ បរិភោគបាយទឹក ពីព្រឹក
ហើយនៃ ដើរដល់ក្នុងព្រៃ យល់ដើមស្វាយនោះ ៗ បណ្ដាលមាណព
ស្មុះស្មាញស្វាបស្ទួប ពានឡើងស្ទានស្ទោះ ប្រាំពីរដងទៃង សំដែងមន្ត
នោះ កើតផ្លែបេះបោះ ពោលជាសរដេរដី ៗ មាណពចុះមក បេះរើស
យក ដាក់កញ្ច្រែង ហើយបរិភោគ អាហារពិសី ពិសាហាក់ពី
ស្កត់ទេពប្រែពៃ ៗ ហើយទើបមាណព រែកផ្លែឈើផ្សេ ចរចេញពីព្រៃ
មកលក់ផ្សរជា ទ្រព្យប្រស្រ័យ បរិភោគសព្វថ្ងៃ ចិញ្ចឹមករិយា ៗ
វិពូសរកុមារ យល់មន្តអគរល ផលនោះប្រាជ្ញា ប៉ុនប៉ងទៅរក រៀន
យកមន្ត្រា ទីងនាំយាត្រា ទៅឋាននគរ ៗ មានថ្ងៃមួយមា- ណពនោះលា-
លា លះលាកចេញចរ ចូលព្រៃក្រៃព្រៃស្ដៅ ឯចៅវិពូសរ- កុមារសាទរ
ទៅតាល់ត្រីហា ៗ ឈរឈប់ទិត្យនៅ ជិតដំណើរហៅ ដណ្ដឹងទៅ
ថា អ្នកគ្រូលោកនៅ ឬទៅឯណា ប្រពន្ធគ្រូថា គាត់ចេញទៅព្រៃ ៗ
វិពូសរកុមារ នៅចាំអាចារ្យ លន់លុះល្ងាចថ្ងៃ មាណពលីលា ក្រ-
ឡាប់ពីព្រៃ បុរសវិលវៃ ទៅទទួលគ្រូ ៗ ចេញទៅពីផ្ទះ ដើរដល់
ប្រទះ និត្យនោខានផ្លូវ លុតជង្គង់ហើយ ឆ្លើយថាអ្នកគ្រូ ខ្ញុំមកឥឡូវ
ចាំទទួលអ្នក ៗ ហើយយកកញ្ច្រែង អម្រែកដាក់លើ ស្មាស្មោះដើរ
ដាក់ ដូចដល់លំនៅ ចូលទៅសំណាក់ ផ្ដាប់ពុំឲ្យអាក់ ឲ្យអន់ចិត្ត ៗ

បំរើសារពើ កិច្ចការផងធ្វើ ហេតុចិត្តប្រាថ្នា ប៉ុនប៉ងរករៀន របៀន
សាស្ត្រា ផ្ចាប់ឥតសង្កា ចិត្តត្រូវផលតិច ៗ មាណពគន់គិត យន់
យល់គំនិត ផ្ចាប់សព្វសេចគ្រប ទើបប្រាប់ភរិយា ដោយទាកល
កិច្ច នាងអើយធ្វើម្តេច ទៅនេះផ្ចាប់ណាស់ ៗ ហេតុចង់បានមន្ត
ពិសេសទិព្វគន់ រៀនយករហ័ស រីឯមន្តនេះ បើបេះស្ទាត់ជ្រះ
បើសប្បុរសណាស់ ពាក្យសត្យឋិតនៅ ៗ បើអ្នកទុជន ទីងរៀនយក
មន្ត នេះពុំបានទៅ បើអញអាស្ទូរ អនុកូលប្រដៅ អសារអាសៅ
អសោចសាបសោះ ៗ ទិព្វសរកុមារ ទះទាំធ្វើការ បម្រើគ្រូនោះ ដងទឹក
កាប់ឧស អម្រែស់លង់លុះ ដូចខ្ញុំស៊ុទ្ធសោះ ចាំគក់ប្រែបាប់ ៗ គ្រូពុំប្រ-
ដៅ បម្រើលង់ទៅ ផ្ចាប់ផ្គុនផ្តេកផ្តិត ចិត្តបាប់ចាំបង ប៉ុនប៉ងពុំក្លួច
លង់លុះទៅតិច ភរិយាមាណព ៗ ប្រសូតកូនចេញ បុរសនោះមិញ
ពិតពុំឈរឈប់ ពុះឧសដងទឹក យប់ព្រឹកផ្លូល់ផ្លូប់ បម្រើសព្វគ្រប់
លុះលាងអាចម៍កូន ៗ ផ្ចាប់ផ្គុនទិត្យនៅ លោកពុំប្រដៅ សិល្បសាស្ត្រ
សោះសូន្យ ហេតុសិល្បសាស្ត្រា ថ្លៃថ្លាទុកខ្ទួន- មានមកគួរកូន សិស្ស
សោតបម្រើ ៗ ឯភរិយាយល់ ទៅនោះខ្វាយខ្វល់ ផ្ទួប់អស់អំពើ
ពោលពាក្យប្រាប់ប្តី ភាណអើយឈ្មោះតើ ទៅនេះបម្រើ លំបាកសព្វ
ថ្ងៃ ៗ គេជាត្រកូល ពូជព្រាហ្មណ៍អំបូរ ប្រសើរថ្លៃថ្លៃ គេចូលមក

ធ្វើ បម្រើរះច្នះនៃ គួរកុំសង្ស័យ ប្រដៅគេទៅ ៗ ប្ដីស្ដាប់ច្បាស់ហើយ ពិតពុំលង់ឡើយ ស្រែកហៅទៅពៅ ទិព្វសារបានដឹង ដំណឹងចូល ទៅ ដល់គ្រូប្រដៅ ចាំសព្វសេចក្រប ៗ ទើបគ្រូផ្ដាំ ថាទៅចូរ ចាំ អស់ទាំងពាក្យពេចន៍ អញប្រាប់ឲ្យដឹង ដំណឹងកលកិច្ច ទៅអើយ កុំភ្លេច ពាក្យអញបរថា ៗ មន្តនេះពិសេស ជាមន្តទិព្វទេស ប្រ- សើរថ្លៃថ្លា បើទៅបានដល់ មណ្ឌលនៃអ- មាត្យនូវមហា- ក្សត្រា ប្ដីផ្ដាន ៗ ទៅទឹងបានយស ប្រសើរខ្ពង់ខ្ពស់ គង់កើតធនធាន បើលោកដណ្ដឹង ដំណឹងដោយជាន ទៅប្រាប់កុំមាន សង្ស័យសង្កា ៗ បងអញជាគ្រូ កុំខ្លាចគាស្រូវ ដំនៀលនិន្ទា បើទៅពុំបែង សំដែង មុសា មន្តនោះយល់ជា អសារសាបសោះ ៗ វ៉ៃឯខ្លួនទៅ សោកសឹងអា សៅ អសោចមានមោះ សិស្សសោគចង់ចាំ បណ្ដាំគ្រូនោះ លាគ្រូបបុះ ដល់ដីដើរទៅ ៗ ប្រទក្សិណបី ជុំស្រែចឃ្មោតខ្ញី ស្មានស្មោះសំដៅ ក្រាប់ក្រង់ផ្ដោះឆ្ពាន ដល់ឋានលំនៅ ទៀងទើបចូលទៅ ទីឋានគាគ្នា ៗ ទិព្វសារកុមារ ជប្យមន្តអគាល កើតជាផលា ស្វាយៈដោយព្រះមន្ត ទិព្វ គន់ថ្លៃថ្លា អ្នកផ្សារម្ចាស់ ទិញយកទៅពៅ ៗ កាលៈណោះអ្នកឆ្នាំ ទន្សាន តែងចាំ យល់ស្វាយទុំឆ្អៅ កទិញស្វាយនោះ នាំស្មោះចូលទៅ ថ្វាយ ក្សត្រចមទៅ ជាតិជាអម្ចាស់ ៗ ស្ដេចសោយផលា ទៀងទើបក្សត្រា

ត្រេកទ្រង់ត្រាស់ បើកបន្ទូលថា ស្វាយអាផ្អែមណាស់ ចូរអារហ័ស វិលទៅវិញទៀត ។ ស្វាយនេះចាំឡែក អស្ចារ្យផ្អែមប្លែក អាទំឃ្លាំ ធ្មៀត ខំទិញឲ្យបាន កុំខានបង់សៀត អានោះទៅទៀត រកទិញម៉្លោ ។ បានស្រេចនាំទៅ ថ្វាយក្សត្របមពៅ សព្វទិនទិវ ទិព្វសរកុមារ ត្រអាលយាត្រា នាំស្វាយផលា ថ្វាយក្សត្រជេស្ឋជ័យ ។ ស្ដេចដាក់ប្រទាន មាសប្រាក់ធនធាន ច្រើនពន់ពេកក្រៃ ទិព្វសរកុមារ ត្រអាលសព្វថ្ងៃ ព្រះបាទក្សត្រថ្លៃ ទុកព្រះចិន្ដា ។ ស្ដេចបើកព្រះសូរ មានព្រះបន្ទូល សាកសួរថៃថា ចៅជាគ្រុឌពជ នាគពជពិទ្យា- ធរ ឬទេវតា ចេះមន្ដប្រពៃ ។ ទិព្វសរទូលថា ខ្លួនខ្ញុំនេះណា ជាមនុស្សព្រៃស័យ ខ្ញុំតែងទំនឹងអប- ទេសជប្បសព្វថ្ងៃ ស្ដេចឮអរក្រៃ បើកបន្ទូលថា ។ បើច្នោះព្រះស្ដែង ចេញទៅសំដែង មន្ដសិល្បសាស្ត្រ ឲ្យអញបានយល់ ឫទ្ធិបេស្ដា ឲ្យអស់ប្រាជ្ញា ចៅចេះមន្ដនោះ ។ សូរសើរច្នោះហើយ ពិតពុំលង់ឡើយ លុះព្រឹកឡើងស្មោះ ស្ដេចទៅឧទ្យាន ទីឋានក្បែរណានោះ ទិព្វសរផ្ទុកផ្ទោះ ចូលក្នុងឧទ្យាន ។ អស់ទាំងសេនា មន្ត្រីយោធា ជួបជុំក្រុមគ្នា ទិព្វសរកុមារ ត្រអាលថ្កើងថ្កាន បៀមទឹកស្រេចបាន ពេញមាត់ម៉្លោ ។

(នៅមានត)

ពិធីទ្វាទសមាស

តាមទំនៀមព្រាហ្មណ៍ក្នុងជនពារាណសី (គណ្ឌៀ) ធៀបនឹងទំនៀមខ្មែរ

(ចុកញ៉ា ទេពពិទូរ (ក្រសេម) កត់តាមសេចក្ដីឲ្យការរបស់ព្រាហ្មណ៍ ឈ្មោះសុចុតទន្ទុម៌ ដែលមកពីនគរពារាណសីថា

ព្រាហ្មណ៍ដំណែនពង្ស្រ មានមុខការត្រូវធ្វើពិធីទ្វាទសមាសដូចមានតទៅនេះ៖

ពិធីខែចេត្រ

ខែចេត្រ មានពិធី ៤ យ៉ាងគឺ៖ ពុទ្ធវិធានធម៌ ១, ទេវវិធានធម៌ ១, កជវិធានធម៌ ១, គជវិធានធម៌ ១ ។

ពិធីពុទ្ធវិធានធម៌នោះ (គឺពិធីពុទ្ធបូជា) នាថ្ងៃ ៥ កើតខែចេត្រ ព្រាហ្មណ៍អ្នកធ្វើពិធី ត្រូវធ្វើកខ្ចីកដំរេកាយឲ្យបរិសុទ្ធ ហើយទៅតាក់តែងគ្រឿងសក្ការបូជា គឺផ្កាទៀនធូបគ្រឿងក្រអូប ទឹកសម្រាប់ប្រឡឹមចំណាប់ជាចង្ហាន់ ទុកនៅគន្ធវិហារ វត្ថុទាំងពីជាស វត្ថុមាំដោជាស ហើយអញ្ជើញព្រះមហាក្សត្រ មន្ត្រី ហោរាដល់ប្រជាកស្ត្រ ទៅប្រជុំព្រមគ្នា ធ្វើសក្ការបូជាព្រះពុទ្ធរូបតាមសមគួរ ហើយប្រគំតូរ្យតន្ត្រី ស្រេចហើយប្រគេនចង្ហាន់យតិ (ព្រះសង្ឃ) ផង ពិធីនេះធ្វើតែ ១ ថ្ងៃស្រេច ។

ទេវវិធានធម៌នោះ (គឺពិធីបូជាទេព្វគ្រោះ) ធ្វើនៅថ្ងៃ ៣ កើតខែចេត្រ តាំងរោងពិធីគន្ធព្រះភជពាំង បូជាទេវតាព្រះគ្រោះទាំង ៩ តាំងឆ្នាំងទឹក ៩

ដូងខ្ចីទៀត ៩ ហើយតាំងប្រទីបលើដូងនោះ ទាំងដោតទង់ ៩ ពណ៌ ៩ គឺទង់ព្រះអាទិត្យពណ៌ក្រហមចាស់ ទង់ព្រះចន្ទពណ៌សលឿងខ្ចី ទង់ព្រះអង្គារពណ៌ក្រហមខ្ចី ទង់ព្រះពុធពណ៌លឿង ទង់ព្រះព្រហស្បតិ៍ពណ៌មាស ទង់ព្រះសុក្រពណ៌ស ទង់ព្រះសៅរ៍ពណ៌ខ្មៅ ទង់ព្រះរាហូពណ៌ផ្សែងក្លែង . ទង់ព្រះកេតុផ្សំពណ៌ទាំង ៨ ខាងដើមមកជាពណ៌ទង់ព្រះកេតុ តែងតាំងបូជាអស់រយៈ ៩ ថ្ងៃ ។

ពិធីរាជវិធានម៍នោះ (គឺពិធីស្រង់រំដោះព្រះគ្រោះ) ធ្វើនៅថ្ងៃ ១១ កើតខែចេត្រ ដោយព្រាហ្មណ៍អ្នកធ្វើពិធីយកទឹក ៩ ឆ្នាំង ដែលបូជាព្រះនព្វគ្រោះពីថ្ងៃមុនទៅស្រោចស្រង់ព្រះមហាក្សត្រ ព្រះមហេសី ព្រះរាជបុត្ត ព្រះប្រយូរវង្ស និងសេនាបតី មន្ត្រី រាជបុរសគ្រប់ដំណែង ស្រេចហើយព្រះមហាក្សត្រទ្រង់គ្រឿងរាជកកុធភណ្ឌសម្រាប់ព្រះមហាក្សត្រ ចេញទ្រង់ស្តីការរាជការ ពួកសេនាបតីនិងរាជបុរសត្រូវតែងខ្លួនតាមដំណែងចូលគាល់ព្រមគ្នា លំដាប់នោះព្រះមហាក្សត្រទ្រង់ប្រទានព្រះរាជទ្រព្យឲ្យព្រាហ្មណ៍អ្នកធ្វើពិធី ។

ពិធីគជវិធានម៍នោះ (គឺពិធីបន្តក់ប្រសិទ្ធិដំរី) ធ្វើនៅថ្ងៃ ១ រោចខែចេត្រ ភ្នាក់ងារដំរីតែងគ្រឿងដំរីព្រះទីន័ង ព្រះមហាក្សត្រទ្រង់គ្រឿងរាជកកុធភណ្ឌគង់លើដំរីព្រះទីន័ងនោះ ពួកសេនាបតីនិងអមាត្យទាំងពួងតែងខ្លួនតាមដំណែង ជិះដំរីចងគ្រឿងហែហែស្តេចជុំវិញព្រះរាជវាំង ដំរី

ឈ្មោលគេគូររូបព្រះអាទិត្យដាក់នៅមុខ ដំរីញីគេគូររូបព្រះចន្ទដាក់នៅមុខ ព្រាហ្មណ៍ពជគ្រូចាំប្រស់ទឹកព្រំទឹកស័ង្ខ ។

ពិធីខែពិសាខ

ខែពិសាខមានពិធីតែ ១ ហៅថា វិសាខវិធានម៍ (គឺពិធីបូជាទេវតារក្សាអាកាសទឹកដី) ធ្វើនៅថ្ងៃ ១ កើតខែពិសាខ តាំងផ្តាំងទឹក ៥ ជូងទៀន ៥ សម្រាប់ចំអាប ៥ បង្អែម ៥ និងទៀនធូបភ្ញីផ្កាបូជាក្នុងព្រះពជស្ថាន និងនៅផ្ទះមន្ត្រី សេដ្ឋី គហបតី អ្នកមានទ្រព្យច្រើន បូជាទេវតា ៥ អង្គដែលជាអ្នករក្សាអាកាសទឹកដី គឺ មហាចរ (មហាសំរៃ?) ១ សុរិយេ ១ វិឃណោស ១ កេសរៈ ១ កេសទិ ១ ។ ព្រាហ្មណ៍ពជគ្រូទៅចាត់ការបូជាគ្រប់ផ្ទះ សម្បែងគ្រប់ ៣ ថ្ងៃហើយ យកទឹកមន្តទាំង ៥ ផ្តាំងនោះទៅស្រោចស្រង់ព្រះមហាក្សត្រ រហូតដល់អមាត្យ មន្ត្រី សេដ្ឋី គហបតី ស្រោចហើយ ព្រះមហាក្សត្រ និងអមាត្យ មន្ត្រី សេដ្ឋី គហបតិ អ្នកមានសម្បត្តិក៏តាំងឧទានគ្រប់ៗផ្ទះ តាមមានច្រើនមានតិច សម្រាប់ឲ្យដល់ដំណើរ អស់ការៈ ៣ ថ្ងៃ លុះដល់ថ្ងៃ ១៥ កើតក៏ព្រមគ្នាទៅកាន់ព្រះមហាពោធិព្រឹក្ស ធ្វើសក្ការបូជាព្រះមហាពោធិព្រឹក្ស ប្រគំត្រៃស័ង្ខតុរិយតន្ត្រី ជាការនក្ខត្តឫក្សដ៏ធំ ។

(នៅមានត)

ប្រទេសអាមេរិកកណ្ដាល

ប្រទេសអាមេរិកកណ្ដាល មានអាណាខេត្តនិងទំហំដីប្រហែលប៉ុនឥណ្ឌូស៊ីនបារាំងសែសលើសខ្វះបន្តិចបន្តួច ប្រកបដោយរដ្ឋផ្សេងៗរួម៦រដ្ឋ គឺ គួតេម៉ាឡា ១ ហុងឌុយរ៉ាស ១ នីការ៉ាក្វ ១ សល្វាដ័រ ១ កូស្តារីកា ១ ប៉ាណាម៉ា ១ ទាំង៦រដ្ឋនេះជាឯករាជ្យ មានរបៀបត្រួតត្រាស្រុកបែបប្រជាធិបតេយ្យ មានរដ្ឋៈជាចំណុះប្រទេសអង់គ្លេស ១ ទៀតហៅថា ហុងឌុយរ៉ាសវែរ ។

ផ្ទៃដី — ជាទីពបខ្ពស់ មានភ្នំភ្លើងជាច្រើន ជាហេតុនាំឲ្យកើតផែនដីកម្រើកជារឿយៗ ទីពបខ្ពស់នោះលាតចុះទៅទិសខាងកើត នាំឲ្យមានដីទំនាបនៅតំបន់តាមដាយសមុទ្រខាងមហាសមុទ្រអត្លង់ទិកក្នុងទីទំនាបនេះដាំដំណាំល្អណាស់ ។ ទន្លេសំខាន់ឈ្មោះសានហួន (១៩២ គីឡូម៉ែត្រ) ហូរធ្លាក់ទៅក្នុងទន្លេសាបនីការ៉ាក្វ ។

ខ្យល់អាកាស — មានអាកាសក្ដៅ មានភ្លៀងធ្លាក់ច្រើនដូចជាប្រទេសទាំងពួងដែលតាំងនៅជិតខ្សែសូន្យ តែលើទីពបខ្ពស់ធាតុអាកាសអន់ក្ដៅបន្តិច ។

ដំណាំ — ស្រូវខ្សាយ, កាហ្វេ, កាកាវ, អំពៅ, ចេក, ដូង, កៅស៊ូ, ថ្នាំជក់, ពោត, ត្រីជាដើម ។

៊ សត្វ — គោ ពពែ សេះ និងជ្រូកគេចិញ្ចឹមទុកជាច្រើន ។

ជំនួញលក់ចេញ — កាហ្វេ, ចេក, ស្បែកសត្វ, ឈើសម្រាប់ជ្រលក់សំពត់, ស្ករ, ដូង, ត្រី, គោ, ឈើ ។ ល ។

ប្រជាជន — ជាជាតិឥណ្ឌៀនពួកកូនកាត់ (អេស្ប៉ាញ៉ុលកាត់ឥណ្ឌៀន) ជាច្រើន មានចំនួនប្រមាណ ៧.០០០. ០០០ នាក់ កាន់គ្រិស្តសាសនា លទ្ធិកាតូលិក ។

ប្រទេសក្វាតេម៉ាឡា — មានទំហំដីប្រមាណ ១២៥, ០៧០ គីឡូម៉ែត្រក្រឡា មានមនុស្សចំនួនជាង ២លាន ទីក្រុងឈ្មោះក្វាតេម៉ាឡា លោហធាតុមាន មាស ប្រាក់ ទង់ដែង ។ ទន្លេសំខាន់ឈ្មោះ ម៉ូតាក្វា ប្រវែង ៤០០ គីឡូម៉ែត្រ ។ ជំនួញលក់ចេញដែលសំខាន់បំផុតគឺកាហ្វេ (៦០ % របស់ជំនួញទាំងអស់) ស្ករនឹងចេក ។

ប្រទេសហុងឌុយរ៉ាស — មានទំហំដី ១១៤,៦៧៦ គីឡូម៉ែត្រក្រឡា មានមនុស្សប្រមាណ ៩០០, ០០០ នាក់ ទីក្រុងឈ្មោះតេគុយស៊ីកាល់ប៉ា ទន្លេសំខាន់ឈ្មោះសេគូវី (៥៦០ គីឡូម៉ែត្រ) មានត្បូងថ្ម, មាស, មាសស, ប្រាក់នឹងដែក, ទ្រុយស៊ីល្ហោជាស្រុកកំពង់ អ្នកស្រុកគេស៊ីធ្វើស្រែនឹងចិញ្ចឹមគោ, ជំនួញលក់ចេញដែលសំខាន់បំផុត

គឺចេកអំបូង មានដំឡៃដល់ ៧៩% នៃជំនួញលក់ចេញទាំងអស់ ក្នុង ព.ស..២៤៧៧ មានចំនួនចេកអំបូងលក់ចេញទៅក្រៅប្រទេស ដល់ ១៩.៤៦២.៥៩៦ ស្ទង ជាប្រាក់ជាង ២០ លានរៀល ។

ប្រទេសហុងឌុយរ៉ាសរបស់អង់គ្លេស — មានទំហំដី ២២,២៦៨ គិឡូម៉ែត្រក្រឡា មានមនុស្សប្រមាណ ៥២,០០០នាក់ ប៉េលិសជាទីក្រុង ។ ជំនួញលក់ចេញមាន ចេក, កាហ្វេ និងឈើមៈហ័កកានី ។

ប្រទេសនីការ៉ាក្វ — មានទំហំដី ១៣៣,៨០០ គិឡូម៉ែត្រក្រឡា មានមនុស្ស ៨០០,០០០ នាក់ ទីក្រុងឈ្មោះម៉ាណាក្វ ។ លោហធាតុមានមាស ប្រាក់ ។ ជំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ, ចេក, អំពៅ, កៅស៊ូ ។

ប្រទេសស័ល្វ៉ាឌ័រ — មានទំហំដី ៣៤,១២៦ គិឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១,៥៣០,០០០ នាក់ ជាប្រទេសតូចបំផុត តែមានមនុស្សច្រើនបំផុត នៅអាមេរិកកណ្ដាល ។ ជំនួញលក់ចេញដែលសំខាន់គឺកាហ្វេ, ត្រី, និងចេក ។ ប្រទេសនេះមានភ្នំភ្លើងច្រើន មានផែនដីកំរើកជារឿយៗ ។

ប្រទេសកុស្តារីកា — មានទំហំដី ៥៩,៥៧០ គិឡូម៉ែត្រក្រឡា ចំនួនមនុស្សក្នុង ព.ស. ២៤៧៣ មានចំនួន ៥៦១.០៣១ នាក់ ទី

ក្រុងឈ្មោះសានស៊ូអាន់ ការធ្វើទឹង ចេកជាជំនួញលក់ចេញដែលសំខាន់បំផុតប្រមាណ ៩០% ។

ប៉ាណាម៉ា — មានទំហំដី ១១៤,៤៩០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៥០០,០០០ នាក់ រីក្រុងឈ្មោះប៉ាណាម៉ា អ្នកស្រុកធ្វើស្រែចំការទើងគេរើសត្បូងខៀវមុក ៗ ជំនួញលក់ចេញដែលសំខាន់គឺចេក (៦០%) កាកាវ, ដូង, ខ្យង, ត្បូងខៀវមុក ផ្សេងៗ ។

ព្រែកជីកប៉ាណាម៉ាដែលភ្ជាប់មហាសមុទ្រប៉ាស៊ីហ្វិក និងមហាសមុទ្រអត្លង់ទិកនៅក្នុងប្រទេសនេះ ព្រែកនេះបណ្តោយ ៨០ គីឡូម៉ែត្រ ទទឹងជាង៩០ម៉ែត្រ គួរកប់ថាជាព្រែកជីកដែលធំទូលាយបំផុតក្នុងលោក ។ មាននាវាតូចធំចេញចូលតាមព្រែកជីកនេះក្នុង ១ ឆ្នាំៗ ប្រមាណ ៣០០០ សហរដ្ឋអាមេរិកជាអ្នកជីកហើយជាម្ចាស់ព្រែកជីកនេះផង ។

ពួកកោះផ្សេង ៗ នៅភាគទិសខាងលិច

មានកោះផ្សេងៗជាច្រើនតាំងពីផ្លោរីដចុះទៅដល់ប្រទេសវេនេស៊ុយឡា គួរចែកចែកជា ៣ ពួក គឺ:

(១) ពួកកោះអង់ទីយធំ មានកោះគុយបា, ហៃទី, សាម៉ាអ៊ីកនិងប៉ូរតូរីកូជាសំខាន់ (២) ពួកកោះអង់ទីយតូច ប្រកបដោយកោះតូចៗជាច្រើនដែលសំខាន់គឺកោះទ្រីនីតេ (៣) ពួកកោះបាហាម៉ា ។

គុយបា — ជាប្រទេសឯករាជ្យ មានរបៀបត្រួតត្រាស្រុកជាបែបប្រជាធិបតេយ្យ មានទំហំដី ១១៤,៣៨៤ គីឡូម៉ែត្រក្រឡា ជាកោះធំបំផុតក្នុងចំណោមកោះអស់នោះ ។ កោះនេះមានអាកាសធាតុល្អជាងពួកកោះជិតខាង ។ ដំណាំសំខាន់បំផុតគឺអំពៅ (ច្រើនបំផុតក្នុងលោក) ថ្នាំជក់នឹងពោត ដំណាំបន្ទាប់មកមានស្រូវ កាហ្វេ កប្បាស កាកាវ ។ គេមានចំនួនចិញ្ចឹមច្រើន ទង់ដែងជីកបានច្រើនជាងលោហធាតុឯទៀត ៗ ។ ជំនួញលក់ចេញ មានស្ករ (ច្រើនបំផុត) ថ្នាំជក់ ហ្វារី ទង់ដែង ។ ប្រជាជនមានចំនួន ៤,០១១,០៨៨ នាក់ (ក្នុង ព.ស. ២៤៧៦) មានពូជអេស្ប៉ាញ៉ុលជាច្រើន ។

ហៃទី — កោះនេះបែងចេញជាប្រទេសរេពុយព្លិក ២ ប្រទេស គឺហៃទីនិងសាំងដូមិង្គ ។ កោះនេះមានផែនដីកម្រើកនឹងខ្យល់ព្យុះជារឿយៗ សម្បត្តិផែនដីដែលសំខាន់ គឺកប្បាស ស្រូវ ពោត អំពៅ កាហ្វេ មាស ប្រាក់ ដែកនិងទង់ដែង ។ ប្រទេសនេះមានទំហំដី ៧២,៤២៨ គីឡូម៉ែត្រក្រឡា ។ ប្រជាជនចំនួន ២,៥៥០,០០០ នាក់, ជំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ កាកាវ ថ្នាំជក់និងឈើ ។

សាម៉ាអ៊ិក — ជាកោះរបស់អង់គ្លេស មានខ្នាតធំនឹងសំខាន់ជាងកោះឯទៀតៗរបស់អង់គ្លេសក្នុងពួកកោះអង់ទីយ៍ ។ មានទំហំ ១១.៥២៥

គីឡូម៉ែត្រក្រឡា ។ ប្រជាជនចំនួន ៩០០,០០០ នាក់ សម្បត្តិផែនដី មានចេក កាហ្វេ ខ្ញី កាកាវ ស៊ីនកូណា ឈើ ផ្លែឈើ ។ ជំនួញលក់ចេញដែលសំខាន់គឺចេកអំបូង មានដំឡៃដល់ទៅជាង ២៦ លានរៀលក្នុង ព.ស. ២៤៧៣ ។

ប៉ូរតូរីកូ — ជាកោះចំណុះរបស់អាមេរិក មានទំហំដីប្រមាណ ៨,៨៩៦ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ១,៦០០,០០០ នាក់ មានអាកាសល្អ មានមនុស្សនៅច្រើន ។ ស្ករសជាជំនួញលក់ចេញសំខាន់បំផុត ចំណាយក្នុង ១ ឆ្នាំ ប្រមាណ ៧ សែនតោន ជំនួញបន្ទាប់មកគឺថ្នាំជក់និងម្នាស់ ។

ចប់ភូមិសាស្ត្រសង្ខេប

ប្រទេសអាមេរិកកណ្ដាល តែប៉ុណ្ណេះ ។

ពង្សាវតាររោម

(តមក)

ហេតុទាស់ទែងទំនងនេះហើយ ដែលនាំឲ្យសេសារនឹងប៉ុមប៉េជាសត្រូវនឹងគ្នាយ៉ាងធំ ៗ ឯសេសារក៏ចាប់ធ្វើការដូចជាមេទ័ពមុនៗធ្លាប់ធ្វើមកហើយ គឺលើកទ័ពចូលក្រុងរោម ។

ហេតុកេទទំនងនេះ មិនមែនជាការដណ្តើមអំណាចក្នុងរវាងពួកក្រុមពីរពួកទេ គឺជាការប្រណាំងប្រជែងគ្នាក្នុងរវាងមនុស្ស ២ នាក់ ឯប៉ុមប៉េដែលពោលកងទ័ពខ្លួនទុកនៅប្រទេសអេស្ប៉ាញនោះ ក៏មិនមានកំឡាំងអ្វីនឹងតស៊ូទប់ទល់នឹងសេសារបាន ទើបគេចរត់ចូលទៅក្នុងប្រទេសក្រិក ឯពួកសមាជិកសភាសេណាត៍ ក្រែងខ្លាចអំណាចសេសារក៏នាំគ្នារត់តាមប៉ុមប៉េទៅ ។ កាលបើដូច្នេះ សេសារក៏មានអំណាចធំបំផុតនៅក្នុងក្រុងរោម លុះចាត់រៀបចំក្រុងរោមរៀបរយហើយ ក៏ចេញទៅប្រទេសអេស្ប៉ាញ ដើម្បីប្រមូលយកកងទ័ពរបស់ប៉ុមប៉េមកទុកក្នុងអំណាចខ្លួនផង ក្នុងការចេញទៅនេះ សេសារវាយយកបានស្រុកម៉ារ្សៀយ ១ ផង រួចហើយទើបឆ្លងសមុទ្រអាទ្រីយ៉ាទិក (Adriatique) ទៅវាយទ័ពប៉ុមប៉េបែកខ្ចាត់ខ្ចាយអស់ ឯប៉ុមប៉េរត់ទៅប្រទេសអេស៊ីប្ត៍ គ្រាន់តែឡើងផុតពីទូកក៏មានមនុស្សលបសម្លាប់ទៅ ។

ក្រុងឈ្មោះសានហូសេ កាហ្វេនិងចេកជាដំនួញលក់ចេញដែលសំខាន់បំផុតប្រមាណ ៩០% ។

ប៉ាណាម៉ា — មានទំហំដី ១១៤,៤៩០ គីឡូម៉ែត្រក្រឡា ចំនួនមនុស្ស ៥០០,០០០ នាក់ រីក្រុងឈ្មោះប៉ាណាម៉ា អ្នកស្រុកធ្វើស្រែចំការនឹងរករើសត្បូងខៃមុក្ត ។ ដំនួញលក់ចេញដែលសំខាន់គឺចេក(៦០%) កាកាវ, ដូង, ខ្យង, ត្បូងខៃមុក្ត ធ្យូងថ្ម ។

ព្រែកជីកប៉ាណាម៉ាដែលភ្ជាប់មហាសមុទ្រប៉ាស៊ីហ្វិក នឹងមហាស. មុទ្រអាត្លង់ទិកនៅក្នុងប្រទេសនេះ ព្រែកនេះបណ្ដោយ ៨០ គីឡូម៉ែត្រ ទទឹងជាង៩០ម៉ែត្រ គួរកប់ថាជាព្រែកជីកដែលធំទូលាយបំផុតក្នុងលោក ។ មាននាវាតូចធំចេញចូលតាមព្រែកជីកនេះក្នុង ១ ឆ្នាំ ៗ ប្រមាណ ៣០០០ សហរដ្ឋអាមេរិកជាអ្នកជីកហើយជាម្ចាស់ព្រែកជីកនេះផង ។

ពួកកោះផ្សេង ៗ នៅភាគទិសខាងលិច

មានកោះផ្សេងៗជាច្រើនតាំងពីជ្រោយហ្វ្លរីដចុះទៅដល់ប្រទេសវេនេស៊ុឡា គួរបែងចែកជា ៣ ពួក គឺ:

(១) ពួកកោះអង់ទីយធំ មានកោះគុយបា, ហៃទី, សាម៉ាអ៊ីកនិងប៉ួ- តូរីកូជាសំខាន់ (២) ពួកកោះអង់ទីយតូច ប្រកបដោយកោះតូចៗជាច្រើន ដែលសំខាន់គឺកោះទ្រីនីតេ (៣) ពួកកោះបាហាម៉ា ។

គុយបា — ជាប្រទេសឯករាជ្យ មានរបៀបគ្រប់គ្រងស្រុកជាបែបប្រជាធិបតេយ្យ មានទំហំដី ១១៤,៣៨៤ គីឡូម៉ែត្រក្រឡា ជាកោះធំបំផុតក្នុងចំណោមកោះអស់នោះ ៗ កោះនេះមានអាកាសអ៊ិនខាល្អជាងពួកកោះដទៃខាង ៗ ដំណាំសំខាន់បំផុតគឺអំពៅ (ច្រើនបំផុតក្នុងលោក) ថ្នាំជក់និងពោត ដំណាំបន្ទាប់មកមានស្រូវ កាហ្វេ កប្បាស កាកាវ ៗ គោមានចំនួនចិញ្ចឹមច្រើន ទង់ដែងដែក បានច្រើនជាងលោហធាតុឯទៀតៗ ៗ ជំនួញលក់ចេញ មានស្ករ (ច្រើនបំផុត) ថ្នាំជក់ ប៉ារី ទង់ដែង ៗ ប្រជាជនមានចំនួន ៤,០១១,០៨៨ នាក់ (ក្នុង ព.ស. ២៤៧៦) មានពួកអេស្ប៉ាញ៉ុលជាច្រើន ៗ

ហៃទី — កោះនេះបែងចេញជាប្រទេសរេពុយព្លិក ២ ប្រទេស គឺហៃទីនិងសាំងដូមិង្គ ៗ កោះនេះមានផែនដីកម្រើកនិងខ្យល់ព្យុះជារឿយៗ សម្បត្តិផែនដីដែលសំខាន់ គឺកប្បាស ស្រូវ ពោត អំពៅ កាហ្វេ មាស ប្រាក់ ដែកនិងទង់ដែង ៗ ប្រទេសនេះមានទំហំដី ៧២,៤២៨ គីឡូម៉ែត្រក្រឡា ៗ ប្រជាជនចំនួន ២,៥៥០,០០០ នាក់, ជំនួញលក់ចេញដែលសំខាន់ គឺកាហ្វេ កាកាវ ថ្នាំជក់និងឈើ ៗ

សាមាអ៊ិក — ជាកោះរបស់អង់គ្លេស មានខ្នាតធំនិងសំខាន់ជាងកោះឯទៀតៗរបស់អង់គ្លេសក្នុងពួកកោះអង់ទីយ៍ ៗ មានទំហំ១១.៥២៥

រឿងព្រះបាទអសោក

(តមក)

ក្នុងខេត្រដែលព្រះបាទអសោកបញ្ជូនព្រះថេរទៅប្រកាសព្រះពុទ្ធ-សាសនានេះ មានទឹកដីជាដែនដែលមិនបាននៅក្នុងអំណាចរបស់ព្រះអង្គតែអាស្រ័យហេតុដែលព្រះអង្គមានអំណាចជាធំក្រៃលែងនៅក្នុងឥណ្ឌា ទើបមិនមានអ្នកណាហ៊ានឃាត់ឃាំងឡើយ ហើយកាលនោះព្រះពុទ្ធសាសនាជាសាសនាដែលដោះទុក្ខរបស់មនុស្សបានពិត ៗ ដូច្នេះ អ្នកប្រទេសទាំង-ឡាយក៏ជ្រះថ្លាជាច្រើន ម្យ៉ាងទៀត បណ្ដាលោកអ្នកដែលប្រកាសព្រះពុទ្ធសាសនានេះ ក៏បានធ្វើប្រយោជន៍ដ៏សំខាន់ឲ្យដល់អ្នកប្រទេសទូទៅ ដូចក្នុងដែនដេក្កាន់ (Dek-kan) ដែលវេលានោះនៅជាមនុស្សព្រៃនៅឡើយ ក៏បានទទួលសេចក្ដីចំរើនរុងរឿងឡើងដោយពុទ្ធានុភាព តែដែលសំខាន់បំផុតក៏គឺកោះលង្កានិងខាងកស្មីរៈ ៗ

ព្រះមហិន្ទត្ថេរ និងព្រះនាងសង្ឃមិត្តាថេរី ជាឱរសនិងធីតារបស់ព្រះបាទអសោក បានមកដល់ក្នុងកោះលង្កា ហើយធ្វើឲ្យស្ដេចក្នុងលង្កាទ្វីបដែលទ្រង់ព្រះនាមថា ព្រះបាទទេវានម្បិយតិស្ស ជ្រះថ្លាក្នុងពុទ្ធោវាទ ហើយសាសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏បានប្រតិស្ឋានក្នុងលង្កាទ្វីបក្នុងកាលពុទ្ធសករាជ ៣១៣ កាលដែលព្រះមហិន្ទត្ថេរនិងព្រះនាងសង្ឃ-មិត្តាថេរីស្ដេចទៅលង្កាទ្វីបនោះ ទ្រង់បាននាំយកមែកពោធិ៍អំពីពោធិ-

ព្រឹក្សដែលព្រះសម្មាសម្ពុទ្ធត្រាស់នោះទៅដាំក្នុងកោះលង្កា ហើយដើមពោធិ៍នោះចំរើនធំឡើងនៅដល់មកសព្វថ្ងៃនេះ ជាឈើដែលរស់នៅបានយូរបំផុតក្នុងលោកមានអាយុជាង ២០១០ ឆ្នាំមកហើយ ។ កាលព្រះពុទ្ធ-សាសនាប្រតិស្ឋានមាំក្នុងកោះលង្កា ពួកជនអ្នកលង្កាក៏ខ្វល់ខ្វាយប្រឹងប្រែងក្នុងការតែងតម្ព័រនឹងប្រកាសព្រះពុទ្ធសាសនាទៅកាន់ប្រទេសភូមា ជ្វា និងឥណ្ឌូស៊ីនទាំងអស់ទូទៅ ហើយតមកក្នុងសម័យកណ្តាល កាលព្រះពុទ្ធសាសនាបានខ្ចាត់ខ្ចាក់ចេញពីឥណ្ឌា ដោយការបៀតបៀនរបស់សាសនាហិណ្ឌូនិងមហាម៉ាត់ (អ៊ិស្លាម) ហើយកោះលង្កាក៏ត្រឡប់ប្រែជាប្រធានរបស់ព្រះពុទ្ធសាសនា ។

ចំណែកប៉ែកខាងជើង គឺខាងគស្មីរៈនិងគន្ធារៈនោះព្រះសាវកជាអ្នកប្រកាសព្រះសាសនា បានធ្វើប្រយោជន៍ជាច្រើនជាងប៉ែកខាងឯទៀត ព្រោះថាព្រះមជ្ឈន្តិកៈ អ្នកនាំព្រះពុទ្ធសាសនាទៅប្រកាសក្នុងដែននោះបាននាំភិក្ខុច្រើនរយរូបទៅជាមួយផង ហើយពួកលោកទាំងអស់នេះបានធ្វើសេចក្តីចំរើនមិនតែផ្សព្វផ្សាយនិងសីលធម៌របស់ប្រជាជនប៉ុណ្ណោះទេ លោកក៏បានទាំងណែនាំជួយក្នុងការសាងទីក្រុង, ធ្វើផ្លូវទឹក, ទំនុកបំរុងក្នុងការដាំដំណាំ, ឲ្យបានសេចក្តីចំរើនក្នុងផ្លូវរកចិញ្ចឹមជីវិតរបស់មនុស្សទៀតផង ក្នុងបទដែលពោលតទៅនឹងឃើញបានថា ខាងគស្មីរៈនិងគន្ធារៈ

នេះឯងដែលជាអ្នកប្រកាសសាសនាចេញទៅកាន់ប្រទេសចិន ដែលបង្កិតជានិកាយមហាយានឡើង ។

លុះព្រះបាទអសោកបានទំនុកបំរុងព្រះពុទ្ធសាសនាឲ្យរុងរឿងពេញបន្ទុកយ៉ាងនេះហើយ ក៏គង់មិនទាន់ពេញព្រះរាជហឫទ័យព្រះអង្គនៅឡើយ បានជាព្រះអង្គព្យាយាមធ្វើឲ្យព្រះពុទ្ធសាសនាផ្សាយចេញទៅដល់ប្រទេសក្រិក តាំងអំពីរជ្ជសម័យព្រះបាទអាឡេក្សាន្ទ្រមហារាជ ទីងផ្សាយទៅដល់ទ្វីបអឺរ៉ុបថែមទៀត ។ មានសិលាចារឹកចុះព្រះនាមស្តេចក្នុងប្រទេសផ្សេង ៗ ដែលជាអ្នកជួយក្នុងការប្រកាសសាសនា តែព្រះនាមរបស់ស្តេចទាំងអស់នោះ ព្រះបាទអសោកយកមកសរសេរជាភាសាបាលីទាំងអស់ ដូច អន្តិយកៈ (ព្រះបាទអែន្តិឧគោសទី ២ ជាស្តេចក្រុងស៊ីរី (Sirie) តុរុមាយៈ (ព្រះបាទប៉តោលេមេ ជាស្តេចដែនដីអេហ្ស៊ីប្ត (Egypte) អន្តិកេនៈ (ព្រះបាទអន្តិគោន ជាស្តេចដែនដីម៉ាសេដ្វាន (Macédoine) អលិកសន្ទរោ (ព្រះបាទអាឡេក្សាន្ទ្រ ជាស្តេចក្រុងអេប៉ីរ (Epire) មកៈ (ព្រះបាទមាគ័ស ស្តេចក្រុងនគរតូច ១ មួយកន្លែងជាខាងកើតប្រទេសអេហ្ស៊ីប្ត) ដោយហេតុនេះទើបត្រូវរាប់ថាព្រះបាទអសោកបានប្រកាសព្រះពុទ្ធសាសនា មិនមានពុទ្ធសាសនិកជនឯណាឲ្យបានត្រឹម ស្មើនឹងព្រះអង្គនោះឡើយ ហើយក្នុងគ្រានេះយើងក៏ចូលចិត្តបានថាហេតុអ្វីគោលសំខាន់ក្នុងគ្រិស្តសាសនាទើបប្រហែលគ្នានឹងព្រះពុទ្ធសា-

សនាដ៏ច្រើនម៉្លេះ ប្រសិនបើព្រះបាទអសោកមិនអស់ព្រះជន្មដោយរហ័ស ឬថាកាលអស់ព្រះជន្មហើយមានអ្នកប្រព្រឹត្តតាមព្រះរាជលំអានតមកដោយសេចក្តីជ្រះថ្លាដ៏ហ្មត់ចត់ មានអំណាចរាជស័ក្តិយ៉ាងព្រះបាទអសោកផងហើយ ក៏មិនបាច់សង្ស័យឡើយទុរបទាំងទ្វីបក៏នឹងកាន់ព្រះពុទ្ធសាសនាមិនខាន កាលបើទុរបទាំងទ្វីបកាន់ព្រះពុទ្ធសាសនាហើយ ព្រះពុទ្ធ-សាសនាក៏នឹងត្រឡប់ជាទីពំនាក់របស់លោកទាំងអស់ទូទៅ ទ្រង់ទ្រាយរបស់លោកហើយនឹងវៃបផែនការងារប្រព្រឹត្តទៅនៃខែត្រផែនក៏នឹងខុសប្លែកពាក់ហេតុគេគន់វេលានេះជាច្រើន ៗ

សិលាចារិករបស់ព្រះបាទអសោក ដែលប្រតិស្ឋានទៅទីប្រសូតរបស់ព្រះពុទ្ធជាម្ចាស់ ដូចបានប្រែមកជាអក្សរខ្មែរនឹងភាសាខ្មែរដូចតទៅនេះ:

១– ទេវានំ បិយេន បិយទសិន លាជិន វីសតិវសាភិសិតេន

២– អតន អាគាច មហីយិតេ ហិទ ពុធេ ជាតេ សក្យមុនីតិ

៣– សិលាវិគឌភីចា កាលាបិត សិលាថំភេច ឧសបាបិតេ

៤– ហិទ ភគវំ ជាតេតិ លុំមិនិគាមេ ឧពលិកេ កះដ

៥– អឋភាគិយេច

ពាក្យប្រែ

១ – ព្រះរាជាប្រិយទស្សីជាទីស្រឡាញ់របស់ទេវតា រាជាភិសេកហើយបាន ២០ ឆ្នាំ[១] ។

២ - ស្ដេចមកបូជាដោយព្រះអង្គឯង ទ្រង់ប្រាប់ច្បាស់ថា ព្រះសក្យមុនីពុទ្ធទ្រង់ប្រសូតហើយក្នុងទីនេះ ។

៣- ទើបប្រោសឲ្យបាកសិលាទុក?[២] និងប្រោសឲ្យតាំងសសរថ្ម ។

៤ – សំដែងប្រាប់ថា ព្រះដ៏មានព្រះភាគទ្រង់ប្រសូតហើយក្នុងនេះ និងប្រោសឲ្យបន្ថយសួយបាន ក្នុងតំបន់ស្រុកលុម្ពិនី ។

៥ – ចុះប្រាំបីភាគ (?) ។

អសន្ធិមិត្តាអគ្គមហេសី

គម្ពីរមហាវង្ស

ព្រះបាទអសោកមហារាជទ្រង់មានអគ្គមហេសីមួយអង្គ ព្រះនាមនាងអសន្ធិមិត្តា[៣] (មានអាយុរ៉ះគតស្នាមដំណា) ព្រះនាងមានរូបឆោមដ៏ល្អ ជាទីត្រេកក្នុងលោក គួរអ្នកផងក្រឡេកមើលដោយសេចក្ដីពេញចិត្ត ព្រះ

---

១ ព្រះនាមពេញរបស់ព្រះបាទអសោកថា "អសោកបិយទសី" ។ ២ ដែលមានគ្រឿងសំគាល់ថ្មច្រះឲ្យដឹងថា អ្នកប្រែមិនស្គាល់ច្បាស់ ។ ៣ តាមសៀវភៅពុទ្ធសាសនារបស់លោកល្វី-ហ្វី ណូត៍ ដែលលោកជុំ-ម៉ៅ ប្រែជាខ្មែរថា ព្រះនាងអសន្ធិមិត្តាមានបុត្រមួយព្រះអង្គ ព្រះនាមកុណាល តែក្នុងមហាវង្សមិនឃើញមាននិយាយ ។

នាងមានបសាទសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងនិមន្តព្រះភិក្ខុសង្ឃទាំងប្រាំមួយម៉ឺនអង្គមកប្រគេនចង្ហាន់ជាមួយនឹងព្រះបាទអសោកជាព្រះរាជស្វាមី ។

ថ្ងៃមួយ ព្រះនាងប្រថាប់នៅលើ (កៅអីមាសជាំត្បូង) កំពុងសោយអំពៅដែលពួកទេវតានាំយកពីហិមវន្តប្រទេសមកថ្វាយ ពេលនោះព្រះបាទអសោកស្ដេចយាងចូលទៅក្នុងទីនោះទ្រង់ទតឃើញព្រះនាងអសន្ធិមិ-ត្តាកំពុងសោយអំពៅ ទើបចំអន់ព្រះនាងក្រសាលព្រះរាជហឫទ័យថា "ហៃនាងមានរូបឆោមនឹងកត្តាដ៏ល្អស្រស់ប្រិមប្រិយ នាងបរិភោគខូវទឹកអំពៅដ៏ផ្អែមត្រជាក់ដូចជារសនៃទឹកឃ្មុំនេះសប្បាយរីករាយចិត្តណាស់ទៅឬ?" ។

ព្រះរាជទេវីបានស្ដាប់ព្រះរាជឧង្ការត្រាស់សរសើរចំអកដូច្នោះក៏តូចព្រះហឫទ័យក្រាបទូលថា: "បពិត្រព្រះសម្មតិទេពដ៏ប្រសើរ អំពៅនេះកើតក្នុងហិមវន្តប្រទេស ទេវតានាំយកមកថ្វាយនេះ ព្រោះតែបុញ្ញានុភាពនៃខ្ញុំម្ចាស់ មិនមែនព្រោះបុណ្យសម្ភារនៃព្រះអង្គទេ" ។

ព្រះមហាក្សត្រិយ៍ត្រាស់តបថា: "នែនាងមានកត្តដ៏ចំរើន ឥស្ស-រិយសម្បត្តិក្នុងសកលជម្ពូទ្វីបនេះជារបស់យើង នាងថាសម្បត្តិទាំងពួងកើតព្រោះបុណ្យរបស់នាងទៅវិញ នាងឯងក៏យឫកស្មើ លើកដំកើងខ្លួនឲ្យខ្ពស់ដល់ភពមហាព្រហ្ម បន្ថោកបុណ្យរបស់យើងទំលាក់ឲ្យទាបដល់អវិចីមហានរកទៅឬ? នាងឯងថាសម្បត្តិកើតព្រោះបុណ្យខ្លួននាង

ឯងឲ្យមានបុណ្យពិតណាស់ហើយ បើដូច្នោះព្រឹកនេះ យើងនឹងលៀងព្រះសង្ឃប្រាំមួយម៉ឺនអង្គ ចូរនាងឯងរកសំពត់ឲ្យបានប្រាំមួយម៉ឺនផាប់នឹងប្រគេនដល់ព្រះភិក្ខុសង្ឃក្នុងថ្ងៃព្រឹកនេះ បើនាងឯងរកបានទាន់ពេលធ្វើទាននេះ ទើបឃើញជាក់ច្បាស់ថានាងមានបុណ្យប្រាកដមែន តែបើរកមិនបានទេ យើងនឹងត្រូវធ្វើតាមរាជអាជ្ញាដល់នាងឯងក្នុងថ្ងៃព្រឹកនេះ" ។

កាលនាងទេវីបានស្តាប់ព្រះរាជឱង្ការដាក់រាជអាជ្ញាដល់នាង ក៏កើតភ័យមានព្រះកន្ត្រាក់ស្លុតស្លាំងដោយរំពឹងថា "ព្រះមហាក្សត្រិយ៍ទ្រង់ព្រះក្រោធដល់អាត្មា" ហើយព្រះនាងសោយសោកហាក់ដូចជាត្រូវថ្នាំពិសពុះក្តៅក្រហល់ជាប់នៅនឹងដួងហឫទ័យភ័យជានិច្ច គប់ផ្ដើមចេញចូល ព្រះនាងរំពឹងថា "នុះអាត្មាអញនេះ នឹងទៅរកសំពត់ក្នុងទីឯណា ឲ្យបានដល់ទៅប្រាំមួយម៉ឺនដូច្នេះហ្ន៎" ព្រះនាងចូលទៅក្នុងក្រឡាព្រះបន្ទំយំទួញបម្រះទ្រៀលទៅមក ។ លើទីសិរីសយនាមិនបាននិទ្រាលក់អស់មួយរាត្រី ដោយថប់បារម្ភថា មុខជានឹងត្រូវស្លាប់ព្រឹកនេះ ហេតុតែតេជះកុសលដែលនាងបានកសាងមកអំពីអតីតជាតិ ក៏ក្តៅដល់ចតុលោកបាលទាំង[១] ៤ គ្រានោះស្តេចវេស្សវ័ណមហារាជបានជ្រាបថា ព្រះនាងអសន្ធិមិត្តាអគ្គមហេសីមានទុក្ខព្រួយដូច្នោះ ក៏ស្តេចចូលទៅកាន់សំណាក់ព្រះ

---

១ ចតុលោកបាល ទេវតារក្សាលោកមាន ៤ អង្គ គឺ កុវេរៈ (ឬវេស្សវ័ណក៏ហៅ) ធតរដ្ឋ វិរូបក្ខនិងវិរុឡ្ហក ។ ទេវតាទាំង ៤ អង្គនេះជាអ្នកដឹងថា សត្វធ្វើល្អធ្វើអាក្រក់គ្រប់យ៉ាង ។

នាងហើយត្រាស់ថា៖ "បពិត្រព្រះរាជទេវី ព្រះនាងកុំសោយសោកថប់បារម្ភឡើយ សំពត់សាដករបស់ព្រះនាង កាលថ្វាយដល់ព្រះបច្ចេកពុទ្ធអំពីជាតិមុននោះ ចូរព្រះនាងពិចារណារំពឹងដល់ផលសំពត់សាដករបស់ព្រះនាងនោះចុះ ទឹងឲ្យផលប្រាកដដល់ព្រះនាងគ្រានេះ" លុះទ្រង់ជាស់តឿនព្រះស្មារតី ព្រះអគ្គមហេសីដូច្នេះ ហើយក៏និម្មិតដោយឫទ្ធិ នាំយកប្រអប់មួយមានជាយសំពត់សាដកចេញមកប្រាកដខាងក្រៅ ប្រគល់ឲ្យព្រះនាងអសន្ធិមិត្តារាជទេវី ហើយត្រាស់បង្គាប់ថា "បពិត្រព្រះរាជទេវី បើព្រះនាងប្រាថ្នាទឹងចង់យកសំពត់សាដកប៉ុន្មានៗក្តី ចូរទាញជាយសំពត់ដែលចេញមកប្រាកដខាងក្រៅនេះចុះ ទឹងកើតសំពត់សាដកយ៉ាងល្អវិសេសដូចចិត្ត មានដំឡៃទឹងកាត់ថ្លៃមិនបានប្រមាណមិនកើត" ៗ លុះព្រះបាទវេស្សវ័ណមហារាជត្រាស់បង្គាប់ព្រះនាងសព្វគ្រប់ហើយ ក៏ស្តេចចេញចាកទីនោះទៅ លុះដល់ព្រឹកព្រលឹមស្រាងឡើង ព្រះបាទអសោកស្តេចអង្គាសព្រះភិក្ខុសង្ឃដោយភោជនាហារដ៏ឧត្តម បូជាដោយសុគន្ធបុប្ផាស្រេចហើយ ក៏ងៀងព្រះនេត្រទតមើលព្រះអគ្គមហេសីត្រាស់ថា "ចូរនាងយកសំពត់ប្រាំមួយហ្មឺនជាប់តាមដោយកំឡាំងបុណ្យរបស់ខ្លួនមកទឹងប្រគេនដល់ព្រះសង្ឃប្រាំមួយហ្មឺនរូបនេះ" ៗ ព្រះរាជទេវីក៏នាំយកប្រអប់ទិព្វមកទាញហូតយកសំពត់ម្តងមួយគូៗ ជាសំពត់កាត់

ថ្ងៃមិនបាន ហាក់ដូចជាសំពត់ទិព្វដែលកើតក្នុងដើមកល្បព្រឹក្ស ថ្វាយដល់ព្រះមហាក្សត្រិយ៍ ហើយក្នុងសំពត់មួយផាប់ៗ នោះល្មមបានចីវរមួយត្រៃៗ ព្រះមហាក្សត្រិយ៍ទ្រង់ប្រគេនដល់ព្រះសង្ឃថេរ ហើយទើបថ្វាយទូទៅគ្រប់ព្រះសង្ឃទាំងប្រាំមួយហ្មឺនរូបដែលគង់នៅក្នុងទីនោះ ព្រះសង្ឃទាំងអស់អនុមោទនា ហើយថ្វាយព្រះពរលា ព្រះមហាក្សត្រិយ៍ចេញទៅកាន់អាវាស ។

ឯព្រះបាទអសោកទ្រង់សព្វព្រះរាជហឫទ័យសប្បាយរីករាយ ស្ញើចនឹងបុណ្យកុសលនៃព្រះនាងទេវី ត្រាស់ស្រស់ស្រាយដោយសេចក្ដីសោមនស្ស ទើបស្ដេចទ្រង់ឈរក្នុងកណ្ដាលប្រជុំពួកស្រីស្នំដ៏រុងរឿងដូចជាព្រះឥន្ទ្រនៅក្នុងកណ្ដាលពួកស្រីទេពអប្សរក្នុងស្ថានសួគ៌ ហើយត្រាស់ថា "នៃនាង! ខ្ញុំបងនេះមានសេចក្ដីជ្រះថ្លាក្នុងកុសលរបស់នាងពន់ពេក យើងដឹងច្បាស់ហើយថា កុសលនាងបានធ្វើទុកមកអំពីជាតិមុនពិតទើបបានមកជួបប្រសព្វនឹងយើងៗធ្វើអាការកិរិយាដល់នាងទាំងនេះ ដើម្បីនឹងល្បងកុសលរបស់នាងមើល នាងកុំតូចចិត្តឡើយ ចូរអត់ទោសចុះ ឥស្សរិយសម្បត្តិទាំងពួងនេះយើងប្រគល់ឲ្យដល់នាងហើយ ចូរនាងជាធំចម្បងជាងពួកស្រីស្នំទាំងមួយហ្មឺនប្រាំមួយពាន់នេះ ចាប់ដើមតាំងតែពីថ្ងៃនេះទៅ" ។

(នៅមានត)

ប្រស្នាចំរើនសតិបញ្ញា

ប្រស្នាទី ១

សេចក្ដីឆ្លើយទី ២

សួរថា: ខ្វាក់នឹងខ្វិនតើណាគ្រាន់បើជាង?

ក្នុងប្រស្នានេះមានសេចក្ដីមុខគួរឲ្យចង់ស្ដាប់ណាស់ · ខ្វាក់ឬខ្វិនពីរចំពួកនេះ គោងមានកំណត់ទាំងសងខាង ៗ ឯចំណងរបស់ខ្ញុំបាទក្នុងការដោះស្រាយប្រស្នានេះត្រូវការកំណត់ថា ពាក្យថា "ខ្វាក់" គឺខ្វាក់ទាំងសងខាងមើលអ្វីមិនឃើញសោះ តែដៃ ជើង ត្រចៀក នៅល្អគ្រប់គ្រាន់ ៗ ពាក្យថា "ខ្វិន" គឺខ្វិនជើងទាំងសងខាងដើរទៅណាមិនរួចឡើយ តែត្រចៀកដៃភ្នែកនៅល្អទាំងអស់ ហើយត្រូវកំណត់ថា អ្នកទាំងពីរនេះឥតអ្នកណាទំនុកបំរុងថែរក្សាទេ គោងចិញ្ចឹមជីវិតដោយទំនេងខ្លួនឯង ៗ បើមានសភាពដូច្នោះ ខ្ញុំបាទយល់ថា អ្នកខ្វាក់ភ្នែកទាំងសងខាងគ្រាន់បើជាងអ្នកខ្វិនជើងទាំងសងខាង ព្រោះភ្នែកខ្វាក់មើលអ្វីមិនឃើញក៏ពិតមែន តែការសំខាន់នៅត្រង់ជើងទាំងសងខាងនៅល្អទាំងអស់ ល្មមជាគ្រឿងចិញ្ចឹមជីវិតដោយខ្លួនឯងបាន ទឹងដើរសុំទានគេឬច្រៀងសុំទានក៏បាន ដូចតាយួនម្នាក់ ខ្វាក់ភ្នែកទាំងសងខាង ចេះកូតទ្រចេះច្រៀង មានក្មេងតូចម្នាក់ដឹកដៃដើរសុំទាននៅទីប្រជុំបុណ្យទានឬនៅ

ទីផ្សារ គាត់បេះគូតទ្រ បេះទ្រៀង មានមនុស្សតែងតែមកឈរមើលឈរ
ស្ដាប់ជុំៗជាច្រើន បោះសេនបោះកាក់ឲ្យជាទាន ក្នុង ១ ថ្ងៃៗបានប្រាក់
គាត់ល្មមចិញ្ចឹមជីវិតបានដោយស្រួលមិនលំបាកវេទនាប៉ុន្មានទេ ។ បណ្ដា
មនុស្សយើងទាំងមានទាំងក្រ តែខ្វាក់ខ្វិនខ្វិចដៃជើងហើយ រមែងមាន
សេចក្ដីត្រូវការតែអាហារមួយចំនែកៗ ក្នុងមួយថ្ងៃៗ ដូចជាសត្វទាំងឡាយ
តែអ្នកដែលខ្វិនខ្វិចជើងទាំងសងខាងឥតអ្នកទំនុកបំរុងហើយ តែងដល់នូវ
សេចក្ដីវិនាស ព្រោះនឹងដើរទៅសុំទានគេឬទៅរកស៊ីឈ្នួលគេក៏មិនបាន
អស់ផ្លូវរកចិញ្ចឹមជីវិតដោយទំនើងខ្លួនបាន ។ ឯអ្នកខ្វាក់តែជើងដៃនៅ
ល្អទាំងអស់ ទុកជាមិនបេះផ្កាកូតទ្រ ឬទ្រៀងជាដើម ក៏ល្មមប្រើជើងដើរ
ទៅសុំទានគេចិញ្ចឹមជីវិតរបស់ខ្លួនបានដែរ មិនលំបាកវេទនាដូចជាមនុស្ស
ខ្វិនជើងទេ ។ ហេតុនេះទើបខ្ញុំបាទយល់ថា អ្នកខ្វាក់ភ្នែកគ្រាន់បើជាង
អ្នកខ្វិន ។ មួយវិញទៀត បើមានគ្រោះថ្នាក់អន្តរាយយ៉ាងធំមកយ៉ាង
ទាន់ហន់ ចួនជាអ្នកខ្វាក់នឹងអ្នកខ្វិននៅក្នុងទីនោះជាមួយគ្នា ដូចជាមាន
រថយន្តឬសេះដំរីគោក្របីជាដើមរត់ចូលមកជិត មុខជានឹងជាន់ឬកិនអ្នក
ទាំងពីរ អ្នកខ្វិនទុកជាមានភ្នែកមើលឃើញត្រចៀកស្ដាប់ឮ ក៏មិនអាចគេច
រត់ឲ្យផុតអន្តរាយទៅបាន គង់ទទួលគ្រោះថ្នាក់ជាដាច់ខាត ។ ឯអ្នក
ខ្វាក់ទុកជាភ្នែកមើលមិនឃើញតែត្រចៀកស្ដាប់ឮ ក៏អាចនឹងគេចរត់ឲ្យ
ផុតអន្តរាយទៅបាន ១ គ្រា មិនដល់ទាល់ច្រកដូចអ្នកខ្វិនទេ នេះក៏ជា

ឧទាហរណ៍ ១ បង្ហាញឲ្យឃើញថា តើខាងណាត្រាន់បើជាងខាងណា អ្នកដែលបណ្ដោយឲ្យរថកិនឬសត្វជាន់ត្រាន់បើជាង ឬអ្នកដែលគេចរត់ឲ្យផុតអន្តរាយទៅបានត្រាន់បើជាង ដូច្នោះគួរយល់ថាខ្វាក់ត្រាន់បើជាងខ្វិន ដូចសេចក្ដីដែលពណ៌នាមកនេះ ។

នាយខ្វាក់

*

* *

ប្រស្នាទី ២

សួរថា: សក់នាំឲ្យបានសុខឬបានទុក្ខ?

ក្នុងប្រស្នានេះ ខ្ញុំបាទបានត្រិះរិះពិចារណាអំពីធម្មតារបស់សក់ដែងកើតមកប្រចាំរូបកាយរបស់មនុស្សទូទៅ យល់ឃើញថាជាគ្រឿងនាំឲ្យកើតទុក្ខរំខានចិត្តឥតស្រាកស្រាន្ត គ្រាន់តែខុសគ្នាត្រង់តិចឬច្រើនប៉ុណ្ណោះ ។ ធម្មតាសក់ស្កុកបរិបូណ៌ អ្នកម្ចាស់សក់តោងតែឧស្សាហ៍ទំនុកបំរុងឲ្យរៀបរយ គឺតោងកក់ តោងសិត តោងកាត់ជានិច្ច បើមិនកាត់សោះ ព្រោះបង់ទុកឲ្យវែងមិនស្អិតស្អាងទេ មុខជាឆ្អេះឆ្អាបកើតចៃចៅដែរក្បាលមិនខាន ដូច្នេះ អ្នកម្ចាស់សក់ត្រូវតែខ្វល់ខ្វាយរកគ្រឿងស្អិតស្អាងឲ្យសក់ស្អាតល្អ គឺក្រមួន, ប្រេងដូង, ក្រាស, កញ្ចក់, កាំបិតកោរ, កន្ត្រៃ ជាដើម អស់នេះបំរុងទុកជានិច្ច ។ កាលណាសក់ដុះវែងបន្តិចឡើង ដោយហោច

ទៅក្នុង ១ ខែគេនឹងទៅជួលជាងកាត់សក់ឬកាល់ជើងសក់ម្តង គេនឹងបង់ខាត
សោហ៊ុយម្តងយ៉ាងតិចត្រឹម ២ កាក់ ឬគ្រាន់តែបៀរជើងសក់ម្តងថ្លៃ១ កាក់
បើហៅគេមកកាត់ឯផ្ទះ គេនឹងបង់ថ្លៃកាត់សក់យ៉ាងតិចត្រឹម ៣ កាក់ហួត
ដល់ ៥ កាក់ ១ រៀលក៏មាន អ្នកខ្លះទំយមកាត់សក់ដល់ ២ ដងឬ ៣ ដង
ក្នុង ១ ខែក៏មាន គេនឹងបង់ខាតប្រាក់កាសរឿងសក់ កាន់តែច្រើនឡើង
ទៅទៀត ។

មួយវិញទៀត កាលបើមានដំណើរចេញពីផ្ទះទៅ ច្រើនតែនាំ
ឲ្យយឺតយូរខូចពេលវេលា ពីព្រោះគេនឹងលាបប្រេងសិតសក់ឲ្យរៀបរយ
ជាមុនសិនទើបទៅបាន ។ សក់នេះមានតែនាំឲ្យបង់ខាតប្រាក់កាស និង
នាំឲ្យកើតកង្វល់ដោយការស្អិតស្អាងបំរុងជានិច្ច ទើបខ្ញុំបាទយល់ថា សក់
នេះមានតែនាំឲ្យកើតទុក្ខព្រួយតែម្យ៉ាង ៗ តែដែលពោលមកនេះហាក់ដូច
ជាសំដីទទឹងទាស់នឹងសេចក្តីនិយមរបស់មនុស្សលោកខ្លាំងណាស់ ព្រោះ
មនុស្សលោកស្រឡាញ់សក់ល្អគ្រប់គ្នា មិនខ្លាចនឿយហត់ក្នុងការស្អិត
ស្អាងសក់នោះឡើយ បើបែរជាសក់វិបត្តិទៅឬគ្រាន់តែស្តើងបន្តិចទៅ រុះ
ខ្លះទៅ ឬមានពណ៌ខុសប្រក្រតីទៅ ឆ្លុះកញ្ចក់មើលវេលាណាក៏ដកដង្ហើម
ធំតែម្តងដោយនឹកស្តាយសក់របស់ខ្លួន ទើបឃើញថាមនុស្សលោកមិន
ខ្លាចនឿយហត់ឬបង់ខាតក្នុងការស្អិតស្អាងសក់ទេ តែងមានទុក្ខព្រួយចិត្ត

នឹងសក់ដែលវិបត្តិប្រែប្រួលទៅនោះច្រើនជាង ដល់ទៅទំបណ្ដុះសក់ឲ្យផ្លាស់ពីពណ៌ប្រក្រតី ទុកជាបង់ខាតថ្លៃថ្នាំយ៉ាងណាក៏សុខចិត្ត ។

ហេតុដូច្នេះទើបឃើញថា សក់នាំឲ្យកើតទុក្ខរំខានចិត្តទាំងអស់ តែសូមសរុបដោយខ្លីៗថា សក់អស់ទៅក៏មិនល្អ សក់មានក៏បង់សោហ៊ុយ ។

អវត្ត

*

* *

ប្រស្នាជាគំរប់ ៣

សួរថា: ស៊ីស្លានឹងជក់បារី តើគួរតែមយ៉ាងណាមុន ?

សេចក្ដីឆ្លើយ ទី ១

ការស៊ីស្លានឹងជក់បារី តើគួរតែមគួរវៀរយ៉ាងណាមុន រឿងនេះលំបាកនឹងវិនិច្ឆ័យណាស់ ព្រោះស្លានឹងបារីនេះជាទីនិយមរាប់អានរបស់ជនជាតិខ្មែរទូទៅ វេលាមានបុណ្យទានអ្វីគេតែងប្រើស្លាបារីជាគ្រឿងមុខ តែមានអ្នកខ្លះចូលចិត្តបារីជាងស៊ីស្លា ខ្លះចូលចិត្តស្លាជាងបារី ជា នានាចិត្ត ដូច្នេះ ។ ក្នុងសម័យសព្វថ្ងៃនេះ ជនទាំងប្រុសទាំងស្រីនិយមជក់បារីថ្នាំបារាំងច្រើនជាងស៊ីស្លា ។ កាលពីដើមនោះប្រុសៗច្រើនជក់បារី ស្រីៗច្រើនស៊ីស្លា

តែកាលបើពិនិត្យពិចារណាដោយសព្វគ្រប់ទៅទើបឃើញថា ការជក់បារីល្អជាងស៊ីស្លា ព្រោះការស៊ីស្លានាំឲ្យកើតទោសច្រើនប្រការ គឺប្រការ១ លំបាកក្រខ្លួនប្រាណទាំងសំពត់អាវឲ្យបានស្អាត ដ្បិតវេលាដែលមានស្លានៅក្នុងមាត់ហើយ កាលនឹងស្ដោះទឹកមាត់នោះរមែងហូរទឹកមាត់ទៅប្រឡាក់សំពត់អាវខ្លួនប្រាណ បើប្អូនជាមិនប្រយ័ត្ន ប្រការ១ទៀត វេលាធ្វើការនៅប៊ុយរ៉ូ បើអ្នកស៊ីស្លាបេះក្រប្ចុកពារកិរិយា ក៏គ្រាន់បើបន្តិច ប្រយ័ត្នមិនឲ្យប្រឡាក់ទឹកខ្ទែងធ្វើការ បើជាអ្នកមិនមានកិរិយាល្អផង ក៏មុខជាទាំងអង្គុយស្ដោះ ឃេរស្ដោះផ្ដេសផ្ដាសគ្រហមព្រាលដោយទឹកមាត់ មុខគួរខ្ពើម ៗ មនុស្សបែបនេះ លុះតែមានកន្ទោរតាំងរៀងកាយសងខាង បំពេញមថ្នល់គ្រប់ៗ ផ្លូវចេញផុតខ្ទិល ៗ បើជាអ្នកកជការទៅធ្វើការក្នុងប៊ុយរ៉ូ ហើយបៀមស្លានៅក្នុងមាត់ផង តែក្លួបខ្លួនមុខជាធ្លាក់កាកស្លាឬទឹកមាត់ស្លាគ្រហមប្រឡាក់ក្រដាសសរសេរ ឬទឹកខ្ទែងធ្វើការមិនខាន នេះក៏សឲ្យឃើញទោសនៃការស៊ីស្លា ១ យ៉ាង ៗ បើជក់តែបារីមិនស៊ីស្លាទេ ទុកជាគោះកំញមបារីធ្លាក់ជ្រុះទៅលើ ក្ដោះផ្ទុំចេញក៏ស្អាតបានដោយងាយ បើបែរជាប្រឡាក់ទឹកមាត់ស្លាវិញ មិនងាយនឹងជុសលាងឲ្យស្អាតបានដោយងាយទេឡើយ ហេតុដូច្នោះ ទើបខ្ញុំបានយល់ថាគួរតែមស្លា ជក់បារីវិញល្អជាង ៗ

ស្លា-បារី

*

* *

ប្រស្នាជាគំរប់ ៤

សួរថា: មានពុកមាត់គួរកោរចេញ ឬគួរទុកឲ្យវែងទៅល្អជាង?

សេចក្ដីឆ្លើយទី ១

ការទុកពុកមាត់នឹងកោរចេញ តើខាងណាស្រួលជាង? រឿងនេះខ្ញុំបាទនឹងសូមថ្លែងតាមយោបល់របស់ខ្លួនដូចមានតទៅនេះ គឺពីដើមប្រទេសក្រិកនឹងបារាំង មនុស្សចូលចិត្តទុកពុកមាត់ពុកចង្កា ប្រទេសក្រៅពីនេះ កោរឬកាត់ទុកតែខ្លីៗ ក៏មាន តាមសេចក្ដីនិយមចូលចិត្តរបស់គេ បើគេមានទុក្ខព្រួយដល់ទាល់ច្រកក៏កាត់ឬកោរចេញក៏មាន ដូចរឿងបួចបួ ទាល់ច្រកជាដើម ។ នៅប្រទេសខ្មែរកាលពីសម័យបុរាណ ទុកពុកមាត់វែងៗ ហើយពត់ជាស្នែងក្របីក៏មាន កោរឬកាត់ខ្លីក៏មាន តែមិនបានទុកពុកមាត់ពុកចង្កាវែងស្កុកស្កាញ ដូចឫសីតាបសដែលមានរឿងដំណាលថា តាបសឥសីទុកពុកចង្កាវែងស្កុញស្កាញអង្គុយឈាន ពួកសត្វចាបចូលទៅធ្វើសំបុកនៅដូច្នោះទេ ។ ឯយោបល់ខ្ញុំបាទយល់ថា កោរចេញក៏មិនល្អ ទុកវែងពេកក៏មិនល្អដែរ បើមានពុកមាត់គួរកាត់តាក់តែងឲ្យស្អាតរៀបរយ ទើបជាការសមគួរ មិនគួរកោររលីងទេ ព្រោះអ្នកដែលមានពុកមាត់នោះ បើគាត់តែងឲ្យត្រូវបែបផែន ក៏មើលឃើញស្រស់បស់សមជាកូនប្រុសមែន បើធ្វើជាទាហានផង កាន់តែមើល

ឃើញសំប៉ើមឡើងទៀត ។ ឯអ្នកដែលគោរពុកមាត់រលីងរលោងនោះ គន់មើលមុខមាត់មិនស្រស់ឡើយ ដូចមុខស្រី រៀវរលីងតែអ្នកដែលឥតពុកមាត់មកពីកំណើតក៏ល្ហើយទៅចុះ ព្រោះសង្ខាររាងកាយរបស់គេភាក់តែងមកដូច្នោះឯង មិនគួរទៅត្មះតិះដៀលគេទេ តែឯអ្នកដែលមានពុកមាត់ពុកចង្កាហើយ ទឹងទុកឲ្យវែងស្កុយមិនកាល់កាត់ឲ្យមានរបៀបរៀបរយក៏មិនល្អមើលដែរ ដ្បិតចួនកាលវេលាដែលបរិភោគអាហារ ទឹងប្រឡាក់សម្លបាយម្ទេសសម្ល ឬគ្រាប់បាយជាប់ពុកមាត់ពុកចង្កាក៏មិនល្អមើលដែរ ។ មួយវិញទៀត វេលាផឹកថ្នាំដល់ថ្នាំផឹកនេះជិតដល់គល់ទឹងពេលទៅនេះពុកមាត់ឈ្លៀមខ្លួនមិនបាន ។ ហេតុដូច្នោះទើបខ្ញុំបាទយល់ថា ពុកមាត់គ្រាន់តែទុកឲ្យល្អមើលសមភេទជាប្រុសប៉ុណ្ណោះ តែកុំទុកឲ្យវែងស្រកាកដូចឥសីនៅព្រៃហិមពាន្តនោះទេ ។

អ្នកកណ្ដាល

រឿងបុរសបាញ់ទុង

មាននិទានមួយដំណាលថា នៅស្រុកមួយនោះ មានបុរស ២នាក់ ម្នាក់ឈ្មោះចៅសោកែ ម្នាក់ទៀតឈ្មោះចៅតាលោ ។ តែងទៅរករៀនមន្តអាគមសិល្បសាស្ត្រចេះហើយ ទើបចៅតាលោរកឧបាយកលចំហូរទ្រព្យរបស់គេមកជារបស់ខ្លួន ។

មានកាលសម័យថ្ងៃ ១ នោះ ចៅសោកែបានចេញទៅបាញ់ទុងបានមួយ ។ ឯចៅតាលោគិតថា សោកែគាត់នឹងជូនសាច់ទុងអញស៊ីផងទេឬអេះ បើគាត់មិនជូនសាច់ទុងអញស៊ីទេ អញនឹងរករឿងគាត់ឲ្យកើតជាក្តីឡើងក្នុងម្តងនេះឯង ។ ឯចៅសោកែស្ងោរអាំងសាច់ទុងរួចស្រេចបរិភោគទៅ ពុំបានជូនចំណែកទៅចៅតាលោះឡើយ ។ ទើបចៅតា-លោទៅប្តឹងចៅក្រមឲ្យកោះចៅសោកែយកទៅជំនុំជំរះ ឯពាក្យដែលចៅតាលោប្តឹងចៅក្រមនោះថា កាលអាពុកខ្ញុំប្របាទឈឺថ្កាត់នោះគាត់ផ្តាំនឹងខ្ញុំប្របាទថា បើគាត់ស្លាប់ទៅនឹងទៅយកកំណើតជាសត្វទុង ដោយដូរចំបូរមេបារៀង ៗ មក សឹងស្លាប់ទៅកើតជាទុងទាំងអស់ បើមានអ្នកណាមួយទៅបាញ់ទុង ឲ្យប្តឹងចៅក្រមឲ្យចាប់យកទៅជំនុំពិចារណាលក់ពិន័យ តាមដោយនូវច្បាប់សម្លាប់គេ ។ ឥឡូវនេះចៅសោកែសម្លាប់អាពុកខ្ញុំស៊ី ហេតុនេះ សូមប្របាទម្ចាស់កាត់សេចក្តីឲ្យពានខ្ញុំប្របាទហោង ។

ឯចៅសោកៃឆ្លើយដោះសាថា អាពុកម្តាយខ្ញុំស្រដីប្រាប់ខ្ញុំរៀង ៗ មកថា មេបាដ៏ដូនជីតាអាពុកម្តាយ អម្បាលដែលស្លាប់ទៅសឹងទៅយកកំណើតជាត្រី ហើយផ្តាំថា ក្រែងមានសរពើសត្វអ្វីទៅសម្លាប់អស់សត្វត្រីស៊ីហើយ ឲ្យខ្ញុំប្រយាទបាញ់សម្លាប់សត្វអស់នោះស៊ីវិញហោង ៗ បើសត្វអស់នោះ មានកូនចៅផៅពង្សនៅជាមនុស្សឲ្យប្តឹងចៅក្រមឲ្យចាប់យកមកជំនុំជំរះ លក់ពិន័យកូនចៅផៅពង្សអស់នោះហោង ៗ ឥឡូវនេះ ហ្វូងទុងនាំគ្នាទៅបួនចាប់ត្រីជាដ៏ដូនជីតាអាពុកម្តាយខ្ញុំប្រយាទស៊ី ទើបខ្ញុំប្រយាទបាញ់ទុងអស់នោះ ៗ ឥឡូវ ចៅពាណោថាទុងនោះជាអាពុកគេដូច្នេះ សូមអស់លោកជាចៅក្រមជំនុំពិចារណាសេចក្តីនេះឲ្យមានខ្ញុំប្រយាទចុះ ៗ

ឯអស់ចៅក្រមជំនុំពិចារណាសេចក្តីនេះមិនដាច់ស្រេចទើបនាំចៅទាំងពីរឡើងទៅក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រ តាមដំណើរសេចក្តីនោះសព្វគ្រប់ប្រការ ៗ ឯចៅពាណោឃើញថា ក្តីរបស់ខ្លួនចាញ់ប្រៀបក្តីរបស់ចៅសោកៃ ទើបនិយាយដោះសាខ្លួនថា ចៅសោកៃថាពុំបានបាញ់ទុងនៅអាយឡើយ បាញ់ទុងមកពីនាយទេ ទូលបង្គំជាខ្ញុំបានប្រកាន់ត្រង់នេះឯង ៗ

សម្តេចព្រះមហាក្សត្រមានព្រះបន្ទូលដណ្តឹងសួរចៅពាលោថា ឯខ្លួនអាពុកចៅនៅអាយស៊ីអ្វី ស៊ីក្តាមខ្យងឬស៊ីត្រី ។ ចៅពាលោក្រាបទូលថាស៊ីត្រី ។ ទើបព្រះអង្គមានព្រះបន្ទូលថា បើដូច្នោះ អាពុកចៅតែងចាប់ត្រីជាអាពុកចៅសោកែស៊ី សមដូចពាក្យចៅសោកែមែន ។ ទ្រង់បង្គាប់ឲ្យលក់ចៅពាលោជាខ្ញុំចៅសោកែ ។ ចៅទាំងពីរក៏សុខចិត្តក្រាបទូលលាត្រឡប់ទៅកាន់លំនៅអាត្មាវិញហោង ។

ចប់រឿងបុរសបាញ់ទុកតែប៉ុណ្ណេះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៥-១៦

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៥
គ.ស. ១៩៤២

បញ្ជីរឿង

ទំព័រ

១ – វិទ្យុធម្មទេសនា កណ្ឌទី ៧ ព្រះគ្រូមុនីសុមេធ (កេត-ប៊ិតស៊ើក) ក្រុមជំនុំព្រះត្រៃបិដកសំដែង ១

២ – បិសាចស្នេហា យ. និពន្ធមន្ត្រី អ្នកតែងសេចក្តីនៅព្រះរាជបណ្ណាល័យជាអ្នកតែង ៨

៣ – កុម្ភជាតក លោកគ្រូអាចារ្យ ឈឹម-ស៊ុម គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ប្រែនឹងរៀបរៀង ពីគម្ពីរខុទ្ទកនិកាយ ព្រមទាំងអដ្ឋកថា ២៦

៤ – ពិធីទ្វាទសមាស តាមទំនៀមព្រាហ្មណ៍ នៅនគរពារាណសី (ប្រទេសឥណ្ឌា) តមកនឹងចប់ ៣៥

៥ – លោកនេយ្យ ពាក្យពេចន៍ របស់លោកអ្នកឧកញ៉ាវង្សាសពេជ្រ (នង) (តមក). . ៤០

៦ – ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់; ទី ២- ប្រវត្តិនាងវិសាខាមិគារមាតា ៤៩

៧ – រឿងព្រេងខ្មែរ រឿងគមាត្យក្សាញ្ញោព្រះរាជទ្រព្យ ៥៩

TABLE DES MATIÈRES

Pages

1. Vidyudhammadesanā (Conférence faite à la Radio Phnom-Penh) par le vénérable Préas Kroū Munisuméth Thitasilo, membre de la Commission du Tripitaka................ 1

2. Bisach-Snéhā, roman par Kh. Nibandha-Mantri (1ère partie).. 8

3. Kumbhajātaka, traduit du pāli par le Vénérable Chhim-Soum professeur de l'Ecole supérieure de pāli (1ère partie)....... 26

4. Cérémonies brahmaniques des douze mois à Bénarès (Inde) par l'Okhnha Tep Pitou Krasem (suite et fin)............ 35

5. Lokaneyya, poème par feu l'Oknhā Vongsāsarpejña (Nong) (suite).. 40

6. La vie des disciples du Bouddha, II. La vie du Visākhā-Migāramātā.. 49

7. Conte populaire cambodgien inédit: " Le gardien de l'orange du Malabar d'un roi"........................ 59

វិទ្យុធម្មទេសនា កណ្ឌទី ៧

អំពីទោសនៃសេចក្ដីល្ងង់

ព្រះគ្រូមុនីសុមេធ (ប៉ិតសីលោ) ក្រុមជំនុំព្រះត្រៃបិដក សំដែង

នៅថ្ងៃអង្គារ ១៤ រោចខែចេត្រ ឆ្នាំមមីចត្វាស័ក ព. ស. ២៤៨៥

(ត្រូវនឹង ១៤ អាវ្រិល ឆ្នាំ ១៩៤២)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

អវិជ្ជា បរមំ មលំ

សេចក្ដីល្ងង់ខ្លៅ ជាមន្ទិលដ៏ក្រៃលែង ។

អធិប្បាយថា ធម្មតាមនុស្សក្នុងលោកទាំងអស់ គ្មានអ្នកណាមួយត្រូវការប្រាថ្នាចង់បានរបស់ដែលជាមន្ទិលស្មោកគ្រោកទេ មានតែចំប្រាថ្នាស្វែងរករបស់ដែលបរិសុទ្ធស្អាតប្រពៃមកកំចាត់បង់របស់ដែលជាមន្ទិលប្រែះស្មឹមនោះជាដរាប ព្រោះថារបស់អាក្រក់ទាំងនោះសុទ្ធតែនាំបណ្ដាលឲ្យកើតទៅជាទោសទុក្ខ ដូចយ៉ាងមន្ទិលញើសក្អែលដែលជក់ជាប់នឹងសំពត់អាវ ឬរបស់ប្រើប្រាស់ផ្សេងៗ គេមិនត្រូវទុកផ្ដាប់ឲ្យដុះស្មឹមយូរពេកទេ តែទុកយូរទៅនឹងធ្វើគ្រឿងប្រដាប់ទាំងនោះឲ្យជាំជាមពុកផុយរលួយធាប់ ។

/ កងកាយរបស់មនុស្សក៏គេត្រូវតែសំអាតជាដរាប គេមិនត្រូវបណ្ដោយឲ្យញើសក្អែលមកកកកុញរួបរឹតច្រើនពេកទេ ព្រោះខ្លាចរបស់ក្រខ្វក់ទាំង

នោះនាំបណ្ដាលឲ្យទៅជាទោសគឺកើតរោគព្យាធិផ្សេងៗ មានរោគកមរោស់កើតអំពីស្បែកជាដើម ។

"អវិជ្ជា បរមំ មលំ"

សេចក្ដីល្ងង់ខ្លៅ ជាមន្ទិលដ៏ក្រៃលែង ។ សេចក្ដីមិនចេះមិនដឹង ហៅថាសេចក្ដីល្ងង់ បើមិនចេះអក្សរនឹងលេខ ហៅថាល្ងង់ក្នុងអក្សរនឹងលេខ បើមិនចេះធ្វើការអ្វីហៅថាល្ងង់ក្នុងការងារនោះ បើមិនចេះគិតហៅថាល្ងង់ក្នុងការគិត ។ អ្នកណាមានសេចក្ដីល្ងង់ អ្នកនោះហៅថាឥតចំណេះវិជ្ជា អ្នកណាឥតមានចំណេះវិជ្ជា អ្នកនោះហៅថាមនុស្សល្ងង់ៗ បើនឹងធ្វើការអ្វី ការនោះមិនកើត បើទុកជាកើតក៏មិនល្អ បើនឹងនិយាយពាក្យណាពាក្យនោះមិនប្រាកដ បើនឹងគិតហេតុអ្វីហេតុនោះមិនចេញមកសំដែងឲ្យប្រាកដជាខុសឬត្រូវបាន ។

មនុស្សល្ងង់មានឧបមាដូចមនុស្សខ្វាក់ ធម្មតាមនុស្សខ្វាក់កម្រនឹងដើរតាមផ្លូវឲ្យត្រង់នឹងរហ័សបាន នោះមានសេចក្ដីញញើតញញើមរញ្ញាកស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម៉្លោះហើយសេចក្ដីមិនប្រាកដក្នុងចិត្តនោះ ក៏ធ្វើដំណើរមិនឲ្យប្រាកដ មិនដឹងជាទៅមុខឬថយក្រោយ តែងទើសទាស់ទទើសទទាសមានទំនងដូចមនុស្សល្ងង់ខ្លៅ បើនឹងធ្វើ និយាយ ឬគិត ក៏ឥតមានប្រាកដក្នុងចិត្ត សេចក្ដីមិនប្រាកដនេះឯង មិនអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសម្រេចទៅបានឡើយ ។

មានពុទ្ធភាសិតមួយក្នុងសំដែងថា មោហៈគឺសេចក្តីល្ងង់ខ្លៅ តែមានក្នុងសន្តានអ្នកឯណាហើយ មិនអាចធ្វើអ្នកនោះឲ្យស្គាល់សេចក្តីអាក្រក់ល្អ និងខុសត្រូវបានឡើយ ។

មានសុភាសិតពុកណាក្នុងហិតោបទេស ជាភាសាសំស្ក្រឹតសំដែងទុកថា "មានកូនដែលគ្មានចំណេះវិជ្ជា ជាមនុស្សខ្លៅ មិនប្រព្រឹត្តតាមគន្លងធម៌ មិនមានប្រយោជន៍អ្វីដោយកូនដូច្នោះ ឧបមាដូចមនុស្សភ្នែកខ្វាក់ មិនមានប្រយោជន៍អ្វីដោយភ្នែកខ្វាក់នោះ មានតែនាំឲ្យអផ្សុកព្រួយចិត្តតែម្យ៉ាង" ។

កូនមាន ៣ យ៉ាង គឺកូនដែលមិនទាន់កើត ១ កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១ កូនដែលកើតហើយនៅរស់តែល្ងង់ខ្លៅ ១ . បណ្តាកូនទាំង ៣ យ៉ាងនេះ គួរយកកូន២ខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែ ១ គ្រាហើយបាត់ទៅវិញ ឯកូនមួយទី ៣ នោះមិនគួរយកទេ ព្រោះកូននោះនឹងនាំបណ្តាលឲ្យបានសេចក្តីទុក្ខព្រួយជានិច្ចជាកាល ។

អ្នកណាមួយ ទោះបីមានរូបឆោមលោមពណ៌ល្អ កំពុងតាំងនៅក្នុងតរុណវ័យ គឺនៅក្មេងកំលោះក្រមុំនៅឡើយ កើតនៅក្នុងត្រកូលខ្ពង់ខ្ពស់ក្តី តែប្រាសចាកចំណេះវិជ្ជា គឺឥតមានចេះដឹងអ្វីឡើយ អ្នកនោះឯងជាមនុស្សឥតពសី ឥតមានដំឡៃដូចគ្នានឹងផ្កាចារ មានពណ៌ល្អស្រស់ តែឥតមានក្លិនក្រអូបបន្តិចឡើយ ។

មានសុភាសិតមួយបទទៀតថា "មនុស្សនិងសត្វមានអាការបរិភោគអាហារ រួមសេមេថុន និងដេកដូចគ្នា តែមនុស្សមានចំណេះវិជ្ជា សំរាប់ធ្វើឲ្យប្លែកអំពីសត្វ មនុស្សណាឥតមានចំណេះវិជ្ជា មនុស្សនោះស្មើគ្នានិងសត្វដូច្នេះ" ។

ដែលនាំរឿងសុភាសិតខ្លះមកអធិប្បាយក្នុងទីនេះដើម្បីឲ្យឃើញថា សេចក្តីល្ងង់នេះតែអ្នកឯណាមិនខំស្វាហ៍ជំរះគោសរូសចេញទេ នឹងប្រែត្រឡប់ទៅជាទោស ធ្វើអ្នកនោះឲ្យបានដល់នូវសេចក្តីទន់ទាបថយថោក តាំងពីក្នុងបច្ចុប្បន្ននេះដរាបដល់ទៅលោកខាងមុខដោយពិត ឯទោសសេចក្តីល្ងង់នឹងឃើញប្រាកដក្នុងបច្ចុប្បន្ននេះដូច្នេះ:

១) បើល្ងង់ក្នុងវិធីអក្សរ គឺមិនចេះសរសេរ មិនចេះមើល នឹងនាំឲ្យខាតប្រយោជន៍ដូច្នេះ:

ក. មិនអាចមើលសាស្ត្រា ឬសៀវភៅដែលមានច្បាប់ប្រដៅប្រយោជន៍ល្អក្នុងព្រះពុទ្ធសាសនា ឬក្រៅព្រះពុទ្ធសាសនាជាគ្រឿងនាំឲ្យកើតគំនិតប្រាជ្ញា ។

ខ. មិនអាចសរសេរសំបុត្រដោយខ្លួនឯង ឲ្យដំណឹងដល់ញាតិមិត្តជិតឆ្ងាយដែលខ្លួនត្រូវការឲ្យដំណឹង ។

គ. សេចក្តីកំបាំងឬការក្រែដែលញាតិមិត្តធ្វើសំបុត្រឲ្យដំណឹងមកចំពោះខ្លួននោះ នឹងមិនសំរេចប្រយោជន៍ ។

២) អ្នកដែលឥតមានចំណេះវិជ្ជាអ្វី បើនៅអាស្រ័យជ្រកកោនក្នុងសំណាក់អ្នកធំ បើគោរពប្រណិប័តន៍ឲ្យអ្នកធំលោកស្រឡាញ់អាណិតមេត្តាដូចម្តេចក្តី អ្នកធំនោះក៏មិនអាចនឹងលើកដំកើងអ្នកល្ងង់ខ្លៅនោះឲ្យមានកេរ្តិ៍ឈ្មោះយសសក្តិបានឡើយ ព្រោះលោកយល់ថាខ្លួនល្ងង់ខ្លៅ បើគ្រាន់បើណាស់ក៏បានត្រឹមតែសេចក្តីសុខ ព្រោះអាស្រ័យនឹងឥស្សរភាពរបស់អ្នកធំនោះប៉ុណ្ណោះ តែក៏គង់មិនរួចផុតអំពីដំណែងដែលជាអ្នកបំរើគេ ។

៣) មនុស្សល្ងង់ ទោះបើមានយសសក្តិ ដោយអំណាចព្រេងសំណាងជួយឧបត្ថម្ភ បើថ្កុំថ្កើងគ្រាន់បើបានតែក្នុងទីឯទៀត តែដល់ក្នុងទីប្រជុំ ក៏នឹងត្រឡប់ទៅជាមនុស្សឥតកសីឥតដំឡៃទៅវិញ ព្រោះមិនចេះរៀបចំធ្វើការថ្កុកថ្កាឲ្យសមគួរដល់ឋានៈរបស់ខ្លួន ឬនឹងហានិយាយស្តីឡើងក៏មិនត្រូវទំនងធម៌នឹងទំនងច្បាប់ ជាហេតុឲ្យអ្នកឯទៀតគេពេបជ្រាយ ដោយអាការមើលងាយ ម្ល៉ោះហើយគេពុំជឿស្តាប់ ពុំកោតខ្លាច ដោយគេដឹងថាខ្លួនជាមនុស្សល្ងង់ ។

៤) មនុស្សល្ងង់ជាមនុស្សខ្សត់មិត្តសំឡាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងគេយកទៅឲ្យជួយធ្វើអ្វី ឬជួយពិគ្រោះប្រឹក្សាការអ្វីក៏មិនកើតទាំងអស់ ។

បើទុកជាមានមិត្តសំឡាញ់ ក៏ច្រើនតែបានមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ។

៥) មនុស្សល្ងង់ បើជារកស៊ីតាមផ្សារ ក៏មិនអាចនឹងធ្វើការឲ្យបានចំរើន ដូចអ្នកដែលមានប្រាជ្ញាចេះដឹងទេ ព្រោះខ្លួនមិនស្គាល់ទំនងនៃរបររកស៊ី មានមិនស្គាល់កាលដែលត្រូវធ្វើ នឹងមិនត្រូវធ្វើជាដើម ហើយទៅធ្វើឲ្យខុសទំនងខុសកាល ។ កាលបើដូច្នេះហើយ ធ្វើម្ដេចរបររកស៊ីនោះនឹងចំរើនឡើងបាន . បើទុកជាធ្វើតាមទៅលើត្រូវទំនងថ្ងៃកាលដែលគួរធ្វើ ក៏មិនរួចអំពីសេចក្ដីលំបាក ។

៦) មនុស្សល្ងង់ មិនដែលបានសេចក្ដីសរសើរ អំពីសំណាក់លោកអ្នកប្រាជ្ញណាមួយដល់ម្ដងសោះ បើបានសេចក្ដីសរសើរខ្លះតែពីសំណាក់មនុស្សដែលល្ងង់ជាងខ្លួន ។

ទោសនៃសេចក្ដីល្ងង់ដែលនាំមកអធិប្បាយក្នុងទីនេះ ជាសេចក្ដីសង្ខេបខ្លីដែលនៅមានតទៅទៀតជាសេចក្ដីវែងឆ្ងាយទូលាយណាស់ ។ ទោសនៃសេចក្ដីល្ងង់នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះទេ ទំងមានទៅក្នុងលោកឯមុខទៀតជាអនេក ។

ហេតុនេះគួរយុវជនទាំងឡាយ គប្បីញ៉ាំងវិជ្ជានឹងទ្រព្យសម្បត្តិឲ្យកើតមានឡើង ឲ្យហាក់ដូចជាមិនចេះចាស់មិនចេះស្លាប់ ទំងគប្បីប្រ-

ញាប់ប្រព្រឹត្តសេចក្ដីល្អ ឲ្យដូចជាមច្ចុរាជចាប់សក់ក្បាលទុកស្រេចហើយ ៗ

វិជ្ជារមែងឲ្យដឹងបទបាទមាត្រា បទបាទមាត្រារមែង ឲ្យកើតគុណ គុណរមែងឲ្យកើតទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិរមែងឲ្យកើតធម៌ ធម៌ឲ្យកើតសុខ ដែលមនុស្សគ្រប់រូបត្រូវការប្រាថ្នាចង់បាន ៗ

សំដែងអំពីទោសនៃសេចក្ដីល្ងង់ សូមបញ្ចប់សេចក្ដីដោយសង្ខេបតែប៉ុណ្ណេះ ៗ ឯវំ ៗ

ចប់វិទ្យុធម្មទេសនាកណ្ឌទី ៣ តែប៉ុណ្ណេះ ៗ

ប៉ិសាចរះស្ទបារ

ឃ. និពន្ធមន្ត្រី ញ. ប៉ែម នៅព្រះរាជបណ្ណាល័យ កម្ពុជា

ជាអ្នកតែង

ម៉ឺង! ម៉ឺង! ម៉ឺង! ម៉ឺង! ម៉ឺង! ស្គរនាឡិកាធំនៅបន្ទប់រៀនមួយក្នុងវិទ្យាល័យ (លីសេ) ស៊ីសុវត្ថិ ម្ជុលខ្លីចង្អុលចំលេខ ៤ ម្ជុលវែងចង្អុលចំលេខ ១២ ប្រាប់ឲ្យដឹងថាដល់ម៉ោង ៤ ហើយ ជាពេលដែលត្រូវឈប់រៀនក្នុងវេលាល្ងាច ។ រ៉ឹង! រ៉ឹង! ស្គរគណ្ឌ៍ក៏លាន់ឮឡើងបន្ទាប់ពីស្គរនាឡិកា បណ្ដាគ្រូនឹងសិស្សប្រុស - ស្រីក៏នាំគ្នាចេញពីវិទ្យាល័យដើរសំដៅទៅគេហដ្ឋានរៀងខ្លួន ៗ ក្នុងចំណោមសិស្សានុសិស្សអស់នោះ មានកុមារីស្ត្រីក្រមុំពីរនាក់ រូបឆោមស្រស់បស់ ជាទីគួរពិតពិលរមិលមើលនៃភ្នែកអ្នកផង នាងទាំងពីរកាន់សៀវភៅនៅដៃដើរចេញពីទ្វារមុខទន្ទឹមគ្នាតាមក្រោយគូនសិស្សប្រុសស្រីឯទៀត ៗ ដល់ផ្លូវប៉ូល្យូខ្លូដាដឺឡាក្រែនៅមុខសាលា ហើយក៏ដើរសំដៅទៅទិសខាងត្បូងតាមចិញ្ចើមថ្នល់នោះទៅ ៗ លុះនាងទាំងពីរដើររៀង ១ មកដល់ផ្លូវមួយត្រង់ទៅខាងលិចឈ្មោះផ្លូវឧកញ៉ាម៉ែនក៏នាំបងប្អូនដើរសំដៅទៅខាងលិចដល់ទៅផ្លូវបត់ ស្រាប់តែមានបក្រយានយន្ត (ម៉ូតូស៊ីក្លូ) ១ បើកមកពីខាងត្បូងតាមផ្លូវនោះសំដៅទៅទិសខាងជើង ហើយមកដល់ជិតខ្លួននាងទាំងពីរ ត្រង់ផ្លូវបត់កាច់ជ្រុងនោះ នាងទាំងពីរក៏ភិតភ័យស្រឡាំងកាំងដើរទៅមុខបន្តិចថយមក

ក្រោយបន្តិច ឯបុរសកំឡោះដែលជិះចក្រយានដោយខ្លាចប៉ះស្ត្រីទាំងពីរ ឬដោយគិតយ៉ាងណាមិនប្រាកដ, ស្រាប់តែកាច់ចង្កូតឡើងចិញ្ចើមថ្នល់ ជល់ទីងសសរខ្សែលួសព្រួស្លូវគ្រាំង! មនុស្សជិះខ្លួតធ្លាក់ទៅដេកស្រប៉ាប លើចិញ្ចើមថ្នល់បែកក្បាលហូរឈាមមិនដាច់សន្ធប់បាត់ស្មារតីទៅ ។ ឯកុមារីទាំងពីរនាក់ក៏ស្រែកយ៉ូយវ៉ូយរ៉ាយ! ទាល់តែភ្ញាក់សំឡេង! លុះនាងបាត់ភិតភ័យស្រឡាំងកាំងហើយ ក៏ស្ទុះចូលទៅពិនិត្យអ្នករងគ្រោះមួយរំពេច, ឃើញមានឈាមហូរស្រោចជង់ខ្លួន, មិនកម្រើកដៃជើង, តែខ្លួននៅក្ដៅឧណ្ហៗ ដឹងច្បាស់ថា បុរសនោះគ្រាន់តែសន្ធប់មិនស្លាប់ទេ ។

ចួនជាវេលានោះស្ងាត់មនុស្សមិនសូវមានអ្នកដើរត្រេចរង្គាត់ទៅមកច្រើនដូចសព្វដង, មេឃងងឹត មានភ្លៀងស្រិចៗបន្តិចផង ទើបនាងសារីជាបងហុចសៀវភៅឲ្យទៅនាងសារុនជាប្អូនកាន់ ហើយក្រឡេកមើលនាយអាយមិនឃើញមានមនុស្សដទៃចូលមកជិតខាងក្បែរទីនោះសោះ នាងក៏ចាប់លើកបុរសកំលោះឲ្យអង្គុយឡើងតែមិនសម្រេច! ទើបនាងប្រាប់ទៅនាងសារុនថា ប្អូនដាក់សៀវភៅទុកសិនទៅរកហៅស៊ីក្លូមួយមកឆាប់ៗ ។

កាលនាងសារីដេញប្អូនឲ្យទៅរកហៅស៊ីក្លូបាត់ទៅនោះ នាងគន់មើលបុរសកំលោះនោះ តាំងពីចុងសក់រហូតដល់ចុងជើង ពិនិត្យមើលមុខមាត់ស្រស់បស់ ប្រមាណអាយុប្រហែល ២៥ ឆ្នាំ ពាក់ស្បែកជើង

អង់គ្រៀងពីណាឡៅខាត់ថ្នាំយ៉ាងរលោង ខោបាក់ង កាវ៉េតក ចងក្រវ៉ាត់ ពាក់មួកសំបុក តាមដែលនាងពិនិត្យមើលរូបរាងសាច់ឈាមសព្វគ្រប់ទៅ សមជាអ្នកមានវង្សត្រកូល ។ នាងសារ៉ែតគន់មើលសព្វគ្រប់ទៅក៏កើតចិត្តអាណិតអាសូរបុរសកំលោះនោះពន់ពេកដែលមានចិត្តក្លាហានអង់អាចស៊ូប្រថុយជីវិតជួយការពារខ្លួននាងមិនឲ្យដល់នឹងចក្រយានយន្ត ប្រសិនបើគេមិនកាច់ចង្កូតឲ្យឡើងទៅលើចិញ្ចើមថ្នល់ទេ មុខជាដល់ខ្លួននាងប្អូននាងមិនខាន ហើយអាចនាំឲ្យអន្តរាយជីវិតឬបាក់ដៃជើងក៏សឹងជាពុំត្រូវ ។ នាងសារ៉ែតនឹក ៗ ទៅ កាន់តែមានចិត្តអាណិតច្រើនឡើង ៗ ហើយមានចិត្តស្នេហាចូលមកផ្ដែកជាមួយផង ...។

មួយស្របក់នាងសារ៉ុនហៅស៊ីក្លូមកបាន ២ ទើបនាងទាំងពីរពិគ្រោះគ្នាថា យើងត្រូវឲ្យដាក់ស៊ីក្លូទៅមន្ទីរពេទ្យ ឬមួយនាំទៅក្បែឯផ្ទះវិញ ? នៅទីបំផុត នាងបងសម្រេចសេចក្ដីថាផ្ទះពេទ្យនៅឆ្ងាយណាស់ ផ្ទះយើងនៅជិតបង្កើយប្រហែល ១០ សសរខ្សែលួសប៉ុណ្ណោះ មិនអីទេអូន បើអូនខ្លាចលោកឪពុកលោកម្ដាយបន្ទោសទុកការៈឲ្យបងនិយាយដោះសារជំនួសអូន, អូនកុំភ្លេចណា ត្រូវឲ្យអ្នកធាក់ស៊ីក្លូដឹកអ្នកបើកចក្រយានយន្តនេះនាំបណ្ដើរទៅផ្ទះជាមួយនឹងអូន ឯស៊ីក្លូឲ្យគេទុកផ្ញើនឹងអ្នកជិតខាងនេះសិនហើយ ត្រូវអូនកាន់យកសៀវភៅបងទៅផង កុំភ្លេច!

នាងសាវ៉ាហើយក៏ម្នីម្នាឡើងជិះលើស៊ីក្លូមួយដោយប្រាប់អ្នកស៊ីក្លូឲ្យនាំគ្នាជួយលើកអ្នករបួសដាក់លើស៊ីក្លូរបស់នាង ហើយនាងបីត្រកងបុរសនោះទៅលើស៊ីក្លូនុ៎ះឯងដោយនាងឥតរង្កៀសបន្តិចឡើយ ។

ឱ ! លោក-អ្នកទាំងឡាយអើយ! បើសន្មតខ្លួនលោកឬខ្លួនខ្ញុំបាទជាបុរសកំលោះនោះវិញ តើចិត្តគំនិតរបស់លោកឬរបស់ខ្ញុំបាទនឹងមានអាការស្រើបស្រៀវស្នេហាយ៉ាងណាទៅ! បើពងកាយនៅក្នុងរង្វង់ដៃដ៏សស្អាតទន់ក្លន់ ថែមទាំងមានក្លិនទឹកអប់ក្រអូបឈ្ងុយឈ្ងប់សព្វសព៌ាង្គកាយ បើនឹងងើបមើលទៅចំផ្ទៃមុខក៏ល្អប្រផង់ដូចដួងចន្ទ្រានាថ្ងៃពេញបូណ៌មី នាងមានអាយុទើបចូលក្នុងឆ្នាំគំរប់១៨កំពុងពេញវ័យក្រមុំ ដូចបុប្ផាផុះផុតពីការី ដើម្បីទទួលរស្មីព្រះសុរិយា ។ ខ្ញុំបាទយល់ថាចិត្តលោក-អ្នកទាំងឡាយនឹងគំនិតរបស់ខ្ញុំបាទ សឹងមានបំណងត្រូវគ្នាថា ចង់ឲ្យបុរសកំឡោះនោះភ្ញាក់រលឹកដឹងខ្លួនឡើងក្នុងពេលនោះភ្លាមទៅ ដើម្បីនឹងគយគន់មើលអាការកិរិយារបស់បុរសស្ត្រីទាំងគូនោះតើគេនឹងធ្វើមុខមាត់ដូចម្ដេចទៅអេះ?

ចំណែកខាងនាងសាវុនជាប្អូននឹកម្នួម៉ៅតែក្នុងចិត្តថា បងអញនេះចំណាប់ចំណាស់ ពាំនាំយកចំណីស្រស់ទៅបាត់ ទុកក្រៀមក្រោះឲ្យឯង! មិនអីទេ! សាវុននឹងប្ដឹងលោកម្ដាយឲ្យគាប់បងសាវ៉ាឲ្យអស់ពីចិត្ត! ហើយនាងបង្គាប់ឲ្យអ្នកស៊ីក្លូដឹកចក្រយានយន្តទាំបណ្ដើរទៅជាមួយនឹងនាង នៅវេលាដែលនាងសាវ៉ានាំអ្នករបួសជិះស៊ីក្លូទៅបាត់នោះ ។

កាលកន្លងមកបានប្រមាណ ៥ នាទីស៊ីក្លូដែលនាងសារីជិះក៏បានមកដល់គេហដ្ឋានមួយធំចំបង មានសរសេរអក្សរធំៗ ដាក់នៅមុខផ្ទះថា "គេហដ្ឋានបរិបូរសម្បត្តិ" ជាផ្ទះសង់តាមបែបសម័យថ្មី ល្អក្រៃលែងជាងគេហដ្ឋាននានា នៅភូមិបឹងកាំង ឃុំលេខ ១៥ ក្រុងភ្នំពេញ ។ ឯពួកមនុស្សម្នាបរិវារក្នុងផ្ទះនោះក៏ផ្អើលឆោឡោមកហោមរោមមើលខ្សឹបខ្សៀវសួរគ្នា ព្រោះជាហេតុការចំឡែកមិនធ្លាប់មាន ព្រោះចៅហ្វាយក្រមុំរបស់ខ្លួន ទៅនាំយកបុរសកំឡោះមុខមាត់ស្រស់បស់មិនដែលស្គាល់គ្នាសោះថែមទាំងមានបែកក្បាលហូរឈាមផង ។ ក្រោយនោះបន្តិចទើបនាងសារុនបានទៅដល់ទីនោះ ពួកបរិវារបានឃើញមនុស្សអ្នកធាក់ស៊ីក្លូដឹកចក្រយានយន្តនាំបណ្ដើរទៅជាមួយនឹងនាងសារុនទៅដល់ ក៏កាន់តែនឹកឆ្ងល់ច្រើនឡើង តែមិនមាននរណាហ៊ានចេញជាលសួររឿងរ៉ាវនោះឡើយ ។

នាងសារីក៏បង្គាប់មនុស្សក្នុងផ្ទះ ឲ្យជួយលើកបុរសរងគ្រោះទៅដាក់នៅបន្ទប់ទទួលភ្ញៀវ នៅលើគ្រែមួយហើយឲ្យដាំទឹកក្ដៅលាងរបួសដាក់ថ្នាំ តាមវិធីបឋមព្យាបាលរបស់ពេទ្យ នាងលាងឈាមដែលប្រឡាក់ពាសកាយស្អាតហើយ ទើបនាងក្រមុំទាំងពីរយកថ្នាំហិតគ្រវីៗនៅច្រមុះអ្នករបួស ហើយយកភួយគ្របឲ្យកក់ក្ដៅ នាងទាំងពីរកំពុងតែខ្វល់ខ្វាយរកគ្រូពេទ្យព្យាបាលអ្នកជម្ងឺនោះ ស្រាប់តែឮសូរថយន្តមកបត់នៅមុខផ្ទះ នៅ

កង់រថយន្តនោះ គឺលោកឧកញ៉ាបរិបូរសម្បត្តិនិងលោកស្រីជាភរិយារបស់លោកដែលជាមាតាបិតារបស់កុមារីទាំងពីរប្រាណនោះ លោកទាំងពីរឃើញមនុស្សម្នាក់ក្នុងផ្ទះនោះឡោចំខ្សែកខុសធម្មតា លោកក៏ស្រូកទឡើងទៅលើផ្ទះក្ដារ ស្រាប់តែឃើញធីតាទាំងគូរបស់លោកធ្វើបឋមព្យាបាលដល់បុរសកំឡោះនោះយ៉ាងប្រញាប់ប្រញាល់ លោកក៏ទឹកឆ្ងល់ទើបសួរទៅថា៖

"សារី, សារុន, កូនស្រី កើតរឿងអ្វី ក៏ញាប់ដៃ-ជើងម៉្លេះ?

"ប៉ា, ប៉ាះ, ទុះហ្ន៎! – នាងសារីចង្អុលទៅខាងអ្នកជម្ងឺ ។

"អើ! វាកើតហេតុគេធ្វើម្ដេច? – លោកឧកញ៉ាឈ្ងោបសួរកូនក្រមុំរបស់លោក ។

"កើតឧប្បត្តិហេតុនឹងចក្រយានយន្តឈ្មោះអ្វីខ្ញុំមិនដែលស្គាល់គេទេ" ។

"ចុះហេតុអី ក៏មកដេកក្នុងទីនេះ?- លោកឧកញ៉ាជាបិតាកាន់តែសង្ស័យច្រើនឡើង ៗ ទើបនាងសារុនជាប្អូននិយាយសារសព្វជំនួសនាងបងថា៖

"គឺអ្នកបងសារីនិងខ្ញុំ កាលចេញពីវិទ្យាល័យស៊ីសុវត្ថិ នៅពេលដែលឈប់រៀន ក៏នាំគ្នាដើរមកតាមចិញ្ចើមថ្នល់ផ្លូវប៊ូល្វ័រឌូដាដឺឡាក្រេ ដើម្បីត្រឡប់មកផ្ទះវិញ ដើរមកដល់ផ្លូវឧកញ៉ាម៉ែន មកខាងលិចដល់ផ្លូវកាច់ជ្រុង ស្រាប់តែចំនេះ (ចង្អុលទៅអ្នករបួស) ជិះចក្រយានយន្តមកពី

ខាងត្បូងបានឲ្យសព្ទសញ្ញាសុំផ្លូវផ្ទេរ ខ្ញុំទាំងពីរមិនបានឮ រថចក្រយាន-យន្តមកជិតខ្លួនខ្ញុំណាស់ហើយ ទើបឮស្នូរសព្ទសញ្ញារំពងទៀត, ខ្ញុំទាំងពីរក៏ស្ទុះឈរស្រឡាំងកាំង ហើយដើរទៅមុខបន្តិច ថយក្រោយបន្តិច រថនោះក៏ឃើញបត់ទៅឆ្វេងបន្តិច ងាកមកស្តាំបន្តិច ដូចជាលេងស្វាដណ្តើមទី នៅប្រហែល ១ ហត្ថប៉ុណ្ណោះនឹងដល់ខ្ញុំទាំងពីរនាក់ស្លាប់ នាងឈប់ដកដង្ហើមធ្វើទឹកមុខស្ញប់ស្ញែងស្រៀវជាពន្លឹកក្នុងហេតុភេទដែលកើតឡើងនោះ រួចនិយាយតទៅទៀតថា :

"ដោយហេតុអ្នកនេះ គាត់មានមេត្តាចិត្តគិតក្រែងដល់ខ្ញុំទាំងពីរប្តីយ៉ាងណាក៏មិនដឹង ស្រាប់តែរថចក្រយានយន្តឡើងទៅលើចិញ្ចើមថ្នល់ ប៉ះនឹងសសរខ្សែលួសយ៉ាងខ្លាំង ចាល់តែបែកក្បាលសន្ធប់ទៅ ហើយអ្នកបងនឹងខ្ញុំក៏ជួយគ្នាហៅស៊ីក្លូដាក់គាត់មករក្សាព្យាបាលនៅផ្ទះនេះ ព្រោះខ្ញុំនឹងអ្នកបងមានគំនិតគិតយល់ព្រមគ្នាថា ត្រូវតែជួយសង្គ្រោះគាត់ ព្រោះគាត់មានបុណ្យគុណស៊ូប្រថុយលះបង់ជីវិតខ្លួន ដើម្បីឲ្យខ្ញុំទាំងពីរនាក់ផុតពីគ្រោះថ្នាក់អន្តរាយ" ។

ឯលោកស្រីជាមាតាក៏និយាយញែកឡើងក្នុងពេលនោះ ទាំងជាបន្ទោសផង ប្រដៅផងថា "យើ! កូនក្រមុំយើងទាំងគូនេះចំណាប់ណាស់តើ! បានរៀនសូត្រវិជ្ជាកាន់តែខ្ពស់ឡើង កាន់តែស៊ីវិល្យខ្លាំងណាស់ឡើង, ចេះសេពគប់កប់រកប្រុសឈ្មោលទាំងមិនដែលស្គាល់មុខគ្នាផងផង ពេល

ទំនៀមទម្លាប់ច្បាប់ស្រីអស់រលីងរលង! ធម្មតាកុមារីស្រីគ្រប់ដែលមានពូជអំបូរល្អ នៅតែងរក្សាកិរិយាឫកពាតាមសណ្ដាប់ច្បាប់ស្រី, ទុកជាដើរដេក អង្គុយ ឈរ ឬ និយាយស្ដីអ្វី គោងឲ្យសមរម្យតាមបែបភាពស្រី មិនដែលមានស្រីគ្រប់ណា នាំប្រុសឈ្មោលមកឡើងផ្ទះសំបែងដូច្នេះទេ នេះ នែ! កូនស្រីមាសម្ដាយ! ផ្ទះពេទ្យពដការមាននៅក្នុងក្រុងនេះម្ដេចក៏មិននាំទៅពេទ្យ? ។

លោកស្រីជាមាតានិយាយមិនទាន់ចប់ លោកឧកញ៉ាជាបិតាក៏និយាយជែកឡើងក្នុងខណៈនោះថា "ណ្ហើយ! រឿងក៏វាហួសទៅហើយ មិនបាច់ពោលពាក្យបន្ទោសអ្វីទេ, អើ, សារី កូនស្រីអាពុកបានឲ្យគេទៅអញ្ជើញគ្រូពេទ្យហើយឬនៅទេ?

"ចា៎ះ ខ្ញុំឲ្យម៉ុកៈទៅអញ្ជើញគ្រូពេទ្យវេជសិទ្ធិហើយ មិនទាន់ឃើញវិលមកវិញ"- នាងសារីឆ្លើយតបពាក្យបិតា ។

"នៅពេលដែលកំពុងជជែកមិនទាន់ចប់ ស្រាប់តែអ្នកជម្ងឺបើកភ្នែកប្រែខ្លួនមានស្មារតីឡើង ធ្វើភ្នែកឡឹងឡង់ដោយទឹកឆ្ងល់ណាស់ យកដៃស្ទាបក្បាលរបួស ។ អ្នកទាំងអស់គ្នាក៏មានសេចក្ដីត្រេកអរ ប៉ុន្តែអ្នកដែលត្រេកអរជាងគេនោះ គឺនាងសារីនិងនាងសារុនកុមារីទាំងពីររបស់លោកឧកញ៉ាបរិបូរសម្បត្តិ ។ ចួនជាគ្រូពេទ្យក៏បានមកដល់ក្នុងពេលនោះភ្លាម ចាក់ថ្នាំកំឡាំងឲ្យ ហើយពិនិត្យមើលវិធីរុំមុខរបួសឃើញត្រឹមត្រូវហើយ

និយាយថា ជម្ងឺនេះមិនជាធ្ងន់ទេ ដែលដល់ទៅជាសន្លប់នោះ ព្រោះប៉ះទៅលើសរសៃប្រសាទសំខាន់របស់អវយវៈ, មិនអីទេនឹងសះជាជាឆាប់ បើមានអ្នកព្យាបាលចំណាប់ចំណួនបែបនេះផង . រឹតតែសះជាឆាប់រហ័សឡើងទៀត" ហើយគ្រូពេទ្យក្រឡេកមើលទៅកុមារីទាំងគូ, នាងទាំងពីរមានសេចក្ដីអៀនខ្មាសឡើងមុខក្រហមងាកមុខចេញទៅ គ្រូពេទ្យនិយាយតែប៉ុណ្ណោះក៏លាម្ចាស់ផ្ទះចុះទៅវិញទៅ ។

លោកឧកញ៉ា លោកស្រី នាងក្រមុំសារីសារុននាំគ្នាចូលទៅជិតអ្នកជម្ងឺ ។

"សូមទានមេត្តាប្រោសអត់ទោស, ហេតុដូចម្ដេចបានជាខ្ញុំបាទមកនៅទីនេះ? លោកមេត្តាជំណាលរឿងរ៉ាវឲ្យខ្ញុំបាទបានដឹងផង" - អ្នកជម្ងឺសួរដោយទឹកឆ្ងល់ខ្លួនឯងខ្លាំងណាស់ ។

លោកឧកញ៉ា- "កុំបាច់ទឹកឆ្ងល់ចង់ដឹងរឿងរ៉ាវអី គង់តែនឹងបានដឹងជាប្រាកដ ហ៎! ហិតថ្នាំនេះទៅនាំឲ្យមានកំឡាំងសម្ងំដេកទៅសិនចុះ គេនឹងនិយាយរឿងឲ្យស្ដាប់ជាក្រោយ" ។ អ្នកជម្ងឺនោះក៏ធ្វើតាមបង្គាប់ដោយស្រួលបានសម្ងំដេកលក់ទៅមួយស្របក់ទៀត ។

អស់លោក-អ្នកមើលរឿងនេះ គង់មិនទាន់បានជ្រាបថា "អ្នកជម្ងឺនោះគឺអ្នកណា ឈ្មោះអ្វី កូនចៅចៅពង្សអ្នកណា ? តាមដោយពិត អ្នកជម្ងឺនោះ ជាអ្នកឯកការក្នុងក្រសួងយុត្តិធម៌ជាចៅក្រម ដែលឯកការទើប

គាត់ចំរើនអាយុ ២៥ ឆ្នាំមិនទាន់មានគ្រួសារនៅឡើយ ជាបុត្រលោកឧកញ៉ាសីហរាជ និងលោកស្រីឡាប់ ឃុំលេខ ១ ក្រុងភ្នំពេញនេះដែរ ឈ្មោះខ្លួនពៅក្រមកំឡោះនេះគេច្រើនហៅថា លោកពៅក្រមរត្ន ដ្បិតមិនទាន់បានព្រះរាជទានងារស័ក្តិនៅឡើយ ។

*
* *

លុះដល់ព្រឹកព្រាងស្វាងព្រះសុរិយា អរុណរះឡើងផុតពីជើងមេឃទិសខាងកើត ជាគ្រឿងសញ្ញាដាស់សព្វសត្វទាំងឡាយលើផ្ទៃផែនដីឲ្យភ្ញាក់រលឹកពីការដេកលក់ឈប់សម្រាកក្នុងវេលាពត្រី ។ បណ្ដាមនុស្សម្នាប្រុសស្រីក្នុងគេហដ្ឋានបរិបូរសម្បត្តិក៏ភ្ញាក់រលឹកឡើងកល់គ្នា ឯលោកពៅក្រមរត្នក៏ភ្ញាក់រលឹកព្រមជាមួយនឹងគេដែរ; ក្រោយដែលបានបរិភោគបបរនានិងទក់ទឹកទឹកដោះគោស្រស់ស្រួបស្រេចហើយ ក៏ហាក់ដូចជាមានកំឡាំងគ្រាន់បើ អាចក្រោកអង្គុយ ឈរឬដើរក៏បាន; លោកក៏ក្រាបលាព្រមទាំងសំដែងសេចក្ដីអរគុណច្រើនជាអនេក ចំពោះលោកឧកញ៉ាបរិបូរសម្បត្តិនិងលោកស្រីជាម្ចាស់ផ្ទះ ព្រមទាំងពីគាទាំងគូរបស់លោកហើយចុះចាកផ្ទះនោះទៅ ។

ស្រាប់តែមានសុភាពបុរសពីរនាក់ដើរចូលមកយ៉ាងអង់អាច ហាក់ដូចជាអ្នកធ្លាប់ស្និទ្ធស្នាលនឹងស្ថានទីនោះ, បុរសទាំងពីរនាក់តែងខ្លួនយ៉ាងហ៊ឺហាក់រ័យាឫកពាសំដែងឲ្យដឹងថា ជាមន្ត្រីជាន់ខ្ពស់, ប៉ុន្តែ

ម្នាក់ក្មេង ម្នាក់ទៀតចាស់ ៗ បុរសចាស់នោះ មានសក់ស្កូវមួយៗ ច្រមុះខ្ពស់មុខមូលទម្រង់ពងក្រពើ ថ្ពាល់ផត មានពុកមាត់ខ្លីៗ សមនឹងផ្ទៃមុខ ប្រមាណអាយុប្រហែល ៥០ ឆ្នាំ ៗ បុរសដែលក្មេងនោះ មានមុខមាត់ទីងទ្រង់ទ្រាយដូចគ្នា ប៉ុន្តែឥតពុកមាត់ ថ្ពាល់មិនផត មុខពេញ សំបុរស្បែកសស្អាតជាងបន្តិច ហើយរូបរាងមិនខ្ពស់មិនទាប ជាមធ្យមបុរស ទាំងនៅក្នុងវ័យកំលោះប្រហែលអាយុ២៣-២៤ឆ្នាំប៉ុណ្ណោះ ៗ

លោកឧកញ៉ាបរិបូរសម្បត្តិ កាលក្រឡេកមើលទៅឃើញលោកឧកញ៉ាកដបម្រើជាសំឡាញ់លោក ដើរចូលមកដូច្នោះក៏ស្រែកសួរជាប្រញាប់ថា "លោកម្ចាស់ថ្លៃអើយ! បាត់មុខមាត់យូរណាស់, ថ្ងៃនេះប្រហែលជាមានភ្ញៀវធំមិនខាន, អញ្ជើញមកខាងណោះ, អ្នកណានុ៎ះ មុខមាត់ដូចលោកម្ល៉េះ ?

"នេះជាកូនប្រុសរបស់ខ្ញុំបាទ លោកភ្លេចហើយឬ? នេះហើយគឺចៅឧត្តម" ៗ

"អឺហឺ! ម៉េចក៏ឆាប់ធាត់ធំអីម្ល៉េះ បាត់ពីសហើយឬចៅឧត្តម ឥឡូវនេះ" - លោកឧកញ៉ាម្ចាស់ផ្ទះនិយាយជន្ទូជន្ទេញលេង, ឯបុរសឈ្មោះឧត្តមឡើងមុខក្រហមដោយសេចក្ដីអៀនខ្មាស ៗ

លោកម្ចាស់ផ្ទះក៏នាំភ្ញៀវទាំងពីរនាក់ឲ្យចូលទៅអង្គុយនៅបន្ទប់ទទួលភ្ញៀវទាំងអស់គ្នា ហើយស្ងប់ស្ងាត់ទៅមួយស្របក់ ទើបលោក

ឧកញ៉ា ម្ចាស់ផ្ទះពោលឡើងមុនគេថា "លោកអញ្ជើញមកនេះ មានធុរៈអ្វីដែរឬគ្មានទេ ?

"បាទ, មានខ្លះ គឺចៅឧត្តម កូនប្រុសរបស់ខ្ញុំបាទនេះវាទទូចទទែ ឲ្យខ្ញុំបាទ ស្ទើរតែរាល់ថ្ងៃ ឲ្យនាំបំណងរបស់វាមកជម្រាបលោកឲ្យបានជ្រាប" ។

"រឿងអ្វីគេះ! ចង់សុំធ្វើការក្នុងក្រសួងរបស់ខ្ញុំ ឬមួយត្រូវការពឹង...?

"មិនមែនដូច្នោះទេ, តានប្រោស ចៅឧត្តមប្រឡងជាប់ទីក្រមការពីឆ្នាំទៅ ឥឡូវបានទៅធ្វើបាឡាត់ស្រុក នៅស្រុកគូកមាស ខែត្រកំពត បានទទួលប្រាក់បៀវត្ស ១ ខែជាង ១១០ រៀលហើយ តានប្រោស ។

"ពូកែមែន! ខ្ញុំឃើញចៅឧត្តមរត់លេងប្រលែងគ្នាកាលពីប៉ុន្មានឆ្នាំនេះឯង ឥឡូវស្រាប់តែបានធ្វើជាមន្ត្រីបានប្រាក់ខែក្នុង ១ ខែជាង ១០០ រៀល មានភ័ព្វវាសនាមែន បន្តិចទៀតនឹងបានយសស័ក្តិជាឧកញ៉ាអ្វីជំនួសលោកឪពុកតវង្សត្រកូល, តែលោកឧត្តមកុំភ្លេចឧកញ៉ាបរិបូរសម្បត្តិដែលធ្លាប់ពប់អានគ្នាមកយូរហើយណា៎ះ! លោកឧកញ៉ាម្ចាស់ផ្ទះនៅតែជន្ទញលេងលោកបាឡាត់ឧត្តមដដែល, ហើយលោកមានប្រសាសន៍តទៅទៀតថា "ចុះក្មួយមានរឿងសំខាន់អ្វីទៀតនិយាយជាមួយនឹងពូដែរឬ? និយាយចុះតាមចិត្ត កុំបារម្ភអី" ។

លោកបាឡាត់កំឡោះនៅតែអង្គុយស្ងៀម ហាក់ដូចជានៅមិនទាន់បាត់អៀនខ្មាស ទឹកមុខក្រហម ស្លឹកត្រចៀកទាំងសងខាងក៏ក្រហម គ្រាន់តែសំដែងអាការញញឹមញញែម ៗ ទើបលោកឧកញ៉ាជាបិតាឆ្លើយឡើងជំនួសថា "គឺមិនមានរឿងអ្វីក្រៅទេ តានព្រោស, ក្មេងកំរ័យនេះច្រើនតែជួបប្រទះនឹងសេចក្ដីមេត្រីស្នេហាខាងកាមារម្មណ៍ ដែលជាវិស័យរបស់លោកយជនហ្នឹងឯង" ៗ

"ហ៊ឹ! ហ៊ឹ! លោកក្ឌយឧត្ដមចង់បានប្រពន្ធ! លោកម្ចាស់ផ្ទះសើចកក្អាកកក្អាយហើយថា "អើចុះស្រឡាញ់នាងណា នៅទីណា? ទុកធុរៈឲ្យខ្ញុំធ្វើជាអ្នកផ្សំចៅមហាទៅដណ្ដឹងឲ្យកុំព្រួយឲ្យសោះ! ៗ

លោកបាឡាត់ឧត្ដមនៅតែផ្ងប់មុខ ដោយអៀនខ្មាសដដែល មិនឆ្លើយតបទៅម្ចាស់ផ្ទះថាអ្វីឡើយ ៗ ទើបលោកឧកញ៉ាជាបិតាឆ្លើយជំនួសថា "តានព្រោស, លោកមិនទាន់បានជ្រាបរឿងរ៉ាវរបស់ឧត្ដមទេ គឺកាលពីប៉ុន្មានខែកន្លងមកហើយនោះ ហាក់ដូចជាលោកធ្លាប់ដែលបានអញ្ជើញទៅមើលកីឡាយុវជនខ្មែរ ដែលមានពួកអ្នកទាត់បាល់ស្ដ្រីយួនមកពីដែនកូសាំងស៊ីន ដើម្បីសំដែងសេចក្ដីក្លាហានរបស់យុវនារីជាតិយួនតទល់នឹងយុវជនជាតិខ្មែរ ៗ នៅវេលាគ្រានោះមានប្រជាជនជាតិយួន, ចិន បារាំង ខ្មែរ, ទាំងប្រុស - ស្រីទៅមើលបាល់ទ្បង់យ៉ាងណែនណាន់តាន់តាប់ ឯខ្ញុំ

បាទមិនបានទៅទីនគេទេ ប៉ុន្តែឧត្តមនេះវាបានទៅមើលហើយឈរនៅក្បែរលោកផង" ។

លោកឧកញ៉ាម្ចាស់ផ្ទះអង្គុយនឹកមួយស្របក់ក៏បញ្ចេញវាចាថា "ឱ! ខ្ញុំនឹកឃើញហើយ គ្រានោះខ្ញុំបានទៅទីនគេដែរ បានទាំងនាំកូនក្រមុំខ្ញុំទាំងគូទៅជាមួយផង" ។

"ហ្នឹងហើយ ទានប្រោស, ឧត្តមកូនខ្ញុំបាទនេះ តាំងអំពីថ្ងៃបានជួបប្រទះនឹងនាងសារុនវេលាណា ក៏កើតចិត្តប្រតិព័ទ្ធស្នេហាគ្មានដាច់ ត្រឡប់មកដល់ផ្ទះវិញមិននិយាយស្តីនឹងអ្នកឯណាមួយម៉ាត់ ព្រោះតែស្ងួមស្ងាត់និយាយរអ៊ូរទាំតែម្នាក់ឯង ដូចជាមនុស្សខ្លោចចូល, លុះខ្ញុំបាទដេញដោលសួរណាស់ទៅ ទើបប្រាប់ត្រង់ថា ស្រឡាញ់នាងសារុន កូនក្រមុំលោក; រឿងរ៉ាវរបស់ចៅឧត្តមត្រឹមប៉ុណ្ណោះឯង" ។

"បើនិយាយឲ្យខ្លីទៅ គឺថាតាំងពីថ្ងៃនោះរហូតមកដល់ថ្ងៃនេះ បាឡាត់ឧត្តមចាប់ចិត្តស្រឡាញ់ស្អិតចំពោះលើរូបនាងសារុន ជាកូនក្រមុំខ្ញុំដូច្នោះឬ ?-លោកឧកញ៉ាម្ចាស់ផ្ទះសួរបញ្ជាក់ ។

"បាទ" -លោកឧកញ៉ាពជបំរើតប ។

"តាំងពីថ្ងៃនោះមកទើបខ្ញុំបាទនិយាយល្បួងលោមរម្ងាប់សេចក្តីស្នេហា ហើយមានខសន្យាថា បើឯងខំរៀនសូត្ររហូតដល់បានប្រឡងជាប់ទ័ក្រមការ បានចូលធ្វើរាជការមានរបៀវត្សប្រាក់ខែល្មមចិញ្ចឹមប្រពន្ធកូន

បានវេលាណា អាពុកទឹងចាត់ការដណ្តឹងឲ្យ; ហេតុនេះហើយបានជាតាំងពីចេញទៅធ្វើជាបាឡាត់ស្រុកវេលាណា បេះតែខ្ញុំមិនដែលខានមួយថ្ងៃ ដើម្បីឲ្យខ្ញុំបានមកជួបនឹងលោក ស្តាប់ប្រសាសន៍លោកមើល តើលោកមានយោបល់ដូចម្តេចក្នុងរឿងនេះ ?

លោកម្ចាស់ផ្ទះងាកទៅសួរបញ្ជាក់ម្ចាស់ខ្លួនថា "ម៉េចហ៏, ក្មួយឧត្តម ចាប់ចិត្តស្រឡាញ់សារុនណាស់ទៅពិតមែនឬ ? ។

គ្រានេះ លោកបាឡាត់ឧត្តមស្ទុះក្រោកឡើងទៅក្រាបសំពះនៅចំពីមុខលោកឧកញ៉ាបរិបូរសម្បត្តិហើយពោលពាក្យផ្អែមថា "បាទ, តាន-ប្រាស ខ្ញុំបាទស្រឡាញ់ប្អូនសារុនពិត ៗ លើសលែងជាងជីវិតរបស់ខ្ញុំបាទទៅទៀត ខ្ញុំបាទចាប់ចិត្តស្នេហាដោយដួងចិត្តដ៏បរិសុទ្ធ ហើយខ្ញុំបាទបានប្តេជ្ញាទុកក្នុងចិត្តជាស្រេចថា ប្រសិនបើមិនបានរៀបមង្គលការជាគូនឹងប្អូនសារុនទេ មុខជាខ្ញុំបាទស៊ូលះបង់ជីវិត ដើម្បីសំដែងឲ្យឃើញសេចក្តីសុចរិតស្មោះត្រង់របស់ខ្ញុំបាទក្នុងលោកនេះ ឲ្យបានឃើញជាក់ស្តែងប្រាកដ ។

លោកឧកញ៉ាម្ចាស់ផ្ទះដកដង្ហើមធំ ហើយនិយាយជាទំនងមិនឲ្យបាក់បែកមេត្រីសេចក្តីកប់ការថា "ចំណែកខាងខ្ញុំឥតយល់ទាស់បន្តិចអំពីរឿងនេះ កុំថាតែរូបលោកក្មួយដែលទុកដូចជាកូនទៅស្រាប់ទៅហើយ សូម្បីអ្នកដទៃទៀតមកដណ្តឹង ខ្ញុំក៏ស្ម័គ្រចិត្តលើកឲ្យដែរ ប៉ុន្តែការនេះក៏មិន

ស្រេចនៅលើខ្លួនខ្ញុំទេ ការសំខាន់ស្រេចនៅលើម្ចាស់ខ្លួនគេទេតើ ចាំខ្ញុំសាកសួរចិត្តកូនមើលសិន ខ្ញុំមិនហ៊ានបង្ខំចិត្តគេទេ បុកណាលោកពោលថា "សង់ផ្ទះតោងតាមចិត្តអ្នកនៅ" មែនទេ? មួយទៀតលោកថា "ចង្អៀតទីចង្អៀតចុះ កុំឲ្យតែចង្អៀតចិត្ត" មែនទេ?

"ពិតដូចមានប្រសាសន៍, រឿងនេះស្រេចនៅលើខ្លួនគេជាប្រមាណ"- លោកឧកញ៉ាកជបំរើពោលអនុលោមតាមពាក្យលោកឧកញ៉ាម្ចាស់ផ្ទះ ។

"រឿងនេះទុកថ្ងៃក្រោយចុះ ក្មួយឧត្តម ចាំឲ្យខ្ញុំសួរចិត្តគេសិន" ។

"បាទ, ខ្ញុំបាទសូមអរគុណជាទីបំផុត" — លោកបាឡាត់ស្រុកកំឡោះលើកដៃសំពះដោយកិរិយាគោរពទន់ភ្លន់ចំពោះលោកឧកញ៉ាជាម្ចាស់ផ្ទះ ។ ក្រោយនោះបន្តិចឪពុកនឹងកូនក៏លាលោកម្ចាស់ផ្ទះចុះពីគេហដ្ឋានបរិបូរសម្បត្តិនោះទៅ ។

* * *

ឯអ្នកដែលមាននាមថា លោកចៅក្រមរ័ត្ននោះ កាលបានត្រឡប់ទៅដល់លំនៅរបស់ខ្លួនហើយ ក៏ខំថែរក្សារបួសនោះទាល់តែសះជាស្រឡះ តែចិត្តគំនិតអណ្តែតអណ្តូងរវើរវាយ ដោយហេតុនឹកក្រូវផង់របស់នាងក្រមុំតាំងគួនោះ មកជាប់នៅនឹងភ្នែករបស់លោកចៅក្រមកំឡោះជានិច្ច នាំឲ្យលោកចៅក្រមកំឡោះចាប់ចិត្តប្រតិព័ទ្ធស្នេហាតាំងពីថ្ងៃនោះមក;

គ្រានេះជាគ្រាដំបូង ដែលលោកវ័ត្តលុះក្នុងអំណាចនៃសេចក្ដីស្នេហាគ្រា តែជាកខ្លួនមិនរួច, ក្នុង ២៤ ម៉ោង លោកវ័ត្តតែងនាំយករឿងឧប្បត្តិហេតុនោះមកគិតមកនឹកតែម្នាក់ឯង, ដូចកាលឡើងទឹកមុខស្រស់ញញឹមប្រិមប្រិយ ចួនកាលស្រពោនស្រពន់ក្រៀមក្រោះ នាំឲ្យអ្នកផងដែលនៅក្នុងផ្ទះជាមួយមានសេចក្ដីងឿងឆ្ងល់ពល់គ្នា តែឥតនរណាមួយដឹងរឿងរ៉ាវនោះឡើយ ទាំងលោកចៅក្រមវ័ត្តក៏មិនបានបញ្ចេញរឿងរ៉ាវរបស់ខ្លួនឲ្យអ្នកដ-ទៃបានដឹងមួយជាពីរឡើយ លាក់ទុកតែក្នុងចិត្ត ក្រែងមិនបានសម្រេចនាំឲ្យខ្មាសគេ ប៉ុន្តែព្យាយាមរកឱកាសចន្លោះ ដើម្បីឲ្យបានជួបនឹងនាងក្រមុំសារី ហើយថ្លែងបំណងរបស់ខ្លួនឲ្យនាងបានដឹងសេចក្ដីពិតក្នុងចិត្តផង ។

ចំណែកខាងនាងក្រមុំសារី និងនាងក្រមុំសារុនបងប្អូន ទាំងពីរនាក់ តាំងពីថ្ងៃនោះគន្លងមក ចិត្តគំនិតរបស់នាងមិនបានជាប់នៅនឹងខ្លួនប្រាណ ហាក់ដូចព្រះកាមទេពបានថ្លែងសរត្រូវត្រង់ទ្រប្រទេសរបស់នាងក្រមុំទាំងគូដោតជាប់នៅនឹងបេះដូង ធ្វើឲ្យចិត្តចេតសិករបស់នាងអណ្ដែតអណ្ដូងទៅតាមអំណាចកាមារម្មណ៍ ទឹករលឹកទៅរកតែបុរសកំឡោះនោះពល់ទិវារាត្រីពុំដែលដាច់ ។

✡

✡ ✡

កាលព្រះសុរិយាជ្រៀងជ្រេជិតអស្ដង្គតមុនចូលកាន់សន្ធ្យារាត្រី រស្មីព្រះអាទិត្យចុះពន្លឺក្រហមច្រាលឆ្អៅទៅលើផ្ទៃមេឃ អ្នកផងគ្រប់ឡក

មើលទៅហាក់ដូចជាព័ណ៌ឈាម ។ នៅឱកាសនេះហើយដែលនាងក្រមុំសារុនចុះពីគេហដ្ឋានទៅអង្គុយលេងនៅក្នុងសួនច្បារក្រោយផ្ទះ ដ៏ដេរដាស ដោយផ្កាកុឡាប, ច័ន្ទទិងក្រៃ សឹងមានក្លិនក្រអូបឈ្ងុយឈ្ងប់ផ្សព្វផ្សាយពេញបរិវេណសួនច្បារ នាងសារុនក៏អង្គុយលើកៅអីវែងមួយក្នុងក៏រវៃតែមើលបុប្ផាផ្កានានា ដោយអាការស្រស់បស់ ស្រាប់តែលេចបាឡាត់ស្រុកកំឡោះដែលមាននាមថា ឧត្តមដើរចូលមកយ៉ាងស្ងប់ស្ងាត់សំដៅត្រង់មកចំចំពោះមុខនាង ហើយបង្អោនកាយសំដែងសេចក្ដីគោរពហើយពោលពាក្យជាទំនងអង្វរថា :

"ប្អូនសារុន! ថ្ងៃនេះបងមានសង្ឃឹមថាប្អូននឹងថ្លែងសេចក្ដីពិតក្នុងចិត្តប្រាប់បងឲ្យបានដឹងជាប្រាកដ នៅវេលាគ្រានេះជាពុំខាន! ។

នាងក្រមុំសារុនភ្ញាក់ព្រើតទាំងខ្លួនប្រាណ ហើយនិយាយឆ្លើយឆ្លងដោយសេចក្ដីធ្ងាប់កប់អានថា "ចុះលោកឲ្យខ្ញុំអាណិតមេត្តាប្រាប់សេចក្ដីពិតអ្វី? លោកបាឡាត់, ខ្លួនខ្ញុំឥតមានរឿងស្ងាត់កំបាំងអ្វីលាក់ទុកក្នុងចិត្តទេ" ។ បាឡាត់ស្រុកធ្លាក់ទឹកមុខមួយរំពេច ហើយនិយាយស្ទើរតែទៅជាខ្សឹបថា :

"ប្អូនសារុនអើយ! — ឈប់ដកដង្ហើមវែង ហើយនិយាយតទៅទៀតថា "ប្អូនបានសញ្ញានឹងបងថានឹងឆ្លើយប្រាប់ឲ្យបងបានដឹងក្នុងថ្ងៃនេះមិនមែនឬ?

(មាតត)

កុម្ភជាតក

សំដែងអំពីដើមកំណើតស្រុកនិងទោសនៃស្រុក

លោកអាចារ្យ ឈឹម-ស៊ុម (សទ្ធម្មបញ្ញោ)

គ្រូបង្រៀនទៅសាលាបាលីជាន់ខ្ពស់ ប្រែនិងរៀបរៀងតាម គម្ពីរខុទ្ទកនិកាយ
ព្រមទាំងអដ្ឋកថា ។

អារម្ភកថា

កុម្ភជាតកនេះ ជាជាតក ១ ដែលមានប្រាកដក្នុងព្រះត្រៃបិដក គម្ពីរខុទ្ទកនិកាយជាតក តឹសនិបាត ជាភាសាបាលី ខ្ញុំបានប្រែនិងរៀបរៀងសេចក្ដីជាខេមរភាសា ដោយសេចក្ដីត្រូវការរបស់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។

ក្នុងវេលាដែលខ្ញុំប្រែនិងរៀបរៀងនោះ ខ្ញុំបានពិនិត្យយកសេចក្ដីពីគម្ពីរអដ្ឋកថានៃគម្ពីរនេះមកដាក់បញ្ចូលផង ដើម្បីឲ្យទាក់ទងសេចក្ដីគ្នា ជាលំអានល្មមស្ដាប់បានដោយងាយ ។ ឯសេចក្ដីដែលពោលតាមគម្ពីរខុទ្ទកនិកាយជាតក តឹសនិបាតនោះ ខ្ញុំដាក់ទាំងបាលីព្រមទាំងសេចក្ដីប្រែជាសម្រាយផង ឥតមានរំលងត្រង់គាថាណាមួយឡើយ រួមទាំងអស់ ៣១ គាថា តែសេចក្ដីប្រែនោះមិនមែននិយមព្យញ្ជនជាប្រមាណទេ ប្រែនិយមយកអត្ថរសជាប្រមាណ តាមទំនងសេចក្ដីនៃគម្ពីរអដ្ឋកថា ។

ខ្ញុំខំច្រៀតធ្វើរឿងនេះ ក្នុងពេលឱកាសមួយស្របក់ៗ ដែលក្រៅអំពីពេលធ្វើការជាប្រក្រតី ដរាបតែចប់សព្វគ្រប់ ហើយបានយកទៅប្រគេនព្រះតេជ-គុណព្រះសិរីសម្មតិវង្ស ព្រះនាម "ឯម" ពាងហ្វាងសាលាបាលីជាន់ខ្ពស់ និងជាអធិបតី ក្រុមជំនុំព្រះត្រៃបិដក ដែលជាធម្មាចារ្យរបស់ខ្ញុំ និងព្រះតេជ-គុណព្រះឧត្តមមុនី ព្រះនាម "ស៊ូ" អធិបតីនៃក្រុមជំនុំ ព្រះត្រៃបិដក សូមឲ្យលោកពិនិត្យឲ្យ លោកក៏បានពិនិត្យឲ្យដោយសេចក្តីមេត្តា ហើយខ្ញុំយករឿងនេះទៅជូនលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ឲ្យលោកចាត់ចែងការបោះពុម្ព ដើម្បីផ្សាយដល់ពួកពុទ្ធសាសនិកជន គ្រប់តម្បន់ដែលមានសេចក្តីត្រូវការ ។

ខ្ញុំសូមប្រគេនបុញ្ញរាសី ដែលកើតអំពីវីរិយភាពរបស់ខ្ញុំនេះទាំងអស់ចំពោះព្រះតេជ-គុណទាំងពីរព្រះអង្គនោះ ដើម្បីជាបតិការតបព្រះគុណដ៏ធំទូលាយ សូមឲ្យព្រះគុណបានសម្រេចនូវឥដ្ឋមនុញ្ញផលតាមគាប់ព្រះទ័យ ហើយសូមសេចក្តីសុខ-ចំរើនមានដល់ខ្ញុំផង ដល់លោកអ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់អស់លោក-អ្នកដែលប្រព្រឹត្តតាមព្រះពុទ្ធសាសនាផង អស់កាលជាអង្វែងទៅហោង ។

លោកអាចារ្យ ឈឹម-ស៊ុម នៅវត្តលង្កា ក្រុងភ្នំពេញ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

កោធាតុកសីតិ ឥទំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ វិសាខាយ សហាយិកា សុរាបីតា បញ្ចសតា ឥត្ថិយោ អារព្ភ កថេសិ ។

កាលដែលសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ព្រះអង្គទ្រង់សម្រាន្ត ព្រះឥរិយាបថនៅវត្តជេតពន ទ្រង់ប្រារព្ធនូវស្រីប្រាំរយនាក់ដែលជាសំឡាញ់នឹងនាងវិសាខា ជាស្រីផឹកសុរា ហើយទ្រង់ត្រាស់សំដែងនូវព្រះធម៌ទេសនាមានបទថា កោ ធាតុក សី ដូច្នេះជាដើម ។

បានឮមកថា: មនុស្សទាំងឡាយលេងមហោស្រពផឹកសុរាកន្លំពង់ក្នុងនគរសាវត្ថី ស្រីៗទាំងប្រាំរយនោះ ចាត់ចែងសុរាជូនស្វាមីដែលកំពុងលេងមហោស្រព រួចស្រេចហើយ ក៏គិតគ្នាថា: "យើងនឹងលេងមហោស្រព" ហើយក៏ទៅបបួលនាងវិសាខាៗប្រកែកថា: "មហោស្រពនេះគេលេងផឹកសុរា ខ្ញុំមិនផឹកសុរាទេ" ស្រីទាំងនោះនិយាយថា: "សូមនាងថ្វាយទានចំពោះព្រះសម្មាសម្ពុទ្ធចុះ យើងនឹងលេងមហោស្រព" ។ នាងវិសាខាទទួលព្រមថា: "ស្រួលហើយនាង" ហើយឲ្យគេនិមន្តសម្តេចព្រះសាស្តាចារ្យមក នាងបានថ្វាយមហាទាន លុះដល់សាយណ្ហសម័យថ្ងៃរសៀល នាងកាន់យកគ្រឿងក្រអូបនឹងផ្កាកម្រងជាច្រើន ស្រីៗទាំងនោះក៏ហែហមចោមរោមជាបរិវារ យាត្រាទៅកាន់វត្ត

ដេកពន់ដើម្បីស្ដាប់នូវធម្មកថា ។ ឯស្រីតាំងនោះទៅឈរទៀបក្លោងទ្វារ ផឹកសុរារួចស្រេចហើយទើបបានចូលទៅកាន់សំណាក់សម្ដេចព្រះសាស្ដា ជាមួយនឹងនាងវិសាខា ។ ថ្វាយបង្គំសម្ដេចព្រះសាស្ដាហើយក៏អង្គុយនៅ ក្នុងទីគួរមួយ ៗ បណ្ដាស្រីតាំងនោះ ស្រីពួកខ្លះរាំ ស្រីពួកខ្លះរាំសដៃរាំស ជើងកើតជារឿងឈ្លោះប្រកែកក្នុងសំណាក់ព្រះបរមសាស្ដាចារ្យ ព្រះអង្គ ក៏ទ្រង់បញ្ចេញនូវព្រះរស្មី អំពីព្រះភមុការោម (រោមចិញ្ចើម) ដើម្បីឲ្យ ស្រីតាំងនោះកើតសង្វេគតក់ស្លុត ក៏កើតជាអ័ព្ទងងឹតជិតសព្វទិសានុទិស ៗ ស្រីតាំងនោះក៏កើតភ័យរន្ធត់តក់ស្លុតមហិមា ដោយសារមរណភ័យមក គម្រាម ៗ សុរាក៏សាបរលាបទៅភ្លាមព្រោះតែភ័យនោះ ។ សម្ដេច ព្រះដ៏ទ្រង់យស ទ្រង់ក្រៀសចេញអំពីបល្ល័ង្កដែលទ្រង់គង់ ទៅប្រថាប់ នៅលើកំពូលភ្នំព្រះសុមេរុ ហើយទ្រង់បញ្ចេញនូវព្រះរស្មីអំពីព្រះឧណ្ណា-លោម (រោមប្រជុំចិញ្ចើម) ពន្លឺក៏ចែងចាំងហាក់ដូចជាព្រះចន្ទនឹងព្រះ អាទិត្យ ១ ពាន់រះឡើង ៗ ព្រះអង្គទ្រង់ប្រថាប់នៅលើកំពូលភ្នំព្រះ សុមេរុនោះ ហើយទ្រង់សំដែងនូវបទព្រះគាថា ដើម្បីឲ្យស្រីតាំងនោះ កើតសង្វេគថា ៖

កោ នុ ហាសោ កិមានន្ទោ
និច្ចំ បជ្ជលិតេ សតិ ?

កាលបើលោកសន្និវាសនេះ ភ្លើងទាំង ១១ កង[១]ឆេះឡើងសន្ធោសន្ធៅជានិច្ច (យ៉ាងនេះ) តើនាងទាំងឡាយសើចដូចម្ដេចកើត ត្រេកអរដូចម្ដេចកើត ?

អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ

នាងទាំងឡាយពិតជាងងឹតគឺអវិជ្ជាដែលមានវត្ថុ ៨ ប្រការ[២]គ្របសង្កត់ហើយ ម្ដេចឡើយក៏មិនស្វែងរកប្រទីបជ្វាលា ពោលគឺប្រាជ្ញា ដើម្បីកំចាត់បង់នូវងងឹតនោះចេញ ។

លុះចប់ព្រះគាថាហើយ ស្រីទាំងប្រាំរយនោះ ក៏បានដល់នូវសោតាបត្តិផល ។ សម្ដេចព្រះទសពល ទ្រង់និមន្តមកវិញ ហើយគង់នៅលើព្រះពុទ្ធាសនៈ ក្រោមម្លប់គន្ធកុដី ។ សម័យនោះនាងវិសាខាថ្វាយវន្ទនាការព្រះអង្គរួចស្រេច ក៏ក្រាបបង្គំទូលថា: សូមទ្រង់ព្រះមេត្តាប្រោស ការផឹកសុរានេះ ជាការទម្លាយនូវហិរិនិងឱត្តប្បៈ (មិនឲ្យមានសេចក្ដីអៀនខ្មាសខ្លាចបាប) តើសុរានេះកើតពីត្រឹមណាមកព្រះអង្គ ? ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់នាងវិសាខាថា:

---

១ ភ្លើងគឺ រាគ, ទោស, មោហ, ជាតិ, ជរា, មរណ, សោក. បរិទេវ, ទុក្ខ, ទោមនស្ស, ឧបាយាស ។ ២ មិនដឹងសេចក្ដីទុក្ខ, មិនដឹងហេតុនៃសេចក្ដីទុក្ខ, មិនដឹងសេចក្ដីរលត់ទុក្ខ, មិនដឹងផ្លូវនៃសេចក្ដីរលត់ទុក្ខ, មិនដឹងអតីត, មិនដឹងអនាគត, មិនដឹងទាំងអតីតទាំងអនាគត, មិនដឹងបដិច្ចសមុប្បាទ ។

អតីតេ កាលេ កាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រ១ ព្រះអង្គទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្រុងពារាណសី (សម័យនោះ) មានជើងព្រៃម្នាក់ឈ្មោះសុរៈ នៅក្នុងកាសិករដ្ឋ គាត់បានទៅព្រៃហេមពាន្តដើម្បីស្វែងរកគ្រឿងកណ្ឋាផ្សេងៗ ។ នៅព្រៃហេមពាន្តនោះមានឈើ ១ ដើម ដុះឡើងកំពស់ ១ ជំហរ ហើយបែកប្រគាបជា ៣ ក្នុងចន្លោះប្រគាបទាំង ៣ នោះមានរណ្តៅទំហំប៉ុនពាង លុះដល់ទឹកភ្លៀងធ្លាក់មកក៏ដក់ទឹក ពេញក្នុងរណ្តៅនោះ ហើយមានដើមស្រម៉, កន្ទួតព្រៃនិងម្រេច ដុះជិតរួបរិតដើមឈើនោះ ផ្លែវាទុំជ្រុះធ្លាក់ចុះក្នុងរណ្តៅនោះ មិនតែប៉ុណ្ណោះ សត្វសេកទាំងឡាយ ក៏កាត់ពាំនាំយកនូវគួរនៃស្រូវសញ្ជាតសាលី អំពីទីជិតខាងមកទំស៊ីនៅលើដើមឈើនោះ គ្រាប់ស្រូវនិងអង្ករ ក៏ធ្លាក់ចុះក្នុងរណ្តៅនោះទៀត ។ ហេតុដូច្នោះទឹកនោះលុះត្រូវកំដៅព្រះអាទិត្យក៏មានពណ៌ក្រហម មានរសខ្លាំងឡើង ៗ ក្នុងនិទាឃសម័យ (រដូវក្តៅ) សត្វបក្សីមានសេចក្តីស្រេកឃ្លានបានមកផឹកទឹកនោះ ហើយស្រវឹង ចម្រេះនទៀលជ្រប់ដួលដេកនៅទៀបគល់ឈើ លុះដេកបន្តិចទៅ ហើយក៏ស្រែកកញ្ជ្រៀវទ្រៀវហោះហើរចៀសចេញទៅ ។ សូម្បីសត្វកំប្រុកនឹងស្វាជាដើម ក៏មានទំនងដូច្នោះដែរ ។

នាយព្រានព្រៃបានឃើញទឹកនោះហើយក៏គិតថា ទឹកនេះ បើជាទឹកពុល សមជាសត្វទាំងនេះស្លាប់ ប៉ុន្តែសត្វទាំងនេះ គ្រាន់តែដេកបន្តិចហើយក៏ទៅដោយស្រួលទៅ ទឹកនេះមិនមែនជាទឹកពុលឡើយ" ហើយគាត់ផឹកខ្លួនឯងគ្រាន់តែស្រវឹង ហើយមានចំណង់ចង់ស៊ីសាច់ គាត់ក៏បង្កាត់ភ្លើង ហើយសម្លាប់សត្វបក្សីទាំងឡាយមានទទាទីងមាន់ជាដើមដែលជ្រប់ដួលនៅទៀបគល់ឈើ ចំអិនលើរងើកភ្លើងហើយកាន់ដៃម្ខាងស៊ីសាច់ដៃម្ខាងនៅក្នុងទីនោះអស់ពីរបីថ្ងៃ ។

សម័យនោះ មានតាបស ១ រូបឈ្មោះវរុណៈ នៅក្នុងទីជិតនោះ ។ ព្រានព្រៃតែងតែទៅកាន់សំណាក់តាបសនោះ ហើយរំពឹងគិតថា: "បើអញផឹកទឹកនេះជាមួយនឹងតាបស (សមជាសប្បាយណាស់)" ហើយគាត់យកទឹកនោះ ១ បំពង់ឫស្សី ជាមួយនឹងដុំសាច់ដែលចំអិនស្រេច ដើរទៅកាន់បណ្ណសាលា ហើយនិយាយថា: "សូមលោកម្ចាស់ឆាន់ទឹកនេះលងមើល" ។ តាបសនឹងព្រានព្រៃទាំងពីរនាក់ ក៏នាំគ្នាទំពាសាច់ផឹកទឹកនោះ ។ មានឈ្មោះជាទឹកសុរាផង ទឹកវរុណីផង ព្រោះហេតុដែលព្រានព្រៃឈ្មោះសុរៈ នឹងតាបសឈ្មោះវរុណៈ បានឃើញ (មុនគេ) ។

អ្នកទាំងពីរគិតគ្នាថា: "នេះឯងជាឧបាយដ៏សំខាន់" ហើយក៏ដងដាក់ពេញបំពង់ឫស្សីជាច្រើន រែកទៅកាន់ស្រុកបច្ចន្តគ្រាម ឲ្យគេ

ក្រាបបង្គំទូលព្រះមហាក្សត្រថា: "មានអ្នកបេះធ្វើទឹកស្រវឹងមកហើយ" ។ ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យហៅអ្នកទាំងពីរនាក់មក អ្នកទាំងពីរនាក់ក៏បង្អោនទឹកនោះចូលទៅក្រាបបង្គំថ្វាយ ។ ទ្រង់សោយទឹកសុរានោះពីរបីដងក៏ស្រវឹងមែន ។ ទឹកសុរានោះបាន់ត្រឹមតែ ១ ថ្ងៃ ២ ថ្ងៃប៉ុណ្ណោះក៏អស់ទៅ ទើបទ្រង់ត្រាស់សួរថា: "ទឹកសុរានេះមានទៀតទេ ? អ្នកទាំងពីរនាក់ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព មានទៀត ។ ទ្រង់ត្រាស់សួរថា: "មាននៅឯណា ? អ្នកទាំងពីរនាក់ក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព មាននៅព្រៃហិមពាន្ត" ។ ទើបទ្រង់បង្គាប់ថា: "បើដូច្នោះចូរអ្នកទាំងឡាយទៅយកមកទៀត" ។ ជនទាំងពីរនាក់នោះទៅនាំយកទឹកសុរាមកអស់ពរម្តងពីរដងហើយគិតគ្នាថា: "យើងមិនអាចទឹងទៅយកអស់កាលជានិច្ចបានទេ" ហើយក៏កំណត់យកនៅគ្រឿងផ្សំគ្រប់មុខបានយកមកផ្សំធ្វើសុរានៅក្នុងព្រះនគរ ។ អ្នកនគរទាំងនោះនាំគ្នាផឹកសុរាហើយក៏ទៅជាអ្នកមានសេចក្តីប្រមាទ ប្រហែសធ្វេសក្នុងការងារត្រឡប់ទៅជាអ្នកកំសត់ទុគ៌ត ព្រះនគរក៏ហាក់ដូចជាសូន្យ ឥតមានមនុស្សឥតមានសេចក្តីចំរើនដោយការងារណាមួយឡើយ ។ ហេតុដូច្នោះបានជាអ្នកធ្វើសុរានាំគ្នារត់ចេញអំពីទីនោះ ទៅកាន់នគរពារាណសីឲ្យគេក្រាបបង្គំទូលសម្តេចព្រះនរបតីថា: "មានអ្នកធ្វើសុរាមកដល់ហើយ" ។ ព្រះរាជាទ្រង់

បង្គាប់ឲ្យហៅមក ហើយទ្រង់ព្រះរាជទានស្បៀងជាដើមទុនឲ្យធ្វើស្រុក ជូនព្រះទៀត ៗ ខេត្តនោះក៏វិនាសដូចខេត្តមុនទៀត ៗ អ្នកធ្វើស្រុកទាំងពីរនាក់ រត់ចេញអំពីខេត្តពោកណាសីទៅកាន់ខេត្តសាកេត រត់ចេញអំពីខេត្តសាកេតទៅកាន់ខេត្តសាវត្ថី ៗ គ្រានោះ ព្រះចៅក្រុងសាវត្ថីទ្រង់ព្រះនាមព្រះបាទសព្វមិត្ត ព្រះអង្គទ្រង់ធ្វើសេចក្ដីសង្គ្រោះដល់អ្នកទាំងពីរនាក់នោះ ទ្រង់មានព្រះបន្ទូលសួរថា: "អ្នកទាំងឡាយត្រូវការវត្ថុអ្វីខ្លះ? អ្នកធ្វើស្រុកក្រាបបង្គំទូលថា: "ទូលព្រះបង្គំជាខ្ញុំ ត្រូវការធ្វើគ្រឿងផ្សំ ទឹកអម្រ៉ៃស្រូវសាលី ហើយនឹងថុទិន(១) ចំនួនប្រាំរយ" ព្រះរាជាក៏ព្រះរាជទានវត្ថុគ្រប់ តាមសេចក្ដីត្រូវការ ៗ អ្នកធ្វើស្រុកទាំងនោះដាក់ស្រុកក្នុងថុទិនទាំងប្រាំរយ ហើយខ្ចាប់ក្រងគណ្ឌូរចូល ក៏ចងឆ្មាមួយៗជិតថុទិនមួយៗ ៗ ឆ្មាទាំងនោះផឹកស្រុកដែលហៀរចេញអំពីថុទិន ហើយស្រវឹងដេកលក់អស់ទៅ ពួកគណ្ឌូរមកដល់ហើយ ក៏កកេរស៊ីត្រចៀក, ច្រមុះ, ចង្កូម នឹងកន្ទុយឆ្មាទាំងនោះរបេអស់ហើយទៅបាត់ទៅ ៗ

---

១ បុរាណហៅថា: ពីង, ប៉ូវ, កប៉ុក សម្រាប់បិទស្រុក ។

ពិធីច្នានសមាស

តាមទំនៀមព្រាហ្មណ៍នៅនគរពាកណាសីប្រទេសឥណ្ឌា

ឧកញ៉ា ទេពពិទូរ ក្រសេម

(រៀបរៀងតមកនឹងឧបប់)

ពិធីខែជេស្ឋ

ខែជេស្ឋ ពិធីជេស្ឋវិធានធម៌ (គឺពិធីស្រង់ព្រះ) (មិនឃើញមានប្រាប់ថ្ងៃដែលធ្វើ) ព្រះមហាក្សត្រឲ្យស្រីព្រហ្មចារីតែងខ្លួន ហើយយកផ្តាំងទឹកទៅដងទឹកទន្លេគង្គា យកផ្លូងផ្កាបិទមាត់ផ្តាំងទឹក ទូលយកទៅឯវត្តប៉ាតលីជាស វត្តម៉ាជោជាស ព្រះមហាក្សត្រស្តេចទៅយកទឹកនោះស្រង់ព្រះពុទ្ធរូប ស្រង់យតិ ធ្វើសក្ការបូជាព្រះពុទ្ធរូបប្រគេនចង្ហាន់យតិ រួចហើយព្រាហ្មណ៍វិលែកយកទឹកនោះទៅស្រង់ទេវរូប ព្រះឥសូរ ព្រះនារាយណ៍ និងធ្វើសក្ការបូជាតាមទំនៀម ។

ពិធីខែអាសាឍ

ក្នុងខែអាសាឍ ពិធីអាសាឍវិធានធម៌ (គឺ ពិធីហែព្រះប្រទក្សិណព្រះនគរ) នៅថ្ងៃ ៥ កើតនិមន្តព្រះពុទ្ធរូបមាស ទៅវត្តប៉ាតលីជាស វត្តម៉ាជោជាស ដាក់លើរថ មហាយតិឡើងគង់ក្រៅស្នង, ព្រាហ្មណ៍កជគ្រូ

អញ្ជើញទេវរូប ព្រះឥស្សូរ នារាយណ៍ដាក់លើរថ ហែតាមក្រោយ ហែជុំព្រះនគរ អស់ការ ១០ ថ្ងៃ លុះគ្រប់ ១០ ថ្ងៃហើយហែចូលទៅក្នុងព្រះរាជវាំង ព្រះមហាក្សត្រទ្រង់គ្រឿងសក្ការបូជា ចេញទៅនមស្សការបូជា ហើយនិមន្តភិក្ខុមកឆាន់ ។ ហើយនិមន្តព្រះពុទ្ធរូប និងទេវរូបប្រតិស្ឋានដូចដើម ។

ពិធីក្នុងខែស្រាពណ៍

ខែស្រាពណ៍ ពិធីនាគវិធានម៌ (គឺពិធីបូជានាគរាជ) ថ្ងៃ ៥ កើត ទ្រង់គ្រឿងសក្ការបូជា នំបន្អែម ទៀនធូបភ្ញីផ្កា បូជានាគរាជឈ្មោះសេសៈ ព្រាហ្មណ៍រាជគ្រូសរសេររូបសេសៈនាគរាជ ក្បាល ៨ កន្ទុយ ៨ កាលទ្រង់បូជានោះគេបិទទ្វារវាំងទ្វារផ្ទះគ្រប់ៗ អន្លើ ហើយនាំគ្នាបូជាទូទៅគ្រប់ផ្ទះ ។

ពិធីក្នុងខែភទ្របទ

ខែភទ្របទ ពិធីភទ្របទវិធានម៌ (គឺពិធីបុណ្យថ្វាយទឹកឃ្មុំ) ថ្ងៃ ១៥ កើតបុណ្យថ្វាយទឹកឃ្មុំ ដល់ភិក្ខុនៅក្នុងព្រះរាជវាំង និងកល់ផ្ទះសំបែង ស្រេចហើយព្រាហ្មណ៍រាជគ្រូយកអំបោះនៅចងកន្ទាំងថ្មី ប្រគល់ឲ្យអ្នកម្ចាស់ផ្ទាំងដែលធ្វើបុណ្យទាំងនោះ យកទៅបណ្តែតក្នុងទន្លេគង្គា ហើយ

ចុះង្ងូតទឹកក្នុងទន្លេនោះ ជំរះកាយឲ្យបរិសុទ្ធស្រេចហើយ តែងខ្លួនរៀបរយមកក្រាបសំពះមាតាបិតា ។

ពិធីក្នុងខែអស្សុជ

ខែអស្សុជ ពិធីអស្សុជវិធានម៍ (គឺពិធីប្រសិទ្ធិអាវុធ) ថ្ងៃ ៥ កើត ព្រះមហាក្សត្រទ្រង់ឲ្យហានធ្វើពិធីជំរះអាវុធ រួចហើយតែងគ្រឿងបូជាប្រសិទ្ធិអាវុធ, ពួកដែលកាន់នៅក្នុងសីលមិនសម្លាប់សត្វ យកអាវុធនោះទៅកាប់ដើមដូងជាដើម អ្នកមិនកាន់សីល យកអាវុធនោះទៅកាប់គោក្របីលអាវុធ ហើយទាហានទៅសំដែងគ្រឿងអាវុធថ្វាយព្រះមហាក្សត្រទតនៅមុខព្រះពន្លាទីទ័ពព្រមគ្នា, ក្នុងខណៈនោះ អ្នកស្រុកដែលមានប្រាក់មាស ក៏យកប្រាក់មាសទៅថ្វាយព្រះមហាក្សត្រតាមមានតិច-ច្រើន អ្នកគ្មានប្រាក់មាស ត្រូវយកផ្កាទៅថ្វាយ គ្រានោះព្រះមហាក្សត្រ ត្រាស់ឲ្យសេនាបតីពិចារណាមើលសេចក្ដីសុខ-ទុក្ខរបស់រាស្ត្រ. ហើយទ្រង់ត្រាស់ឲ្យប្រុងប្រៀបសេនាទាហានអ្នកចំបាំង ឲ្យមានគ្រប់គ្រាន់ព្រមទុកសម្រាប់ផែនដី ។

ពិធីខែកត្ដិក

ខែកត្ដិក ពិធីកត្ដិកវិធានម៍ (គឺពិធីបណ្ដែតគោមថ្វាយព្រះ) ថ្ងៃ ១ កើត យកឈើរវែងមកធ្វើជាដងគោម ដោតជាំក្នុងព្រះរាជស្ថាន បណ្ដែតគោម

ពួកអ្នកស្រុកគ្រប់ស្រុក-ភូមិ-ផ្ទះ បង្ហូតគោមដូចគ្នានេះ បូជាអស់រយៈ ១៥ ថ្ងៃ លុះដល់ថ្ងៃ ១ រោច ធ្វើផែតូចៗ អុជប្រទីបបណ្តែតទៅក្នុងទន្លេគង្គា ហើយអុជកាំជ្រួចបូជាព្រះនៅវត្តប៉ាតលីជាស វត្តម៉ាដោជាស រួបសម្រុតគោមចុះ ។

ពិធីខែមិគសិរ

ខែមិគសិរ ពិធីមិគសិរវិធានម៍ (គឺពិធីបូជាទេវតារក្សានគរ) ថ្ងៃ ៥ កើតយកទង់ធំសម្រាប់ស្រុកទៅដោតនៅទីតាំង ៨ ទិសជុំវិញព្រះនគរ ហើយតែងគ្រឿងពលិកាអ្នកតាម្ចាស់ស្រុក និងទេវតារក្សាព្រះនគរ, ចំនួន ១០ ថ្ងៃ លុះគ្រប់កំណត់ថ្ងៃហើយ ក្នុងថ្ងៃទី ១០ ពាហានឡើងជិះសេះ ជិះដំរីលងដើងនៅមុខព្រះទីនាំងថ្វាយព្រះមហាក្សត្រទត បើត្រូវការធ្វើសឹកសង្គ្រាមនឹងប្រទេសណា ច្រើនតែលើកទៅក្នុងខែនេះ ។

ពិធីខែបុស្ស

ខែបុស្ស ពិធីបុស្សវិធានម៍ (គឺពិធីបូជាព្រះគង្គា) ថ្ងៃ ១ កើត ព្រះមហាក្សត្រនិងអាមាត្យមន្ត្រី ទៅធ្វើពិធីបូជាព្រះគង្គា ក្នុងទន្លេគង្គា ហើយអង្គុយបរិកម្មប្រលេះផ្កានៅមាត់ទន្លេគង្គា ១ ថ្ងៃពាល់ល្ងាច ។

ពិធីខែមាឃ

ខែមាឃ ពិធីមាឃវិធានម៌ (គឺពិធីយោលទោង) នៅថ្ងៃ ១៣ កើត យករូបព្រះឥសូរទៅដាក់ទោងយោលនិងធ្វើសក្ការបូជាទេវរូបនោះ ៣ថ្ងៃ ។

ពិធីខែផល្គុន

ខែផល្គុន ពិធីផល្គុនវិធានម៌ (គឺពិធីស្រោចទឹក) ថ្ងៃ ៥ កើត ព្រាហ្មណ៍រាជគ្រូចូលទៅស្រោចទឹកថ្វាយព្រះមហាក្សត្រ ព្រះអគ្គមហេសីនិងព្រះរាជបុត្រ ព្រះរាជធីតា គ្រានោះពួកអ្នកស្រុកយកទឹកស្រោចគ្នា សាចគ្នា និងយកផ្កាបោលគ្នា ដោយមិនមានប្រកាន់គ្នា ស្រេចហើយបបួលគ្នាទៅវត្ត ធ្វើសក្ការបូជាព្រះពុទ្ធរូប និងនិមន្តយតិឆាន់ ។

ឧ — ទេពពិទូរ ។

លោកនេយ្យកាព្យ

(តមក)

ឃើញដើមស្វាយនោះ លោលោតឡើងស្ទោះ លើចុងព្រឹក្សា ទឹកមន្តអាគម ឧត្តមបណ្ដា សែកសិល្បសាស្ត្រា ដូចគ្រូប្រដៅ ៗ ឯស្វាយផ្លែផ្កា ច្រើនឥតគណនា សន្ធោទុំខ្មៅ ជ្រុះមកដល់ដី ទុំខ្ចី ក្រាស់ក្រៅ មនុស្សម្នាចូលទៅ រើសបរិភោគា ៗ ឯក្សត្រត្រានត្រើយ សោយស្វាយស្រេចហើយ ប្រទានទ្រព្យា ទើបស្ដេចបន្ទូល សាស្ដូរទៅថា ចៅចេះពីណា មន្តនេះប្រពៃ ៗ ទេព្វសរកុមារ ស្ដាប់ព្រះឧង្ការ ក្សត្រក្សាន្តជេស្លដៃ ពុំថ្លែងដោយពិត ពុំទិត្យឡើយនៃ មុសាវាទក្រៃ ពុំពិតសត្យា ៗ ក្រាបថ្វាយបង្គំ ទើបទូលថាខ្ញុំ ស្វះស្វែងយាត្រា ត្រាច់ទៅសំណាក់ ទាល់តក្កសិលា រៀនពីទិសា—បាមោក្ខជាគ្រូ ។ ហេតុតែអន្ធពាល ល្មិលគុណគ្រូកាល—ណោះឯងឈ្មោះក្បូរ ក្បិណានោះទៀត ប្រាកមុខគ្រូ អង្គឲ្យអាស្រូវ សិល្បសាស្ត្រសូន្យសោះៗ

មានកាលមួយថ្ងៃ ស្ដេចត្រេកព្រះទ័យ ប៉ុនប៉ងចំពោះ ត្រាស់ឲ្យជប្បមន្ត ទេព្វគន់ស្នានស្មោះ ទេព្វសរកាលណោះ ជប្បថ្វាយក្សត្រា ៗ បៀមទឹកពេញមាត់ ពានឡើងដល់ថ្នាក់ លើចុងព្រឹក្សា ព្រួសចេញពីមាត់ បង់បាត់ផ្លែផ្កា មន្តសាបសោះសា ឥតពំនាក់ឡើយ ៗ កាលណោះមហាក្សត្រ បើកបន្ទូលថ្នាក់ ត្រាស់ថាចៅអើយ ពុំសំដែងមន្ត

ទំពួកទ់ព្រងើយ ខៈខុលៅអើយ សំងំធ្វើអ្វី ៗ បុរសស្ដែងស្ដាប់ អស់អាថិ
សារស័ព្ទ ព្រះបាទចក្រីទៀងទើបគន់គិត ក្នុងចិត្តថារ៉ឺ អញនឹងស្រដី
ដូចម្ដេចក៏ជា ៗ បើថ្លែងដោយពិត សមស្ដេចគន់គិត ថាអញនេះណា
កុហកលើសលន់ ពេកពន់សោះសា ខ្ញាសចិន្ដា គួរមុសាវ៉ាច ៗ
ទើបទូលទៅថា បពិត្រក្សត្រា សម្ដេចនរនាថ ពីមុនស្ដេចប្រើ ខ្ញុំធ្វើ
សង្គ្រាម ត្រូវឬក្សពុំឃ្លាត បានដូចប៉ុនប៉ង ៗ ស្ដេចស្ដាប់ហ្នោះហើយ
ពិតពុំលង់ឡើយ បន្ទូលសាសង ពីមុនព្រះស្ដែង ពុំថ្លែងទំនង រក
ឫក្សពារផង ប្រាប់អញឲ្យដឹង ៗ វ៉ៃក្រងព្រះស្ដែងធ្វើ ស្វាធ្យាយអំពើ
ទីទៃផ្សេងៗ ទឹងត្រូវប្រដៅ ដោយនូវដំណឹង មាននេះខុសដឹង ទើប
សាបមន្តនោះ ៗ ទំពួសស្ដាប់ហើយ ពុំអាចផ្ទាសឆ្លើយ នៅស្ងៀម
ស្ងួនស្រោះ ស្ដេចបន្ទូលទៀត ទំល្បៀតឆ្លើយដោះ ដោយដំណើរនោះ
ស្ដេចជ្រាបសេចក្ដី ៗ ទ្រង់ព្រះសរង្វេគ ស្ងប់ស្ងៀមឯងឯក ពុំមានមេត្រី
ស្ដេចបើកព្រះសូរ បន្ទូលរំងំខ្ញី ថាអាអប្រិយ អសារមន្តសោះ ៗ
ព្រះអង្គទេសនា សូត្រជាគាថា សូរស័ព្ទពីរោះ ជៀលល្អិតគុណត្រូ
អាស្រូវសូន្យសោះ បន្ទូលតែម៉្លោះ សូត្រជាគាថា ៗ

ឃរដ្ឋាបិ អដ្ឋសេបិ កសិធិការា ការបសុតិ ធុមធិការា
វនោហិតា ធុមុត្តមេ ៗ វៃហមហាជនផង នេះគឺទំនង បាលីបទ្វៃ

ថាយំធំពិត យំផ្ទិតស្ទិតឯ[១] ដើមឈើផ្លូវទេ លោកហៅឧត្តម គួរនាជួប
ធម៌ សិល្បសាស្ត្រសម្មា អ្នកហ៊ានមធ្យម បើមានបេះជ្រះ ជាក់ច្បាស់
លោកសម លោកហៅឧត្តម ប្រសើរវិញណា ៗ ព្រះបាទក្សត្រថ្លៃ
បន្ទូលប្លោះនៃ ទ្រង់ព្រះក្រោធា ត្រាស់ប្រើអាមាត្យ សង្កាត់ម៉ម្មា ឲ្យចាប់
ចង្កា លិ្ចលគុណគ្រូទៅ ៗ ធ្វើទុក្ខធ្វើទោស កុំឲ្យសន្តោស អាពោរគំ-
ទៀត អាមាត្យផងផាប់ ចូលចាប់នាំទៅ តាមក្សត្របមហៅ ត្រាស់ល្មើ
សិរសោ ៗ ត្រាស់ហើយបង្គាប់ ថាអាក្រឡាប់ ទៅឯគ្រូអា សង្កាត់រក
រៀន របៀនសាស្ត្រា ទើបមកទន្ទាក ប្រទេសនេះបាន ៗ រីឯអានោះ
ចរះចេញទៅស្លោះ សំដៅទៅឋាន គ្រូគ្រឡេកយល់ សិស្សដល់មកដ្ឋាន
ទៅរ៉ូយទៅមាន បើមករកអ្វី ៗ បុរសជំពប ទុនសំពះក្រាប ថាម្ចាស់
សិរសី ខ្ញុំជួបមនុស្សម្នាក់ ក្មេកខ្វាក់ដើរដី ពុំយល់ស្មើ ថ្ងស់ធ្លាក់ក្នុងជ្រោះ ៗ
សូមពានម្ចាស់ស្រង់ ស្វាធ្យាយជម្រង់ មន្តនោះសាបសោះ បណ្ដាល
មាណព ដឹងត្រប់ផ្លូវប្លោះ ថាឧអះឧះ ស្ដាយកុំប្រដៅ ៗ មានមន្តឯណា
ថ្ងៃកដ្រសួងពីគ្នា នេះអាគំទៀត ធម៌មន្តឲ្យរៀន របៀនជ្រះជ្រៅ អ្នកពាល
គំទៀត ពុំដែលថេរថិត ៗ មួយអ្នកកាន់កាច ពោលពាក្យកំណាច មួយ
អ្នកទ្រុស្តម៉ែត្រ មួយស្រដីកួត ពុំស្ងួតពាក្យពិត មួយគឺអ្នកឥត សីលសុទ្ធ
សត្យា ៗ មួយលិ្ចលគុណគ្រូ ទាំងប៉ុន្មាននេះគួរ បើអ្នកឯណា បេះហោះបេះ

---

១ ច្បាប់ខ្វះថា "យំធំយំផ្ទិត បើស្ទិតឯរឯ" ។

ធមិ សព្វសិល្បសាស្ត្រ បេះមន្តក្រិត្តិកា សាបសោះឥតត្រើយ ៗ ទិព្វសរ
កុមារ ស្តាប់ពាក្យអាចារ្យ ទូន្មានទោះហើយ ថាខ្លួនអសារ ឥតការ
ឥតត្រើយ ពុំចង់រស់ឡើយ ចូលស្នាក់ក្នុងព្រៃ ៗ មហាសត្វនាំទ-
ពានថ្លែងអំពី និយាយនោះនៃ ទើបទូលព្រះមហា — ក្សត្រាជេស្ឋជ័យ
នេះឯងក្សត្រថ្លៃ អ្នកល្មិលគុណគេ ៗ ទេព្តាបាក មុខមានទុក្ខា ឥត
ឯល្ហើយល្ហែ មានទុក្ខនោះធ្ងន់ ពិតពុំទំនេ បេះភ្លេចគុណគេ បានបាប
ធ្ងន់ក្តាត់ ៗ សេនាបតី ស្តាប់ពាក្យពោធិ៍ អៀនអាក់អន់ចិត្ត រំជួលក្នុង
ថ្លើម ជង្ហើមក្តៅក្តាត់ ទូលថាបពិត្រ សម្តេចក្សត្រា ៗ ហេតុធនញ្ជ័យនេះ
ចិត្តធំជៀលគេ ដែលខ្ញុំករុណា អញ្ជាខ្ញុំសូមកាប់ សម្លាប់ខ្លួនវា ស្តេច
ស្តាប់សេនា–បតីនោះហើយ ៗ សៀមចូលទៅក្នុង ប្រាសាទរម-គ្គល
គន់ព្រងើយ សេនាបតី ចុះពីគាល់ហើយ ខេរខឹងឥតស្បើយ ទៅ
ឋានគ្រឹះហា ៗ និទានតាយថែង បរបាថ្លាថ្លែង ពីអាចិប្រែស្នា អ្នក
ភ្លេចគុណគេ បន្ទូគាថា ស្មុរេចពណ៌នា ដំណើរម្ល៉េះហោង ៗ

បទពុំនោលថ្លែងទំន ពោធិ៍ច្បាស់ច្បង ប្រាំមួយជណ្តប់ធ្លាំហើយ
សេនាបតីឥតត្រើយ ខេរខឹងពុំស្បើយ កំឡើងទៅគាល់ក្សត្រា ៗ
ក្រាបថ្វាយបង្គំទូលថា បពិត្រព្រះមហា- កជអើយរកជការផង ៗ
ថ្ងៃក្រោមពីមុនមកហោង មួយអ្នកទ្រើសឃ្លង មានកាតុភាពមហិមា ៗ
មួយអ្នកឈ្មោសវៃអគ្យា- ស្រ័យសារបញ្ហា មួយគឺបំពោតវិលវល់ ៗ

មួយគឺលេះលោះធ្វើកល លោកថាបុគ្គល ទាំង ៤ ជំពូកនេះណា ៗ
លោកប្រើក្សត្រៃអស់ក៏ នេះពុំយកជា អាមាត្យជំនិតស្និទស្នោះ ៗ
ឲ្យក្សត្រសម្លាប់ក៏នោះ បើពុំដូច្នោះ ឲ្យដាក់ច្រក់ក់គាពង ៗ ដាក់គុក
ចាក់សោខ្នោះឃ្នាង ឲ្យក៏បានពង បណ្ដេញចេញពីនគរ ៗ បពិត្រថ្លៃ
ក្រោមកូជរ ធនញ្ជ័យកូតករ កុហកព្រះបាទក្សត្រា ៗ ហើយចេះបំ-
ពោតមាយា បពិត្រក្សត្រា ស្ដេចឲ្យសម្លាប់ត្រូវគាប់ ៗ បើព្រះអង្គពុំ
សម្លាប់ សមក៏ទីងកាប់ ព្រះអង្គអម្ចាស់វិញណា ៗ ស្ដេចស្ដាប់សារស័ព្ទ
ក៏ថា ព្រួយព្រះចិន្ដា ភិតភ័យពេកពន់កន្លង ៗ ហើយបើកបន្ទូលសាសង
ឈ្មោះយើងប៉ុនប៉ង បំណងគំនិតគិតម្ដេច ៗ បើយើងសម្លាប់ពុំស្រេច
ក៏ប្រែគិតគេច វិលមកសម្លាប់យើងវិញ ៗ ទោះយើងចំបរបណ្ដេញ
ក៏ចរចាកចេញ ទៅឯប្រទេសទៃទៀត ៗ នឹងនាំសត្រូវមកបៀត ឲ្យ
ខូចបង្អៀត ឥតការអសារសូន្យសោះ ៗ គិតគួរស្វះស្វែងមើលទោះ
មន្ទិលទោសនោះ ខុសហើយយើងធ្វើទោសបាន ៗ ធម្មតាអ្នកប្រាជ្ញ
បើមាន ទោសទាស់ទាល់ប្រាណ សឹងដឹងកំហុសអាត្មា ៗ ហេតុនោះ
អស់យើងគ្រប់គ្នា ស្វះស្វែងទោសក៏ ឲ្យបានលុះកណ្ដាប់ដៃ ៗ សេនា-
បតីអរព្រៃ ក្រោដលាវិលវៃ មកដល់មណ្ឌលអាត្មា ៗ ចាប់ដើមពីនោះ
ក្សត្រា អាមាត្យសេនា- បតីឃ្លាំទោសមហាសត្វ ៗ លោកថាបើ
ស្រឡាញ់បាត់ ផ្គាំផ្គងខុសខាត ប៉ុន្មានសឹងជាគាប់វិញ ៗ បើស្អប់

មែនមិនស្រឡាញ់ ផ្គាប់ប៉ុន្មានវិញ សឹងជាប្រែខុសវិញស្មោះ ៗ ពោ-
ធិសត្វសោកដឹងខ្លោះ ពិតពីទោសនោះ អ្នកមិនស្រដីឡើយហោង ៗ
ទោះអ្នកឡើងគាល់ម្តងៗ អស់នរអ្នកផង សំងំពុំហានចរចា ៗ ពុំយល់
កំហុសទោសា ប្រាំពីរទិវា វែងអស់កវបណ្ឌិត ៗ ទាំងបីមិញប្រែភ័យគិត
ប្រយ័ត្នគំនិត ខ្លាចខុសឯខ្លួនឯងវិញ ៗ មានកាលមួយថ្ងៃស្តេចចេញ ផ្ទៃ
ពេជធំមិញ សេនាមន្ត្រីបរិពារ ៗ គង់គាល់អនេកជាសជា ជួបជួន
អាចារ្យ ទាំង ៤ ឡើងគាល់ក្សត្រា ៗ ស្តេចថប់បទសៀមគ្រប់គ្នា បើក
បន្ទូលថា អាចារ្យម្តេចមិនស្រដី ៗ ម្តាយបង្កើតព្រះស្តែងពី មុនមកបទអ្វី
ឲ្យរៀនច្បាប់សៀមប្តូរម្តេច ៗ បណ្ឌិតទាំងបីយល់សេច- ក្តីច្បាប់ជាកិច្ច
ទូលឲ្យតែរូបអាត្មា ៗ ស៊ុន្ទរពល័យទូលថា បពិត្រក្សត្រា ខ្ញុំចេះច្បាប់មួយ
ផ្សំថ្នាំ ៗ ឈ្មោះបញ្ចប័ត្រឈើទាំងប្រាំ យកស្ងួតផ្សំថ្នាំ ឲ្យមានអាយុយឺន
ក្រែ ៗ គឺស្ងួតរលួសមួយនៃ ស្ងួតខ្ញីវិស័យ មួយស្ងួតកន្ទ្រីស្ងួតស្តៅ ៗ
ស្ងួតកញ្ជ្រុកដូចម៉េច្ឆ ទាំងប្រាំនេះហៅ ថ្នាំពិសេសសុទ្ធគ្នាគណា ៗ ឲ្យ
ស្ងួតឲ្យធ្វើជាគុលិកា លេបសព្វទិវា ប្រែជាអាយុវែងវិញ ៗ រីច្បាប់ខ្ញុំឯងនេះ
មិញ ដូចអ្នកស្រឡាញ់ បាបបាយឲ្យអាយុមាន ៗ ស្តេចស្តាប់ដណ្តឹង
ទៅថ្កាន ឥដ្ឋារម្មណ៍មាន ច្បាប់នោះដូចម្តេចព្រះស្តែង ៗ ឥដ្ឋារម្មណ៍
បន្ទូលថ្លែង បពិត្រខ្ញុំឯង ខ្ញុំចេះច្បាប់ដេកវិញណា ៗ បើប្រែក្បាលទៅ
បូព៌ា នូវមានប្រាជ្ញា ក្រៃលែងអ្នកផងទាំងឡាយ ៗ បែរទៅទិស

ទក្សិណសាយ អាយុវែងឆ្ងាយ បើប្រែទៅទិសឯលិច ។ កើតទុក្ខក្តៅ
ចិត្តបន្តិច អពមង្គលកិច្ច កើតទុក្ខអង្គអនាថ ។ ទោះប្រែក្បាលទៅ
ឧត្តរ ទៀងនឹងតែនឹងមរណ៍ ស្លាប់ឆាប់ប្រាកដពុំលែង ។ ទើបស្តេចបើក
បន្ទូលថ្លែង ថាអត្ត័យឯង ព្រះស្តែងតើចេះច្បាប់អ្វី ។ អត្ត័យបណ្ឌិត
ទូលថា ខ្ញុំចេះច្បាប់ធំ- បាយ ហើយក៏ដេកនឹងឆាត់ ។ ហូបបាយហើយ
ដោះទៀងថ្វាត់ កំឡាំងច្រើនក្កាត់ ឥតអ្នកឯណាស្មើឡើយ ។ ហូបបាយ
ដើរចង្ក្រមហើយ ប្រសើរជាត្រើយ នឹងមានអាយុវែងក្រៃ ។ ហូបបាយ
ហើយតែវិលវៃ អ្នកនោះឯងនៃ នឹងស្លាប់ឆាប់ក្រៃក្កាត់ណា ។ មួយសោត
ដូចដេកវិញជា ប្រែទៅបូព៌ា នឹងមានអាយុយឺនក្រៃ ។ ប្រែទៅឯត្បូង
នោះនៃ មានទ្រព្យប្រពៃ ប្រែទៅឯលិចនោះណា ។ នឹងមានកិត្តិយស
សក្តា ប្រែទៅឧត្តរ នឹងស្លាប់វិនាសឥតត្រើយ ។ ស្តេចស្តាប់សារស័ព្ទ
ហ្នោះហើយ ពិតពុំលង់ឡើយ ថាធនញ្ជ័យតើចេះម្តេច ។ កាលណោះព្រះ
ពង្សពោធិ-សត្វសារបារមី ពន្ធកពង្សពុទ្ធសាស្តា ។ គន់គិតក្នុងចិត្ត
ឯងថា អញយកធម្មា ទូន្មានសឹងថាជាខុស ។ អស់នេះសឹងឥតសប្បុរស
ត្រូវថាជាខុស ខុសហើយយកមកថាត្រូវ ។ ទូលថាបពិត្រព្រះភូ-បាល
ខ្ញុំឥឡូវ ចេះច្បាប់ប្រាំពីរប្រការ ។ ស្តេចស្តាប់ហើយព្រះភូបាល ត្រាស់
ថាអាចារ្យ ច្បាប់នោះតើហេតុដូចម្តេច ។ ទៅថ្លែងសំដែងសេចក្តី
ឲ្យដឹងកលកិច្ច ដំណឹងដំណើរនោះណា ។ ពោធិសត្វក្រាបទូលថា

បពិត្រធម្មតា ស្រីក្រមុំទាំងឡាយ ។ បើមានអន្ទកសេហាយ ស្អប់នៃក្តី ណាយ នៅថ្ងៃសីងជិនណាស់ណា ។ ចង់តែងនិតសន្សា នោះឯង ថាជា ប្រសើរឯស្រីអប្បលក្ខណ៍ ។ រីអ្នកកំឡោចស្អប់អ្នក ពាហាន សិទ្ធិស័ក្តិ មួយគឺអ្នកខ្សត់នោះណា ។ ស្អប់នៃអ្នកមានទ្រព្យា មួយ ទៀតណា ស្អប់នៃអ្នកមានប្រាជ្ញប្រាយ ។ មួយអ្នកទុជិនទាំងឡាយ សីងស្អប់ជិនណាយ នៃអ្នកសប្បុរសប្រពៃ ។ មួយគឺអាមាត្យក្សត្រថ្ងៃ ជ្រោមស្អប់ជិននៃ អ្នកគាប់ទឹងម្ចាស់សិរសា ។ នេះហៅវត្តប្រាំពីរ ប្រា- ការត្រួតក្សត្រា ស្តេចជ្រាបដំណើរសេចក្តី ។ កាលណោះសេ- នាបតី ស្តាប់ពាក្យពោធិ - សត្វហើយក៏ត្រេវត្រាធក្រៃ ។ ខាំមាត់ ហើយលាត់ទាំងដៃ- អារទើបថាហៃ ធនញ្ជ័យម្តេចថាដូច្នោះ ។ ទៅ ថាយើងស្អប់ទៅនោះ បទៅបេះដោះ បេះផ្គាប់ព្រះបាទក្សត្រា ។ ថាយើងជ្រោមស្អប់គ្រប់គ្នា ទៅឯងទៅជា អ្នកសប្បុរសប្រពៃ ។ ទៅផ្គាប់ត្រូវព្រះហឫទ័យ អស់យើងសព្វថ្ងៃ ទៅថាយើងស្អប់ទៅណា ។ ពោធិស្តាប់ហើយឆ្លើយថា ឱអ្នកសេនា-បតីអើយពាក្យអញនេះ ។ អញ ពុំស្រដីបទះបេះ ហើយរកកលរេះ អាស្រ័យដោយយោបល់ថ្លៃង ។ ឱសេនាបតីឯង ជាអ្នករង្វេង ខ្ទេចខ្ទង់ឈ្មោះពិតណា ។ ព្រះបន្ទូល ជាធម៌ថា ឥតសប្បុរសា យល់គេមានទុក្ខអវៃក្រ ។ មួយបើយល់គេ មានភ័យ បង់ទ្រព្យទីទៃ ក៏អរឥតឯឱបមា ។ មួយបើយល់គេឈ្មោះគ្នា

អវេងវែងសោះសា ហេតុចិត្តអន្ទះអាលពេកក្រៃ ។ អ្នកកាចរុជិនចរស្រៃ
មានឈ្មោះមួយថ្ងៃ សរស្រៃសរស្រើនចិន្តា ។ អ្នកកាចដួចបន្ទា ត្រូវត្រង់
បាតា កម្មុតចេញឈាមសស្រាក់ ។ បើការបន្ទាឲ្យពាក់ ស្បែកជើងដើរ
ជាក់ ដាទំលើឲ្យល្អិតស្ងួនស្រះសោះ ។ អ្នកកាចចិត្តចង់ស្មានស្មោះ ពិយាជ
គេនោះ ស្មានជីវិតឯងវែងក្រៃ ។ សំបានមួយពាន់ឆ្នាំទៃ ពុំដឹងទំនង់ក្ស័យ
ទង់ធ្លាក់ទៅឋានអវិចី ។ បើការអ្នកកាចអប្រិយ លោកឲ្យបៀសពី
បំផ្លាយឲ្យធ្លាយឲ្យដាច់ ។ សេនាបតីស្តែងស្គាប់ អស់សាបីសារស័ត្វ
រើងខ្លាចអំណាចអ្នកហោង ។ ពុំបានស្រដីសាសង នៅស្ងៀមជាម្តង
អគ្គិយពត្ថិះសោះសា ។ កាលណោះឯមហាក្សត្រា កិតភ័យតក្កមា
ក៏ចូលទៅក្នុងប្រាសាទ ។ មាសម័យសន្លៅស្អាងស្អាត ត្រែះរះសន្ធាត
មើលមហាបុរសសេដ្ឋោ ។ បសំសានិបញ្ហោ វនិដ្ឋគោ រ័ប្រស្នា
ច្បាប់ចប់ម៉្មេះហោង ។

(មានត)

ប្រវត្តិពុទ្ធសាវិកា

វិសាខា-មិគារមាតា — ជាអ្នកស្រុកភទ្ទិយៈនៅដែនអង្គៈ ជាកូនធនញ្ជ័យសេដ្ឋី ទំនងនាងសុមនទេវី ត្រូវជាចៅរបស់មេណ្ឌកសេដ្ឋី ។ លុះនាងវិសាខា មានអាយុបាន ៧ ឆ្នាំ ព្រះបរមសាស្តាស្តេចទៅនគរនោះ វេលានោះមេណ្ឌកសេដ្ឋី បានដឹងដំណឹងថា ព្រះទសពលស្តេចមកដល់ស្រុករបស់ខ្លួន ទើបផ្តាំឲ្យនាងវិសាខាទៅទទួលព្រះអង្គ ។ សម្តេចព្រះបរមសាស្តាទ្រង់ទេសនាប្រោស នាងបានសម្រេចសោតាបត្តិផល កាលស្តេចចូលទៅដល់ស្រុកភទ្ទិយៈហើយ មេណ្ឌកសេដ្ឋីក៏ចូលទៅគាល់ បានស្តាប់ព្រះធម្មទេសនាបានសម្រេចសោតាបត្តិផលដែរ លោកធ្វើទានយ៉ាងធំថ្វាយព្រះអង្គជាវេលាកន្លះខែ ឯព្រះបរមសាស្តា ស្តេចប្រថាប់ល្មមសមគួរនឹងពុទ្ធអធ្យាស្រ័យហើយក៏ស្តេចចៀសចេញទៅ ។

ឯព្រះបាទកោសលរាជនៃក្រុងសាវត្ថី បានចាត់ផ្ញើព្រះរាជសារទៅថ្វាយព្រះបាទពិម្ពិសារ មានសេចក្តីថា សេដ្ឋីដែលមានទ្រព្យសម្បត្តិរាប់ប្រមាណមិនបាន ក្នុងស្រុករបស់ទូលបង្គំជាខ្ញុំឯណោះមិនមានឡើយ តែក្នុងស្រុករបស់ទ្រង់មានច្រើន ដូច្នេះសូមទ្រង់ប្រទានត្រកូលសេដ្ឋីទៅឲ្យទូលបង្គំជាខ្ញុំខ្លះផង ។ ឯព្រះបាទពិម្ពិសារ កាលបានទទួលព្រះរាជសារក៏ទ្រង់ប្រឹក្សានឹងពួកអាមាត្យរាជបរិពារសេដ្ឋីគហបតីទាំងពួង ទីប្រជុំសម្រេចថា ត្រូវបញ្ជូនធនញ្ជ័យសេដ្ឋី ជាបុត្ររបស់មេណ្ឌកសេដ្ឋីឲ្យទៅ

ទើបឲ្យធ្វើព្រះរាជសារតបទៅព្រះបាទកោសលរាជ ព្រះបាទកោសលរាជក៏មានព្រះទ័យត្រេកអរ ហើយទ្រង់ព្រះរាជទានស្រុកសាកេត មានចំងាយពីស្រុកសាវត្ថី ៧ យោជន៍ដល់ធនញ្ជ័យសេដ្ឋី ។

នៅក្រុងសាវត្ថី មានបុត្ររបស់មិគារសេដ្ឋីម្នាក់ឈ្មោះបុណ្ណវឌ្ឍនកុមារ លុះចំរើនវ័យឡើង បិតាគិតរកភរិយាឲ្យសម្រាប់ជាគូគ្រងតាមទំនៀមយកកស ហើយឲ្យស្វះស្វែងរកកូនប្រសារហូតទៅដល់ស្រុកសាកេត ពេញចិត្តនឹងនាងវិសាខា ជាធីតារបស់ធនញ្ជ័យសេដ្ឋីទើបចាត់ចែងជណ្តឹងតាមរបៀប លុះព្រមព្រៀងគ្នាហើយ ទើបចាត់ចែងរៀបមង្គលការ នៅស្រុកសាកេតនោះ ។ ការរៀបមង្គលការគ្រានោះ រៀបចំធ្វើយ៉ាងអឹកធឹកមហោឡារ ព្រះបាទបសេនទិកោសល ស្តេចយាងទៅជាអធិបតីក្នុងមង្គលការនោះដែរ ។ ធនញ្ជ័យសេដ្ឋីបានរៀបចំទទួលទ្រង់សមព្រះកិត្តិយសគ្រប់ប្រការ មុននឹងបញ្ជូននាងវិសាខាទៅកាន់ត្រកូលស្វាមី បានឲ្យឪវាទ ១០ ខ មានសេចក្តីថា :

១. ភ្លើងខាងក្នុងកុំនាំចេញ ។

២. ភ្លើងខាងក្រៅកុំនាំចូល ។

៣. កាលបើគេឲ្យគោងឲ្យតប ។

៤. កាលបើគេមិនឲ្យកុំឲ្យ ។

៥. កាលបើគេឲ្យក៏ដោយ មិនឲ្យក៏ដោយគោងតែឲ្យ ។

៦. គប្បីអង្គុយឲ្យសប្បាយ ។

៧. គប្បីបរិភោគឲ្យសប្បាយ ។

៨. គប្បីដេកឲ្យសប្បាយ ។

៩. គប្បីបំរើភ្លើង ។

១០. គប្បីសំពះទេវតាខាងក្នុងផ្ទះ ។

ឱវាទ ១០ ខនេះមិគារសេដ្ឋី អែបស្តាប់បានឮដែរ លុះព្រឹកឡើង លោកធនញ្ជ័យសេដ្ឋីឲ្យប្រជុំពួកពលបរិវាររួចតាំងកុដុម្ពី ៨ នាក់ទុកសម្រាប់ជំនុំជម្រះទោសានុទោសរបស់ធីតា លុះធ្វើមង្គលពិធីរួចស្រេចហើយ ទើបបញ្ជូនធីតាទៅកាន់ត្រកូលរបស់ប្តីព្រមទាំងភោគសម្បត្តិ និងបរិវារប្រុសស្រីជាចំនួនច្រើន ។ ឯនាងវិសាខាបានប្រដាប់ដោយគ្រឿងប្រដាប់ហៅថាមហាលតាប្រសាធន៍ ដែលមានថ្លៃដល់ ៩ កោដិ ។ នាងវិសាខាទៅកាន់ត្រកូលស្វាមីគ្រានោះ មហាជនអ្នកក្រុងសាវត្ថីមានសេចក្តីបីតិត្រេកអរណាស់ ឯនាងវិសាខាក៏បានធ្វើបដិសណ្ឋារៈ នឹងមហាជនដោយកិរិយាសុភាពទន់ភ្លន់ ហើយឲ្យបណ្ណាការតបដល់អ្នកដែលនាំបណ្ណាការមកជូនទាំងប៉ុន្មានរៀបរយគ្រប់ប្រការ ។

ក្នុងយប់នោះ មេលាបានសម្រាលកូនឧបកជាសេះអាជានេយ្យ ទើបនាងវិសាខានាំទាសីចុះទៅជួយក្នុងការសម្រាលកូននៃមេលានឹងកូនរបស់វានោះ ។

ឯលោកមិគារសេដ្ឋី ជាពួកមិច្ឆាទិដ្ឋិ លុះរៀបមង្គលការហើយ ត្រឡប់មកដល់ក្រុងសាវត្ថី ក្នុងទៅបាន ៧ ថ្ងៃ ក៏ចាត់ចែងនិមន្តសមណៈអាក្រាតជាច្រើនមកធ្វើភត្តកិច្ចក្នុងផ្ទះ ហើយឲ្យហៅនាងវិសាខាជាកូនប្រសាមកសំពះសួរ ។ នាងវិសាខាបានមកឃើញ ក៏មិនមានសេចក្តីជ្រះថ្លា ហើយត្មះតិះដៀលថាជាមនុស្សមិនមានហិរិឱត្តប្បៈ មិនមែនជាសមណៈទេ ចុះបិតាឲ្យហៅខ្ញុំមកធ្វើអ្វី ហើយនាងក៏ត្រឡប់ទៅវិញ ។ ពួកសមណៈអាក្រាតបានឃើញដូច្នោះ ក៏នាំគ្នាត្មះតិះដៀលជាច្រើន ហើយណែនាំពន្យល់ឲ្យសេដ្ឋីបណ្តេញកូនប្រសាកាឡកណ្ណីនោះចេញទៅ ។ ឯមិគារសេដ្ឋីមិននិយាយថាអ្វីគ្រាន់តែនៅស្ងៀម ហើយបញ្ជូនសមណៈអាក្រាតអស់នោះឲ្យត្រឡប់ទៅវិញ កាលសេដ្ឋីបរិភោគអាហារដោយខ្លួនឯង នាងវិសាខាក៏ចាត់ចែងបំរើដោយល្អ ។

ខណៈនោះ មានព្រះថេរមួយអង្គដើរបិណ្ឌបាតមកឈរនៅមាត់ទ្វារផ្ទះរបស់សេដ្ឋី ។ នាងវិសាខាបានឃើញគិតថា អញមិនគួរជំពបឪពុកក្មេកទេ ហើយថយទៅបន្តិច ដើម្បីឲ្យសេដ្ឋីបានឃើញ ។ មិគារសេដ្ឋីបានឃើញហើយ ធ្វើព្រងើយ ហើយធ្វើជាឈ្លោតបរិភោគអាហារទៅ នាងវិសាខាឃើញថា លោកនៅរង់ចាំយូរពេកទើបពោលទៅនឹងព្រះថេរៈថា និមន្តប្រោសសត្វទៅខាងមុខចុះលោកម្ចាស់ ឪពុកក្មេកខ្ញុំករុណាលោកបរិភោគតែបុណ្យចាស់ទេ ។

លុះបានឮពាក្យនោះ មិគារសេដ្ឋីក៏លាស់ដៃលែងបរិភោគអាហារភ្លាម ហើយបញ្ចេញវាចាបណ្ដេញនាងវិសាខាឲ្យចុះចេញពីផ្ទះ ព្រោះសេដ្ឋីបានទំអត់សង្កត់ចិត្តមិននិយាយស្ដី តាំងអំពីគ្រាដែលពួកនិគ្រន្ថយល់ទាស់មកម្ដងហើយ តែម្ដងនេះទំអត់សង្កត់ចិត្តទៅទៀតពុំបាន ទើបសេដ្ឋីចោទទោសនាងវិសាខាថា នាងពោលពាក្យដៀមដាមថាខ្ញុំស៊ីអសុចិ ជាការមើលងាយប្រមាថយ៉ាងខ្លាំង ៗ តែពួកខ្ញុំកម្មករនៅផ្ទះនោះ គ្មាននរណាហ៊ានធ្វើតាមបង្គាប់សេដ្ឋីឡើយ ឯនាងវិសាខាដដែលតវ៉ាថា បើដូច្នោះឲ្យហៅកុដុម្ពីទាំង ៨ នាក់ដែលបិតានាងបានតាំងមកឲ្យមើលការខុសត្រូវ ៗ លុះមិគារសេដ្ឋីបានអញ្ជើញកុដុម្ពីទាំង ៨ នាក់មកហើយ ទើបប្ដឹងដល់ក្រុមជំនុំជាទដំបូងថា នាងវិសាខាបានជេរខ្ញុំថាជាអ្នកស៊ីអសុចិ ៗ នាងវិសាខាបានដោះស្រាយថា ថ្ងៃដែលកើតរឿងនោះ នាងកំពុងជប់លៀងសេដ្ឋីស្រាប់តែមានភិក្ខុមួយអង្គ ដើរបិណ្ឌបាតចូលមកឈរនៅមុខផ្ទះនឹងដំពបសេដ្ឋីក៏នឹកក្រែងចិត្ត ងើបថយចេញទៅបន្តិចដើម្បីឲ្យលោកបានឃើញ លោកបានឃើញហើយត្រឡប់នាំធ្វើព-ងើយក្រែងលោករង់ចាំយូរពេកទើបពោលទៅថា សូមលោកម្ចាស់និមន្តទៅប្រោសសត្វខាងមុខ បិតាក្មេករបស់ខ្ញុំករុណាលោកពិសាតែបុណ្យចាស់ទេ ឯពាក្យថាបុណ្យចាស់នេះ មានសេចក្ដីអធិប្បាយថា លោកឪពុក

បានធ្វើបុណ្យទុកពីជាតិមុន ទើបបានធ្វើជាសេដ្ឋីក្នុងជាតិនេះ លោកបរិភោគតែទ្រព្យសម្បត្តិ ដែលធ្វើទុកពីជាតិមុនប៉ុណ្ណោះ ក្នុងជាតិនេះលោកមិនសន្សំធ្វើទុកតទៅទៀតទេ ។

កុដុម្ពីទាំង ៨ នាក់គាត់សេចក្ដីថា នាងវិសាខាមិនមានខុស ។ ឯមិគារសេដ្ឋីបានចោទទោស ខពីរតទៅទៀតថា កាលដែលថ្ងៃមកដល់នោះ នាងវិសាខាមិនរវល់នឹងគូនរបស់ខ្លួនទេ ចេះតែទៅណាមកណាតាមទំនើងចិត្ត ។

នាងវិសាខាពោលដោះស្រាយថា ក្នុងថ្ងៃដែលមកដល់នោះវេលាយប់ មេលាសម្រាលកូនសេះអាជានេយ្យ ខ្ញុំបានចុះទៅជួយព្យាបាលឲ្យវាសម្រាលបានដោយស្រួល ទាំងវេលានោះក៏មានពួកទាសីជាច្រើននាក់ចោមរោមទៅជួយជាមួយផង នឹងថាខ្ញុំចុះទៅដោយទំនើងចិត្តតែម្នាក់ឯងដូចម្ដេចបាន ។

មិគារសេដ្ឋីក៏ពោលលើកទោសតទៅទៀតថា កាលនឹងត្រឡប់មកនោះ លោកធនញ្ជយសេដ្ឋី បានឲ្យឱវាទ ១០ ខមានសេចក្ដីដូច្នេះខ ១ ថាភ្លើងខាងក្នុងកុំឲ្យនាំចេញ គឺថាគ្រាន់តែភ្លើង មិនព្រមឲ្យអ្នកផ្ទះជិតខាងខ្ញុំមិនអាចធ្វើដូច្នោះបានទេ ។ ខ ២ ថាភ្លើងខាងក្រៅកុំឲ្យនាំចូលមក គឺថាបើភ្លើងក្នុងផ្ទះរលត់ មិនព្រមឲ្យយកភ្លើងក្រៅផ្ទះមកប្រើទេឬ ។

នាងវិសាខាថា ខ ១ ដែលថា ភ្លើងក្នុងកុំនាំចេញ ភ្លើងក្នុងនេះ សំដៅយកមនុស្សខាងក្នុងផ្ទះ រាប់តាំងអំពីឪពុកក្មេកម្ដាយក្មេកនិងស្វាមីជាដើម ព្រោះជាមនុស្សដែលគួរគោរពកោតក្រែងទុកដូចជាភ្លើង បើអ្នកអស់នេះនិយាយការសម្ងាត់អ្វីមួយ មិនត្រូវស្រីជាកូនប្រសានាំយកចេញទៅផ្សាយខាងក្រៅផ្ទះទេ ។ ខ ២ ដែលថាភ្លើងក្រៅកុំនាំចូលនោះ គឺសំដៅដល់រឿងដែលអ្នកក្រៅផ្ទះនិយាយគ្នា មានពាក្យនិន្ទាចាក់ដោតមនុស្សខាងក្នុងផ្ទះជាដើម ស្រីជាកូនប្រសាមិនត្រូវនាំចូលមកផ្សាយខាងក្នុងផ្ទះទេ នាំឲ្យកើតជំលោះទាស់ទែងគ្នាឥតប្រយោជន៍ ។ តអំពីនេះទៅជាសេចក្ដីដោះស្រាយរបស់នាងវិសាខា ក្នុងខតទៅជាលំដាប់ ។

១៣– ថាកាលបើគេឲ្យសឹមឲ្យតប គឺថាបើអ្នកណាខ្ចីរបស់យើង ហើយគេយកមកសងយើងវិញ ដល់គេមកខ្ចីទៀត យើងគោងឲ្យទៀតដែរ ។

១៤– ថាកាលបើគេមិនឲ្យកុំឲ្យ គឺបើគេខ្ចីរបស់យើងគេមិនយកមកសងយើងវិញ ដល់មកខ្ចីក្រោយទៀតកុំឲ្យ ។

១៥– ថាកាលបើគេឲ្យក៏ដោយ មិនឲ្យក៏ដោយ យើងត្រូវតែឲ្យ គឺញាតិមិត្តអ្នកទីទាល់ក្រមកដល់ គេមិនអាចឲ្យអ្វីមកយើងទេ យើងគួរជួយទំនុកបំរុង ឲ្យរបស់ផ្សេងៗទៅគេចុះ ដល់គ្រាក្រោយ គេឲ្យក្ដីមិនឲ្យក្ដី មិនបាច់ទារគ្នាទេ ។

១ ៦- គប្បីអង្គុយជាសុខ គឺកាលបើឃើញឪពុកក្មេកក្តី ម្តាយក្មេកក្តី ប្តីក្តី គប្បីអង្គុយកន្ទុយជើងសមគួរ បើត្រូវក្រោកទទួលក៏គង់ក្រោកទទួល មិនត្រូវអង្គុយធ្វើព្រងើយទេ ។

១ ៧- ជាគប្បីបរិភោគជាសុខ គឺមិនត្រូវបរិភោគអាហារមុនឪពុកក្មេក ម្តាយក្មេក និងប្តីទេ ត្រូវជប់លៀងលោកអស់នេះឲ្យរួចសិន សឹមបរិភោគខ្លួនឯងជាខាងក្រោយ ។

១ ៨- ជាគប្បីដេកជាសុខ គឺកូនប្រសាមិនត្រូវចូលដេកមុនឪពុកក្មេក ម្តាយក្មេក និងប្តីទេ គង់ចាត់ចែងការងារឲ្យរួចស្រេច សឹមចូលដេកជាក្រោយ ។

១ ៩- ជាគប្បីបំរើភ្លើង គឺគប្បីសំគាល់ឪពុកក្មេក ម្តាយក្មេក និងប្តី ទុកដូចជាគងភ្លើង ឬស្តេចនាគរាជ កូនប្រសាស្រីត្រូវគោរពកោតក្រែងឲ្យច្រើន ។

១ ១០- ជាគប្បីឱនលំទោន ដល់ទេវតាខាងក្នុង គឺកូនប្រសាស្រីគប្បីសំពះ សំដែងសេចក្តីគោរពចំពោះឪពុកក្មេកម្តាយក្មេក និងប្តី ដែលទុកដូចជាទេវតានៅក្នុងផ្ទះខ្លួនឯង ។

កុដុម្ពីទាំង ៨ នាក់ជំនុំជំរះកាត់ឲ្យនាងវិសាខារួចពីពាក្យទោសគ្រប់ប្រការ នៅទីបំផុត សេដ្ឋីបានសូមខមាទោសនាងវិសាខា តែនាងថ្លែងសេចក្តីថា នាងក៏ព្រមទទួលខមាលុះត្រាតែសេដ្ឋីអនុញ្ញាត ឲ្យនាងធ្វើ

បុណ្យកុសលតាមសទ្ធារបស់ខ្លួន ៗ មិគារសេដ្ឋីក៏ព្រមអនុញ្ញាត តមកនាង វិសាខាបានក្រាបទូលនិមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រមុខ ដើម្បីទទួល បិណ្ឌបាតក្នុងផ្ទះរបស់ខ្លួន នៅឱកាសបុណ្យនេះ នាងវិសាខាបានអញ្ជើញ មិគារសេដ្ឋី ឲ្យមកស្តាប់ព្រះធម្មទេសនាផង ៗ ដំបូង លោកមិគារសេដ្ឋី សំដែងកិរិយារឹងរូសដល់ព្រះបរមសាស្តា តែដោយសេចក្តីក្រែងចិត្តកូន ប្រសាទើបមកតាំងបង្ខំ ហើយអង្គុយអែបស្តាប់ធម៌ ពីខាងក្រៅកាំងនន ៗ សម្តេចព្រះបរមសាស្តា ទ្រង់ជ្រាបហេតុការណ៍នោះទាំងអស់ ទើប ទ្រង់សំដែងធម៌ដម្រូវចបនិស្ស័យរបស់សេដ្ឋី នៅទីបំផុតព្រះធម៌ទេ-សនា មិគារសេដ្ឋីបានសម្រេចសោតាបត្តិផល ទើបញែកកាំងននចេញ ក្រៅ ហើយថ្វាយបង្គំព្រះបរមសាស្តា ហើយពោលទៅចំពោះកូនប្រសា ថា តាំងអំពីថ្ងៃនេះជាដើមទៅ ឪពុកនឹងតាំងកូនជាម្តាយរបស់ឪពុកវិញ គអំពីនោះមកនាងវិសាខា ទើបមានឈ្មោះជាប់ថែមឡើងទៀតថា "វិសា-ខា-មិគារមាតា" ប្រែថា នាងវិសាខាជាមាតារបស់មិគារសេដ្ឋី ៗ

ក្នុងសម័យថ្ងៃមួយ នាងបានទៅស្តាប់ព្រះធម្មទេសនាក្នុងព្រះជេត-វនមហាវិហារ លុះវេលាត្រឡប់មកផ្ទះវិញ ស្រាប់តែឮកតាស័ក្កូប មហាលតាប្រសាធន៍ ក្រោយមកទើបរលឹកឃើញ ទើបដក់បនាងវិសាខា ហើយត្រឡប់ទៅយកមកតែនាងលែងប្រើប្រាស់ទៀតហើយ គិតជំនៀ

មហាលតាប្រសាធន៍ ហើយយកប្រាក់ដ៏ថ្លៃនេះកសាងវិហារមួយឈ្មោះ បុព្វារាម ថ្វាយព្រះបរមសាស្តា ។

នាងវិសាខាមហាឧបាសិកានេះ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួនបរិច្ចាគទានធ្វើការកុសលជានិច្ច អាស្រ័យហេតុនេះ ទើបទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងស្ត្រីជាទាយិកាទាំងឡាយ ។

នាងវិសាខានេះតាមប្រវត្តិពោលថា បរិបូណ៌ដោយកូនប្រុស-ស្រីច្រើនណាស់ សុទ្ធតែឥតជម្ងឺឈឺថ្កាត់ មានចំនួនដល់ ២០ នាក់ ជាកូនប្រុស ១០ ស្រី ១០ ហើយកូនអស់នោះ មានជាកូនពូនជាទៅម្នាក់ ២០ ៗ តទៅទៀត ទើបលោកសន្មតថា ជាមង្គលដ៏ឧត្តមហើយមានវ័យល្អតាំងពីក្រមុំរហូតដល់ចាស់ជរា នាងមានអាយុសង្ខារដល់ ១២០ ឆ្នាំ ទើបអនិច្ចធម្ម ៗ

ចប់ប្រវត្តិសង្ខេប របស់នាងវិសាខាមហាឧបាសិកាតែប៉ុណ្ណេះ ។

រឿងអាមាត្យរក្សាល្ពៅព្រះរាជទ្រព្យ

មានទិតានមួយដំណាលថា មានអាមាត្យម្នាក់តែងរក្សា ទីងពប់ផ្លែល្ពៅព្រះរាជទ្រព្យរបស់ព្រះមហាក្សត្រមួយព្រះអង្គ កាលណាផ្លែល្ពៅនោះទុំក៏បេះយកទៅថ្វាយជានិច្ចពុំដែលខាន ៗ មានគាប់ជួនថ្ងៃមួយនោះ បុរសម្នាក់កាន់ទំពក់ទៅបេះផ្លែល្ពៅ ដើរទៅក្បែរខាងដើមល្ពៅ ដែលអាមាត្យនៅចាំថែរក្សានោះ ៗ អាមាត្យមើលទៅយល់បុរសកាន់ទំពក់ថ្ពក់ផ្លែល្ពៅដូច្នោះ ទើបចេញទៅត្រួត ពប់ផ្លែល្ពៅនៅដើមនោះ ស្រាប់តែឃើញនៅតែទងទទេ ទើបគិតថាសមអាលីទំពក់ថ្ពក់ផ្លែល្ពៅទៅអម្បាញ់មិញនេះឯងជាចោរលួចហើយ អាមាត្យក៏រត់ទៅតាមចៅនោះឃើញមានផ្លែល្ពៅនៅថ្ពក់ទំពក់នៅដៃ អាមាត្យក៏ចាប់គោះនាំទៅប្ដឹងចៅក្រម ថាចៅនេះឯងជាចោរលួចផ្លែល្ពៅព្រះរាជទ្រព្យ ខ្ញុំចាប់បានផ្លែល្ពៅនៅថ្ពក់ទំពក់នៅដៃ ៗ

ទើបចៅក្រមដណ្ដឹងសួរថា ចៅឯងជាចោរលួចបេះផ្លែល្ពៅព្រះរាជទ្រព្យមែនឬទេ ៗ ចៅនោះឆ្លើយថាខ្ញុំមិនមែនជាចោរលួចទេ ឯផ្លែល្ពៅនោះខ្ញុំបានបេះមកពីព្រៃដទៃទៀតទេ ៗ ទើបចៅក្រមនាំសេចក្ដីនោះក្រាបបង្គំទូលដល់ព្រះមហាក្សត្រ · តាមដំណើរសេចក្ដីនោះសព្វគ្រប់ ៗ

ទើបព្រះអង្គមានព្រះបន្ទូលថា កុំអាលឲ្យគាបវាឡើយ ហើយត្រាស់ឲ្យយកផ្លែល្ពៅអំពីចៅនោះ ទៅដាក់ផ្ទាប់ទល់នឹងទងដែលល្ពៅជ្រុះ

ចេញទៅនោះ តើត្រូវឬមិនត្រូវ រួចសឹមទំលាក់ផ្លែល្ពៅនោះទៅដី ហើយពិចារណា គេដើមហេតុឲ្យឃើញពិតប្រាកដសិនសឹមធ្វើទោសវា ។

អាមាត្យទទួលព្រះរាជឱង្ការ ហើយយកផ្លែល្ពៅនោះទៅដាក់ជាប់នឹងទងល្ពៅ តែមិនត្រូវទំនងគ្នាសោះ ហើយទំលាក់ទៅដី ផ្លែល្ពៅនោះក៏ជ្រុះទៅក្នុងថ្លុកកប់កក់ទៅ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យគេកាយកក់រកផ្លែល្ពៅនោះ ក៏បានឃើញផ្លែល្ពៅដែលទើបនឹងធ្លាក់ទៅ នឹងផ្លែល្ពៅដែលជ្រុះអំ-ពីមុននោះ ទើបព្រះអង្គឲ្យយកផ្លែល្ពៅដែលជ្រុះអំពីមុននោះទៅដាក់ផ្ជាប់លមើល ក៏ឃើញត្រូវនឹងទងនោះមែន ទើបព្រះអង្គត្រាស់បង្គាប់ឲ្យយកផ្លែល្ពៅខុសនឹងទងវាឲ្យទៅបុរសលើទំពាក់វិញ ហើយឲ្យលើកលែងទោស ។ ទើបទៅនោះយកទំពាក់នឹងផ្លែល្ពៅ ទៅកាន់លំនៅអាត្មាវិញ ព្រះមហាក្សត្រទ្រង់រកសេចក្តីពិតឲ្យបានឃើញជាក់ស្តែងដូច្នេះ ជាការត្រឹមត្រូវ តាមទំនងគន្លងធម៌ប្រពៃពេកហោង ។

ចប់រឿងអាមាត្យរក្សាល្ពៅព្រះរាជទ្រព្យតែប៉ុណ្ណេះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៧-១៨

Vol. 14 17 - 18

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

បញ្ជីរឿង

ទំព័រ

១ — វិទ្យុធម្មទេសនា កណ្ឌទី ៩ លោកអាចារ្យ ឃួរ-អ៊ុន, ក្រុមជំនុំប្រែព្រះត្រៃបិដក សំដែង ១

២ — ច្បាប់ប្រុស ចំឡងចេញពោះពុម្ពផ្សាយ តាមច្បាប់សាស្ត្រាស្លឹករឹត ១២

៣ — បិសាចស្នេហា ឃ. និពន្ធមន្ត្រី អ្នកតែងសេចក្តី នៅព្រះរាជបណ្ណាល័យ ជាអ្នកតែង (តមកនឹងចប់) ២០

៤ — កុម្ភជាតក លោកគ្រូអាចារ្យ ឈឹម-ស៊ុម គ្រូបង្រៀននៅសាលាបាលីជាន់ខ្ពស់ ប្រែនឹងរៀបរៀងពីគម្ពីរខុទ្ទកនិកាយ តឹសនិបាត (តមកនឹងចប់) ៤២

៥ — រឿងព្រេងខ្មែរៈ “រឿងស្ត្រីឈ្មោះត្រង់នឹងស្វាមី” ៦២

TABLE DES MATIÈRES

Pages

1. Vidyudhammadesanā (conférence faite à la Radio Phnom-Penh), par le vénérable Achar You-Oun, membre de la Commission du Tripitaka.............................. 1

2. Chbab Prôs (Conseils aux fils).............................. 12

3. Bisach-Snéhā, roman khmer par Kh. Nibandha-Mantri, 2ᵉ partie (suite et fin).............................. 20

4. Kumbhajātaka, traduit du pāli par le Vénérable Chhim-Soum, professeur à l'École supérieure de Pāli, 2ᵉ partie (suite et fin). 42

5. Conte populaire cambodgien inédit: " Une femme fidèle à son mari ".............................. 62

អនាមតធម៌

អាចារ្យ យូរ-អ៊ុន ក្រុមជំនុំព្រះត្រៃបិដក
សំដែងដាក់វិទ្យុ លើកទី ៩

ក្នុងថ្ងៃ ១៤ កើតខែវិសាខ ឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥
ត្រូវនឹងថ្ងៃ ២៩ អាវ្រិល ឆ្នាំ ១៩៤២

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអនាមតធម៌ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញានៃពុទ្ធសាសនិកជន ។ មុននឹងសំដែងញែកបំបែកចេញជាមាតិកានៃធម៌នេះ សូមអធិប្បាយអំពីពាក្យថា អនាមតធម៌ សិន ។

ពាក្យថា អនាមតធម៌ ប្រែថា "ធម៌ធ្វើសត្វមិនឲ្យស្លាប់" តែសូមកុំចូលចិត្តថា ធម៌នោះជាថ្នាំទេសជីវិតសត្វឲ្យរស់នៅអស់កប្បកល្បឡើយ; ព្រោះជីវិតរបស់សត្វក្នុងលោកនេះ ទោះថោកក្តី ថ្លៃក្តី គ្មានអ្វីទល់ទប់បានទេ, តែងតែវិនាសបាត់បង់ទៅដូចៗគ្នាទាំងអស់ ។ ត្រង់ពាក្យថា "ធម៌ធ្វើសត្វមិនឲ្យស្លាប់" ក្នុងទីនេះ ត្រូវសំគាល់យកគុណធម៌មួយយ៉ាងដែលធ្វើមិនឲ្យស្លាប់កេរ្តិ៍ឈ្មោះ មិនឲ្យមានគ្រោះថ្នាក់ គឺជាអ្នកលេចឈ្មោះបោះសំឡេង មិនបាត់ឈ្មោះសូន្យឈឹងដូចគេបាញ់ព្រួញទៅក្នុងទីងងឹត, បើទុកជាជីវិតស្លាប់ទៅ ក៏កេរ្តិ៍ឈ្មោះនៅពិរោះ មានគេគោរពរាប់គេយកជាតម្រាប់តាមស្អិត ដូចមានសុភាសិតថា "រស់ក៏គាប់ ឆាប់

ក៏គួរ" គួរយ៉ាងដូចអ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើម កាលទ្រង់គង់ធរមាននៅឡើយ ទ្រង់បានបំពេញអនាមតធម៌ក្នុងសន្តាន ក៏បានទីជាសាស្តាអស្ចារ្យក្នុងលោក សូម្បីព្រះអង្គបរិនិព្វានបាត់ទៅពិត តែគុណ-ធម៌សុចរិតដែលព្រះអង្គប្រព្រឹត្តឥតបាត់បង់ទៅជាមួយព្រះអង្គទេ នៅផ្សាយកេរ្តិ៍កិត្តិគុណរបស់ព្រះអង្គស្មើសព្វប្រទេស ហាក់ដូចជាព្រះអង្គមិនមែនបរិនិព្វាន នៅមានព្រះជន្មទ្រង់ទ្រមន្តទេសនាទូន្មានសត្វតាមធម្មតា, ទាំងនេះក៏មកពីព្រះអង្គមានអនាមតធម៌ក្នុងព្រះខន្ធសន្តាន ។

អនាមតធម៌នោះមានប្រភេទចែកជា ៥ ប្រការ ដោយពុទ្ធភាសិតថា

យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ ។

សេចក្តីថា: គុណធម៌ ៥ ប្រការគឺ សច្ចៈ១ ធម៌១ អហឹសា១ សញ្ញមៈ១ ទមៈ១ មានក្នុងបុគ្គលណា ព្រះអរិយទាំងឡាយរមែងគប់រកបុគ្គលនោះ, គុណធម៌មានសច្ចៈជាដើមនេះ ឈ្មោះថាអនាមតធម៌ តែងប្រតិស្ឋាននៅក្នុងលោក ។

ឯគុណធម៌ទាំង ៥ ប្រការក្នុងព្រះគាថានេះ មានមកក្នុងទីដទៃៗ ជាច្រើន លោកសំដែងអធិប្បាយទុកដោយបរិយាយខ្លះ ដោយហេដ្ឋិម-ន័យខ្លះ អនុលោមតាមហេតុខ្លះ, ក្នុងទីនេះ នឹងអធិប្បាយឲ្យសមគួរដល់ភាពជាអនាមតធម៌ ដើម្បីជាសាធារណប្រតិបត្តិទៅ ។

១ — ការប្រព្រឹត្តកាយវាចាព្រមដោយចិត្តពិត ៗ ឈ្មោះថាសច្ចៈ គឺថាបើប្រព្រឹត្តធ្វើអ្វីដោយកាយក្តី ដោយវាចាក្តី ក៏ឲ្យចិត្តព្រមធ្វើផង ទើបឈ្មោះថាសច្ចៈ, បើធ្វើតែកាយនឹងវាចា ចំណែកចិត្តមិនព្រមធ្វើ ដូចថ្វាយបង្គំសោះតែកុំឲ្យគេថា ពោលវាចាសោះតែមិននិយាយកេ ដូច្នេះឲ្យឈ្មោះថាសច្ចៈមិនបាន ។ បើពោលដោយសេចក្តីអធិប្បាយ បានដល់ភាពជាអ្នកកាន់ទៀងត្រង់នឹងសំឡាញ់ មិនទ្រុស្តមិត្តមានចិត្តស្មោះត្រង់នឹងគ្នា, ទៀងត្រង់ចំពោះកាលវេលាដែលជាពេលត្រូវចូលត្រូវចេញ, ទៀងត្រង់ចំពោះកិច្ចការដែលជាមុខក្រសួងខ្លួនត្រូវធ្វើ មិនចាប់នេះចាប់នោះមិនផ្តោះត្រង់ណា, ទៀងត្រង់នឹងចៅហ្វាយនាយមិនមានគំនិតវៀចវេរ មានកតញ្ញូកតវេទីចំពោះលោកអ្នកមានគុណមិនរំលុបបំភ្លេចគុណលោកចោល, ទាំងនេះហៅថាសច្ចៈ ។ សច្ចៈនេះប្រើបានទាំងខាងល្អទាំងខាងអាក្រក់ តែក្នុងទីនេះសំដៅយកសច្ចៈដែលជាប្រយោជន៍ផង ជាធម៌ផង ។ គុណធម៌នេះជាសំខាន់មួយក្នុងកិច្ចការរបស់ពួកមនុស្ស, មែនពិត កិច្ចការគ្រប់យ៉ាងមិនថាផ្លូវលោកឬផ្លូវធម៌ទេ ដែលនឹងសម្រេចកើតការដូចប្រាថ្នាទៅបាន ក៏ព្រោះមានសច្ចៈជាគ្រឿងជួយទំនុកបម្រុង, ព្រោះធ្វើអ្វីធ្វើពិត គិតអ្វីគិតមែន រៀនអ្វីរៀនមាំ រមែងបានទទួលផលពិតដូចគ្នា បើវៀរចាកសច្ចៈចេញហើយ ផលមិនបានសម្រេចទៅតាមបំណងឡើយ ។ បុគ្គលអ្នកកាន់សច្ចៈទៀងត្រង់ប្រៀបដូចបានកែវដ៏មានដំឡៃ ព្រោះអាចនឹង

ដឹកនាំប្រជុំជនឲ្យមានសេចក្ដីស្រឡាញ់គោរពរាប់អាន មានកេរ្តិ៍ឈ្មោះក្រអូបសុះសាយសព្វទិស ហេតុនោះទើបព្រះទសពលទ្រង់ត្រាស់ថា សច្ចេន កិត្តិំ បប្បោតិ "បុគ្គលរមែងមានកេរ្តិ៍ឈ្មោះក៏ព្រោះសច្ចៈ"។ មួយទៀត សច្ចៈនេះ ជាបច្ច័យឲ្យសម្រេចប្រយោជន៍ខ្លួនឯងនិងប្រយោជន៍បុគ្គលដទៃ បណ្ដាសេចក្ដីរីករាយជាទីគាប់ចិត្តគាប់ថ្លើមនៃគ្នានឹងគ្នាកប់ថា ជារសឆ្ងាញ់ដ៏សំខាន់ជាងរសវត្ថុដែលមានក្នុងលោកនេះ, រសអាហារសម្បូរឆ្ងាញ់ពិសាត្រឹមណា ក៏គង់មិនជាទីគាប់ចិត្តរបស់មនុស្សទូទៅ សម្បូរត្រូវមានថ្ងៃៗ ក៏គង់មានវេលានឿយណាយ, ចំណែករសគឺសច្ចៈនេះ អាចឆ្ងាញ់គាប់ចិត្តមនុស្សគ្រប់ជាតិគ្រប់ជាន់ ជារសដែលមិនចេះទ្រាន់មិនជិនណាយ ទោះទៀតកាលណា ចិត្តក៏រីករាយពេលនោះ សមដូចពុទ្ធភាសិតថា សច្ចំ ហវេ សាធុតរំ រសានំ "សច្ចៈការកាន់ទៀងត្រង់ ជារសឲ្យសម្រេចប្រយោជន៍ជាងរសទាំងឡាយ" ។ សច្ចៈនេះជាគុណអាចធ្វើបុគ្គលឲ្យជាទីគោរពកោតក្រែងនៃជនដទៃ ដូចសេចក្ដីដែលពោលមក ហេតុនោះទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

២ - ពាក្យថា ធម៌នេះ ជាពាក្យប្រើទូទៅទាំងចំណែកល្អទាំងចំណែកអាក្រក់ទឹងជាគណនា ១ ក្នុងទីនេះ សំដៅយកសភាវៈដែលល្អ, ហៅថាធម៌ តែធម៌នុះមានច្រើនក្រៃពេក សូម្បីគុណ ៤ ប្រការក្នុងក្រម

អនាមគធម៌នេះក៏ហៅថាធម៌ដែរ, តែកាលបើលោកលើកធម៌មកចាត់ជាអង្គមួយដូច្នេះ ត្រូវសំគាល់ដល់គុណដទៃវិញ ក្នុងទីនេះនឹងលើកយកគារវធម៌មកសំដែង ។ ពាក្យថា គារវៈ ប្រែថា "សេចក្តីគោរព" បានដល់ការក្រាបសំពះ បុគ្គលដែលគួរក្រាបសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរឲ្យ ប្រាប់ផ្លូវដល់បុគ្គលដែលគួរប្រាប់ ធ្វើសក្ការបូជាដល់បុគ្គលដែលគួរធ្វើ ។ គារវធម៌នេះ ជាគុណសំខាន់របស់ពួកជនគ្រប់ជាន់ ជាគ្រឿងអប់រម្យសេចក្តីសាមគ្គីឲ្យរឹងប៉ឹង ទាំងជាគុណនាំឲ្យកើតសួស្តីជ័យមង្គល ។ មែនពិត ប្រជុំជនដែលរួមគ្នានៅជាពួក ៗ ចាប់តាំងអំពីត្រកូលមួយរហូតដល់ប្រទេសមួយ តែងមានអធ្យាស្រ័យចិត្តគំនិត នឹងការប្រព្រឹត្តផ្សេងៗគ្នា, ព្រោះហេតុនោះក្នុងសមាគមមួយ ៗ គេត្រូវតាំងមនុស្ស ១ នាក់ឲ្យជាប្រមុខ ជាអ្នកគ្រប់គ្រងមើលសេចក្តីសុខទុក្ខគ្រប់ប្រការ, ជនក្រៅអំពីនេះ ត្រូវមានសេចក្តីគោរពរាប់អានជឿស្តាប់ ធ្វើតាមពាក្យបង្គាប់របស់អ្នកជាប្រមុខ, ឯជនជាអធិបតីក៏គប្បីគោរពច្បាប់សម្រាប់ប្រព្រឹត្តទៅរកអ្នកតូចដែលហៅថាយុត្តិធម៌ មិនលំអៀងដោយអំណាចអគតិទាំង ៤ មានឆន្ទាគតិជាដើម; កាលបើសាធុជនបានតាំងខ្លួនក្នុងគារវធម៌យ៉ាងនេះ នឹងមានតែសេចក្តីចំរើនកេរ្តិ៍ឈ្មោះយសសក្តិដូចព្រះចន្ទក្នុងសុក្កបក្ខ (ខាងខ្នើត)តែម្យ៉ាង ។

ហេតុនោះទើបព្រះមហាមុនីត្រាស់ទុកក្នុងអបរិហានិយធម្មសូត្រត្រង់ទី ៤ ថា "ម្នាលភិក្ខុទាំងឡាយ បើភិក្ខុឯណាជាថេរៈ មានវ័យចំរើន ជាសង្ឃបិតា ជាសង្ឃបរិនាយក, ភិក្ខុនាំគ្នាធ្វើសក្ការៈគោរពរាប់អានបូជាជឿស្តាប់ពាក្យរបស់ភិក្ខុជាថេរៈនោះត្រឹមណា, នឹងមានតែសេចក្តីចំរើនត្រឹមណោះ ។ សេចក្តីគោរពនេះ មិនមែនគ្រាន់តែជាផ្លូវប្រតិបត្តិរបស់ជនជាសាមញ្ញទេ, សូម្បីព្រះអរហន្តសម្ពុទ្ធជាកំពូលសាស្តាក្នុងត្រៃភព ក៏ទ្រង់ធ្វើសេចក្តីគោរពដែរ, ដូចនឹងឃើញបាន កាលព្រះអង្គត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណហើយថ្មីៗ ស្តេចគង់នៅក្រោមដើមអជបាលនិគ្រោធក្បែរច្រាំងស្ទឹងនេរញ្ជរា, ទ្រង់រំពឹងឃើញថា ការមិនមានអ្នកណាជាទីគោរពជាការមិនប្រពៃ, ទើបទ្រង់ស្វែងរកបុគ្គលដែលគួរព្រះអង្គធ្វើសក្ការគោរពរាប់អាន, តែមិនបានជួបប្រទះសមណព្រាហ្មណ៍ណាមួយដែលមានគុណវិសេសជាងព្រះអង្គ, បើទុកជាដូច្នោះ, ក៏គង់ទ្រង់ធ្វើសក្ការគោរពព្រះធម៌ដែលព្រះអង្គត្រាស់ដឹងហើយ ពិតមែន ព្រះពុទ្ធទាំងឡាយ និព្វានកន្លងទៅហើយក្តី នឹងត្រាស់ឡើងក្នុងកាលខាងមុខក្តី ក្នុងកប្បកល្បឥឡូវនេះក្តី ទ្រង់ធ្វើសេចក្តីគោរពចំពោះព្រះធម៌តែម្យ៉ាង, នេះជាទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ។ សេចក្តីគោរពនេះ ជាគ្រឿងអលង្ការរបស់ពួកជន អាចឃុំគ្រងពួកក្រុមឲ្យតាំងនៅក្នុងសាមគ្គីរក្សា

សន្តិសុខឲ្យប្រព្រឹត្តទៅ ហេតុនោះ ទើបឈ្មោះថាអនាមគធម៌ ដោយប្រការដូច្នេះ ។

៣ – ការមិនគិតបៀតបៀនធ្វើទុក្ខធ្វើបាបដល់សត្វនិងបុគ្គលដទៃ ឈ្មោះថា អហឹសា, លោកបំណងយកមេត្តាចិត្ត គឺចិត្តដែលគិតប្រាថ្នារកសេចក្ដីល្អឲ្យដល់គ្នានឹងគ្នា, បើពោលឲ្យខ្លីគឺសេចក្ដីប្រាថ្នាឲ្យគេបានសុខនោះឯង ។ មេត្តានេះលោករាប់ជាព្រហ្មវិហារធម៌ គឺធម៌ជាគ្រឿងអប់រំសន្តានរបស់អ្នកធំជាប្រធាននៃពួក, អធិប្បាយថា ជនជាធំជាអធិបតីក្នុងសមាគមមួយ ៗ រាប់តាំងអំពីត្រកូលមួយស្រុកមួយឡើងទៅ ត្រូវផ្ដល់ខ្លួនក្នុងព្រហ្មវិហារធម៌ គឺត្រូវមានចិត្តមេត្តាប្រាថ្នាឲ្យអ្នកតូចមានសេចក្ដីសុខ-ចំរើន, បើអ្នកតូចមានសេចក្ដីទុក្ខព្រួយក៏មានចិត្តអាណិតអាសូរករុណាប្រាថ្នានឹងជួយដោះឲ្យរួចអំពីទុក្ខនោះ មិនព្រងើយកន្តើយ, កាលបើអ្នកតូចចំរើនដោយលាភយសហើយ ក៏មានមុទិតាចិត្តរីករាយជួយផ្សាយអនុមោទនា មិនគិតឫស្យាច្រណែនគ្នា, កាលបើអ្នកតូចមានសេចក្ដីសុខ-ចំរើន ក៏តាំងចិត្តជាឧបេក្ខាមិនគិតបៀតបៀនឲ្យអ្នកតូចបានទុក្ខលំបាកឡើយ: អ្នកធំកាលបើតាំងនៅក្នុងមេត្តាធម៌នេះហើយ អ្នកតូចរមែងនិយមរាប់អាន, ការរាប់អាននោះជាគ្រឿងអំណាច, អ្នកមានអំណាចលុះណាតែមានគេកោតក្រែងគោរពរាប់អានលើកដំកើងឲ្យជាធំជាប្រធាន

ប្រព្រឹត្តតាមខន្តីមានមេត្រីយ៉ាងស្មោះអស់ពីពោះ មិនឃានសេចក្តីរង្កៀសសង្ស័យ, ត្រូវតាមន័យពុទ្ធភាសិតថា វេរា ន ឥស្សរិយំ លោកេ "អំណាចវេរមិនជាធំក្នុងលោក" ។ អ្នកធំកាលតាំងខ្លួនក្នុងមេត្តានេះ រមែងជាទីរាប់អានរបស់មនុស្សទូទៅអាចនឹងគ្រប់គ្រងសមាគមនោះៗ ឲ្យតាំងនៅបានដោយសួស្តី ។ អហឹសា ការមិនបៀតបៀននេះជាគុណធម៌នាំឲ្យកើតសេចក្តីគោរពរាប់អានគ្នា ដូចបានពណ៌នាមកនេះ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

៤ – ការសង្រួមរាំងខ្លួនឲ្យរួចចាកទោសដែលបណ្ឌិតគប្បីតិះដៀលឈ្មោះថា សញ្ញមៈៗ នេះ លោកតែងយោងសេចក្តីផ្សេងៗគ្នា, ក្នុងទីខ្លះលោកតែងប្រាប់ថាសីល ក្នុងទីខ្លះថាឥន្ទ្រិយសំវរៈ ក្នុងទីខ្លះថាសមាធិចិត្ត, តែកាលបើពោលដោយរួបរួម បានដល់ការសង្រួមរាំងខ្លួនមិនធ្វើការអ្វីដែលបណ្ឌិតគប្បីតិះដៀលឬមិនធ្វើការអ្វីដែលមានទោស ដោយវិធីរក្សាសីល ដោយការសង្រួមឥន្ទ្រិយឬដោយចំរើនសមាធិភាវនា ។ សញ្ញម-ធម៌នេះ ជាគុណសម្រាប់អ្នកធំប្រការមួយ, ក៏ដូចគ្នា អ្នកធំបើមិនសង្រួមរាំងខ្លួនក្នុងកិច្ចការដែលត្រូវធ្វើទេ ប្រកបតែកម្មដែលជាទោស ក៏មិនជាទីគោរពរាប់អាននៃអ្នកតូច ជាផ្លូវធ្វើឲ្យអ្នកតូចមើលងាយអស់សេចក្តីកោតក្រែង ព្រោះហេតុនោះអ្នកធំទើបត្រូវសង្រួមរាំងខ្លួនឲ្យរួចចាក

មន្ទិលសៅហ្មងដែលអ្នកប្រាជ្ញគប្បីតិះដៀល ដោយវិធីក្យាស័ល ឬដោយការសង្រួមឥន្ទ្រិយ ឬក៏ដោយការចំរើនសមាធិភាវនាដូចពោលហើយ, កាលបើសង្រួមរាំងយ៉ាំងនេះ សេចក្តីអាក្រក់នឹងមិនមានឱកាសកើតឡើងបាន ដូចពុទ្ធភាសិតថា សញ្ញមតោ វេរំ ន ចីយតិ "អ្នកសង្រួមរមែងមិនកំពៀរវេរាឲ្យកើតឡើយ" ។ តអំពីនោះមកទៀត ប្រសពផលផ្ទៃខ្លួនឲ្យជាទីគោរពរាប់អានរបស់អ្នកតូច អាចគ្រប់គ្រងនិយាយស្តីទៅរកអ្នកតូចបានពេញមាត់ ហេតុនោះ សញ្ញមៈ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ។

៨– ការទប់ឃាត់ចិត្ត ការប្រាបប្រាមចិត្ត ការហ្វឹកហ្វឺនទូន្មានចិត្តឲ្យប្រាសចាកភ័យអន្តរាយ ឈ្មោះថាទមៈៗនេះ លោកក៏ចែប្រាប់សេចក្តីផ្សេងៗគ្នាដែរ គឺចួនកាលលោកប្រាប់ថា បានដល់ឥន្ទ្រិយសំវរៈ ចួនកាលថាបានដល់វិបស្សនាបញ្ញា, តែបើពោលដោយរួបរួម ក៏គឺការទប់ឃាត់ប្រាបប្រាមទូន្មានខ្លួនឲ្យឃ្លាតចាកការកំរើករំភើបជ្រួលច្របល់ចិត្តដែលបណ្តាលមកអំពីសង្កិលេសធម៌ គឺរាគៈ ទោសៈ មោហៈ ឬដែលជាប់មកអំពីលោកធម៌ ដោយវិធីសង្រួមឥន្ទ្រិយ ឬក៏ដោយវិធីចំរើនវិបស្សនា ឈ្មោះថា ទមៈ ។ ធម៌នេះ ជាគុណសំខាន់សម្រាប់ជនគ្រប់ថ្នាក់ ព្រោះថាធម្មតាមនុស្សយើងបើឥតធម៌នេះក្នុងសន្តានហើយ ក្នុងពេលដែល

ក្រោធៈ ទោសៈ មោហៈ ផុះផាលក្នុងពោះឡើង ក៏នឹងនាំចិត្តឲ្យលុះក្នុងអំណាចកិលេសនោះ ៗ ជាហេតុឲ្យហ៊ានប្រព្រឹត្តអាក្រក់ផ្លូវកាយវាចាច្រើនប្រការ, រហូតដល់ក្បត់ក្បួមហ៊ានជាតិប្រទេស មិនមានសេចក្ដីខ្មាសបាបខ្លាចបាបទេ, ក្លាយទៅជាមនុស្សមានកំហុសធំក្នុងលោក ដែលមិនជាទីគោរពរាប់អានកោតក្រែងរបស់ប្រជាជន, ក្នុងពេលដែលប្រទះលោកធម៌ ទោះជាចំណែកគួរប្រាថ្នាក្ដី មិនគួរប្រាថ្នាក្ដី ក៏នឹងទប់ឃាត់ចិត្តមិនបាន នឹងសំដែងសេចក្ដីឆ្វេងឆ្វាចិត្តឬខ្ទន់បាត់ស្មារតីដែលជាចំណែកខូចភូមិរបស់មនុស្ស, បើមានគុណធម៌នេះនៅប្រចាំក្នុងចិត្តវិញ រមែងមិនគិតគិតបារម្ភញាប់ញ័រទេ បើទុកជាប្រែខ្លះក៏មិនប្លែកខុសធម្មតា ចូលក្នុងតម្រាថា "ព្រឹក្សាឫសមាំត្រូវខ្យល់បោក គ្រាន់តែយោគយោកជ្រុះសន្លឹក" មួយទៀតសមដូចបាលីថា សុខេន ផុដ្ឋា អថវា ទុក្ខេន ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ "បណ្ឌិតទាំងឡាយ ទោះបីសុខនឹងទុក្ខពាល់ត្រូវហើយ ក៏មិនសំដែងអាការឡើងចុះឡើយ" ៗ សេលោ យថា ឯកឃនោ វាតេន ន សមីរតិ ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា "បណ្ឌិតទាំងឡាយ តែងមិនញាប់ញ័រព្រោះនិន្ទានឹងសរសើរ ដូចភ្នំថ្មគ្រាន់មួយមិនរញ្ជួយ ព្រោះខ្យល់ព្យុះដូច្នោះឯង ៗ ទាំងនេះក៏ដោយមានទមធម៌នៅប្រចាំក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា អនាមតធម៌ ដោយប្រការដូច្នេះ ៗ

ធម៌ទាំង ៥ ប្រការគឺ សច្ចៈ, ធម៌, អហិំសា, សញ្ញមៈ, ទមៈ, មានបរិបូណ៌ នៅក្នុងបុគ្គលឯណា ព្រោះអរិយទាំងឡាយរមែងសេពគប់បុគ្គលនោះ ធម៌មានសច្ចៈជាដើមនោះ ឈ្មោះថាអនាមតគធម៌ គឺធម៌មិនចេះចាស់ឈឺស្លាប់ មានន័យដូចសេចក្ដីអធិប្បាយដោយសង្ខេបមកនេះឯង ។

អាត្មាភាពសំដែងមកក្នុងអនាមតគធម៌ តបស្នងទ្រង់សទ្ធានៃពុទ្ធសា-សនិកជន ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញបារមី សន្មតថាបប់តាមសមគួរ ដល់កាលវេលាត្រឹមប៉ុណ្ណេះ ។

ចប់វិទ្យុធម្មទេសនាកណ្ឌទី ៩ តែប៉ុណ្ណោះ ។

ច្បាប់ប្រុស

បទព្រហ្មគីត

នេះបទព្រហ្មគីត ពាក្យព្រេងព្រឹទ្ធបុរាណ ថែងចងជានិទាន ទុកគ្រាន់មើលជាច្បាប់ថ្មី ៗ ឲ្យអស់កូនចៅក្រោយ ស្ដាប់កុំឲ្យភ្លេចស្មារតី ប្រដៅទាំងប្រុសស្រី យកទុកខ្លួនគ្រប់គ្នា ។ ធម្មតាកើតជាមនុស្ស នោះស្រីប្រុសគ្រណាស់ណា ក្រគិតក្នុងចិន្ដា ឲ្យបានដឹងសមទំនួរ ៗ ទាំងអស់ញាតិសន្ដាន សោះគេមានពាក្យថាជួ កុំធ្វើងកុំតែងគួ ធ្វើកំប៉ោងកុំពាក្យធំ ៗ ទំនើរដូចកូនដង្គ ឲ្យខុសអង្គសាចបារម្ភ ឲ្យត្រូវទំនងច្បាប់ក្រម គួរប្រតិបត្តិកុំឲ្យគ្គង ៗ រៀនបទរៀនបាទចាស កុំចេញឡាសលើរៀមច្បង ស្រដីទំនងអ្នកផង ពាក្យឲ្យគួរកុំឯងរុយ ៗ កំអើអញផាច់សាច់ ក្ដិងពាក្យពេចន៍គេស្រដី ដើមដៀលឲ្យអប្រិយ ស្រដីថាកូនឥតពូជ ៗ ចាស់ទុំមិនប្រដៅ ដេរកូនចៅទើបរាំខូច គេថាកូនឥតពូជ មិនដឹងច្បាប់ទំនងចាស់ទុំ ៗ គេដៀលដល់ម៉ែឪ គេត្រីតាស្រវស្អុយហើ គេស្ដីដើមដៀវផ្ទុំ ដំនៀលនោះដល់មកចាស់ ៗ កុំរាចកុំស្លូតពេក កុំចំអៀកវៀនហើស កុំខ្លាចកុំហ៊ានណាស់ ឲ្យរំពឹងរំពៃគ្រប់ ៗ ទោះដេកឲ្យរហ័ស ភ្ញាក់មុនចាស់ដោះឡើងលុប មុខមាត់មើលឲ្យគ្រប់ ទ្រព្យរបស់សិមដេករិញ ៗ ស្លាមួស៊ុំឲ្យប្រៀក កុំបំបៀកទាំងមូលមិញ ភ្ជួចធំឲ្យប្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ ៗ

ដេកយប់កុំដេកយូរ ហើយទទូរដូចគេឆាប់ សំពត់ស្បៀកឲ្យខ្ជាប់ កុំឲ្យ
អាក្រាតក្រៅខ្លួន ។ ទឹងដេកកុំទ្រមក់ ឲ្យលង់លក់ក្រៅពីក្បួន បើភ្ញាក់
ឲ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្លាំង ។ បែប្រាណប្រែងវិញ្ញាណ ខ្លាច
ក្រែងមានទោសចិត្តខ្លាំង ប្រញ្ញប្រាណប្រែបជញ្ជាំង ជញ្ជូនទ្រព្យលួចយក
ចេញ ។ បើឥតមោះមន្ទិល កុំឲ្យខ្ជិលដេកទៅវិញ ភ្ញាក់ហើយឲ្យក្រោក
ចេញ រកដក់ថ្នាំស៊ីមូស្លា ។ ទោះពេលពន់ព្រលប់ គន់ឲ្យគ្រប់ទ្រព្យ
នានា កាំបិតខាងអាត្មា ឲ្យស៊ិតទឹកដាក់ចុងជើង ។ ប្រអប់ដាក់ទឹមស្លា
ថ្វាយទេព្តារក្សាយើង ហើយឲ្យបំពក់ភ្លើង នៅក្រានក្រៅកុំឲ្យដាច់ ។
កុំឲ្យអស់រលើង រលត់ឆេងហើយថាភ្លេច សព្វថ្ងៃមើលកុំដាច់ កុំដើរ
យកពីផ្ទះគេ ។ ថែទាំមើលជើងក្រាន ឲ្យទុសមានកុំទំនេរ បង្កាត់
បង្កើតកេរ្តិ៍ កុំប្រហែសឲ្យសូន្យសុង ។ ប្រយ័ត្នក្រែងក្រឆាយ ពុំ
សប្បាយឈើពោះពុង បង្កាត់កំដៅអង្គ អុជបំភ្លឺមើលនេះនោះ ។ មាន
កាលយប់ងងឹត ភ្លេចមិនគិតជួនកូនជុះ គ្មានភ្លើងអុជចន្ទុះ ក្រានរលុះ
រលត់ឆេង ។ រត់រកភ្លើងសស្រាក់ ព្រួយលំបាកតែខ្លួនឯង ហេតុខ្ជិលពុំ
គិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ ។ ហើយឲ្យថែទាំទឹក ទោះយប់
ព្រឹកកុំគិតឆាយ ដងដាក់ក្អមកក់កាយ សព្វព្រួចពាងអាងអុងធំ ។ កុំ
ឲ្យស្ងួតក្អមឆេង អស់រលីងពីពាងធំ គ្មានសោះនោះមិនសម ជួនក្រែង
ក្រឆាយយប់ថ្ងៃ ។ ទោះដើរទៅឆ្ងាយជិត កាន់កាំបិតកំដរដៃ ក្រែង

មានមែកឈើព្រៃ កាប់កាន់មកទុកជាធ្មេស ៗ ជូនកាលក្រែងបន្លា មុត
អាត្មាគ្រាន់បាក់ដោះ ជាគ្រឿងគប់មិនខុស ការស្រួតតោះធ្នាក់ ៗ
ដើរព្រៃឲ្យមើលលើ ឃើញស្វិតឈើជាបន្ទែ កាន់កាប់កុំដៃទេ អង្គុយ
គន់មើលឆ្វេងស្តាំ ៗ ក្រែងមានឈើព្រៃឆាប់ គួរកាប់កាប់យកជាថ្នាំ
ធ្វើក្រានគ្រាន់ដណ្តាំ បាយបានឆ្អិនឆាប់ដូចចិត្ត ៗ សោះស្រីស្រដីបាន
ប៉េះសមានមិនព្រួយចិត្ត សព្វថ្ងៃប្រើគំនិត ថែទាំទើបគង់របស់ ៗ
មាសប្រាក់ស្រូវអង្ករ ទុកឲ្យល្អកុំសប្បុរស សំប័យកុំឲ្យអស់ មើល
ថែជួនខ្លួនឯងណា ៗ ស្បូវស្លួចកុំឲ្យដាច់ បើរកកិចឲ្យឧស្សាហ៍ រះរក
ឆ្នាំទៀតណា ឲ្យបានច្រើនក្រវើនទុក ៗ ទឹងតាយឲ្យគិតក្រោយ ទោះ
ទឹងឲ្យៗមើលមុខ កុំឲ្យស៊ុកគ្រលុក ទោះទឹងទុកឲ្យចំណាំ ៗ រដូវ
ធ្វើចំការ ឲ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ ស៊ុកក្រខ្មីគ្រប់ត្រៃ គ្រាត្រៃសក់
សព្វបន្លែ ៗ កុំខ្ជិលកុំប្រឆុស ទៅផ្ទុះគេសូមគេ គេមិនឲ្យឯងទេ
តែគឺមោះព្រោះខ្ជិលដាំ ៗ ទោះធ្វើស្រែចំការ ឲ្យឧស្សាហ៍មើលថែទាំ
កុំខ្ជិលកុំប្រមាថ បបបួកដីកស្មៅល្អផង ៗ កុំឲ្យបង់កំឡាំង ទោះខែ
ប្រាំងប្រើឲ្យផង ទំកទៅស្រោចស្រប់ផង ឲ្យល្អតលាស់មានផ្កាផ្លែ ៗ
ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ ខ្លាំងខ្សោយកុំឲ្យល្ហែ ខ្លាច
តែនឿយហើយមិនធ្វើ ៗ ដាំងយប់ចិតថ្ងស្សើ ត្បាញជាល្អតៅករញ្ជួ
កុំឲ្យស្រីស្តីលើ ឥតអំពើធ្វើលេងទៅ ៗ កុំទុកដៃទទេ ដាំងទំខេរ

បោចស្មៅក្រៅ ខាងផ្ទះខាងលំនៅ ឲ្យរាល់កាលកើតសុខា ។ ឲ្យ មានក្ដីបារម្ភ ធ្វើស្រែកុំចោលចំការ ដឹងដែកកាំបិតព្រា ទុកឲ្យជាកុំឲ្យ បាត់ ។ ដេកយប់ឲ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន ត្រចៀកចាំ កុំភ្លាត់ កុំភ្លេចចោលមិនដឹងខ្លួន ។ ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ ដូរមើលថៃធ្នូ ទោះទ្រព្យរបស់ខ្លួន ឲ្យសួរកូនសួរប្រពន្ធ ។ កុំអាង ឯងជាប្រុស ពាយរបស់មិនគិតគន់ មិនដឹងដល់ប្រពន្ធ ព្រមព្រៀង គ្នាឥតបើថា ។ ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ ទោះទៅលេង ឥតការ ឥតគេកេដើរឆ្ងាយជិត ។ ឲ្យប្រាប់អ្នកនៅផ្ទះ កុំលះឥត គំនិត គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា ។ បើទៅជា មានភ័ព្វ ប្រសើរគាប់នោះឥតថា ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុក ឥតគេសម ។ ទោះដើរមានដំណើរ ឲ្យរំពឹងគិតបារម្ភ ទឹងដើរៗឲ្យ សម យប់ព្រលប់ឲ្យមាត់ក ។ កុំស្ងៀមកុំស្ងាត់ពួន លបលាក់ខ្លួន ខ្លាចមិនល្អ ឲ្យមើលឲ្យមាត់ក ដើរឲ្យស្មោះសោះគេថា ។ ទោះខ្លួន ជាប៉ុន្មាន ពាក្យសន្ដានវែងមុសា នៃម៉ែមកអាត្មា តាមដំណឹងដំណើរ ខុស ។ កូនអើយបាកុំភ្លោយ កុំភ្ជាប់ឲ្យអាប់កេរ្តិ៍យស ធម្មតាកើតជា ប្រុស ឲ្យរករៀនច្បាប់មាត្រា ។ លោកថាហៅធ្លុតបី មួយធ្លុតស្រី មួយធ្លុតស្រា មួយធ្លុតល្បែងពាលា លេងបៀរប៉ោះផ្លុំគាត់ ។ ទាក់ មាន់ទាក់ទា ផល់ភ្នាល់គ្នាបរបាញ់សត្វ អន្ទាក់ដាក់បង្កាត់ ល្បែង

អស់នោះមិនកំណើត ៗ ជម្នាញបៀទឹងបៀ មិនដែលខ្វះណា ទឹងគ័ត
មិនព្រមមានកំណើត មានតែលិចលង់ខ្លួនទេ ៗ ដូនកាលគេទាញឯង
លៀងពល់ល្បែងតែងទឹងរ មានកាលឯងទាញគេ កុំទុកចិត្តថាឯងប៉ិន ៗ
ព្រឹកស្លៀកហូលផា ល្ងាចស្លៀកសម្លុះបង់ក្បិន ព្រឹកក្បែកក្បាល
ចិន ល្ងាចមិនទាន់ចិនដាក់ខ្នោះ ៗ ដូនកាលរាំបង់ជើង ព្យួរខ្លួន
ទៀងក្បាលដាំចុះ ក្អែកស៊ីងតឹងក្រញ៉ះ រាំទារប្រាក់ឲ្យបានឆាប់ ៗ
មើលមុខល្អិតបម្លឺ មិនខ្មាសស្រីផ្កាឈើស្អាប់ មុខមិញដូចគេស្លាប់
មាត់ស្ងៀមស្ងាញពេបដូចក្អែង ៗ ស្រែកថាអះអួយអើយ អាចឹកអើយ
អាណាក់តែលែង អញគេប្រាក់ឲ្យឯង ឲ្យអាចឹកស្អែកនេះបាន ៗ ចិនព្រម
ត្រមស្រាយមក បណ្ដើរគេប្រាក់សន្លាន តឹងទារទោលតែបាន ទ្រព្យ
ឲ្យទៅវិញរាំលែង ៗ អ្នកអាយអ្នកអើយកុំ គួរប្រាស្ពាល់តែល្បែង
កុំលកុំល្បិកលេង គួរឲ្យរាំងឲ្យរៀរសោះ ៗ កុំឈរកុំឈប់ជិត ក្រែង
មិនអត់ចង់គេគ្រោះ កុំល្បួងល្បែងនោះសោះ គួរឲ្យដោះឲ្យដើរចេញ ៗ
ច្បាប់នេះចាំកល់ខ្លួន កោះបងប្អូនមិត្តសំឡាញ់ តឹងខ្លួនឯងឲ្យចេញ
ណានាទ្រព្យគេយកទៅ ៗ ឯទ្រព្យបានទៅរាំ ឯងណានាស្រាប់តែនៅ
រាំបានទ្រព្យយកទៅ ខ្លួនឯងនៅណានាស្រាប់ ៗ ដល់គេមកតឹងទារ
អ្នកណានាឲ្យបានឆាប់ មិនបានគេប្រតាប់ ទៅជាខ្ញុំព្រោះណានា ៗ ទោះ
បងប្អូនផ្ទះ ក្រជំពាក់គេតឹងទារ បើមានទ្រព្យជួយផា កុំណានាណាអ្នក

អាយ ៗ កូនអើយចូរចាំ ឪពុកផ្តាំកុំបីណាយ ប្រយ័ត្នពល់រូបកាយ
កុំឲ្យភ្លេចពាក្យនេះណា ៗ មួយទៀតហៅឆ្នូតស្រី គួរកុំបីសេពកាមា
វាតែងទាញអាត្មា នាំវង្វេងភ្លេចបាបបុណ្យ ៗ ភ្លេចសីលទានសូន្យ
សោះ ភ្លេចឃ្លាំងខ្ទះដល់ជីពជន្ម ភ្លេចទោសភ្លេចរាំងគុណ ភ្លេចទាំង
ការកាន់រសាយ ៗ បង្កើតតែទោសទុក្ខ បើបានសុខសិងប្រែក្លាយ
បង្កើតក្តៅក្រហាយ ឲ្យទាស់ទែងខឹងនឹងគ្នា ៗ ចងទោសគុំគួន មិន
គិតខ្លួនខ្លាចមរណា មានកាលក្ស័យទឹងមា គុំធ្វើគ្នាឲ្យសោះសូន្យ ៗ
បង្កើតតែចិត្តធំ ទៅគំនុំទឹងជីដូន ឯបងខឹងនឹងប្អូន ម្តាយទឹងកូនគុំធ្វើគ្នា ៗ
រខ្ញុំគុំគាប់ម្ចាស់ ឲ្យក្តៅណាស់ក្នុងអង្គា កើតទោសខឹងនឹងគ្នា ជាគំនុំ
ពុំគ្រាស្បើយ ៗ មានកាលគេដាក់ឃ្នាង វាមិនរាងចាលចិត្តឡើយ
លក់ព្ឃយខ្ញុំគេហើយ មិនខ្លាចស្លាប់ដល់អាត្មា ៗ គេកាប់ដោតចាំងក្បាល
មិនរេះចាលចិត្តឡើយណា ភ្លេចខ្លួនសូន្យសោះសា ទឹកតែត្រង់សេព
សប្បាយ ៗ រឯកាមកិលេស កុំប្រហែសគួរឲ្យណាយ ស្អិតណាស់
ណាអ្នកអាយ អ្នកអើយកុំគិតសង្ស័យ ៗ នេះឯងហៅឆ្នូតស្រី គួរកុំ
បីឲ្យគាល័យ ចូរចងចាំសព្វថ្ងៃ ទុកទូន្មានអង្គអាត្មា ៗ អ្នកប្រាជ្ញ
លោកនិទាន ទុកទូន្មានឪពល់រូបា មួយហៅឆ្នូតសុរា នោះកុំផឹកវាស្រវឹង ៗ
វានាំភ្លេចវិញ្ញាណ ភ្លេចសីលទានសោះសូន្យឈឹង ផឹកហើយមិនដែល

ទឹង នាំចិត្តនោះឲ្យធំក្រៃ ។ ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ កំឡាំងឯងស្មើថៃ មិនកោតគេតិចឡើយណា ។ ត្រូងត្រាងពាក្យកន្ត្រ អួតពូកែបង្ខំបានស្រា មិនមានខ្លាចនរណា ស្រដីកោងកេកលឈ្លោះ ។ បញ្ចោរបញ្ចៀសផ្តាស ដេរដងរាសមិនចំឈ្មោះ នាំហេតុតែខាងឈ្លោះ ឆ្លើយឆ្លងពាក្យឲ្យបានទាក់ ។ ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំ អ្នក ឯងទឹងលោភយធាក់ ដោយចិត្តធំបង្ខំបានស្រា ។ មានកាល ជួនស្រវឹង ពុំមានដឹងខ្លួនឡើយណា ដើរដួលដេកផ្កាប់ផ្ការ ស្រាត សំពត់អស់ពុំដឹង ។ គេឃើញអស់ខ្មាសក្ដី ក្មេងជៀវជុំសើចទ្រហឹង ។ ដេកដូចគេស្លាប់ឈឹង ក្អែកក្អួតពាសពេញទាំងខ្លួន ។ កំណើតអ្នកផឹក ស្រា កុំអួតថាឯងទឹងខ្លួន ផឹកហើយស្រវឹងមួន ខ្លួនខ្សត់ទេអួតថា មាន ។ អ្នកស្លូតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន ខុសត្រូវទៅ បំពាន បំពុលខ្លួនឲ្យបានបាប ។ នេះឯងហៅឆ្កួតស្រា ក្នុងធម៌ថា ជៀវដេកប អ្នកណាផឹកៈហើយបាប បង់កិត្តិយសពុំសួស្ដី ។ ត្រូវកុំសេព សុរា នាំសាត្រាឲ្យអប្រិយ ទឹងធ្លាក់ទៅអវីចី នរកនឹងទុក្ខវេទនា ។ ហៃ អស់ជនទាំងឡាយ កុំកាយមាយក្នុងអង្គា ចូរស្ដាប់ច្បាប់នេះណា ទុក ទុក្ខានខ្លួនសព្វថ្ងៃ ។ នេះឯងហៅឆ្កួតបី លោកស្រដីក្នុងធម៌ថ្ងៃ បើ អ្នកណាមួយនៃ នឹកប្រាថ្នាដោយចំណង់ ។ លោកបង់ជាឧបមា ឲ្យ

អ្នកណាមួយផ្ចិតផ្ចង់ យកដែកដុលពោះបង់ ក្នុងភ្លើងក្រានឆេះព្រាល ផ្ដៅ ៗ បើកាន់ដែកដែលដុត នោះមិនមុតមិនមានក្ដៅ កាន់បាននោះ ទើបហៅ ចិត្តមុតមែនមិនគិតប្រាណ ៗ នោះទើបលោកឲ្យធ្វើ នូវ អំពើទាំងបីបាន ដោយធម៌ពីបុរាណ លោកឧបមាដូច្នេះណា ៗ ចាត់ចែងតែងជាបទ ព្រហ្មប្រាកដកាលបិតា ប្រដៅខ្ញុំនេះណា សព្វសេចក្ដី ដូច្នេះនៃ ៗ កិច្ចកាព្យពយរៀបរេស ខ្ញុំនាមឈ្មោះបណ្ឌិតមៃ គិតបងជា សេចក្ដី ប្រដៅជនចប់ម៉្លេះហោង ៗ

ច្បាប់ប្រុស ចប់តែប៉ុណ្ណេះ ៗ

បិសាចស្នេហា

(ភាគទី៦ចប់)

ក្នុងមួយរំពេចនោះ ទឹកមុខរបស់នាងក្រមុំទៀងស្វាង ចុះទៅជាងមុនច្រើន ដោយនាងសារុនដឹងជាក់ច្បាស់ថា ឧត្តមស្រឡាញ់ខ្លួននាង ចាប់ចិត្តប្រតិព័ទ្ធចំពោះរូបនាងយ៉ាងច្រើនលើសលន់គណនា ប៉ុន្តែនាងមិនចាប់ចិត្តស្រឡាញ់គេសោះឡើយ ព្រោះនាងទៅជាប់ចិត្តស្ងួនចិត្តស្រឡាញ់លោកតែងពៅក្រមកំឡោះយ៉ាងជ្រៅជក់ខ្លួនមិនរួច តែតាមដោយពិតនោះ នាងមានចិត្តអាណិតអាសូរឧត្តមជាទីបំផុត តែខ្លួននាងមិនអាចផ្តាច់សេចក្តីស្នេហារបស់នាងដែលជាប់នៅនឹងរូបលោកតែងឲ្យត្រឡប់មកបែរទៅលើរូបរបស់ឧត្តមបានឡើយ ! ទើបនាងនិយាយត្អូញថា :

"ពុទ្ធោអើយ ! នេះហើយជាកម្មពៀររបស់សារុន!" នាងនិយាយទាំងទឹកភ្នែកហូរស្រោកដោកក្តាលទាំងសង្វាង មុខគួរឲ្យអាណិតអាសូរពេកពេក "ខ្ញុំក៏បានឃើញសេចក្តីស្រឡាញ់ដ៏ពិតប្រាកដរបស់លោកជាក់ស្តែងហើយ ! ប៉ុន្តែ ៗ លោកកុំឲ្យខ្ញុំថាឡើយ" នាងឈប់ដកដង្ហើមវែងមិនដឹងជាអ្វីទៀត ហើយយកដៃទាំងពីរបិទមុខផ្ដប់នៅនឹងភ្នាក់កៅអីយ៉ាងហោស ; ពាក្យចុងក្រោយបង្អស់ដែលនាងសារុនពោលចេញមកនោះ ធ្វើឲ្យឧត្តមបាក់ទ្បាក់កំឡោះស្ទើរតែបាត់ស្មារតី , ភ្នែកទាំងពីរមើលទៅដោយអារម្មណ៍រវើរវាយ ហើយមានព័ណ៌ក្រហមព្រឿងៗមកមុខគួរឲ្យសង្វេគ, ទើបឧត្តមលូកដៃទៅចាប់ដៃនាងសារុនហើយថា :

"ប្អូនសារុន ! ឱ ! ប្អូនមិនស្ម័គ្រចិត្តរៀបការនឹងបងសោះហើយឬ ? ឧត្តមនិយាយទាំងខ្សឹកខ្សួល ទឹកមុខឡើងស្លាំងជាងមុនទៅទៀត មុខស្គរឲ្យអាសូរករុណាដល់បុរសកំឡោះនោះពន់ពេក ។

"ចា៎ះ, ទេលោក" - នាងងើបឡើងហើយនិយាយថា "មិនមែនដូច្នោះទេ លោកឧត្តម" នាងសារុនឈប់ដកដង្ហើមធំមួយដងហើយថា "លោកអើយ ! ខ្ញុំ-ខ្ញុំ-មាន-មានគូឯក! ណ្ហើយកុំឲ្យខ្ញុំថាឡើយ" ។

"ប្អូន ! ឧត្តមតាំងចិត្តនឹងស្ងួបញាក់ម្តងទៀតតែហាមាត់ប្រហ ។ ទើបនាងសារុនឆ្លើយតបយ៉ាងខ្សឹកខ្សួលថា "ខ្ញុំផុងចិត្តគំនិតទៅលើលោករួចទៅហើយ" ថាហើយក៏រត់ម្នីម្នាឡើងទៅលើផ្ទះបាត់ទៅ ។ ខាងលោកឧត្តមឈរមើលស្រឡាំងកាំង កើតសេចក្តីទោមនស្សត្រូវចិត្តស្ទើរសន្លប់នៅទីនោះឯង ។

ប៉ុង ! ប៉ុង !- ស្គរតាំក្អឹងលាន់ឮឡើង ក្រោយដែលនាងសារុនរត់ឡើងទៅដល់លើផ្ទះ ឯរាងកាយរបស់បាឡាត់កំឡោះនោះក៏ដួលស្រុសនៅទីនោះឯង ហើយពោលពាក្យចុងក្រោយបន្ទស់ថា:

"ប្អូន — ប្អូនសារុន ! បង — សូមលា — សិនហើយ, ជាតិ — ជាតិក្រោយ - សុំឲ្យបានជួបគ្នា . . . . អូយ ! — អូយ ! — មច្ចុរាជ . . . ." ឧត្តមចំប្រឹងនិយាយតទៅទៀត តែហាមាត់មិនរួច ព្រោះស្តេចមច្ចុរាជចាប់អូសយកជីវិតឧត្តមបាត់ទៅហើយ ។ "ពុទ្ធោ ! ពុទ្ធោ ! អនិច្ចា

សង្ខារទាំងឡាយមិនទៀងទេឡើយ! ក្មេងស្លាប់ទៅមុនចាស់មានគរគោក ដូចរូបឧត្ដមបុរសកំលោះ មានអាយុត្រឹម ២៤ ឆ្នាំប៉ុណ្ណោះបានដល់អនិច្ច-កម្មទៅ ព្រោះតែសេចក្ដីស្នេហា តាំងមុខលះបង់ជីវិតខ្លួនគ្មានអាឡោះអាល័យដោយដៃខ្លួនឯង ៗ មួយវិញទៀត ព្រោះឧត្ដមគិតឃើញថា ជីវិតសត្វលោកតែប្រាសចាកសេចក្ដីស្នេហាជាជីវិតឥតខ្លឹមសារ ព្រោះមនុស្ស-លោកដែលមានជីវិតស្រស់បស់រីករាយសប្បាយនៅក្នុងលោកនេះបាន ដោយសារតែសេចក្ដីស្នេហាជាបច្ច័យ . . . ។

ក្នុងខណៈនោះ បណ្ដាមនុស្សម្នា ក៏ផ្អើលឆោឡោឡើងមកហោមរោមនៅជុំវិញរាងកាយឧត្ដម, តែលោកឧកញ៉ាបរិបូរសម្បត្តិចាត់បម្រើឲ្យយករថយន្តទៅទទួលលោកឧកញ៉ាកជបម្រើនិងលោកស្រីឲ្យមកជាប្រញាប់ ហើយហាមមិនឲ្យនរណាទៅប៉ះពាល់រាងកាយរបស់ឧត្ដមឡើយ ។ លោកឧកញ៉ានិងលោកស្រីជាមាតាបិតាមកដល់ ក៏យំសោកខ្សឹកខ្សួល បោកខ្លួនបោកប្រាណ ដោយកូនសំឡាញ់តែមួយមកបោះបង់ជីវិតកំពុងពេញកំលោះស្អាតដូច្នោះ មុខគួរឲ្យសោកស្ដាយណាស់ លោកឧកញ៉ាម្ចាស់ផ្ទះព្រមទាំងបុត្រភរិយា នាងសារី-នាងសារុន សឹងនាំគ្នាយំសោកដោយសេចក្ដីអាឡោះអាល័យទាំងអស់គ្នា ក្នុងចំណោមអ្នកយំសោកនោះនាងសារុនមានសេចក្ដីអាល័យខ្លាំងយំសោកច្រើនជាងគេ ព្រោះឧត្ដមបាត់បង់ជីវិតទៅនោះ ដោយសារខ្លួននាងឯងជាដើមហេតុ នាងតោងបាត់បង់

សង្សារកំសត់ស្មោះត្រង់បំផុតតែមួយ ក្នុងលោកនេះនឹងរកបុរសដទៃឲ្យមានសេចក្ដីស្មោះត្រង់នឹងនាងស្មើនឹងឧត្ដមពុំមានឡើយ ៗ លុះស្បើយសេចក្ដីសៅសោកគ្រាន់បើបន្តិចហើយ ទើបលោកឲ្យកញ្ញាម្ចាស់ផ្ទះនឹងមាតាបិតានាំគ្នាពិនិត្យមើលសពរបស់ឧត្ដម ឃើញមានកាំភ្លើងដៃនៅនឹងខ្លួនសព ដែលមាតាបិតាស្គាល់ច្បាស់ថាជាកាំភ្លើងគូដៃរបស់ឧត្ដម ក្រៅពីនោះឃើញមានកូនសំបុត្រមួយចំពោះដល់នាងសារុន មានសេចក្ដីខ្លីៗថា

ប្អូនសារុន!

កូនសំបុត្រនេះ ជាសាក្សី សំដែងសេចក្ដីស្នេហាដ៏បរិសុទ្ធរបស់បង! មុនប្អូនបានឃើញសំបុត្រនេះ បងស្មានថាប្រហែលជាបងបែកឋានទៅជាំដូចប្អូនទៅលោកខាងមុខរួចទៅហើយ!

ឱ! សារុន មាសព្រលឹងក្រៃលែងជាងជីវិតរបស់បង ជីវិតបងសព្វ-ថ្ងៃជាជីវិតក្រៀមក្រោះឥតសប្បាយរីករាយបន្តិច! សូមប្អូននៅឲ្យបានសេចក្ដីសុខក្សេមក្សាន្តណា៎ះប្អូនណា៎! ។

ណាសិនហើយៗ! ប្អូនសំឡាញ់ស្មើជីវិត ជាតិក្រោយសឹមជួបគ្នា ហើយសុំឲ្យបានរួមរសស្នេហាកុំបីឃ្លាត!

សួស្ដី!

ប្អូនស្រីសំឡាញ់បង!

ឧត្ដម

គង់ពីនោះ លោកឧកញ៉ាជាមាតាបិតានឹងលោកឧកញ៉ាជាម្ចាស់ផ្ទះ ក៏ចាត់តែងធ្វើបុណ្យឧទ្ទិសផលដល់អ្នកដែលបានទៅតាមទំនៀម ៗ ឯរឿងពាំនៃហេតុអគ្គិវិនិបាតកម្មនេះ ក៏ស្ងប់ស្ងាត់ត្រឹមណោះឯង ព្រោះត្រកូលទាំងពីរធ្លាប់មានមេត្រីភាពនឹងគ្នា ដោយសេចក្តីស្មោះត្រង់តាំងពីដើមរៀង ៗ មក ឥតមានខមោះវៃមមខ្វល់អ្វីដល់គិតឡើយ ៗ

☼

☼ ☼

អំណើះកាលជាលំដាប់មក លោកក៏ត្រូវលោកទៅក្រមក្តែតែងធ្វៀតកេតកាសទៅលេងផ្ទះបរិបូរសម្បត្តិ ក្រាតែមានសេចក្តីស្និទ្ធស្នាលនឹងលោកឧកញ៉ាជាម្ចាស់ផ្ទះព្រមទាំងកុមារីទាំងគូ គឺនាងសារីនឹងនាងសារុន ៗ តាមៈជាយពីគនោះ! លោកក៏ត្រូវចាប់ចិត្តស្នេហាទាំងបងទាំងប្អូន កងចិត្តមិនដឹងជាពេលណាយកណា ប៉ុន្តែគំនិតគិតបងចង់បានទាំងពីរ, មកដល់ត្រង់ណេះខ្ញុំក្បាលលោកក៏តែគិតចលាចលក្នុងពមិនដាច់ស្រេច លុះគិតយូរៗទៅ ក៏ដាច់ចិត្តផ្ទះស្រឡះថា "បើបានបងហើយ តើប្អូននឹងទៅណា!" ៗ

✓ កាលគន្ធងទៅមិនយូរប៉ុន្មាន មានកំណត់រៀបមង្គលការរៀងលោកទៅក្រមក្តែធ្វើការនៅសាលាវិទ្យាល័យជាគូនឹងនាងក្រមុំសារី ធីតារបស់ឧក-ញ៉ាបរិបូរសម្បត្តិ ៗ លុះបានឫក្សពារពេលាល្អ ទើបលោកឧក-ញ៉ាជាម្ចាស់ផ្ទះក៏ឲ្យចាត់តែងប្រដាប់ប្រដាគេហដ្ឋានរបស់លោកដោយខ្ទង់

ជ័យខ្ទង់ជាតិច្រើនជាអនេក ហើយឲ្យចងផួងផ្កានានាតាមបន្ទប់ទ័ងទ្វារ សឹងមានក្លិនក្រអូបឈ្ងុយឈ្ងប់ផ្សព្វផ្សាយទូទៅទាំងគ្រឹហស្ថាន, បណ្ដាភ្ញៀវដែលមានសំបុត្រអញ្ជើញមកលៀងភោជនាហារ ក៏បានមកជួបជុំមិនខ្វះខាត, ធ្វើឲ្យលោកឧកញ៉ាជាម្ចាស់ផ្ទះមានសេចក្ដីសប្បាយរីករាយក្នុងចិត្តក្រៃពេក ; លុះដល់វេលារាត្រី ភ្លើងអគ្គិសនីក៏អុជបំភ្លឺពេញទាំងបរិវេណផ្ទះសឹងមានពណ៌ខៀវ - ស - ក្រហម - លឿង - បៃតងគ្រប់បែបគ្រប់យ៉ាង មានពន្លឺភ្លឺព្រោងព្រាត សឹងល្អមើលជាចំឡែកនៅតាមមែកព្រឹក្សានានា មុខគួរឲ្យមានគេម្រែកត្រេកត្រអាលដល់បណ្ដាភ្ញៀវដែលបានមកជួបជុំនៅពេលនោះទាំងអស់គ្នា ។

ក្នុងវេលារាត្រីនោះព្រះចន្ទរះឡើងពេញដួងបាំងពន្លឺរស្មីមកពាសពេញផ្ទៃផែនដី ហាក់ដូចជួយបំពេញសេចក្ដីសុខក្សេមក្សាន្តដល់ក្រមុំកំលោះទាំងគូ ដែលកំពុងប្រថែលគ្នាលេងក្នុងសួនច្បារក្រោយគេ-ហដ្ឋាន ។ អាការសប្បាយរីករាយដែលប្រកបដោយកិត្តិយសដ៏ថ្កុំថ្កើងនៃពិធីមង្គលការដ៏ឧឡារិកនោះ នាំសំរើបចិត្តរបស់ក្រមុំកំលោះទាំងឡាយឲ្យនឹកចង់រៀបមង្គលការពល់ៗគ្នា ។ បណ្ដាជនប្រុស-ស្រី-ក្មេងចាស់-ពោះម៉ាយ-មេម៉ាយសឹងមានសេចក្ដីរីករាយក្សេមក្សាន្តជូនពរសព្ទ-សាធុការដល់ក្រមុំកំលោះទាំងគូឮសូរសព្ទសាទិន; ចំណែកខាងនាងក្រមុំសារុនជាប្អូនក៏សំដែងទឹកមុខញញឹមឲ្យពរសព្ទសាធុការដូចអ្នកផងដែរ

ប៉ុន្តែខាងក្នុងទ្រូងនាងក្តៅក្រហាយក្រហល់ស្ទើរនឹងឆេះជាភ្លើង តែឥតមានគេណាមួយដឹងដល់បេះដូងរបស់នាងឡើយ   ក្នុងចិត្តរបស់នាងស្រពោនស្រពាប់ស្លុតក្រៀម   ព្រោះសេចក្តីទោមនស្សអន់ចិត្តយ៉ាងក្រៃលែង   ទើបនាងកើតចិត្តធុញទ្រាន់នឿយណាយនឹងមនុស្សលោកនេះជាទីបំផុត   ចង់គេចចេញចាកលោកនេះឲ្យផុតស្រឡះ   ព្រោះពិភពលោកដ៏ធំទូលាយនេះ   ក្លាយទៅជាទីចង្អៀតចង្អល់ចិត្តឥតមានសុខសប្បាយចិត្តបន្តិចឡើយ ។

ទើបនាងក្រមុំសារុនរកឱកាសដកខ្លួនចេញចាកប្រជុំជនហើយចូលទៅកាន់បន្ទប់នាងអង្គុយសោយអារម្មណ៍ក្រៀមក្រំតែម្នាក់ឯង   នាងដាក់ខ្លួនអង្គុយលើកៅអីក្បែរបង្អួចចំហរយកខ្យល់អាកាស តែនាងមិនបើកភ្លើងទេ ទុកឲ្យពន្លឺដួងព្រះចន្ទចាំងចូលមកតាមចន្លោះបង្អួច   ឯខ្លួននាងក៏អង្គុយមើលរស្មីនៃដួងចន្ទយ៉ាងស្រងូតស្រងាត់ ។ ក្នុងខណៈនោះព្រះចន្ទហាក់ដូចមានចិត្តលំអៀងចូលគំនិតនឹងនាងសារ៉ាវ៉ាបងរបស់នាង   ព្រោះយប់នោះភ្លឺអោយស្រឡះ   ពន្លឺព្រះចន្ទភ្លឺច្បាស់ត្រចះត្រចង់ដែលនាំឲ្យក្រមុំកំលោះទើបរៀបការថ្មី   មានសេចក្តីស្នេហាដល់គ្នានឹងគ្នាកាន់តែខ្លាំងឡើង,   ប៉ុន្តែជារឿងផ្ទាស់ចិត្តរបស់នាងក្រមុំសារុនយ៉ាងខ្លាំង   ព្រោះក្នុងវេលានោះ   នាងដេកក៏មិនសុខ   អង្គុយក៏មិនស្រួល   ហាក់ដូចជាក្រហល់ក្រហាយអន្ទះអន្ទែងខ្លួន,   ទើបនាងប្រុះក្រោកទៅឈរនៅមាត់បង្អួចក្រឡេកមើលទៅសព្វទិសានុទិស   ដើម្បីដកដង្ហើមឲ្យបានធូរទ្រូងបន្តិច

ប៉ុន្តែក្នុងខណៈដែលគ្រូឡេកមើលចំទៅស្រាប់តែភ្ញាក់ខ្លួនព្រឺតមានសេចក្តីភិតភ័យតក្កមា ព្រោះបានឃើញរូបភាពមនុស្សស្គមៗ លេចចេញពីស៊ុមទ្រុមគុម្ពឈើមួយក្នុងសួនច្បារ ជារូបបុរសកំឡោះដូចជាខ្មោចដែលទើបស្លាប់ទៅ ហើយអណ្តែតឡើងមកសំដៅមាត់ទ្វារបង្អួចដែលនាងនៅ ក្នុងកាយរបស់នាងគ្រូក៏ញាប់ញ័ររន្ធត់ស្ទើរលើកស្មារតី ចង់ស្រែកហៅគេឲ្យមកជួយក៏ហាមាត់មិនរួច ទឹងឈានជើងរត់ក៏រត់មិនកើត ក៏រឹងគាំងទាំងអស់ នាងឈរស្រឡាំងកាំងមួយស្របក់ ទើបរូបកងបិសាចនោះអណ្តែតឡើងមកចូលតាមចន្លោះបង្អួចមកជិតខ្លួននាងគ្រូៗយកដៃទាំងពីរចាត់ច្រានយ៉ាងខ្លាំងប៉ងឲ្យបិសាចនោះថយឆ្ងាយពីខ្លួននាង តែដៃទាំងពីរដែលខំច្រានចាត់ទៅនោះ ឥតសម្ផស្សប៉ះអ្វីឡើយ ក្រៅអំពីអាកាសទទេ, ហើយរូបបិសាចនោះក៏ឈានជើងដើររំលងក្បាលនាងទៅអង្គុយលើកៅអីមួយដែលនៅចំពីមុខនាង ហាក់ដូចជាមនុស្សមានជីវិតវិញ្ញាណសុទ្ធសាធ ។ នាងគ្រូសារុនក៏ងាកបែរទៅមើលរូបបិសាចនោះ ដោយកិរិយាស្ងួតស្រឡាំងកាំងហាក់ដូចមនុស្សឥតវិញ្ញាណ នាងឃើញច្បាស់ថា រូបបិសាចនោះ គឺជារូបខ្មោចសង្សារកំសត់របស់នាងឥតល្អៀង រហូតដល់សំពត់អាវស្លៀកពាក់ទ្រង់ទ្រាយឫកពា ក៏ជាខ្មោចសុទ្ធសាធដូចជាសំលៀកបំពាក់ក្នុងថ្ងៃដែលស្លាប់ដោយឧបទ្ទវហេតុនោះឯង, នាងគ្រូចាំបានជាក់លាក់ជាប់នៅនឹងភ្នែកនាង, ទើបនាងនឹកតែក្នុងចិត្តថា "មែន

ហើយ ! មែនហើយ ! ជារូបបិសាចឧត្តម សង្សាររបស់នាងជាប្រាកដ" ។ ក្នុងមួយស្របក់នោះ បិសាចនោះក៏សន្សឹមៗ ហាមាត់និយាយបន្តិចៗ; នាងស្រីក្រមុំបានឮសំដីយ៉ាងត្រជាក់ស្រែក ឮស្រួយស្រួចត្រលួចខុសពីមនុស្សធម្មតា មុខគួរឲ្យព្រឺក្បាលយ៉ាងសំបើម; សំដីបិសាចនោះថា:

"នាងសារុនអើយ ! ខ្លួនខ្ញុំនេះ គឺឧត្តមសង្សារកំសត់របស់នាង ។ ចាំខ្ញុំបានទេ ? ទុកជាខ្ញុំស្លាប់បាត់ទៅហើយក៏ពិតមែន ប៉ុន្តែវិញ្ញាណរបស់ខ្ញុំមិនបានស្លាប់ទៅជាមួយនឹងរាងកាយទេ ខ្ញុំនៅមានចិត្តស្រឡាញ់នាងជានិច្ចសូម្បីស្លាប់ទៅជាខ្មោចហើយក៏ដោយ, ពុទ្ធោអើយ ! នាងឥតចិត្តអាណិតអាសូរដល់ខ្ញុំបន្តិចឡើយ នាងគង់បានដឹងប្រាកដហើយថា ឧត្តមនេះជាប់ចិត្តស្នេហាលើរូបនាងត្រឹមណា ? ខ្ញុំស្លាប់ទៅនេះ ដោយសារតែនាងផ្ដាច់មេត្រីចិត្តដាច់ស្រឡះពីខ្ញុំ មិនព្រមរៀបការនឹងខ្ញុំសោះឡើយ ខ្ញុំនឹងទ្រាំទ្រដ៏រែកដំក្រៀមក្រំ មានតែទុក្ខតទៅទៀតពុំបានទេ ទើបលាលះមនុស្សលោកនេះទៅមុន, ឱ, សារុននាងអើយ ជាតិនេះមានកម្មនាំឲ្យនាងឥតចិត្តករុណាខ្ញុំ ជាតិក្រោយសូមនាងមេត្តាខ្ញុំខ្លះផង, សារុន នាងអើយ ! បែរមុខមកញញឹមឲ្យខ្ញុំធូរទ្រូងបន្តិចបំណាច់ចំណៀតមកស្រួដល់បន្ទប់ដេករបស់នាង, ពុទ្ធោអើយ ! ឧត្តមមិនចង់ឃ្លាតចេញពីខ្លួនទន់នាងបន្តិចឡើយ ព្រោះឧត្តមស្រឡាញ់ប្អូនទឹកលើកជានិច្ច តែនឹងមកក្រោះនៅយូរដូច្នេះមិនបានទេ, សារុនអើយ ខ្ញុំសូមលាសិនហើយ.

សូមឲ្យនាងនៅជាសុខក្សេមក្សាន្តទៅចុះ!" ហើយបិសាចនោះក៏ក្រោក ឡើងលើកដៃទាំងពីរដោយទំនងចង់ឱប ហើយនិយាយថា "សារុន នាងអើយ ចូរនាងមកជិតខ្ញុំបន្តិចសិនពា!" ។ ឯនាងស្រីក្រមុំកាល បានស្តាប់សំដីបិសាចមុខគួរឲ្យអាណិតវេទនាដូច្នោះ ខ្លួននាងក៏ដើរចូល ទៅក្បាមទាំងមិនដឹងខ្លួន មានទឹកភ្នែកហៀរហូរចេញមកសស្រាក់, កាលនាងបានចូលទៅជិតខ្លួនបិសាចនោះស្រាប់តែស្ទុះស្រឡាំងកាំងទឹក ឆ្ងល់ណាស់ ព្រោះរូបបិសាចដែលនៅចំពោះមុខនាងនោះបាត់ទៅមួយ រំពេច ។ នាងក្រមុំសារុនទឹកស្តាយណាស់ដែលមិនបានឲ្យសេស្នេហាដល់ ឧត្តម រឿងនេះនាងទឹកក្រៀមក្រំស្តាយក្រោយជាបំផុត ព្រោះក្នុងលោក នេះនឹងរកបុរសដទៃឲ្យមានសេចក្តីស្នេហាស្មោះត្រង់ស្មើនឹងឧត្តមមិនមាន ឡើយ ថែមទាំងបំណងរបស់នាងក៏មិនបានសម្រេចដូចសេចក្តីប្រាថ្នា ព្រោះបុរសកំលោះជាទីគាប់ចិត្តរបស់នាង ដែលមាននាមថាចៅក្រមរត្ន ហើយខ្លួននាងមានសង្ឃឹមថាមុខជាបានរៀនឡើយរួមរស់ស្នេហាជាមួយនឹង នាងនោះ បែរជាបានទៅនាងក្រមុំសារីជាបងស្រីរបស់នាងស្រឡះ ថែម ទាំងខូចបង់ប្រុសកំលោះដែលមានចិត្តស្មោះត្រង់បំផុត ស្រឡាញ់ខ្លួននាង ជាបំផុតទៅម្នាក់ទៀតផង ។

តាំងអំពីការៈនោះរៀងៗមក នាងក្រមុំសារុនចាប់មានចិត្តរវើរវាយ ខ្វល់ ខ្វាញ់ស្មៅហ្មងយ៉ាងក្រៃលែង កងកាយក៏ស្គាំងស្គមស្លេកស្លាំង, បិសាច

ចង្កូមដែលនាងបានឃើញក្នុងយប់នោះទៅជានិមិត្តជាប់ជិតនៅក្នុងចិត្ត របស់នាង ជាហេតុធ្វើឱ្យចិត្តគំនិតនាងកាន់តែភ័យខ្លាចព្រឺឡើងស្ញើរ ទៅជាគ្រុនលលា; នៅវេលាព្រឹកមួយនោះ ចិត្តគំនិតនាងអណ្ដែតអណ្ដូង ភ័យខ្លាចស្លុតស្លាស គិតតែខំប្រយ័ត្នបំភាសពន្លត់សន្យារបស់បងស្រី ដើម្បីឱ្យសេចក្ដីប្រាថ្នារបស់នាងបានសម្រេច, តែនាងស្វែងរកឱកាស ពុំទាន់បាន ដែលនាងបានឃើញសេចក្ដីស្រះស្រលាញ់មិត្តនៃស្វាមី ភរិយាត្រូវនឹងផងទៀត, ការនេះវេលាកាន់តែកន្លងទៅ, សេចក្ដីស្នេហា កាន់តែភ្ជាប់ខ្លួនមាំមួនឡើងរាល់ៗថ្ងៃ ។ អនិច្ចា! ទុក្ខស្ត្រីណាតើការស្នូរ ចាន់ក្រមុំសាវ័ន្តគាន់កេត! នាងឥតយល់កេទុកាសបរទ្បារនិងបំបែកបំបាក់ សន្យារបស់បងស្រីនាងពុំបានឡើយ, ទើបនាំឱ្យរាងកាយរបស់នាង ក្រមុំកាន់តែស្រៀមស្រំស្គាំងស្គមជាយកំឡាំង សម្បុរស្បែកស្គាំងឥតមាន ឈាមស្លក់ក្នុងខ្លួន ។

*

* *

ពិតតាលោកបានរៀបជុំវិញខ្លួនឯង ២៩ ជុំត្រៃជា ២៩ ថ្ងៃ, លោក ចៅក្រមដ៏គួរមានបន្ទាប់ពីពេជ្ជការចេញទៅពិនិត្យក្ដីសំខាន់នៅសាលាជំ ម្រះក្រុងកំពតជាប្រញាប់ហើយដល់វេលាយប់ថ្ងៃផង, ទើបលោកក៏ត្រូវតាំង ចេញចោលភរិយាដាច់ស្នេហាទៅតាំងទីតក្កោក មានសេចក្ដីគាទ្បាះគា-

ល័យដល់គ្រួសារជាបំផុត ព្រោះទើបរៀបការថ្មីៗ ហើយរួមរស់ស្នេហា មិនទាន់បានពេញ ១ ខែផង, ស្រាប់តែមកព្រាត់ប្រាសនិរាសគ្នាទៅទៀត ចោលសង្សារស្រីឲ្យនៅកណ្ដោចកណ្ដែងតែម្នាក់ឯង ។

ក្នុងវេលារាត្រីមួយរំលងអធ្រាត្រហើយ, ទ្វារបន្ទប់ដេករបស់នាងសារី ភរិយារបស់លោកចៅក្រមរ័ត្ន បើមានគេចាំគន់មើលគង់បានឃើញទ្វារ នោះសន្សឹមៗបើកចេញបន្តិចម្ដងៗដោយដៃស្ដ្រីក្រមុំកងតូចស្ដើង, ស្បែកខ្មៅ, ពាក់ខ្មៅ, ទទូរក្រមាខ្មៅ, ឃ្លុំមុខផង, នាងនោះសន្សឹមៗលបដើរចូលទៅក្នុងបន្ទប់, ដៃម្ខាងកាន់កាំបិតស្នៀតសស្គាប ចុងស្រួច កាំបិតនោះមុតជាបំផុត ។ នាងនោះដើរចូលទៅជិតគ្រែដេករបស់នាងសារី នៅវេលានោះ នាងសារីកំពុងដេកលក់យ៉ាងស៊ប់ស្លូនឥតដឹងខ្លួន ប្រមើមបន្តិចឡើយ, ថែមទាំងក្នុងអធ្រាត្រនោះស្ងាត់ជ្រៀប ឥតមានសូរណាមួយក្នុងផ្ទះគួរគ្រហែបដល់តិចសោះ ។ កាលនាងនោះចូលដល់ជិតខ្លួននាងសារីហើយ ក៏ស៊ើយមុខឡើង យកដៃទាំងពីរចាប់កាំបិតលើកឡើងលើផុតក្បាលនាង បំរុងនឹងចាក់ឲ្យចំបំពង់ករបស់នាងសារីដែលកំពុងដេកលក់ស៊ប់នោះ, ស្រាប់តែមានរូបបិសាចឈ្មោះឧត្តមមកប្រាកដជាក់ស្ដែងនៅក្បែរខ្លួននាងសារី ចំពីមុខនាងសារុន ធ្វើឲ្យសារុនក្រមុំស្រីព្រឺគ្រប់រន្ធរោម ព្រឺក្បាលសំពោង: ឯរូបបិសាចនោះស្លៀកសពាក់ស: ការក្បាលខុសប្លែកពីយប់មុន ប៉ុន្តែមុខមាត់ពកកៅគឺឧត្តមហ្នឹងឯង ។

"នាងសារុនអើយ!" បិសាចនោះពោលដោយសូរសំឡេងខ្សាវៗ ល្អមតែនាងសារុនបានឮតែម្នាក់ឯង តែជាសំឡេងខ្លោចសុទ្ធៗ ឱ! សា-រុនអើយ! ចូរនាងកុំធ្វើអំពើអាក្រក់ដូច្នេះឡើយ នាងជាស្ត្រីមិនគួរមានចិត្តកាចសាហាវដល់ម៉្លេះទេ នាងឯងមិនមានចិត្តមេត្តាករុណា អាណិតអាសូរនាងសារីជាបងស្រីរបស់នាងសោះឡើយឬ ? អំពើនេះមិនសមគួរដល់ខ្លួននាងសោះតិចឡើយ នាងគិតសម្លាប់បងស្រីរបស់ខ្លួន ដើម្បីដណ្តើមស្វាមីរបស់គេ ? កុំ-កុំ- នាងគិតខុសច្រើនតែម្តង នាងបំផ្លាញសេចក្តីសុខរបស់បងស្រី-ផ្តាច់ជីវិតបងស្រី ដើម្បីសេចក្តីសុខសប្បាយរបស់ខ្លួន, ខ្ញុំយល់ថា អំពើនេះខុសទាំងតាមផ្លូវលោកទាំងតាមផ្លូវធម៌, ឱ! សារុនអើយ ចូរនាងបោះកាំបិតនោះចោលទៅតាមបង្អួចទៅ, ហើយផ្លាស់គំនិតដែលគិតខុសយ៉ាងធំនេះចេញ: ខ្ញុំគោរពលាទៅសិនណា ប្អូនស្រី តែកុំភ្លេចបណ្តាំរបស់ខ្ញុំដែលបានមកជួបអ្នកក្នុងគ្រានេះឲ្យសោះ ។ រួចបិសាចនោះក៏សន្សឹមៗ បាត់ទៅនៅជ្រុងជើងមុងនោះឯង ។

កាលនាងគ្រមុំសារុនបានស្តាប់សំដីបិសាចជាសព្វគ្រប់ របស់នាងចប់ហើយ ចិត្តគំនិតនាងក៏ទន់ល្វន់ដូចគ្រួនគ្រាប់ថ្មមួយរំរប, ដៃទាំងពីរដែលចាប់កាំបិតនោះក៏ជ្រះរបូតទៅក្រោយខ្នងនាងទៅ ហាក់ដូចជាមិនមានសរសៃស្រាប់យឹតយោងអវយវៈសោះឡើយ, ហើយនាងភ្ញាក់

ស្មារតីដឹងខ្លួនថានាងប្រព្រឹត្តខុសទំនងគន្លងធម៌យ៉ាងធំតែម្ដង, តែអាល នាងនឹកដល់សេចក្ដីស្នេហា នាងនឹកស្ដាយនឹកខ្ញាញ់ក្នុងចិត្តជាទីបំផុត, សំឡឹងឃើញលោកដ៏ធំទូលាយនេះមិនមានប្រយោជន៍មិនមានសេចក្ដីសុខដល់នាងសោះឡើយ, មើលឃើញសុទ្ធតែទុក្ខទាំងមានរសជាតិល្វីងជូរចត់ទាំងអស់, នាងខូចបង់ប្រុសកំលោះដែលមានសត្យសុចរិតស្មោះត្រង់ជាបំផុតទៅដោយខ្លួននាងឯងទៅប៉ុនប៉ងចង់បានឈ្មោះរ័ត្ន ដោយនាងនឹកសង្ឃឹមថានឹងបានឈ្មោះនេះមកជារបស់នាង, ប៉ុន្តែទទេធេង; ជៀតឈ្មោះរ័ត្នបែរជាទៅរៀបការនឹងបងស្រីរបស់នាងវិញ, សមដូចពាក្យគេតែងនិយាយថា "រួចទាំងត្រី រួចទាំងទន្សាយ" ដែលមានដំណាលក្នុងរឿងសុភាទន្សាយ ៗ សំដីគ្រប់ម៉ាត់របស់បិសាច សុទ្ធតែចូលជ្រួតជ្រាបដល់បេះដូងរបស់នាង, ទើបអាចដាស់តឿនគំនិតគិតខុសរបស់នាងក្នុងខណៈនោះបាន ប៉ុន្តែនាងនៅតែខ្ញាញ់មិនបាត់ដោយបងស្រីនាងដណ្ដើមយកឈ្មោះរ័ត្នរបស់នាងទៅ ត្រូវតែនាងសម្លាប់បងស្រីសងសឹកដើម្បីឲ្យបានសម្រេចតាមចំណង់របស់នាង ប៉ុន្តែឥឡូវនេះនាងនឹងប្រព្រឹត្តដូច្នោះមិនបានទេ; ព្រោះជាអំពើបាបធំណាស់ សឹងត្រូវទុកទោសយ៉ាងធ្ងន់ទាំងខាងគតិលោក ទាំងខាងគតិធម៌ សមដូចពាក្យបិសាចគ្រប់ប្រការថែមទាំងមានចិត្តអាណិតបងស្រីនាងខ្លះផង; បើដូច្នេះ ធ្វើម្ដេចខ្លួននាងនឹង

បានឈ្មោះតែមកជាកម្មសិទ្ធិរបស់នាង? នៅទីបំផុត នាងស្រីក្រមុំសារុន គិតដាច់ស្រេចក្នុងចិត្តថា ខ្លួននាងនៅមានជីវិតរស់នៅក្នុងលោកនេះដរាបណា, នឹងមិនបានសេចក្ដីសុខដរាបនោះ; បើដូច្នេះ នាងមានជីវិតរស់នៅតទៅទៀតក៏ជាការឥតប្រយោជន៍ ! គួរនាងទៅស្វែងរកសេចក្ដីសុខនៅលោកខាងមុខវិញប្រសើរជាង ។ មួយទៀត នាងនឹកអរគុណបិសាចនោះជាទីបំផុត ព្រោះថាប្រសិនបើបិសាចមិនបានទៅរំលឹកដាស់តឿនស្មារតីនាងក្នុងខណៈនោះទេ, មុខជានាងភ្លាត់បំណាច់ធ្វើឃាតកម្មបងស្រីនាងជាប្រាកដពុំខាន, ម្ល៉េះសមកើតហេតុធំទៅថ្ងៃក្រោយ, ឯចំណង់របស់នាងបានសម្រេចឬមិនបានសម្រេចក៏នឹងប្រកាន់យកជាការទៀងទាត់ពុំបានដែរ ។ ឥឡូវនេះនាងក្រមុំ មានស្មារតីភ្លឺច្បាស់យល់ការខុសត្រូវគ្រប់ប្រការ ទើបនាងគិតឃើញថាបុរសកំលោះឈ្មោះឧត្តមជាប្រុសឯកក្នុងលោកនេះ ដែលមានចិត្តស្នេហាស្មោះត្រង់បំផុត, ស៊ូលះបង់ជីវិតខ្លួន ដើម្បីជាសាក្សីនៃសេចក្ដីប្រឡាញ់ដ៏បរិសុទ្ធ; ស៊ូម្បីស្លាប់ទៅជាខ្មោចបិសាចហើយក៏នៅតាមមកសំដែងសេចក្ដីស្នេហា ថែមទាំងជួយទំនុកបំរុងខ្លួននាងឲ្យបានរួចរបូតពីអំពើបាបយ៉ាងធំទៀតផង, បើដូច្នេះគួរតែខ្លួននាងក្រមុំសម្រលកាយ សម្រលចិត្តទៅតាមបំណងរបស់គេទើបត្រូវ, មិនគួរខ្លួននាងរឹងទទឹងនឹងមេត្រី

ចិត្តដ៏បរិសុទ្ធរបស់គេឡើយ, គួរខ្លួននាងទៅតាមបិសាចឈ្មោះ ឧត្តម ដើម្បីរួមរស់ស្នេហាទាំងសុខទុក្ខជាមួយគ្នា នៅនាលោកខាងមុខ ក្នុងវេលាគ្រាតទៅនេះចុះ ។ នាងស្រីក្រមុំសារុនគិតស្រេច ទើបរើសកាំបិតដ៏មុតស្រួចនោះមកមួយរំពេច ហើយចាប់កាំបិតដោយដៃទាំងពីរ ហើយចាក់ចំចុងដង្ហើមរបស់នាងឯង ដោយពេញទំហឹងដៃ, ទើបកងកាយដ៏តូចស្តើងរបស់ខ្លួននាងក្រមុំ ក៏ដួលស្រូសហូរឈាមស្រោចពាសពេញបន្ទប់ដេករបស់បងស្រីនោះឯង ដាច់ខ្យល់ស្លាប់មួយរំពេច ឥតមានស្ទូរស្រែកបន្តិចឡើយ ។

អនិច្ចា! ជីវិតស្ត្រីក្រមុំព្រហ្មចារិណី ជាបុត្រីរបស់លោកឧកញ៉ាបរិបូរសម្បត្តិ បានក្សិណក្ស័យហើយ, មុខគួរឲ្យអាណោចអធម្មជាទីបំផុត, ដោយឧប្បត្តិហេតុចំឡែកណាស់ជារហស្យកម្មអស្ចារ្យ; គ្មាននរណាមួយដឹងរឿងរ៉ាវថ្មមានមោះមែមន្ទិលសង្ស័យឡើយ; មើលទៅហាក់ដូចជារឿងស្ងាត់កំបាំងជ្រាលជ្រៅណាស់ ប៉ុន្តែពាក្យចចាមអារ៉ាមច្រើនធ្លាក់ទៅលើនាងសារីដែលជាបងស្រី ព្រោះស្លាប់នៅក្នុងបន្ទប់របស់នាង, ប៉ុន្តែស្ត្រីបងប្អូនទាំងពីរនាក់ឥតមានរឿងទាស់ទែងគ្នាបន្តិចបន្តួចសោះ, បណ្តាមនុស្សម្នាទាំងលោកឧកញ៉ាជាមាតាបិតា ក៏គ្មាននរណាមួយមានទង្គៀសក្នុងចិត្តដល់គិតឡើយ ។ ហើយលោកឧកញ៉ាជាម្ចាស់ផ្ទះបានទោះសត្វ

ទៅប្រាប់លោកចៅក្រមរ័ត្នឯខែត្រកំពត ថាអាដំសារុនមានគ្រោះថ្នាក់ តែកុំឲ្យចៅក្រមរ័ត្នព្រួយបារម្ភ ថ្ងៃក្រោយទើបបានដឹងរឿងសព្វគ្រប់ ។ លោកចៅក្រមរ័ត្នទូរសព្ទសួរថា គ្រោះថ្នាក់ដូចម្ដេច ? លោកឧកញ៉ាឆ្លើយថា បន្តិចបន្តួចទេ កុំព្រួយអី ។ ចំណែកខាងកងការរក្សាទឹកដីគឺបាត់ការស៊ើបពិនិត្យឃាតកកម្មនោះយ៉ាងម៉ឺងម៉ាត់ ប៉ុន្តែចាប់រកហេតុពិតមិនបានឡើយ ទាំងកាំបិតស្នៀតដែលប្រើប្រហារជីវិតរបស់នាងក្រមុំនោះ ក៏គ្មាននរណាដឹងថាជារបស់នរណា គ្មាននរណាដែលបានឃើញសោះ ។

*

* *

យប់ថ្ងៃកន្លងទៅយ៉ាងស្រួលទន់ដូចជាគ្រឿងចក្រ សារព័ត៌មានបានចុះផ្សាយរឿងនេះយ៉ាងអឹកធឹក ហើយផ្សាយទៅគ្រប់ខែត្រខណ្ឌក្នុងកម្ពុជរដ្ឋ ។ នៅខែត្រកំពត សារព័ត៌មានក៏ផ្សាយទៅដល់សាលាដំបូងមុនបង្អស់ ឯលោកចៅក្រមរ័ត្នក៏បានចាប់យកកាសែតលើកឡើងមើលភ្លាម ស្រាប់តែភ្ញាក់ខ្លួនព្រើត ដោយលោកបានចោលភ្នែកក្រឡេកទៅឃើញចំណងជើងមួយអក្សរធំៗ:

ឃាតកកម្មចំឡែក

នៅគេហដ្ឋានបរិបូរសម្បត្តិ

កាលពីថ្ងៃ ២ មេ ឆ្នាំនេះ - នៅគេហដ្ឋានបរិបូរសម្បត្តិ ឃុំលេខ ៤ ក្រុងភ្នំពេញ មានឃាតកកម្មស្ត្រីក្រមុំរូបឆោមស្រស់បស់ម្នាក់ អាយុ ១៧ ឆ្នាំ ជាបុត្រីលោកឧកញ៉ាបរិបូរសម្បត្តិឈ្មោះនាងសារុន ។

ក្នុងវេលាយប់រំលងអធ្រាត្រហើយ នាងក្រមុំនោះដេកនៅក្នុងបន្ទប់ដេករបស់ខ្លួនជាប់នឹងបន្ទប់មាតាបិតា ទាំងមាតាបិតានិងមនុស្សក្នុងផ្ទះក៏បានឃើញទាំងអស់គ្នា ប៉ុន្តែនាងត្រឡប់ជាទៅដេកស្លាប់ក្នុងបន្ទប់របស់បងស្រីដែលនៅជាប់ដោយឡែកគ្មាននរណាមួយដឹងដើមហេតុឬមានចម្ងល់សង្ស័យដល់តិចឡើយ ។

នាងក្រមុំសារុននេះទទួលអនិច្ចកម្មដោយអំណាចកាំបិតស្នៀតមួយមានចុងស្រួចមុតបាក់ចំចុងដង្ហើម ដេកស្តូកស្តឹងស្លាប់ក្បែរគ្រែដេករបស់បងស្រី ។ ក្នុងខណៈដែលយើងបានទទួលដំណឹងនេះ មិនទាន់ដឹងជាក់ច្បាស់ថា នាងស្លាប់ដោយដៃរបស់អ្នកដទៃឬដោយដៃរបស់ខ្លួនឯង,ប្រសិន

បើនាងធ្វើអត្តវិនិបាតកម្មខ្លួនឯងទេ ម្ដេចក៏មកដេកស្លាប់ក្នុងបន្ទប់របស់បងស្រីនោះវិញ ? ទីងថា នាងស្លាប់ដោយដៃរបស់បងស្រីក៏មិនឃើញមានទំនងសោះ ព្រោះស្ត្រីទាំងគូនេះមិនដែលមានរឿងទាស់ទែងខ្វែងគំនិតគ្នាដល់តិចឡើយ ចុះហេតុអ្វីក៏នាងមកស្លាប់ក្នុងបន្ទប់របស់បងស្រី ? រឿងនេះស្ងាត់កំបាំងពន់ពេក ស្ទើរតែហួសវិស័យនឹងរកឲ្យឃើញសេចក្ដីពិត សព្វថ្ងៃនេះពួកការរក្សាទឹកដីកំពុងស៊ើបពិនិត្យរកដើមហេតុយ៉ាងម៉ឺងម៉ាត់; យើងមានសេចក្ដីសង្ឃឹមថា ពួកការ នឹងស៊ើបរកសេចក្ដីពិតឲ្យឃើញជាក់ស្ដែងនៅថ្ងៃក្រោយជាប្រាកដ ៕

កាលលោកពៅក្រមរ័ត្នអានដំណឹងចំរៀកនេះចប់, កាសែតក៏ជ្រុះរបូតធ្លាក់ពីដៃមិនដឹងខ្លួន ដោយលោកមានចិត្តក្រឡាកាលយ ស្ដាយនាងសារុនយ៉ាងក្រៃលែង, ដែលតាំងមានព្រួយបារម្ភលើសលប់, ដ្បិតនាងទៅដេកស្លាប់ក្នុងបន្ទប់ដេករបស់ភរិយាខ្លួនដែលត្រូវជាប់ចោទយ៉ាងមាំទៅលើរូបភរិយា ។ ក្នុងរាត្រីនោះ លោករ័ត្នកើតទុក្ខព្រួយខ្សត់ខ្សោលសោក

ក្រៀមក្រំជាពន្ទឹក ។ឃើញសុទ្ធតែជាគ្រោះកាចចាំងអស់, ម្ល៉ោះហើយក្នុងយប់នោះលោកចៅក្រមរត្នដេកមិនលក់ អន្ទះអន្ទែងក្នុងខ្លួនយ៉ាងចំឡែក, តាំងចិត្តថា ដល់ព្រឹកឡើងនឹងសុំច្បាប់មកក្រុងភ្នំពេញ ដើម្បីស៊ើបសួររឿងរ៉ាវនោះ ។

នាឡិកាក្នុងផ្ទះវាយឮសូរម៉ោង១ បួនដង លោកចៅក្រមរត្នទោះដេករសាប់រសល់មិនទាន់លក់នៅឡើយទេ ស្រាប់តែឮសំឡេងទ្វារស្រួចមកតាមចន្លោះបង្អួចក្បែរដំណេក ទើបលោកក្រោកឡើងអង្គុយក្រឡេកមើលទៅតាមចន្លោះបង្អួច ស្រាប់តែឃើញរូបរាងស្ត្រីក្រមុំម្នាក់ស្លៀកខ្មៅពាក់ខ្មៅសក់រំសាយចំប្រែះស្មា រាងរៅដូចនាងសារុនប្អូនថ្លៃសុទ្ធសាធ; ស្ត្រីនោះកាន់តែអណ្តែតជិតមក ៗ ហើយហាមាត់និយាយឮសូរគ្រលួចជាសំឡេងខ្មោចថា:

“អ្នកបងរ័ត្ន អ្នកបងកំពុងធ្វើអីនៅនេះ? លោករត្នភ្ញាក់ព្រើត ព្រឺក្បាលសំពោង តែកមើលទៅចំរាងស្ត្រីក្រមុំនោះមិនប៉ប្រែច ចាំបានជាក់ច្បាស់ថាជារូបនាងសារុនដែលទើបទទួលអនិច្ចកម្មទៅកាលពីប៉ុន្មានថ្ងៃមុននេះ ស្រាប់តែលាន់មាត់ដោយមិនដឹងខ្លួនថា

“ឱ! ប្អូនសារុន ឬ?

“ អ្នកបងនៅចាំខ្ញុំបានឬ ? ពុទ្ធោ! ពុទ្ធោអើយ អ្នកបងមិនដឹងទេឬដែលសារុនស្លាប់តើស្លាប់ដោយហេតុអ្វី ? អ្នកបង! អ្នកបងចាំស្តាប់ឲ្យ

ប្រាស់ពត៌:   នឹកតាំងពីថ្ងៃដែលខ្ញុំបានជួបនឹងអ្នកបងនៅថ្ងៃដែលកើតទុក្ខព្រាត់-ហេតុដោយបក្រែហានយក្ខនោះ   ចិត្តគំនិតស្ទើរជាប់នៅគំនិតចំណងស្នេហាដកខ្លួនមិនរួចតែម្តង, ឱ! អ្នកបងអើយ! ថ្ងៃនោះហើយដែលព្រះកាមទេពជាម្ចាស់ទ្រង់ផ្តែងសរផ្កាមកត្រចៀកបេះដូងរបស់ខ្ញុំ,   ធ្វើឲ្យខ្ញុំផុងចិត្តស្រ-ឡាញ់អ្នកបងយ៉ាងខ្លាំងបំផុត   តែចំណែកខាងអ្នកបងមិនសំដែងសេចក្តីស្នេហាតបឡើយ   ថែមទាំងបានរៀបការនឹងអ្នកបងសារីទៅទៀត,   ទើបធ្វើឲ្យខ្ញុំកាន់តែកើតទុក្ខក្រៀមក្រំយ៉ាងលើសលន់គណនា   ធុញទ្រាន់នឿយណាយនឹងមនុស្សលោកនេះជាទីបំផុត   ទើបខ្ញុំប្រហារជីវិតខ្លួនឯងដោយកាំបិតស្នៀត   ហើយខ្ញុំក៏ស្លាប់-ស្លាប់ព្រោះតែស្នេហាលើរូបអ្នកបង; ឱ ! អ្នកបងអើយ ! ណាក់ចាំងក៏ ,   កាំបិតស្នៀតនោះហើយដែលខ្ញុំកាន់ចូលទៅក្នុងបន្ទប់បងសារីការីយារបស់អ្នកបង   ប៉ងនឹងសម្លាប់បងស្រី   ដោយកំណាចប្រណែនទំនងស្នេហាដ៏ងងឹតមុខបំផុត ប៉ុន្តែគាត់ចួនជាបិសាចទុត្តមសង្ក្រកំសត់របស់ខ្ញុំបានទៅប្រាកដជាក់ស្តែងខ្លួនខ្ញុំប្រជាំកងពេលនោះ,   ទើបខ្ញុំបានស្មារតីឡើង   ហើយយកកាំបិតនោះប្រហារជីវិតខ្លួនឯងវិញ : ឱ ! អ្នកបង ! ឥឡូវខ្ញុំលែងស្រឡាញ់អ្នកបងហើយ   ខ្ញុំបានបំភ្លេចរឿងការទាំងនោះអស់ហើយ   សូមឲ្យអ្នកបងរីករួមនឹងអ្នកបងសារីប្រកបដោយសេចក្តីសុខសប្បាយតរៀងៗទៅចុះ! ៗ មួយវិញទៀត   ដើម្បីជាសេចក្តីសង្ស័យរបស់មនុស្សលោកឲ្យបានជ្រះ

ស្រឡះ, កុំឲ្យគេមានសេចក្ដីងឿងឆ្ងល់តទៅទៀត សូមឲ្យអ្នកបងជ្រាបថា បុរសកំឡោះដែលឈ្មោះ ឧត្ដម ធ្វើអត្តវិនិបាតកម្មខ្លួនឯងនៅក្រោយគេហដ្ឋានលោកឧត្តមកគ្គិសួនច្បារនោះ, ព្រោះតែគេចាប់ចិត្តស្នេហាយ៉ាងខ្លាំងលើរូបខ្ញុំ តែខ្ញុំមិនព្រមស្រឡាញ់មិនព្រមរៀបការនឹងគេ: ទើបគេសម្លាប់ខ្លួនគេបង់ទៅ ដើម្បីប្រកាសឲ្យឃើញសេចក្ដីស្នេហាដ៏បរិសុទ្ធរបស់គេមកលើរូបខ្ញុំ; ឥឡូវនេះខ្លួនខ្ញុំនឹងគេបានជួបជុំមូលមិត្រគ្នាហើយ! ពិតមែនតែយើងទាំងពីរនាក់មិនបានរួមរស់ស្នេហាជាមួយគ្នានៅនាស្ថានមនុស្សលោកនេះ ប៉ុន្តែនៅនាលោកបិសាចខាងនាយឯណោះ រសជាតិនៃសេចក្ដីស្នេហាក៏មិនចាញ់ប្រៀបមនុស្សលោកនេះប៉ុន្មានទេ; ល្ហើយ, អ្នកបង ខ្ញុំសុំលាសិនហើយ!" ។ ហើយរូបបិសាចនាងសារុនក៏បាត់ពីទីនោះទៅមួយរំពេច; លោកចៅក្រមក៏អង្គុយស្រឡាំងកាំងនៅទីនោះមួយស្របក់ធំ ទើបភ្ញាក់ខ្លួនមានសតិសម្បជញ្ញៈឡើង ។ ដោយសេចក្ដីសាស័ព្ទប្រាប់រឿងរ៉ាវសព្វគ្រប់របស់បិសាចនាងសារុននោះហើយ បានជាគេអាចចងក្រងរឿងរ៉ាវនេះបានសម្រេច ឲ្យឈ្មោះថា "រឿងបិសាចស្នេហា" ។

ចប់រឿងបិសាចស្នេហាតែប៉ុណ្ណេះ ។

កុម្ភជាតក

(តមកនឹងចប់)

ពួកអាយុត្តកបុរសនាំយកសេចក្តីទៅក្រាបបង្គំទូលព្រះមហាក្សត្រថា: "ខ្ញុំទាំងឡាយផឹកស្រាពុលស្លាប់អស់ទៅហើយ" ព្រះរាជាក៏ទ្រង់ព្រះពិរោធឡើងថា: "ពួកទាំងនេះជាអ្នកធ្វើថ្នាំពុលឬទេតើ" ហើយទ្រង់បង្គាប់ឲ្យកាត់ក្បាលជនទាំងពីរនោះក៏ចង់ផឹកស្រាហើយក៏ស្រែកថា: "បពិត្រព្រះសម្មតិទេព ទឹកឆ្ងាញ់ៗ" ដូច្នេះ ដរាបតែស្លាប់ទៅទើបបាត់មាត់ ។ ព្រះរាជាទ្រង់បង្គាប់ឲ្យសម្លាប់អ្នកទាំងពីរនោះហើយ ឲ្យរំលាយពាងថុចិន[១] ថែមទៀត ។ លុះផល់ស្រាសាបហើយ ខ្ញុំទាំងឡាយក៏ក្រោកឡើងលេង បាក់កញ្ចក់ខ្ទៀវក្ដា ទើបពួកអាយុត្តកបុរសនាំយកសេចក្តីទៅក្រាបបង្គំទូលព្រះរាជា ។ ទ្រង់ព្រះចិន្តនាការថា: "បើទឹកនោះជាទឹកពុល សមជាខ្ញុំទាំងនោះស្លាប់ ទឹកនោះមានសេចក្ដីឆ្ងាញ់ពិតមែនទេដឹង អញនឹងផឹកលងមើលអេះ" ហើយទ្រង់បង្គាប់ឲ្យរាជសេវកាមាត្យទាំងឡាយរៀបចំប្រដាប់តែងព្រះនគរ ឲ្យធ្វើបារាំមណ្ឌបក្នុងព្រះរាជលាន ហើយទ្រង់ឡើងគង់លើព្រះរាជបល្ល័ង្ក ក្រោមស្វេតច្ឆត្រ ក្នុងមណ្ឌបដែលប្រដាប់តុបតែងដោយគ្រឿងអលង្ការមហាប្រសើរ មានពួកអមាត្យហែហមជាបរិវារ ព្រះអង្គប្រុងប្រៀបនឹងសោយស្រា ។

គ្រានោះ សម្ដេចសក្កទេវរាជ ទ្រង់ប្រមើលមើលទូរសត្វលោកថា: "នរណា ខ្លះហ្ន៎ ជាអ្នកប្រព្រឹត្តសម្រេចកុសលធម៌ទាំងឡាយ មានការ

---

១ បុរាណហៅថា ពាង, ប៉ូវ, កំប៉ុក. សម្រាប់បិទស្រា ។

បម្រើនូវមាតានិងបិតាជាដើម! អ្នកណា ខ្វះហ្នឹ ជាអ្នកបំពេញនូវសុចរិត ទាំង៣! សម្តេចសហស្សន័យក៏បានឃើញនូវព្រះបាទសត្តុមិត្ត កំពុងតែ គន់ប្រុងប្រៀបនឹងសោយសុក ព្រះអង្គទ្រង់ព្រះចិន្តនាការថា: "បើព្រះបាទ សត្តុមិត្តនេះសោយសុក មុខជាអ្នកជម្ពូទ្វីបទាំងអស់នឹងវិនាស បើដូច្នោះ មានតែអញនឹងធ្វើស្តេចនោះកុំឲ្យសោយសុកបានអេះ" ហើយទ្រង់កាន់ យកក្អមមួយ ដាក់សុកពេញក្អែងភេទជាព្រាហ្មណ៍មកស្ថិតនៅឰដ៏អាកាស ក្នុងទីចំពោះព្រះភក្ត្រព្រះរាជាហើយពោលពាក្យនាយថា: "អ្នកទាំងឡាយចូរ ទិញក្អមនេះចុះ អ្នកទាំងឡាយចូរទិញក្អមនេះចុះ" ។ ព្រះបាទសត្តុមិត្ត បានទ្រង់ទស្សនាការឃើញនូវព្រាហ្មណ៍នោះ ស្ថិតនៅឰដ៏អាកាស ហើយនិយាយដូច្នោះ ក៏ទ្រង់មានព្រះបន្ទូលចរចាជាមួយនឹងព្រាហ្មណ៍ នោះថា "ព្រាហ្មណ៍ឯងទើបមកពីណាហ្នឹង? ហើយទ្រង់ពោលបទព្រះ គាថា ៣ ព្រះគាថាដូច្នេះថា:

១– កោចាតុរាសី តិដ្ឋសិ នភម្ហិ

ឱភាសយំ សំវរី ចន្ទិមាវ

គត្តេហិ តេ រស្មិយោ និច្ឆរន្តិ

សតេរិតា(១) វិជ្ជុរិវន្តលិក្ខេ ។

---

១ ឱរោបិតេ ចក្កេ សតេរតាតិ បាឋោ ។

អ្នកឯងមកពីណា អ្នកមកអំពីពិភពនៃត្រៃត្រឹង្សឬកើតនៅក្នុងអាកាស ខេះទេ ក៏បំភ្លឺក្រឡៃស្វាងរុងរឿង ដូចជាព្រះចន្ទដល់ម្ល៉េះៗ រស្មីនៃអ្នក ដែលផ្សាយចេញអំពីខ្លួន ហាក់ដូចជាផ្កាយព្រឹកឈ្មោះសុក្រតារា ដែល លេចឡើងក្នុងកណ្ដាលអាកាស ។

២ — សោ ឆិន្នកាំ កាមសី អយម្ភិ
វេហាសយំ គច្ឆសិ តិដ្ឋសី ច
ឥទ្ធី នុ តេ វត្ថុកតា សុភាវិតា
អនទ្ធគូនម្បិ[1] ទេវតានំ ។

អ្នកឯងឥតមានទ្យល់ចុងឡើងទេ ប៉ុន្តែប្រព្រឹត្តទៅក្នុងអាកាសដ៏ ពេលក៏បាន អ្នកឯងនៅឬស្ថិតនៅក្នុងអាកាសវេហាសក៏បាន រិទ្ធិដែល អ្នកឯងធ្វើឲ្យជាទីពឹង (របស់ខ្លួន) ដែលអ្នកឯងចំរើនហើយដោយល្អ (ហាក់ដូចជាមិនមែនរិទ្ធិរបស់មនុស្ស) ប្រហែលជារិទ្ធិរបស់ទេវតាដែល ជាអ្នកមិនដែលដើរដីទៅកាន់ផ្លូវឆ្ងាយទេដឹង[2] ។

៣ — វេហាសយំ កាមមាគម្ម[3] តិដ្ឋសិ
កាតុំ កិំ សោជាតិ យេនកមត្ថំ
តោ ក តុំ កិស្សវតាយ ការម្ភោ
អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ ។

---

១ ឧភោបិយោគ្គកេ អនទ្ធគូនំ អបិ ។ ២ ទេវតាទាំងឡាយអើបមាគមំណើរទៅកាន់ ទីឆ្ងាយ រមែងហោះទៅតាមអាកាស ។ ៣ ឧភោបិបវេ គ្គកេ សង្គមាគម្មតិ ជាបេ ។

- អ្នកឯងឈានទៅក្នុងអាកាសវេហាស៍ ហើយឈរពោលពាក្យនាយថា: "អ្នកទាំងឡាយចូរទិញក្អមចុះ" អ្នកឯងឈ្មោះអ្វី? ម្យ៉ាងទៀត ក្អមនេះជាក្អមអ្វី? ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ ។

លំដាប់នោះ សម្ដេចសក្កទេវរាជ បានទ្រង់ព្រះសវនាការហើយ ទ្រង់មានព្រះបន្ទូលថា: "បើដូច្នោះសូមព្រះអង្គទ្រង់ព្រះសណ្ដាប់ចុះ" ហើយទ្រង់សំដែងនូវទោសសុរាថា:

៤– ន សប្បិ កុម្ភោ នបិ តេលកុម្ភោ
ន ផាណិតស្ស ន មធុស្ស កុម្ភោ,
កុម្ភស្ស វជ្ជានិ អនប្បកានិ,
ទោសេ ពហូ កុម្ភគតេ សុណាថ ។

ក្អមនេះមិនមែនក្អមសប្បិ មិនមែនក្អមប្រេង មិនមែនក្អមស្ករអំពៅ មិនមែនក្អមទឹកឃ្មុំទេ, ទោសរបស់ក្អមនេះមានច្រើនប្រការ, សូមព្រះករុណាទ្រង់ព្រះសវនាការនូវទោសដ៏ច្រើនដែលមាននៅក្នុងក្អមនេះចុះ ។

៥– គលេយ្យ យំ បិត្វា, បតេបបាតំ
សោព្ភំ បបាតំ ចន្ទនិយោឡិគល្លំ,
ពហុំបិ ភុញ្ជេយ្យ អភោជនេយ្យំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកឯងផឹកនូវសុរាឯណា ហើយដើរដួលស្រួសស្រស, ធ្លាក់ចុះក្នុងជង្ហុក ក្នុងអណ្តូង ក្នុងរូង ក្នុងរណ្តៅជ្រៅ ក្នុងរំលុង, ហើយត្រូវការបរិភោគតែអាហារដែលមិនគួរបរិភោគជាច្រើន៖ អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៦- យំ វេ(១) បិត្វា ចិត្តស្មិំ អនេសមានោ
អាហិណ្ឌតី គោរិវ ភក្ខសាទី(២),
អនាថមានោ ឧបគាយតិ ណច្ចតិ ច,
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកឯងផឹកនូវសុរាឯណា ហើយមិនបានជាឥស្សរៈលើចិត្ត (ចិត្តគិតយ៉ាងណា ក៏ប្រព្រឹត្តអាការកិរិយាដូច្នោះឥតមានប្រាជ្ញាជាគ្រឿងទប់ទល់ឡើយ) ដូចជាគោដែលស៊ីបាយមុក តែស៊ីហើយកាលណា តែងដើរផ្ទេក, មមកស្វែងរកអាហារក្នុងទីតែផ្កាស, អ្នកប្រមឹកនោះជាមនុស្សគ្មានទីពឹង បើបានឮគេច្រៀងក៏ចូលទៅច្រៀងផង បានឃើញគេរាំ ក៏ចូលទៅរាំផង, អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៧- យំ វេ បិត្វា អចេលកោវ នគ្គោ
ចរេយ្យ គាមេ វិសិខន្តរានិ

១ ឱរោបិយបោត្ថកេ វេសទ្ទោ ន ទិស្សតិ ។ ២ ឱរោបិយបោត្ថកេ ភក្ខសាទិ ។

សម្មុឡ្ហចិត្តោ អតិវេលសាយី [១]

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរាឯណា (ភ្លេចបិទបាំងគ្រឿងខ្មាស) ជាមនុស្សអាក្រាតដូចជាអចេលកៈ ហើយត្រូវទៅពាសស្រុកពាសផ្លូវថ្នល់ ជាមនុស្សមានចិត្តវង្វេង ដេកដើរហួសវេលា; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៨- យំ វេ បិត្វា ឧដ្ឋាយ បវេធមានោ

សីសញ្ច បាហុញ្ច បចាលយន្តោ

សោ នច្ចតិ ទារុកដល្លកោវ

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកនូវសុរាឯណា ហើយក្រោកឡើងដ្រុលដ្រួសងក់ក្បាល ក្តាដៃ ពំរែក (ទៅតាមតែបានឥតមានទំនួល) ហាក់ដូចជារូបយន្តដែលគេធ្វើដោយឈើ; អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ។

៩- យំ វេ បិត្វា អគ្គិទឌ្ឍា សយន្តិ

អថោ សិង្គាលេហិបិ ខាទិតាសេ

ពន្ធំ វធំ ភោគជានិញ្ចុបេន្តិ

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

១ អតិវេលចារីតិបិ បាឋោ ។ (អដ្ឋកថា) ។

ជនទាំងឡាយដ៏ផឹកនូវសុរាឯណា ហើយមានសេចក្ដីក្ដៅក្រហាយដូចជាភ្លើងឆេះ ដេកនៅក្នុងទីតែផ្ដាស សត្វទាំងឡាយមានឧបចកជាដើមចំពាស៊ីក៏មាន ប្រព្រឹត្តអនាចារផ្សេងៗ មានរាំយ, កាប់នឹងសម្លាប់គេជាដើម ដកបតែកដកការពាប់ចងនាំទៅសម្លាប់ ឬរឹបជាន់ទ្រព្យសម្បត្តិអស់ទៅក៏មាន: អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៗ

១០- យំ វេ បិត្វា កាសេយ្យ អកាសនេយ្យំ,
សកាយមាសិនោ អបេតវត្ថោ
សមត្តិតោ វត្តតោ ព្យសន្នោ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកផងផឹកនូវសុរាឯណា ហើយពោលនូវពាក្យដែលគេមិនគប្បីពោល, ទុកជាអង្គុយនៅក្នុងរោងជាទីប្រជុំក៏ភាក្រោកសំពត់ភាវ (មិនដឹងខ្លួន) ជាមនុស្សមានត្របកភ្នែកទន់ព្រមត្រាំនៅក្នុងកំអួតរបស់ខ្លួន ហើយដល់នូវសេចក្ដីវិនាសផ្សេងៗ: អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៗ

១១ - យំ វេ បិត្វា ឧត្តត្ថោ អាវិលក្ខោ
មមេវ សព្វបរិតិ(១) មញ្ញតិ(២)

---

១ សព្វ បរិតិបិ បាហេ (អដ្ឋកថា) ។ (២) ឱ មញ្ញេ ។

ន មេ សមោ ជាតុរេត្ថាបិ ភវោ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

អ្នកជនផឹកនូវសុរាឯណា ហើយក្អេងក្អាងអួតអាងថា ខ្លួនជាអ្នកចាហានហានក្លា ឥតមាននរណាស្មើនឹងខ្លួនឡើយ ជាមនុស្សមានភ្នែកក្រហមជានិច្ច តែងមានសេចក្ដីសម្គាល់មើលងាយថា: ផែនដីទាំងមូលជារបស់អញ ទុកជាស្ដេចដែលជាឥស្សរៈលើផែនដីធំមានព្រំប្រទល់ដល់សមុទ្រទាំងបួន ក៏នៅតែមិនស្មើនឹងអញដែរ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៦ – ឆាតិមាធា កុលបោរិ បេសុណិ(១)

ធុត្តណ្ណីនី ឧក្កយិនី បលាយិនី

ភោកុណាធុត្តាន(២) គតី និកេតោ;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកនូវសុរាឯណា ហើយធ្វើនូវជម្លោះព្រោះសេចក្ដីមើលងាយគេ ជាមនុស្សប្រះបួយពោលពាក្យញុះញង់ ដើម្បីបំបែកបំបាក់គេ ជាមនុស្សមានសម្បុរគគ្រក់ អាក្រាតជាប្រក្រតី បើជួនជាខាចអ្វីរត់ឥតបើគិត ឯលំនៅរបស់ជនទាំងនោះក៏ជាទីប្រជុំនៃពួកអ្នកលេងចាស់; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ឱរោបិយបោត្ថកេ បេសុណានិ ។ ២ ឱរោបិយបោត្ថកេ ភោគានំ ធុត្តានំ ។

១៣ - ឥទ្ធានិ ផីតានិ កុលានិ អស្សុ
អនេកសាហស្សធនានិ លោកេ
ឧច្ឆិន្នភាយជួកតានិមាយ;
តស្មា បុញ្ញំ កុម្មិតំ ករិណាថ ៕

ត្រកូលដែលសម្រឹទ្ធិបរិបូណ៌ដោយវត្ថាលង្ការ នឹងប្រដាប់ប្រដាផ្សេងៗ មានធនធានទ្រព្យច្រើនពាន់, គេធ្វើត្រកូលដូច្នោះឲ្យអស់កេរ្តិ៍អាករ រលីងទៅបាន ព្រោះតែសុរានេះ: អ្នកទាំងឡាយចូរវិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៕

១៤ - ធញ្ញំ ធនំ រជតំ ជាតរូបំ
ខេត្តំ គវំ យត្ថ វិនាសយន្តិ.
ឧច្ឆេទនី វិត្តវតំ កុលានំ;
តស្មា បុញ្ញំ កុម្មិតំ ករិណាថ ៕

ជនទាំងឡាយបំផ្លាញនូវសម្បត្តិផ្សេងៗ មានស្រូវ, ទ្រព្យ, ប្រាក់, មាស, ស្រែដីគោជាដើមឲ្យវិនាសទៅក្តី; ជាអ្នកផ្តិលផ្តាច់វង្សត្រកូលដែលធ្លាប់ប្រព្រឹត្តទៅកាន់សេចក្តីចំរើនឲ្យធ្លាក់ចុះទៅកាន់សេចក្តីវិនាសក្តី ព្រោះតែសុរាឯណា អ្នកទាំងឡាយចូរវិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ៕

១៥ – យំ វេ[1] បិត្វា ទុជ្ជរូបោវ[2] ពោសោ

អក្កោសតិ បិតរំ មាតរញ្ច,

សស្សុបិ[3] គណ្ហេយ្យ អថោបិ សុណ្ហំ

តស្សា កុម្ភមិមំ កិណាថ ។

មនុស្សប្រុសស្ទួតបួត បានផឹកសុរាឯណា ហើយត្រឡប់ក្លាយជាមនុស្សរបើនរឹងរូស ហ៊ានជេរប្រទេចផ្ដាសាបិតាមាតា បើមានម្ដាយក្មេក ហ៊ានចាប់ម្ដាយក្មេក បើមានកូនប្រសា ហ៊ានចាប់កូនប្រសា សម្គាល់ថាជាភរិយារបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៦ – យំ វេ បិត្វា ទុជ្ជរូបាវ នារី

អក្កោសតិ សស្សុរំ សាមិកញ្ច,

ទាសំបិ គណ្ហេ បរិចារិកញ្ច;

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សស្រីស្ទួតបួត បានផឹកសុរាឯណា ហើយត្រឡប់ក្លាយជាមនុស្សរបើនរឹងរូស ហ៊ានជេរប្រទេចផ្ដាសាឪពុកក្មេកឬស្វាមី ភាន់ច្រឡំចាប់ខ្ញុំកំដរ សម្គាល់ថាជាស្វាមីរបស់ខ្លួន; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

---

១ ឧភោបិ ពោត្ថកេ យញ្ច បីត្វា ។ ២ ឱ ទុជ្ជរូបោ ។ ៣ ឱ សស្សុំបិ ។

១៧ - យំ វេ បិត្វាន ហនេយ្យ បោសោ
ធម្មេ ឋិតំ សមណំ ព្រាហ្មណំ វា,
គច្ឆេ អបាយំបិ អតោ និទានំ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនប្រុសស្រីផឹកសុរាឯណា ហើយហ៊ានសម្លាប់ នូវសមណឬព្រាហ្មណ៍ដែលស្ថិតនៅក្នុងសុចរិតធម៌, ក៏ធ្លាក់ទៅកើតក្នុងអបាយភូមិគឺៈ នរក ប្រេត អសុរកាយ តិរច្ឆាន ព្រោះតែការសម្លាប់សមណឬព្រាហ្មណ៍នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៨ - យំ វេ បិត្វា ទុច្ចរិតំ ចរន្តិ
កាយេន វាចាយ ច ចេតសា វា,
និរយំ វជន្តិ ទុច្ចរិតំ ចរិត្វា;
តស្សា បុណ្ណំ កុម្ភមិមំ កិណោថ ។

ជនទាំងឡាយផឹកសុរាឯណា ហើយប្រព្រឹត្តនូវទុច្ចរិតដោយកាយ, ដោយវាចាឬដោយចិត្ត, លុះប្រព្រឹត្តទុច្ចរិតគឺធ្វើអកុសលទាំង ១០ ប្រការ ដោយទ្វារទាំង ៣ ប្រការយ៉ាងនេះហើយ ក៏ធ្លាក់ចុះទៅកើតក្នុងនរក; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

១៩ - យំ យាចមានា ន លភន្តិ បុត្តេ
ពហុំ ហិរញ្ញំបិ បរិច្ចជន្តា,
សោ តំ បិត្វា អលិកំ ភណាតិ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

បុរសស្ត្រីទាំងឡាយឯណា កាលដើមឡើយជាមនុស្សពោលពាក្យសត្យប្រាកដប្រជា ទុកជានរណាមួយឲ្យប្រាក់សំណូកជាច្រើន ហើយអង្វរគេថា: “សូមអ្នកនិយាយកុហកបន្តិចចុះ” ដូច្នេះក៏នៅតែមិនបាន លុះបុរសស្ត្រីនោះបានផឹកសុរាវេលាណា ក៏រមែងពោលពាក្យលេះលោះ មិនសមហេតុ - ផល តាំងពីវេលានោះមក អ្នកទាំងឡាយចូរទិញក្អមនេះដែលពេញទៅដោយសុរានោះចុះ ៗ

២០ - យំ វេ បិត្វា បេសលោ[1] បេសយន្តោ[2],
អច្ចាយិកេ ការិយម្ហិ ជាតេ[3],
អត្ថម្បិ សោ នប្បជានាតិ វុត្តោ:
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ៗ

កាលបើមានការរួសរាន់កើតឡើង គេប្រើប្រេសណីយបុរស (បុរសជើងសារ) ដែលផឹកសុរា ឲ្យទៅដើម្បីបញ្ជាក់សេចក្តីដល់អ្នកឯណោះៗ

១ ឱភោបិយបោត្ថកេ បរិត្វា បេសនេ បេសិយន្តោតិ បាឋោ ។ ២ ឱ. បេសិយន្តោ ។
៣ ឱ. ជាតោតិ បាឋោ, សោ ន យុត្តោ ។

សួរថា: អ្នកឯងមកមានការអ្វី ? វាក៏មិនដឹងសេចក្តីអ្វីសោះ ព្រោះស្រវឹងសុរាស្តាប់ពាក្យបណ្តាំមិនបាន: អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២១ - ហិរីមតា អហិរីកតាំ

ឆាតុំ ករោន្តិ មទនាយ(១) មត្តា,
ជីវាមិ សទ្ធា ពាហុតំ ភណន្តិ;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយ ទុកជាមានចិត្តប្រកបដោយហិរិ (សេចក្តីខ្មាស) យ៉ាងណាក៏ដោយ តែស្រវឹងសុរាហើយ ក៏ធ្វើនូវភាពនៃខ្លួនជាមនុស្សមិនមានហិរិ ឲ្យប្រាកដជាក់ស្តែងដល់ភ្នែកអ្នកទាំងពួង, ឯលោកអ្នកប្រាជ្ញទាំងឡាយជាសប្បុរស មានសន្តានស្ងប់ស្ងាប់រមែងពោលពាក្យដំនៀលជាច្រើន, អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២២ - យំ វេ បិត្វា ឯកច្ចា សំយន្តិ
អនាសកា ថណ្ឌិលទុក្ខសេយ្យំ(២)
ទុព្វណ្ណិយំ អាសយកញ្ញុបេន្តិ(៣)
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

១ ឱ. មទិរាយាតិ ពហេ ។ ២ ឱកេបិយ ពោត្ថកេ សយ្យា ។ ៣ ឱ. អាយសក្កញ្ចុបេន្តិ ។

មនុស្សដ៏ថៃ្លថ្លាទាំងឡាយ ផឹកនូវសុរាឯណា ហើយដេកប្រគាក់ប្រគងប្រគគ្នា ទីងមនុស្សមានជាតិថោកទាបដូចជាកូនជ្រូក, កាលពីដើមជាមនុស្សបរិបូណ៌ដោយភោជនាហារ ទីងលំនៅ ក៏ត្រឡប់ទៅជាមនុស្សឥតអាហារ ដេកកើតទុក្ខលើផែនដី ជនប្រុសស្រីរមែងថ្លែងសេចក្ដីសគេរ្ដិ៍ដ៏អាក្រក់ៗ គេតែងតិះដៀល ដោយដំនៀលផ្សេងៗ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៣. យំ វេ បិត្វា បត្តត្ថា សយន្តិ
ឆមេ ឆមាយំ, ឧ ហំ
ភារុណិយា វេតា ឧរេព សុស្សុហោរ៉;
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកសុរាឯណា ហើយទន់គរទៀកដេកនៅ ដូចជាគោដែលមនុស្សគំណាចចាក់ដោយខ្សែពួរហើយនាំទៅ វាមិនស៊ីស្មៅមិនផឹកទឹក ដូច្នោះឯង, ឯកម្លាំងសុរា ឥតមាននរណាប្រឹងប្រែងទប់ទល់បានឡើយ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៤- យំ មនុស្សា វិវជ្ជន្តិ សព្វំ
ឃោរសមិវ, តំ ឈោគោ វិសសមានំ

កោ នោ ឆាតុមហារតិ;

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សទាំងឡាយដែលជាអ្នកដឹងសេចក្ដីខុសត្រូវ រមែងវៀរលែងនូវសុរាឯណា ដូចជាគេជៀសវាងសត្វពស់ដែលមានពិសដ៏ពន្លឹក, នរណាហ្ន៎ ទើបគួរដើម្បីផឹកនូវសុរានោះ ដែលប្រហែលគ្នានឹងពស់មានពិសក្នុងលោកដូច្នោះ; អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

២៩— យំ វេ បិត្វា អន្ធកវេណ្ហុបុត្តា(១)

សមុទ្ទតីរេ បរិចារយន្តា

ឧបក្កមុំ មុសលេហញ្ញមញ្ញំ;

តស្មា បុណ្ណំ កុម្ភមិមំ កិណាថ ។

កាលពីដើម មានព្រះរាជបុត្តក្សត្រជាបងប្អូននឹងគ្នា ១០ ព្រះអង្គ កាលដែលពួករាជសេវកៈកំពុងបម្រើ នៅទៀបឆ្នេរសមុទ្រ ក៏ទ្រង់ប្រហារគ្នានឹងអង្រែទៅវិញទៅមក ព្រោះតែផឹកនូវសុរាឯណា, អ្នកទាំងឡាយចូរទិញក្អមនេះ ដែលពេញទៅដោយសុរានោះចុះ ។

៣០— យំ វេ បិត្វា បុព្វទេវា បមត្តា

តិទិវា ចុតា សស្សតិយា សមាយា,

---

១ ឧ. អន្ធកវេណ្ឌុបុត្តា ។

តំ តាទិសំ មជ្ឈិមំ និវត្តកំ
ជានំ មហារាជ គតំ បវេយ្យ ។

ពួកអសុរទាំងឡាយមានសេចក្តីប្រមាទហើយច្យុតចាកតាវតឹង្សទេវ-លោកដែលលោកសន្មតថាជាទីទៀង ព្រោះមិនស្ងប់ប្រែប្រួលដោយសេចក្តីស្លាប់កើត ធ្លាក់មកព្រមទាំងពួកអសុរមាយាស្លួមស្រិគ្គាផង ព្រោះតែផឹកនូវសុរាឯណា, បពិត្រមហារាជ បណ្ឌិតបុរសជាអ្នកមានប្រាជ្ញប្រហែលព្រះអង្គ កាលបើជ្រាបថាសុរានោះជាទឹកឥតប្រយោជន៍យ៉ាងនេះហើយនឹងសោយសុរានោះម្តេចកើត ។

២៧– នយិមស្មឹ កុម្ភស្មឹ ទធិ មធុវា
ឯវំ អភិញ្ញាយ ភណាហិ រាជ,
ឯវញ្ហិ មំ កុម្ភកតា(១) មយា តេ
អក្ខាតរូបំ តវ សព្វមិត្តាតិ ។

ទធិក្តី, ទឹកឃ្មុំក្តី មិនមានក្នុងក្អមនេះទេ, បពិត្រព្រះរាជា ព្រះអង្គបានជ្រាបច្បាស់យ៉ាងនេះហើយ សូមទិញក្អមនេះចុះ, ឯទោសដែលមាននៅក្នុងក្អមរបស់ខ្ញុំយ៉ាងនេះ ខ្ញុំបានថ្លែងថ្វាយព្រះអង្គសព្វគ្រប់ហើយ, បពិត្រព្រះបាទសព្វមិត្ត ពាក្យដែលខ្ញុំបានពោលថ្វាយព្រះអង្គ ជាពាក្យពោលតាមសេចក្តីពិត ។

---

១ កុម្ភកតា ឥយាតិ កុម្ភគតំ ឥយាតិ អយមេវ វា បាឋោ ។ (អដ្ឋកថា) ។

ព្រះមហាក្សត្របានទ្រង់ព្រះសវនាការសេចក្ដីនោះសព្វគ្រប់ហើយ ទ្រង់ជ្រាបច្បាស់នូវទោសនៃសុរា ទ្រង់មានព្រះទ័យត្រេកអរហើយទ្រង់ធ្វើបាមនាការ សរសើរសម្ដេចសក្កទេវរាជ ហើយពោលព្រះគាថា ២ ព្រះគាថាដូច្នេះថា៖

២៨- ឆ មេ បិតា វា អថវាបិ មាតា
ឋតានិសោ យានិសតោ តុរំ-ករិ
ហិតានុកម្បី បរមត្ថកាមោ,
សោហំ ករិស្សំ វចនំ តវជ្ជ ។

២៩- ទទាមិ តេ គាមវរានិ បញ្ច
ទាសីសតំ សត្ត គវំ សតានិ
អាជញ្ញយុត្តេ ច រថេ ទសា ឥមេ
អាចរិយោ ហោសិ មមត្ថកាមោតិ ។

អ្នកឯងនេះជាបិតាឬជាមាតារបស់ខ្ញុំក៏ទេដែរ, ប៉ុន្តែជាអ្នកអនុគ្រោះខ្ញុំដោយពាក្យសំដីដ៏មានប្រយោជន៍ ជាអ្នកប្រាថ្នានូវប្រយោជន៍ដ៏ឧត្តមដល់ខ្ញុំ, តាំងពីថ្ងៃនេះតទៅ ខ្ញុំនឹងធ្វើតាមពាក្យអ្នក ឥឡូវនេះខ្ញុំសូមជូនស្រុកសួយប្រាំស្រុក ដែលមានសួយឡើង ១ សែនៗក្នុង ១ ឆ្នាំៗ នឹងខ្ញុំស្រី ១ រយ គោ ៧ រយ កដរថដែលទឹមដោយសេះអាជានេយ ១ គូៗ ទាំង

១០ នេះដល់អ្នកឯង, អ្នកឯងដែលជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ, សូមតាំងខ្លួនជាគ្រូអាចារ្យខ្ញុំចុះ ៕

សម្តេចសក្កទេវរាជបានទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏សំដែងនូវអត្តភាពជាទេព្តាវិញ ឲ្យព្រះរាជាស្គាល់ខ្លួនហើយស្ថិតនៅឰដអាកាស ទ្រង់ពោលព្រះគាថា ២ ព្រះគាថាដូច្នេះថា:

៣០ - ទេវ ទាសីសតមត្ថុ រាជ,
គាមា ច គាមេ ច ទេវ ហោន្តុ
អាជញ្ញយុត្តា ច រថា ទេវ,
សក្កោ ហមស្មិ តិទសានមិន្ទោ ៕

៣១ - មំសោទនំ សប្បិបាយញ្ច កុញ្ជ(១)
ខាទស្សុ ច ត្វំ មធុមាសបូវេ,
ឯវំ តុវំ ធម្មរតោ ជនិន្ទ
អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ៕

បពិត្រព្រះរាជា ទាសីទាំង១រយ សូមជារបស់ព្រះអង្គវិញចុះ, ខ្លួនខ្ញុំឈ្មោះសក្កជាគួឥន្ទ្រាធិបតី នៃទេព្តាក្នុងពិភពតាវត្រៃត្រឹង្សមិនសម្លឹងចង់បានសម្បត្តិរបស់ព្រះអង្គប៉ុណ្ណោះទេ ៕ សូមតែព្រះអង្គកុំសោយសុរា សូម

១ ខ. ភុញ្ជ ៕

ក្សត្រទ្រង់សោយតែក្រយាស្ងោយដែលប្រកបដោយម្ហូបតាមធម្មតា និង ទឹកសម្លវិញ បើសព្វព្រះទ័យចំណីឈ្ងុយឆ្ងាញ់ សូមព្រះអង្គទ្រង់សោយនំសណ្តែកដែលលាយដោយទឹកឃ្មុំចុះ, បពិត្រព្រះជនិន្ទពិនភាព បើព្រះកជាវៀរបង់មិនទ្រង់សោយសុក ហើយក្សត្រាទ្រង់សោយតែក្រយា-ស្ងោយដែលមានសេដ្ឋីប្រសើរផ្សេង ៗ ទ្រង់លះលែងទុច្ចរិតទាំង ៣ មានព្រះទ័យត្រេកអរចំពោះសុចរិតធម៌ទាំង ៣ ប្រការយ៉ាងនេះហើយ ឥតមានវេលាណា និន្ទាព្រះអង្គបានឡើយ ហើយព្រះអង្គនឹងបានទៅកើតក្នុងស្ថានសួគ៌ទៀត ។

សម្តេចសក្កទេវរាជ ទ្រង់ប្រទានឱវាទដល់ព្រះបាទសព្វមិត្តនោះដូច្នោះហើយ ក៏ត្រឡប់ទៅលំនៅរបស់ព្រះអង្គវិញ ។

ឯព្រះបាទសព្វមិត្តនោះមិញ ក៏ឈប់សោយសុក ក្សត្រាទ្រង់ឲ្យទម្លាយភាជនៈសម្រាប់ដាក់សុកចេញអស់ ហើយទ្រង់សមាទានសីល ៥ សីល ៨ បក្រិទ្រង់បរិច្ចាគព្រះរាជទ្រព្យឲ្យទៅជាទានដល់សមណព្រាហ្មណាចារ្យ ទាំងស្មូមយាចកអ្នកកំសត់ទុគ៌តជាច្រើនហើយព្រះអង្គទ្រង់គង់នៅដរាបដល់សោយព្រះទិវង្គតក្ស័យព្រះជន្មទៅ បានទៅយកព្រះជាតិកំណើតកើតនៅក្នុងស្ថានសួគ៌ ។

ឯសុកក៏កើតឡើងជាលំដាប់ ៗ ផ្សាយពាសពេញទាំងជម្ពូទ្វីបតាំងពីកាលនោះមក ។

សម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់នាំមកនូវព្រះធម៌ទេសនានេះ ហើយ ទ្រង់ប្រជុំជាតកថា: ព្រះបាទសព្វមិត្តនោះ លុះបេរវិលវិញមក បានជាភិក្ខុឈ្មោះអានន្ទ ឯសក្កទេវរាជ គឺជាតួអង្គតថាគតនេះឯង ។

កុម្ភជាតកំ ឆដ្ឋំ ។

ចប់កុម្ភជាតកតែប៉ុណ្ណេះ ។

រឿងស្ត្រីស្មោះត្រង់នឹងស្វាមី

មាននិទានមួយដំណាលថា នៅក្នុងនគរមួយនោះ មានសេដ្ឋីពីរនាក់ សេដ្ឋីម្នាក់មានកូនស្រី សេដ្ឋីម្នាក់ទៀតមានកូនប្រុស ទើបសេដ្ឋីទាំងពីរ គិតផ្សំផ្គុំកូនប្រុស-ស្រីរបស់ខ្លួនឲ្យបានជាស្វាមីភរិយា ។ គាប់ប្អូនជានគរនោះកើតចលាចល បះបោរឡើង ហើយសេដ្ឋីទាំងពីរនាក់ក៏បាក់បែកខ្ចាត់ខ្ចាយចេញទៅនៅទីទៃៗពីគ្នា តមកសេដ្ឋីមានកូនស្រីនោះក៏ផ្សំផ្គុំកូនស្រីឲ្យមានប្ដីនឹងបុរសដទៃទៅ កូនស្រីក៏ព្រមទទួលយកជាប្ដីតាមប្រពៃណី លុះនាងបានទៅនៅនឹងប្ដីហើយ ទើបនាងស្រដីនឹងប្ដីថា ដ្បិតអាពុកខ្ញុំបានផ្សំផ្គុំខ្ញុំឲ្យមានប្ដីអំពីមុនរួចហើយ តែពុំទាន់បានមូលលំនៅស្ថាន ស្រាប់តែអ្នកបានខ្ញុំមកជាភរិយា ហើយខ្ញុំពុំទាន់បានដោះប្ដេជ្ញានឹងប្ដីមុននោះនៅឡើយ ឥឡូវនេះខ្ញុំសូមលាអ្នក ទៅដោះប្ដេជ្ញានឹងប្ដីដើមនោះសិន បើអម្ចាស់បើកទើបខ្ញុំហ៊ានទៅ បើអម្ចាស់ពុំបើកឲ្យទៅទេខ្ញុំពុំហ៊ានទៅឡើយ ។

ឯប្ដីនោះឆ្លើយថា អញគិតថានាងជ្រះស្រឡះទំនេរឥតប្ដីទេ បើនាងមានស្វាមីអំពីមុនរួចមកហើយដូច្នោះ ចូរនាងទៅដោះប្ដេជ្ញានឹងប្ដីដើមឲ្យជ្រះស្រឡះសិនចុះ អញពុំឃាត់ឃាំងនាងឡើយ ។ លុះនាងបានអនុញ្ញាតពីប្ដីដូច្នោះហើយ ក៏តាក់តែងស្អិតស្អាងកាយ ប្រដាប់គ្រឿងសម្រាប់អាត្មារួចស្រេចហើយ ក៏លីលាចេញទៅ សំដៅស្មោះ

ចំពោះរកកូនសេដ្ឋីជាប្តីដើមនោះ ស្រាប់តែទៅពើបប្រទះនឹងខ្លាធំអត់អាហារមក ៧ ថ្ងៃហើយ ទើបខ្លាលោតទៅប្រុងនឹងចាប់នាងជាចំណែកអាត្មា ៗ នាងក៏រ៉ាយរឿងនាងឲ្យខ្លាស្តាប់សព្វគ្រប់ ខ្លាក៏លែងបើកឲ្យនាងត្រឡប់ទៅដោយស្រួល ៗ

ឯនាងទំស្រុតដើរ គអំពីនោះបន្តិចមកកូរ ស្រាប់តែជួបប្រទះនឹងចោរ ៧ នាក់ ចោរយល់នាងនោះមានគ្រឿងប្រដាប់សម្រាប់អាត្មាសឹងដ៏ជារបស់មានដំឡៃ ទើបចោរគិតគ្នានឹងទៅចាប់នាងយកអភរណ៍អស់នោះ ៗ នាងក៏និយាយសារស័ព្ទប្រាប់ចោរតាមដំណើរសព្វគ្រប់ ពួកចោរបានស្តាប់ដូច្នោះ ក៏មិនយកទ្រព្យទាំងនោះឡើយ ហើយបើកឲ្យនាងទៅដោយស្រួល ៗ

នាងបានរួចរបូតពីកណ្តាប់ដៃចោរដូច្នោះហើយ ក៏ទំដើរត្រឡប់ត្រង់ទៅរហូតដល់លំនៅប្តីដើមនោះ ៗ ក៏សួរថា នាងមកអំពីទីតំបន់ណា ? នាងអង្គុយនាស្ថានដ៏សមគួរហើយ ជំរាបថា អាពុកខ្ញុំជាសេដ្ឋីបានផ្សំផ្គុំខ្ញុំឲ្យជាភរិយាអ្នកអំពីមុនរួចមកហើយ ឥឡូវនេះ អាពុកខ្ញុំលើកខ្ញុំឲ្យមានប្តីនឹងបុរសដទៃទៀត ឯខ្ញុំពុំទាន់បានក្រាបលា បេ្តជ្ញានឹងអ្នកជាប្តីដើម ឲ្យបានជ្រះស្រឡះ ដូច្នេះបើម្ចាស់បើកឲ្យខ្ញុំទៅខ្ញុំក៏ទៅ បើម្ចាស់ពុំព្រមបើកឲ្យទៅទេ ខ្ញុំពុំហ៊ានទៅឡើយ ៗ

ឯចៅនោះឆ្លើយឡើងថា នាងមានចិត្តស្មោះចំពោះមកដល់អញ ៗ

អណោស់ តែឥឡូវនេះឪពុកនាងលើកនាងឲ្យមានប្ដីហើយ អញនឹងទៅតក់ប្រាថ្នានាងជាប្រពន្ធពុំបានឡើយ ចូរនាងទៅកាន់ប្ដីនាងហោង ៗ ទើបនាងក្រាបលាចៅនោះត្រឡប់ទៅផ្ទះវិញ ៗ

គាប់ជួនជានាងដើរមក តាមផ្លូវស្រាប់តែចេបពះប្រទះនឹងចៅម្នាក់កំពុងដើរទេសរកប្រពន្ធ បានយល់នាងមានរូបឆោមស្អាងស្អាតមានទាំងគ្រឿងប្រដាប់ដ៏ល្អនៅនឹងខ្លួន ទើបចៅនោះនិយាយថាចង់ប្រាថ្នានឹងយកនាងជាប្រពន្ធ ៗ ឯនាងក៏ថ្លែងសេចក្ដីប្រាប់ដោយដំណើររឿងតាំងពីដើមរៀងមក ចៅនោះក៏ពុំដែលតក់ប្រាថ្នានាងនោះឡើយ លុះនាងបានទៅដល់លំនៅប្ដីហើយ ក៏នៅរួមគ្នាជាសុខក្សេមក្សាន្តតរៀងទៅ ៗ

នៅទីបំផុតនៃនិទានរឿងនេះ មានសេចក្ដីពោលទុកថា បើអ្នកឯណាសរសើរចិត្តប្ដីរបស់នាងនោះ ហេតុតែអ្នកនោះជាមនុស្សច្រើនប្រ-ពណ្ឌ បើអ្នកឯណាសរសើរចិត្តខ្លា ហេតុតែអ្នកនោះជាមនុស្សតាប់ចិត្តបៀតបៀនបំបាត់ជីវិតគេ ៗ បើអ្នកឯណាសរសើរចិត្តចោរទាំង ៧ នោះហេតុតែអ្នកនោះជាមនុស្សមានចិត្តលោភចង់បានតែទ្រព្យគេ ៗ បើអ្នកឯណាសរសើរបុរសដើរទេសរកប្រពន្ធនោះ ហេតុតែអ្នកនោះជាមនុស្សចូលចិត្ត ប្រព្រឹត្តបរទារកម្មនឹងភរិយាគេ ៗ បើអ្នកឯណានិមួយវៀរក្ដីទាំង ៤ ចំពូកនេះបានអ្នកនោះនឹងបានឆ្លងរំលងទៅដល់-ស្ថានសួគ៌នាយហោង ៗ

ចប់រឿងស្រីឈ្មោះគ្រង់នឹងស្វាមីតែប៉ុណ្ណោះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ១៩-២០

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

បញ្ជីរឿង

ទំព័រ

១ – វិទ្យុធម្មទេសនា ក្រុងភ្នំពេញ កណ្ឌទី ១០ លោកអាចារ្យ ញូង-សឿង ក្រុមជំនុំព្រះត្រៃបិដក សំដែង ១

២ – ច្បាប់ស្រី ចំឡងចេញបោះពុម្ពផ្សាយអំពីច្បាប់សាស្ត្រស្លឹករឹត ១៤

៣ – ច្បាប់អរិយសត្ថា ចំឡងចេញបោះពុម្ពផ្សាយអំពីច្បាប់សាស្ត្រស្លឹករឹត ២៦

៤ – សេចក្ដីសង្ខេបនៃគម្ពីរបញ្ចតន្ត្រ ៣១

៥ – ពាក្យវិការកោម, ស្រង់ចេញពីគោលបារីកផ្សេងៗ ក្នុងពាក្យវិការលោក (តមក) . ៣៧

៦ – ភូមិសាស្ត្រសង្ខេប ប្រទេសអាមេរិកខាងត្បូង ៥០

TABLE DES MATIÈRES

Pages

1. VIDYUDHAMMADESANĀ (Conférence faite à la Radio Phnôm-Penh), par le Vénérable Achar NHOUNG-SŒUNG, membre de la Commission du TRIPITAKA........................ 1

2. CHBAB-SREY (Conseils aux filles)........................ 14

3. CHBAB ARIYASATTHĀ (Conseils aux enfants)................ 26

4. Abrégé du PAÑCATANTRA.................................. 31

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite)................................ 37

6. Géographie sommaire de l'Amérique du Sud................ 50

វិទ្យុធម្មទេសនា គាថា ទី ១០

លោកអាចារ្យ ញ. សឿង ក្រុមជំនុំព្រះត្រៃបិដក

សំដែងក្នុងថ្ងៃព្រហស្បតិ៍ ៨ រោច ខែពិសាខ ឆ្នាំមមីចត្វាស័ក ព. ស. ២៤៩៥
(ត្រូវនឹងថ្ងៃ ៣ ខែមេ ឆ្នាំ ១៩៥២)

សុទ្ធាសុទ្ធិកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះរតនត្រ័យដោយគោរព ៗ

វេលានេះ អាត្មាភាពនឹងសំដែងអំពីសេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធ របស់ពួកសត្វ ដើម្បីចែកជូនជាសាធារណប្រយោជន៍ចំពោះសាធុជនតាម លំអានពុទ្ធភាសិតយ៉ាងនេះថា:

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ៗ

សេចក្តីថា: សត្វទាំងឡាយរមែងបរិសុទ្ធដោយហេតុ ៥ ប្រការនេះ គឺ: កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធ ព្រោះគោត្តឬព្រោះទ្រព្យឡើយ ៗ

ភាសិតនេះសំដែងថា សេចក្តីបរិសុទ្ធជាផលសម្រេចមកអំពីហេតុ ទាំង ៥ ប្រការនេះឯង ហើយសំដែងបដិសេធសេចក្តីបរិសុទ្ធដោយហេតុ

ជាទៃ; វេលានេះសូមលើកយកហេតុទាំង ៥ ប្រការមកអធិប្បាយមួយម្តងៗ តាមមាតិកាដែលទាក់ទងជាប់គ្នាជាលំដាប់ដូចតទៅនេះ:

១- កម្ម បានដល់ចេតនាគឺការតាំងចិត្ត ព្រោះជាតួធម៌ដែលបង្គាប់បញ្ជាប្រើឲ្យធ្វើឲ្យនិយាយឲ្យគិតសមដូចពុទ្ធភាសិតថា "ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ភិក្ខុទាំងឡាយ! តថាគតហៅចេតនាថាជាតួកម្ម" ។ បើតាំងចិត្តធ្វើនិយាយគិតប្រកបដោយ លោភៈ ទោសៈ មោហៈ ហៅថាបាបកម្ម (កម្មអាក្រក់) បើតាំងចិត្តសម្បយុត្តដោយមេត្តាករុណាវៀរចាកអកុសលមូលទាំង ៣ នោះហៅថាកុសលកម្ម (កម្មល្អ) កម្មទាំងពីរនេះរមែងហុចកំរៃផលឲ្យដល់អ្នកធ្វើផ្សេងៗគ្នា គឺបើធ្វើបាបកម្មត្រូវទទួលសេចក្តីសៅហ្មង បើធ្វើកុសលកម្មត្រូវទទួលសេចក្តីបរិសុទ្ធ សមដូចពុទ្ធភាសិតថា:

អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

សេចក្តីថា: ធ្វើបាបខ្លួនឯង រមែងសៅហ្មងខ្លួនឯង មិនធ្វើបាបខ្លួនឯង រមែងស្អាតផូរផង់ខ្លួនឯង សេចក្តីស្អាតនឹងមិនស្អាត ស្រេចតែនឹងខ្លួនឯង អ្នកដទៃជួយតែអ្នកដទៃឲ្យស្អាតបរិសុទ្ធមិនបានទៀយ ។ មានតែកម្មជាកុសល ទើបអាចធ្វើកាយវាចាចិត្តឲ្យស្អាតបាន គឺអាចធ្វើកាយឲ្យមាន

មារយាទរម្យទមរៀបរយ, ធ្វើវាចាឲ្យពីរោះសុភាពរាបសា, ធ្វើចិត្តឲ្យស្ងប់រម្ងាប់នឹងនួន ឥតមានអ្វីដទៃដែលអាចធ្វើខ្លួនឲ្យស្អាតប្រសើរជាជាង ការធ្វើល្អ និយាយត្រូវ គិតត្រូវនេះទៀតឡើយ; ទឹកឬគ្រឿងដំរះដទៃ ៗអាចបំ-បាត់បានតែគ្រឿងសៅហ្មងគ្រោកគឺមន្ទិលក្អែលខាងក្រៅប៉ុណ្ណោះ ចំណែកខាងកុសលកម្មអាចជម្រះលាងឲ្យស្អាតបានទាំងខាងក្នុងទាំងខាងក្រៅ ព្រោះហេតុនេះ ទើបលោកលើកយកកុសលកម្មថាជាហេតុនៃសេចក្តីបរិសុទ្ធ ៗ ធម្មតាមនុស្សក្នុងលោក សុទ្ធតែត្រូវធ្វើ ត្រូវនិយាយ ត្រូវគិត, អំពើដែលសម្រេចមកអំពីការធ្វើ ការនិយាយ ការគិតទាំងនោះឯង មិនចេះស្អាតល្អបានដោយទៅនោះ ត្រូវអាស្រ័យវិជ្ជាគឺការចេះដឹងជួយកែបនៃបគាំទ្រផង, ព្រោះអាស្រ័យហេតុនេះ ទើបលើកយកវិជ្ជាមកសំដែងជាលំដាប់ទី ២ ៗ

២– វិជ្ជា សេចក្តីចេះដឹងច្បាស់ប្រាកដស្គាល់ហេតុផលនៃអំពើល្អនឹងអំពើអាក្រក់នោះ ៗឈ្មោះថាវិជ្ជា, គុណសម្បត្តិនេះ ជាបដិបក្ខទំនាស់គ្នានឹងអវិជ្ជាគឺសេចក្តីល្ងង់ខ្លៅមិនចេះមិនដឹង; អវិជ្ជានេះ ជាគូមន្ទិលមួយដ៏ក្រៃលែងជាងមន្ទិលទាំងពួង រមែងរឹតរួតរុំហ៊ុំបិទបាំងដួងចិត្តឲ្យងងឹតងងល់មិនឲ្យសត្វគិតយល់ដល់សេចក្តីពិតៗ សមដូចពុទ្ធភាសិតថា "អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលលេខ ១" លុះតែជនដែលមានវិជ្ជា ទើបអាចកំចាត់បង់ បន្សាត់ចាត់ចោលនូវមន្ទិលគឺអវិជ្ជានោះបាន ព្រោះវិជ្ជាគួរជា

ដូចជាពន្លឺដ៏រុងរឿង ដែលកំចាត់បង់នូវងងឹត ពុំនោះសោតដូចជាគ្រឿងអលង្ការសម្រាប់លើកកសិជួយកែមនុស្សឲ្យមានសិរីសួស្តីចំរើនរុងរឿង ប៉ុន្តែធម្មតាមនុស្សប្រែសិនបើមានតែវិជ្ជាម្យ៉ាងហើយ ខ្វះធម៌សម្រាប់ជួយគាំទ្រផង ក៏ធ្វើខ្លួនឲ្យទៅជាបុគ្គលបរិសុទ្ធមិនកើត ទំនងប្រែខ្លួនទៅជានាំបណ្តាលឲ្យបានសេចក្តីទុក្ខលំបាកទៅវិញ សេចក្តីនេះ សមគ្នានឹងពុទ្ធភាសិតថា :

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធមស្ស វិបាតយំ ។

សេចក្តីថា: ការចេះដឹងកើតឡើងដល់បុគ្គលពាលដើម្បីសេចក្តីវិនាសតែម្យ៉ាង (គឺថាធម្មតាបុគ្គលពាលចេះចំណេះវិជ្ជាណាមួយនាំបំផ្លាញតែខ្លួនឯង) វិជ្ជានោះរមែងសម្លាប់ចំណែកនៃកុសលរបស់បុគ្គលពាល ធ្វើប្រាជ្ញាឲ្យរត្តកយទ្ធាត់ខ្ចាយខូចអសារគតការ ។ សេចក្តីនេះបញ្ជាក់ឲ្យឃើញថា លុះណាតែមានធម៌ជួយជាកំឡាំងផង ទើបវិជ្ជាដើរទៅត្រង់មិនទីសទាសខុសឆ្វេង, ព្រោះហេតុនេះត្រូវលើកយកធម៌មកសំដែងជាលំដាប់ទី ៣ ។

៣ – ធម្មៈ សេចក្តីល្អ ដែលទ្រទ្រង់លើកស្ទួយអ្នកប្រព្រឹត្តមិនឲ្យធ្លាក់ទៅក្នុងទីអាក្រក់អាប់ឱនទាបឈ្មោះថាធម៌ក្នុងទីនេះ ធម៌នោះមានច្រើនប្រការ ប៉ុន្តែដែលនឹងលើកយកមកសំដែងក្នុងថ្ងៃសេចក្តីនេះសំដៅយកហិរិឱត្តប្បៈ ។ សេចក្តីខ្មាសបាបខ្ពើមដែលលូតលាស់ផុះផុលផុះ

ចេញមកអំពីដួងចិត្តរបស់ខ្លួនឯងហើយ មិនហ៊ានប្រព្រឹត្តធ្វើអំពើទុច្ចរិត ដោយពិចារណាដល់ជាតិ ត្រកូល វ័យ សេចក្ដីក្លៀវក្លានឹងសេចក្ដីចេះដឹង របស់ខ្លួន, យ៉ាងនេះឈ្មោះថាហិរិ មិនមែនសំដៅយកត្រង់ដែលអៀនខ្មាសដល់អ្នកផង ហើយមិនហ៊ានធ្វើបាបនោះឡើយ ។ ការដែលតក់ស្លុតខ្លាចរអារចំពោះទោសនឹងអំពើទុច្ចរិត ហើយមិនហ៊ានប្រព្រឹត្តធ្វើអំពើទាំងនោះ ដោយពិចារណាឃើញភ័យ ៤ យ៉ាងគឺ ភ័យអំពីខ្លួនឯងតិះដៀលខ្លួនឯង ១ ភ័យអំពីអ្នកដទៃតិះដៀល ១ ភ័យអំពីរដ្ឋការដាក់អាជ្ញា ១ ភ័យអំពីការកើតក្នុងអបាយភូមិ ១ យ៉ាងនេះឯង ឈ្មោះថាឱត្តប្បៈ ។ ហិរិនឹងឱត្តប្បៈទាំងពីរនេះជាគូនឹងគ្នា ព្រះវិជិតមារទ្រង់ត្រាស់ហៅថាធម៌ស ព្រោះជាធម៌អាចញុំាងបុគ្គលអ្នករក្សាឬអ្នកកាន់តាមឲ្យសបរិសុទ្ធផូរផង់; បុគ្គលក្នុងលោកលុះណាតែមានធម៌ទាំងពីរនេះដិតជាប់នៅក្នុងខន្ធសន្ដាន ទើបអាចប្រព្រឹត្តធម៌ដទៃ ៗ ឲ្យផូរផង់ ប្រៀបដូចជាសំពត់ដែលស្អាត ប្រាសចាកក្អែល រមែងទទួលស្រូបយកទឹកជ្រលក់គ្រប់ពណ៌តាមបំណងអ្នកជ្រលក់ដូច្នោះឯង ។ ហិរិនឹងឱត្តប្បៈនេះ មានក្នុងសន្ដានរបស់ជនណា ជននោះរមែងជាអ្នកមានសីល ហើយអាចដុសខាត់សីលនោះឲ្យស្អាត, រក្សាការពារឃុំគ្រងមិនឲ្យដាច់ធ្លុះធ្លាយពព្រុះពពាលថែមទៀត, ព្រោះហេតុនេះ ត្រូវលើកយកសីលមកសំដែងជាលំដាប់ទី ៤ ។

៤- សីល ការរក្សាកាយវាចាឲ្យស្ងប់ស្ងៀមរម្យទមរៀបរយ ហាមសេចក្ដីប្រព្រឹត្តប្រទូស្សរបស់លើសខុសឆ្គងមិនឲ្យកើតឡើងឈ្មោះជាសីល។ នេះបើបុគ្គលរក្សាឲ្យផូរផង់ហើយ រមែងការពារកំនូវវិប្បដិ-សារៈ (សេចក្ដីក្ដៅក្រហាយស្ដាយក្រោយ) មិនឲ្យកើតក្នុងសន្ដាន ហើយគាបទប់ក្រសោបប្រមូលនាំយកសេចក្ដីបរិសុទ្ធឬសេចក្ដីសុខមកឲ្យអ្នករក្សាបានតាមបំណង ៗ កាលបើមានសីលហើយ រមែងរកស៊ីចិញ្ចឹមជីវិតតាមផ្លូវសុចរិតមិនបៀតបៀនសត្វដទៃ ព្រោះតែជីវិតរបស់ខ្លួន ព្រោះហេតុនេះ ត្រូវលើកយកជីវិតដ៏ឧត្តមមកសំដែងជាលំដាប់ទី ៥ ។

៥- ជីវិតដ៏ឧត្តម សេចក្ដីចៀសវាងជំនួញមិនគួរជួញ ៥ ប្រការ និងអំពើទុច្ចរិតវៀចវេរផ្សេង ៗ មានការឆបោក បំបាត់បំភាន់បៃជាន់យកសម្បត្តិអ្នកដទៃជាដើម ហើយប្រកបការងារចិញ្ចឹមជីវិតតាមផ្លូវត្រូវមានកសិកម្ម (ការធ្វើស្រែចំការ) និងវាណិជ្ជកម្ម (ការជួញប្រែ) ជាដើម, យ៉ាងនេះឯងហៅថាជីវិតដ៏ឧត្តម ព្រោះជីវិតដែលរស់នៅដោយសារសម្បត្តិដែលរកបានមកតាមផ្លូវសុចរិតនោះ ជាជីវិតត្រជាក់ត្រជុំមិនក្ដៅក្រហាយ ៗ កាលបើមានជីវិតបរិសុទ្ធហើយ ទោះបីយកសម្បត្តិទាំងនោះទៅចាយវាយ ឬយកប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍បរលោកឲ្យបានច្រើនកើនលើសជាងធម្មតាទៅទៀត គឺអាចសម្រេចសមតាមប្រាថ្នា, ប្រយោជន៍ដែលបានមកនោះទៀតសោតក៏ឈ្មោះថាជាប្រយោជន៍បរិសុទ្ធ

ព្រោះហេតុនេះ ទើបព្រះសុគតទ្រង់ត្រាស់លើកយកជីវិតដ៏ឧត្តមមក សំដែងថាជាហេតុនៃសេចក្ដីបរិសុទ្ធ ។ គុណធម៌ទាំង ៤ ប្រការដែលសំដែងមកនេះ ជាហេដ្ឋិមបរិយាយ (ថ្នាក់ក្រោម) បើពោលដោយឧបរិមបរិយាយ (ថ្នាក់លើ) វិញនោះយ៉ាងនេះគឺៈ កម្មបានដល់ការតាំងចិត្តបំពេញអដ្ឋង្គិកមគ្គ (ផ្លូវប្រកបដោយអង្គ ៨), វិជ្ជា បានដល់សម្មាទិដ្ឋិ (សេចក្ដីយល់ត្រូវ) នឹងសម្មាសង្កប្បៈ (សេចក្ដីត្រិះរិះត្រូវ), ធម៌ បានដល់សម្មាវាយាមៈ (សេចក្ដីខំប្រឹងត្រូវ) សម្មាសតិ (សេចក្ដីរលឹកត្រូវ) នឹងសម្មាសមាធិ (សេចក្ដីដំកល់ចិត្តឲ្យនឹងនួនត្រូវ), សីល បានដល់សម្មាវាចា (សំដីត្រូវ) នឹង សម្មាកម្មន្តៈ (ការងារត្រូវ), ជីវិតដ៏ឧត្តមបានដល់សម្មាអាជីវៈ (សេចក្ដីចិញ្ចឹមជីវិតត្រូវ) ។ អ្នកដែលដើរតាមផ្លូវទាំង ៨ នេះ រមែងធ្វើខ្លួនឲ្យបរិសុទ្ធតាមថ្នាក់តាមជាន់រហូតទៅទល់ភ្នានឹងប្រានភាពបុថុជ្ជនចោលហើយឡើងទៅកាន់អរិយភាពបាន, យ៉ាងនេះឯងឈ្មោះថាជាអ្នកបរិសុទ្ធដ៏ឧក្រិដ្ឋ ។ សេចក្ដីដែលសំដែងមកទាំងអស់នេះបំភ្លឺឲ្យឃើញជាក់លាក់ថា ពួកសត្វ លុះណាតែមានគុណធម៌ទាំង ៤ យ៉ាងនេះ ទើបអាចធ្វើខ្លួនឲ្យបរិសុទ្ធមិនមែនបរិសុទ្ធព្រោះគោត្តវង្សត្រកូលសែស្រឡាយ ឬព្រោះទ្រព្យសម្បត្តិឡើយ ព្រោះថាធម្មតាបុគ្គលគប់រូប សូម្បីមានវង្សត្រកូលខ្ពង់ខ្ពស់ ព្រមទាំងបរិបូណ៌ដោយធនធានស្តុកស្តម្ភមាំមួនច្រើនពោរពាសយ៉ាងណាក៏ដោយ ប៉ុន្តែបើខ្វះធម៌ទាំង ៤ ប្រការនេះហើយ

វង្សត្រកូលនឹងកោតសរសើរតាំងទោះនឹងកាប់ខ្ទេចខ្ទីតាមស្រុកស្រែរបស់ សាបសូន្យទៅជាលំដាប់តំណាន, កាលបើគោត្តត្រកូលនឹងសម្បត្តិវិនាសហើយ ប្រយោជន៍ដែលសម្រាប់ផ្ដុំឲ្យបរិសុទ្ធផូរផង់ ក៏សម្រេចផល់បុគ្គលនោះមិនបានដែរ ។ ម្យ៉ាងទៀត មិនមែនបរិសុទ្ធឬមានសិរីសួស្ដីឥតសិរីសួស្ដីព្រោះឈ្មោះល្អឬឈ្មោះអាក្រក់ឡើយ; មានពួកជនខ្លះយល់ថាជោគជ័យកើតមកអំពីឈ្មោះពីរោះសមល្អ បានជាក្នុងពេលដែលបានបុត្រាបុត្រីវេលាណា គេច្រើនតែរើសរកឈ្មោះដែលពីរោះៗ មកដាក់ឲ្យបុត្រាបុត្រីទាំងនោះ ដើម្បីនឹងធ្វើសិរីសួស្ដីឲ្យកើត; ត្រង់ដែលរើសយកឈ្មោះល្អសមរម្យមកដាក់ឲ្យបុត្រាបុត្រីនោះ ជាការប្រពៃណាស់ហើយ ដើម្បីនឹងនាំឲ្យពីរោះដល់ត្រចៀកអ្នកផង ឬដើម្បីនឹងឲ្យងាយហៅស្រួលមាត់ មិនជាការទាស់ខុសអ្វីទេ ប៉ុន្តែសូមកុំយល់ថាជោគជ័យសម្រេចមកអំពីឈ្មោះល្អ ការឥតជោគជ័យកើតមកអំពីឈ្មោះអាក្រក់នោះឡើយ ព្រោះសេចក្ដីយល់នេះទំនាស់នឹងពុទ្ធភាសិតខាងដើម ។ សូមលើកយករឿង ១ មកសំដែងបំភ្លឺសេចក្ដីនេះឲ្យឃើញច្បាស់លាស់ដូចតទៅនេះ ។

ក្នុងកាលដ៏កន្លងទៅហើយ ព្រះបរមពោធិសត្វនៃយើងកើតក្នុងត្រកូល ១ ទ្រង់សិក្សាវិទ្យាសាស្ត្រចេះចប់សព្វគ្រប់បានឡើងថ្នាក់ជាសាស្ដាចារ្យទិសាបាមោក្ខ បង្ហាត់បង្រៀនមាណពច្រើនរូបនៅសាលា-វិទ្យាល័យក្នុងក្រុងតក្កសិលា ។ បណ្ដាមាណពជាសិស្សទាំងនោះមាន

មាណពម្នាក់ឈ្មោះ "គំរក់(១)" មាណពទាំងអស់គ្នា តែងហៅថា ចៅគំរក់ៗ ដូច្នេះជាធម្មតា ។ ថ្ងៃ១ មាណពនោះមានសេចក្ដីត្រិះរិះថា ឈ្មោះអាត្មាអញនេះអពមង្គលធំណាស់ បើដូច្នោះគួរអាត្មាអញនឹងចូលទៅសុំឲ្យអាចារ្យទិសាបាមោក្ខរកឈ្មោះដែលជាមង្គលមានជោគជ័យមកផ្លាស់ជំនួសវិញ, លុះគិតរួចហើយទើបចូលទៅសារស័ព្ទជំរាបអាចារ្យតាមសេច-ក្ដីយល់របស់ខ្លួន, អាចារ្យទិសាបាមោក្ខក៏តបមកវិញថា អញមិនដឹងជារកឈ្មោះណាមកផ្លាស់ដាក់ឲ្យត្រូវចិត្តឯងទេ បើដូច្នោះចូរឯងដើរទៅសួរស្វែងរកឈ្មោះណាដែលខ្លួនពេញចិត្ត ហើយនាំយកមកប្រាប់អញនឹងផ្លាស់ឲ្យ ។ ចៅគំរក់បានស្ដាប់ហើយក៏រៀបចំស្បៀងអាហារបក្ករតាមផ្លូវ សំពះលាអាចារ្យចេញចាកក្រុងតក្កសិលា ឆ្ពោះទៅកាន់ស្រុកដទៃដើម្បីនឹងស្វែងរកឈ្មោះជាមង្គល, លុះដើរទៅដល់ភូមិ ១ បានឃើញជនច្រើនមីរដេរដាស កំពុងតែសែងខ្មោចយកទៅដុត ចៅគំរក់ ក៏សួរថា អ្នកដែលស្លាប់នេះឈ្មោះអ្វី?

– ឈ្មោះរស់(២) ។

– បើឈ្មោះរស់ដូចម្ដេចក៏ស្លាប់?

– ទេ! ល្ងង់អ្វីក៏ល្ងង់ម្ល៉េះ ដូចជាគ្មានដឹង ១០ សោះហើយនេះ,

---

១ បាលី បាបកៈ ។ ២ បាលី ជីវកៈ ។

ទោះបីឈ្មោះរស់ក៏ដោយ ឈ្មោះស្លាប់ក៏ដោយ តែបើដល់កំណត់ត្រូវស្លាប់ហើយ គង់តែស្លាប់ដូចគ្នាទេ, ឯឈ្មោះនោះគ្រាន់តែជាឈ្មោះសម្រាប់ហៅប៉ុណ្ណោះទេតើ មិនមែនគ្រាន់តែឈ្មោះរស់ហើយរស់រហូតលែងស្លាប់នោះកាលណា ។ ចៅតំរក់បានស្តាប់ជាក់ក៏នឿយណាយរសាយចិត្តក្នុងឈ្មោះល្អឈ្មោះអាក្រក់ ដោយគិតឃើញថាឈ្មោះនេះយកជាប្រមាណមិនបាន ហើយទើបត្រឡប់វិលមកក្រុងតក្កសិលាវិញ, លុះដើរមកដល់ផ្សារ ១ បានឃើញចៅហ្វាយនាយកំពុងតែចងខ្ញុំស្រីម្នាក់ហើយវាយដំព្រំពាត់ស្ដីបន្ទោសដោយពាក្យទ្រគោះផ្សេងៗ, ចៅតំរក់ក៏ដើរសរសៀរចូលទៅជិតហើយសួរថា សូមលោកអត់ទោស, ចុះនាងនេះត្រូវជាអ្វីនឹងលោក ហើយហេតុដូចម្ដេចក៏វាយដំគ្នាខ្លាំងម្ល៉េះ?

— នាងនេះត្រូវជាខ្ញុំស្រីរបស់យើង បានជាយើងចងវាយយ៉ាងនេះព្រោះវាខ្ជិលធ្វើការងារ ។

— នាងនេះឈ្មោះអ្វី?

— ឈ្មោះនាង "គ្របសម្បត្តិ [១]"

— បើឈ្មោះនាងគ្របសម្បត្តិ ហេតុដូចម្ដេច ក៏ក្រីក្រនៅខ្ញុំគេដូច្នេះ?

— យីអើ! ព្រលអ្វីក៏ព្រលម្ល៉េះ បើកុំតែមានដង្ហើមចេញចូលនឹងគេនិយាយ កុំអីគាមោងសុខហើយគាត់ទេះ, ប្រយោជន៍អ្វី ដោយឈ្មោះនោះ

---

១ បាលី: ធនបាលី ។

ទោះបីឈ្មោះរក្សាសម្បត្តិក្តី ឈ្មោះបំផ្លាញសម្បត្តិក្តីតែត្រូវក្រីក្រហើយ គង់តែក្រីក្រដូចគ្នាទាំងអស់ទេ, ការមានហើយនឹងក្រីក្រមិនមែនសម្រេច មកអំពីឈ្មោះនេះឡើយ ។

មាណពបានស្តាប់ហើយ កាន់តែសោយចិត្តជាងមុន ក៏ដើរចេញ អំពីផ្សារនោះមកទៀត, លុះមកដល់ពាក់កណ្តាលផ្លូវបានជួបនឹងបុរស ម្នាក់កំពុងតែវង្វេងផ្លូវដើររើមកមៗ ចុះឡើងៗ ទើបសួរថា:

– អ្នកឯងដើររកអ្វីរើមកមៗ ដូច្នេះ?

– ខ្ញុំវង្វេងផ្លូវទេតើ ។

– ចុះអ្នកឯងឈ្មោះអ្វី ?

– ខ្ញុំឈ្មោះ “ ចៅស្គាល់ផ្លូវ [១] ”

បើឈ្មោះចៅស្គាល់ផ្លូវ ហេតុដូចម្តេចក៏វង្វេងផ្លូវទៅវិញ ?

– ទេ! ផ្តាសៗ! ដំឡូងមូលសុទ្ធហើយអ្នកនេះ, អ្នកឯងមកពីស្រុក ណាមកហ្នឹង? ទោះបីឈ្មោះស្គាល់ផ្លូវក៏ដោយ វង្វេងផ្លូវក៏ដោយ, តែ បើត្រូវនឹងវង្វេងហើយ គង់តែវង្វេងដូចគ្នាទាំងអស់, មិនមែនគ្រាន់ តែខ្ញុំឈ្មោះស្គាល់ផ្លូវហើយមិនវង្វេងផ្លូវនោះទេ, យកឈ្មោះមកជាប្រ- មាណដូចម្តេចកើត ? ឈ្មោះនេះគេគ្រាន់តែដាក់មកឲ្យពីរោះត្រចៀកប៉ុ ឲ្យ ងាយចំណាំ ងាយស្គាល់ ងាយហៅតែប៉ុណ្ណោះទេតើ ។

១ បន្ថកៈ ។

មាណពបានស្តាប់ពាក្យនោះហើយក៏រំងិតតែក្ដីច្បាស់នឿយណាយរសាយចិត្ត លែងទុកទោមនស្សនឹងឈ្មោះរបស់ខ្លួន ដើរចូលមកកាន់ក្រុងតក្កសិលាវិញ ហើយចូលទៅកាន់សំណាក់អាចារ្យទិសាបាមោក្ខ ក៏សួរថាដូចម្ដេចទៅៈចៅកំរក់, ឯងរកឈ្មោះជាមង្គលបានហើយឬនៅ? មាណពក៏ជំរាបតាមរឿងរ៉ាវដែលខ្លួនបានជួបប្រទះថាៈ បាទទេ, ដូចជាដូចទេ លោកគ្រូ រឿងនេះ ឈ្មោះរស់ក៏ស្លាប់, ឈ្មោះនាងរក្សាសម្បត្តិក៏ក្រីក្រ, ឈ្មោះចៅស្គាល់ផ្លូវក៏វង្វេងផ្លូវ, ហើយចុះខ្ញុំបាទសុខចិត្តយកឈ្មោះចៅកំរក់ចាស់ដដែលនោះវិញ មិនបាច់ផ្លាស់ប្ដូរទេ ព្រោះមិនមែនមានសិរីសួស្ដីឬក៏ឥតសិរីសួស្ដីអ្វីមកអំពីឈ្មោះល្អឬអាក្រក់នោះឡើយ ។ អាចារ្យទិសាបាមោក្ខក៏និយាយបំភ្លឺថែមទៀត ហើយពោលគាថាយ៉ាងនេះថាៈ

ជីវកញ្ច មតំ ទិស្វា ធនបាលិញ្ច ទុគ្គតំ
បន្ថកញ្ច វនេ មូឡ្ហំ បាបកោ បុនរាគតោ ។

សេចក្ដីថាៈ មាណពឈ្មោះកំរក់ដើរទៅស្វះស្វែងរកឈ្មោះជាមង្គលបានឃើញបុរសឈ្មោះរស់ក៏ស្លាប់, ឃើញស្ត្រីឈ្មោះនាងរក្សាសម្បត្តិក៏ក្រីក្រ ឃើញបុរសឈ្មោះចៅស្គាល់ផ្លូវក៏វង្វេងក្នុងព្រៃ ឥឡូវនេះ ត្រឡប់មកវិញហើយ ។

រឿងដែលសំដែងមកនេះ ដើម្បីបញ្ជាក់ឲ្យឃើញជាក់លាក់ថា សេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធមិនមែនសម្រេចមកអំពីឈ្មោះល្អ ឬឈ្មោះអាក្រក់

នោះឡើយ, ត្រង់ដែលបរិសុទ្ធស្រេចតែនឹងមានគុណធម៌ទាំង ៤ យ៉ាង ដែលមិនបរិសុទ្ធមកអំពីខ្លះធម៌ទាំងនោះ ដូចពោលមកហើយខាងដើម ។

អាត្មាភាពសំដែងអំពីសេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធរបស់ពួកសត្វ ក៏សន្មតថា ចប់ដោយសង្ខេបល្មមសមគួរដល់កាលវេលា ។

ធម្មទេសនានុភាវេន សុខិតា ហោន្តុ បាណិនោ

ទិដ្ឋសុ អត្ថេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ ។

ដោយអានុភាពនៃធម្មទេសនា (នេះ) សូមឲ្យសត្វទាំងឡាយបាន សេចក្តីសុខសាន្តត្រាណ សូមឲ្យបានសម្រេចប្រយោជន៍ទាំងពីរយ៉ាង (គឺ ប្រយោជន៍បច្ចុប្បន្ននិងប្រយោជន៍បរលោក) ព្រមទាំងពួកញាតិសាច់ សាលោហិតទាំងអស់គ្នា កុំបីឃ្លាតឡើយ ។

ចប់វិទ្យុធម្មទេសនា កណ្ឌទី ១០ តែប៉ុណ្ណេះ ។

ច្បាប់ស្រី

បទភុជង្គលីលា

នេះបទកំណត់ចងជា ភុជង្គលីលា ចងជាច្បាប់ស្រី ៗ កាលនាងឥន្ទ្រទេវី ចរចាកតាមប្តី គឺបុណ្ណកយក្សា ៗ នាងវិមលាជាមាតា បើកបន្ទូលថា ហៃកូនពិសី ៗ នាងនឹងត្រាច់ត្រង់តាមប្តី ចេញចាកអំពី ពិភពនាគនេះ ៗ ទៅស្ថានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បំរើស្វាមី ៗ ធ្វើតែប្រតិបត្តិប្រក្រតី កុំឲ្យស្វាមី អាក់អន់ចិន្តា ៗ នាងអើយគម្លែងក្រឡា ជាម្ចាស់សិរីសោ កូនកុំមាក់ងាយ ៗ ហៃកូនស្រីស្ងួនមាសម្តាយ ត្រណាស់នាងអាយ តាមរបាយច្បាប់ស្រី ៗ ត្រមួយមិនបានសំដី ពាក្យទន់តិចនៃ ឲ្យញាតិចូលចិត្ត ៗ ត្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងឆ័ស្វា ៗ ទោះមានមិនមានក្តីណា ពាក្យផ្អែមបវរា ទើបគេស្រឡាញ់ ៗ កុំផ្ចិតស្វិតកំណាញ់ មិនម្ចាស់អស់អញ នឹងញាតិសន្តាន ៗ កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី ៗ ទោះនឹងនិយាយស្រដី ការគេក្តីជាស្រី កុំស្តីលេះលោះ ៗ ថាលេងដូចក្មេងញ៉េរញ៉ោះ ឃើញប្រុសកំឡោះ សសៀរចូលជិត ៗ បើចព្រៀងបញ្ញៀងមិនគិត ប្រុសព្រើលបានចិត្ត តាមហានៈវាយស្មារ ៗ ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទកន្ទ្រួ ៗ

សើរើពុំធ្វើទីងទួន ស្រដីមិនមួន មិនមានអៀនអន់ ។ ឃើញគេបៀត
បែរគេយកគន់ សើចស្អួរចំអន់ ចំអកឲ្យប្រុស ។ ហៅស្រីអប្រិយទុរយស
មិនខ្លាចខ្លួនខុស មារយាទគ្រិតគ្រម ។ ធ្វើការអន្ទ្រយច្រឡំ នឹងសម
ពុំសម ផ្កាឯងជាស្រី ។ មិនកោតមិនខ្លាចចិត្តប្តី ឲ្យប្រុសដទៃ មាក់
ងាយប្តីណា ។ ហៅស្រីឥតលក្ខណា ឥតមានកិរិយា មារយាទពុំសម ។
ធ្វើការផងណាប្រែចំ ទោះត្បាញតាក់ដំ នាងខំឲ្យហើយ ។ កុំទុក
ទៅមុខទៀតឡើយ ថាចាំបង្ហើយ កម្រណាស់ណា ។ ទោះធ្វើ
ហូលគោមព្រែផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ ។ ធ្វើ
ឲ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឲ្យដើរ លេងផ្ទះគេណា ។ ឲ្យស្ងួន
ខ្ចិមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ ។ មានប្តីបានអ្វីជាចំ
រវល់កូនយំ កម្របេះធ្ងៀត ។ ព្រួយចិត្តគំនិតចង្អៀត មួយហើយ
មួយទៀត យំទារតែធី ។ រីឯព្រួយទាំងមួយទាំងពីរ រកបានឲ្យធី
ទើបបានបាត់មាត់ ។ ទោះកាន់ការធ្វើឲ្យស្អាត ហូលគោមគាតកាត់
អន្ទង់ត្បាញទៅ ។ កុំទុកក្តងស្តគ្រស្បញនៅ រែងដល់យូរទៅ ខាត
ខូចអសារ ។ ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី ។
ចូរគេរៀនយកច្បាប់ស្រី ឲ្យកោតខ្លាចប្តី តម្តែងក្រឡា ។ ធ្វើវត្តប្រតិ-
បត្តិសោតណា ឲ្យនាងរក្សា ក្នុងភ្លើងទាំងបី ។ ឲ្យកាត់ឲ្យគង់ប្រក្រតី

សព្វថ្ងៃកុំបី ក្មេងផុំឲ្យនេះ ៗ ក្រែងកាលជួបជាលព្រាយព្រេះ កើតក្តៅ
រលេះ រលាកអស់អង្គ ៗ ក្មេងក្រៅកុំនាំទៅគង្គ ឲ្យនេះបំផុង រឹងជុំ
បង្អាត់ ៗ ក្មេងក្មេងមិនប្រែប្រយ័ត្ន នាំមកបង្អាត់ ឲ្យនេះឯក្រៅ ៗ អ៊ុជ
កាលបណ្តាលឲ្យក្តៅ ជាលដល់កូនទៅ អសោចអប្រិយ ៗ ឲ្យនាងខំ
ប្រុងស្មារតី មើលក្មេងតាំងបី រក្សាឲ្យគង់ ៗ ក្មេងនោះឲ្យគុណតាំលង់
ទីងឲ្យខ្ពុង ខ្ពស់យកខ្លួន ៗ កើតយសរបស់ត្រកូល បរិបូណ៌ឥតហ្មង
ប្រសើរក្តាត់ណា ៗ ក្មេងមួយនោះឲ្យរក្សា គុណមាតា បិតាសួន
ត្រង់ ៗ ឲ្យនាងធ្វើដោយគន្ធង ប្រណិបត់ទំកុំគ្រង ទីងក្តាយឪពុក ៗ
ឲ្យខំថែទាំញាំកញ្ញុក ចំណាំចំណុក ចំណង់អាត្មា ៗ កុំឃ្លានទុកចោទឡើយ
ណា ឆ្ងាញ់លួយពិសា ជូនជាប្រក្រតី ៗ ពាក្យពេចន៍ការកិច្ចអ្វីៗ
អត់ទុកកុំបី ឲ្យអាក់ចិន្តា ៗ ក្មេងមួយគម្ពែងក្រឡា គីបីអាត្មា បិតថេរ
រូបរ័ក្ស ៗ ឲ្យនាងប្រណិប័តន៍ជៀងជាក់ កុំធ្វើឲ្យអាក់ ឲ្យអន់ចិត្ត
ប្តី ៗ អត់ទុកខ្លាចខ្លួនដៀតស្រី កុំឲ្យស្រដី ទុកគេជាស្មើ ៗ គោះ
កើតហេតុកេទសារពើ ពាក្យពុំប្រសើរ ផញ្ជឹងចាំស្តាប់ ៗ គោះប្តី
ស្រដីពុំគាប់ ពុំគួរឲ្យប្រាប់ បានដឹងដល់ម្តាយ ៗ កើតទំនាស់រង្វែងខ្វាយ
ពុំភាក្យពីម្តាយ ខ្សឹបខ្សៀវប្រាប់ប្តី ៗ មិនក្សាន្តបែកបានពីរបី កើត
ជាសំង៉ី សួរចុះសួរឡើង ៗ ពុំស្ងាត់ស្ងៀមបាត់បង់ ជជែកនាំ
ឡើង ចរចើងមិនបាត់ ៗ គតាំងពាក្យខ្លាំងមិនស្ងាត់ ខំនស្ងៀមឲ្យបាត់

ឲ្យបានទីសុខ ៗ ជាដែកស្មើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ ឡើយនៃ ៗ នេះហៅក្អកក្អែងទាំងបី ម្ដាយផ្ដាំកូនស្រី ឲ្យចំរក្សា ៗ នាងអើយគម្ពែងក្រឡា ខុសគ្គងម្ដេចម្ដា ម្ដាយផ្ដាំកូនស្រី ៗ ឲ្យអត់ សង្កត់ហ្ឫទ័យ កូនកុំស្រដី ដើមប្ដីកំហឹង ៗ កុំដេកកុំចេញផាត់ខ្នាំង ខ្សត់ខ្សោយខ្លៅខ្លាំង នាងកុំមើលងាយ ៗ ល្ងង់ខ្សោយប្រើឲ្យនិយាយ ណែនាំលេងលាយ ឲ្យស្រួលពិតា ៗ ទោះប្ដីស្រដីម្ដេចម្ដា ខេរខឹង ជេរថា ប្រោះពាក្យទម្ងន់ ៗ គ្រោធក្រេវធ្ងុលធេវមិនអន់ មិនអាក់ស្រាក ស្រន្ត ដោយចិត្តគ្មានគ្នាញ់ ៗ ខ្ញូរទាំទេន្ទេញ ជេរថាជន្ទេញ ផ្សិត តាស់ទឹងចិត្ត ៗ ឲ្យក្លូនស្រីស្ងួនទំអត់ ឲ្យបានរលត់ រលាយកំហឹង ៗ កុំកួនកាន់ខ្ញូនប្រែប្រឹង តតបទៅទឹង អ្នកជាស្វាមី ៗ ខេទឹងក្រញឹង សំដី មិនគិតខ្លួនស្រី ស្រដីទ្រគោះ ៗ ប្រកែកស្ដីពាក្យគំរោះ គំរាម បញ្ឆោះ បញ្ឆោះឲ្យខឹង ៗ រឹងរូសមើលមុខសំឡឹង សំឡក់ទៅរឹង បង្ហើងនាំឈ្លោះ ៗ រឹងធ្ងង់ឆ្លើយពាក្យបញ្ឆោះ បំបែកជាឈ្លោះ បំបែរ តាំងទៀង ៗ ជេរថាឆ្កែធ្លាបំពៀង ដៀលត្មះបញ្ឈៀង បញ្ឈឺចិត្តប្ដី ៗ ថោកបោះប្រទះអ៊ូៗ ពាប់ពាលទៅដី បែកបាក់ពុំគិត ៗ មិនស្រួល ទទួលបាត់មាត់ ម្នះម្នេញកងចិត្ត ឲ្យបានប្ដីចាញ់ ៗ ទើបបានសុខចិត្ត ជាវិញ ហៅស្រីម្នះម្នេញ អ័ប្បគេត្រៀយសង្ហាយ ៗ ហៅកូនស្រីស្ងួន មាសម្ដាយ ខុសណាស់នាងអាយ កុំធ្វើដូចគេ ៗ ទោះបីប្ដីនាងជេរ

នាងចូលទៅឯ ដំណេកគិតស៊ិន ៗ ចេញមកនាងយកពាក្យទន់ ស្រដី
ឲ្យអន់ស្រាយទោសនោះទៅ ៗ ទោះបីប្ដីប្រដៅ ត្រូវនាងចាំនៅ ទុក
ក្នុងអាត្មា ៗ ពាក្យពេចន៍កុំត្រូវឡើយណា ក្រែងឆ្គងម្ដេចម្ដា ដ្បិតបាន
ផ្ដុំស្រាប់ ៗ ព្រោះឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បង្កើតតែ
ឈ្លោះ ៗ ឥតសុខអាក្រក់តែឈ្លោះ ត្រូវតែប្រពោះ មិនចេះហៅល្ហ ៗ
នេះពុំគប់ជាស្រីទេ ជាអ្នកប៉ោឡៃ បិត្តទោរជកទង ៗ ឲ្យមាត់បន្ថែម
ប្ដីផង ឲ្យគេស្ដាប់ហោង ថាឯងគ្រាន់បើ ៗ គឺមោះនាងនោះមិនប្រើ មិន
បើកឲ្យដើរ បញ្ជាឲ្យទេ ៗ ទោះបីប្ដីប្រើហាសមេ កុំកូនចាំកែ ចំអៀកមិន
ទៅ ៗ ផ្ទាយផិតកុំគិតរងំនៅ ក្រោកក្រែសដើរទៅ កុំឲ្យប្ដីដេរ ៗ កុំទៅ
យូរនៅផ្ទះគេ រវល់ទំនេរ វៀសមកណា ៗ ដូចកូនខ្ញុំម្ខនមាតា ជាស្រី
នេះណា កម្រណាស់នាង ៗ មិនថាផ្សិតល្អរូបរាង មិនរើសផ្សិតផាង
ចេះការទាំងគ្រប់ ៗ មិនបានស្គាល់ទីគោរព ស្គាល់តែឧបទ្រព ទាំងផប់
ប្រការ ៗ ហៅតែទឹងល្អរូបា ពិតហើយចេះការ គួរកោតដោយយ៉ាង ៗ
មួយល្អរូបស្រស់ឡាង ឥតគេធ្វើមមាង ច្បាប់ផងមិនចេះ ៗ ល្អពិតគំនិត
មិនផេះ ទោះទៅក្រដេះ ការសោតសមគួរ ៗ គឺមោះនាងនោះមិនផ្គួ
ចេះដឹងសមគួរ ស្គាល់អស់ភរិយា ៗ នេះឯងពីព្រេងលោកថា ហៅល្អ
រូបា គបកល្យាណ៍ ៗ ហៃកូនស្រីស្ងួនពីសី ម្ដាយប្រាប់អំពី ឧបទ្រព
ចង្រៃ ៗ កាន់ក្បាលប្ដីហើយកេវៃ មិនបាទលើកដៃ តីទូលសំពះ ៗ

លោកទុកស្មើកុកទំផុះ រង្គុំរង្គុះ នឹងបង់អស់ទ្រព្យ ។ កន្ទុងដើងប្ដីពុំគាប់ ព្រោះចិត្តបង់ឆាប់ រំលងដើងប្ដី ។ ស្មើសត្វលលកខ្មោចខ្មី ហើរប្រាស់ អប្រិយ កើតព្យាធិពេគា ។ ចង្រៃមួយនៃពល់គ្នា បេញចូលមាត់ទ្វារ ពុំបានបិទបាំង ។ ឆ្កួសប្រាណខុសខានមិនពាំង មិនរុំញបំបាំង មើល យល់សាយសុះ ។ ទុកស្មើគេអុជបន្ទុះ ឲ្យចោរចូលចុះ យកទ្រព្យទាំង-ឡាយ ។ ស្រីមួយស៊ើបលេងក្អាកក្អាយ ព្រះលបបម្វាយ រំលងផ្ទះបី ។ ស្មើសត្វបាតបក្សី ចូលកូមិផងក្ដី ចង្រៃក្ដាត់ណា ។ ស្រីមួយដេកដាក់ កាយា ប្រះប្រែអាត្មា ឲ្យខ្ទង់ទៅប្ដី ។ ទុកស្មើពស់ក្រាយអប្រិយ ឡើងផ្ទះឥតបី ឥតបើគណនា ។ ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាស គ្នា ពុំបានវែងឆ្ងាយ ។ ស្រីមួយសក់វែងអន្ទាយ រំសុះរំសាយ សក់ សោតសេព ។ នៅមាត់អណ្ដូងមាត់ទ្វារ បីដូចមង្ឃាក ឆ្មាលាក់ក្រចក ។ ចង្រៃឥតបីបើរក រកសំកក មិនចុកសក្កឆាយ ។ ស្រីមួយដើរទៅ ទាត់ដាយ ព្រលានស្មើរក្លាយ ប្រែបពីសន្ធឹក ។ សំពត់ដាច់ដាចមិនគិត ដើរព្រួគគឹក ស្មើស្វារខ្នុះ ។ ញាំញើដំណើរលលះ ដាក់ជើងលើផ្ទះ គគ្រាំគគ្រែង ។ កក្រើកផ្ទះទាំងបីល្វែង ដូចគលគៃសែង របស់បេញ ទៅ ។ ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្ទុងហួសទៅ មិនចាប់បេញទុក ។ ពុំថែរបំណោរទៅមុខ ពុំបេះដាក់ទុក កយកពល់តែល្វែង ។ ទ្រព្យនោះ លេស់បេញឯង ចង្រៃតាស់ខែង ត្បូឲ្យអគ្គពយ ។ តោះឯចំណីខ្វះបាយ

លបល្បូកកកាយ ពមពុំសណ្ដាប់ ៗ កូនអើយនេះហើយចូរស្ដាប់ ហៅ
ក្ដីឧបទ្រព ទាំងជប់ប្រការ ៗ ឲ្យរៀបអស់ទាំងនេះណា ឲ្យរៀន
លក្ខណា ទាំងប្រាំពីរផង ៗ គឺព្រះមានបុណ្យត្រទ្រង់ ទេសនាចែងចង
ជាបទគាថា ៗ មួយមាតុមួយមិត្តភរិយា ភាតុភរិយាជា ទាសភរិយា
ផង ៗ ទាំងបួនប្រសើរកើតហ្មង គួរឲ្យចាំបង ទុកក្នុងអង្គា ៗ រីឯហៅ
មាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្ដាយ ៗ ចរិតបីប្រការគុណ
កាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឲ្យប្ដី ៗ បានក្ដីរុងរឿងឮល្បី
មិនឲ្យអាប់ប្ដី ឲ្យបានស័ក្ដិយស ៗ មួយបើប្ដីស្លៀកពាក់ចាស់ យកថ្មីឲ្យ
ផ្លាស់ ចាស់ស្លៀកខ្លួនឯង ៗ បេះរៀបណ្ដាប់គាក់តែង បំណាំផងស្ងួន
គេមកឲ្យប្ដី ៗ មួយបើប្ដីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្ដី រកថ្នាំសង្កូវ ៗ រក
ពេទ្យមេមត់ឡូគ្រូ គ្រោះយាមគន់គូរ មើលប្ដីឲ្យជា ៗ រីឯហៅភាតុភរិយា
ប្រសើរសោភា ប្រពន្ធស្មើបង ៗ នោះមានចរិតពាំផង ដូចប្អូននឹងបង
ចិត្តមូលមួយប្រាណ ៗ មួយធ្វើឲ្យប្ដីក្សេមក្សាន្ត របស់ប្ដីបាន បេះទុក
រក្សា ៗ មួយព្រោះឮពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្ដី ៗ ពុំ
ត្រែអស្រែអប្រិយ បេះការគេក្ដីប្ដី ប្រែបានជាសុខ ៗ ទោះបីបើប្ដី
មានទុក្ខ គិតឲ្យបានសុខ យកខ្លួនធានា ៗ មួយសោតឯមិត្តភរិយា
មានចរិតជា បីប្រការមិញ ៗ បីដូចគល់មិត្តសំឡាញ់ មានចិត្តអស់
អញ មិនឲ្យមានហ្មង ៗ បីដូចគល់ប្អូននឹងបង ប្រាស់យូរលង់ហោង

ទើបមកជួបគ្នា ។ មានចិត្តប្រតិព័ទ្ធម៉ហិមា ដ្បិតបានជួបគ្នា មិនឲ្យមានហ្មង ។ មួយមានមារយាទកន្ទង ពោះឃើញប្រុសផង មិនល្មៀងចិត្តទៅ ។ វិទាសភរិយានោះគួរ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្តី ។ ចរិត ៤ ប្រការទី មួយចិត្តខ្លាចប្តី តែងប្តីវាយជេរ ។ ប្រឹងចិត្តការគិតខ្មាសគេ មិនឲ្យប្តីជេរ បន្ទោសខ្លួនបាន ។ ទោះប្តីខឹងតែប៉ុន្មាន មិនបេះហៅហាន ឆ្លើយឈ្មោះតមាត់ ។ មួយទោះប្តីនោះកាចក្តាត់ ទឹងដល់វាយវៃ ជេរពោរជេកចង ។ មិនហ៊ានឆ្លើយឈ្មោះរំលង តតបទៅផង តែងញុះកើ្តឆ្ងាយ ។ មួយបេះប្រងាប់រៀបចាយ ប្តីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ ។ អត់ចាំចាំពីប្តីមក ជួបជុំទើបយក បរិភោគជងគ្នា ។ នេះឯងហៅទាសភរិយា សម្តេចគតរ៉ា ទេសនាប្រោសប្រាប់ ។ បើគស់ស្រីណាបានស្តាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ ។ លុះអស់អាយុក្សិណក្ស័យ បានទៅកើតឮ តុសិតសួគ៌នាយ ។ នឹងបានក្រេមក្រាន្តពណ្ណាពយ សេពសុខសប្បាយ និរទុក្ខភយា ។ រីឯប្រពន្ធពុំជា ពេជ្ឈ-ឃាតភរិយា ចរិតមានបួន ។ កុំឲ្យយកទុកក្នុងខ្លួន ឲ្យចៀសចេញជួនកើតកម្មពៀក ។ មួយចិត្តគំនិតចងជា ឆ្លាស់ឆ្លើយបំពារ បំពានឲ្យប្តី ។ ប្រទូស្តរឹងរូសខ្សូវខ្ញី មិនបេះពាញប្តី ថាឯងគ្រាន់បើ ។ ឆ្លើយឆ្លងសួរសេងបណ្តើរ ចង់ឈ្មោះឲ្យស្មើ ឲ្យលើសប្តីវិញ ។ មួយមិនចង់ធ្វើបំពេញ បង្អាប់ប្តីវិញ ឲ្យថ្កើងខ្លួនឯង ។ ភាន់ពេះដៀលតិះតុំតែង

ឲ្យប្តីស្តាប់ឯង ដោយចិត្តអន្ធពាល ៗ មួយមានចិត្តនោះស្រើបស្រាល ចង់ត្រេកត្រអាល ចោរចេញក្បត់ប្តី ៗ មួយចិត្តទ្រឹស្តិទ្រុសអប្រិយ ចង់សម្លាប់ប្តី ស្រឡាញ់ប្រុសទៀត ៗ គិតកាប់សម្លាប់បង្បៀត នឹងយកប្រុសទៀត ធ្វើប្តីមាណា ៗ រីឯស្ត្រីកិរិយា ចរិតពុំជា ប្រាំ-ពីរប្រការ ៗ មួយមិនខ្លាចប្តីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត ៗ មួយរឹងទ្រមឹងស្ងៀមស្ងាត់ ប្តីសួរមិនមាត់ ពុំស្រដីផង ៗ មួយប្តីស្រដីតន្ទង ប្រដៅច្បាប់ផង ពុំចូលចិត្តស្តាប់ ៗ មួយមិនចង់ឲ្យប្តីគាប់ មិនចង់ប្រដាប់ ឲ្យប្តីថ្កើង ៗ មួយទោះនឹងស្រដីឡើង ពាក្យធំចចេង ចចេសនឹងប្តី ៗ មួយទោះប្តីលោះខ្ញុំស្រី រាប់អីប្តី មិនឲ្យអាក់អន់ ៗ ឃើញគាប់រីស្អប់ខ្ពាញ់គ្នាន់ ក្នុងចិត្តប្រចណ្ឌ ដេរជានាយអាយ ៗ មួយផ្សិតប្តីមានសហាយ ហួរហែកសុះសាយ ឲ្យប្តីអាស្រូវ ៗ រីទោរកិរិយានោះគួរ ចរិតពុំត្រូវ មានបីប្រការ ៗ មួយចង់ចាយទ្រព្យប្តីណា ឲ្យខូចអសារ មិនគង់ជាល្អ ៗ មួយប្តីឃ្លាតទីទំរក់ របស់បានមក មិនថែទាំទុក ៗ លួចឲ្យទៅម្តាយឪពុក ប្តីសួររកមុខ មិនប្រាប់ឡើយណា ៗ មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់ ៗ ដេកលេងចំខែងអស់កល់ លុះប្តីគេយល់ ពុតធ្វើជាឈឺ ៗ ទទូរដេកថ្ងូរហ៊ឺៗ ប្តីហៅមិនឮ ពុតចង់តែស្លាប់ ៗ នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ ៗ លុះអស់អាយុ

ក្ដីបក្លាយ ធ្លាក់ទៅអបាយ ទាំងបួនបំពូក ។ តែងនឹងរងទុក្ខរងសោក

រដោះរួចមក កើតជាមនុស្សខ្ញើយ ។ ហេតុអកុសលនេះហើយ ដ្បិតខ្លួន

ឥតត្រើយ ធ្វើខុសគន្លង ។ ខុសវត្តប្រតិបត្តិផាំផ្គង មិនរៀនមិនរង

ខុសទំនងច្បាប់ស្រី ។ មាក់ង៉ាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌

លោកថា ។ មាក់ង៉ាយមួយនោះឯងណា ដ្បិតប្ដីពិការ មិនបានមួនមាំ ។

ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ គ្រូគ្រោះមេមត់ ។ មើលប្ដីឲ្យ

ជាធាប់ធុត ខឹងវិញមិនអត់ បន់ឲ្យប្ដីស្លាប់ ។ មាក់ង៉ាយមួយប្ដីខ្សត់ទ្រព្យ

គ្មានកេរ្ដិ៍កោះគាប់ ស្មើនឹងអាត្មា ។ ដៀលត្មះថាធ្លះដោយសារ ព្រោះ

ខ្ជិលធ្វើការ ទើបគ្មានរបស់ ។ មាក់ង៉ាយដ្បិតប្ដីអប្បយស ឯងត្រកូល

ខ្ពស់ ពូជពង្សត្រុំស្មើ ។ ធ្វើងខ្លួនឲ្យប្ដីបំរើ ឈ្មោះឡើងហើយដើរ ដៀល

ត្មះពូជពង្ស ។ មាក់ង៉ាយមួយដ្បិតប្ដីល្ងង់ ខ្ញៅខ្លួនទ្រមង់ ទ្រមក់យឺត

យូរ ។ ដៀលត្មះតុំបេះអាសូរ សំដីខ្មោះខ្លូរ មិនក្រែងប៉ុនសក់ ។ មាក់

ង៉ាយមួយប្ដីអាក្រក់ សាប់ខ្មៅប៉ប៉ក់ មុខអុតស៊ុស៊ុស ។ កន្ទ្រលពងលេ

ក្រឡុះ សក់ស្កាញស្កួវស៊ុស ពោះធំប៉ុនពាង ។ ខ្លួនឯងចិញ្ចែងរូបពង ខ្លួន

សល្អជាង ថាប្ដីមិនសម ។ មាក់ង៉ាយមួយប្ដីមិនខំ ធ្វើការលោលំ ឲ្យ

ឲ្យរដើរលេង ។ ឆ្ងៀតឆ្លើយបោះពាក្យគគ្រេង ឈ្មោះដើរមិនឈ្មង

គិតខុសមាត្រា ។ មាក់ង៉ាយមួយប្ដីផឹកស្រា ស្រវឹងបោលការ ដើរពេង

តែគោ ។ ពាក្យគ្រើងពាំបៀងឡោ ឲ្យក្ដៅព្រះនេ ផ្ដើលភ្នាក់កូនចៅ ។

ព្ទមាត់ប្ដីហើយទឹងក្ដៅ ប្រទេចជេរទៅ តាមដោយចិត្តគ្នាញ់ ។ អាក់-
ង៉ាយមួយទៀតនោះមិញ ដៀតប្ដីស្រឡាញ់ លលួកប្រខ្សែង ។ មួល
បិចទាក់ចុចជាខ្សែង មិនមានគោតក្រែង បានចិត្តជេរវិញ ។ ដៀតតែ
យល់គេស្រឡាញ់ ស្រដីផងមិញ គំពេះគំរើយ ។ ធ្វើគ្នាញ់បែរបេញ
ព្រងើយ ទេរទឹងកន្ដើយ ក្ដិចក្ដក់មាយ៉ា ។ ពុំបានក្រេមក្សាន្ដទីងគ្នា
មាក់ង៉ាយនេះជា គំរប់ប្រាំបី ។

កូនអើយនេះហើយច្បាប់ស្រី ឲ្យកូនពិសី រករៀនគេក្សា ។ យក
ទុកក្នុងអត្តសាគ្នា ប្រសើរក្ដាត់ណា កើតសុខសួស្ដី ។ ប្រសើរទាំង
នាលោកិយ ទោះបរលោកក្ដី សឹងលុះប្រាថ្នា ។ ទោះចិត្តគន់គិត
សទ្ធា ជាពុទ្ធមាតា សឹងបានបរិបូណ៌ ។ ដូចចិត្តឆាប់ធុតពុំយូរ
កបកើតសម្បូរ សម្បត្តិទ្រព្យផង ។ កើតយសខ្ពង់ខ្ពស់គន្លង យើន
យូរផុតហ្មង ដូចក្ដីប្រាថ្នា ។ ច្បាប់នេះឧត្ដមថ្លៃថ្លា ទោះស្រីឯណា ព្ទ
ហើយមានគិត្ត ។ ជាល្អកម្របានស្ដាប់ ស្ដាប់ហើយចូរចាប់ ចូរចាំ
គ្រប់គ្នា ។ បានដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូរចាំកុំភ្លេច ។
ចរចាអស់អាថ៌ពាក្យពេចន៍ ពាក្យឥតកាព្យកិច្ច បរិបូណ៌ប្រពៃ ។ ប្រាជ្ញ
ប្រែងឯនាយខៃ ខ្ញុំឈ្មោះម៉ឹងម៉ៃ មែនមានសទ្ធា ។ មានចិត្តគួបគិត
កាព្យា កបកើតប្រជ្ញា ត្រែកត្រដំកុសល ។ សទ្ធាប្រាថ្នាមគ្គផល

ផុលផុះយោបល់ លេចលើកទុកទៅ ៗ ទោះបីសេចក្ដីខុសត្រូវ សូមទានជម្រើ ដម្រង់ឲ្យផង ៗ កុំគ្នះគិះដៀលឡើយហោង សូមសាងផលផង ទុកគសាសនា ៗ សម្រាប់ជាច្បាប់មាត្រា សូរេចបភាព បរិបូណ៌ថៃ្ងចប់ ៗ

ចប់ច្បាប់ស្រី តែប៉ុណ្ណេះ ៗ

ច្បាប់អរិយសត្ថា [១]

បទកាកគតិ

អរិយសត្ថា គន់គិតថែងថារ បង់ទុកជាច្បាប់ ឲ្យអស់សិស្សជន ត្រង់ត្រាប់សណ្ដាប់ យកជាតម្រាប់ តម្រង់អាត្មា ៗ ឲ្យមានប្រ-យោជន៍ ប្រយ័ត្នអសោច ពល់រូបអ្នកណា អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា ការគេត្ត៍លោកិយ ៗ តោះទង់ចេញទៅ ប្រយោជន៍នានៅ ផ្គាប់ផ្គុំទមទ្រ ឲ្យត្រូវទំនងច្បាប់ សណ្ដាប់សួស្ដី ដូចលោកស្រដី ប្រដៅទុកមក ៗ បើមិនចង់ទេ ចង់ទៅទំនេរ ផ្ញួញប្រិះគេបំញ៉ឹមជីវិត គួរគិតរៀនយក របៀននោះមក ទើបរកទ្រព្យបាន ៗ ការលេខគាត់ក្បាច់ សិនផ្សំសម្រេច ឲ្យបានដឹងជាន ដឹងដើមដឹងចុង ដឹងបង់ដឹងបាន ដឹងគិតប្រមាណ កត់ត្រាបញ្ជី ៗ ឲ្យបានប្រយោជន៍ ប្រយ័ត្នអសោច ជាអ្នកគេស៊ី សម្រាប់លោកិយ ប្រក្រតីជាទី សំគាល់បញ្ជី ស្មៀនត្រាសៀវភៅ ៗ គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ ឲ្យស្ទាត់ដោយនូវ ការលេខគាត់ក្បាច់ ឲ្យស្រេចឃើញផ្លូវ សឹមថយចេញទៅ តាមផ្លូវលោកិយ ៗ ល្មមដឹងតិចច្រើន ល្អដឹងក្រវើន ទ្រព្យធនអ្វីៗ លេខនិងអក្សរ កំដរស្មារតី សម្រាប់លោកិយ នោះឯងទើបត្រូវ ៗ បើតែវិលវល់ ខ្ជិលដេកស្រមេះ ស្រមូញស្មូញស្មូរ ស្រពាន

១ ប្រហែលជាព្រះសង្ឃដែលមានសមណសក្ដិជា ព្រះអរិយសត្ថា ទីមេគណឬចៅអធិការ ជាអ្នកតែងច្បាប់នេះ បានជាឲ្យឈ្មោះជា "ច្បាប់អរិយសត្ថា" ដូច្នេះ ។

លើខ្នើយ កន្ទើយលក់ទៅ នរណាទីងទៅ ដាស់តឿនឲ្យទៀត ៗ មិន
ដឹងឬអ្វី កង្កពដលោកិយ ពដការបង្អៀត នរណាទុកឯង លេងរាយ
ដៃព្រាត ឃើញហើយគេបៀត តម្រៀតពដការ ៗ ហេតុនោះគួរ
គិត គួរកាន់គំនិត គួរគិតឧស្សាហ៍ សង្វាតរករៀន របៀនសាស្ត្រា
តម្រិះប្រាជ្ញ បន្ការទុកទៅ ៗ ទើបដោះខ្លួនរួច ពប់ជាអ្នកស្រួច ដឹងគិត
ពក់ជ្រៅ កង្កពដលោកិយ សេចក្ដីឥឡូវ គិតឲ្យឃើញផ្លូវ នឹងទៅមុខ
ទៀត ៗ រីត្រង់ឯងខ្ជៅ គេថយចេញទៅ រកសុំបង្អៀត គិតគួរម្ដេចម្ដា
ប្រាំបីរបៀត ពឹងអ្នកកន្ទៀត ដូចខ្លួនកាលណា ៗ ហេតុតែខ្លួនឯង
បេះគិតភាក់តែង ឲ្យគ្រប់ប្រការ ទាំងលេខទាំងក្បាច់ ស្រេចទូវអាត្មា
ឯងឲ្យអស់ការ គិតគួរសព្វសាយ ៗ ទើបបានគេកោត គេមានចំណោទ
គេកោតប្រាជ្ញប្រាយ គេយល់ឯងបេះ ចំណោះវៃលបខាយ ពុំមានក្លែង
ក្លាយ បំបាត់បាំនឡើយ ៗ រីត្រង់អ្នកខ្ជៅ ផ្ដេកផ្ដិតចិត្តទៅ យកគេជា
ត្រើយ កាលម្ដងគេត្រង់ គង់ចិត្តនៅឡើយ ផល់ពីដេងហើយ គេប្រែ
ប្រាជ្ញ ៗ គេគិតទាយទាត់ វាយលេខបំភ្លាត់ បំផ្លាញអាត្មា ចំណេញ
ទៅគេ ទទេអសារ ខ្លួនឯងឥតការ ខាតទុនក្រខ្លួន ៗ នេះឯងក្មេងអើយ
កុំប្រែហែសឡើយ រៀនទុកជាក្បួន ទាំងៈលេខទាំងក្បាច់ ឲ្យស្រេច
នៅខ្លួន អក្សរឲ្យសួន ទាន់ខ្លួននៅក្មេង ៗ តែបាស់បន្តិច វិញ្ញាណភ្លាំងភ្លេច
គំនិតប្រែផ្សេង គិតការព្រើនមុខ កើតទុក្ខកន្ទេង ប្រាប់អស់ក្មេង ៗ

ឲ្យដឹងឲ្យហើយ ៗ កុំការងរម៉ែឪ សម្បត្តិដែលនៅ មានច្រើននោះឡើយ
ក្រែងវត្តធម៌ម៉ែ ធ្ងន់ធុរទៅហើយ ខ្លួនឡើងគោកដើយ ធ្ងន់ធំគល្ងង់
មោហា ៗ ក្រែងអស់តាំងទ្រព្យ នោះរាមិនខ្លាច នៅដឹងការគ្នា ខ្លួន
ឯងគោកនៅ កំឡោមោហា មិនចេះគេក្បា មិនបានគុណទេ ៗ ខ្លួចខាត
មិនខាន គំនិតមិនបាន ប្រហែសខ្ញុំគេ គេវាយគេជាក់ គេប្រើគេដេរ
មិនឲ្យទំនេរ ខ្លាសគេតិចអ្វី ៗ ដូចេះគួរគិត គួរឃើញគំនិត គួរគិត
សេចក្តី ជាមនុស្សដូចគេ គួរតែឃ្លាតខ្លី រំពឹកស្មារតី ស្រឡាញ់រៀន
កុំគិតក្តិលពេក កុំគិតពួនដេក កុំគិតវេះវៀន កុំគិតមានពុត រមិត
គិតរៀន កុំគិតអៀនប្រៀន វេះវៀនចិត្តគាប ៗ ឲ្យរៀនចិត្តល្អ ដឹង
ធម៌អក្សរ គួរគិតគោតខ្លាច ការគ្រឿងប្រយ័ត្ន គួរកាត់បោលកាប គួរ
ឲ្យខ្លួនខ្លាច កុំឲ្យត្រូវទោស ៗ ពាក្យត្រូវណាស់ ដំទៀលដល់តាស់
ពីព្រេងមុននាយ ឯត្រង់ពាក្យម្តាយ ទំនាយត្រូវតាយ នេះឯងមិនណាយ
អាក្រក់ណាស់ណា ៗ ឲ្យប្រុងប្រយ័ត្ន បម្រើប្រណៅប័តន៍ កាត់ចិត្ត
ស្នេហា កុំឲ្យអន់អាក់ ចាំងចាក់ចិន្តា ត្រូវតាយហើយណា ធុតធាប់
ណាស់ហោង ៗ ឲ្យដឹងបាបបុណ្យ ស្គាល់ទោសទំងគុណ ជាទុន
ទៅមុខ គុណគ្រូបាធ្យាយ គុណម្ដាយអាពុក រៀមច្បងទំនុក ឲ្យ
សុខអនុកូល ៗ គ្រួមួយផងគ្នា រួមរក្សចិត្តជា ស្នេហាមិត្រមូល កុំ
នាំអុជហេតុ បំបែកចេញចូល កាច់កិនត្រកូល បង្កើតមារគក ៗ

កុំធ្វើមាក់ងាយ ទឹងត្រូវបាចព្រាយ រៀនចិត្តឲ្យល្អ ទោះអ្នកឯណា វែកផ្លូវ
អក្សរ អ្នកនោះឯងអរ ឲ្យចិត្តមេត្រី ៗ កុំឲ្យសៅហ្មង លើលោកកន្ទង
ពោលពាក្យស្រដី រឹងរូសទ្រគោះ ឈ្លាសឈ្លោះសេចក្តី កើតទោស
អប្រិយ ដេរពោលប្រមាថ ៗ អ្នកនោះស្មើត្រូ បង្កើតអកិរូ គុណ
ទេទុកទ គេជួយប្រដៅ គេហៅទុហាត ដាស់តឿនសង្វាត ឲ្យឯង
បេះនាប់ ៗ បើឯងបេះហើយ កុំភ្លេចគុណឡើយ ឲ្យដឹងដោយច្បាប់
គ្រូគិតកោតខ្លាច ដើរតាមសណ្តាប់ តន្ទងធម៌ច្បាប់ កុំឲ្យមាក់ងាយ ៗ
នេះឯងគន្ទង ត្រឹមត្រូវទំនង អំពីព្រេងនាយ ឯកជឥឡូវ ច្រើនតែ
មាក់ងាយ បេះហើយដេរម្តាយ ប្រមាថគ្រូវិញ ៗ ហេតុដូច្នោះឯង
លោកិយយល់ស្តែង តែងឃើញម្តេចមិញ ហិនហោចស្ងួនស្ងួន លិច
លង់ទៅវិញ ទោសនោះឯងមិញ កើតពីឯណា ៗ កើតពីចិត្តឯង
បង្កើតស្ទះស្ទែង បំផ្លាញអាត្មា ពេលពលកុងពោះ ធេះកុងទុក បង្កើត
ទោសា ឲ្យទុក្ខរូបឯង ៗ បេះតែបន្តិច លើកខ្លួនកំប៉ុច កំប៉ោងឥត
ក្រែង តែងឃើញរៀងមក យ៉ាងដូច្នេះឯង ម្ល៉ោះហើយរកតែង ខុសទិង
ទេព្តា ៗ អ្នកចិត្តល្អ ដឹងធម៌អក្សរ បេះពិចារណា ស្គាល់គុណទឹង
ទោស សន្តោសអាត្មា អត់ទុនចិន្តា កុំដែលសៅហ្មង ៗ អ្នកនោះ
ឯងនៃ សោតស៊ីងប្រពៃ សួស្តីតន្ទង បរលោកលោកិយ ឥតបីសៅហ្មង

តាំងទេព្តាផង ចំរើនឲ្យសុខ ៗ ដរាបរៀងទៅ សុខពីឥឡូវ រៀងទៅឯមុខ ចៀសចាកប្រាសប្រាណ ពីស្ថាននរក រៀងរួចបានសុខ ដល់សួគ៌ាល័យ ៗ

អរិយសត្ថា គន់គិតតែងចារ តែងចងសេចក្តី កម្រងកម្រាប់ ជាច្បាប់យ៉ាងថ្មី ដាស់តឿនស្រដី សំស្រួលសព្វប្រការ ៗ គួរគិតរករៀន កិច្ចការរបៀន របបសាស្ត្រា តាមច្បាប់និទាន ខ្លួនអាត្មា រៀងរាល់រូបា សួរចេះចប់ហោង ៗ

ចប់ច្បាប់អរិយសត្ថាតែប៉ុណ្ណេះ ៗ

គម្ពីរបញ្ចតន្ត្រ

គម្ពីរប្រជុំនិទាន៥ពួក

នេះជាឈ្មោះគម្ពីរមួយដែលប្រជុំនិទានផ្សេងៗ ដែលល្បីល្បាញណាស់នៅក្នុងប្រទេសឥណ្ឌាសម័យបុរាណ ដ្បិតមាននិទានជាច្រើនណាស់ ដែលគេបានប្រែចេញពីភាសាសំស្ក្រឹត មកជាភាសាអ្នកស្រុកអាស៊ី និងភាសាពួកឧរុប កាលពីពុទ្ធសករាជ ១១១៣ ឡើងទៅ ។ ឯនិទានរឿងព្រេងអស់នេះ គេសន្មតថា កំណើតដើមរឿងនៅប្រទេសឥណ្ឌាទាំងអស់ ជាគម្ពីរមួយយ៉ាងចាស់ ប្រហែលកើតឡើងក្នុងរវាងពុទ្ធសករាជ ៦៥០ ។

អ្នកតែងរឿងជាជាតិព្រាហ្មណ៍ម្នាក់ ឈ្មោះវិស្ណុសរ្ម័ន ។ ឯគម្ពីរនេះមានប្រយោជន៍ក្នុងការសិក្សារបស់ពួកក្សត្រ សម្រាប់ឲ្យពួកក្សត្រចេះរបៀបត្រួតត្រាស្រុកទេស និងប្រព្រឹត្តឲ្យត្រូវតែខ្លួនផ្ទាល់អង្គក្សត្រផង ។ មានរឿងខ្លះ គេឃើញមានក្នុងរឿងជាតក ដែលដកយកមកអំពីគម្ពីរបញ្ចតន្ត្រ មានសុភាសិតជាច្រើន ដែលប្រកបដោយសីល ធម៌, សម្មាអាជីវៈ និងប្រសាសនោបាយរបស់ក្សត្រ ។ រឿងនេះសុទ្ធតែតែងជាភាសាសំស្ក្រឹត ឯរឿងខ្លះ នាំឲ្យមានប្រយោជន៍ដល់ចិត្តគំនិតនោះ ដូចនិទានដែលយើងរើសប្រមូលមកនេះ ។

អំពីមេបង្កងមួយជួយជីវិតព្រាហ្មណ៍ម្នាក់

ក្នុងតំបន់មួយនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះព្រហ្មទត្ត[១] ។ ព្រាហ្មណ៍នេះ ត្រូវការធ្វើដំណើរចេញទៅកាន់ស្រុកមួយទៀត ដោយកិច្ចធុរៈដែលខានពុំបាន ។ មាតាគាត់ទើបសួរទៅគាត់ថា "ម្នាលកូន, ហេតុដូចម្ដេចក៏កូនចេញទៅតែម្នាក់ឯង? ចូរឯងរកសម្លាញ់ម្នាក់ជាគ្នា ដើរផ្លូវទៅជាមួយផង ។ ព្រាហ្មណ៍ជាកូនពោលតបទៅវិញថា "លោកម្ដាយ, ខ្ញុំបាទមិនខ្លាចអ្វីទេ ផ្លូវនោះឥតមានគ្រោះថ្នាក់អ្វីទេ ខ្ញុំបាទមានការសំខាន់មួយខានទៅពុំបាន ទុកជាម្នាក់ឯង ខ្ញុំបាទក៏គង់តែទៅឥឡូវនេះដែរ ។ ឯម្ដាយកាលបានឃើញសេចក្ដីតាំងចិត្តដាច់ស្រេចដូច្នោះ ទើបនាងទៅដងយកមេបង្កងមួយ អំពីអណ្ដូងជិតខាងលំនៅ ហើយនិយាយទៅនឹងកូនថា "កូន, ប្រសិនបើត្រូវតែទៅខានពុំបានទេ ចូរឯងយកមេបង្កងនេះធ្វើដំណើរទៅជាមួយផងចុះ ។ ឯព្រាហ្មណ៍បានទទួលយកដោយសេចក្ដីគោរព យកដៃទាំងពីរទ្រ ហើយដាក់បង្កងក្នុងកន្ទោងកប្បូរ ហើយដាក់ទៅក្នុងថង់ប្រាក់ ១ ជាន់ទៀត ហើយចេញដើរទៅដោយប្រញាប់ ។ ប៉ុន្តែកាលដែលព្រាហ្មណ៍កំពុងដើរទៅនោះ ត្រូវកំដៅថ្ងៃជាខ្លាំងក៏ចូលទៅជ្រកក្រោមដើមឈើ ១ ដើម ដែលនៅក្បែរផ្លូវហើយដេកលក់ទៅ

---

១ ឈ្មោះនេះប្រែថា ដែលព្រហ្មប្រទានមក ។

ដោយសេចក្ដីក្រៀមក្រំ ៗ ខណៈនុ៎ះ មានពស់ខ្មៅ ១ ចេញមកពីប្រហោងដើមឈើ ហើយវារទៅលើខ្លួនព្រាហ្មណ៍នោះ តែពស់ធុំក្លិនកប៉ូរ ទើបវារចេញពីខ្លួនព្រាហ្មណ៍ ហើយហែកថង់ប្រាក់នោះចេញ ទើបខាំស៊ីកន្ទោងកប៉ូរដែលនៅខាងក្នុងថង់ ដោយចិត្តលោភនឹងឃ្លានជាខ្លាំង ៗ ឯមេបង្កងក៏ត្រូវពស់នោះស៊ីដែរ តែពស់លេបចូលទៅក្នុងបំពង់កស្លាក់ ហើយពស់នោះស្លាប់ទៅ ៗ លុះដល់ព្រាហ្មណ៍ក្រោកពីដេកឡើងក្រឡេកមើលទៅខាងៗខ្លួន ក៏ឃើញពស់ខ្មៅមួយស្លាប់នៅក្បែរខ្លួន ហើយនៅក្បែរពស់នោះឃើញមេបង្កង ៗ កាលព្រាហ្មណ៍បានឃើញហេតុដូច្នោះហើយក៏គិតថា: ឱ! មែនហើយ ម្ដាយអញបាននិយាយនឹងអញថា (ទៅទីណា) ត្រូវតែមានគ្នាទៅជាមួយផង មិនត្រូវចេញដំណើរទៅតែម្នាក់ឯងឡើយ ៗ ដោយហេតុអញប្រតិបត្តិតាមដំបូន្មាន របស់ម្ដាយដោយសេចក្ដីជឿយ៉ាងពិតប្រាកដ ទើបអញបានរស់រួចពីសេចក្ដីស្លាប់ពីពស់ចឹក ដោយមេបង្កងជួយសង្គ្រោះអញ ៗ មួយវិញទៀត គេបានពោលដូច្នេះថា:

សូម្បីតែគ្នាដើរផ្លូវដ៏មានកំឡាំងទន់ខ្សោយយ៉ាងណាក៏ដោយ ក៏ជាហេតុនាំឲ្យកើតសុខដែរ មើលចុះ អ្នកដំណើរម្នាក់បានផុតពីត្រូវពស់ចឹកស្លាប់ ដោយសារគ្នាដែលដើរផ្លូវទៅជាមួយនឹងខ្លួន ៗ

អំពីអណ្ដើកនិងហង្សពីរ

(រឿងនេះមានសេចក្ដីស្របគ្នាក្នុងជាតក និងអវទាន)

នៅក្នុងស្រះ ១ នោះ មានអណ្ដើក ១ ឈ្មោះកម្ពុគ្រីវៈ[1] ហើយអណ្ដើកនេះ មានសំឡាញ់ពីរជាសត្វហង្សឈ្មោះសង្កដ[2] ១ ឈ្មោះវិកដ[3] ១ សត្វទាំងពីរនេះ ក៏មានចិត្តស្រឡាញ់អណ្ដើកដោយស្មោះត្រង់ ហើយតែងនាំគ្នាទៅកាន់មាត់ស្រះនោះជានិច្ច ហើយបានដំណាលរឿងការឲ្យអណ្ដើកស្ដាប់សព្វគ្រប់ អំពីរឿងទេវឫសី[4] ព្រហ្មឫសី[5] និងរាជឫសី[6] ដរាបដល់ព្រះអាទិត្យអស្ដង្គតទៅ ទើបនាំគ្នាទៅសំបុករបស់ខ្លួនវិញ ។ លុះក្នុងសម័យតៗមក ទឹកនោះក៏រាំងឥតទឹកភ្លៀង ស្រះនោះក៏កាន់តែស្ងួតបន្តិចម្ដងៗ ។ សត្វទាំង ៣ ក៏កើតទុក្ខដោយគ្រោះថ្នាក់នេះ ទើបហង្សទាំងពីរនិយាយគ្នាថា "ឱ! សំឡាញ់ស្មោះចិត្តអើយ ឥឡូវនេះស្រះនេះមានតែភក់, ចុះសំឡាញ់គិតគូរដូចម្ដេច? យើងព្រួយចិត្តណាស់ សព្វថ្ងៃនេះ" ។ កាលកម្ពុគ្រីវៈ បានឮដូច្នោះហើយ ទើបនិយាយឡើងថា "អើ! សំឡាញ់ ប្រសិនបើគ្មានទឹក, ចំណែកខ្លួនខ្ញុំមិនមានផ្លូវរស់តទៅទៀតទេ ដូច្នេះត្រូវយើងគិតគូររកឧបាយដោះខ្លួន ដ្បិតគេតែងពោលទុកថា :

---

១ ប្រែថាមានកកញ្ចាក់ ។ ២ ប្រែថា តូច ។ ៣ ប្រែថា ធំ ។ ៤ ប្រែថា ឥសីទេវតា ។ ៥ ប្រែថា ឥសីតាមរបៀបព្រាហ្មណ៍ ។ ៦ ប្រែថា ឥសីក្នុងពួកក្សត្រ ។

"ញាតិសាច់ក្ដី មិត្រក្ដី ក្នុងពេលដែលមានគ្រោះថ្នាក់មកដល់ អ្នកសប្បុរស តែងខំប្រឹងខ្វល់ខ្វាយជួយដោយម៉ឺងម៉ាត់" វាចានេះហើយ ដែលលោកមនុប្បានពោលទុកមក ដូច្នេះចូរសំឡាញ់យកវត្ថុអ្វីមួយជាខ្សែយ៉ាងវែង ឬកំណាត់ឈើ ១ តូចជាដើម ហើយត្រូវនាំយើងទៅរកស្រះណាមួយដែលមានទឹកច្រើន ៗ

ឯយើងនឹងខាំត្រង់កណ្ដាលឈើនោះនឹងធ្មេញយើង សំឡាញ់ទាំងពីរពាំចុងកំណាត់ឈើម្ខាងម្នាក់ ហើយនាំយើងទៅកាន់ស្រះនោះ ៗ ទើបហង្សឆ្លើយឡើងថា "ឱ! សំឡាញ់ស្មើចិត្តអើយ! យើងនឹងធ្វើដូច្នោះក៏បាន ប៉ុន្តែសំឡាញ់ឯងសន្យាថា កុំនិយាយអ្វីឲ្យសោះទើបបាន តែហាមាត់និយាយហើយ មុខជាសំឡាញ់របូតជ្រុះពីបង្គង់ឈើមិនខាន ហើយសំឡាញ់នឹងខូចខ្លួនជាមិនខាន អណ្ដើកនិយាយឡើងថា ពិតដូចសំឡាញ់ទាំងពីរពោលមែន បើដូច្នេះ ខ្ញុំសុំធ្វើសន្យាថានឹងនៅស្ងៀមតាំងពីឥឡូវនេះទៅ ដរាបដល់ធ្វើដំណើរទៅតាមអាកាស ទាល់តែខ្ញុំបានដល់ទៅស្រះនោះ ៗ

'កាលព្រមព្រៀងគ្នាធ្វើដូច្នេះហើយ ទើបកម្ពុគ្រីវៈ ក្នុងពេលដែលធ្វើដំណើរទៅតាមអាកាសនោះ បានសង្កេតឃើញភូមិមួយនៅពីខាងក្រោម ៗ ពួកអ្នកស្រុកនៅភូមិនោះ បានឃើញដំណើរសត្វទាំង ៣ ដូច្នោះ ក៏និយាយឡោឡាឡើងដោយសេចក្ដីអស្ចារ្យៈ ហ:ហា! អ៊ុំទុះហ្ន៎!

មូលដូចគង់មានសត្វបក្សីពីរពាំនាំហើរទៅ! ឯកម្ពុជ្រី: កាលបើបានឮសំដីវែកញែករបស់អ្នកស្រុកដូច្នោះ ទ្រាំអត់មិនបាន ក៏និយាយចេញទៅថា "អើ! ចុះស្អីវែកញែកអ្វីហ្នឹង? អណ្តើកនេះគ្រាន់តែហាមាត់និយាយមិនទាន់បានពាក់កណ្តាលមាត់ ក៏របូតខ្លួនចុះចាកបង្គង់នុះមកបែកខ្ទេចជាបំណែកៗ កណ្តចំណោមអ្នកស្រុកនុះឯង ។

ហេតុដូច្នេះហើយ ទើបមានពាក្យពោលទុកមកថា: "នៅនាលោកយនេះ អ្នកឯណាមួយ ដែលមិនព្រមធ្វើតាមដម្បូន្មាន ដែលមានមេត្រីចិត្តស្មោះត្រង់ទេ នឹងវិនាសខ្លួនមិនខាន ដូចជាអណ្តើកខ្លៅ ដែលធ្លាក់ចុះពីបង្គង់ឈើដូច្នោះដែរ ។

(នៅមាននិទានដទៃ ៗ តទៅទៀត)

ពង្សាវតារស្រុករោម

វគ្គទី ៨

ផាមតាំងមហាអាណាចក្រ

កាលដែលសេសារស្លាប់ទៅនេះ ធ្វើឲ្យស្រុករោមកើតចលាចលវរវឹកឡើងយ៉ាងធំសំបើម ពួកដែលធ្វើការសម្លាប់សេសារគ្រានេះ មានសេចក្ដីតាំងចិត្តថា នឹងធ្វើស្រុករោមឲ្យប្រតិបត្តិតាមរបៀបចាស់ គឺមិនឲ្យធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់បុគ្គលម្នាក់ ។ ទើបពួកនេះនាំគ្នាសម្លាប់សេសារ លុះសម្លាប់ហើយក៏ចេញពីទីប្រជុំសេណាត៍ស្រែកប្រាប់ប្រជាជនទូទៅថា "ឥឡូវនេះប្រជាជនគ្រប់គ្នាមានឥស្សរភាពពេញទី មិនបាច់នៅក្រោមអំណាចរបស់បុគ្គលណាមួយទៀតឡើយ" តែពួកប្រជាជនមិនបាននាំគ្នាត្រេកអរ បែរជាទោមនស្សនឹកស្ដាយសេសារទៅវិញ ដោយនឹករលឹកដល់ម្ចាស់បុណ្យដ៏ក្សេមក្សាន្ត ដែលសេសារធ្លាប់ធ្វើមកនាំឲ្យពួកគេបានសេចក្ដីសុខសប្បាយជាច្រើន ទើបពួកនេះកើតទោមនស្សសៅសោកប្រាកដឃើញជាក់ស្ដែង ។ ឯសភាសេណាត៍ក៏នឹកឃើញស្ដាយក្រោយថា ការដែលសេសារត្រូវបង់ជីវិតទៅគ្រានេះ មិនមែនជាប្រយោជន៍ដល់សភានោះឡើយ ព្រោះក្នុងសម័យនោះ នៅស្រុករោម បើអ្នកឯណាមានកំឡាំងទាហាននៅក្នុងដៃ រមែងចង់បានអំណាចនៅក្នុងរោម

ហើយអ្នកណាមួយនឹងដណ្ដើមអំណាចនេះទៅគាត់ ក៏គ្មានអ្នកឯណាដឹងបានឡើយ ។ ការដែលសកាមានសេចក្ដីព្រួយបារម្ភនេះជាការត្រឹមត្រូវណាស់ ព្រោះតមកមិនយូរប៉ុន្មានអង់ត្វាន (Antoine) ធ្លាប់ធ្វើជានាយទាហានដ៏ក្លាហានមួយរបស់សេសារ មានមនុស្សគាប់ចិត្តច្រើន ទើបចាប់យកឱកាសនេះធ្វើខ្លួនឲ្យមានអំណាចឡើង ។ បុរសនេះឯងដឹងច្បាស់ថាប្រជាជនមានចិត្តស្រឡាញ់នឹងស្ដាយសេសារណាស់ ទើបនាំយកពន្ទីស្មើរបស់សេសារជាគ្រឿងផ្សាយអំណាចរបស់ខ្លួន ។ នៅថ្ងៃធ្វើបុណ្យសពសេសារអង់ត្វានជាអ្នកថាត់ថែង បានសូត្រសុន្ទរកថាក្នុងទីប្រជុំជនលើកសរសើរសេសារជាពន្ទឹក ទើបនាំឲ្យប្រជាជនកាន់តែនឹកសង្វេគស្ដុតចិត្តអាណិតនឹកស្ដាយសេសារកាន់តែខ្លាំងឡើង អង់ត្វានបានយកអាវផាយរបស់សេសារ ដែលប្រឡាក់ទៅដោយឈាមនឹងមានស្នាមត្រូវគេចាក់ដោយអាវុធ ២៨ អន្លើ លើកបង្ហាញឲ្យប្រជាជនមើល គ្រាន់តែប្រជាជនបានឃើញ ក៏មានចិត្តទោសោកើតឡើងពល់គ្នា រកសងសឹកអ្នកដែលធ្វើការឃាតកម្មសេសារមួយរំពេច ទាល់តែប្រ៊ូទុស ព្រមទាំងបក្ខពួករត់ចេញពីក្រុងរោមទៅ ។

ក្នុងវេលាដែលកំពុងចលាចលនេះ អុកតាវ (Octave) ដែលជាក្មួយនឹងជាកូនធម៌របស់សេសារ កំពុងសិក្សាវិជ្ជានៅក្រុងអាថែន្សនោះ លុះបានដំណឹងថា សេសារស្លាប់ក៏ប្រញាប់ចូលមកក្រុងរោមវិញ ដើម្បីទទួល

មរដករបស់ឪពុកធំ ៗ ក្នុងខណៈអុកតាវមានអាយុត្រឹម ១៩ ឆ្នាំ មាន រូបកាយតូច ពិការជើងហើយច្រើនមានរោគ និយាយសំដីមិនគ្រោះក្សាយ តាំងខ្លាចច្រើន ខ្លាចងងឹតនិងសូរផ្គរ តែជាមនុស្សប៉ិនប្រសប់ ៗ លុះមក ដល់ក៏និយាយលើកជើងជំរើសសភាសេណាត៍ ហៅស៊ីសេរ៉ុងថាឪពុក ចំណាយប្រាក់ចែកចាយពួកទាហានចាស់របស់សេសារ មិនយូរប៉ុន្មាន ក៏បានធ្វើជាអធិបតីនៃកងទ័ព ៗ ឯស៊ីសេរ៉ុងមានចិត្តនឿយណាយនឹង អំណាចរបស់អង់ត្វាននោះ ក៏និកស្មានថា នឹងបានអុកតាវជួយជាកំ-ឡាំង ដើម្បីផ្តាច់អំណាចរបស់អង់ត្វាន ៗ នៅវេលានោះ អង់ត្វានបាន ចេញពីក្រុងរ៉ូមទៅតាមចាប់ប្រ៊ូទុស ទើបស៊ីសេរ៉ុងប្រកាសកាត់ឈ្មោះ អង់ត្វានចេញពីអំណាចច្បាប់រ៉ូម ហើយតាំងអុកតាវជាមេទ័ពសម្រាប់ ចាត់ការប្រាបប្រាមអង់ត្វាន បើអង់ត្វានមកបង្កការចលាចលដល់ក្រុង រ៉ូម ៗ

ទើបអុកតាវប្តឹងសុំឲ្យតាំងខ្លួនជាកុងស៊ុលផង ខាងសភាសេណាត៍មិន យល់ព្រម ចួនជាអង់ត្វានដែលចេញទៅប្រាបប្រាមនោះ បានធ្វើស្ពាន មេត្រីនឹងរដ្ឋបាលប្រទេសគូលនឹងប្រទេសឥតាលី ហើយមានកងទ័ពមក ជាមួយផង ៗ ឯអ្នកទាំងពីរគឺអង់ត្វាននិងអុកតាវសឹងយល់ដឹងការច្បាស់ ថា ការគិតធ្វើការឲ្យបានផលប្រយោជន៍ដល់ខ្លួនឯងនោះ ត្រូវតែរួមកំ-ឡាំងគ្នាតទល់នឹងសភាសេណាត៍ ដែលជាពួកញុះញង់ឲ្យធ្វើការសម្លាប់

សេសារ មានបុរសម្នាក់ទៀត ជាមន្ត្រីធំត្រួតត្រាប្រទេសគូលមកចូល រួមជាមួយផង ឈ្មោះលេពីត (Lépide) បុរសទាំង ៣ នាក់នេះរួបរួមគ្នាជាគណៈមួយឡើង ហៅតាមប្រវត្តិសាស្ត្រថា ត្រៃយុមវិរ៉ាត់ទី ២ (Deuxième Triumvirat) ហើយបែងខេត្តដែនបែកគ្នាត្រួតត្រា ១ ភាគម្នាក់ ។ កិច្ចការដែលជនទាំង ៣ នាក់ចាប់ធ្វើជាដំបូង គឺតាមចាប់ប្រហារជីវិតពួកដែលសម្លាប់នឹងពួកដែលញុះញង់ឲ្យសម្លាប់សេសារអស់ចំនួនច្រើន ឯស៊ីសេរ៉ុងដែលអុកតាវធ្លាប់ហៅថាឪពុក ៗ នោះ ក៏ត្រូវចាប់យកទៅប្រហារជីវិតដែរ ។

លុះរៀបចំធ្វើដូច្នេះហើយ ទើបអុកតាវនឹងអង់តូានក៏នាំគ្នាឆ្លងសមុទ្រអាទ្រីយ៉ាទិកទៅតាមចាប់ប្រ៊ុទុស ដែលចេញទៅតាំងកងទាហានចាំទប់ទល់នៅក្នុងខេត្តម៉ាសេដ្វាន បានវាយកងទ័ពប្រ៊ុទុសបាក់បែកខ្ចាត់ខ្ចាយ ហើយប្រ៊ុទុសក៏សម្លាប់ខ្លួនឯង ក្នុងពុទ្ធសករាជ ៥០១ (មុន គ.ស. ៤២) ។

តអំពីនោះ អង់តូានក៏ចេញទៅប្រទេសអេស៊ីប្ត ដើម្បីប្រាប់ប្រាមប្រទេសអេស៊ីប្ត ដែលជាអ្នកជួយឲ្យកំឡាំងដល់ប្រ៊ុទុសក្នុងកាលដែលបានជួបនឹងព្រះនាងក្លេអូប៉ាត្រ (Cléopâte) ក៏ភ្លេចភ្លាំងកិច្ចការមុខក្រសួងរបស់ខ្លួនអស់លើង ទើបអុកតាវចេញធ្វើការតែម្នាក់ឯង ពោលគឺគោងទៅប្រាបប្រាមក្លូនប៉ុមប៉េដែលតាត់តាំងកងទ័ពជើងទឹកយ៉ាងរឹងប៉ឹង ហើយជាម្ចាស់សមុទ្រមេឌីទេរ៉ាណេ ។ ជ័យជំនះរបស់អុកតាវនេះ សម្រេចបាន

ដោយអាស្រ័យសម្លាញ់ខ្លួនម្នាក់ឈ្មោះអាគ្រិបប៉ា (Agrippa) ។ ឯលេពីត ដែលជាសម្លាញ់រួមគណៈជាមួយគ្នាក៏ប្រាកដជា បានធ្វើការជាប្រឹងដែរ តែមិនបានចេញមុខចេញមាត់ម៉ាំមួនទេ តែអុកតាវក៏មានសេចក្តីអរគុណ ទំនងដឹងគុណហើយតាំងឲ្យជាអ្នកសម្រេចកិច្ចការខាងសាសនា ។

តាំងអំពីនោះមក អ្នកដែលប្រណាំងប្រជែងដណ្តើមអំណាចគ្នាយ៉ាងមុឺងម៉ាត់ មានត្រឹម ២ នាក់ គឺអុកតាវនឹងអង់តូនតែពីរនាក់ប៉ុណ្ណោះ ។ ឯអង់តូននោះ កាលចេញពីប្រទេសអេស៊ីប្តទៅបានទៅច្បាំងនឹងពួកប៉ារ-ថីតែបរាជ័យ ត្រូវតែអង់តូនវិលចូលទៅក្រុងរោមវិញ បែរជាទៅរកព្រះនាងក្លេអូប៉ាត្រាទៀត ហើយគ្រានេះ អង់តូនក៏ធ្វើនកាន់តាំងនៅក្នុងអេស៊ីប្តហើយគិតតាំងអាណាចក្ររបស់ខ្លួនមួយឡើងនៅចំណែកទិសខាងកើតដោយឡែកទៅ ។ ឯអុកតាវក៏ព្យាយាមពន្យល់ឲ្យប្រជាជនយល់ថាអង់តូនជាមនុស្សក្បត់នឹងជាតិខ្លួន ទើបត្រូវធ្វើសង្គ្រាមប្រាបប្រាមអង់តូននឹងព្រះនាងក្លេអូប៉ាត្រ ។ អង់តូនលើកកងទ័ពជើងទឹកនឹងជើងគោកមកតាំងចាំទទួលនៅប្រទេសក្រិក ។ លុះកងទ័ពអេស៊ីប្តបរាជ័យហើយ ព្រះនាងក្លេអូប៉ាត្រនាំអង់តូនរត់ចូលមកប្រទេសអេស៊ីប្តវិញ ។ អុកតាវក៏ដេញតាមច្បាំងអង់តូនរហូតដល់ស្រុកអាលេក្សង់ឌ្រិ (Alexendrie) អង់តូនក៏ចាញ់គេទៀត ហើយត្រូវព្រះនាងក្លេអូប៉ាត្របញ្ឆោតឲ្យផឹកថ្នាំបំពុលស្លាប់ទៅ ដូចមានសំដែងក្នុងពង្សាវតារប្រទេសអេស៊ីប្តនោះស្រាប់ ហេតុនេះហើយ

ដែលនាំឲ្យអុកតាវបានធ្វើជានាយចៅហ្វាយក្រុងរ៉ូមតែម្នាក់ឯង ហើយតាំងអំពីនោះមក រេពុយព្លិកក្រុងរ៉ូមក៏ផុតរលត់ត្រឹមប៉ុណ្ណឹង គឺរបៀបត្រួតត្រាក្រុងរ៉ូម បានផ្លាស់ប្តូរជារបៀបរាជាធិបតេយ្យ ក្នុងពុទ្ធសករាជ ៥១២ ។

សម័យក្សត្រអាជ្ញាសិទ្ធិរាជ្យ

តាមដោយពិត ការផ្លាស់ប្តូរត្រួតត្រាស្រុក ពីរបៀបរេពុយព្លិកមកជារបៀបរាជាធិបតេយ្យនេះ គឺអុកតាវ (កាលបានប្រកាសខ្លួនជាក្សត្រឡើងហើយ ក៏តាំងឈ្មោះខ្លួនថា អូគុស្តសេសារ(១)) បានធ្វើជាធំមានអំណាចយ៉ាងសំបើមនៅក្រុងរ៉ូម ប៉ុន្តែរបៀបត្រួតត្រាក្រុងរ៉ូមមិនបានប្រែប្រួលយ៉ាងណាឡើយ ទាំងសភាប្រស្ដង់និងសភាសេណាតក៏គង់មាននៅជាធម្ម ថែមទាំងបានតាំងកុងស៊ុលឡើងវិញទៀតផង ។ ព្រះបាទអូគុស្តសេសារទ្រង់បានឃើញគ្រប់យ៉ាងមកហើយថា ការតាំងខ្លួនជាឌិកតាទ័រនៃក្រុងរ៉ូមនេះឲ្យទោសច្រើនជាពន្ទឹក ហេតុនេះទើបទ្រង់ប្រគល់អំណាចឲ្យសភាផ្សេងៗកាន់កាប់រក្សាតាមដើម តែមិនបានទ្រង់បណ្តោយ

---

១ ពាក្យថា សេសារនេះ ពីដើមមកជាឈ្មោះរបស់មហាបុរសម្នាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញដូចបានពោលរួចមកហើយ តមកគ្រាក្រោយទើបសំដៅសេចក្តីថា ព្រះចៅផែនដី តែក្រុងរ៉ូមគ្រានោះគួរហៅស្តេចក្រុងរ៉ូមថា "ព្រះចៅផែនដី ឬព្រះរាជា" ប្រែជាហៅថា សេសារ តមករុស្ស៊ីតាំងពោះប្រែហៅថា "សារ៍" អាល្លឺម៉ង់យកពោះប្រើថាកៃសារ (ឬកៃស៊ែរ) ។

ឲ្យពួកអស់នោះ ទុកទ្រង់ព្រះអង្គជាដុំថ្មអ្នកតាទេ គឺនៅតែក្តាប់អំណាចផ្សេងៗ មកទុកក្នុងព្រះហស្តព្រះអង្គ ពោលគឺទ្រង់ជាសមាជិកម្នាក់របស់សភាកស្រ្ត ទ្រង់ជាអ្នកបញ្ជាការកងទ័ព ទ្រង់ជាអ្នកឧបត្ថម្ភសាសនា, នឹងទ្រង់ជានាយកនៃសភាសេណាត៍ ទ្រង់សំដែងសុទ្ធតែជាក្នុងទីប្រជុំសេណាត៍ដូចជាសមាជិកសភា ទ្រង់បោះឆ្នោតក្នុងសភាកស្រ្តដូចជាកស្រ្តដែរ ៗ វិធីនេះជាវិធីឆ្លាតបំផុត ព្រោះទ្រង់រួបរួមក្រុងរោមទាំងមូលមកទុកក្នុងព្រះហស្តបាន ឥតនរណាដឹងខ្លួនថាទ្រង់ធ្វើដូច្នោះឡើយ ឯសភាទាំងពីរនឹងធ្វើការអ្វីឲ្យលើសពីព្រះបំណងរបស់ទ្រង់ទៅពុំបានឡើយ ហេតុនេះទើបគួរនឹងពោលថា ព្រះបាទអូគុស្តុសេសារជាមហាក្សត្រ ១ អង្គ ដែលទ្រង់ធ្វើឲ្យប្រជាជនយល់ថាទ្រង់ជាក្សត្រឥតអំណាចពេញសក្តិអ្វីឡើយ តែការពិតទ្រង់ជាក្សត្រអាជ្ញាសិទ្ធិភព្យ ៗ

អំពីក្រុងរោមក្រោមអំណាចមហាក្សត្រអូគុស្ត

តាំងពីតាំងជាពេជអាណាចក្រឡើង ក្រុងរោមក៏មានសេចក្តីចំរើនឡើងច្រើន ទាំងប្រាសាទពេជស្ពាន ទាំងអក្សរសាស្ត្រហើយបានកើតសាងជាវិវត្តសំខាន់ៗ ឡើងជាច្រើន មានពួកអ្នកប្រាជ្ញសំខាន់ៗកើតឡើងដូចជាមេសែន (Mécène) ជាអ្នកប្រាជ្ញអក្សរសាស្ត្រ ទីត-លីវ អ្នកប្រាជ្ញពង្សាវតារ (Tite-Live) នឹងអ្នកប្រាជ្ញខាងចិន្តកវី មានវែស៊ីល, ហូរ៉ាស៍

(Vigile et Horace) ជាដើម ជាគ្រឿងប្រដាប់កិត្តិយសរបស់មហាក្សត្រ ។ ចំណែកខាងប្រជារាស្ត្រក៏ប្រកបដោយសេចក្ដីសុខសប្បាយ ប្រហែលសម័យស៊ីលសេសារដែរ ។

ព្រះបាទអូគុស្តស៍សេសារ មិនមានព្រះរាជឱរស ទើបទ្រង់តាំងកូនរបស់អាគ្រីបប៉ា ដែលជាសំឡាញ់ស្មោះស្ម័គ្ររបស់ទ្រង់ ក្នុងខណៈដែលច្បាំងនឹងអង់ត្វាន នោះឲ្យឡើងទៅជារជ្ជទាយាទ (សឹបករាជសម្បត្តិ) តែកូនរបស់អាគ្រីបប៉ាអនិច្ចកម្មទៅមុន ទើបទ្រង់ប្រគល់ដំណែងនេះដល់ទីបែរ ដែលជាកូនចិញ្ចឹមរបស់ព្រះអង្គ គឺជាកូនរបស់ព្រះជាយាដែលជាប់មកពីប្ដីចាស់ ។ ព្រះបាទអូគុស្តស៍សេសារមានព្រះជន្មាយុ ៧៦ វស្សា ទើបទ្រង់ទិវង្គតទៅ ក្នុងពុទ្ធសករាជ ៥៥៧ (ក្រោយ គ.ស. ១៤ ឆ្នាំ) ។ ក្នុងពេលរៀបពិធីសពរបស់ទ្រង់ មិនបានដុតបូជាដូចសម័យបុរាណទេ គឺគេយកទៅកប់ទុក ។

រាជបល្ល័ង្កក្រុងរោមបានមកដល់ទីបែរដោយរៀបរយ ទាំងប្រជាជនក៏ពេញចិត្តនឹងរបៀបត្រួតត្រាបែបនេះ ព្រោះតាំងពីចាប់ធ្វើការគាមកជាធិបតេយ្យឡើងកាលណា ក្រុងរោមក៏ស្ងប់ស្ងាត់រៀបរយ ហើយប្រជាជនគ្រប់ជាន់ក៏ធូរស្រួលសប្បាយឡើងជាងកាលពីមុន ។ ឯព្រះបាទទីបែរក៏ទ្រង់បន្ថយអំណាចរបស់ទ្រង់ ឲ្យតូចជាងព្រះបាទអូគុស្តស៍សេសារទៅទៀត

គឺត្រាន់តែទទួលដំណែងជាអធិបតីនៃសភាសេណាត៍ប៉ុណ្ណោះ ឯដំណែងដទៃៗទៀតទ្រង់តាំងអ្នកដទៃទៀតជំនួសទាំងអស់ ។ ដ្បិតទីបេរនេះចូលមកទទួលរាជសម្បត្តិ ក្នុងវេលាទ្រង់មានព្រះជន្មដល់ ៥០ វស្សាហើយ ទើបទ្រង់មិនប្រាថ្នាបុណ្យអំណាចរាជសក្តិយ៉ាងធំទេ ទីបេរជាក្សត្រទ្រង់ប្រកបដោយយុត្តិធម៌ ១ តែតមកក្រោយមានព្រះសតិមិនប្រក្រតី ក្លាយទៅជាមនុស្សពោរសោច្រើន បានសម្លាប់មនុស្សជាចំនួនច្រើនណាស់ ទីបេរទ្រង់ទិវង្គតទៅក្នុងពុទ្ធសករាជ ៥៨០ (គ.ស. ៣៧) ។

អ្នកដែលទទួលរាជសម្បត្តិជាបន្ទាប់មក ឈ្មោះកាលីគុឡា (Caligula) ។ ដំបូងជាក្សត្រទទ្រង់យុត្តិធម៌ល្អ តែច្រើនមានអាពាធប្រចាំកាយហើយក្លាយទៅជាឆ្កួត ចាយវាយប្រាក់កាសខ្ជះខ្ជាយ ដូចជាឲ្យយកគោមជាចំនួនច្រើនទៅអុជបំភ្លឺលេងលើខ្នងភ្នំ ធ្វើការផាវដូចជាក្មេងមិនទាន់លែងដោះ ដូចជាតាំងឲ្យសេះរបស់ខ្លួនធ្វើជាកុងស៊ុលជាដើម ។ លុះតមកទើបពួកទាហានរួបរួមគ្នាតាំងមនុស្សម្នាក់ឡើង ឲ្យឡើងសោយរាជឈ្មោះក្លោត (Claude) គេទុកជាក្សត្រអន្តដំបូងដែលពួកទាហានតាំងឡើង ក្សត្រថ្មីនេះមិនមានចំណេះចេះដឹងមាំមួនទេ បានរៀបមង្គលការនឹងស្ត្រីមេម៉ាយម្នាក់ឈ្មោះអាគ្រីពីណា (Agrippina) មានកូនជាប់មកពីប្តីចាស់ម្នាក់ផង ។ តមកព្រះនាងអាគ្រីពីណា លបដាក់ថ្នាំពុលសម្លាប់ព្រះរាជស្វាមី គឺព្រះបាទក្លោតបង់ទៅ ដើម្បីឲ្យកូនរបស់ព្រះនាងឡើង

សោយរាជ្យ ហើយខ្លួនព្រះនាងជាអ្នកសម្រេចរាជការផែនដី ។ បុត្ររបស់ព្រះនាងអាគ្រីពីណា នេះ ឈ្មោះនេរ៉ុង (Néron) ជាក្សត្រមានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុតមួយរបស់ក្រុងរោម តែជាកេរ្តិ៍ឈ្មោះខាងអាក្រក់ ។

កាលព្រះបាទនេរ៉ុងឡើងសោយរាជ្យនោះ ទ្រង់មានព្រះជន្មត្រឹម ១៧ វស្សា ព្រះនាងអាគ្រីពីណា ជាអ្នកសម្រេចរាជការ មានអ្នកប្រាជ្ញម្នាក់ឈ្មោះសេណែក (Sénèque) ជាអ្នកជំនួយនឹងប៊ុររុស (Burrhus) ជាមេទ័ព ។ លុះនេរ៉ុងធំឡើង មិនព្រមឲ្យព្រះជននីជួយសម្រេចរាជការតទៅទៀត ថែមទាំងរកឧបាយសម្លាប់ម្ដាយខ្លួនបង់ទៅផង គឺដំបូងឲ្យយកព្រះជននីទៅបោះចោលក្នុងសមុទ្រទៅ តែព្រះជននីមិនស្លាប់បានទាំហែលទឹករស់រួចជីវិតមកបាន ទើបនេរ៉ុងទ្រង់បង្គាប់ឲ្យមនុស្សទៅចាប់ច្របាច់កសម្លាប់ទៅ ទុកជាបាបធំបំផុតដែលនេរ៉ុងបង្គាប់ឲ្យធ្វើនេះ នេរ៉ុងនៅតែប្រព្រឹត្តអាក្រក់សាហាវតទៅទៀត គឺឲ្យចាប់ព្រះអគ្គជាយារបស់ទ្រង់យកទៅសម្លាប់ ហើយប្រព្រឹត្តបទអាក្រក់ផ្សេងៗ ជាមនុស្សស្រវឹងខ្លួប ដើរលេងល្ខោនផ្ដេសផ្ដាសក្នុងទីប្រជុំជន ដែលកស្ត្រប្រកាន់ថាជាអំពើថោកទាបបំផុត ។ ក្នុងរជ្ជសម័យនៃក្សត្រនេះ កើតភ្លើងឆេះក្រុងរោម ១ គ្រាយ៉ាងធំ មានពាក្យចំណាលថា នេរ៉ុងជាអ្នកបង្គាប់ឲ្យដុត ដើម្បីបំផ្លាញពួកអ្នកកាន់សាសនាគ្រិស្ត ដែលទើបកើតឡើងនៅក្រុងរោម ។

នេរ៉ុងប្រព្រឹត្តអាក្រក់សាហាវបែបនេះជាវេលា ១៣ ឆ្នាំ ទៅទីបំផុត ពួកទាហានផ្សេងៗ ដែលនៅក្រៅក្រុងរ៉ូមនាំគ្នាបះបោរឡើង នេរ៉ុងរត់ចេញទៅនៅស្រុក ១ ហើយធ្វើអត្តវិនិបាតកម្ម (សម្លាប់ខ្លួនឯង) ក្នុងពុទ្ធ-សករាជ ៦១១ (គ.ស. ៦៣) ។

កប់តាំងអំពីសម័យនេរ៉ុងតទៅទៀត ជាវេលា ១៤២ឆ្នាំមានក្សត្រគ្រងរាជ្យជាដំណតគ្នាជាច្រើនអង្គ ហើយក្រុងរ៉ូមសម័យនេះ ក៏ប្រែប្រួលផ្លាស់ប្តូរប្លែកជាងសម័យបុរាណជាច្រើន ពោលគឺជាស្រុកគិតតែខាងការសប្បាយរីករាយ ដើរលេងស៊ើបកំសាន្តនឹងចាយវាយខ្ជះខ្ជាយ ក្នុងវេលា ១ ឆ្នាំ ក្រុងរ៉ូមមានថ្ងៃធ្វើបុណ្យដល់ទៅ ១៧៥ថ្ងៃ (ស្ទើរតែក្នុង ២ ថ្ងៃមានថ្ងៃធ្វើបុណ្យ ១ ថ្ងៃ សុទ្ធតែជាថ្ងៃដែលពួករ៉ូមាំងធ្វើបុណ្យសម្ពោធផ្សេងៗ) ក្រុងរ៉ូមមានមន្ទីរល្ខោន ១ ធំសំបើម ចុះមនុស្សអ្នកមើលជាចំនួន ៣០០.០០០ នាក់ ល្បែងដែលគេនិយមណាស់ក្នុងគ្រានោះគឺការងូតទឹក សឹងមានរូបតំនួរតមកដល់ឥឡូវនេះ បន្ទប់ងូតទឹកជាបន្ទប់ធំសំបើមអស្ចារ្យ មានភ្លើងបង្កាត់ទុកពីខាងក្រោមសម្រាប់កំដៅបន្ទប់នឹងទឹក មានកន្លែងទាំងទប់ទឹកសម្រាប់ឲ្យមនុស្សទាំងឡាយស្រាតចុះងូតជាមួយគ្នាមិនបាច់មានអៀនខ្មាសគ្នាទេ ពួករ៉ូមាំងគិតតែនាំគ្នាស្វែងរកសេចក្តីក្សេមក្សាន្តគ្រប់យ៉ាង ដើម្បីឲ្យមានសំរេចខាងកាមគុណ

ការស្រើបស្រាលនេះហើយដែលធ្វើឲ្យជាតិរ៉ូម៉ាំងធ្លាប់ជាមហាអំណាចមកនោះ ត្រូវតែសាបសូន្យថយខ្សោយអំណាចទៅវិញ ។

ចាប់តាំងអំពីព្រះបាទអូគុស្តសេសារ កាលពីពុទ្ធសករាជ ៨១២ រហូតមកដល់ពុទ្ធសករាជ ៧៣៨ មានស្តេចល្អៗ ចំនួន ៥ អង្គ ដែលសមគួរលើកទុកនៅទីនេះ ២ អង្គគឺព្រះបាទត្រាសង់ (Trajan) ដែលទ្រង់ធ្វើការផ្សេងៗ ដែលជាប្រយោជន៍ដល់សាធារណជន ដូចជាចាត់ការទំនុកបំរុងពាណិជ្ជកម្ម ក្សេត្រកម្ម, របនាទីងអក្សរសាស្ត្រឲ្យចំរើនឡើង ហើយជាក្សត្រអង្គដំបូងដែលទ្រង់រៀបចំក្រសួងពន្ធការសម្រាប់ជួយទំនុកបំរុងក្មេងកំព្រាទីទាល់ក្រ ក្សត្រអង្គនេះគេរាប់ថា ទ្រង់មានព្រះទ័យសប្បុរសល្អជាបំផុត ទាល់តែមានទំនៀមតមកក្រោយៗ កាលបើមានក្សត្រឡើងសោយរាជសម្បត្តិ សភាសេណាត់រៀបចំធ្វើពិធីថ្វាយព្រះពរជ័យនិងថ្វាយឧវាទដល់ក្សត្រអង្គថ្មីថា "សូមឲ្យទ្រង់ប្រកបដោយសេចក្តីសុខសម្រាន្ត ក្រៃលែងជាងព្រះបាទអូគុស្តសេសារ និងសូមឲ្យទ្រង់ប្រកបដោយកុសលវត្តយ៉ាងប្រសើរក្រៃលែងជាងព្រះបាទត្រាសង់" ។ ព្រះបាទត្រាសង់ទិវង្គតក្នុងពុទ្ធសករាជ ៦៦០ (គ.ស. ១១៧) ។

ឯក្សត្រ ១ អង្គទៀត គឺព្រះបាទម៉ារ-អូរ៉ែល (Mare-Aurèle) ជាអ្នកប្រាជ្ញ និងទ្រង់ឧបត្ថម្ភក៍ពួកខ្ញុំ (ទាសា - ទាសី) និងទ្រង់ចាត់តាំងស្ថានកុសលឡើងជាចំនួនច្រើន ពួកគ្រិស្តាំងមានសេចក្តីសរសើរក្សត្រអង្គ

នេះប្រែថា ដ្បិតទ្រង់ជាក្សត្រដំបូង ដែលទ្រង់ទំនុកបំរុងនឹងជួយផ្សាយលទ្ធិសាសនានេះ ។

ក្រៅពីក្សត្រពីរអង្គនេះ ក៏មានក្សត្រអង្គខ្លះ ដែលទ្រង់ធ្វើសេចក្តីល្អជាដំណាតមកក៏មាន ក្សត្រអង្គខ្លះធ្វើផ្តេសផ្តាសឆ្កួតវង្វេងដូចយ៉ាងនេះក៏មាន ។ តាំងអំពីព្រះបាទម៉ារ-អូរ៉ែលទិវង្គតទៅ គ.ស. ១៧៨ ក្រុងរោមចាប់ផ្តើមទ្រុឌទ្រោមអាប់ឱន មានព្រះរាជឱរសទទួលរាជសម្បត្តិជាដំណាតមក ទ្រង់ព្រះនាម កុមម៉ោត (Commode) តែត្រូវគេធ្វើគុត ក្នុងពុទ្ធ-សករាជ ៧៣៥ (គ.ស. ១៩២ ។

ភូមិសាស្ត្រនានាប្រទេស

ប្រទេសអាមេរិកខាងត្បូង

ខ្នាតប្រទេស – បណ្ដោយវែងបំផុត ៧,៣៤៣ គីឡូម៉ែត្រ ទទឹងធំបំផុត៤,៨៦១ គីឡូម៉ែត្រ ។ ទំហំដីទាំងមូលប្រមាណ ១៧,៧៤៨,៣៦០ គីឡូម៉ែត្រក្រឡា ។

ផ្ទៃផែនដី – ប្រហែលប្រទេសអាមេរិកខាងជើង មានជួរភ្នំធំមហិមាដែលជាភ្នំមានខ្នាតវែងបំផុតក្នុងលោក ហៅថាករឌីយែរដេសង់ដ៍ (វែងជាង៦,៤០០ គីឡូម៉ែត្រ) តាំងនៅលើដីកបខ្ពស់ទិសខាងលិច ហើយខាងកើតមានដីកបក់លយ៉ាងធំទូលាយនៅកណ្ដាលប្រទេស ។ ខាងមាត់ច្រាំងសមុទ្រត្រើយខាងកើត មានជួរភ្នំតូចៗ ជាច្រើនតាំងនៅលើដីកបខ្ពស់ បន្ទាប់ពីភ្នំអស់នោះទៅជាទីទំនាបទល់នឹងមហាសមុទ្រអត្លង់ទិក ។

ភ្នំ – កំពូលភ្នំដែលខ្ពស់បំផុតក្នុងទ្វីបនេះ មាននៅក្នុងប្រទេសស៊ីលី មានកំពស់ ៦,៨៦០ ម៉ែត្រ ក្នុងប្រទេសប្រេស៊ីល មានភ្នំជាច្រើនត្រង់ភាគកណ្ដាល នឹងភាគខាងកើត ។

ទីដីកប – មានច្រើនអន្លើហៅឈ្មោះផ្សេងៗ គឺ:

១ – ឡាណូស ជាទីកបនៅដងទន្លេអូរេនោក៍

២ – ស៊ែល្វាស – ជាទីដីកបនៅដងទន្លេ អាម៉ាស៊ូន ទីកបនេះមានព្រៃព្រឹក្សាជាច្រើន ។

៣- ក្រង់សាគូ ជាទីដីរបាយខ្សាច់ នៅចន្លោះបោលីវីប៉ារ៉ាក្វ័យ នឹង អាសង់ទីន មិនសូវមានរុក្ខជាតិដុះលូតលាស់ល្អទេ ។

៤- ប៉ម្ប៉ា ជាវាលស្មៅយ៉ាងធំ ជាទីចិញ្ចឹមសត្វធ្វើស្រែនៅចន្លោះ ក្នុងអាងទន្លេប៉ារ៉ាណា ។

៥- សមុទ្រគ្រួស នៅក្នុងដែនប៉ាតាហ្គូនី ភាគខាងត្បូងស្រុកអាសង់ទីនមិនសូវមានមនុស្សនៅ មិនសូវមានភ្លៀងធ្លាក់ផង ។

៦- សមុទ្រខ្សាច់ នៅក្នុងប្រទេសស៊ីលី តំបន់នេះស្ទើរតែមិនមានភ្លៀងធ្លាក់សោះឡើយ មិនមានរុក្ខជាតិដុះទេ ។

ទន្លេ — ទន្លេវែងៗ ក្នុងអាមេរិកខាងក្រោមនោះ សុទ្ធតែហូរធ្លាក់ទៅក្នុងសមុទ្រទិសខាងកើតទាំងអស់ ឯទន្លេសំខាន់ៗនេះមាន ៤ អន្លើ គឺ:

១ អាម៉ាសូន ដើមទឹកកើតពីភ្នំ ហូរធ្លាក់ទៅក្នុងមហាសមុទ្រអត្លង់ទិកក្នុងប្រទេសប្រេស៊ីល ទន្លេនេះបណ្ដោយវែងណាស់ ប្រមាណ ៦,១៦៦ គីឡូម៉ែត្រ មានដៃទន្លេជាង ២០០ អន្លើ ហូរធ្លាក់ចុះទៅក្នុងទន្លេ ។ នេះជាទន្លេធំបំផុតក្នុងលោក មានខ្នាតវែងជាទី ២ ក្នុងលោក មានកប៉ាល់តូច-ធំចេញចូលបានរហូត តាំងពីមាត់ទន្លេរហូតដល់ប្រទេសប៉េរូ ។

២- ប៉ារ៉ាណា ជាទន្លេមានខ្នាតវែងទី ២ ក្នុងអាមេរិកខាងត្បូងឬខាងក្រោមប្រមាណ ២,៦៨០ គីឡូម៉ែត្រ ។

៣ អូរេនោក៏ ខ្នាតវែង ២,២៤០ គីឡូម៉ែត្រ ហូរកាត់ប្រទេស វេនេស៊ុអេឡា ។

៤ សង់ហ្វ្រង់ស៊ិស្កូ ខ្នាតវែង ១,៦០០ គីឡូម៉ែត្រ នៅក្នុងប្រទេស ប្រេស៊ីល ។

អាកាស — ទ្វីបអាមេរិកខាងក្រោមមានផែនដីជាប់នឹងតំបន់មាន អាកាសក្តៅដល់ទៅ ២ ភាគក្នុង ៣ ភាគ ហើយមានអាកាសក្តៅច្រើន វៀរលែងតែទីកបខ្ពស់ទិសខាងលិចក្នុងប្រទេសស៊ីលី នឹងអាសង់ទីន ហើយ មានអាកាសអ៊ុនល្អ ។

ភ្លៀង — ខ្យល់ធំនៅទិសខាងកើតឆៀងខាងត្បូងជាខ្យល់បក់យក ទឹកភ្លៀងអំពីសមុទ្រអត្លង់ទិក ឲ្យមកធ្លាក់នៅក្នុងទ្វីបអាមេរិកខាងត្បូង ។ ភ្លៀងនេះច្រើនធ្លាក់នៅតាមភ្នំ នឹងទីកបខ្ពស់ ក្នុងប្រទេសប្រេស៊ីល នឹងក្នុងប្រទេសគុយយ៉ាន នឹងក្នុងវេនេស៊ុអេឡា ។ មិនសូវមានភ្លៀង ធ្លាក់នៅកណ្តាលទ្វីបទេ នៅចំណែកខាងមហាសមុទ្រប៉ាស៊ីហ្វិក ភ្លៀង ក៏ជាប់នៅត្រឹមជួរភ្នំករឌីល្លាដេសង់ដ៍អស់ ធ្វើឲ្យផែនដីកណ្តាលមិនសូវ មានភ្លៀងសោះឡើយ ។

ដំណាំ — ដំណាំសំខាន់ដែលដាំច្រើន គឺកៅស៊ូ, កាហ្វេ, អំពៅ, ថ្នាំជក់, កាកាវ, គ្រឿងទេស, កប្បាស, ត្រី, ស្រូវផ្សេងៗ ។

សត្វ — សត្វព្រៃ មានស្វា, ប្រមា, ខ្លាខ្មៅ, ខ្លាឃ្មុំ, ពស់ផ្សេងៗ សេក, សារិកា, ត្មាត, ។ល។ សត្វស្រុក មានសេះ កែះ គោ, និងឡាម៉ា

លោហធាតុ — មានបរិបូណ៌ទួទៅ តែមិនសូវមានអ្នកដឹកយកមកប្រើការទេ លោហធាតុដែលរកបានច្រើន គឺ ពេជ្រ, ចន់ដែក ។

ប្រជាជន — ប្រមាណ ៨៣,៤៣១,៥០០នាក់ ច្រើនតែជាពួកឥណ្ឌៀនឹងពួកមិទីហ្ស (ពួកកូនកាត់អាពុកជាជាតិខុរុបម្តាយជាអ្នកស្រុក) ក្រៅពីនេះជាពួកអេស្ប៉ាញល, ព័រទុគេស, នែគ្រ៍ ។

ឯជាតិដែលមកពីប្រទេសដទៃមកនៅរកស៊ី មានជាតិអាល្លឺមង់, ជប៉ុន, ឥតាលី, និងអង់គ្លេសជាច្រើន ។ ជនអស់នោះច្រើនតែកាន់លទ្ធិសាសនាកាតូលិក ។ ភាសាអេស្ប៉ាញលជាភាសាកណ្តាលរបស់ពួកទ្វីបអាមេរិកខាងក្រោម តែពួកប្រេស៊ីលប្រើភាសាព័រទុគេស ។

ឯប្រទេសផ្សេងៗ នៅក្នុងទ្វីបអាមេរិក ខាងក្រោមនេះ មានប្រទេសរេពុយព្លីក ១០ ប្រទេសនឹងដែន ៣ ដែន ដែលជាចំណុះប្រទេសឯទៀតៗ ដូចមានរាយឈ្មោះខាងក្រោមនេះ គឺ:

ប្រទេស	ទំហំដី	ចំនួនមនុស្ស	ទីក្រុង
ប្រេស៊ីល	៨.៥៥០.០០០ក.ម.	៨៦.០១០.០០០	រីអូដឺស័នេរ៉ូ
អាសង់ទីន	៣.០០០.០០០ "	២២.៥០០.០០០	ប៊ុយណូសអៃរ៉ុស

ប្រទេស	ទំហំដី	ចំនួនមនុស្ស	ទីក្រុង
ស៊ីលី	៧៤១.៦៥០ ក.ម.	៤.៣០០.០០០	សង្ទីអាកូ
ប៉េរូ	១.២៤៩.០០០ "	៦.២០០.០០០	លីម៉ា
បូលីវី	១.៥៦៩.១០០ "	៣.០៦៦.៩០០	ស៊ុក្រេ
កូឡុំប៊ី	១.៤៦១.៧៩០ "	៩.០០០.០០០	ប៉ោកូតា
វ៉េនេស៊ុយអេឡា	៩៤២.០០០ "	៣.២៦២.០០	កាក៉ាស
អេក្វាទ័រ	៤៤៣.៧៤០ "	២.៦០០.០០០	គីតូ
ប៉ារ៉ាក៉ួយ	១៥៩.៨៣០ "	៨៧០.២០០	អាស៊ុំស្យុង
ឧរុក៉ួយ	១៨៧.០០០ "	២.០២ .៩៤០	ម៉ុងតេវីដេអូ
គុយយ៉ាន (អង់គ្លេស)	២៣១.៧៥០ "	៣១២.៥១.	សិកតូហ៊្វ
គុយយ៉ាន (ហុល្លង់)	១៤០.៦១១ "	១៧០.០០០	ប៉ារ៉ាម៉ារិបូ
គុយយ៉ាន (បារាំងសែស)	៨៩.៩៧០ "	៤៧.៥០០	កាយ៉ែន

ភូមិសាស្ត្រសង្ខេប

ប្រទេសប្រេស៊ីល

ខ្នាត — ប្រេស៊ីលជាប្រទេសដែលមានខ្នាតធំ ជាងប្រទេសដទៃៗ ទាំងអស់ ក្នុងទ្វីបអាមេរិកខាងក្រោម មានទំហំដីធំជាងសហរដ្ឋអាមេរិក ដល់ ៨ សែនគីឡូម៉ែត្រក្រឡា ។

អាកាស — ឧណ្ហភូមិមធ្យមនៅក្នុងចន្លោះ ៦៣° ដល់ ៧៩° ។ មានភ្លៀងធ្លាក់ច្រើន (ពី ១២៧០-២៥៤០ មិល្លីម៉ែត្រ ។

ដំណាំ — កាហ្វេ (ច្រើនបំផុតក្នុងលោក) កាកាវ (ជាទី ២ ក្នុងលោក), កៅស៊ូ, អំពៅ, ពោត, ស្រូវ, ថ្នាំជក់, កប្បាស, ដំឡូង, ទំពាំងបាយជូរ, និងឈើផ្សេងៗ ។

សត្វ — ចំនួនសត្វក្នុង ព.ស. ២៤៧៥ មានដូចនេះ: គោ ៤២ លាន ជ្រូកប្រមាណ ២១ លាន, កែះ ១០ លាន សេះ ៦ លាន ពពែ ៥ លាន លានិងលជាង ២ លាន ។

ជ្រិក — មាននៅក្នុងប្រទេសប្រេស៊ីល មានច្រើនជាងប្រទេសឯទៀតៗ ទាំងអស់ ក្នុងទ្វីបអាមេរិកក្រោម ។

លោហធាតុ — ប្រេស៊ីលមានពេជ្រត្បូង, មាសនិងដែកយ៉ាងបរិបូណ៌ ម៉ង់កាណែសជាលោហធាតុសំខាន់បំផុត ។

ជំនួញលក់ចេញ — កៅស៊ូជាជំនួញដែលលក់ចេញមានដំឡៃច្រើនបំផុត ជំនួញសំខាន់ម្យ៉ាងទៀត គឺកាហ្វេ មានចំនួនដល់៦៩% នៃជំនួញកាហ្វេ ក្នុងលោក ។ ជំនួញបន្ទាប់មក គឺ កាកាវ, សាច់សត្វ, កៃ, ស្ករ, ថ្នាំជក់, កប្បាស, ស្បែកសត្វ, ឈើ, ពេជ្រ, មាស, និងខ្លាញ់គោ ។

ប្រទេសប្រេស៊ីល — ធ្វើជំនួញនឹងសហរដ្ឋអាមេរិក, អង់គ្លេស, អាល្លឺម៉ង់, បារាំងសែស ។

ជំនួញលក់ចូល — សំពត់អម្បោះ, គ្រឿងដែក, គ្រឿងម៉ាស៊ីន, សំពត់រោមសត្វ, ធ្យូងថ្ម, គ្រឿងធ្វើពីស្បែក ។

ផ្លូវគមនាគម — មានផ្លូវរថភ្លើង ៣៥,៦៤៦ គីឡូម៉ែត្រ (ព.ស. ២៤៧៦) ថ្នល់វែង ២១,៣២៨ គីឡូម៉ែត្រ ។

របៀបត្រួតត្រាស្រុក — មានប្រធានាធិបតីជាអ្នកប្រើអំណាចត្រួតត្រារួមជាមួយនឹងគណៈរដ្ឋមន្ត្រី ។ រដ្ឋសភាដែលប្រកបដោយសភាជាន់ខ្ពស់ និងសភាតំណាងរាស្ត្រ ជាអ្នកបញ្ញត្តិច្បាប់ ឯសមាជិកនៃសភាទាំងពីរនោះនៅក្នុងដំណែងម្នាក់ ៤ ឆ្នាំ ប្រហែលនឹងប្រធានាធិបតី ។ ពុយពឹកប្រេស៊ីលនេះធ្វើតាមរបៀប សហរដ្ឋអាមេរិក ប្រទេសនេះប្រកបដោយរដ្ឋផ្សេងៗ រួម ២០ រដ្ឋ រដ្ឋអស់នេះមានរដ្ឋសភានិងរដ្ឋបាលរបស់ខ្លួនឯង ដោយបណ្តារាស្ត្រជ្រើសតាំងឡើង បណ្តារាស្ត្រទាំងប្រុសទាំងស្រីដែលមានអាយុតាំងពី ១៨ ឆ្នាំឡើងទៅមានអំណាចបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងប្រធានាធិបតី ។

ទីក្រុងសំខាន់ៗ — រីអូដឺសាណេរ៉ូ ជាទីក្រុងនិងជាស្រុកសំខាន់បំផុត ហើយជាស្រុកល្អបំផុតនៅទ្វីបអាមេរិកខាងត្បូង មានចំនួនមនុស្ស ១.៤៦៨.៧០០ នាក់ ។ កាហ្វេលក់ចេញអំពីស្រុកនេះច្រើន ។ សង់តូស ជាស្រុកកំពង់និងជាស្រុកធំទីពីរ មានកាហ្វេលក់ចេញច្រើនជាង

ស្រុកឯទៀតៗ ប៉ែណាំប៊ុកនឹងបាហៀជាកំពង់លក់កប្បាស, ក្រាវប៉ាក៏និង មាក៉ានញ៉ាវជាកំពង់លក់កៅស៊ូនិងរបស់ព្រៃផ្សេងៗ សាវប៉ូឡោ ជាស្រុកធំ មានការលក់ដូរច្រើន, ម៉ាណាអូសជាស្រុកសំខាន់ក្នុងដងទន្លេអាម៉ាសូន, ឌីយ៉ាម៉ង់ទីណា ជាទីប្រជុំលក់ពេជ្រនិងថ្មពេជ្រ នៅក្នុងចន្លោះភ្នំប្រាំងកា និងភ្នំអេសពីញ៉ាសូ ។

ភូមិសាស្ត្រសង្ខេប
ប្រទេសអាសង់ទីន

ផ្ទៃផែនដី– ជាទីដីរាបដ៏ធំទូលាយ មិនសូវមានភ្នំទេ ក្រៅពីមហាភ្នំករឌីយេរ ដេសង់ដ៏ដែលនៅព្រំប្រទល់ដែនទិសខាងលិច ទីដីរាបក្រុងសាកូនៅទិសខាងជើង វាលស្មៅប៉ម្ប៉ានៅភាគកណ្ដាល សមុទ្រក្រស នៅខាងក្រោម. ទន្លេធំៗ គឺទន្លេប៉ារ៉ាណានិងអ៊ុរុក្វាយ (១៦០០គីឡូម៉ែត្រ) ដែលហូរមករួមគ្នាត្រង់ជិតដល់មាត់សមុទ្រ ត្រង់ដែលរួមគ្នានេះជាទន្លេយ៉ាងធំទូលាយហៅថា ឡាប្លាត ។

ខ្យល់អាកាស– នៅតំបន់ទៅក្រោមៗទៅ មានអាកាសរងាត្រជាក់ ពពកចុះច្រើនហើយភ្លៀងក៏ធ្លាក់ច្រើន នៅតំបន់ខាងលើមានអាកាសអ៊ុនល្អ មានភ្លៀងធ្លាក់ច្រើន នៅតម្បន់ទិសខាងកើត ទន្លេប៉ារ៉ាណា ។

ដំណាំ — ពោតជាដំណាំដែលដាំច្រើនបំផុត ស្រូវប៊្លេជាទីពីរ រីឯដំណាំយ៉ាងដទៃទៀត មានស្មៅ, ទំពាំងបាយជូរ, ដំឡូងបារាំង, ថ្នាំជក់, អំពៅ, កប្បាស, តែ ។

សត្វ — ក្នុង ព.ស. ២៤៧៣ មានចំនួនសត្វជ្រូះ គឺកែះ ៤៤.៤១៣.២២១ គោ ៣២.២១១.៨៥៥ សេះ ៩.៨៥៨.១១១ ពពែ ៥.៦៤៧.៣៩៦ ជ្រូក ៣.៧៦៨.៧៣៨ ។

ប្រទេសនេះចិញ្ចឹមកែះ, ពពែ, លា, និងសេះច្រើនជាងប្រទេសដទៃ ៗ នៅទ្វីបអាមេរិកខាងក្រោម ចំពោះកែះមានចំនួនច្រើន ជាងប្រទេសនានាទាំងអស់ក្រៅពីអូស្ត្រាលី ។

លោហធាតុ — មានតែត្បូងថ្ម ១ មុខ ដែលជីកចេញបានក្រែល គ្រាន់បើ លោហធាតុដទៃទៀតមិនសូវមាន ។

ជំនួញដែលលក់ចេញ — ស្រូវប៊្លេ, ពោត, សាច់គោ, សាច់កែះ សត្វគោ, សត្វកែះ, រោមកែះ, ប៊ឺរ, ស្បែកសត្វ, ខ្លាញ់គោ ។ ជំនួញអស់នេះបញ្ជូនទៅលក់ប្រទេសអង់គ្លេស, បារាំងសែស, អាល្លឺម៉ាញ, បែលហ្ស៊ិក, និងសហរដ្ឋអាមេរិក ។

ជំនួញលក់ចូល — គ្រឿងសំលៀកបំពាក់, គ្រឿងដែក, គ្រឿងម៉ាស៊ីន, គ្រឿងកែវ, គ្រឿងចាន, ធ្យូងថ្ម, ក្រដាស, គ្រឿងប្រដាប់សម្រាប់ប្រើក្នុងក្សេត្រកម្ម, ឡាបីយែរ, ស្ករ, ថេយក្ត ។

ផ្លូវគមនាគម — មានផ្លូវរទេះភ្លើងវែង ៤៣,៤៥៨ គីឡូម៉ែត្រ ។ ថ្នល់វែង ២០៥,៩២០គីឡូម៉ែត្រ រថយន្ត ១៦០,០១០ ។

របៀបត្រួតត្រាស្រុក — ជារបៀបរេពុយព្លិក ប្រហែលប្រទេសកាណាដា តែច្បាប់ព្រះគ្រមធម្មរដ្ឋរបស់អាស៊ីន ធ្វើតាមបែបសហរដ្ឋអាមេរិក ។ ប្រធានាធិបតីនៅក្នុងដំណែងកំណត់ ៦ ឆ្នាំ រដ្ឋសភាប្រកបដោយសភាជាន់ខ្ពស់និងសភាដំណាងរាស្ត្រ បណ្ដារាស្ត្របោះឆ្នោតរើសតាំងដូចសហរដ្ឋអាមេរិកដែរ ។

ស្រុកសំខាន់ — ប៊ុយណូសអៃរ៍ស ជាទីក្រុង មានមនុស្ស ១៨០០,០០០នាក់ ហើយជាស្រុកកំពង់យ៉ាងសំខាន់ផង ជាស្រុកធំបំផុតក្នុងទ្វីបអាមេរិកខាងក្រោម ។ ស្រុកឡាប្លាតា, រេសារីអូ, ជាស្រុកកំពង់ ។ ករដូបា, ម៉ង់ដូសា ជាទីជំនុំលក់ដូរខាងជើងគោក ។

ប្រទេសស៊ីលី

ខ្នាត — បណ្ដោយវែងបំផុត ៤.២៥៨ គីឡូម៉ែត្រ ទទឹងនៅក្នុងរវាង ៩៦ ដល់ ៤៣៧ គីឡូម៉ែត្រ ។

ផ្ទៃផែនដី — មានភាគផែនដីជម្រាលពីទិសខាងកើតទៅខាងលិច ហើយពីទិសខាងជើងទៅខាងត្បូង ។ ភាគខាងជើងជាទីស្ងួតក្រៀម

ព្រោះដាំដំណាំមិនកើត ភាគកណ្ដាលដាំដំណាំល្អ ហើយភាគខាងត្បូងស្ដុកទៅដោយព្រៃព្រឹក្សា ។

ទន្លេ - មីតូ, ប៊ីអូប៊ីអូ និងវ៉ាល់ឌីវីយ៉ា ជាទន្លេសំខាន់ ។

ដំណាំ - ដែលដាំជាច្រើន គឺស្រូវប៊្លេ និងស្រូវឯទៀតៗ, ទំពាំងបាយជូរ, ក្រូច, អូលីវ, បេត្តីរ៉ាវ កាហ្វេនិងកប្បាស ។

លោហធាតុ - មានធាតុនីត្រាតសល់ផែត (ធាតុម្សៅ) ច្រើនបំផុតក្នុងលោក ជាលោហធាតុបញ្ជូនទៅលក់ទ្វីបឥរុប លោហធាតុយ៉ាងផ្សេងទៀត មានទង់ដែង, អ៊ីយ៉ូត, អម្បិល, បូរ៉ាក់ស, ប្រាក់, សំណប៉ាហាំង, ម៉ង់ហ្គាណែស, មាស, ស្ពាន់ធ័រ, អាចម៍សត្វ, ដែក, និងត្បូង ។ លោហធាតុផ្សេងៗ មានច្រើនក្នុងភាគខាងជើងនៃប្រទេស ឯភាគ មានច្រើនក្នុងសមុទ្រខ្សាច់ ។

សត្វ - មានចៀមនិងគោជាសំខាន់ក្នុង ព.ស. ២៤៧៣ មានចៀម ៦.២៦៣.៤៨២ គោ ២.៣៨៧.៩៤០ ពពែ ៧៨៨.៨៣១ សេះ ៤៤១.០២៧, ជ្រូក ៣៣១.១៥៦ ។

ជំនួញលក់ចេញ - ជំនួញលក់ចេញដែលសំខាន់បំផុតរបស់ស៊ីលីមាន ២ យ៉ាងគឺ នីត្រាតនិងទង់ដែង ជំនួញសំខាន់បន្ទាប់ចុះទៅ គឺ: រោមចៀម, ធាតុដែក, សាច់សត្វ, អ៊ីយ៉ូត, កាហ្វេ, កប្បាស, ធាតុម៉ង់ហ្គាណែស, ស្ករ, កៅស៊ូ ។

ផ្លូវគមនាគមន៍ – មានថ្នល់វែង ៣៩.០៦២ គីឡូម៉ែត្រ រថភ្លើង ៨.៨៦៤ គីឡូម៉ែត្រ ។

របៀបគ្រប់គ្រងស្រុក – ធ្វើតាមរបៀបសហរដ្ឋអាមេរិក ប្រធានាធិបតី ត្រូវរាស្ត្របោះឆ្នោតរើសតាំងឡើងនៅក្នុងដំណែង ៦ ឆ្នាំ សមាជិកសភាជាន់ខ្ពស់ និងសមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែង ៤ ឆ្នាំ រដ្ឋមន្ត្រីមានចំនួន ៩ នាក់គោងទទួលខុសត្រូវចំពោះប្រធានាធិបតីតែមួយ ។

ស្រុកសំខាន់ៗ – សន្ទិអាកូជាទីក្រុង វ៉ាលប៉ារ៉ៃសូជាស្រុកកំពង់សំខាន់បំផុត កូពីអាប៉ូ ជាទីប្រជុំជីកលោហធាតុ កុងសិបស្យុងនិងវ៉ាលឌីវិយ៉ាជាកំពង់កប៉ាល់ ។

ប្រទេសឯទៀតៗ

បូលីវី – នៅទិសខាងលិចជាដីរាបខ្ពស់ ជម្រាលទៅទិសខាងកើតមានទន្លេសំខាន់ឈ្មោះម៉ាដេរ៉ា ទីជម្រាលទិសខាងកើតជាទីដាំកៅស៊ូ, កាកាវ, កាហ្វេ, ស្រូវប៊ើ, ពោត, លើទីដីរាបខ្ពស់ ដាំដំឡូងបារាំង, ស្រូវប៉ើ, ប្រទេសនេះមានសំណប៉ាហាំង, សំណ, ប្រាក់និងមាសបរិបូណ៌ច្រើន ។ សំណប៉ាហាំងជាជំនួញលក់ចេញសំខាន់បំផុត (៦៣%) ។ ទីក្រុងរបស់បូលីវី ហៅថា ស៊ុក្រែ ឡាប៉ាសជាស្រុកតាំងរដ្ឋសភា មានប្រជាជននឹង

ជំនួញច្រើនជាងប្រទេសឯទៀត ។ អូរុយរ៉ូជាកន្លែងជីកលោហធាតុ ។ ប្រធានាធិបតីនិងសមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែងបានត្រឹម ៤ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៦ ឆ្នាំ ។

ប៉េរូ – មានកប្បាស, កាហ្វេ, អំពៅ, កាកាវ, ស្រូវរ៉េ, ស្រូវឡាយ, ពោត, ថ្នាំជក់, ទំពាំងបាយជូរ, កៅស៊ូ, ជាដំណាំសំខាន់ ។

លោហធាតុសំខាន់ – មានវុលហ្វ្រាម, ប៉េត្រូ ទង់ដែង, ប្រាក់, ទាំងមានធ្យូងថ្មយ៉ាងស្តុកស្តម្ភ, ស្រុកលីម៉ាជាទីក្រុង ។ កាលគ្រាពីសារ៉ូមទ័ពអេស្ប៉ាញ៉ុលមកកាន់ប្រទេសនេះ ពោលថាពួកប្រទេសប៉េរូ ជាជាតិចំរើនរុងរឿង ជាងបណ្តាជាតិទាំងអស់ដែលនៅអាមេរិកក្រោម ។ ជំនួញលក់ចេញដែលសំខាន់មានប្រេងប៉េត្រូ (ក្នុង ១ ឆ្នាំៗ លក់ចេញ ១.៥០០.០០០ តោន) ធ្យូងថ្ម ១៥០.០០០ តោន កប្បាស, ទង់ដែង, ស្ករ, ប្រាក់, ថ្នាំជក់, ស្បែកសត្វ ។

មានជីរបីភ្លើង – ៤,៤៩៦ គីឡូម៉ែត្រ របៀបត្រួតត្រាស្រុកប្រហែលសហរដ្ឋអាមេរិក ប្រធានាធិបតីសមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែងត្រឹម ៥ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៦ ឆ្នាំ ។

ប៉ារ៉ាហ្គាយ - មានតែ, ថ្នាំជក់, ស្រូវម៉េ, អំពៅ, ជាដំណាំដែលគេដាំខ្លះទៅ ។ ជំនួញលក់ចេញមានតែ, ស្បែកសត្វ, សាច់សត្វជាសំខាន់ ។

ស្រុកអាស៊ុងស្យុនជាទីក្រុង ។ ប្រធានាធិបតី, សភាជាន់ខ្ពស់ និងសមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែង ៤ ឆ្នាំ ។

អ៊ុរុក្វ័យ - ក្សេត្រកម្មជារបស់សំខាន់របស់ប្រជាជន ស្រូវឬ, និងពោតគេដាំជាចំនួនច្រើន ។ សត្វមានគោនិងកែះ ទីក្រុងហៅថា ម៉ុងតេ-វីដេអូ, ស្រុកប៉ាយស័នឌុ, និងហ្វ្រៃបេនតុសមានរោងម៉ាស៊ីនធ្វើសាច់ដាក់កំប៉ុងជាច្រើន ។ ប្រធានាធិបតីនៅក្នុងដំណែង ៤ ឆ្នាំ សមាជិកសភាជាន់ខ្ពស់ នៅក្នុងដំណែង ៦ ឆ្នាំ សមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែង ៣ ឆ្នាំ ។

អេក្វាទ័រ - ជំនួញសំខាន់របស់ប្រទេសនេះមានកាកាវ, (ច្រើនបំផុត) កាហ្វេ, មាស, ប្រាក់ ។ ស្រុកក្វៃអាគីលជាស្រុកកំពង់ធំបំផុត គីតូជាស្រុកក្រុង ។ ប្រធានាធិបតីនិងសមាជិកសភាជាន់ខ្ពស់នៅក្នុងដំណែង ៤ ឆ្នាំ ឯសមាជិកសភាតំណាងរាស្ត្រនៅក្នុងដំណែង ២ ឆ្នាំ ។

កូឡុំប៊ី — ជំនួញលក់ចេញរបស់ប្រទេសនេះ គឺកាហ្វេ,(ច្រើនបំផុត) ស្បែកសត្វ, ថ្នាំជក់, កាកាវ, កៅស៊ូ, កប្បាស, ប្លាក់ទីនមាស ។ ទីក្រុងឈ្មោះបូកូតា មេដិលជាស្រុកដែលមានការ ជីកធាតុប្លាក់ទីនធាតុមាសជាច្រើន ។ របៀបត្រួតត្រាស្រុកដូចប្រទេសអេក្វាទ័រ ។

វេនេស៊ុអេឡា — ជាប្រទេសមានលោហធាតុជាសម្បត្តិយ៉ាងសំខាន់ (មានធាតុប្រេងច្រើនបំផុតក្នុងអាមេរិកក្រោម) មាស, ទង់ដែង,

ប្រាក់, ដែកទីងអំបិលជាជំនួញលក់ចេញយ៉ាងសំខាន់ ។ ជំនួញលក់ចេញយ៉ាងដទៃទៀត មានកាហ្វេ, កាកាវ, ស្ករ, ស្បែកសត្វ, គោ, ឈើជ្រលក់សំពត់ ។

ការ៉ាកាស – ជាស្រុកក្រុង ស្រុកកំពង់មានដល់ទៅ ៣២ស្រុក ។ ប្រធានាធិបតី នៅក្នុងដំណែង ៧ ឆ្នាំ ឯសមាជិកសភាជាន់ខ្ពស់ នឹងសភាដំណាងរាស្ត្រនៅក្នុងដំណែង ៣ ឆ្នាំ ។

គុយយ៉ាន – បែកចេញជា ៣ ផែន ជាចំណុះអង់គ្លេស, បារាំងសែស, នឹងហុល្លង់ ទ្រព្យសម្បត្តិផែនដីដែលសំខាន់ មានកាហ្វេ, អំពៅ ថ្នាំជក់, ចេក, ស្រូវខ្យាយ, កប្បាស, ឈើ, មាស ពេជ្រ, គ្រឿងទេស ។

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ២១-២២

គណៈរដ្ឋមន្ត្រីនឹងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៥

គ. ស. ១៩៤២

បញ្ជីរឿង

ទំព័រ

១— វិទ្យុធម្មទេសនា កណ្ឌទី ១២ លោកគ្រូអាចារ្យពាង-សុខ ក្រុមជំនុំព្រះត្រៃបិដក សំដែង : ១

២— លទ្ធិកម្មសុត្តី ពិធីដុតខ្លួនឲ្យស្លាប់ទៅតាមប្ដីដែលស្លាប់ទៅហើយ របស់ស្រីឥណ្ឌៀ ៥

៣— ច្បាប់ផ្សេងៗ ភាគ ៣ :

១) ច្បាប់ភតិនេតិ ១១

២) ច្បាប់បណ្ដាំបិតា ១៧

៣) ច្បាប់ហែមហាជន ២៤

៤— សេចក្ដីកត់ហេតុផ្សេងៗ ៣២

៥— ប្រវត្តិសាវិការបស់ព្រះពុទ្ធជាម្ចាស់: ៣— ប្រវត្តិនាងខុជ្ជុត្តរា ឧបាសិកា ៤— ប្រវត្តិ ព្រះនាងសាមាវតី ភគីទេវី ៣៧

៦— អំពីគម្ពីរបញ្ចតន្ត្រៈសង្ខេប (តមកនឹងចប់) ៤៥

៧— រឿងព្រះបាទអសោកមហារាជ អ្នកអាចារ្យ គីម-អាន ប្រែនិងរៀបរៀង (តមក) ៦២

៨— ពង្សាវតារក្រុងរោម ស្រង់យកអំពីពោលបារីកផ្សេងៗ ក្នុងពង្សាវតារលោក (តមក) ៧៦

TABLE DES MATIÈRES

Pages.

1. VIDYUDHAMMADESANĀ (Conférence faite à la Radio Phnôm-Penh), par le Vénérable Achar PÉANG-SOK, membre de la Commission du TRIPITAKA........................ 1

2. SATTISAMMASUTTI (Cérémonie du bûcher des femmes indiennes) par l'OKNHA TÉP PITOU KRASÉM........................ 5

3. CHBAB divers:

I. CHBAB RĀJANET........................ 11

II. CHBAB BANDAM BEIDA........................ 17

III. CHBAB HAIMAHĀJANA........................ 24

4. Notes diverses........................ 32

5. Vies des disciples du BOUDDHA:

III. La vie de KHUJJUTTARĀ, — IV. La vie de SĀMĀVATĪ... 37

6. Abrégé du PAÑCATANTRA (suite et fin)........................ 49

7. Légende de l'Empereur ASOKA de l'Inde antique, par feu l'Achar KIM-AN. (suite)........................ 62

8. Histoire de Rome. Extraits de diverses documents de l'histoire universelle (suite)........................ 76

វិទ្យុធម្មទេសនា កណ្ឌទី ១២

លោកគ្រូអាចារ្យ ពាង-សុខ ក្រុមជំនុំព្រះត្រៃបិដកសំដែង

នៅថ្ងៃព្រហស្បតិ៍ ១៤ កើតខែពិសាខឆ្នាំមមីចត្វាស័ក ព.ស. ២៤៨៥

(ត្រូវនឹងថ្ងៃ ២៨ ខែម៉ៃឆ្នាំ ១៩៤២)

សុភាសិតគាថា

សាធុ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញកា
វាតោ វហតិ ឯកដ្ឋំ ព្រហន្តម្បិ វនប្បតឹ ។

ប្រែជា ៣ ផ្នែក គឺ:

ទី ១ - ញាតិមានច្រើនប្រពៃ ឈើក្នុងព្រៃក៏ដូចគ្នា ព្រះពាយតែងពាធា ឈើដុះនាទីវាលល្វឹង ជាឈើតែមួយដើម ធំសំបើមកង់ចង្ក្រឹង សូម្បីធំយ៉ាងហ្នឹង គង់ទទឹងខ្យល់មិនបាន ។

ទី ២ - ពួកញាតិច្រើនគ្នាទើបពូកែ សូម្បីពួកឈើដែលដុះក្នុងព្រៃច្រើនដើមពូកែដែរ ខ្យល់តែងបក់កើចពាញទូវឈើដែលតាំងនៅតែឯង សូម្បីយ៉ាងធំជម្រងយកទៅបាន ។

ទី ៣ - ពួកឈើដែលដុះក្នុងព្រៃច្រើនដើម មានមែកនិងមែកបាក់ ស្រេះប្រទាក់គ្នាទៅវិញទៅមក សូម្បីវេរម្ភកគឺខ្យល់ព្យុះបក់មកប្រសព្វ

គ្នា ក៏មិនអាចនឹងរស់រលើងបាន យ៉ាងណាមិញ ពួកញាតិច្រើនគ្នា មានសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងស្រុះស្រួលគ្នា ពួកសត្រូវមិនអាច នឹងបំផ្លិចបំផ្លាញបាន យ៉ាងនោះដែរ ពួកឈើច្រើនដើម មានមែកនឹង មែកកន្ទែកមែកខ្វែកចេញពាក់គ្នា ជាឈើមិនខ្ជាប់ខ្ជួនមាំមួន តែងរស់ រលើងទៅដោយខ្យល់ព្យុះដែលបក់កើបទង់ទាញយកទៅបាន យ៉ាងណា មិញ ពួកញាតិច្រើនគ្នាមានវិវាទៈ គឺសេចក្ដីប្រកែកជជែកគ្នា ទឹង វិគ្គហៈគឺសេចក្ដីប្រណាំងប្រជែងគ្នាជាដើម ក៏មិនពូកែតែងដួលរលំទៅ ដោយសត្រូវចូលលុយលុករុករានគគ្គានទ្រានមកផ្ដួលរំលំបាន យ៉ាង នោះដែរ ព្រោះហេតុនោះ សេចក្ដីខ្លាំងពូកែ កាលដែលកើតឡើងបាន ក៏កើតឡើងព្រោះអាស្រ័យនូវសាមគ្គី គឺសេចក្ដីព្រមព្រៀងគ្នា ព្រោះ សាមគ្គីអាចធ្វើរបស់ដែលស្រាលឲ្យធ្ងន់បាន ដូចជាអង្ករមួយគ្រាប់ដែល នៅតែឯងជារបស់ស្រាល កាលបើបានរួបរួមចូលជាមួយ នឹងអង្ករឯ ទៀតច្រើនគ្រាប់ ក៏ទៅជារបស់ធ្ងន់បាន ។ អាចធ្វើរបស់ដែលធ្ងន់ឲ្យ ស្រាលបាន ដូចជាសសរមួយដែលមនុស្សម្នាក់លើកបញ្ឈរមិនបាន កាល បើមនុស្សប្រជុំគ្នាបាន ១០ នាក់ឬ ២០ នាក់ជាដើមក៏អាចលើកសសរនោះ បញ្ឈរបាន ។ អាចធ្វើរបស់ដែលផុយឲ្យជាប់បាន ដូចជាអំបោះមួយសរសៃ

ដែលនៅតែឯងជារបស់ផុយ កាលបើរួបរួមចូលជាមួយនឹងអំបោះឯទៀតច្រើនសរសៃ ក៏ទៅជារបស់ជាប់បាន, អាចធ្វើរបស់ដែលជាប់ឲ្យផុយបាន ដូចជាពួរមួយកន្ទុយដែលមនុស្សម្នាក់ទាញមិនដាច់ កាលបើមនុស្សរួបរួមគ្នាបាន ១០ នាក់ឬ ២០ នាក់ជាដើម ក៏អាចទាញពួរនោះឲ្យដាច់បាន; អាចធ្វើរបស់ដែលតិចឲ្យច្រើនបាន ដូចជាមនុស្សជាដើម ដែលនៅតែឯងតិច កាលបើរួបរួមចូលគ្នា ក៏ទៅជាច្រើនបាន ។ អាចធ្វើរបស់ច្រើនឲ្យតិចឬឲ្យពាយលេសឬឲ្យអស់ទៅក៏បាន ដូចជាទាបមួយ មិនអាចធ្វើស្រូវក្នុងស្រែមួយឲ្យអស់បាន កាលបើទាបរួបរួមគ្នាបានច្រើន ក៏អាចធ្វើស្រូវក្នុងស្រែមួយៗ ឲ្យតិចឬឲ្យពាយលេស ឬក៏ឲ្យអស់បាន ដោយអំណាចរបស់សាមគ្គីយ៉ាងនេះជាដើម; ព្រោះហេតុនោះមិនដាច់ស្រេចតែមានគ្នាច្រើនទេ តោងអាស្រ័យនូវសាមគ្គីផង ឈើតែមួយដើមសូម្បីយ៉ាងធំដម្បងបរិបូណ៌ដោយមែកស្លឹកទងត្រួយ ក៏មិនអាចតស៊ូនឹងខ្យល់ព្យុះដែលបក់មកបំបាក់រំលំរំលើងបានយ៉ាងណាមិញ បុគ្គលតែម្នាក់ឯង សូម្បីមានសរីរពល (កំឡាំងកាយ) ភោគពល: (កំឡាំងទ្រព្យ) និងញាណពល: (កំឡាំងអាជ្ញា) ក៏មិនអាចតស៊ូនឹងពួកខ្មាំងដែលព្យាយាមដើម្បីបំផ្លិចបំផ្លាញ បង្ហិនបង្ហោចបានយ៉ាងនោះដែរ សមនឹងសុភាសិតថា:

ធម្មតាឈើតែមួយដើម

ទោះធំសំបើមគង់តែរលំដោយខ្យល់

ជាតិមនុស្សតែឯងតែងផល់

នូវទុក្ខជាផលនៃការបៀតបៀននៃខ្មាំង ។

សព្វសង្ខាហិកសុភាសិតកាព្យ

ពួកមានសាមគ្គីព្រះមុនីទ្រង់សរសើរ

ពួកឈ្លោះគ្នាបណ្តើរមិនប្រសើរដល់ជនម្នាក់

ពួកតែម្នាក់ឯងយូរឆាប់តែងមានគ្រោះថ្នាក់

ពួកគ្នាច្រើននាក់ឯគ្រោះថ្នាក់កម្រមាន ។

និដ្ឋិតា ទេសនា ឯវំ ។

លទ្ធិកម្មសុត្តី

ពិធីដុតខ្លួនឲ្យស្លាប់ទៅតាមប្ដីដែលស្លាប់ទៅហើយ
របស់ស្ត្រីឥណ្ឌា

ពាក្យប្រារព្ធរបស់អ្នករៀបរៀង

ទោះបីរឿងនេះ មិនត្រូវតាមទំនងគន្លងធម៌ របស់ព្រះពុទ្ធជាម្ចាស់ ទាំងជារឿងដែលមិនមានប្រយោជន៍ដល់យើងដោយចំពោះក៏ពិត តែជារឿងដែលមានភស្តុតាងពិតប្រាកដមិនមែនភូតភរ ទាំងជារឿងដែលគេរាប់ថាជាទំនៀមទម្លាប់ ១ យ៉ាងរបស់ឥណ្ឌា សឹងមានមកអំពីបុរាណកាលមកហើយ ៗ សម្រាប់ "អ្នកដែលស្រឡាញ់វិជ្ជាជុំខ្លួន" រមែងមិនរង្កៀសក្នុងការដែលនឹងមើលនឹងសិក្សារឿងសូម្បីដូចជារឿងនេះឡើយ អា-ស្រ័យហេតុនេះជាប្រមាណ រឿងលទ្ធិកម្មសុត្តីទើបមកកន្លងប្រាកដក្នុងទីនេះ ដើម្បីប្រយោជន៍ដល់បុគ្គលជំពូកខ្លះ ដែលត្រូវការចង់ចេះដឹង ៗ

(ឧកញ៉ា ទេពពិទូរ ក្រសេម គន្ថបណ្ឌិត)

ពិធីដុតខ្លួនឲ្យស្លាប់ទៅតាមប្ដីអ្នកដែលស្លាប់ទៅមុនហើយនេះហៅតាមភាសាឥណ្ឌាថា "សុត្តី" មានមកក្នុងបំពួករឿងទំនៀមទម្លាប់របស់ឥណ្ឌា សឹងជារឿងដែលគេអាងថា កើតមកអំពី "ទេវបញ្ញត្តិ" គឺជាទេវត្តាបញ្ញត្តិទុកមកឲ្យធ្វើដូច្នោះ ដោយសេចក្ដីថា :

ភរិយាអ្នកមានសេចក្ដីស្វាមិភក្ដិនឹងប្ដី កាលប្ដីទទួលមរណភាពទៅហើយ ដល់វេលាគេយកសពប្ដីទៅដុតរំលាយតាមទំនៀមស្រុកទេសនោះ រមែងចូលទៅដុតខ្លួនទាំងរស់ឲ្យស្លាប់ទៅតាមប្ដី ដោយរួមជើងថ្ករជាមួយគ្នា ឲ្យសមនឹងពាក្យថាដែលគេហៅស្រីថា "សមរ" សំនៅប្រែថា "អ្នករួមស្លាប់" ការសម្លាប់ខ្លួនដោយពិធីកម្មសតីនេះ ឥណ្ឌៀគេកាន់ថាជាបុណ្យកុសលណាស់ណា នាងសាម៉ខ្លួននោះនឹងបានឡើងទៅកើតឯឋានសួគ៌រួមជាមួយនឹងប្ដីរបស់ខ្លួន ដោយមិនមានឃ្លៀងឃ្លាត ៗ អាស្រ័យសេចក្ដីជឿក្នុងទេវបញ្ញត្តិជាមាំ ពួកស្រីឥណ្ឌៀអ្នកដែលភក្ដីនឹងស្វាមី ក៏បានប្រណិប័តន៍តៗគ្នាមកជាអន្លើងហើយ, តាំងពីកើតទេវបញ្ញត្តិឲ្យមានសតីនោះមក ស្ត្រីដែលត្រូវស្លាប់ដោយដុតខ្លួនក្នុងគំនរភ្លើងដែលរំលាយសពប្ដី ប្រសិនជាមានបញ្ជីកត់ទុក មើលទៅប្រហែលជាមានចំនួនណាស់ណា ស្ទើរតែរាប់មិនអស់ទៅហើយទេដឹង ។

លុះអង់គ្លេសមកបានជាធំគ្រប់គ្រងប្រទេសនោះ ឃើញថា លទ្ធិកម្មសតី ជារបស់អសារឥតការ ទើបត្រាជាច្បាប់បញ្ញត្តិទុកជាដាច់ខាតមិនឲ្យស្ត្រីឯណាធ្វើដូច្នោះតទៅ ទោះបីដូច្នោះ ក៏នៅមានស្រីខ្លះលបធ្វើជារឿយ ៗ មក, តាមដែលប្រាកដក្នុងសេចក្ដីរាយការណ៍ មានដល់ទៅ ៣០ នាក់ហើយជាការគ្រាំគ្រាពេកណាស់ ដែលនឹងគិតលុបលាងប្រវេណី

ដែលប្រកបឡើងដោយទេវបញ្ញារបស់ទេពជាម្ចាស់ ដែលគេទ័យមមក
ជាយូរយារពេកប់វេលាតាំង ២០០០ ឆ្នាំមកហើយ ។

ដូចយ៉ាងកងឆ្នាំ ព.ស.២៤៨០ នេះ មានអ្នកធ្វើលទ្ធកម្មសុគ្គិដក់
ទៅពីរនាក់ គឺ នាងម្នាក់នោះឈ្មោះ កាលាវតី នាងម្នាក់ទៀតឈ្មោះ
"រូប៉ាគានី" អាយុ ២៥ ឆ្នាំនៅតំបន់ស្រុក អាគរា បានធ្វើសុគ្គិកងខែដេស្ត
ព.ស.២៤៨០ ។ សុគ្គិនោះ មិនមែនថាជាកិច្ចដែលធ្វើបានងាយងាយ
នេះព្រោះ ១- ត្រីស្រ្តីចិត្តដាច់ដែលអាចនឹងធ្វើដូច្នោះ ២ - កាលមានស្រី-
ស្ត្រីដែលអាចនឹងធ្វើហើយ ក៏គោងត្រូវគេការពារហាមឃាត់មិនឲ្យធ្វើ;
ទោះមានឥទ្ធិពលអាចនឹងចោលខ្លួនទៅកងគំនរភ្លើងបាន ក៏គោងរង់ចាំ
រៀបចំខ្លួនឲ្យត្រូវតាមពិធីចរិតប្រវេណីជាមុនសិន គឺគោងប្រងប្រៀបទុក
ជាមុនប្រមាណ ១០ ដល់ ១២ ម៉ោងទើបធ្វើបាន ។ នាងរូប៉ាគានីកាលប្តី
ស្លាប់ហើយ, ពេទ្យប្រចាំតំបន់បានមកពិនិត្យសពនឹងប្រកាសមរណភាព
កងវេលាល្ងាចនៃថ្ងៃនោះ ហើយនាងក៏ស្នើរសេចក្តីបំណងរបស់នាងឲ្យ
ពពួកញាតិមិត្រតាំងឡាយជ្រាប នឹងបង្អង់ការឈាបនកិច្ចទុកដល់ថ្ងៃស្អែក
ឡើង ដើម្បីនាងនឹងមានឱកាសធ្វើកិច្ចដែលគួរធ្វើរបស់នាង ។

គ្រានោះ ពួកអ្នកដែលមកប្រជុំកងប៉ុណ្ណោះនោះតាំងប្រុសតាំងស្រី
តាំងអ្នកជិតតាំងអ្នកឆ្ងាយ រហូតដល់ទៅស្វាមីខ្ញុំប្រុសខ្ញុំស្រីរបស់នាង ក៏
ចូលទៅអង្វរហាមឃាត់នាងមិនឲ្យធ្វើកម្មឯណានីមួយដែលជាការល្មើស

ច្បាប់អង់គ្លេស ដែលបញ្ញត្តលុបលាងមិនឲ្យមានលទ្ធិកម្មសុត្តិជាដាច់ខាត ហើយនាងមេម៉ាយក្រមុំក៏តបតាមបទបញ្ញត្តិដែលមានក្នុងគម្ពីរវេណ្ឌ សឹងមានសេចក្តីបញ្ញត្តិថា "មុខងាររបស់ភរិយាក៏គឺមិនព្រមចាកស្វាមីក្នុងយាមរស់ឬក្នុងយាមស្លាប់" កាលពួកញាតិមិត្របានប៉ះទឹងបទបញ្ញត្តិរបស់មនុស្សនឹងទេវតាដែលនាងនាំមកអាងដូច្នោះហើយ ក៏មិនអាចនឹងហើយហាហាមប្រាមនាងដូចម្តេចទៀត អ្នកខ្លះក៏និយាយថា "យើងត្រូវតែស្ងើរសេចក្តីផល់ពដការឲ្យបានប្រាប់តាមការ" ។

គ្រានោះ មានយោគីកន្លាត់ម្នាក់នៅក្នុងស្រុកនោះ ជាអ្នកបំភ្លឺទំ-នៀមឈាបនកិច្ចក្នុងឥណ្ឌៀ ច្រើនតែធ្វើខាងក្នុងវេលាពីរបីម៉ោងជាខាងក្រោយវេលាស្លាប់ហើយ វៀរតែស្លាប់ក្នុងវេលាល្ងាច សឹងមិនអាចនឹងចាត់ការឲ្យទាន់ពេលបាន ការមរណភាពប្តីនាងរូប៉ាតានី វេលានោះជារដូវក្តៅខ្លាំង នាងទើបបង្អង់ការឈាបនកិច្ចឲ្យយឺតទៅបន្តិច ដើម្បីនឹងបានត្រៀមការដែលត្រូវធ្វើ សម្រាប់ពិធីសុត្តិឲ្យរៀបរយ ។

លុះវេលាល្ងៀមអរុណរះហើយ រូប៉ាតានី ក៏ចាត់ចែងបំពាក់គ្រឿងអំពារណ៍ឲ្យប្តីយ៉ាងផ្ចិតផ្ចង់តាមទំនៀមស្រុក ហើយក៏ថែមកតាក់តែងខ្លួនរបស់នាងវិញ គឺ ស្លៀកពាក់គ្រឿងវិវាហមង្គលហើយ ខ្ចាស់ផ្កាឈើនឹងមាសពេជ្រគ្រឿងប្រដាប់ប៉ោងដៃ១ ហើយយកជាតហិង្គុលសំបុរក្រហមស្រស់មកដាក់ត្រង់ថ្ងាសរបស់នាង ជាគ្រឿងសំគាល់នៃភរិយាភាពក្នុងគ្រាក្រោយ

បំផុត ស្រេចហើយនាងក៏បើកទ្វារចេញទៅមានកិរិយាឫកពាជាសុខុមាលភាព ហាក់ដូចជានាងក្រមុំដែលកំពុងថៃរមុខទៅមណ្ឌាស[1] មួយអន្លើដោយប្ដីរបស់នាង មើលទៅដូចជាមិនមែនស្រីមេម៉ាយ ដែលប្រុងនឹងផុតខ្លួនឲ្យស្លាប់ទៅតាមប្ដីទេ ។

ខណៈដែលនាងចេញ មានស្រីជាញាតិមិត្ត ១ ពួកបានគៀនស្មារតីឲ្យនាងត្រិះរិះជាថ្មីឲ្យស្រួលសិន ក្នុងការដែលនាងធ្វើការល្មើសច្បាប់លោកដូច្នេះ តែពាក្យតបរបស់នាង ធ្វើឲ្យអ្នកអំបាលនោះស្ងាត់មាត់ស្ងៀមតែម្ដងដោយថា "ពួកអ្នកពល់គ្នាដែលមកហាមឃាត់ខ្ញុំដូច្នេះ នឹងត្រូវបណ្ដាសាទេពតាឲ្យបាត់ថ្ងឹងថ្ងៃរហូតទៅ ព្រោះការដែលខ្ញុំធ្វើពិធីនេះ ធ្វើដោយសេចក្ដីស្មោះត្រង់នឹងស្វាមីសំឡាញ់ នឹងទេពតាដែលជាទីគោរពរបស់ខ្ញុំ" ។

ខណៈនោះ គេក៏សែងខ្មោចប្ដីរបស់នាងចេញមកដាក់នៅធរណីទ្វារអស់បួនប្រាំមីនុត ដើម្បីទទួលទឹកពររបស់អ្នកបួស ដែលជាពិធីដំបូង គ្រានោះរូបាគានីបានយកជាយសំពត់រ៉ាហៈរបស់នាងទៅចងភ្ជាប់នឹងខ្មោច ដើម្បីជាសញ្ញាលាក្នុងគ្រាក្រោយបំផុតថា នាងជាភរិយាមិនមែនជាស្រីមេម៉ាយទេ កាលអ្នកបួសឲ្យពរទឹកចប់ហើយ នាងក៏ដើរបំបាំងខ្លួនទៅក្នុងពពួកទិករជន-លុះទៅដល់ទីផុតហើយ រូបាគានី ក៏ទៅពួនលាក់

១ ទៃមណ្ឌ ជាទីទក្ខិណាដែលគេតែងរៀបការប្ដីប្រពន្ធ ។

ជូនក្បែរជើងថ្ករ អ្នកបួសមកសូត្រមន្តឲ្យពរម្តងទៀត លុះចប់ហើយគេក៏លើកសពដាក់ទៅលើជើងថ្ករ គ្រឿងតូរ្យតន្ត្រីក៏ប្រគំឡើងលាន់ទ្រហឹងអឺងកងព្រមគ្នា វេលានោះព្រះភ្លើងក៏ឆេះសន្ធោរឡើង រូប៉ាតានី បានលបលោបប្រែងជាកតាំងខ្លួនហើយ ក៏ស្ទុះចូលទៅឱបប្តីក្នុងគំនរភ្លើងក្នុងមួយរំពេចសេចក្តីក៏ផ្តាច់ទៅដល់កងត្រៃវេលាៗ បីនាក់បានរត់ចូលមកការពារ តែមិនសម្រេច ដោយវេលានោះមានស្រី ៩ នាក់ ដែលជាញាតិមិត្របស់នាងបានរាំងកម្មនឲ្យចូលមកបាន ខណៈនោះ គេឮសំឡេងនាងស្រែកថ្ងូរ ដោយអំណាចត្រូវកំដៅភ្លើងយ៉ាងក្តៅដែលនាងមិនអាចទ្រាំទ្រាបាន ហើយក៏បាត់ឈឹងទៅវិញ ឮតែសូរសន្ធឹកព្រះភ្លើងឆេះគឹកៗឡើង អ្នកបួសក៏សូត្រធម៌ឡើងម្តងទៀតជាក្រោយបំផុតទាំងពួកគ្រហស្ថក៏ស្រែកសូត្រឲ្យសព្ទសាធុការពរព្រមគ្នាឡើងតែកល់ៗគ្នា វេលានោះវិញ្ញាណរបស់ រូប៉ាតានី ក៏រលត់បាត់សូន្យឈឹងទៅដោយប្រការដូច្នោះ ./. ៸

ច្បាប់រាជនេតិ

ឬ

ច្បាប់ព្រះរាជសម្ភារ[១]

បទកាកគតិ

ហៃសាធុជនផង នេះគឺចំណង បទបាឡីថា គម្ពីរសេធមិ អាណា-ក្រិត្តិកា គួរគប្បីមហា- ជនផងត្រងត្រាប់ ៗ ធមិនេះជម្ពូនាន រួមរក្សាប្រាណ ឲ្យបានក្ដីគាប់ ដល់លោកបរលោក ហៅសេពុំស្ងាប់ ធមិនេះជាច្បាប់ ក្ដីគាប់បរិយាយ ៗ កុំទុកចិត្តបរទេស កុំទុកចិត្តអកិទេស កុំទុកចិត្តអកិប្រាយ បើស្ទុំតែងខ្ពស់ រំពឹងឲ្យឆ្ងាយ ស្ដាប់ពាក្យបរិយាយ បណ្ដាំមេជី ៗ កុំជឿងដោយខ្យល់ កុំខុនពាក្យពល កុំខ្វល់ដោយស្រី កុំកាន់ពិសុយន់ គប់ទឹងស្ត្រី សមណជនជី កុំឲ្យក្ដីត្រូវ ៗ កុំនៅញ៉ាំងឈ្លោះ កុំស្ដាប់អសុរស កុំស្ដាប់អាស្រូវ កុំដើរពានស្កុន កុំស្កាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ នៅផ្លូវដំរី ៗ ផ្អែមពីរប្រការ ចំណោរនៅដាល កុំអាលឲ្យធី ផ្អែមមួយពាក្យពាល តែងកលរកក្ដី ផ្អែមមួយពាក្យស្រី ស្រដីមាយា ៗ ពាក្យត្រូវតែងរឹង ស្រាតែងស្រវឹង ពុំផលពីសា ពាក្យពិតតែងស្លូន ពុំពីរោះថា បណ្ដាំមេបា តែងថាពុំគាប់ ៗ ខ្ញាតែងស្អុប

១— ដែលហៅថា "ច្បាប់ព្រះរាជសម្ភារ" នោះ ហៅតាមព្រះនាមលោកអ្នកតែង គឺព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសម្ភារ ព្រះចៅក្រុងកម្ពុជាធិបតី ។

បេះ ខ្សត់ឥតចំណោះ ស្អប់អ្នកមានទ្រព្យ ស្រីស្រាលប្រពន្ធ វង់ ស្អប់ខ្ជិតាប់ ពាលពិតឥតច្បាប់ វង់ស្អប់ប្រដៅ ៗ ចង់បុណ្យបានបាប ចបើងបង់លោក វង់ប្រាក់ខេះទៅ មានៈប្រាក់មិត្រ ឥតអ្នកជាទៅ ត្រេវត្រាចលោភលោវ វែងប្រាក់អគ្គិ ៗ ស្វែងគាប់បាទយស បង់ ស្វែងរបស់ ប្រើបេះផ្គត់ផ្គង់ បង់ធំកុំអួត ដើមមានពូជពង្ស បង់ឲ្យខ្លួន ត្រង់ ប្រើផ្គាប់អ្នកមុខ ៗ ខ្វិនហើរវៀតខ្យល់ ឆាយធ្វើងវៀតពល រក្សា ឲ្យសុខ ទ្រព្យគង់វៀតស្រី បេះសំបៃទុក មានផ្ទះស្រណុក វៀតករិយា ជា ៗ បាត់យសវៀតខ្ជិល បាត់ញាណគានសីល វៀតសេពសុរា ប្រមាទ បាត់បុណ្យ ទឹងបាត់ប្រាជ្ញា លេញលេងវៀលថា បាត់ករិយាគាប់ ៗ អត់ធ្មត់ឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ មេត្រីជាញាតិ រក្សា ដល់ស្លាប់ បៀសក្តីពុំគាប់ ជាគន្ធពិដោរ ៗ ទឹកបាក់ទៅតាម បុណ្យ បាត់វៀតបាប ណាកបាត់វៀតលោភ ទឹកថ្លាវៀតលេក ពុំយល់ស្រមោល ទោសកើតវៀតកោល លុះមាក់ឈ្មានពាន ៗ ទៅវែងស្អប់ប្រាជ្ញ នាអ្នក ខ្ជិនខ្ចាប វែងធ្វើជាបារិន ខ្សត់ខ្សោយស៊ុតទ្រុឌ វែងធ្វើជាមាន អ្នកឥត សន្តាន វែងមើលគេងាយ ៗ ចាបានធ្វើងវៀតសឹក ធ្វើស្រែវៀតទឹក ត្រែកពលវៀតបាយ សិស្សប្រាជ្ញវៀតគ្រូ ដេរពោលដំកាយ ពលជាវៀត នាយ ហ៊ុកហ៊ុនខះទំ ៗ នៀនក្តីគួរគិត ចាស់ឥតប្រព័ត្ត នៅប្រែប្រួល អ្នកជា ៗ គាប តូចប្រែជាធំ ពង្សពូជឧត្តម ព្រឡើជាកស្ត្រ ៗ ឃើញសេះ

ជាលា ក្ងានជាទា ពពាយជាពាស សំណជាប្រាក់ ស្ពាន់ធ្លាក់ជាមាស
បន្ទាយជាជាស កប្បាសជាគរ ៗ ហេតុនេះគួរគិត គួររិះរកហិត ដឹងរស
គន្ធ ពីដោរអស់ដោរ ពីសាសាចរ ហិតហើយឆប្ប បរកោក្កាក្កិត ៗ
ល្អិតក្រពីពាក្យ សាកសួររកសាច់ សន្តានព្រេងព្រឹទ្ធ រករិះកលអ្វី សុចរិត
ទុច្ចរិត ហើយហោងគួរគិត ឲ្យដឹងខ្ពស់ទាប ៗ ដូចខ្លាក់ចាំងស្បែក មួយ
ដូចទំពែក ចង់សុំប្រែងលាប ដូចច្លង់ស្ពាប់ប្រៀង ទះដៃព្រាកៗ ដូចខ្វិន
អាចឡាប ចង់ចងក្បៀនរត់ ៗ ពុកញ្ញាយមានបី មួយដូចដំរី សាហាវ
ឥតបទ អាចផ្សះផ្សាំងបាន កន្ទ្រើរកាន់កត់ ជាលជេញ្ញគោត្តគត់ ប្រាំមួយ
ហត្ថហោង ៗ មួយចង់ឈ្មានីស ចិត្តចង់ចចេស ពុំដោយគន្ធង ពាក្យ
ពោលអ្នកធំ ប្រឡំសួរសេង ពុំគិតក្តីហ្មង ចង់ចេរអន្តរាយ ៗ មួយ
ស្រីពេស្យា បំពេញព្រហ្មចា- រីរួសអតិប្រាយ អំពើទាំងបី ហៅ
ពិសពុកញ្ញាយ សាធុសម្លាយ ចៀសកុំបីគ្រាប់ ៗ ប្រាជ្ញពុំស្មើពុក
បំរើលំអត ពុំស្មើក្តីគាប់ មានគុណពុំស្មើ អ្នកមានបុណ្យក័ព្ទ ស្នែង
រៀនរកច្បាប់ ពុំស្មើចិត្តជា ៗ ស័ក្តិពុំស្មើយស អ្នកមានរបស់ ពុំ
ស្មើស័ក្តា ស្វាបង់ធនធាន កុំខុសអាជ្ញា ស្វាមានពេគា កុំឲ្យមើល
ងាយ ៗ ស្វាសុំកុំយក គ្នាស្មើកុំរក ដូចបាវនឹងនាយ ខុសគាប់
ស្វាអត់ កុំឲ្យព្រួយឆ្ងាយ ក្តីសុខមទាំងឡាយ កុំខ្វាយស្វាស័ព្ទ ៗ ធម៌នេះ
ជម្ងឺនាន រួមរក្សាប៉ុណ្ណា ឲ្យបានក្តីគាប់ ស្វាបង់ធនធាន កុំឲ្យខ្វួន

ស្ដាប់ សូរស្ដាប់គ្រូគោប់ សេធម៌កុំបីបង់ ។ បណ្ឌិតមេធា អំបូរ
លោកថា ទូកតាមគំពង់ សំពៅតាមខ្យល់ ចន្ទ្រជម្រង់ មេឃលឹម
តែងត្រង់ ត្រីវិស័យជាមុខ ។ ដូចចិត្តប្ដីជា ដូចមានការិយា នៅផ្ទះ
ស្រណុក ដូចកូនទទួល យកពាក្យអាពុក ដូចខ្ញុំឲ្យមុខ អម្ចាស់ប្រើ
ហៅ ។ បណ្ឌិតមេធា អំបូរលោកថា ព្រេងព្រឹទ្ធប្រដៅ ទើងធី
ប្រើក ទើងស្ងួនប្រើទៅ ទើងស្ទុះប្រើហៅ មិត្រមកជាមិត្រ ។
ពាក្យខុសកុំស្ដាប់ ក្ដីខុសកុំត្រាប់ អ្នកកាចកុំប៉ិត ល្ងង់កុំស្រដី ខ្សត់
កុំទុកចិត្ត ពាលោកុំប៉ិត ជាមិត្រមេត្រី ។ ប្រើថ្ងៃឲ្យស្មើ ទោះបី
ទីងប្រើ ប្រើអ្នកបេះក្ដី កុំយកពាក្យស្មោក ជួមខឹងគម្ពីរ កុំយកពាក្យ
ដី ជួមនូវពាក្យពាល ។ មើលភ្នែកជញ្ជីង ក្ដិចិត្តឲ្យដឹង ណា
ផ្ទន់ណាស្រាល កុំយកមណីរ័តន៍ មាសមានជាកាល ចិត្តកុំបណ្ដោល
នូវបង់សីលធម៌ ។ ប្រើដឹងគុណបាប ប្រើដឹងខុសទាប មានភ្នែក
យល់ល្អ ទោះដឹងទឹកមាស ពុំបេរនៅថ្ម ទោះដឹងដីស ពុំបេរសំបុត្រ ។
ធ្វើស្រែមើលស្មៅ សន្ទានមើលដៅ បំរើមើលពុត ទោះដឹងពុតជា
ពុំបេរពុតត្បុត ដឹងចិត្តបរិសុទ្ធ ពុំបេរកិរិយា ។ ទេពីមើលក្រិត្យ
ក្សត្រាមើលឫទ្ធិ៍ ទាហានមើលចេស្ដា ដាងមើលអំពើ អំពីហក្ដា ទោះ
យកការិយា មើលនាល់នៅ ។ អសារក្ដីប៊ី បណ្ឌិតមេធី ព្រេងព្រឹទ្ធប្រដៅ
អង្គសេសុទ្ធ ចំអិនឲ្យនៅ ពីស៊ីហើយខ្ទៅ ប្រាជ្ញឥតមារយាទ ។ អ្នក

បួសឥតក្រឹត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ ភរិយាផុយផាយ ចាយរាយឥតខ្នាត ពលពាលសុទ្ធសាធ ប្រដៅក្របាន ៗ ផ្ទះក្មេងមានបី អំពើពុតស្រី ទឹងឥតប្រមាណ កូនកាចចចេស ពុំដោយដំបូន្មាន ឪ គេចកៀសប្រាណ ពុំឲ្យម្ចាស់ប្រើ ៗ ហោរាប្រើគូរ កុម្ភប្រើមូល ស្ទង់ទឹកប្រើស្មើ បន្ទាត់ប្រើត្រង់ ពលផ្ទង់គប្បីប្រើ ពុំហើយគប្បីធ្វើ កុំលែងគប្បីក្រា ៗ ក្តីគោគមានបី គោគមួយពួកស្រី ស្រដីមាយា គោគមួយពាក្យពិស អាស្រូវដេរថា គោគមួយពាក្យពា- លោលោកុទុជិន ៗ ពិសពស់នានា ក្នុយខ្លាយទន្ទា កាលគត់ស្តាប់មន្ត ត្រង់ពិសពាក្យពាល ពេលពលពុំស្រន្ត សូម្បីអស់ជន្ម ក្រមន្តពុំសបាន ៗ ហេតុនោះគួរគិត គួរវៀរគេហិត ថ្នាំពិសឲ្យស្រាន្ត ដ៏លោកនេះគួរ រកអ្នកទ្រង់ញាណ សេពសាងសីលទាន ជាថ្នាំលោកិយ ៗ រីថ្នាំបរលោក ចៀសបាកទុក្ខសោក បង់បញ្ចឥន្ទ្រិយ គប្បីដឹកសត្តតិង្ស- ពោធិបក្ខីយ៍ អាចនាំដល់ត្រៃ- ពិធសម្បត្តិសារ ៗ ពិដោរផ្កាបី ពិដោរមេត្រី ស្អូរសីលាចារ ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល ដល់សួគ៌ពុំស្បើយ ៗ ពិដោរផ្កាបី តែកលែងក្លិនក្បិ ឥតងលែ្ហល្ហើយ ដោយខ្យល់ច្រាសខ្យល់ នៅត្រៃយទួងត្រៃយ ពិដោរពុំស្បើយ ហៅសេគន្ធា ពិសាផ្ទៃប្រាំ ៗ ពិសារសេធមិ

ពិសាសត្យ ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសាសេក - ចាចេញ
មធូរ ៗ ពិសាផ្លែប្រាំ គិតជានាយនាំ ឥន្ទ្រិយទៅចូល ត្រីពិធសម្បត្តិ
ចិត្តតែងអនុកូល បំណោរទៅចូល មោក្ខមគ្គាល័យ ៗ ធម៌នេះជាច្បាប់
ប្រសើរមហាគាប់ ឧត្តមពេកក្រៃ ក្រអ្នកណាបាន ប្រាជ្ញ ឈ្លាសវៃ
អាចដឹងដោយន័យ សេធម៌គាថា ៗ គួរបេះគួរចាំ គួរតាមបណ្តាំ ទូល
ទុកសិរសា ធម៌នេះស្មើត្បូរ អម្រឹតឆាក់ សម្តេចគត់ សាធុប្រាស់
ប្រាណ ៗ អ្នកណាបានស្តាប់ អ្នកណាបានត្រាប់ អ្នកណាបានធ្យាន
សេធម៌នេះគាប់ ជាច្បាប់ទូន្មាន អ្នកនោះស្មើបាន ដល់និព្វានហោង ៗ

ចប់ច្បាប់ភជនេតិ តែប៉ុណ្ណេះ ។

ច្បាប់បណ្តាំបិតា

បទកាកគតិ

នេះបទកាកគ- តិទើបចង់ជា ច្បាប់ច្បាស់ខ្ញុំនាំ តាមដោយ គន្លង ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោកទិតាន ប្រដៅបុត្រា ។ ហៃ កូនពន្លក ស្ងួនអើយចាសយក បណ្តាំបិតា អាពុកនេះចាស់ ក្រែតអ្វី ឲ្យបា ស្ងួនអើយរក្សា ពាក្យអាពុកនៅ ។ ឱកូនកំសត់ រៀនទុន រៀនអត់ រៀនគិតក្នុងក្រៅ រៀនទុនលំទោន កុំឲ្យអាសោ- ហ្មងដល់ ខ្លួនទៅ កេរ្តិ៍ដល់អាពុក ។ ដឹងខ្វួយជ្រួតជង កូនសោតវង្គង់ ជ្រួតតែអាពុក ទ្រព្យគង់ជ្រួតស្រី បេះរៀបដាក់ទុក ប្រាសដេកធាប់ លក់ ជ្រួតឥតបើគិត ។ ចំណេះទាំងឡាយ កិច្ចកលដោះស្រាយ ជ្រួតតែគំនិត ដឹងកិច្ចដឹងកល ដឹងឆ្ងាយដឹងជិត ដូចកលកាំបិត កាប់ ធ្លាទំលាយ ។ ល្មមទៅល្មមទាន ល្មមដើរបំពាន ពុំគិតត្រង់ឆាយ ល្មមឈប់បង្អង់ ល្មមទាននៅកាយ ក្តីក្រកុំស្រាយ ក្តីឆាយកុំធ្វេស ។ ស្ងូវដើរកុំដេក ស្ងូវឈប់កុំត្រែក សេចក្តីប្រហែស ស្ងូវទានកុំពារ ចិត្ត ចង់ចបេស ស្ងូវចូលកុំចៀស រាសរួបសិមគួរ ។ លឿនកុំបំបោល ពាក្យព្រេងកុំចោល ខឹងកុំមួមួរ ស្រាយចេញឲ្យធាប់ កុំទុកឲ្យបេរ្វូ សេចក្តីមធ្យួរ ទឹងដឹងខុសត្រូវ ។ ដេកកុំដំណើច គេក្រកុំសើច គេភ័យ កុំព្យួហ៍ គោះទឹងប៉ុន្មាន ធ្វើជាឲ្យគួរ គឹងគិតឲ្យធ្ងួរ យូរគិតឲ្យធាប់ ។

សេចក្ដីសំរុង ពាក្យដើមពាក្យចុង ប្រកាន់ឲ្យខ្ជាប់ សូវទៀងឯខ្លួន កុំឲ្យបង់ទ្រព្យ សូវបង់ក្ដីតាប់ កុំឲ្យខ្លួនស្លាប់ ៗ សូវស្លាប់ទៅជា កុំបង់ធម្ម ឥរិយាសីលតាប់ ឲ្យគិតជញ្ជីង រំពឹងឲ្យសព្វ ពាក្យស្លូតកុំស្រូប ពាក្យតាប់ឲ្យយក ៗ ចង់គង់ឲ្យទុក បង់បានក្ដីសុខ ឲ្យស្លូតដើររក ឃើញច្បាប់ធម៌គាថា ឲ្យយកខ្លួនជែក ក្ដីសោកប៉ះម៉ោក ឲ្យចៀសចេញ ឆ្ងាយ ៗ កូនអើយលោកឃ័យ នេះឲ្យរៀនក្ដី រៀនច្បាប់ទាំងឡាយ រៀនតាំងសំដី កុំប៊ុកយមាយ ក្ដីក្រក្ដីងាយ ក្ដីគួរក្ដីសម ៗ ទុកកូនចាំណា ធម្មតាអ្នកជា ឲ្យរៀនថែទាំ រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរករៀនសម លក់ចេញទិញចូល ៗ មួយសោតឯច្បាប់ បើបានមានទ្រព្យ មនុស្សផងមកមូល ពឹងពាក់ប្រាណណា ចាំយកប្រមូល សន្សំផ្សំចូល យកមកជាគ្នា ៗ កូនអើយឯម្លប់ មនុស្សផងចូលពប់ សម្រាន្តអាត្មា ព្រោះឈើមានម្លប់ ត្រសុំសាខា ម្ដេចឡើយបែរជា ក្ដៅជ្រកពុំបាន ៗ មនុស្សផងវិលង៍ រកម្លប់ទៀតហោង ចូលចតសម្រាន្ត ម្លប់នោះត្រជាក់ ត្រសាក់ក្សេមក្សាន្ត មនុស្សផងចូលថ្កាន មិនមានហៅអាក់ ៗ ឧបមាដូចទឹក ជ្រាលជ្រៅពន្លឹក ជាទីសំណាក់ មច្ឆាមច្ឆា ចេញចូលពឹងពាក់ ព្រោះទឹកត្រជាក់ មិនមានហ្វូងសៅ ៗ ពុំគិតឡើយហោង ឯទឹកនោះសោត ម្ដេចបែរជាក្ដៅ មច្ឆាទាំងឡាយ ត្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ ពំនាក់អាត្មា ។ ៗ កូនអើយបើល្មោះ អសោចកេក្ដិ៍នោះ ត្រូវ

ត្រង់ខ្នងបា ព្រៀងលានទាំងឡាយ គេនឹងនិន្ទា តំនៀលដៀលថា
បាឯងពុំចេះ ៗ អំបូរឥតប្រាជ្ញ អំបូរទាំងឥរិយា យោបល់ចំណេះ
អំបូរទាំងមារយាទ អំបូរទាំងត្រមិះ ដ្បិតបាឯងនេះ ពុំចេះរក្សា ៗ
គុណនាដូចទឹក កូនអើយបើល្គឹក ពុំមានមញ្ញា មួយគ្រាន់ពន្លៀក នៅ
កុងគង្គា ពុំពប់ហៅជា ប្រសើរឡើយហោង ៗ មួយសោតអ្នកណា
គេមកប្រាប់ថា បទបាធ្លើឆ្គង បាគិតជញ្ជឹង រំពឹងដើមទង កុំបាកែង
គោង ក្អេងក្អាងពុំស្ដាប់ ៗ ទូកហួសកំពង់ ករែបង្អង់ ថយមកចូល
ចាប់ ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់ ពុំបាន
ឡើយណា ៗ អង្គុយហួសស័ក្ដិ ស្រដីហួសថ្នាក់ បង់បោយហួស
ស្នា ពុំមើលប្រមាណ ទំនងប្រាណអាត្មា ហាហួសចង្កា ថាហួស
សេចក្ដី ៗ រីឯកន្ទប មុខដូចគោពេប ហាឡើងស្រដី អួតឯង
កំឡាំង ផលទឹងដំរី តោះទាំងរាជសីហ៍ ក៏អញពុំខ្លាច ៗ មួយសោត
ចចក ដកកកក់ អួតឯងអំណាច ទំនងដែកប្រពី ទៅទាំនាគរាជ
ដណ្ដើមយករាជ្យ កូមិកពនាគា ៗ រីសត្វអណ្ដើក ពារឡើងរើក មក
អួតអាត្មា ថាអញទំនងលោក រំលងបព្វតា ហោត្តក៏មោហា ពុំដឹងខុស
គាប់ ៗ រីឯគង្គក់ លោតឡើងពីកក់ ម៉េបេទៅគួរស្អប់ អួតខ្លួនថា
ល្អ ដូចមាសទឹកដប់ ពងអញចំប្រប់ ដូចពជស័ហា ៗ ហាឡើង
មិនច្បាន. ស្ដីមិនប្រមាណ ទំនងប្រាណអាត្មា ស្មូវគុនកុំផើប ស្មូវ

ស្ងៀមកុំថា ស្ដីវែងកុំយារ ស្ដីកាប់កុំឆ្ងុស ៗ នឹងកូនពន្ទក ច្បាប់
នេះចូរយក ស្ងួនកុំប្រមាស ច្បាប់នេះប្រសើរ ហើយមហាពិសេស
កូនអើយកុំភ្លេច នឹងច្បាប់នេះណា ៗ មួយសោតឯល្បែង សប្បាយ
ចង់លេង នឹងមានគយា នឹងកើតទុក្ខក្រោយ នឹងចង់ទ្រព្យ នឹង
កើតទិដ្ឋា បង់មារយាទគាប់ ៗ សប្បាយធ្វើស្រែ ចម្ការជួញប្រែ
នោះមានគេគាប់ សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយ
នោះគាប់ សប្បាយយឺនយូរ ៗ មួយសោតឯស្រី ចេះលើកយសប្ដី
ចេះគិតចេះគូរ ចេះរៀបចេះចំ ចេះសមចេះគួរ អ្នកជននឹងសួរ កេ
ឈ្មោះពុំខាន ៗ នាងនេះឈ្មោះល្អ បុរុសចាត់ប្រិមប្រិយ សមជាអ្នក
មាន ម៉្លោះហើយនឹងកើត ទ្រព្យផងពុំខាន ព្រោះពាក្យសន្តាន
ព្រៀងលានគេទាយ ៗ រីឯពាក្យមនុស្ស ពុំដែលនឹងខុស ហួសពីទំនាយ
ពុំដែលនឹងល្អៀង មិនជិតមិនឆ្ងាយ អ្នកផងទាំងឡាយ គួរគិតកុំធ្លល់ ៗ
ពាក្យព្រេងលោកថា លោកមានឧបមា ឲ្យគិតឲ្យយល់ ពាក្យលោក
ទំនៀម មិនមានឲ្យសល់ កូនអើយកុំធ្លល់ នឹងពាក្យនេះណា ៗ កុំ
អួតកុំអាង ដើរកុំមើលកង មើលអង្គកត្នា កុំដើរផ្ទះគេ ហួសពេល
វេលា កុំទៅជានា ទ្រព្យគេទាំងឡាយ ៗ កុំដេកផ្កាប់មុខ កុំដើរ
ពានថ្កុក ថាឯងសប្បាយ មានទោសនឹងគេ កុំឲ្យនិយាយ ដើមគេ
នឹងក្រោយ កើតទោសទៀតធំ ៗ ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង

ប្រាំឱបក្នុ ចាស់គោរកាន់ប្រាំ អ្នកអានប្រាំ ក្រអ្នកផ្ចុំ ប៉ុពោកយក
ខ្យល់ ៗ ទ្វាក់ឆ្ទុរកញ្ចក់ ផកកក្លក់ ហាក់ឯងមើលយល់ ទ្វិនអ្នក
នឹងផ្ទះ រលងលើគល់ ខំពែករកកល បង់បានប្រែងលាប ៗ ក្លែង
បង់កំ ក្រោកឡើងទន្ទាំ កែងកោងអាបឡប ថ្ងង់បង់ស្លាប់ប្រៀង
ផ្ទៀងផ្គងអាបឡាប ចែតូចខ្លួនទាប បង់ឈោងចាប់ផ្កាយ ៗ កូន
អើយចូរស្តាប់ ពាក្យនេះមហាគាប់ គ្រប់គ្នាទាំងឡាយ បាគិតពឹង
ផញ្ចឹងឲ្យឆ្ងាយ កុំធ្វើកយមាយ នឹងច្បាប់នេះណា ៗ មួយសោតគេ
ប្រាប់ ថាបាពុំគាប់ ទោសដល់អាត្មា កុំបាភិតភាំង ស្លុតស្មាំងកាយោ
ប្រាណប្រឹងសរិយោ ស្មារតីឲ្យនឹង ៗ វិរកតំនិត ផ្ចិតយោបល់គិត ទង់
ទាញសន្ទឹង ប្រាជ្ញជួយកាត់ ចាត់ឡើងឲ្យដឹង បំណោះមួយរឹង ធ្វើ
ហាក់មិនក្លក ៗ កូនអើយលោកថា ពាក្យលោកឧបមា ដូចគជសារសឹក
គាំភ្លើងដៃជុំ ពុំផែលនឹងក្លឹក បេញជួញគតឹក គគុកបោលចូល ៗ
ធម្មតាអ្នកជា អ្នកមានប្រាជ្ញ សន្តានត្រកូល ឲ្យគិតឲ្យដឹង រំពឹង
ឲ្យមូល ប្រាជ្ញឲ្យចូល ចងចាំទុកនៅ ៗ កុំអួតកុំអាង កុំកូតបំព្រាង
កុំឲ្យបែបប្លូវ កុំកាចកុំកិន រអែរអ្វរ កុំនាំពាក្យទៅ ប្រាប់ឲ្យកើតទោស ៗ
កុំវៀរកុំវៀន កុំបៀតកុំបៀន កុំស្តីគោសមោស គ្នាបានជាខុស ឲ្យ
មានសន្តោស កុំហាឲ្យហួស ផ្ដួសពាក្យទៅមុន ៗ ចូលសឹកកុំញោច
ដំពាក់កុំះបាច ខ្ជិលកុំបង់ពន្ធ ជាគ្រូអាត្មា កុំឲ្យលោកអន់ សេចក្តីទម្ងន់

សន្សឹមកុំបោល ៗ កុំអួតកំឡាំង កុំអាងខ្លួនខ្លាំង រត់ទឹងស្រមោល
កុំអាងជាធំ កុំដាយពាក្យរោល ពាក្យព្រៃកុំពោល កុំថ្កោលទោស
សង្ស ៗ កុំពោលផ្លូវវៀច កុំអាងអំណាច ដើរកាត់ជម្រង់ ក្រែង
បង់ភរិយា ស័ក្តាពុំគង់ លោកហៅជាល្ងង់ អាប់អស់ប្រាជ្ញា ៗ កូន
អើយចូរស្តាប់ ពាក្យមួយមហាគាប់ មានចិត្តស្នេហា ឲ្យមើលមារយាទ
មើលសព្ទភរិយា ឲ្យដឹងថាជា ជាក់ជាប់វៀចត្រង់ ៗ ឲ្យសមឲ្យស្ងួន
ឲ្យល្មមទឹងខ្លួន ឲ្យដួនទឹងអង្គ សឹមយកជាមិត្ត បិតថេរដ័លង់ ទៅ
មកជម្រង់ ចេញចូលស៊ីចុក ៗ មិត្តមួយសោតណា ទៅមកកាន់គ្នា
បង្កើតឲ្យសុខ មិត្តមួយឲ្យទោស បង្កើតជាទុក្ខ មិត្តមួយឲ្យធុក ឲ្យ
បង់ទ្រព្យា ៗ មិត្តមួយបង្អិទ ទៅមកខ្លាទ់ៗ ជក់ប្រាំស៊ីស្លា ចុះ
ឡើងអស់អាក់ ទឹងហិនអាត្មា កូនអើយលោកថា អសារបង់ទ្រព្យ ៗ
ទុកូនពិស័ កូនប្រុសកូនស្រី ស្ងួនអើយចាស្តាប់ ទំនិមទំនង គន្លង
ផ្លូវច្បាប់ ទុកជាសណ្តាប់ ខែនរេនជាតិ ៗ មួយសោតលោកថា
ម្យកក្នុងអាត្មា មានបីពុំឃ្លាត មួយស៊ីមួយដេក មួយដើរជាខ្នាត ស៊ី
អតមារយាទ ពុំត្រូវសណ្តាប់ ៗ ដើរឥតបើគិត ដើរឥតគំនិត ហៅ
ខុសទឹងច្បាប់ ដេកដល់ថ្ងៃរះ ហៅឥតគំនាប់ ចង្រៃអកុត្ញ ទឹងអាប់
អាត្មា ៗ ទឹងស្មូនកេទ្រព្យ ចង្រៃអកត្ញ មិនឲ្យដំនា ឲ្យកើតតែទុក្ខ
ឲ្យបង់ទ្រព្យា ទឹងរេកភរិយា ហាក់ដូចគេណាយ ៗ ព្រោះក្តីអកត្ញ

ចាំផ្ទែនូវអាប់ អពមង្គលទាំងឡាយ ចូលក្នុងអាត្មា មិនមានទៅឆ្ងាយ
ជ្រោមជាប់ក្នុងកាយ ក្នុងអង្គអាត្មា ។ ទោះប្រុសទោះស្រី បើមាន
ឫកពី ដូចច្បាប់លោកថា ឫកដេកឫកដើរ ឫកស៊ីអាហារ ជាអ្នករក្សា
ឥរិយាមារយាទ ។ ខ្វាចៈមខ្វាចបា ទោះបីធ្វើការ មិនមានឲ្យឃ្លាត
ទោះបីនឹងសើច នឹងលេងមានខ្នាត ជាអ្នកសង្វាត ខំឃ្មាតធ្វើការ ។
អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយល់ឥរិយា គេយល់ចំណេះ
ជាអ្នកស្ងៀមស្ងា គេចង់ចងជា ពន្ធយកជាញាតិ ។ មានទ្រព្យពុំគិត
យកតែគំនិត យកតែរបៀប ឲ្យរេះរៀបចំ ទុកជាក់ជាខ្នាត ឧស្សាហ៍
សង្វាត រក្សាទ្រព្យ ។ រីម្តាយឪពុក នឹងបានលើកមុខ ដោយ
កូនពុំឆ្គា ទាំងអស់បងប្អូន ដីដូនដីតា ម្តាយមីងនូវមា សឹងស្រួល
ចូលចិត្ត ។ ដ្បិតកូនសុភាព ជាអ្នករាបទាប ត្រូវនឹងគំនិត គ្រប់
អស់បងប្អូន ទោះឆ្ងាយទោះជិត សឹងបានដូចចិត្ត ដូចដួងចិន្តា ។
កូនអើយចូរស្តាប់ ចូរចាំឲ្យខ្ជាប់ ទុកក្នុងអាត្មា ទំនៀមទំនង គន្លង
ឧបមា ទើបចងវែងជា បទព្រហ្មគីត ។

កូនអើយស្ងួនតែមួយ ទុកជាត្រួយគំនិត កូនអើយមាសតាំងចិត្ត
តាំងចរិតគិតកុំធ្លល់ ។ ធម្មតាកើតជាមនុស្ស ទោះស្រីប្រុសគិតឲ្យដល់
ពាក្យលោកតែងខ្វាយខ្វល់ ជាបឋមចប់ម្ល៉េះហោង ។

ចប់ច្បាប់បណ្តាំបិតា តែប៉ុណ្ណោះ ។

ច្បាប់ហៃមហាជន

បទព្រហ្មគីត

ហៃមហាជនសប្បុរស ពោះស្រីប្រុសគប់កិរិយា គួរគិតយកប្រាជ្ញា
បង់ចាំច្បាប់ជាគន្លង ៗ មានច្បាប់ពីបុរាណ លោកខ្ញុំនាទៀងទុកឲ្យ
ជនជាតិនៅឯក្រោយ បង់ចាំច្បាប់ទុកគ្រប់ប្រាណ ៗ ធម្មតាអ្នកចិត្តល្អ
ពុំដែលក្រខ្សត់ប៉ុន្មាន ទេត្រាជាប្រមាន តែងចម្រុងចម្រើនឲ្យ ៗ បើ
ធ្វើចិត្តអាក្រក់ ដើរលួចឆក់លោកសៅហ្មៅ ទ្រព្យនោះណាបាត់ទៅ ដូច
អគ្គីឆេះពេលកល ៗ ទេត្រានឹងផ្ទួន ឲ្យវេទនានៅកណ្ដាល នរកទុក្ខ
អម្បាល លំបាកណាស់ណាអ្នកអើយ ៗ សម្បត្តិគង់លោកីយ បរលោក
ក៏ពុំគ្រាសៀយ ទុក្ខច្រើនពេកណាស់ហើយ តែងនឹងនរកកម្មវេរា ៗ បើ
បង់ឲ្យបានសុខ ឲ្យរកគន្ធចិន្តា ខិតខំពិចារណា នឹងបរហាមានមេត្រី ៗ
បើចង់បានជាធំ នោះឲ្យចំរៀនសេចក្ដី ឲ្យច្បាស់តាមបាលី កេរ្ដិ៍គម្ពីរ
ច្បាប់ធម៌ថា ៗ កុំអាងតែសក្តិបុណ្យ ចិត្តលោភលន់លើសមាត្រា រី
បុណ្យនោះអសារ ទ្រព្យធនណានឹងអន្តរាយ ៗ បេះចាំគុណសេចក្ដី មាន
មេត្រីពាក្យបរិយាយ មេត្តាអ្នកទាំងឡាយ អ្នកនោះនឹងជួយឲ្យតារ ៗ
កុសលនោះទ្រទ្រង់ ជួយឲ្យគង់សក្តិយសល្អ នោះនឹងចូលអាគារ ទ្រព្យ
ធនមកពីជិតឆ្ងាយ ៗ បើកាន់ទំនាប់ដោយធម៌ សក្តិយសល្អពេញ
សប្បាយ ទ្រព្យធនធានទាំងឡាយ ទុកឲ្យកូនចៅបាន ៗ គួរគន់

គិតរំពឹង រិះជញ្ជឹងមើលប្រមាណ កុសលព្រេងនោះមាន ទីពឹងទំហូរពេក
អម្បាយ ៗ ច្បាប់ធម៌ពីបុរាណ មានទំនាងជាបរិយាយ គម្ពីរចាស់
ចែងចាយ ទូន្មានមកទុកឲ្យស្តាប់ ៗ កុំទំហួសសាសនា កុំបោះបោល
ឯច្បាប់ កុំប្រឹងបោលសណ្តាប់ កុំបន្ទប់បោលឯខ្លាត ៗ ធ្វើអ្វីគួរឲ្យគិត
មើលពិនិត្យដោយបទបាទ គប្បីឲ្យសង្វាត កុំឲ្យខាតប្រយោជន៍ខ្លួន ៗ
ទៅមុខប្រយ័ត្នក្រោយ កុំឲ្យធ្លោយគិតឲ្យមួន ការអ្វីមើលឲ្យធ្មួន ឲ្យត្រូវ
ដូនទឹងរកការ ៗ កុំអាងថាខ្លួនចេះ អ្នកបំណេះមានប្រាជ្ញ ឲ្យដឹង
ពិចារណា ត្រិះត្រាវខ្វល់តូចធំ ៗ រកឯជាតិនេះនែ ទោះប្រុសស្រី
ឲ្យគួរសម ទើបបានធ្វើជាធំ និយាយលើគេនោះបាន ៗ ដូចអគ្គព្រះ
អាទិត្យ មានបុទ្ធីជាប្រធាន ពន្លឺក្លឺសព្វស្ថាន នោះពុំមានបន្ទោះ
ឡើយ ៗ គិតឃើញគួររំពឹង កុំស្ងៀមឈឹងឈប់ព្រងើយ កុំស្ងៀម
ធ្វើកន្តើយ ខ្លួនធំហើយត្រូវត្រួតត្រា ៗ បើស្ងៀមពុំរិះគិត ទឹងងងឹត
ដូចយប់ណា ឆ្ងាយផ្ទះខុសខ្វបការ រីទោសាជិតដល់ខ្លួន ៗ ហេតុតែ
ពុំពិនិត្យ ដោយសុចរិតតាមច្បាប់ក្បួន ផ្ទះឆ្ងាយឲ្យខ្ចប់ខ្លួន នេះនែដូន
ដូចព្រឹក្សា ៗ ដើមឈើដុះក្នុងព្រៃ តូចធំក្តីច្រើនត្រៀបត្រា ឲ្យផ្ទែ
នៅដោយសារ គិតខុសការខ្លួនអប្រិយ ៗ ផ្ទែតគអសុរស ដូច
មនុស្សគ្រឡត្រីយ រតែរតឲ្យមានភ័យ គាប់អន់អស់អគ្គរូបា ៗ បើ
ស្តីឲ្យពិនិត្យ ពាក្យណាពិតសឹមចរចា កុំចាត់ដោយមុសា កុំពាលោ

ដោយច្បាប់ក្បួន ៗ រក្សាកេរ្តិ៍មារយាទ កុំឲ្យឃ្លាតនៃសណ្ដាប់ មាន
គន្ថគម្ពីរស្រាប់ គួរទំនៀមរក្សាខ្លួន ៗ រក្សាអស់ទ្រព្យធន យសស័ក្តិ
បុណ្យឲ្យមាំមួន ដោយតេជតេជះខ្លួន កេរ្តិ៍គម្ពីរទុកទូន្មាន ៗ បើចង់
ធ្វើមេបា ឲ្យឧស្សាហ៍នៅភូមិស្រុក ចង់បានប្រាណស្រណុក ច្បាប់
ចង់ទុកឲ្យរៀនគិត ៗ បើបានការស័ក្តិយស ចិត្តឲ្យស្មោះនឹងមហាក្សត្រ
បើចង់គង់សម្បត្តិ ច្បាប់លោកថាកុំស្ងួតចាយ ៗ បើចង់ធ្វើជាហោរ
ឲ្យរៀនគូរលេខទំនាយ ចង់សងគុណតាំងឡាយ បើនិយាយឲ្យបរមត្ថ ៗ
បើចង់ឲ្យបរិសុទ្ធ ឲ្យលំអុតកេរ្តិ៍មារយាទ បើចង់រក្សាញាតិ កុំឲ្យឃ្លាត
ទីប្រតិបត្តិ ៗ បើចង់ឲ្យបានសុខ ចៀសចាកទុក្ខឲ្យអំណត់ បើស្ដីរ
តាមបទ បើឃើញពុតកុំក្រេវក្រោធ ៗ សន្ដានទៅកន្ទស្រុក អំពល់
ទុក្ខកុំពិរោធ គង់តែគេនឹងគោត ខ្លាចអំណាចអំណត់នោះ ៗ បើចង់
ឲ្យអប្រិយ បង្កើតក្ដីការក្រក់ឈ្មោះ បើចង់ឲ្យត្រូវខ្មោះ នោះឲ្យគិតធ្វើ
ជាហោរ ៗ សេចក្ដីនេះមានច្រើន រាប់យេពាន់កន្ទនគរ និទានច្បាប់
ទុកមក គ្រាន់តែមើលដឹងសេចក្ដី ៗ ឲ្យគិតពិចារណា ដោយប្រាជ្ញា
ញាណពន្លឺ ត្រិះរិះអធ្យាស្រ័យ គួរឲ្យគិតក្រោកកាយ ៗ រីលោក
មានស័ក្តិយស បុណ្យខ្ពង់ខ្ពស់ធំទូលាយ អ្នកតូចកុំមើលងាយ កុំថ្លឹម
កាយនឹងលោកឡើយ ៗ បើស្ដីឲ្យមានក្រែង កុំផ្ទង់ផ្ទល់ពាក្យលោក
ឡើយ គតបន្ថែមរឿយៗ មានទោសហើយខ្លួនកស្រូវ ៗ ដូចអ្នក

បេះពុះខុស ពុំដែលខុសសុទ្ធតែត្រូវ ខុសសាញដូចម្ដេចក៏ ត្រូវដដែល សឹងវែកបាន ។ ហេតុនេះគួរប្រយ័ត្ន តាមព្រះត្រិត្យធម៌ទូន្មាន កុំបី ធ្វើបំពាន រក្សាប្រាណកុំបីធ្លោយ ។ បើទឹងដូចម្ដេចក្ដី ប្រឹងស្មារតីកុំ ឲ្យធ្លោយ ទឹងនោះទឹងខុសក្រោយ ទឹងនោះឲ្យមានទោសា ។ ទោស ឲ្យបង់ស័ក្តិបុណ្យ បង់ទ្រព្យធនបុត្រភរិយា មានកាលក្ស័យជន្មា ដល់ អាត្មាសោតសឹងមាន ។ បីដូចសត្វមមាច កាន់ចិត្តកាចទ្រុស្តសាមាឲ្យ ហិនហើរដល់ពុះពាន ព្រះអគ្គីនេះឆាប់ក្រៃ ។ ហេតុនោះគួររិះគិត គួរបួលចិត្តកុំសង្ស័យ គួរប្រឹងប្រុងស្មារតី តាមវិន័យច្បាប់ធម៌ថា ។ ទោះផ្ដាំព្រះមហាក្សត្រ ទាំងព្រាហ្មណ៍ព្រឹទ្ធទូវយោធា ទោះផ្ដាំព្រះមាតា ព្រះបិតាជាប្រធាន ។ ឲ្យដឹងកលកិច្ចការ បើអធ្យាស្រ័យប្រមាណ បើលោកព្រះទ័យក្សាន្ត មានសេចក្ដីសុំចរចា ។ កលមួយលោកនិយាយ អ្នកផិតធ្លាយពីពដការ ស្ដីលេងក្ដីណា កុំចរចាកាន់លោកឡើយ ។ ទោះបើលោកសប្បាយ ឈប់និយាយនោះស្រេចហើយ តាមហេតុនោះ អ្នកអើយ កុំចរចាការអ៊ឹ ។ មួយលោកនឹងស្ដីផង ចូរចាប់ចងចាំសេចក្ដី កុំឲ្យភ្លេចឡើយនៃ ពាក្យបណ្ដាំគ្រប់ប្រការ ។ មួយបើគ្រូបាធ្យាយ ឪពុកម្ដាយទូវយោធា ព្រះមហាក្សត្រក្ដីណា លោកមានការជាក្រឆាយ ។ លោកប្រើឲ្យទៅមើល សត្វសារពើការទាំងឡាយ ទោះការនៅជិតឆ្ងាយ គួរពិនិត្យមើលឲ្យជាក់ ។ ឲ្យដឹងការវែងខ្លី តូចធំក្ដីទោះមាសប្រាក់ ពិនិត្យ

មើលឲ្យជាក់ ក្នុងបញ្ជីជាចំណាំ ៗ ទោះបីឥតជំណាន់ ការពុំដឹងភ្លេចពុំចាំ
ទោះនឹងធ្វើជាធំ ស្តីលើគេពុំបានឡើយ ៗ បើដឹងការកលកិច្ច ចាំពុំភ្លេច
គុណវិញ្ញាណ ទើបធ្វើជាធំបាន ហេតុដោយមានមារយាទល្អ ៗ បើ
លោកមានគ្រោះក្រាច ស្តីពិរោធខឹងរឹករះ ជេរពោលបន្ទោសមក
តាមដំណើរដែលខ្លួនធ្វើ ៗ កុំប្រឹងតបតទ្វង ធ្វើយសាសរសេរក្តីដំណើរ
ពាក្យពេចន៍សព្ទសារពើ ប្រឹងប្រកែកដណ្តើមឈ្នះ ៗ ប្រៀបដូចភ្លើង
ឆេះផ្ទះ ដំណើរនេះខំចំពោះ កុំខឹងប្រកែកឈ្លោះ ទឹកភ្លើងទោះពុំឈ្នះ
ឡើយ ៗ មួយដូចដំណើរខ្លួន អ្នកធំគួរមិនត្រាស់ឡើយ ដូចភ្លើងនេះ
ឯងហើយ គួរព្យួលចិត្តគិតបង្ខាំ ៗ គួរតែយកទឹកទៅ លត់ភ្លើងក្តៅ
តាមចំណាំ សោះលោកខឹងខ្លួនទាំ យកអំណត់ទើបលត់បាន ៗ
អត់ចាំលោកបាត់ក្រោធ ទើបពិកេណពុះស្រាកស្រាន្ត កុំថែមដោយដើម
ជាន ដំណើរនោះជាក់ក្រោយ ៗ លោកនឹងកោតជាពេះ មានចំណោះ
មិនភ្លេចស្តាយ លោកគិតអាណិតក្រោយ ឃើញដឹងដោយសេចក្តី
ត្រង់ ៗ លោកជាខ្លួនចេះអត់ មានអំណត់មិនល្ងីល្ងង់ នោះលោក
នឹងគម្រង់ ឲ្យគង់គេក្តីកើតសុខា ៗ ទោះបីលោកអាណិត ខំរិះគិតពិ-
ចារណា រិះរកថ្នាំថ្នា រក្សាខ្លួនដោយប្រក្រតីក្រម ៗ យាលោកជា
ទីពឹង ពាំទឹងលើលោកជាធំ គួរគិតឲ្យគួរសម ទោះផុតដើរទុក្ខយក្តី ៗ
ឲ្យមានចិត្តប្រតិបត្តិ គួរប្រយ័ត្នប្រុងស្មារតី ទោះទ្រព្យលោកបោកថ្លៃ គង់

រីតែមើលរក្សា ៗ ខ្លួនពឹងលើលោកហើយ កុំព្រងើយប្រហែសការ ប្រយ័ត្នប្រុងប្រាជ្ញ តាមសណ្ដាប់ច្បាប់ប្រដៅ ៗ ប្រៀបដូចដើមឈើធំ វល្លិដុះជុំព័ទ្ធពីក្រៅ វល្លិស្អូមសំណាក់នៅ ដើមឈើនោះដុះខ្ពស់ឡើង ៗ វល្លិខ្ពស់ព្រោះគុណឈើ វល្លិព័ទ្ធលើនោះឯងហោង វល្លិរារព័ទ្ធទាក់ទង មានផ្លែផ្កាច្រើនក្រាស់ក្រៃ ៗ ឈើដូចលោកមានបុណ្យ វល្លិដុះពឹងពាក់ប្រស្រ័យ ដូចអ្នកតូចនោះវៃ គួរគិតកុំភ្លេចឡើយហោង ៗ បើអ្នកណាដឹងគុណ កុសលបុណ្យចំរើនឲ្យ បើភ្លេចគុណគេហើយ បាបផ្ដន្ទាឃើញថ្មីៗ ៗ បរលោកមើលមិនយល់ ឃើញដឹងគលគេក្ដីលោកិយ ដឹងគុណពុំភ្លេចក្ដី ដូចប្រុសស្រីដឹងស្រាប់ហើយ ៗ ហេតុនោះគួររេគិត រិះពិនិត្យកុំព្រងើយ កុំធ្វេសប្រហែសឡើយ គុណនោះស្មើយានជំនិះ ៗ ឈ្មួញទឹកពិតពឹងទូក រីឈ្មួញគោកពឹងរទេះ សំណាងពឹងចំណេះ ប្រាជ្ញប្រាយបេះពឹងគម្ពីរ ៗ ព្រះសង្ឃពឹងវិន័យ សត្វកពៃត្រពឹងធរណី សេនាពឹងឫទ្ធិ ឯអ្នកជីពិតពឹងវត្ត ៗ វីមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់ កិរិយាពឹងសំពត់ ឯបរិសុទ្ធពិតពឹងសីល ៗ សត្វត្មាតពិតពឹងរុយ សាច់សត្វស្អុយពឹងអម្បិល មង្គលការពឹងពពិល ក្រោសីលពិតពឹងទាន ៗ ទានមានគុណប្រសើរ ទោះទីងធ្វើបុណ្យសីងបាន ជូនឧទ្ទិសសព្វស្ថាន ផលបុណ្យខានដូចប្រាថ្នា ៗ រីទាននោះមានច្រើន កប់រយម៉ឺនក្នុងសីមា ក្រមានអ្នកឯណា ខឹងស្គាល់ទានឲ្យគ្រប់

ទៀត ។ ទោះបើអ្នកឯណា មានកំសត់ក្រោកដហើយ ប្រតិបត្តិតានជា ត្រើយ តាមទ្រទ្រង់តាំងភតាត្រៃ ។ ថាបើបានប្រតិបត្តិ តាមក្រោកដហើយ ប្រែត បំផុតស្ថានកែវថ្ងៃ វែកវែងនៅគង់ផ្លូងផ្កាល្អ ។ តាមជួយឲ្យបានសុខ រួចនរកបានសុខា សុខនៅលោកិយណា សុខដល់សួគ៌ទិព្វានហោង ។ តាំងតាំនាក់នៅ ពីងឲ្យត្រូវតាមគន្លង ពីងខុសទីងសៅហ្មង ទីងខាត ខូចខ្ទេចអន្តរាយ ។ ផែកស្រុកពិតពីងមនុស្ស ទុកចិត្តស្មោះថាសោយ យូរទៅកើតផលកាយ រងទុក្ខទល់ប្រាសព្រាត់គ្នា ។ មួយដូចគោគ្របី សេះដំរីខ្លួយមាន់ទា នៅនៃទីងមនុស្សា យូរប្រែជាសត្រូវផង ។ មាន កាលពរក់បម្រាស ឲ្យព្រាត់ប្រាសពីមេពង ផ្ទុនក្ស័យជីវិតផង ហេតុ បំណងខុសប្រាថ្នា ។ កន្ទ្រើបតិ៍ទ្ធក់ហ៊ុង អរឃើញគៀងស្រក់សស្រាក់ នាំគ្នាស្រែកព្រឹជាក់ ហោតលេងសាយកាលគៀងនៅ ។ លង់លុះដល់ គៀងកំង ដីវែងគាំងស្ទូតទាំងស្មៅ កន្ទ្រើបហ៊ុងកាសៅ ទេសាខទៅ ចាប់កំយធ៌ ។ កន្ទ្រើបហ៊ុងលាក់ខ្លួន ផែកពីងពួនក្នុងធរណី គេតាម តាំងចាប់ធី លុះជីវិតក្ស័ណក្ស័យហោង ។ ក្ស័យហេតុកូនតូចៗ ខុស ខាតខូចបង់តាំងពង ព្រាត់ព្រាយប្រាសហេតុរូង ជ្រិតទំស្រែកសស្រែក ខ្លាំង ។ ហេតុនោះគួររិះគិត ប្រុងគំនិតកុំភ័ន្តភាំង គួរយកព្រះធម៌តាំង ទូន្មានចិត្តតាមនិទាន ។ បើកាន់ចិត្តអាក្រក់ ដូចឈើពុកស្លឹកសព្វស្ថាន ពុកតាំបណ្តូលប្រាណ សឹងបាក់បែករែកហេតុដើម ។ ជ្រះស្លឹកជ្រះផ្កា

វែងវេទនាឃើញសម្បើម ហេតុនោះគួរឲ្យខ្ពើម ចិត្តអាក្រក់កុំទុក
ប្រាណ ៗ ទុកយូរបន្តិចទៅ ដូនក្រែងត្រូវតាមទិទាន ទឹងកើតក្តីវិនាន
កុំឲ្យប្រាណកេយរេចរស ៗ កុំកាន់ចិត្តឫស្សា កុំបរទាទោលសប្បុរស
ឥតទោសកុំថាខុស អ្នកចិត្តស្មោះកុំបញ្ឆោត ៗ ផ្គរលាន់ឮគក្រែង
កុំអួតក្អៀងថាជ្រុះមក ក្រែងខ្យល់ផាត់បក់បោក ត្រានពពកមេឃ
ស្រឡះ ៗ គិតការគួររំពឹង មើលសំឡឹងឲ្យជាក់ច្បាស់ គិតការកុំ
ទោលទាស់ ដូនក្រែងពាស់ទឹងខុសក្រោយ ៗ

បើផនជាតិឯណា មានកុសលបុណ្យលោកជួយ កាន់ច្បាប់ខ្ជាប់
មិនក្លោយ កុសលឲ្យបានសុខា ៗ ឲ្យបានសុខទាំងបី សុខលោកិយ
សុខសួគ៌ា សុខដល់និញ្វានណា ច្បាប់ធម៌ថាសុខស្រេចហោង ៗ

ចប់ច្បាប់ហៃមហាជន តែប៉ុណ្ណេះ ។

សេចក្ដីផ្សេងៗ

អំពីការរាំក្របីនឹងកាំពស់

នៅតាមភូមិឥណ្ឌៀប្រទេសអាមេរិក

នៅវេលាក្រោយៗ មកនេះ យើងបានមើលរឿងព្រេងមួយនៅស្រុកពោធិ៍សាត់ ដែលគេធ្វើបុណ្យលេងកំម្សាន្ត - អ្នករាំពាក់ស្នែងក្របីពីរនៅលើក្បាល ។ ឯពួកឥណ្ឌៀនៅទ្វីបអាមេរិក គេក៏លេងរាំមានក្បាលពាក់ស្នែងក្របីព្រៃស្គរអេគ្រឺនសំបកឃ្មោកខ្ចីងកោទស្លាបសត្វ ប៉ុន្តែការរាំដែលសំខាន់បំផុតនោះ គឺការរាំហៅក្រៀងដោយប្រើពស់ឲ្យរាំ គេតែងធ្វើពិធីរាំនេះក្នុងពីរឆ្នាំម្ដង នៅខែ ៗ ភូមិ ហើយគេលេងរាំនេះដល់ ៩ ថ្ងៃ ។ ពួកអ្នករាំតែងនាំពាំពស់ត្រង់ពាក់កណ្ដាលដងខ្លួនពាក់ ដើម្បីឲ្យក្បាលពស់នឹងកន្ទុយពស់ពន្លេះទៅមកជាទំនងរាំ ។

មុនដំបូងគេចាប់ពស់ដាក់ទៅក្នុងផ្ដុំកន្ត្រក រួចទើបគេយកទៅដាក់ក្នុងផ្ទាំង ឯពួកអ្នករាំនោះ ក្នុង ១ ពួកៗ មានពីរនាក់ក៏មាន ៣ នាក់ក៏មាន ហើយក្នុងពួកនីមួយៗ មានពស់រាំមួយម្នាក់ ។ ឯអ្នកដែលចាប់បានពស់ ១ ហើយ គឺនាំទីងខាត់រួចចេញទៅក្រមួយរំពេច ៗ ទើបអ្នកទីពីរក្នុងពួកនោះ ក៏យកស្លាបសត្វត្រដែដូរពស់ ។ គពីនោះបន្តិចអ្នកឯទាក់បំណក់ពីក្នុងមាត់ចេញមក អ្នកទី ៣ ក៏រើសរៀបគទៅទៀត គេធ្វើដូច្នេះជាច្រើនលើកច្រើនគ្រា ៗ លុះរាំរួចហើយ គេក៏វាក់ស្រ

ទៅជាជុំៗ មាន ៦ ជុំ ជាដំណាងទ្វីបទាំង ៤ ព្រមទាំងស្ពានលើនឹងស្ពានក្រោម លុះគេឲ្យសញ្ញាហើយ ពួកលោកសង្ឃអ្នកកាំក៏ស្ទុះចូលក្នុងវង់ភ្លាម ឈោងចាប់ពស់ឲ្យបានច្រើនបំផុតហើយរត់ទៅក្នុងភូមិ ដកបដល់គេលែងពស់អស់នោះទៅក្នុងទិសទាំង ៤ ។ កិច្ចធ្វើបុណ្យនេះ ដើម្បីប្រកាសប្រាប់ដល់ពួកទេវតាឲ្យបានដឹងថា គេធ្វើបុណ្យបន់ស្រន់សុំដល់ទេវតាជាមេភ្លៀងសុំឲ្យបង្អុរភ្លៀងចុះមក ។ តអំពីនោះមក គេក៏រង់ចាំមើលពពកនឹងបង្អុរទឹកភ្លៀងចុះមកឬទេ ។

អំពីការនេសាទត្រីទឹកសាប

នៅស្រុកខ្មែរ

នេះជាឈ្មោះរឿងមួយ ដែលគេបានបោះពុម្ពជាសៀវភៅមាន ២ ក្បាលក្នុងឆ្នាំ ១៩៤០ ជាភាសាបារាំងសែសមានរូបជាចំនួនច្រើននៅក្នុងសៀវភៅនេះផង ។ ឯបញ្ហារឿងដែលយើងស្រង់យកមកបង្ហាញនេះនាំឲ្យយើងមានគំនិតបេះពិនិត្យជ្រៅជ្រះអំពីរឿងដែលលោកអ្នកតែង បានពោលទុកក្នុងសៀវភៅនេះ ។ ឯសៀវភៅភាគទី ១ នោះនិយាយអំពី:

១) ទឹកលិចនៅទន្លេសាប, ទឹកជន់ក្នុងដងទន្លេនឹងដងស្ទឹង ព្រែកបឹងបួរទៅ ។

២) ត្រី – ត្រីមានប្រភេទផ្សេងៗ – ចំពូកត្រីដែលធ្វើជាជំនួញ- ត្រីជាត់ធំចំរើនឡើង – ត្រីដែលមានពងតាមរដូវកាល –

៣) ព្រៀងនេសាទត្រី - កន្លែងចាប់ត្រីក្នុងដែនទន្លេ - ក្នុងទន្លេសាប -

៤) ជំនួញត្រីស្រស់ - ជំនួញត្រីងៀត ជំនួញត្រីជាផលប្រយោជន៍ទី ២ ដែលបានមកពីការនេសាទត្រី ។

៥) ការជួលកន្លែងចាប់ត្រី - ការលួចបន្លំចាប់ត្រី ។

៦) សេចក្ដីសរុបបញ្ចប់និយាយពីការការពារកន្លែងចាប់ត្រី ។

ក្នុងសៀវភៅភាគទី ២ មានផែនទីសំដែងកន្លែងនេសាទត្រី នៅខេត្តព្រៃវែង, តាកែវ, កណ្ដាល, កំពង់ចាម, កំពង់ឆ្នាំង, ទន្លេសាប, និងបាត់ដំបង ។ ក្នុងវគ្គបញ្ចប់នៃសៀវភៅនេះ លោកអ្នកតែងបានធ្វើសេចក្ដីសំគាល់ទុកថា ប្រសិនបើមានចំនួនត្រីកាន់តែតិចទៅគឺពីព្រោះមានអ្នកនេសាទត្រីច្រើនឡើងលើសប្រមាណ ថែមទាំងពួកលួចចាប់ត្រីឥតបង់ពន្ធក៏ធ្វើឲ្យខូចខាតយ៉ាងសំបើមខាងរបរត្រីនេះផង ។ ប្រសិនបើត្រីថយតិចចុះទៅ ពីព្រោះតែការនេសាទមានញឹកញាប់ពេកហើយគួត្រីធាត់ធំពេញប្រម៉ាណទាន់ ដោយហេតុតែចំនួននេសាទកម្មចំរើនឡើងលើសលុបពេក ។ ដូច្នេះត្រូវទុករដូវមួយបញ្ឈប់នេសាទកម្ម ការពារឲ្យត្រីក្រាស់គួនតាមរដូវរបស់វា គឺត្រូវតែហាមដាច់កុំឲ្យមានការនេសាទត្រីតាំងពីថ្ងៃ ១ ខែយុ្កំងកល់ៗ ឆ្នាំរៀងទៅ កុំបើកឲ្យចាប់ត្រីរហូតដល់ថ្ងៃ ១៥ សេបតំប្រ៍ នេសាទកម្មនេះ ត្រូវធ្វើដូចរបៀបព្រៃឈើដែលរកការ

រក្សាទុក កុំឲ្យដើមឈើអន្តរាយអស់ទៅ ឯរបៀបនេសាទកម្មក្នុងការរក្សាពូជត្រី កុំឲ្យចាប់ត្រីដែលត្រូវហាម ក៏ត្រូវធ្វើឲ្យមានចំនួនដូចគ្នាដែរ ។

- ត្រូវបញ្ញត្តឲ្យប្រើប្រដាប់ក្នុងការនេសាទត្រីចំពួកខ្លះ ត្រូវហាមឃាត់កុំឲ្យប្រើប្រដាប់សំរាប់នេសាទត្រីចំពួកខ្លះ ។

- ត្រូវរៀបចំរបៀបលក់ត្រីងៀតចេញទៅប្រទេសក្រៅ ។

- ត្រូវចេះប្រើក្បាលត្រី ក្រពះត្រីគ្រឿងក្នុងពោះត្រីឲ្យមានប្រយោជន៍ឡើង ពីព្រោះគេអាចយកទៅចម្រាញ់យកខ្លាញ់ប្រើការបាន ហេតុនេះបានជាគេបង្កើតរោងម៉ាស៊ីន ១ នៅក្បែរទន្លេសាប ។ គេបានចាត់តាំងសមាគមជួយឧបត្ថម្ភអ្នកនេសាទត្រីនៅស្រុកខ្មែរ ដែលឲ្យពួកអ្នកនេសាទចងការប្រាក់និងចាត់ចែងលក់ត្រីផង ។

ឯរាជការអាណាព្យាបាលក្រុងកម្ពុជាក៏បានបង្កើតមន្ទីរសម្រាប់ល្បងវិទ្យាសាស្ត្រ ដើម្បីពិនិត្យសិក្សាអស់ទាំងប្រស្នាទាំងពួងនេះដែលជាប្រយោជន៍ដល់នេសាទកម្មនៅស្រុកខ្មែរនេះ ។

គ្រឿងជ្រលក់សំពត់

១ - មរ ឬហៅថាធ្លះ ធ្វើអំពីស្លឹកត្រម ជ្រលក់ទៅជាពណ៌ខៀវ-ខ្មៅ ។

២ – ក្បួន ធ្វើអំពិល្បូនដើមផ្ទី ផ្តល់នៅជាពណ៌ខ្មៅប្រផេះ ។

៣– មក្លឿ ផ្លែឈើបុកលាយទឹក ផ្តល់ ពណ៌ខ្មៅ ។

៤ – ព្រហូត សំបកឈើ ស្ងោរ ផ្តល់ ពណ៌លឿង ។

៥ – សំបកស្តាច់ សំបកឈើ ស្ងោរ ផ្តល់ ពណ៌ក្រហម ប្រផេះ ។

៦ – សំបកព្រីង សំបកឈើ ស្ងោរ ផ្តល់ ពណ៌ក្រហម ប្រផេះ ។

៧ – សំបកស្នែ សំបកឈើ ស្ងោរ ផ្តល់ ពណ៌ក្រហមជាំ ។

៨ – ស្បែង ខ្លឹមឈើ ស្ងោរ ផ្តល់ ពណ៌ក្រហម ។

៩ – ផ្លែផ្កុល បុក ផ្តល់ ពណ៌ខ្មៅ ។

១០– ខ្លឹមខ្នុរ ស្ងោរ ផ្តល់ ពណ៌លឿង ។

១១– មើមរមៀត បុកលាយទឹក ផ្តល់ ពណ៌លឿង ។

១២– ព្រះអង្កោល បុកលាយទឹក ផ្តល់ ពណ៌លឿង ។

១៣– ល័ខ ស្ងោរ ផ្តល់ ពណ៌ក្រហម ។

១៤– សំបកកណ្ដាល ស្ងោរ ផ្តល់ ពណ៌ក្រហមព្រឹក ។

១៥– ផ្លែជម្ពូទេស ស្ងោរ ផ្តល់ ពណ៌ក្រហម ។

ប្រវត្តិពួកឧបាសិកា

៣ — ខុជ្ជុត្តរា - ឧបាសិកា – ជាបុត្រីរបស់ស្រីមេដោះក្នុងផ្ទះឃោសកសេដ្ឋីនៅក្រុងកោសម្ពី ។ ប្រវត្តិសង្ខេបមានដំណាលដូច្នេះថា សម័យមួយព្រះដ៏មានព្រះភាគជាម្ចាស់ ស្តេចយាងទៅកាន់ទីនិមន្តរបស់នាយមាលាការ ជាអ្នកក្រងផ្កាថ្វាយព្រះមហាក្សត្រ ព្រះនាមឧ-ទេនក្នុងក្រុងកោសម្ពី ។ នាយមាលាការនេះឯងតែងក្រងផ្កាទៅថ្វាយព្រះនាងសាមាវតីជាព្រះអគ្គមហេសីព្រះបាទឧទេនរាល់ៗថ្ងៃ ឯនាងខុជ្ជុត្តរាតែងទៅយកផ្កាអំពីនាយមាលាការមកថ្វាយព្រះនាងរាល់ៗថ្ងៃ ។ ក្នុងថ្ងៃនោះនាងខុជ្ជុត្តរា ក៏បានទៅកាន់ផ្ទះនាយមាលាការ បានឃើញនាយមាលាការកំពុងអង្គាសព្រះបរមសាស្តា ទើបនាងចូលទៅជួយអង្គាសព្រះសង្ឃ លុះស្រេចភត្តកិច្ចហើយ នាងបានស្តាប់ព្រះធម្មទេសនារបស់ព្រះទសពល ក៏បានសម្រេចសោតាបត្តិផល ទើបនាងយកផ្កានោះទៅថ្វាយព្រះនាងសាមាវតី ហើយបានទូលអំពីការបានជួបប្រទះនឹងព្រះបរម-សាស្តា ហើយបានស្តាប់ព្រះធម្មទេសនាយ៉ាងពីរោះឲ្យព្រះនាងសាមាវតីទ្រង់ជ្រាបគ្រប់ប្រការ ។

ឯព្រះនាងសាមាវតីទេវី កាលបានស្តាប់សេចក្តីសារសព្វនេះ គួរតែទ្រង់ពិរោធក្រោធនឹងនាងខុជ្ជុត្តរា បែរជាទ្រង់បីតិត្រេកអរទៅវិញ ទើបមានព្រះរាជសវនីយ៍ ឲ្យនាងខុជ្ជុត្តរាសំដែងធម៌ឲ្យព្រះនាងទ្រង់ព្រះ

សណ្តាប់ ៗ នាងខុជ្ជុត្តរា ក៏សំដែងធម៌នោះ តាំងអំពីដើមរហូតដល់ចប់ ព្រះនាងសាមាវតីនឹងស្ត្រីបរិវារចំនួន ៥០០ នាក់ ក៏បានសម្រេចសោតាបត្តិផលព្រមគ្នា ៗ នាងខុជ្ជុត្តរា បានស្តាប់ធម៌ចំពោះព្រះភក្ត្រព្រះបរមសាស្តាតែម្តង ហើយនៅជាសេខបុគ្គល . តែអាចសំដែងធម៌បានដោយល្អរៀបរយ . អាស្រ័យហេតុនេះ ទើបព្រះបរមសាស្តា ទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងជាងឧបាសិកាដែលជាធម្មកថិកា ៗ

ចប់ប្រវត្តិសង្ខេបរបស់នាងខុជ្ជុត្តរា ឧបាសិកាតែប៉ុណ្ណេះ ។

៤— ព្រះនាងសាមាវតី រាជទេវី ជាធីតារបស់សេដ្ឋីម្នាក់ ឈ្មោះភទ្ទវតិយៈ នៅក្នុងដែនភទ្ទវតិយនគរ ៗ ព្រះនាមដើមថា "សាមា" កាលបានចំរើនវ័យឡើង ស្រុកភទ្ទវតិយនគរ កើតទុរ្ភិក្សអត់បាយ ហើយកើតជម្ងឺឆ្លងពាសពេញ បណ្តាអ្នកស្រុកស្លាប់ទៅជាចំនួនច្រើន ទើបភទ្ទវតិយសេដ្ឋីឃើញភ័យក្នុងអនាគត ក៏នាំភរិយានិងធីតារត់ចេញអំពីស្រុកនោះ ៗ ភទ្ទវតិយសេដ្ឋីនេះជាសំឡាញ់គ្នានឹងឃោសកសេដ្ឋី នៅក្រុងកោសម្ពីដោយមានផ្ញើរជំនូនទាក់ទងគ្នាទៅវិញទៅមក តែមិនដែលបានជួបប្រទះគ្នាផ្ទាល់ខ្លួនទេ ទើបសេដ្ឋីគិតរត់សំដៅទៅឯក្រុងកោសម្ពី ប៉ងនឹងទៅផ្ទះឃោសកសេដ្ឋីដែលជាសំឡាញ់របស់ខ្លួន គ្រាន់តែបានទៅដល់ស្រុកកោសម្ពី ក៏អស់ស្បៀងទើបប្រើនាងសាមាជាធីតា ឲ្យទៅសូមអាហារនៅ

រោងទាន របស់ឃោសកសេដ្ឋី ខណៈនោះ មិត្តកុដុម្ពិជាអ្នកចំណាយជំនួសសេដ្ឋី ៗ នាងសាមាក៏ទៅសុំអាហារ សម្រាប់ចំនួនមនុស្ស ៣ នាក់ មកជូនមាតាបិតា លុះកន្លងពីរថ្ងៃមកមាតាបិតានាងក៏អនិច្ចកម្មទៅ នៅតែនាងសាមាម្នាក់ឯង ជាជោគកំសនាមិនដល់ថ្នាក់រងទុក្ខលំបាកខ្លាំងពេក ទើបនាំឲ្យមិត្តកុដុម្ពិទទួលនាងទុកជាកូនធម៌របស់ខ្លួនតមក ៗ ឯនាងសាមាជាស្រីមានប្រាជ្ញាឈ្លាសវៃ ឃើញរោងទានដែលឪពុកធម៌តាក់តែងនោះ មានសូរសំឡេងកងរំពងរបស់ពួកស្មូម ទើបប្រាប់ឧបាយឲ្យឪពុកធម៌ធ្វើរបងព័ទ្ធជុំវិញរោងទាន ហើយធ្វើទ្វារចូលមួយ ទ្វារចេញមួយ សូរសំឡេងអឺកធឹកនោះក៏ស្ងប់បាត់ទៅ ៗ ឃោសកសេដ្ឋី មិនបានឮសូរសំឡេងនោះ ក៏ហៅមិត្តកុដុម្ពិមកសួរទើបបានដឹងថា មានធីតាម្នាក់ជាអ្នកមានប្រាជ្ញា ជាកូនសេដ្ឋីដែលជាសំឡាញ់របស់ខ្លួន ទើបឃោសកសុំយកនាងសាមាពីមិត្តកុដុម្ពិទៅចិញ្ចឹមទុកជាកូនធម៌របស់ខ្លួនវិញ ៗ ឯនាងសាមាតាំងពីបានចាត់ចែងឲ្យឪពុកធម៌ធ្វើរបងជុំវិញរោងទានរម្ងាប់សូរសំឡេងគោឡានោះ ក៏មាននាមថែមថ្មីឡើងទៀតថា សាមាវតី ៗ

នៅក្នុងផ្ទះឃោសកសេដ្ឋីនោះ មានស្ត្រីម្នាក់ឈ្មោះនាងខុជ្ជុត្តរា ជាកូនមេដោះនៅក្នុងផ្ទះនុ៎ះឯង មានអាយុស្រករគ្នានឹងនាងសាមាវតី ដូចមានប្រវត្តិដែលយើងបានពោលរួចមកហើយ ៗ

លុះចំណេរកាលតមក ព្រះកជាព្រះនាមឧទេន ទ្រង់គ្រងក្រុងកោសម្ពី បានទ្រង់សូមនាងសាមាវតីទៅតាំងជាព្រះអគ្គមហេសី ។

ក្នុងគ្រានោះ នៅក្រុងកោសម្ពីមានសេដ្ឋី ៣ នាក់ គឺឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ បាវារិកសេដ្ឋី ១ បានដឹងដំណឹងថា ព្រះសម្មាសម្ពុទ្ធស្តេចឧប្បត្តិឡើងក្នុងលោកហើយ ទើបនាំគ្នាចូលទៅគាល់ព្រះបរមសាស្តា ស្តាប់ព្រះធម្មទេសនាហើយបានសម្រេចសោតាបត្តិផល រួចត្រឡប់មកស្រុកកោសម្ពីវិញ នាំគ្នាកសាងវិហារថ្វាយម្នាក់មួយអន្លើៗ គឺឃោសកសេ-ដ្ឋីកសាងឃោសិតារាម កុក្កុដសេដ្ឋីកសាងកុក្កុដារាម បាវារិកសេដ្ឋីបានកសាងបាវារិកម្ពវន ។ សេដ្ឋីទាំងបីបានព្រមព្រៀងគ្នា ក្រាបទូលអារាធ-នា ព្រះបរមសាស្តាឲ្យស្តេចយាងចូលទៅកាន់ក្រុងកោសម្ពី ។

ព្រះដ៏មានព្រះភាគជាម្ចាស់ស្តេចយាងទៅកាន់ក្រុងកោសម្ពី ជាមួយនឹងភិក្ខុសង្ឃជាច្រើន កាលស្តេចយាងទៅដោយលំដាប់នោះទ្រង់បានជួបនឹងមាគណ្ឌិយព្រាហ្មណ៍ក្នុងពាក់កណ្តាលផ្លូវ ឯព្រាហ្មណ៍នេះមានកូនក្រមុំម្នាក់មានរូបឆោមល្អបំផុត មិនទាន់មានគូស្រករឲ្យសមនឹងរូបឆោមរបស់នាងនៅឡើយ ទើបតែមកជួបប្រទះនឹងព្រះទសពល បានពិនិត្យមើលរូបឆោមសព្វគ្រប់ទៅ ក៏មានសេចក្តីពេញចិត្ត គិតតែក្នុងចិត្តថា បុរសនេះមានពណ៌សម្បុរដូចជាមាស មានរូបច្រៀបដោយព្រហ្ម សមនឹងកូនស្រីអញណាស់ ទើបគាត់ចូលទៅគាល់ព្រះបរមសាស្តា ទោល

ពាក្យថា សមណៈខ្ញុំមានកូនស្រីម្នាក់រូបឆោមល្អណាស់ សមនឹងលោក សូមឲ្យនៅរង់ចាំក្នុងទីនេះមួយស្របក់សិន ខ្ញុំនឹងទៅនាំមកជូនលោក ។ កាលព្រាហ្មណ៍ពោលពាក្យដូច្នេះហើយ ក៏រួសរាន់ទៅផ្ទះប្រាប់ភរិយាឲ្យតែងខ្លួនកូនស្រីជាប្រញាប់ រួចនាំមកជួបនឹងព្រះសាស្តា ព្រមទាំងនាងព្រាហ្មណីជាភរិយា ។ ព្រះអង្គទ្រង់សំដែងព្រះធម្មទេសនា ដោយទ្រង់ត្មះតិះដៀលរូបជាច្រើនប្រការ អម្បាលធីតារបស់ក្រុងមារជាស្ត្រីទិព្វ ព្រះអង្គឥតព្រះទ័យជាមែក ទំងបាច់និយាយទៅថ្វីដល់ស្ត្រីមនុស្សលោក ដែលពាសពេញទៅដោយអសុចិដូចជាធីតារបស់អ្នកនេះ ។

ឯនាងមាគណ្ឌិយាជាកូនក្រមុំរបស់ព្រាហ្មណ៍ គ្រាន់តែបានស្តាប់ពាក្យត្មះតិះដៀលនេះក៏ចងចិត្តអាឃាតព្យាបាទក្នុងព្រះបរមសាស្តាតាំងអំពីនោះមក តែមាតាបិតារបស់នាងមាគណ្ឌិយាបានសម្រេចអនាគាមិផល ទើបប្រគល់កូនក្រមុំដល់ព្រាហ្មណ៍ជាប្អូនរបស់ខ្លួន តមកនាងមាគណ្ឌិយាបានធ្លាក់ទៅជាមហេសីរបស់ព្រះបាទឧទេនដែរ ។

ចំណែកឯសម្តេចព្រះបរមសាស្តា ស្តេចត្រាច់ចារិកទៅដោយលំដាប់ ដរាបដល់ក្រុងកោសម្ពី ពួកសេដ្ឋីអស់នោះបានទទួលព្រះអង្គ ហើយនិមន្តឲ្យនៅក្នុងវិហាររបស់ខ្លួន ។ សម្តេចព្រះបរមសាស្តាប្រថាប់នៅស្រុកកោសម្ពី ទ្រង់សំដែងធម៌ប្រកាសព្រះសាសនានៅក្នុងទីនោះ ។ ឯព្រះនាងមាគណ្ឌិយា ជាព្រះអគ្គមហេសីរបស់ព្រះបាទឧទេន ធ្លាប់ចង

ចិត្តអាឃាតនឹងព្រះអង្គមកពីមុន គឺបង្គាប់ឲ្យពួកមនុស្សខ្ញុំកម្មករ ដើរជេរព្រះពុទ្ធជាម្ចាស់នឹងព្រះសាវក ទាល់តែព្រះអានន្ទកើតរកាចិត្ត ទើបទូលអញ្ជើញឲ្យស្តេចចេញទៅប្រថាប់នៅស្រុកឯទៀត ។ ព្រះអង្គមានព្រះពុទ្ធដីកាថា បើទៅស្រុកនោះនៅតែមានគេជេរទៀតតើនឹងទៅឯណា ។ ព្រះអានន្ទក្រាបទូលថា ត្រូវចេញពីស្រុកនោះទៅស្រុកឯទៀតៗតទៅទៀត ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ធ្វើដូច្នោះមិនសមគួរទេ អធិករណ៍កើតឡើងនៅទីណា គួរឲ្យស្ងប់ម្ងាប់នៅទីនោះសិនរួចសឹមចេញទៅ តថាគតប្រៀបដូចដំរីដែលចូលទៅតយុទ្ធក្នុងសង្គ្រាម ត្រូវតែអត់ទ្រាំចំពោះធ្នូដែលគេបាញ់មកអំពីទិសទាំង៤ យ៉ាងណា តថាគតត្រូវតែអត់ទ្រាំនឹងពាក្យចាក់ដោតរបស់ពួកមនុស្សទ្រុស្សីលដូច្នោះដែរ ។ អ្នកណាអត់ធន់ដល់ពាក្យដែលគេមើលងាយប្រមាថបានអ្នកនោះចាត់ជាមនុស្សប្រសើរក្នុងជំនុំជន សូម្បីសេះឬដំរីដែលគេបានបង្ហាត់រៀបរយហើយ ទើបនាំចូលទៅកាន់ទីប្រជុំបាន ស្តេចក៏តែងទ្រង់វាហនៈដែលបានបង្ហាត់ល្អហើយដែរ ទើបគួររាប់ថាសេះអស្សតរក្តី សេះអាជានេយ្យក្តី ដំរីក្តី ដែលគេបានបង្ហាត់ហើយទើបចាត់ជាវាហនៈដ៏ប្រសើរបាន តែមនុស្សដែលបានហាត់ទូន្មានខ្លួនបានហើយចាត់ជាប្រសើរជាងវាហនៈអស់នោះទៅទៀត ។

នាងមាគណ្ឌិយា ប្រើមនុស្សឲ្យជេរព្រះពុទ្ធជាម្ចាស់ ដោយបំណងចង់ឲ្យព្រះអង្គរត់ចេញពីស្រុកនោះទៅ តែពួកមនុស្សដែលមកជេរបានស្តាប់ព្រះធម្មទេសនាហើយ ថ្វាយខ្លួនជាពុទ្ធសាវកក៏មាន ទើបមិនអាចបណ្តេញព្រះបរមសាស្តាឲ្យរត់ចេញទៅបាន ។

តមកថ្ងៃមួយ សម្តេចព្រះបរមសាស្តា ស្តេចយាងទៅកាន់ទីនិមន្តរបស់នាយមាលាការ ដែលតែងតែធ្វើកម្រងផ្កាទៅថ្វាយព្រះនាងសាមាវតី ហើយនាងខុជ្ជុត្តរតែងទៅយកមកថ្វាយព្រះនាងសាមាវតីរាល់ៗថ្ងៃ ដូចបានពោលមកហើយ ក្នុងប្រវត្តិរបស់នាងខុជ្ជុត្តរ-ឧបាសិកា ។ នាងខុជ្ជុត្តរ-ឧបាសិកានេះ បានស្តាប់ធម្មទេសនាហើយ បានសម្រេចសោតាបត្តិផល ហើយនាំព្រះធម្មទេសនានោះមកសំដែងឲ្យព្រះនាងសាមាវតីទ្រង់ព្រះសណ្តាប់ ចប់ព្រះធម្មទេសនា ព្រះនាងបានសម្រេចសោតាបត្តិផល ។ តាំងពីព្រះនាងបានសម្រេចមគ្គផលហើយ ក៏មានព្រះបំណងចង់ឃើញព្រះបរមសាស្តា តែមិនមានឱកាសបានឃើញព្រះអង្គសោះ ព្រោះដំណាក់របស់ព្រះនាងនៅជិតផ្លូវថ្នល់ដើរទៅមកនៃមហាជន សូម្បីសម្តេចព្រះបរមសាស្តាស្តេចយាងមកតាមផ្លូវនោះជារឿយៗ ក៏មិនដែលបានឃើញព្រះអង្គ ទើបមានបន្ទូលឲ្យគេចោះប្រហោងតូចៗ ល្មមទតមើលឃើញព្រះបរមសាស្តា ។ ព្រះនាងមាគណ្ឌិយា បានទតឃើញក៏ដេញដោលសួរ កាលបានជ្រាបសេចក្តីសព្វគ្រប់ហើយ ក៏ខ្ញាល់ទឹងនាង

សាមាវតីដែលគោរពបូជាព្រះបរមសាស្ដា ដែលខ្ញុំបានចងចិត្តអាឃាត ទើបព្រះនាងទៅក្រាបទូលព្រះមហាក្សត្រថា ព្រះនាងសាមាវតីមានព្រះទ័យបែកជាពីរ ប្រាថ្នាចេញទៅសេពគប់បុរសខាងក្រៅ បានជាចោះផ្ញាំង ៗ ព្រះកជាស្ដេចចេញទៅទតព្រះនេត្រពិចារណាសួរ តែមិនមានសេចក្ដីពិតដូចជាពាក្យចោទ ក៏ទ្រង់នៅស្ងៀម ៗ

ព្រះនាងមាគណ្ឌិយា នៅតែមានចិត្តឫស្យាខឹងប្រចណ្ឌកាន់តែខ្លាំងឡើង កាលមិនអាចញ៉ាំងព្រះកជាឲ្យទ្រង់ព្រះពិរោធបានក៏នៅតែព្យាយាមដោយប្រការផ្សេង ៗ តែមិនសម្រេច ៗ លុះមកដល់គ្រាមួយព្រះបាទឧទេន ស្ដេចទៅប្រថាប់នៅដំណាក់ព្រះនាងសាមាវតី ទ្រង់បានយកពិណវិសេសដែលហៅថា ហត្ថិកន្តវីណា ជាប់ទៅជាមួយផង ឯព្រះនាងមាគណ្ឌិយាបានឱកាសល្អ ក៏លបយកពស់វែក ១ ស៊កចូលទៅក្នុងប្រហោងពិណហើយយកឆ្នុកចុករន្ធពិណជាប់ ៗ លុះដល់កំណត់ថ្ងៃស្ដេចយាងទៅប្រាសាទនាងសាមាវតី ព្រះនាងមាគណ្ឌិយាក៏ក្រាបទូលថាអំពីយប់មិញនេះខ្ញុំម្ចាស់យល់សប្តិមិនល្អសោះ បើព្រះអង្គយាងទៅដំណាក់ព្រះនាងសាមាវតី ខ្ញុំម្ចាស់សូមតាមស្ដេចទៅជាមួយផង ៗ ព្រះបាទឧទេនក៏ទ្រង់យល់ព្រមតាមអធ្យាស្រ័យ រួចស្ដេចទ្រង់កាន់ពិណវិសេសនោះទៅដំណាក់ព្រះនាងសាមាវតីហើយទ្រង់ដាក់ពិណនៅក្បែរខាងក្រឡាព្រះបន្ទំ ៗ ឯព្រះនាងមាគណ្ឌិយាកាលសង្កេតឃើញព្រះកជាទឹងពួក

អាមាត្យក្មេងខ្លួន ដោយការសប្បាយរីករាយ ទើបព្រះនាងលបដកយកឆ្នុកពីពិណនោះចេញ ឯពស់វែកដែលអត់អាហារមកជាច្រើនថ្ងៃ ក៏លូនចេញមកពីខាងក្នុងពិណ លើកពារសំដែងអាការឃោរឃៅ សឹងបានឃើញទាំងអស់គ្នា ទើបព្រះរាជាមានព្រះដម្រាស់សួរថា អ្នកណាយកពស់មកលាក់ទុកនៅទីនេះ ៗ ព្រះនាងមាគន្ទិយា ឃើញបានឱកាសល្អទើបទូលស្នងព្រះឱង្ការថា ប្រហែលជាអំពើរបស់ព្រះនាងសាមាវតី សមដូចខ្ញុំម្ចាស់បានយល់សប្តិឃើញអំពីយប់មិញនេះ ៗ ព្រះរាជាទ្រង់ព្រះក្រោធពេញកំឡាំង ទ្រង់ចាប់ព្រះសែងធ្នូដែលត្រាំថ្នាំពិស បែរព្រះភក្ត្រទៅរកព្រះនាងសាមាវតី ហើយទ្រង់ដំឡើងព្រះសែងធ្នូដោយព្រះបំណងនឹងផ្តាច់ជីវិតព្រះនាងសាមាវតី និងពួកស្ត្រីជាបរិវារ ៗ តែព្រះនាងសាមាវតី និងពួកបរិវាររបស់ព្រះនាង ប្រកបដោយមេត្តាព្រហ្មវិហារធម៌ព្រះនាងឲ្យផ្សាយមេត្តាចិត្តក្នុងខ្លួនយ៉ាងណា ក៏ចូរផ្សាយមេត្តាចិត្តក្នុងព្រះរាជា នឹងនាងមាគន្ទិយាដូច្នោះចុះ ៗ អាស្រ័យមេត្តាគុណនេះឯងជាឧបាយការពារ បណ្តាលមិនឲ្យកូនសរបួតចេញពីដងរ៉ ហើយថែមទាំងព្រះរាជាមិនអាចដាក់ធ្នូសរបានផង ទាល់តែព្រះសេទហូរចេញជោកព្រះវរកាយ ទ្រង់បានសេចក្តីលំបាកព្រះទ័យយ៉ាងក្រៃពេកទើបទ្រង់គិតឃើញគុណរបស់ព្រះនាងសមាវតី ហើយទ្រង់សុំខមាទោសចំពោះព្រះនាងសាមាវតីៗ ទ្រង់ទទួលខមាទោសហើយ ទើបទ្រង់

ទម្លាក់ព្រះសែងធ្នូសហោលទៅបាន តាំងអំពីនោះមកព្រះរាជាទ្រង់រាប់អានព្រះនាងសាមាវតីលើសជាងពីមុនៗ នោះទៅទៀត ។

ឯព្រះនាងមាគណ្ឌីយា កាន់តែមានព្រះទ័យប្រចណ្ឌខឹងក្រេវក្រោធកាន់តែខ្លាំងឡើង គិតរកឧបាយឲ្យព្រះរាជាណាយព្រះទ័យ នឹងព្រះនាងសាមាវតីមិនបាន ទើបគិតឧបាយម្យ៉ាងទៅចុងក្រោយបង្អស់ គឺឲ្យឪពុកមារបស់ព្រះនាងបិទទ្វារដំណាក់ព្រះនាងសាមាវតីឲ្យជាប់ ហើយយកភ្លើងដុតដំណាក់ព្រះនាងសាមាវតី នឹងស្ត្រីជាបរិវារដែលនៅខាងក្នុងដំណាក់ៗ ក៏ត្រូវភ្លើងឆេះស្លាប់អស់ឥតសល់ នៅវេលាដែលព្រះរាជាស្ដេចចេញទៅប្រពាតព្រះរាជឧទ្យាន ។ លុះព្រះបាទឧទេនបានទ្រង់ជ្រាបហេតុ ក៏ស្ដេចស្រពន់ តែទ្រង់ជួយតែខៃមិនទាន់ ព្រះអង្គជាអ្នកឈ្លាសវៃក្នុងកលោបាយ ទ្រង់ជឿច្បាស់ក្នុងព្រះទ័យថា គង់ជាអំពើអាក្រក់របស់មនុស្សខាងក្នុងព្រះរាជវាំងជាប្រាកដ ។ ទើបទ្រង់ប្រកាសក្នុងទីប្រជុំថា ព្រះនាងសាមាវតីមិនគាប់ចិត្តអញមកយូរហើយ តែគ្រានេះមានមនុស្សមកជួយដោះទុក្ខអញទៅបាន អញមានអំណរនឹងអរគុណណាស់ នឹងសងគុណឲ្យបំណាច់រង្វាន់ ។ ឯព្រះនាងមាគណ្ឌិយាបានស្ដាប់ព្រះរាជតម្រាស់ដូច្នោះក៏ចេញមុខទទួលស្នងព្រះឱង្ការ ព្រះរាជាមានព្រះបន្ទូលថា អញមានចិត្តជ្រះថ្លានឹងព្រះនាងណាស់នឹងប្រទានបំណាច់

រង្វាន់ដល់ព្រះនាង ព្រមទាំងពពួកញាតិរបស់ព្រះនាង ចូរព្រះនាងឲ្យប្រកាសហៅពពួកញាតិមកឲ្យព្រមគ្នាចុះ ។ ឯពួកញាតិរបស់ព្រះនាងមាគណ្ឌិយា ក៏នាំគ្នាចូលមកគាល់អ្នកដែលមិនមែនញាតិ ក៏សំដែងខ្លួនជាញាតិក៏មាន ។ ព្រះបាទឧទេនទ្រង់មានព្រះរាជឱង្ការឲ្យជីករណ្ដៅកប់ពួកញាតិរបស់ព្រះនាងទាំងប៉ុន្មានឲ្យសល់ទុកត្រឹមក ហើយឲ្យយកភ្លើងដុតទាំងរស់ ឲ្យយករនាស់ដែកកាស់ ត្រាតែស្លាប់អស់ទៅ ។ ឯព្រះនាងមាគណ្ឌិយា ទ្រង់ក៏ឲ្យសម្រេចទោសជាមួយនឹងពពួកញាតិអស់នោះដែរ ។ គ្រានោះពួកភិក្ខុអស់នោះក៏បានជ្រាបរឿងរ៉ាវអស់នោះដែរ ទើបនាំគ្នាសន្ទនាថា ព្រះនាងសាមាវតីក៏ស្លាប់ ព្រះនាងមាគណ្ឌិយាក៏ស្លាប់ទាំងពីរនេះតើ ខាងណាទុកជាស្លាប់ពិតមែន ។ ព្រះបរមសាស្ដាស្ដេចមកត្រាស់សួររឿងនោះ លុះភិក្ខុទាំងនោះបានទូលឲ្យទ្រង់ជ្រាបហើយទើបមានព្រះពុទ្ធដីកាថា អ្នកដែលមានសេចក្ដីប្រមាទ ទុកជាស្លាប់ទៅក្ដីរស់នៅក្ដី ក៏ឈ្មោះថាស្លាប់ទៅហើយ ព្រោះទុកជាមានជីវិតរស់នៅ ក៏ឥតធ្វើប្រយោជន៍អ្វីដែរ ។ ឯអ្នកដែលមិនប្រមាទ ដូចព្រះនាងសាមាវតីមានជីវិតរស់នៅក្ដី ឥតជីវិតក្ដី ឈ្មោះថាមិនស្លាប់ទេ ព្រោះកាលដែលមានជីវិតរស់នៅឡើយ តែងធ្វើប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ ទោះបីស្លាប់ទៅក៏នៅមានមនុស្សសរសើរ នឹងយកជាគំរូ ។

អាស្រ័យហេតុព្រះនាងសាមាវតី ជាអ្នកមានមេត្តាជាវិហារធម៌ អាចការពារអន្តរាយ ក្នុងគ្រាដែលព្រះរាជាទ្រង់ព្រះក្រោធបាន មិនត្រឹមតែប៉ុណ្ណោះ ទោះបីព្រះនាងមាគណ្ឌិយាមានព្រះទ័យគុំគួនព្យាបាទយ៉ាងណាក្តី ក៏មិនបានក្រោធតបតឡើយ អាស្រ័យហេតុនេះហើយ ទើបព្រះបរម-សាស្តាទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងពួកឧបាសិកាដែលមានមេត្តាព្រហ្មវិហារធម៌ ។

ចប់ប្រវត្តិសង្ខេបរបស់ព្រះនាងសាមាវតីតែប៉ុណ្ណេះ ។

អំពីគម្ពីរបញ្ចតន្ត្រៈ

(តមកនិងចប់)

អំពីជាងកោរពុកមាត់និងអ្នកសុំទាន

៧ មានតំបន់ ១ នៅខាងត្បូងស្រុក ១ ហៅថាមហិឡារោប្យៈ ។ នៅទីនោះមានអ្នកជំនួញម្នាក់ ឈ្មោះមណិភទ្រ អាស្រ័យនៅ ។ គេបានបំពេញការកិច្ច, ផលប្រយោជន៍, ការសប្បាយរីករាយ និងការធ្វើបុណ្យទាន ។ អ្នកជំនួញនេះ បានបង់ខាតទ្រព្យសម្បត្តិអស់ទៅដោយធ្វើតាមចំណង់ព្រេងសំណាង រួចតមកក៏មានមនុស្សមើលងាយប្រមាថគេ ដោយហេតុគេបាត់បង់វិនាសទ្រព្យអស់ទៅ ទើបមានសេចក្តីសៅសោកជាខ្លាំង ។ ក្នុងសម័យមួយនោះ នៅវេលាយប់គេគិតថា អាហ៍! ថ្វីយចៅសេចក្តីទាល់ក្រនេះអាក្រក់ណាស់តើ! ហេតុដូច្នេះហើយទើបលោកពោលទុកថាៈ

ការប្រព្រឹត្តតាមសីលធម៌, សេចក្តីបរិសុទ្ធ ខន្តិ សេចក្តីយុត្តិធម៌ សេចក្តីសុភាព ត្រកូលកំណើតដ៏ខ្ពង់ខ្ពស់ របស់អស់នេះមិនមែនចុះពទ្វី ស្ទើចូលទៅក្នុងផ្ទះរបស់មនុស្សណា ដែលហិនហោចទ្រព្យសម្បត្តិទេ ។

កិត្តិយសនិងកិរិយាថ្លៃថ្នូ, ចំណេះវិជ្ជា, លំអនិងសតិបញ្ញាដ៏ធំទូលាយ តែងបាត់បង់សាបសូន្យព្រមគ្នា គឺមិនមានដល់មនុស្សហិនហោចទ្រព្យសម្បត្តិឡើយ ។

ការស្រស់បស់នៃផ្កាក្នុងរដូវរងា តែងតែត្រូវខ្យល់បក់ក្នុងរដូវស្លឹកឈើលាស់សន្ធឹកយ៉ាងណា សតិបញ្ញារបស់អ្នកប្រាជ្ញក៏មានទំនងដូចគ្នាដែរ គឺតែងតែរបេះរលស់ទៅកាលពៃ ដោយគ្រឿងកង្វល់ក្នុងគ្រួសារ ។

ប្រសិនបើមនុស្សដែលមានប្រាជ្ញាតិច សតិបញ្ញារបស់គេតែងអន្ត-រាយទៅ ដោយគ្រឿងកង្វល់រឿយៗ ទិនបៀ, អំបិល, ប្រេង, អង្ករ, សំ-លៀកបំពាក់ ហើយនឹងវិនាសដោយភ្លើង ។

មេឃឥតផ្កាយ, អណ្ដូងហែងហួតរីងទឹក ទីប៉ាឆាមុខគួរឲ្យស្ញប់ស្ញែង នេះមានឧបមាយ៉ាងណា ឯផ្ទះរបស់អ្នកកំសត់ទុកជាល្អដូចម្ដេច គឺទៅជាផ្ទះមុខគួរខ្ពើមយ៉ាងនោះដែរ ។

គ្មានអ្នកណា មើលឃើញពួកអ្នកកំសត់ទុគ៌តទេ ទុកជាគេមកនៅចំមុខយើងក៏ដោយ ជនអស់នេះមានទំនងដូចពពុះទឹកដែលនៅក្នុងទឹក គ្រាន់តែកើតឡើងក៏បែកទៅវិញ ។

ប្រជុំជនតែងរាប់អានអ្នកដែលមានត្រកូលខ្ពស់ ឈ្លាសវៃ និងស្មោះត្រង់ តែគេតែងរាប់អានអ្នកមានសម្បត្តិ ដូចជាដើមកល្បព្រឹក្ស ទុកជាអ្នកមានសម្បត្តិនេះជាអ្នកឥតត្រកូល មិនឈ្លាសវៃ មិនមានសីលធម៌ក៏ដោយ ។

អំពើសុចរិតដែលបានធ្វើទុកមកក្នុងជាតិមុន តែងមានផលជាផ្លែផ្កានៅនាលោកិយនេះ: អ្នកឯណាមួយដែលជាអ្នកប្រាជ្ញ ហើយបានកើត

ក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ មិនយូរទេ អ្នកប្រាជ្ញនេះទៅជាអ្នកបំរើរបស់ជនដែលមានទ្រព្យសម្បត្តិទៅវិញ ។

លោកតែងពោលសរសើរដោយសេចក្ដីត្រេកអរចំពោះជនជាម្ចាស់ទឹក ទុកជាគេនិយាយស្ដីគម្រោះគម្រើមយ៉ាងណាក៏ដោយ នៅលោកិយនេះ អំពើដែលពួកអ្នកមានធ្វើទៅ សុទ្ធតែគ្មានកើតសេចក្ដីអៀនខ្មាសសោះឡើយដូច្នេះដែរ ។

លុះនាយពាណិជបានត្រិះរិះពិចារណាដូច្នេះហើយ គេក៏គិតថា: អាត្មាអញនឹងលែងបរិភោគអាហារ ហើយអាត្មាអញនឹងលះបង់ជីវិតចោលនៅថ្ងៃព្រឹកស្អែកនេះ ។ នឹងមានប្រយោជន៍អ្វី ក្នុងសំសារវដ្ដដែលប្រកបដោយសេចក្ដីទុក្ខនេះ កាលគេគិតស្រេចដូច្នេះហើយក៏ដេកលក់ទៅ ។

ឯកំណប់ផ្កាឈូក ក៏មកប្រាកដក្នុងនិមិត្តជារូបរាងអ្នកសមណម្នាក់ ឈ្មោះផៃន: ហើយនិយាយថា ម្នាលឈ្មួញអើយ! អ្នកកុំអាលអស់សង្ឃឹម ។ ខ្លួនខ្ញុំនេះជាកំណប់ផ្កាឈូក ដែលជីដូនជីតារបស់អ្នកបានកប់ទុកមក ។ បើដូច្នេះ ក្នុងព្រឹកស្អែកនេះ ខ្ញុំនឹងចូលមករកអ្នកតាមទ្រង់ទ្រាយនេះក្នុងផ្ទះរបស់អ្នក ហើយឲ្យអ្នកយកដំបងវាយក្បាលខ្ញុំ ១ ដំបង ដើម្បីឲ្យខ្លួនខ្ញុំនេះក្លាយទៅជាមាស ហើយជារបស់តាយាយមិនចេះអស់ផង ។ លុះព្រឹកនាយពាណិជក៏ភ្ញាក់ក្រោកឡើងនឹករលឹកដល់និមិត្តយល់សប្តិនេះ ហើយ គេត្រិះរិះពិចារណាថា អើ! អញមិនដឹងជាយល់សប្តិជាការពិតឬកុហក

ទេ ប៉ុន្តែជាក់ជាគុហកប្រាកដ ពីព្រោះទាំងថ្ងៃទាំងយប់អញគិតតែពីទ្រព្យសម្បត្តិ ដ្បិតលោកពោលទុកថា:

ការយល់សប្តិដែលប្រាកដដល់មនុស្សជម្ងឺ, មនុស្សមានទុក្ខ, មនុស្សមានសេចក្តីក្រវល់ក្រវាយ , មនុស្សជាប់ដោយសេចក្តីស្នេហា , មនុស្សស្រវឹងតែងតែធ្វើឲ្យឃើញផលជាទីសប្បាយចិត្ត ។

ទុកជាយ៉ាងណាក៏ដោយ មានជាងកោរពុកមាត់ម្នាក់ចូលមកដុសខាត់ក្រចកដៃរបស់ប្រពន្ធនាយពាណិជនោះ ។ កន្លងខណៈដែលគេកំពុងដុសខាត់ដូតក្រចកដៃប្រពន្ធនាយពាណិជនោះ ស្រាប់តែលេចមនុស្សសម្បម្នាក់ មានសណ្ឋានទ្រង់ទ្រាយដូចក្នុងយល់សប្តិ ។ លុះនាយមណិកទ្រក្រឡេកទៅឃើញក៏កើតចិត្តរីករាយអរណាស់ ហើយចាប់យកដំបង ១ ដែលនៅក្បែរនោះវាយបំក្បាលសម្ប ។ សម្បនោះ ក៏ក្លាយទៅជាមាស ហើយដួលទៅលើដី ១ រំពេចនោះឯង ។ ប៉ុន្តែនាយពាណិជ ក្រោយដែលបានលើកយកមាសទៅទុកនៅកណ្តាលផ្ទះ ពិនិត្យមើលរូបហើយ ស្រាប់តែក្រឡេកទៅឃើញជាងកោរពុកមាត់នោះ ។ កាលនោះគេគិតថា អាហ៍ ! ប្រហែលជាវាបានឃើញហើយ កាលដែលវាដើរចូលមកនេះ បើដូច្នេះអញមុខជាហិនហោចមិនខាន ។ លុះគេបានត្រិះរិះដូច្នេះហើយ គេក៏យកប្រាក់ឲ្យទៅជាងកោរពុកមាត់នោះហើយផ្តាំថា: ចូរអ្នកយកប្រាក់នឹងសំពត់អាវដែលខ្ញុំបានឲ្យអ្នកអស់នេះទៅចុះ ប៉ុន្តែសំឡាញ់អើយ កុំ

និយាយប្រាប់អ្នកឯណាឲ្យសោះ អំពីមនុស្សដែលចូលមករកខ្ញុំនេះ ៗ ឯជាងកោរពុកមាត់ក៏ទទួលសន្យានេះដែរ រួចគេដើរចេញពីផ្ទះនោះទៅ ហើយគិតថា: ប្រាកដជាពួកស្មូមអាក្រាតនេះក្លាយទៅជាមាស កាលណាបើគេវាយក្បាលទំងដំបង ៗ ហេតុដូច្នេះព្រឹកស្អែកនេះ គួរតែអញទៅអញ្ជើញពួកស្មូមអាក្រាតមកឲ្យបានច្រើន ហើយអញទំងយកដំបងទ្វ៉ាយ ដើម្បីឲ្យវាក្លាយទៅជាមាស ៗ កាលគេរំពឹងពិចារណាដូច្នេះ អស់យប់១ ថ្ងៃ ១ សព្វគ្រប់ទៅ រួចដល់ព្រឹកឡើង គេក៏ក្រោកឡើងដើរសំដៅទៅឯវិហាររបស់ពួកស្មូមជៃន: ពាក់សំពត់ចៀងស្មា ហើយថ្វាយបង្គំទៅស្មូមជៃន: ៣ ដង លូនទៅទំងជង្គង់ យកមាត់ខាំជាយសំពត់ចៀងស្មា ហើយលើកដៃប្រណម្យហើយសូត្រស្លោកនេះដោយសំឡេងយ៉ាងខ្លាំងថា:

សូមសិរីសួស្តីបូរមានដល់ពួកជៃន: ដែលមានចំណេះចេះដឹងទៀងទាត់ មានចិត្តបានត្រាស់ដឹងសេចក្តីពិតក្នុងជីវិតពោលគឺសំសារវដ្តនេះ ៗ

លុះគេពោលដូច្នេះហើយ ទំងពោលចំរើនសិរីសួស្តី ដល់ស្មូមជៃន: យ៉ាងដទៃទៀត ហើយទើបគេចូលទៅជិតស្មូមជៃន: ទី ១ ហើយលុតជង្គង់ដើរទានិយាយថា ខ្ញុំសូមគោរពលោក សូមនមស្ការលោក រួចគេក៏បានទទួលពរសព្ទសាធុការរួមជាមួយនឹងការថ្វាយបង្គំ ដើម្បីចំរើនសេចក្តីពិតទំងកិច្ចសិក្សាខាងផ្លូវសាសនា ដោយសទ្ធាជ្រះថ្លា មានវ្យៃផ្គាំវែង ១ ចំរើនសេចក្តីសុខ ធ្វើជាចំណាង ១ ពាក់លើសំពត់ចៀងស្មា

ហើយគេនិយាយដោយសេចក្ដីគោរពថា៖ បពិត្រលោក ឥឡូវនេះ ខ្ញុំសូមឲ្យលោកទៅក្រសាលសប្បាយជាមួយនឹងគាបសទាំងឡាយ នៅគេហស្ថានរបស់ខ្ញុំ ៗ អ្នកសូមនោះឆ្លើយឡើងថា៖ ម្នាលសាវកអើយ, ហេតុអ្វីក៏ចៅនិយាយដូច្នេះ ចៅមិនចេះព្រាប់អ្វីទេឬ? ពួកយើងនេះជាពួកព្រាហ្មណ៍ ចុះចៅនិមន្ដយើងទៅធ្វើអ្វី?

កាលណាយើងឃើញសាវកម្នាក់ ដែលប្រតិបត្តិធម៌អាចិត្រឹមត្រូវ យើងតែងទៅកាន់ផ្ទះរបស់គេ យើងក្រែមជាប់ចិត្តទទួលនិមន្តណាស់ ហើយយើងឆាន់របស់ណាដែលសម្រាប់តាំងទុកអត្តភាពប៉ុណ្ណោះ ៗ ចៅទៅចុះ ក្រោយៗ កុំនិយាយដូច្នេះទៀតណា ៗ កាលណោះ ជាងកោរពុកមាត់បានឮពាក្យដូច្នោះក៏និយាយទៅវិញថា៖ បពិត្រលោក, ខ្ញុំដឹងរឿងនោះខ្ញុំនឹងធ្វើដូច្នោះដែរ ប៉ុន្តែមានសាវកជាច្រើនទទួលរាប់អានលោកជាច្រើន ឯខ្ញុំក៏បានចាត់ចែងសំពត់ជាច្រើនផាប់ នឹងរបស់មានដំឡៃឯទៀតៗ សុំឲ្យសមគួរយកទៅគ្រប់គម្ពីរ ហើយខ្ញុំឲ្យប្រាក់ឈ្នួលអ្នកចម្លងគម្ពីរផង ✓ ទើបត្រូវតែលោកធ្វើឲ្យសមនឹងឱកាសនេះមិនគួរខានឡើយ ៗ លុះគេនិយាយដូច្នេះហើយក៏ដើរទៅផ្ទះគេទៅ ៗ លុះបានដល់ទៅផ្ទះ គេរកដំបង ១ ជាតិឈើខ្ទិះស្ងួតខ្លួន ហើយដាក់ដំបងនោះនៅកៀនទ្វារ លុះវេលាម៉ោង ៤ កន្លះ គេក៏ត្រឡប់ទៅឯក្រុងហើយឈប់ចាំនៅមាត់ទ្វារវិញ ៗ លុះគ្រូអ្នកសូមដើរចេញទៅដល់ទ្វារ មកហើយ គេក៏នាំដើរបួលទៅក្នុងផ្ទះ

ទាំងអស់ ៗ ដោយសេចក្ដីលោភចង់បានសំពត់និងប្រាក់ ពួកអ្នកស្គមអស់នេះក៏លះបង់ពួកសាវកដែលកាន់ធម៌ម៉ឺងម៉ាត់ ដែលចេះដឹងហើយចាំ ប្រតិបត្តិតាមដោយពេញចិត្តទៅ ៗ ដូច្នេះហើយទើបលោកពោលពាក្យពិតដែលមានហេតុផលទុកថា :

មនុស្សសន្តោសដែលបានលះបង់ផ្ទះសម្បែង គ្មានភាជនះអ្វី ១ ក្រៅពីដៃ គ្មានសំពត់ស្លៀកទេ ក្រៅពីអាកាស ក៏នៅតែមានចិត្តអន្ទះអន្ទែងក្នុងលោកដោយតណ្ហា អញ្ជើញមើលចុះរបស់ចំឡែកគួរតែមើល ៗ

នរជនដែលចាស់ជរា, សក់គេក៏ចាស់, ធ្មេញគេក៏ចាស់, ភ្នែកគេក៏ចាស់, ត្រចៀកគេក៏ចាស់, ប៉ុន្តែតណ្ហារបស់គេប៉ុណ្ណោះនៅតែក្មេងជានិច្ច ៗ

តពីនោះមក ជាងកោរពុកមាត់ក៏ច្រាប់ពួកស្គមអស់នោះ ឲ្យចូលទៅក្នុងផ្ទះ រួចគេបិទទ្វារហើយយកដំបងសំពងក្បាលពួកស្គម ៗ ក្នុងចំនួនពួកស្គមដែលត្រូវវាយនេះ មានស្គមខ្លះស្លាប់ទៅ ស្គមខ្លះបែកក្បាល ស្គមខ្លះស្រែកយំទ្រហោឡើង ៗ ខណៈនោះ ពួករាជបុរសបានឮសំឡេងស្រែកទ្រហោយំដូច្នោះ ក៏នាំគ្នាមក ៗ គេនិយាយគ្នាថា ទុះហ្ន៎! សួរ សំឡេងអ្វីស្រែកកងរំពងនៅកណ្ដាលក្រុងនេះ? ហើយគេស្រែកឡើងថា យើងទៅៗ ហើយគេនាំគ្នារត់សំដៅទៅផ្ទះនោះ មើលទៅឃើញពួកស្គមមានឈាមស្រោចលើខ្លួន កំពុងរត់ចេញមកពីផ្ទះរបស់ជាងកោរពុកមាត់នោះ ទើបរាជបុរសដណ្ដឹងសួរថា: កើតរឿងអ្វីរឿង? មនុស្សអស់នោះ

ក៏ជំណាលរឿងរ៉ាវដែលកន្លងមកហើយ អំពីហេតុអន្តរាយដែលជាន់គោ-ពុកមាត់នោះបានបន្តទៀត ។ ទើបពួកកសិបុរសចាប់ចងជាន់គោពុកមាត់ទីងវែង ១ យ៉ាងជាប់រួចនាំខ្លួនទៅសាលាវិនិច្ឆ័យជាមួយនឹងពួកសម្ព ដែលរសេរសល់ពីស្លាប់ ។ ពួកចៅក្រមដណ្ដឹងសួរគេថា "អ៊ើយ ហេតុអ្វីក៏ឯងហ៊ានធ្វើអំពើអាក្រក់ដូច្នេះ? គេឆ្លើយថា ពុះឲ្យខ្ញុំបាទធ្វើដូចម្ដេចបានប្រាស ? អំពើដែលខ្ញុំបាទបានធ្វើនេះសឹងមានសាក្សី ដូចអំពើដែលគេបានធ្វើរួចមកហើយ នៅផ្ទះរបស់អ្នកជំនួញម្នាក់ឈ្មោះមណិកទ្រ ។ លុះគេពោលដោះសាដូច្នេះហើយ ទើបគេជំណាលពីដំណើរហេតុគេទនៃអ្នកជំនួញមណិកទ្រ ដែលគេបានឃើញមកនោះសព្វគ្រប់ ។ ពួកចៅក្រមក៏បញ្ជូនមនុស្សម្នាក់ ឲ្យទៅហៅឈ្មួញមណិកទ្រនោះមក ។ លុះគេនាំឈ្មួញមណិកទ្រមកដល់ ទើបពួកចៅក្រមដណ្ដឹងសួរថា: អ៊ើយ, ឈ្មួញឯងបានសម្លាប់សម្ពម្នាក់មែនទេ? ឈ្មួញមណិកទ្រក៏ជំណាលរឿងរ៉ាវទាំង-ពួងឲ្យពួកចៅក្រមស្ដាប់ដោយសព្វគ្រប់ ទើបពួកចៅក្រមពោលទៀតថា អើ! បើដូច្នោះ គេត្រូវធ្វើទោសទៅជាន់គោពុកមាត់គំណាបនេះ ដ្បិតវាបានធ្វើទៅដោយឥតពិចារណា ហើយពួកចៅក្រមពោលតទៅទៀតថា:

មិនត្រូវធ្វើការអ្វីដោយឥតពិចារណាទេ បើនឹងធ្វើការអ្វីត្រូវតែពិនិត្យពិចារណាជាមុន បើមិនធ្វើដូច្នេះទេ នឹងមានសេចក្ដីក្ដៅក្រហាយស្ដាយ

ក្រោយជាមិនខាន ដូចប្រពន្ធរបស់ព្រាហ្មណ៍ម្នាក់កើតទោមនស្សព្រោះកូនស្កា ១ ប៉ុណ្ណោះ ។

ឈ្មួញមណិកទើបសួរទៅថា ចុះរឿងនោះដូចម្ដេចទៅ? ទើបពួកទៅក្រមដំណាលថា :

រឿងព្រាហ្មណ៍ប្ដីប្រពន្ធនឹងកូនស្កា

នៅតំបន់ ១ នោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះទេវសម៉ុន ។ ឯប្រពន្ធព្រាហ្មណ៍នេះសម្រាលកូនប្រុស ១ នៅថ្ងៃជាមួយគ្នានេះ មេស្កា ១ នៅផ្ទះព្រាហ្មណ៍ ក៏សម្រាលកូន ១ ដែរ នាងព្រាហ្មណីក៏ស្រឡាញ់ពេញចិត្តនឹងកូនស្កានេះជាខ្លាំង បានចិញ្ចឹមកូនស្កាដូចជាកូនរបស់ខ្លួន គឺបានឲ្យទឹកដោះ ដុសខាត់នឹងប្រេងជាដើម ។ ប៉ុន្តែនាងព្រាហ្មណីគិតក្រែងទៅថា កូនស្កានេះជាសត្វកាចពេស នាងមិនទុកចិត្តសោះ ក្រែងវាធ្វើបាបដល់កូនខ្លួន ។ ដ្បិតមានសេចក្ដីដែលលោកពោលទុកមកថា:

" ពិតដូចពាក្យលោកពោលទុកថា ខ្ទមចន្ទន៍ជារបស់ស្រស់ក្រអូបឈ្ងុយ តែតាមដោយពិតនោះ សម្ពស្សខ្លួនរបស់កូននោះ នៅមានក្លិនក្រអូបស្រស់ក្រៃលែងជាងខ្ទមចន្ទន៍ជាច្រើនទៅទៀត ។

តាមធម្មតា មនុស្សយើងមិនសូវចង់បានមេត្រីនឹងអាពុកល្អ ឬនឹងអ្នកដទៃ ដូចជាចង់បានមេត្រីនឹងកូនខ្លួនទេ ។

ក្នុងសម័យថ្ងៃ ១ កាលនាងព្រាហ្មណីបានផ្តេកកូនលើគ្រែកាន់ក្អមទឹកហើយផ្តាំប្តីថា: ម្នាលអ្នកជាស្វាមី ខ្ញុំនឹងទៅដងទឹកក្នុងអណ្តូង ចូរអ្នកមើលកូនផង ក្រែងស្កាវាធ្វើបាបកូនយើង ៗ ប៉ុន្តែកាលនាងចេញទៅផុតទៅ ព្រាហ្មណ៍ជាស្វាមីក៏ចុះចោលផ្ទះនោះទៅដែរ ដើម្បីដើរទៅរកស៊ីទានគេ ៗ ខណៈនោះមានពស់ខ្មៅ ១ ចេញមកពីរន្ធ ១ បំណងនឹងស្វែងរកចំណីអាហារទៅក្បែរគ្រែកូនតូចនោះ ៗ ឯកូនស្កាបានក្រឡេកទៅឃើញគូសត្រូវនោះ ក៏ស្ទុះកាត់ផ្លូវពស់ក្រែងវាទៅចឹកសម្លាប់បងវា ហើយវាខាំទៅពស់កំណាចនោះ កាត់ចេញជាច្រើនកំណាត់ ហើយបោះចោលទៅឆ្ងាយពីទីនោះទៅ ៗ ឯកូនស្កាកាលបើបានសម្លាប់ពស់ហើយ ក៏សប្បាយចិត្តណាស់ កន្ទុយវាប្រឡាក់ទៅដោយឈាមពស់ ទើបវាដើរទៅខាងមុខនាងព្រាហ្មណីជាម្តាយ ដើម្បីបង្ហាញការណ៍ដែលវាបានធ្វើ ៗ ឯម្តាយកាលបានឃើញកន្ទុយវាប្រឡាក់ទៅដោយឈាមដូច្នោះ ក៏ខឹងប្រឡោតះឡោងដោយនឹកក្រែងទៅសត្វកំណាចនេះគង់វាខាំស៊ីកូនអញជាប្រាកដ ទឹកខឹងជាខ្លាំងឥតពិចារណា ក៏លើកក្អមទឹកមានទឹកនៅពេញនោះបោះទៅចំកូនស្កា ៗ នោះត្រូវ ១ ក្អមទឹកនេះក៏បាត់ជីវិត ១ រំពេច រួចនាងព្រាហ្មណីលេះលាំងដើរចូលទៅក្នុងផ្ទះ បានឃើញកូនដេកលក់ស្រួលដូចពីមុន ហើយនៅខាងគ្រែដំណេកនោះមានពស់ធំខ្មៅ ១ ត្រូវកាត់ចេញជាកំណាត់ ៗ រួចនាងក៏មានចិត្តក្តៅខ្លោចផ្សា ដែលខ្លួនបាន

សម្លាប់សត្វឥតទោសដោយសេចក្ដីប្រមាទ ដែលបានជួយកូនខ្លួនឲ្យផុតពីសេចក្ដីស្លាប់ ហើយនាងក៏យំសោកកន្ទក់កន្ទេញបោកក្បាលគក់ទ្រូងទ្រហោយំ ។ ក្រោយដែលព្រាហ្មណ៍ដើរសុំទាន ហើយវិលមកវិញព្រមទាំងរបស់ដែលសុំបានមក ហើយចូនជាដើរមកក្បែរទីនោះ ក៏ស្រាប់តែបានឃើញនាងព្រាហ្មណីយំសោកសង្រេងសង្រែងដូច្នោះ គឺដើរចូលទៅទើបនាងព្រាហ្មណីជាភរិយាត្អះតិះដៀលថា អឺយមនុស្សល្មោភអ្នកឯងត្រូវសេចក្ដីលោភគ្របសង្កត់ជាខ្លាំង អ្នកឯងមិនធ្វើតាមពាក្យដែលខ្ញុំផ្ដាំទុក បានជាបានទទួលសេចក្ដីក្ដៅក្រហាយដល់ម៉្លេះ ដោយកំហុសរបស់អ្នកឯង ៗ សេចក្ដីលោភនាំឲ្យមនុស្សទៅជាខ្វាក់ងងិតបានដោយពិត ៗ

អំពីអណ្ដើកនិងហង្សពីរ

(រឿងនេះមានសេចក្ដីស្របគ្នាក្នុងជាតកនិងគវិទាន)

នៅក្នុងស្រះ ១ នោះ មានអណ្ដើក ១ ឈ្មោះកម្ពុគ្រីវៈ[១] ហើយអណ្ដើកនេះ មានសម្លាញ់ពីរជាសត្វហង្សឈ្មោះសង្កដ[២] ១ ឈ្មោះវិកដ[៣] ១ សត្វទាំងពីរនេះ ក៏មានចិត្តស្រឡាញ់អណ្ដើកដោយស្មោះត្រង់ ហើយតែងនាំគ្នាទៅកាន់មាត់ស្រះនោះជានិច្ច ហើយបានជំណាលរឿងរ៉ាវឲ្យអណ្ដើកស្ដាប់សព្វគ្រប់ អំពីរឿងទេវឫសី[៤] ព្រហ្មឫសី[៥] និងរាជឫសី[៦] ដរាបដល់ព្រះអាទិត្យអស្ដង្គតទៅ ទើបគេនាំគ្នាត្រឡប់

(១) ប្រែថា មានកពក្វាក់ ។ ២ ប្រែថា តូច ។ ៣ ប្រែថា ធំ ។ ៤ ប្រែថា ឥសីទេវតា ។ ៥ ប្រែថា ឥសីតាមរបៀបព្រាហ្មណ៍ ។ ៦ ប្រែថា ឥសីក្នុងពួកក្សត្រ ។

ទៅសំបុករបស់ខ្លួនវិញ ៗ លុះក្នុងសម័យតៗ មកទីនោះក៏កើតឥតទឹកភ្លៀង ស្រះនោះក៏កាន់តែស្ងួតទឹកទៅបន្តិចម្តង ៗ សត្វទាំង ៣ ក៏កើតទុក្ខ ដោយគ្រោះថ្នាក់នេះ ទើបហង្សទាំងពីរនិយាយគ្នាថា ឱ! សម្លាញ់សេចក្តីអើយ, ឥឡូវនេះស្រះនេះមានតែកក់ ចុះសម្លាញ់គិតគូរដូចម្តេច? យើងព្រួយចិត្តណាស់សព្វថ្ងៃនេះ ៗ កាលកម្ពុគ្រីវៈបានឮដូច្នោះហើយ ទើបនិយាយឡើងថា អើ! សម្លាញ់ ប្រសិនបើគ្មានទឹក បំណែកខ្លួនខ្ញុំមិនមានផ្លូវរស់តទៅទៀតទេ ដូច្នេះត្រូវយើងគិតគូររកឧបាយដោះខ្លួន ផ្សិតសេតែងពោលទុកថា:

"ញាតិសាច់ក្តី មិត្រក្តី ក្នុងពេលដែលមានគ្រោះថ្នាក់មកដល់ អ្នកសប្បុរសតែងខំប្រឹងខ្វល់ខ្វាយជួយដោយម៉ឺងម៉ាត់" ពាក្យនេះហើយដែលមនុស្សលោកបានពោលទុកមកដូច្នេះ ៗ

ចូរសម្លាញ់យកវត្ថុមួយ ជាខ្សែយ៉ាងវែង ឬកំណាត់ឈើមួយតូចជាដើម ហើយត្រូវនាំយើងទៅរកស្រះណាមួយដែលមានទឹកច្រើន ៗ ឯយើងនឹងខាំត្រង់កណ្តាលឈើនោះនឹងធ្មេញយើង សម្លាញ់ទាំងពីរពាំចុងកំណាត់ឈើម្ខាងម្នាក់ ហើយនាំយើងទៅកាន់ស្រះនោះ ៗ ទើបហង្សឆ្លើយឡើងថា ឱ! សម្លាញ់សេចក្តីអើយ! យើងនឹងធ្វើដូច្នោះក៏បាន ប៉ុន្តែសម្លាញ់ឯងសន្យាថា កុំនិយាយអ្វីឲ្យសោះទើបបាន តែហាមាត់និយាយហើយ មុខជាសម្លាញ់របូតជ្រុះពីចង្កឹះឈើមិនខាន ហើយ

សម្លាញ់នឹងខូចខ្ញុំជាមិនខាន ។ អណ្ដើកនិយាយឡើងថា ពិតដូចសម្លាញ់ទាំងពីរពោលមែន បើដូច្នេះ ខ្ញុំសុំធ្វើសន្យាថានឹងនៅស្ងៀម តាំងពីឥឡូវនេះទៅ ដរាបដល់ធ្វើដំណើរទៅតាមអាកាស ទាល់តែខ្ញុំបានដល់ទៅស្រះនោះ ។

កាលព្រមព្រៀងគ្នាធ្វើដូច្នេះហើយ ទើបកម្ពុគ្រីវៈ ក្នុងពេលដែលធ្វើដំណើរទៅតាមអាកាសនោះ បានសង្កេតឃើញភូមិមួយនៅពីខាងក្រោម ។ ពួកអ្នកស្រុកនៅភូមិនោះ បានឃើញដំណើរសត្វទាំងបីដូច្នោះ ក៏និយាយឆោឡោឡើងដោយសេចក្ដីអស្ចារ្យ ហៈហា ! អ៊ុំទុំហ្ន៎ មូលដូចកង់មានសត្វបក្សីពីរពាំនាំហើរទៅ! ។ ឯកម្ពុគ្រីវៈ កាលបើបានឮសំដីរែករោករបស់អ្នកស្រុកដូច្នោះ ទ្រាំអត់ពុំបាន ក៏និយាយចេញទៅថា “អើ ! ចុះសូររែករោកអ្វីហ្នឹង? អណ្ដើកនេះគ្រាន់តែហា-មាត់និយាយមិនទាន់បានពាក់កណ្ដាលម៉ាត់ ក៏របូតខ្លួនចុះបាកបង្គង់ទុះមកបែកខ្ទេចជាបំណែកៗ ក្នុងចំណោមអ្នកស្រុកទាំងឯង ។

ហេតុដូច្នេះហើយ ទើបមានពាក្យពោលទុកមកថា :

“នៅនាលោកិយនេះ អ្នកឯណាមួយ ដែលមិនព្រមធ្វើតាមដំបូន្មានដែលមានមេត្រីចិត្តស្មោះត្រង់ទេ នឹងវិនាសខ្លួនមិនខាន ដូចជាអណ្ដើកខ្លៅដែលធ្លាក់ចុះពីបង្គងឈើដូច្នោះដែរ” ។

រឿងព្រះបាទអសោក

(តទៅ)

៥ កាលព្រះបាទអសោកទ្រង់ប្រទានឥស្សរិយយសដល់ព្រះនាងអសន្ធិមិត្តាអគ្គមហេសីដូច្នេះ ក៏ស្រីស្នំទាំងឡាយដែលគាល់បំរើស្និទ្ធស្នេហាទាំង ព្រះបាទអសោកមានសេចក្ដីឫស្យាពោលពាក្យនិន្ទាដល់ស្ដេច ព្រះមហាក្សត្រិយ៍ទ្រង់ជ្រាបហេតុនោះ ទើបត្រាស់បង្គាប់ឲ្យពួកអ្នកពិសេសធ្វើនំឲ្យបានមួយហ្មឺនប្រាំមួយពាន់ ហើយយកនំមួយនោះទ្រង់បង្កប់ព្រះទម្រង់ដ៏មានដំឡៃកាត់ថ្លៃមិនបានមួយវង់ ទើបត្រាស់ឲ្យហៅពួកស្រីទាំងនោះឲ្យចូលមកគាល់ព្រមគ្នា ព្រះអង្គត្រាស់ឲ្យព្រះស្នំទាំងឡាយ កាន់យកនំមួយម្នាក់ៗ ដើម្បីនឹងល្បងមើលបុណ្យពួកស្រីទាំងនោះ តែឲ្យនាងអសន្ធិមិត្តាយកក្រោយគេជាបំផុត ហេតុតែបុណ្យនាងក៏បានត្រូវជួបទៅលើនំដែលមានព្រះទម្រង់នោះ ទើបព្រះមហាក្សត្រិយ៍ត្រាស់ឲ្យស្រីទាំងនោះបកនំឲ្យព្រមគ្នាក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ក៏ពួកស្រីឯទៀតបកមើលនំរបស់ខ្លួនៗ ទៅមិនឃើញមានតែស៊ុកនំនោះ ឯនាងអសន្ធិមិត្តាបកនំទៅឃើញព្រះទម្រង់មួយវង់កាត់ថ្លៃមិនបានប្រាកដច្បាស់ ដល់ពួកនាងស្នំទាំង ១៦ ម៉ឺនប្រាំមួយពាន់នោះ ។ ទើបព្រះបរមក្សត្រិយ៍មានព្រះឱង្ការត្រាស់ថា “ម្នាលនាងទាំងឡាយ នាងរាល់គ្នាបានរើសយកនំមុននាងអសន្ធិមិត្តាៗយកក្រោយ ហេតុដូចម្ដេចក៏បានព្រះទម្រង់ទៅនាងអសន្ធិមិត្តា ?

ព្រោះដូច្នោះពួកនាងមិនគួរនឹងតិះទៀនដល់នាងអសន្ធិមិត្តា ជាអ្នកមានបុញ្ញា-និធិធ្វើទុកមកហើយក្នុងកាលមុននោះទេ ដែលជាស្រីអាចនឹងទទួលគ្រប-គ្រងនូវស្រិយសម្បត្តិបាន ” ។ ចាប់ដើមតាំងតែពីត្រឹមនោះមក ស្រីស្នំទាំងឡាយ ក៏នាំគ្នាស្ងៀមស្ងាត់ក៏តាមិនហ៊ានឫស្យាព្រះនាងអសន្ធិមិត្តាទៀតឡើយ កាលព្រះនាងអសន្ធិមិត្តានឹងសំដែងកុសលអំពីមុនឲ្យប្រាកដនោះ ព្រះនាងកាន់ប្រអប់ទិព្វដោយព្រហស្តខាងឆ្វេង ចាប់យកសំពត់ទិព្វដោយព្រះហស្តខាងស្តាំ ហូតយកបានចំនួនមួយពាន់ផាប់ថ្វាយដល់ព្រះមហាក្សត្រិយ៍ ហើយព្រះនាងចរិច្ចាគសំពត់ប្រាំរយៗ ដល់ព្រះរាជ-វង្សានុវង្ស ដល់ពួកស្រីស្នំ ដល់ពួកសេវកាមាត្យ ព្រមទាំងចតុរង្គសេនាទូទៅទាំងនគរ ព្រះបាទអសោកករាជបពិត្រ បានជ្រាបះហេតុអស្ចារ្យបំ-ភ្លែកដូច្នោះ ទើបព្រះអង្គត្រាស់សួរព្រះនាងថា: “នុ អសន្ធិមិត្តា នាងបានប្រអប់ទិព្វនេះមកអំពីទីឯណា ក៏អស្ចារ្យចំឡែកម៉្លេះទាញយកសំពត់ទាំងសែនក៏មិនចេះអស់សោះ?” ។

ព្រះនាងអសន្ធិមិត្តាក្រាបបង្គំទូលតបថា “បពិត្រមហារាជ កុសលដែលខ្ញុំម្ចាស់បានសន្សំទុកហើយអំពីអតីតជាតិ ទើបដល់មកជាតិបច្ចុប្បន្ននេះបានជាកុវេរមហារាជ ដែលជាអ្នករក្សាលោកទ្រង់ជ្រាបថា ខ្ញុំកំពុងមានទុក្ខព្រួយ គ្រាកាលព្រះមហាបពិត្រដាក់ព្រះរាជអាជ្ញាឲ្យរកសំ-ពត់ប្រាំមួយម៉ឺនមកប្រគេនដល់ព្រះសង្ឃនោះ ក៏កុវេរមហារាជបានប្រាប់

ខ្ញុំម្ចាស់ ឲ្យលើកដល់កុសលដែលបានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធ អំពីបុព្វជាតិនោះ ហើយប្រទានប្រអប់វិញនេះដល់ខ្ញុំម្ចាស់ ដែលជាប្រអប់ឲ្យនូវសេចក្តីប្រាថ្នាដល់ខ្ញុំម្ចាស់បានគ្រប់យ៉ាង ការឲ្យទានសំពត់សាដកមួយដល់ព្រះបច្ចេកពុទ្ធនោះ បានផលមកវិញយ៉ាងនេះឯង" ។

រឿងឲ្យទានជី

ខ្ញុំសូមទីពឹងនឹងព្រះភគវ័ន្ត ព្រះអង្គជាអសេក្ខបុគ្គលទ្រង់គង់ប្រថាប់នៅនាព្រៃឫស្សីកលន្ទក: ទៀបក្រុងរាជគ្រឹះ ។

សម័យមួយ ជាពេលគួរព្រះភគវ័ន្តទ្រង់ឃ្លុំចីវរហើយកាន់បាត្រមានពួកភិក្ខុខាងមុខ ខាងក្រោយហោមរោមជុំវិញ ស្តេចយាងចូលសំដៅទៅក្រុងរាជគ្រឹះ ត្រេចបិណ្ឌបាតតាមច្រកល្ហកក្នុងក្រុងនោះ ។

មានសេចក្តីដំណាលថា : "ព្រះអង្គជាបុគ្គលមិនរំភើបញាប់ញ័រ ហាក់ដូចជាភ្នំមាសមួយ ការយាងយាត្រារបស់ព្រះអង្គគួរឲ្យជ្រះថ្លា ហាក់ដូចជាការយាងយាត្រានៃរាជកុញ្ជរ ទ្រង់មានព្រះភក្ត្រមូលក្រឡង់ ហាក់ដូចដួងព្រះចន្ទពេញវង់[១] ទ្រង់មានភិក្ខុហោមរោមជាពួកៗ ទ្រង់យាងចូលទៅក្នុងព្រះមហានគររាជគ្រឹះអរិយាបថព្រះអង្គក៏សមរម្យជាទីបំផុត" ។

---

(១) តាមអដ្ឋកថាប៉ែកខាងបាលី ដែលអធិប្បាយពីមហាបុរិសលក្ខណថា ព្រះពុទ្ធមានព្រះភក្ត្រដូចវង់ព្រះចន្ទក្នុងថ្ងៃ ១២ កើត (គឺមិនពេញជាមូលសុទ្ធនោះទេ) ។

ព្រោះដូច្នោះ ព្រះអង្គទ្រង់ពុទ្ធដំណើរទៅដល់ទីក្រុងនោះហើយ គ្រាន់តែជាន់ព្រះបាទទៅត្រង់មាត់ទ្វារនគរ ក៏កក្រើកប្រថពី ៦ ដង ក្នុងពេលនោះ ។

មានសេចក្ដីដំណាលថា :

កាលព្រះមហាមុនីជាន់ព្រះបាទទៅត្រង់មាត់ទ្វារក៏ប្រថពីដែលប្រដាប់ទៅដោយមហាសមុទ្រព្រមទាំងភ្នំទាំងទីក្រុងសព្វអន្លើទាំងអស់ក៏ប៉ោងខ្ពស់ឡើងហើយស្រោមចុះទៅវិញខ្លួនឯង ។ កាលដែលព្រះអង្គយាងចូលទៅក្នុងក្រុងដោយទំនងយ៉ាងនោះ ពួកជនប្រុសស្រីទើបកើតមានសទ្ធាជ្រះថ្លាដ៏បរិសុទ្ធពល់ៗ គ្នាក្នុងក្រុងទាំងមូល ក៏ផ្អើលជ្រួលសូរគឹកកងរំពងទ្រហឹងអឹងអាប់ ហាក់ដូចជារលកនៃមហាសមុទ្រ គ្រាកាលដែលខ្យល់បក់ផ្ទួបមក ជនទាំងនោះនាំគ្នាបន្លឺសំឡេងដ៏ពីរោះរងំមុខគួរស្រណោះ ហាក់ដូចជាមិនមានអ្នកក្នុងលោកឲ្យលើសលុបជាងទៅទៀតឡើយ ។ ពេលដែលព្រះពុទ្ធជាម្ចាស់កំពុងយាងចូលទៅក្នុងក្រុងនោះ ទីទួលទីងភ្នំតូចៗ ទាំងឡាយ ក៏រាបស្មើទៅឯង មិនឲ្យមានខ្ពប់ទីងដុំក្រួសដីរដិបរដុបសោះឡើយ បន្ទាន់គំនរសម្រាមទាំងឡាយ ក៏បាត់បង់អស់រលីងពីលើផ្ទៃប្រថពី ពួកមនុស្សខ្វាក់ក៏បានមើលឃើញឡើង ពួកថ្លង់ក៏បានស្ដាប់ឮឡើង ពួកគក៏បាននិយាយកើតឡើង ពួកខ្វិនគមក៏បានដើរត្រង់ខ្លួនឡើង ពួកឆ្កួតក៏ត្រឡប់បានស្មារតីឡើង ពួកអ្នកខ្សត់ទុគ៌តក៏មាន

សម្បត្តិទ្រព្យបរិបូណ៌ឡើង ពួកអ្នកឈឺក៏ជាសះស្បើយបាត់រោគទៅ ក្មេង តូរ្យតន្ត្រីទាំងអស់ក៏កើតឮសូរសព្ទសាទរទំហឹងអឺងកង ដោយឥតគេវាយ គ្រឿងប្រដាប់ដ៏មានដម្លៃ ក៏រណ្ដំគ្នាឮសូរសព្ទសាទរគ្រប់បែបគ្រប់យ៉ាង ព្រះរស្មីដែលចេញពីព្រះសម្មាសម្ពុទ្ធក៏ផ្សាយទៅគ្របលើលោកសន្និវាស ទាំងមូល ដ៏ប្រសើរលើសក្រៃលែងជាងព្រះអាទិត្យទាំងមួយសែន រស្មី នោះបំភ្លឺគ្រប់វត្ថុទាំងខាងក្នុងទាំងខាងក្រៅឲ្យមានពន្លឺឃាក់ដូចជាពណ៌ នៃមាសរំសើយ ព្រះរស្មីដែលផ្សាយពីព្រះសម្មាសម្ពុទ្ធគ្របទៅលើពន្លឺ ព្រះអាទិត្យនិងព្រះចន្ទ្រ ហើយបំភ្លឺបាំងបាណកសត្វទាំងឡាយ ឲ្យមាន សម្ផស្សដ៏ត្រជាក់ ធ្វើឲ្យបាណកសត្វទាំងឡាយនោះ មានចិត្តសោមនស្ស សប្បាយរីករាយជាទីបំផុតគ្រប់ៗគ្នា ។ ហាក់ដូចគេលាបស្រឡាបលាយ លំអិតចន្ទន៍ក្រស្នាដល់អ្នកមានជម្ងឺគ្រុនឲ្យបាត់ក្តៅក្រហល់ក្រហាយ ទៅបាន" ។

គ្រានោះឯង ព្រះភគវ័ទមានព្រះអានន្ទជាបច្ឆាសមណៈព្រះអង្គ យាងតាមផ្លូវបានជួបនឹងកុមារ ២ នាក់ ម្នាក់ឈ្មោះជ័យ[១] ជាកូននៃមហា- ត្រកូល ម្នាក់ទៀតឈ្មោះវិជ័យ[២] ជាកូននៃត្រកូលសុភាពរាបសាៗ កុមារ ទាំងពីរនាក់នោះ កំពុងតែច្របាច់ដីលេងជាមួយគ្នា កសូន្យដីធ្វើជាទីក្រុង

(១) ជ័យកុមារ ដែលបានមកជាស្ដេចអសោកចក្រពត្តិ ។ (២) វិជ័យកុមារដែលបានមកជាសេនាបតីឯកឈ្មោះ រាធគុត្តៈ ។

មួយ ក្នុងក្រុងនោះធ្វើឲ្យមានដេរដាសទៅដោយទីគេហស្ថាន និងកោ-ដ្ឋាគារទាំងឡាយ ក៏ស្ទូឡដីនោះធ្វើជាគ្រាប់ស្រូវដាក់ពេញៗកោដ្ឋាគារទាំងនោះ ។ លុះកុមារទាំងពីរនាក់នោះ បានឃើញព្រះសម្មាសម្ពុទ្ធប្រដាប់ដោយទ្វត្តឹសមហាបុរិសលក្ខណៈ មានរស្មីពណ៌មាសផ្សាយចេញព្រោងព្រាយក្ដីពណ្ណរាយខ្ចៀលធ្លាក់ទៅទាំងក្នុងក្រុងទាំងក្រៅក្រុង ចាំងមកត្រូវវត្ថុទាំងឡាយក៏ក្លាយទៅជាពណ៌លឿងដូចជាមាសទាំងអស់មិនមានពណ៌អ្វីឲ្យក្លឹលុបលាងបាន លុះឃើញដូច្នោះហើយ ទើបមានចិត្តជ្រះថ្លា ក៏ជ័យកុមារចាប់យកដីដែលខ្លួនសន្មតថា គ្រាប់ស្រូវនៅក្នុងកោដ្ឋាគារនោះមួយក្ដាប់ថ្វាយទៅព្រះភគវ័ទដោយសេចក្ដីគោរព ។ រីជ័យកុមារជាសំឡាញ់ បានលើកដៃឡើងប្រណម្យជួយអនុមោទនាដោយសេចក្ដីពេញចិត្ត ។ ក្នុងលំដាប់នោះជ័យកុមារបានសូត្រគាថាសរសើរព្រះអង្គថា:

"លោក-អ្នកដែលពេញទៅដោយមេត្តាចិត្តត្រាស់ដឹងខ្លួនឯងដោយឥតសាស្ដាណាប្រដៅ មានព្រះរស្មីមូលក្ដីចិញ្ចែងជាពណ៌មាសខ្ចៀលធ្លាក់ផ្សព្វផ្សាយព្រះសរីរៈ ព្រះអង្គមានទឹកព្រះភក្ត្រដ៏ប្រកបដោយខន្តីនិងសោរច្ចគួរដល់សេចក្ដីគោរពនិងសេចក្ដីជ្រះថ្លា ខ្ញុំសូមថ្វាយដីដល់ព្រះតថាគត ខ្ញុំសូមឱនសិរសាគោរពចំពោះព្រះភក្ត្រនៃព្រះភគវ័ទ ចំពោះព្រះភក្ត្រលោកអ្នកដែលមានវដ្ដសង្សារកំចាត់បង់ហើយ" ។

គ្រាជយកុមារថ្វាយទានដីនោះ បានតាំងសេចក្តីប្រាថ្នាថា "អំណើះតទៅអនាគត ខ្ញុំសូមឲ្យលោកសន្និកសទាំងមូលតាំងនៅក្រោមស្វេតច្ឆត្រពង្សរបស់ខ្ញុំ(១) លុះសូត្រនូវគាថានេះហើយទើបថ្វាយនូវគ្រឿងបូជានោះទៅ មានសេចក្តីដំណាលថា :

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបថា កុមារនោះបានតាំងដំកល់សេចក្តីប្រាថ្នាត្រឹមត្រូវគង់ចិត្តល្អហើយ ពីព្រោះបានធ្វើទានមកលើបុញ្ញក្ខេត្តដ៏ឧត្តម នឹងមិនខានបានទទួលផលដ៏ប្រសើរនោះទេ ។

ព្រះភគវ័ន ព្រះអង្គពេញទៅដោយមេត្តាចិត្ត លុះទ្រង់បានទទួលដីមួយក្តាប់នោះហើយ មុនពេលដែលនឹងត្រឡប់មកវិញទ្រង់បានធ្វើអនុមោទនាដល់កុមារនេះឯងជាដើមហេតុដែលបណ្តាលឲ្យកុមារនោះបានជាស្តេច ។

ពេលនោះព្រះភគវ័ទព្រះអង្គទ្រង់ញញឹម ។ ព្រះអានន្ទលុតជង្គង់ លើកកំបង់អញ្ជលីប្រណម្យ ក្រាបទូលសួរថា "បពិត្រព្រះភគវ័ទ មិនមែនជាឥតហេតុឥតផលទេ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយទ្រង់ញញឹម មានហេតុការអ្វីបានជាព្រះអង្គសំដែងសេចក្តីញញឹមឲ្យប្រាកដឡើង ?"

គ្រានោះ ព្រះអានន្ទសូត្រនូវគាថានេះថា

---

១ ឯកច្ឆត្រា ឬចំរើ ដាក់ផែនដីនៅក្រោមស្វេតឆត្រតែ ១ ។

"លោកអ្នកដែលលះផុតស្រឡះចាកសេចក្តីសោកស្តាយ និងសេចក្តីទន់ដោយលោកធម៌ ហើយជាឯកអគ្គបុគ្គលក្នុងលោក មិនមែនឥតហេតុទេ ដែលទ្រង់ទឹងបញ្ចេញព្រះទន្តមានពណ៌ដ៏ដូចជាស័ង្ខនិងដូចជាក្រអាវឈូក ។ បពិត្រព្រះអង្គ! ទ្រង់មានព្រះសូរសៀង ហាក់ដូចជាផ្គរកំពុងលាន់ឮចេញមកចាកពពក ព្រះអង្គមានព្រះនេត្រហាក់ដូចជាភ្នែកគោឧសភរាជ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរផលបុណ្យនៃទានដីមួយក្តាប់នេះ ហើយនិងការដែលទ្រង់ធ្វើសេចក្តីញញឹមឲ្យប្រាកដនេះ" ។

ព្រះសម្មាសម្ពុទ្ធនេះទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទថា "ឱ អានន្ទ យ៉ាងហ្នឹងហើយ! យ៉ាងហ្នឹងហើយ! មិនមែនឥតហេតុឥតផលទេ ការដែលព្រះពុទ្ធទាំងឡាយទ្រង់ញញឹមនោះ អ្នកបានឃើញកុមារពីនាក់អម្បាញ់មិញនេះឬទេ? ។

ព្រះអានន្ទទូលតបថា បពិត្រព្រះភគវ័ន្ត! ខ្ញុំព្រះអង្គឃើញ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា មួយរយ(១)ឆ្នាំអំពីតថាគតបរិនិព្វានទៅ កុមារនេះនឹងបានជាស្តេចមានបុញ្ញានុភាពអាចញុំាងចក្រឲ្យប្រព្រឹត្តទៅ (ស្តេចចក្រពត្តិ) ជាម្ចាស់លើទ្វីបមួយក្នុងទ្វីបទាំងបួន(២) ជាស្តេចទ្រង់សច្ច-ធម៌ព្រះនាមព្រះអង្គថា អសោក ក្នុងក្រុងកុសុមបុរ (បាដលិបុត្រ) ស្តេច

---

១ សៀវភៅពុទ្ធសាសនារបស់លោកល្វី - ហ្វីណូត៍ ថា ស្តេចអសោកបានសោយរាជ្យខាងក្រោយព្រះពុទ្ធបរិនិព្វាន ២៦៦ ឆ្នាំ ។ ២ ទីប្រទាន: ចតុភាគិចក្រវ៉ិន ។

អង្គនោះ នឹងបានបែងចែកព្រះសារីរិកធាតុបានសាងព្រះស្តូប ៨៤,០០០ សុទ្ធសឹងតែវត្ថុមានដំឡៃ ដើម្បីជាប្រយោជន៍នឹងសេចក្ដីចំរើនដល់សត្វលោក" ។

ពេលនោះ ព្រះភគវ័ទ្រង់ត្រាស់គាថានេះថា:

"ក្នុងកាលជាខាងក្រោយនៃនិព្វានតថាគតទៅនឹងកើតស្ដេចអសោកឡើង គេហៅឈ្មោះរបស់ស្ដេចនោះនឹងល្បីឮទូទៅក្នុងទីឆ្ងាយ ស្ដេចនោះនឹងបានរៀបគាត់តែងអដ្ឋិធាតុរបស់តថាគត ហើយបានចែកចាយពេញទូទៅទាំងជម្ពូទ្វីប មានពួកមនុស្សព្រមទាំងទេពតាកាន់យកគ្រឿងសក្ការៈមកបូជាសារីរិកធាតុនោះ ។ ការឲ្យដីបន្តិចនេះ នឹងបានផលមកវិញដ៏ឧត្ដមយ៉ាងនេះ" ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់គាថានេះហើយ ព្រះអង្គប្រទានដីមួយក្ដាប់នោះទៅព្រះអានន្ទ ដើម្បីនឹងបានបាចព្រោះទៅត្រង់ទីដែលព្រះតថាគតស្ដេចយាងទៅ[1] គ្រានោះព្រះអង្គទ្រង់ត្រាស់ព្រះពុទ្ធដីកានេះថា "ឱ អានន្ទ[2] . . . . ។

១ ក្នុងរាល - ក៏ង: អានន្ទលាយអាចម៍គោជាមួយដីឡប់មួយក្ដាប់ដែលបានពីកុមារឡានោះ ហើយបោះទៅក្រឹត់ក្នុងវង្គចង្ក្រមនៃព្រះសម្មាសម្ពុទ្ធ ។

២ មានសេចក្ដីពិស្ដារទៅទៀត តែសៀវភៅច្បាប់ដើមមិនបានតនិយាយ ព្រោះតែចុចច្រើនជាគ្រឿងសំគាល់ថានៅមានតទៅទៀត ។

ក្នុងអតីតកាល ព្រះបាទពិម្ពិសារបានសោយរាជសម្បត្តិក្នុងក្រុងរាជគ្រឹះ ព្រះអង្គមានព្រះរាជឱរសដែលជាប់ជាដំណព្រះវង្សមកទ្រង់ព្រះនាមអជាតសត្រូវ ។

ព្រះបាទអជាតសត្រូវ មានរាជឱរស ទ្រង់ព្រះនាម ឧទានកក្រ ។
ព្រះបាទឧទានកក្រ " " មុណ្ឌ ។
ព្រះបាទមុណ្ឌ " " កាកវណ្ណី ។
ព្រះបាទកាកវណ្ណី " " សផល ។
ព្រះបាទសផល " " កុលកុចី ។
ព្រះបាទកុលកុចី " " សហមណ្ឌល ។
ព្រះបាទសហមណ្ឌល " " ប្រសេនជិត ។
ព្រះបាទប្រសេនជិត " " នន្ទ(១) ។
ព្រះបាទនន្ទ " " វិន្ទុសារៈ ។

ព្រះបាទវិន្ទុសារគ្រងក្រុងបាដលិបុត្រ ព្រះអង្គមានព្រះរាជឱរស ព្រះនាមសុសីមៈ(២) (ត្រូវជា ១៤ ដំណ) ។

---

១ អៈយុ- វង- កិត: ស្តេចនៃលកាន់ក្រុងបាតលិបុត្រជាដំបូង ទ្រង់ព្រះនាមព្រះបាទចន្ទ្រគុប្តៈ ព្រះអង្គមានឱរសព្រះនាមវិន្ទុសារ ព្រះនាមថាចន្ទ្រគុប្តនេះមិនមានក្នុងទីវ្យាវទានដឹងអាយុៈ វង- ចូនទេ ប៉ុន្តែពួកអ្នកប្រាជ្ញក្នុងទ្វីបអឺរ៉ុបច្រើនដឹងថាចន្ទ្រគុប្តនាមអាយុ. វង- កិង ។

២ រាជសម្បត្តិមិនបានសុសីមៈនេះទេ ក៏បានទៅអសោកជារាជឱរសដែរ តែក្នុងមហាវង្ស ហៅថា សុមនរាជកុមារ ។

គ្រានោះ ក្នុងក្រុងចម្បាល មានព្រាហ្មណ៍ម្នាក់មានកូនស្រី ១ ដែលបរិបូណ៌ដោយរូបសម្បត្តិដ៏ល្អសម នាងជាស្រីកែវ ហោរាពាក្យបាន ទាយជូនបិតារបស់នាង កាលពីថ្ងៃដែលនាងកើតមកថា "នាងកុមារិកានេះ នឹងបានជាអគ្គមហេសីនៃស្តេចអង្គមួយជាប្រាកដ នឹងបានជាទីសព្វព្រះរាជហឫទ័យនៃព្រះរាជាអង្គនោះ ហើយនឹងមានឱរសដែលល្បីកេរ្តិ៍ឈ្មោះពីរព្រះអង្គ មួយព្រះអង្គនឹងបានជាស្តេចចក្រពត្តិ គ្របគ្រងប្រថពីមណ្ឌល ជាម្ចាស់លើទ្វីបមួយក្នុងទ្វីបទាំង ៤ មួយព្រះអង្គទៀតកាលបើចេញបួសក្នុងព្រះពុទ្ធសាសនាហើយនឹងបានសម្រេចព្រះអរហត្តផល" ។

ចំណែកព្រាហ្មណ៍ កាលបើបានស្តាប់ពាក្យទំនាយដូច្នោះមានចិត្តពេញទៅដោយសេចក្តីត្រេកអរក្រៃពេក ទើបនាំធីតាចេញពីគេហស្ថានទៅកាន់ក្រុងបាដលិបុត្រ លុះដល់ព្រះនគរនោះហើយទើបគាត់តែងស្អិតស្អាងធីតានោះដោយគ្រឿងប្រដាប់ដ៏ល្អប្លែកៗ ហើយនាំទៅថ្វាយដល់ព្រះបាទពិន្ទុសារៈ ដើម្បីជាបាទបរិចារិកា ក្រាបទូលថា "សូមព្រះរាជតេជះសូមព្រះអង្គទទួលទុកព្រះនេត្រចំពោះនាងដ៏ល្អព្រម" ។ ព្រះបាទពិន្ទុសារក៏ទទួលនាងទុកជារាជបរិពារខាងក្នុងតែពួកនាងស្នំគំនាល់ក្នុងព្រះបរមរាជវាំង ជាស្រីប្រកបដោយសេចក្តីឫស្យា ក៏នាំគ្នាត្រិះរិះថា: "នាងនេះមានរូបល្អចំណាប់ កាលបើក្រឡេកមើលទៅ មុខគួរជាទីស្នេហា

គ្រប់ៗគ្នា នាងជាមហាសិរីរបស់នគរ បើព្រះមហាក្សត្រិយ៍ទ្រង់ទទួលទុកជាព្រះស្នំហើយ សមព្រះអង្គនឹងសព្វព្រះរាជហឫទ័យចំពោះតែនាងជាប្រាកដ នឹងមិនទ្រង់ប្រោសប្រាណដល់ពួកយើងឡើយជាដាច់ខាត បើដូច្នោះយើងត្រូវបង្រៀនវិជ្ជាដ៏ថោកទាបដល់នាង ដើម្បីកុំឲ្យស្ដេចសព្វព្រះរាជហឫទ័យ" ទើបគេបង្រៀនវិជ្ជាខាន់ព្រះកេសដល់នាង នាងទើបមាននាទីជាអ្នកកែងព្រះកេសា និងព្រះមស្សុនៃព្រះរាជា តាំងអំពីដើមមករហូតដល់មានសេចក្ដីស្ទាត់ជំនាញក្នុងសិល្បនោះ ។ ថ្ងៃមួយពេលដែលព្រះរាជាកំពុងផ្ទំ គេប្រើនាងឲ្យចូលទៅកោរព្រះមស្សុថ្វាយព្រះអង្គ លុះស្ដេចតើនឡើងចាកព្រះបន្ទំ ទ្រង់មានព្រះបន្ទូលថា "ចូរនាងកោរព្រះមស្សុឲ្យអញ" នាងក្រាបបង្គំទូលថា "ពរម្ចាស់ខ្ញុំម្ចាស់កោររួចស្រេចហើយ" ។ ពេលនោះព្រះរាជាទ្រង់ទតទៅឯកញ្ចក់ឃើញមែនដូច្នោះ ទើបទ្រង់ព្រះប្រណីនាង បានត្រាស់សួរថា "នាងត្រូវការបង់បានអ្វីខ្លះ?" ។

នាងទូលស្នងវិញថា "សូមទេជះ! ព្រះករុណាជាម្ចាស់ជីវិតលើត្បូង សូមទ្រង់ប្រោសមេត្តាតាំងខ្ញុំម្ចាស់ក្នុងទីជាមហេសីនៃព្រះអង្គ" ។

ព្រះបាទវិទូសារៈទ្រង់ប្រកែកថា "យើងជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នាងឯងជាស្រីជាតិថោកទាប នឹងឲ្យយើងតាំងនាងជាមហេសីដូចម្ដេចបាន? ។

នាងកុមារីក្រាបទូលស្នងថា "ព្រះម្ចាស់ខ្ញុំម្ចាស់មិនមែនជាធីតាមានជាតិដ៏ថោកទាបទេ ខ្ញុំម្ចាស់ជាធីតានៃព្រាហ្មណ៍ ៗ នោះបាននាំខ្ញុំម្ចាស់មកថ្វាយព្រះអង្គ ដើម្បីជាព្រះមហេសី ៗ តែពួកស្រីជាគំនាល់ មានសេចក្ដីប្រចណ្ឌឫស្យា បានបង្ហាត់វិជ្ជាដ៏ថោកទាបនេះដល់ខ្ញុំម្ចាស់ បានជាខ្ញុំម្ចាស់តាំងនៅក្នុងដំណែងនេះរបស់ព្រះអង្គ" ។

ព្រះពជាទ្រង់មានព្រះបន្ទូលថា "ចាប់ដើមតាំងតែពីត្រឹមថ្ងៃនេះទៅនាងកុំធ្វើកិច្ចនេះទៀតឡើយ " ។

កាលគ្រានោះ ព្រះមហាក្សត្រិយ៍ទ្រង់ដំកល់នាងទុកជាមហេសីឯក ទ្រង់មានព្រះរាជហឫទ័យស្នេហាប្រោសប្រាណចំពោះនាង តមកព្រះនាងក៏ទ្រង់គភ៌ កាលគ្រប់កំណត់ហើយក៏ប្រសូតព្រះឱរសមួយអង្គ ព្រះរាជាបានធ្វើពិធីសម្ពោធឲ្យទីថ្វាយព្រះនាមព្រះឱរសដោយមហាកម្មដ៏ធំ ពេលនោះទ្រង់ត្រាស់សួរព្រះនាងថា "នាងថ្វាយព្រះនាមព្រះឱរសដូចម្ដេច?" ព្រះនាងក្រាបទូលថា . "កាលដែលប្រសូតនោះ ខ្ញុំម្ចាស់មិនបានឈឺ
✓ ចាប់សោះ ព្រោះហេតុនេះ សូមថ្វាយព្រះនាមព្រះឱរសថា អសោក (ឥតសោក)" ៖ គ្រាខាងក្រោយតពីនោះមក ព្រះនាងបានប្រសូតព្រះឱរសទី ២ ទៀត ព្រោះព្រះនាងមិនបានលំបាកអ្វីក្នុងការប្រសូតសោះ ទើបថ្វាយព្រះនាមថា វីតសោក (ប្រាសចាកសេចក្ដីសោក[១] " ។

---

១ មហាវង្សបា ព្រះមាតាអសោកពុទ្ធិរសព្រះនាមនាង សិរិធម្មាមាតរាជបុត្រពីរព្រះអង្គគឺ: អសោក១ តិស្ស ១ ។

ព្រះសិរីពរយៈរបស់អសោករាជកុមារ មានសម្ផស្សរឹងគ្រោតគ្រាត ព្រោះដូច្នោះទើបមិនបានជាទីប្រោសប្រាណរបស់ព្រះបិតាឡើយ ។ ព្រះបាទពិន្ទុសារៈ មានព្រះអគ្គមហេសីនឹងព្រះឱរសឯទៀតជាច្រើនអង្គ ថ្ងៃមួយទ្រង់មានព្រះរាជហឫទ័យនឹកក្ដុកចង់ជ្រាបទំនាយដួងជាតាព្រះរាជកុមារទាំងអស់អង្គ ទើបត្រាស់ឲ្យហៅរាជបុរោហិតឈ្មោះបិង្គលវច្ឆមកហើយត្រាស់ថា “ចូរអ្នកពិចារណាមើលដួងជាតាកំណើតរាជឱរសរបស់ខ្ញុំទាំងអស់នេះ តើឱរសណានឹងបានជាស្ដេច ? ” ៕

(នៅមានត)

ពង្សាវតារក្រុងរោម

(តមក)

វគ្គទី ៦

មហាអាណាចក្ររោមខាងក្រោម

កាលព្រះបាទកុម្មោតអស់ព្រះជន្មទៅហើយ ក្រុងរោមក៏កើតចលាចលឡើងហូតវេលា ១ សតវត្ស ការចលាចលនេះ កើតឡើងដោយសារពួកទាហាន តែងតាំងរាជាធិរាជរបស់ខ្លួនឡើង ៗ តាមអំពើចិត្ត តាំងអំពីមានទំនៀមអនុញ្ញាត ឲ្យពួកទាហាន រើសតាំងនាយចៅហ្វាយរបស់ខ្លួនធ្វើជារាជាធិរាជឡើងកាលណា ការចលាចលក៏កើតឡើងមិនចេះចប់ ម្រាំខ្លះបានតាំងរាជាធិរាជឡើងម្ដង ៗ គេធ្វើសង្គ្រាមខូចជីវិតមនុស្សជាចំនួនច្រើន អ្នកឯណាមានជីវិតរស់នៅក្រោយគេបង្អស់ អ្នកនោះទើបបានទទួលដំណែងរាជាធិរាជ នៃមហាអាណាចក្ររោម ៗ ក្នុងវេលា ៩៣ ឆ្នាំមានរាជាធិរាជ សោយរាជ្យក្នុងក្រុងរោមដល់ ២៥ ឆ្នាំ សម័យនេះគួររាប់ថាជាសម័យដែលពួកទាហានបង្ហិនស្រុកទេស ៗ ការដែលពួកទាហានខំព្យាយាមរើសនាយចៅហ្វាយខ្លួនឡើង ធ្វើជារាជាធិរាជដូចពោលមកនេះ ព្រោះប្រសិនបើអ្នកឯណាបានធ្វើជារាជាធិរាជឡើង ទើងឲ្យរង្វាន់ដល់ទាហានជាចំនួនច្រើន ជួនកាលមានការដេញថ្លៃគ្នា

យ៉ាងសំបើម ដូចជារបស់ឡាយឡុងក្នុងផ្សារ ។ មានសម័យ ១ មានមនុស្សម្នាក់ត្រូវរើសធ្វើជាកជាធិកដោយទទួលក៏ប៉ុងជាទីងឲ្យរង្វាន់ដល់ពួកទាហាន ដែលបោះឆ្នោតរើសខ្លួនជាចំនួនម្នាក់ ៥០០០ ត្រណោក, មានមនុស្សម្នាក់ទៀតសន្យាថាទីងឲ្យរង្វាន់ទាហានម្នាក់ជាចំនួន ៦០០០ ត្រណោក ។ អ្នកខាងក្រោយនេះត្រូវបានទទួលដំណែងជាកជាធិកដ តែពួកទាហានដែលបោះឆ្នោតរើសនេះជាចំនួនកប់ហ្មឺននាក់ ទើបស្តេចដែលទើបសោយរាជ្យថ្មីរកប្រាក់ឲ្យបានគ្រប់គ្រាន់មិនបាន ជាហេតុឲ្យពួកទាហានសម្លាប់ស្តេចថ្មីនេះឥតត្រាប្រណី ។

ក្រៅពីការចលាចលនៅក្រុងរេម ពួកទាហានដែលនៅប្រចាំការនៅស្រុកក្រៅ ក៏បបួលគ្នាតាំងនាយរបស់ខ្លួនឲ្យឡើងជាកជាធិកដដែរ ហើយលើកទ័ពចូលមកក្រុងរេម ដែលជាហេតុឲ្យកើតសង្គ្រាមឡើងខាងក្នុងស្រុកឥតស្រាក ។ ដូចជាក្រុងរេមទើបកាន់តែអាប់ឱនចុះទៅជានិច្ច ក្រៅពីនេះពួកអាល្លឺម៉ង់ ដែលពួករេម៉ាំងធ្លាប់ហៅថា មនុស្សព្រៃនោះ ក៏លុកលុយចូលក្រុងរេមសាថែមទៀតផង ។ ក្នុងគ្រានេះឯង ពួករេម៉ាំងទើបដឹងខ្លួនថា ការឈ្លោះទាស់ទែងគ្នាឯងនេះ ជាភ័យមួយយ៉ាងធំ នាំឲ្យអន្តរាយស្រុកទេសទៅថ្ងៃក្រោយមិនខាន ទើបនាំគ្នាកែប្រែវិធីរើសជាថ្មី គឺជ្រើសរើសយកតែមនុស្សដែលមានគុណសម្បត្តិពូកែមែនៗ សម្រាប់ជួយស្រោចស្រង់ក្រុងរេមក្នុងគ្រាក្រនេះ

ទើបរើសបានក្សត្រ ១ អង្គទ្រង់ព្រះនាម អីល្លីរី (Illyrie) ក្សត្រអង្គនេះ មាននាមឆាយាថា ជាអ្នកកាន់ដែកក្នុងដៃ ព្រោះព្រះរាជាអង្គនេះធ្លាប់ប្រកាសថា ព្រះអង្គទ្រង់មានមាសទុកឲ្យមិត្តសម្លាញ់ និងមានដែកទុកឲ្យពួកខ្មាំង ។ ព្រះបាទអីល្លីរីទ្រង់គ្រប់គ្រងក្រុងរោមជាវេលា ៦ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៨១៣ ដល់ ៨១៨ (គ.ស. ២៧០-២៧៥) ទើបបាត់ការប្រាប់ប្រាមពួកមនុស្សព្រៃឲ្យដកថយចេញទៅបាន ។ តពីក្សត្រអង្គនេះ មានស្ដេច ១ អង្គទៀត ទ្រង់ព្រះនាម ប្រូបុស (Probus) ទ្រង់គ្រប់គ្រងក្រុងរោមជាវេលា ៧ ឆ្នាំ តាំងពីពុទ្ធសករាជ ៨១៩ ដល់ ៨២៥ (គ.ស. ២៧០ - ២៧៥) មានគេក្ដីឈ្មោះថាជាក្សត្រ មិនទ្រង់ប្រកាន់ខ្លួន មិនព្រមធំកើតកិត្តិយស ទ្រង់ធ្វើព្រះអង្គដូចជាមនុស្សធម្មតាសាមញ្ញ ។ តមកមានក្សត្រ ៣ អង្គទៀត ទ្រង់ព្រះនាមឌិយោក្លេទៀង (Dioclétien) ទ្រង់គ្រប់គ្រងក្រុងរោម ជាវេលា ២២ ឆ្នាំ តាំងពីពុទ្ធសករាជ ៨២៧ ដល់ ៨៤៨ (គ.ស. ២៨៤-៣០៥) ។ ក្សត្រអង្គនេះត្រូវពួកទាហានរើសតាំងឡើងដែរ តែដូនជាទៅត្រូវលើមនុស្សល្អ ព្រះអង្គទ្រង់ពង្រីកអាណាខេត្តចេញទៅទៀត ហើយថែមទាំងវេលានោះ ពួកស្រុកចំណុះផ្សេងៗ ក៏កើតចលាចលតតស្រាក សព្វត្រាន់កន្លងបរិវេណក្រុងរោមក៏មានចលាចលជានិច្ចដែរ ។ ព្រះបាទឌិយោក្លេទៀងទ្រង់យល់ថា មហាអាណាចក្រក្រុងរោមនេះ ធំទូលាយលើសកំលាំងមនុស្សម្នាក់ និងគ្រប់គ្រងឲ្យ

សព្វគ្រប់បាន ទើបទ្រង់ចែងអាណាចក្រជា ២ ភាគ ព្រះអង្គទ្រង់គ្រប់គ្រង ១ ភាគនៅចំណែកទិសខាងកើត តាំងទីក្រុងនៅនិកូមេឌី (Nicomédie) មួយភាគទៀតជាចំណែកទិសខាងលិច ទ្រង់ប្រទានឲ្យសម្លាញ់របស់ព្រះអង្គម្នាក់ឈ្មោះមក្សីមយាន (Maximien) មានសក្តិជារាជាធិរាជដែរ តាំងទីក្រុងនៅមីឡង់ (Milan) ។ ឯក្រុងរោមគេបានបោះបង់លែងតាំងទីក្រុងតទៅទៀត ។

ទុកជាបែងចែកមហាអាណាចក្ររោមជាពីរភាគដូច្នេះហើយ ក៏នៅតែឃើញថាធំហួសកំឡាំងក្សត្រពីរអង្គនឹងត្រួតត្រាបាន ទើបបែងចេញទៅទៀតជា ៤ ភាគ ទ្រង់តាំងកូឈួយថែមទៀតពីរនាក់ហៅថា សេសារ ។ ឯសេសារពីរនាក់ម្នាក់ឈ្មោះកុងស្តង់គ្លោរ (Constance Chlore) តាំងទីក្រុងនៅស្រុកត្រែរ (Trêves) ម្នាក់ទៀតឈ្មោះកាឡែរ (Galère) តាំងទីក្រុងនៅស្រុកសៀរមីយុម (Sirmium) ។ ក្នុងសម័យនេះជាសម័យដែលក្រុងរោមមានអូគុស្ត[1] ២ អង្គនឹងសេសារ ២ អង្គដែរ មានទីក្រុង ៤ មានរដ្ឋ-បាលក៏ ៤ ដែរ ។

ខណៈនេះ ព្រះបាទឌីយោក្លេទៀង ទ្រង់ផ្លាស់ប្តូរកែប្រែវិធីគ្រប់គ្រងស្រុកជាច្រើនយ៉ាង ហើយតមកខ្លួនព្រះអង្គនឹងមក្សីមយានក៏លា

១ ពាក្យថា អូគុស្ត ប្រែថា រាជាធិរាជ; សេសារ ប្រែថា ព្រះរាជា ។

ចេញពីរាជសម្បត្តិ ហើយព្រះឌីយោគ្លៀនក៏ទិវង្គតទៅ ក្នុងកំណត់ព្រះជន្ម ៦៨ វស្សា ។

វិធីគ្រប់គ្រងស្រុកតាមបែបដែលព្រះបាទឌីយោគ្លៀនទ្រង់ធ្វើទុកមកនេះ មិនបានស្ថិតស្ថេរចិរកាលតាមព្រះរាជបំណងទេ ព្រោះតែមកមិនយូរប៉ុន្មាន សេសារទាំងពីរនាក់ ក៏តាំងខ្លួនឯងឡើងជាអូគូស្ត៍ ហើយតាំងសេសារឡើងថ្មីទៀត នាំឲ្យពួកទាហានមិនពេញចិត្តជាច្រើន ទើបពួកទាហាននាំគ្នាតាំងកូនរបស់កុងស្តង់ត្យូរ ដែលមាននាមថា កុងស្តង់-តាំង (Constantin) នោះឡើងដំណែងជារាជាធិរាជដែរ ហើយតពីនោះមកក៏កើតសង្គ្រាមខាងក្នុងស្រុកឡើងទៀត ដោយហេតុការឡែករាំងរកទទឹងទាស់ ៗ ឯមក្ស៊ីមៀនដែលលាចេញទៅហើយនោះ បែរជាត្រឡប់ចូលមកដណ្ដើមអំណាចទៀតដែរ ហើយបាននាំយកកូនខ្លួនឈ្មោះម៉ុក្សង់មកជួយផង ៗ ក្នុងវេលាដែលកើតសង្គ្រាមខាងក្នុងប្រទេសនេះ ក្រុងរោមមានព្រះរាជាធិរាជដល់ ៦ ព្រះអង្គ តែនៅទីបំផុត កុងស្តង់តាំងមានកំឡាំងទាហានពូកែជាងគេ ទើបមានជ័យជំនះហើយបានធ្វើជានាយបៅ-ហ្វាយក្រុងរោមតែម្នាក់ឯង ក្នុងរវាងពុទ្ធសករាជ ៨៤៩ ដល់៨៨០ជាវេ-លា ៣២ ឆ្នាំ (គ.ស. ៣០៦-៣៣៧) ។ ព្រះបាទកុងស្តង់តាំងនេះ ជាក្សត្រមានបុណ្យសក្តិធំនៃក្រុងរោម ហើយបានធ្វើការសំខាន់ៗ មាន ជាប់នៅក្នុងពង្សាវតាររោមដល់ ៣ យ៉ាងគឺ: (នៅមានត)

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែ ១ ក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ២៣-២៤

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

សេចក្ដីជូនពរឆ្នាំថ្មី

គ្រិស្តសករាជ ១៩៥៣

ថ្ងៃ ១ យ៉ាំងវីយេ ឆ្នាំ ១៩៥៣ ជាថ្ងៃចូលឆ្នាំថ្មីតាមបែបលោកនិយម ទស្សនាវដ្ដី "កម្ពុជសុរិយា" សូមអនុភាពព្រះត្រៃរ័ត្នដែលជាឧត្ដមសរណៈក្នុងលោក ជួយអភិបាលឧបត្ថម្ភលោក - អ្នកជាទាំងប៉ុន្មាន សូមឲ្យបានប្រកបដោយសេចក្ដីសុខ - ចំរើន - អាយុយឺនយូរ - និរភ័យ - និរោគគ្រប់ទិវាត្រីកុំបីឃ្លាតឡើយ ៗ

កម្ពុជសុរិយា.

សេចក្ដីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពសៀវភៅថ្មីៗ ចេញផ្សាយដូចមានកយឈ្មោះខាងក្រោមនេះ:

១ - កាឡកសូត្រ និយាយពីកាឡកយក្សប្រែស្នាព្រះដ៏មានព្រះភាគ ៗ ដំឡៃ ១ កាត ០៛.៧៥ ៗ

២ - អភិនវភាសិត គឺសុភាសិតបាលី ដែលបានស្រង់យកពីគម្ពីរផ្សេងៗ ហើយប្រែជាពាក្យកាព្យភាសាខ្មែរ ៗ ដំឡៃ ១ កាត ០៛.១៥ ៗ

៣ - ព្រហ្មចារិយកថា និយាយពីព្រហ្មចារិយធម៌ ១០ ប្រការ តាមសីលទានជាដើម ។ ដំឡៃ ២៛.៤០ ។

៤ - កុម្ភជាតក និយាយពីដើមកំណើតសុរា និងទោសរបស់សុរា ។ ដំឡៃ ២ ភាគ ០៛.៣០ ។

៥ - បិសាចស្នេហា ជារឿងសម័យទំនើបថ្មី សេចក្តីពិរោះស្តាប់ ចាប់ចិត្តអ្នកមើល ។ ដំឡៃ ២ ភាគ ០៛.៣៥ ។

៦ - គម្ពីរវិសុទ្ធិមគ្គភាគ ១ បាលីសុទ្ធជាបែបរៀនបាលី សម្រាប់សាលាបាលីជាន់ខ្ពស់ ។ ដំឡៃភាគទី ៩ ១ ភាគ ២៛.៩០ ។

៧ - ច្បាប់ផ្សេងៗ ភាគទី ២ គឺច្បាប់កេរនេតិ - ច្បាប់បណ្តាំបិតា ច្បាប់ហៃមហាជន ។ ដំឡៃ ១ ភាគ ០៛.៣០ ។

*

* *

ទស្សនាវដ្តី "កម្ពុជសុរិយា" ឆ្នាំថ្មី គឺឆ្នាំ ១៩៤៣ នេះ យើងនឹងរៀបចំផ្សំរឿងឲ្យកាន់តែល្អមើលពិរោះស្តាប់ឡើងទៀត ទាំងខាងគតិលោកទាំងខាងគតិធម៌ ។ មួយទៀត សូមជូនដំណឹងថា អស់លោកអ្នកប្រាជ្ញជាក្រុមជំនុំព្រះត្រៃបិដក នឹងជួយតែងរឿងកំរៃផ្សេងៗ ដែលជាប្រយោជន៍ ទាំងខាងផ្លូវលោក ទាំងខាងផ្លូវធម៌ ទាំងពាក្យកាព្យ ទាំងពាក្យរាយ សម្រាប់ចុះផ្សាយក្នុងកម្ពុជសុរិយានេះដែរ ដូច្នេះ

ទំស្សនាវដ្ដីឆ្នាំថ្មីគង់មានរឿងល្អមើល សេចក្ដីក៏កាន់តែពិរោះពិសារឡើងទៀតពុំខាន ។ ក្រៅអំពីនេះ យើងនឹងប្រមូលរូបរួមដំណើរផ្សេងៗ ក្នុងលោក ធ្វើជាសេចក្ដីសង្ខេបខ្លីៗ ក្នុងមួយខែៗ ដើម្បីឲ្យអស់លោក-អ្នកជាវកម្ពុជសុរិយា បានជ្រាបហេតុភេទក្នុងលោកសព្វថ្ងៃនេះ ដោយឡែកទៀតផង ។

ហេតុនេះ សូមអស់លោក - អ្នកដែលត្រូវការចង់ជួយទំនុកបំរុងអក្សរសាស្ត្រ និងចំណេះចេះដឹងរបស់លោកអ្នកឲ្យបានចំរើនឡើង សូមមេត្តាទៅចុះឈ្មោះជាវតាំងអំពីដើមឆ្នាំនេះឲ្យហើយស្រេចទៅ ដើម្បីឲ្យពុទ្ធសាសនបណ្ឌិត្យលៃលកបោះពុម្ព ឲ្យបានចំនួនគ្រប់គ្រាន់ដល់អ្នកជាវទាំងអស់គ្នា ។

បញ្ជីរឿង

ទំព័រ

១ — វិប្បធម្មទេសនា កណ្ឌទី ១៣ ព្រះគ្រូវិនយធម្ម ហ៊ំ-ជា ក្រុមជំនុំព្រះត្រៃបិដក សំដែង ១

២ — ច្បាប់ផ្សេង ៗ ភាគ ៤ :

១) ច្បាប់មហាវេត ភាគសូស្តី ១០

២) ល្បើកច្បាប់ក្រិត្យក្រម ២៧

៣ — ប្រវត្តិពួកឧបាសិកា ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់ :

៥) នាងឧត្តរា - នន្ទមាតា ៤៥

៦) នាងសុប្បវាសា - កោលិយធីតា ៤៧

៤ — រឿងព្រះបាទអសោក អ្នកអាចារ្យ គឹម - អាន ប្រែនិងរៀបរៀង (តមក) . ៥១

៥ — ពង្សាវតារខេមរ ស្រង់យកអំពីគោលបារីកផ្សេង ៗ ក្នុងពង្សាវតារលោក (តមកនិងចប់) ៦៦

៦ — ភូមិសាស្ត្រសង្ខេប នៃទ្វីបអូស្ត្រាលី ៧៣

TABLE DES MATIÈRES

Pages

1. Vidyudhammadesanā (conférence faite à la Radio Phnôm-Penh), par le Vénérable Préas Krou Vinayadhamma Hy-Chéa, membre de la Commission du Tripitaka 1

2. Chbab divers (4ᵉ partie):

I. Chbab Mahanet Rājasvasti.......................... 10

II. Lbeuk chbab krit-kram 27

3. Vies des disciples du Bouddha:

V. La Vie de Uttarā Nandamata.......................... 45

VI. La vie de Suppavāsā-Koliyadhita.......................... 48

4. Légende de l'Empereur Açoka de l'Inde antique, par feu l'Achar Kim-Ann (suite) 50

5. Histoire de Rome. Extraits de divers documents de l'histoire universelle (suite et fin).......................... 66

6. Géographie sommaire du continent australien 78

វិទ្យុធម្មទេសនា កណ្ឌទី ១៣

ព្រះគ្រូវិនយធម្ម ហឹ-ជា ក្រុមជំនុំព្រះត្រៃបិដក

សំដែងនៅថ្ងៃសុក្រ ១៤ កើតខែជេស្ឋ ឆ្នាំមមីចត្វាស័ក ពុទ្ធសករាជ ២៤៨៥

ត្រូវនឹងថ្ងៃ ២៩ ម៉ៃឆ្នាំ ១៩៤២ ។

វេលានេះ អាត្មាភាពនឹងសំដែងធម្មកថា ពណ៌នាព្រះសទ្ធម្មដែលជាពាក្យប្រដៅរបស់ព្រះដ៏មានព្រះភាគ តាមអភិលក្ខិតសម័យ ដែលត្រូវវេនមកដល់អាត្មា ដោយលំដាប់ ដើម្បីជាផ្លូវចំរើនសតិបញ្ញា និងសម្មាបដិបត្តិ នៃពុទ្ធមាមកបរិស័ទទាំងឡាយ ។

ធម៌ទេសនានេះ អធិប្បាយផ្លូវធម៌នៃផ្លូវលោក គឺសេចក្ដីជាអ្នកអង់អាច ក្នុងករណីយកិច្ចតូចធំទាំងពួង គឺប្រកបដោយសេចក្ដីពិចារណា ស្ទង់មើលដោយឧបាយដ៏ប្រពៃ ហើយទើបចាត់ធ្វើដំណើរកិច្ចានុកិច្ចនោះៗ ឲ្យផុះដាលជាផលល្អ តាមដែលត្រូវការរបស់ខ្លួន របស់អ្នកដទៃ រហូតដល់ទៅជាតិ សាសនា មហាក្សត្រ ស្រុកទេសរបស់ខ្លួន ។

សំដែងសមត្ថទេសនា គឺសេចក្ដីជាអ្នកអង់អាច . សមត្ថទេសនានេះ មានសេចក្ដីទូលាយណាស់ ទើបគួររួមកំណត់ទុកឲ្យនៅក្នុងរង្វង់ តាមដែលត្រូវការដូច្នេះគឺ:

១ អាចសមតាមអត្តភាព

២ អាចសមតាមដំណែងមុខការ

៣ អាចសមតាមពួកគណៈ

៤ អាចសមតាមធម៌ ។

សេចក្ដីអធិប្បាយក្នុងសមត្ថទាំង ៤ យ៉ាងនេះគឺ:

១ – ការដែលតាំងខ្លួនបានជាបុគ្គលស្អកស្អមម៉ាំមួន ឈ្មោះថាអាចសមតាមអត្តភាព; ដោយសេចក្ដីគឺស្គាល់ដំឡៃរបស់ខ្លួនមានដើមថា មានជាតិដូចម្ដេច មានត្រកូលដូចម្ដេច មានភេទដូចម្ដេច មានយសស័ក្ដិត្រឹមណា ក៏អាចតាំងខ្លួនឲ្យសមតាមនោះ ចាប់ដើមតាំងតែជាអ្នកសុភាពរាបសា តែជាអ្នកអង់អាចក្លាហាន ក្នុងករណីយកិច្ចតូចធំ មិនជាក់ផុះព្យាយាម ប្រឹងធ្វើទាល់តែសម្រេចមកបាន ៗ មនុស្សដែលទន់ជាបំផុត មិនអាចនឹងតាំងខ្លួនឯងបាន ទើបមិនសមគួរនឹងប្រព្រឹត្តដូច្នោះ សូម្បីក្នុងខណៈធ្វើករណីយកិច្ច ប្រសិនបើមានឧបសគ្គមកជំទាស់ ក៏មិនគួរនឹងរអាចិត្តធុញថប់ចុះចាញ់ងាយ ៗ គោងប្រុងប្រយ័ត្នកុំឲ្យខូចការ តាំងចិត្តកំណត់ប៉ុនប៉ងធ្វើរឿយ ៗ ទៅកុំឈប់ ធ្វើដំណើរចិត្តឲ្យរីកកាយក្នុងសេចក្ដីមិនប្រមាទ ហើយថ្នមគ្រាចិត្តនោះទុកទាល់តែអាចដកខ្លួនឲ្យផុតឧបសគ្គនោះជាដាច់ៗ រហូតដល់ជាន់ទីបំផុត ប្រៀបដូចជានិទងដែលស្វាហ៍

ខាត់ជំរះមន្ទិលមាសឲ្យស្អាតបន្តិចម្តងៗ ទាល់តែមាសឡើងពណ៌ភ្លឺថ្លា គួរប្រើជាគ្រឿងប្រដាប់ដ៏មានដំឡៃ ។ ដោយន័យនេះ បុគ្គលដែលសុខចិត្តចាញ់ឧបសគ្គណាយៗ ក៏ដូចជាឧបក្រសោបខ្ទុកមកខ្ទុកក្នុងខ្លួន ទើបសមគួរណាស់ ទឹងយកចិត្តទុកដាក់សង្កេតមើលការងាររបស់ខ្លួន ដែលធ្វើសម្រេចហើយ ឬនៅមិនទាន់សម្រេច កាលឃើញថាមានឧបសគ្គមកជំពាស់ ក៏ទឹងមិនបានទម្រន់ដាក់ធុរៈអាចិត្តណាយ ។ ហើយខំព្យាយាមពុះពារឲ្យរួចផុតទៅបាន ក៏អាចតាំងខ្លួនជាធំបានដោយពិតប្រាកដ ។

២ – សេចក្តីអាចសមតាមចំណែកមុខការ មានអធិប្បាយដូច្នេះ មនុស្សយើងពល់រូបរស់នៅបានដោយអាហារ ទើបត្រូវតែស្វែងរកអាហារមកចិញ្ចឹមជីវិត ដោយប្រកបកិច្ចធុរៈតាមបេះដូង ទឹងសេចក្តីគាប់ចិត្តរបស់ខ្លួន តែចិត្តរបស់មនុស្សនេះផ្សេងៗគ្នា ហេតុនោះ ទឹងប្រកបកិច្ចធុរៈប្រភេទជាមួយគ្នា តែទាំងអស់គ្នាក៏មិនបាន កិច្ចធុរៈទើបមានច្រើនប្រភេទ មនុស្សម្នាក់ៗ ទឹងធ្វើឲ្យសព្វគ្រប់ប្រភេទក៏ពុំបាន ទើបភាគចែកមុខគ្នាធ្វើដោយមុខដោយយ៉ាងទៅ ដូចយ៉ាងមុខការបង្ហាត់បង្រៀនប្រដៅ, មុខការពេជការ, មុខការលក់ដូរ, មុខការស្រែចំការ, មុខការចំណែកខ្លួនជាដើម រួមសេចក្តីទៅថាមនុស្សយើងតែងមានមុខការសម្រាប់ខ្លួនពល់រូប ហេតុនោះ សេចក្តីអាចសមតាមមុខការ ទើបជាកិច្ចដែលត្រូវប្រាថ្នា កាលមានមុខការយ៉ាងណា ក៏អាចចាត់ធ្វើឲ្យសមមុខការយ៉ាងនោះ

បដិបត្តិយ៉ាងណា ដែលអ្នកប្រាជ្ញលោកហៅថា អាចសមតាមមុខការ ក៏គោរពបដិបត្តិយ៉ាងនោះ មានដើមថា ជាអ្នកល្អិតល្អ មានសេចក្តីចេះដឹងករណីយកិច្ចតូចធំ ក្នុងមុខក្រសួងរបស់ខ្លួនសព្វគ្រប់ ហើយបដិបត្តិទៀងត្រង់ក្នុងមុខក្រសួង រក្សាមុខការឲ្យរៀបរយជាដរាប មិនបណ្តែតបណ្តោយឲ្យការងារសេសសល់ ទាំងគោរពគិតតែខំជួសជុលបំពេញឲ្យចំរើនជឿនទៅមុខជាទីតាំងប្រយ័ត្នរាំងមិនឲ្យសាបសូន្យថយចុះ ដូច្នេះគួររាប់ថាអាចសមតាមមុខការ ។

ទី ៣– សេចក្តីអាចសមតាមពួកគណៈ មានសេចក្តីអធិប្បាយថា:

មនុស្សយើងនឹងនៅតែម្នាក់ឯងក្នុងលោកនេះមិនបាន ត្រូវតែបងសម្ពន្ធទាក់ទងគ្នាទៅវិញទៅមក សេចក្តីសម្ពន្ធនេះឯង បង្គាប់ឲ្យរួមជាពួក តាំងដើមអំពីរួមគ្នាជាគ្រួសារនិមួយៗ ឬក្នុងរវាងវង្សញាតិនិមួយៗ ឡើងទៅ ដរាបដល់រួមជាជាតិនិមួយៗ ជាទីបំផុត ក៏តែគ្រួសារវង្សញាតិ ឬជាតិនោះដែលនឹងតាំងនៅមាំមួនអស់កាលជាយូរ ក៏គោរពអាស្រ័យបុគ្គលដែលនៅក្នុងពួកព្រមព្រៀងចិត្តគ្នា ប៉ុនប៉ងបំណងរកសេចក្តីចំរើនមកឲ្យពួក មានគោលដែលបំណងត្រង់ត្រូវគ្នា មានសេចក្តីស្និទ្ធស្នាលស្រឡាញ់រាប់អានគ្នាជាចិត្តមួយ អនុគ្រោះសង្គ្រោះបែកចាយដល់គ្នាទៅវិញតាមដែលត្រូវការ មានសេចក្តីប្រព្រឹត្តស្មើគ្នា រួមកម្លាំងផងគ្នា ជួយគ្នារក្សា ទំនុកបម្រុងពួករបស់ខ្លួន ចូរមើលតួយ៉ាងពួកដែលរុង-

រៀងហើយ គេចាត់ការទំនុកបម្រុងពួករបស់គេឲ្យរុងរឿងដោយវិធីយ៉ាងណាខ្លះ ក៏ជួយគ្នានាំយកវិធីការ (បែបផែន) របស់គេនោះមកប្រៀបធៀបនឹងវិធីការ (បែបផែន) របស់ខ្លួន ឃើញត្រង់ណាដែលជាការល្អទៅ ខ្វះកង្វះ ក៏ជួយគ្នាទំនុកបម្រុងឲ្យបរិបូណ៌ឡើង ត្រង់ណាដែលស្តុកស្តម្ភមាំមួនហើយ ជួយគ្នាជ្រោមជ្រែងរក្សាការនោះឲ្យបានឋិតថេរចិរកាលទៅ ឲ្យមានកិត្តិយសជាអារ្យជាតិ អារ្យជនដូចគេទាំងឡាយ ដោយន័យប៉ុណ្ណោះល្មមឲ្យឃើញថា សេចក្តីអាចសមតាមពួកនេះជារបស់ដែលមនុស្សគ្រប់រូបត្រូវតែប្រាថ្នា ដ្បិតពួកគណៈដែលនឹងចំរើនឡើង នឹងគង់ទ្រង់នៅដដែល ឬនឹងអ័ប្បឱនចុះព្រោះបុគ្គលអ្នកនៅក្នុងពួកនោះឯង ៗ កាលចំរើនរុងរឿងថ្លៃថ្លាវិសេស មានកេរ្តិ៍ឈ្មោះល្បីខ្ទរ មានសម្បត្តិស្តុកស្តម្ភសមតាមភាព បុគ្គលអ្នកនៅក្នុងពួកក៏ត្រកាលថ្លៃថ្លាដូច្នេះដែរ ចំណែកខាងសេចក្តីអ័ប្បឱន ក៏គប្បីដឹងដោយន័យនេះ ព្រោះហេតុនោះ កាលរួមនៅក្នុងពួកណា ក៏គេតែងប្រាថ្នារកសេចក្តីអាចឲ្យសមពួកនោះ ៗ

ប្រការមួយទៀត សេចក្តីអាចសមតាមពួកនេះកាលនឹងពោលតាមគោលគន្លងធម៌ រមែងសម្រេចមកពីអដ្ឋសម្បត្តិ ៨ ប្រការ គឺ សេចក្តីឈ្លាសវាងវៃក្នុងហេតុផល ១ សេចក្តីក្លាហានក្នុងផ្លូវដែលគាប់ ១ ស្តាប់អត្ថធម៌ច្រើន ១ ទឹងចងចាំទុកច្រើន ១ បដិបត្តិសមមុខការជាយ៉ាងល្អ ១

សេចក្តីជាអ្នកមានចិត្តធ្ងន់ មិនរហើររហាយហៅហារ ១ គោលធម៌ទាំង ៨ នេះ ជាអង្គសម្បត្តិឲ្យកើតសេចក្តីភាពសមតាមពួក ។

ទី ៤ – សេចក្តីភាពសមតាមធម៌ រីឯសេចក្តីភាពដែលនិយមថាជាឯក គឺគោរពយកធម៌ជាគោល ដូចពាក្យថាភាពជាឯកដូច្នេះ អ្នកពោលសំដៅដល់ពាក្យនិយាយដែលមានគោល ដែលអាចឲ្យសម្រេចផលសមតាមសំដី ដូចយ៉ាងពុទ្ធភាសិត ឬសុភាសិតជាដើម ពោលដោយបុគ្គលាធិដ្ឋាន សូមលើកយកទោណព្រាហ្មណ៍ជាឧទាហរណ៍ ដែលពោលទុកក្នុងពុទ្ធប្បវត្តិត្រង់បរិច្ឆេទចែកព្រះសារីរិកធាតុ មានសេចក្តីថា ក្សត្រទាំង ៦ នគរនិងមហាព្រាហ្មណ៍ម្នាក់បានជ្រាបកិត្តិស័ព្ទថា សម្តេចព្រះដ៏មានព្រះភាគស្តេចបរិនិព្វានទៅសាលវនោទ្យាន ក្នុងក្រុងកុសិនារា-កជាតិគឺបញ្ជូនទូតឲ្យទៅអញ្ជើញកងសារទនិងព្រាហ្មណ៍ សារ ឲ្យទៅសុំចំណែកព្រះសារីរិកធាតុ ។ ចំណែកឯក្សត្រទាំងឡាយដែលគ្រប់គ្រងព្រះនគរកុសិនារាទ្រង់ទទឹងទាស់យ៉ាងខ្លាំង មិនព្រមបែងចំណែកព្រះសារីរិកធាតុឲ្យ ការនោះគឺកម្រើកជិតតែនឹងកើតជាសង្គ្រាម កណ្តាលក្រុងកុសិនារា តែគ្រោះជា ដោយគ្រានោះ ទោណព្រាហ្មណ៍ ដែលជាធំចាស់ទុំមានបញ្ញាយោបល់ក្នុងការដែលនឹងសម្រួបសម្រួម ឲ្យត្រូវតាមគតិលោកគតិធម៌មានកថាជាសុភាសិត ជាទីជឿទុកចិត្តរបស់ប្រជុំជន អាចនឹងហាមឃាត់ការពារអធិករណ៍នោះឲ្យស្ងប់ទៅដោយសាមគ្គីធម៌ លុះបានពុស្ស

សត្វកំហែងហាននៃមល្លក្សត្រដូច្នោះ ទើបត្រិះរិះឃើញថា វាចាដូច្នោះ មិនជាធម៌ ទើបសំដែងខន្តិកថានិងសាមគ្គីធម៌សង្រួបសង្រួម ពាល់តែបានសម្រេចតាមវាចារបស់ខ្លួន គឺបានទទួលដំណែងជាអធិបតីចែកព្រះសារីរិកធាតុ ការឈ្លោះប្រកែករកផលខ្លួន ព្រាហ្មណទូតនិងមល្លក្សត្រទាំងឡាយក៏ស្ងប់ស្ងាប់ទៅបាន ។ រឿងនេះជាឧទាហរណ៍យ៉ាងទាបនៃពាក្យថា វាចាឯក និងវាចាអាចសមតាមធម៌ ទោះបីដូច្នោះ ក៏នៅប្រព្រឹត្តទៅដើម្បីសន្តិសុខក្នុងរវាងប្រជុំជនដូចពោលមកនេះបាន ហេតុនោះ សេចក្តីអាចសមតាមធម៌ ជាគុណដែលត្រូវប្រាថ្នាដោយពិត ដើម្បីជាបន្ទាត់វិនិច្ឆ័យករណីយកិច្ចតូចធំទាំងឡាយ ឲ្យត្រូវតាមគន្លងធម៌ក៏បាន ដើម្បីសន្តិសុខដល់ខ្លួននិងប្រជុំជនជាច្រើនក៏បាន ។ កាលនឹងពោលដោយធម្មាធិដ្ឋានសំដៅសេចក្តីដោយត្រង់ ក៏គឺអាចសាងសន្ទស្សុចរិតប្រព្រឹត្តល្អឲ្យមានឡើងបរិបូណ៌ក្នុងត្រៃទ្វារ ។ គុណធម៌នេះមាននៅក្នុងអ្នកឯណា រមែងធ្វើអ្នកនោះឲ្យមានសេចក្តីអៀនខ្មាសនិងខ្លាចសេចក្តីអាក្រក់ទាំងក្នុងទីកំបាំងទាំងក្នុងទីវាល គ្រប់កន្លែង គ្រប់វេលា ដោយយ៉ាងទាប សូម្បីតែបិទទ្វារ ហើយអង្គុយដំកង់លេងល្បែងភ្នាល់ ដែលច្បាប់ហាមក៏មិនហ៊ានលេង ព្រោះមានសេចក្តីអាចសមតាមធម៌នៅក្នុងខ្លួន ខ្ពស់ឡើងទៅ ក៏ជួយជ្រោមជ្រែងចិត្តឲ្យមានកំឡាំងអាចក្លាហានករណីយ-កិច្ចតូចធំទាំងពួង សមខ្លួន សមមុខការនាទី សមពួកគណៈបានល្អពិត

ទាល់តែអាចប្រមូលសេចក្តីល្អទាំងក្នុងផ្លូវលោកទាំងក្នុងផ្លូវធម៌ឲ្យមានបរិបូណ៌ឡើង ៗ ឯសេចក្តីល្អទាំងនោះ កាលមានដូច្នោះហើយ រមែងមិនបេរិលអស់ទៅឡើយ ទោះបីត្រូវសត្រូវបៀតបៀន ឬត្រូវអ្នកណាទីមួយសង្កត់សង្កិនឲ្យធ្វើសេចក្តីអាក្រក់ ក៏មិនធ្វើ ទោះនឹងសម្លាប់បង់ជាប្រាកដ សូម្បីដូច្នេះក៏គុំនិតឡើយថា អ្នកអាចសមតាមធម៌នឹងព្រមធ្វើសេចក្តីអាក្រក់ ព្រោះការជួយជីវិតខ្លួនឡើយ វិស័យអ្នកអាចសមតាមធម៌ រមែងឈ្លាសក្នុងឧបាយវិធីយកខ្លួនឲ្យរួចអំពីសេចក្តីអន្តរាយទាន់មនុស្សទាន់ហេតុការណ៍គ្រប់វេលា តែប្រសិនបើអំណាចលោកគ្របសង្កត់ខ្ទាំងហើយ ក៏គាត់សុខចិត្តស្លាប់ តែត្រង់សេចក្តីអាក្រក់ទៀងជាមិនព្រមធ្វើដាច់ខាត ដោយអំណាចធម៌ចូលទៅជំរះចិត្តឲ្យផូរផង់ ទើបចិត្តបាត់ងងឹតបានសេចក្តីព្រាងក្នុងចិត្តថា ទោះបីខ្លួនស្លាប់ក៏នៅល្អជាជាងដែលធ្វើសេចក្តីអាក្រក់ឲ្យបង់កិត្តិគុណ ព្រោះហេតុនោះ សេចក្តីជាអ្នកមានចិត្តដាច់ ប្រព្រឹត្តតែសេចក្តីល្អគ្រប់យ៉ាង មិនព្រមប្រព្រឹត្តសេចក្តីអាក្រក់ជាដាច់ខាត គួររាប់ថាអាចសមតាមធម៌ដូច្នេះ ៗ

គុណធម៌ខនេះ កាលមាននៅក្នុងបុគ្គលឯណា រមែងធ្វើបុគ្គលនោះឲ្យស្វាហាប់ក្លាហានអត់ធន់ ធ្ងន់ (មិនស្រើបស្រាលហោហា) អង់អាចក្លាហាន មិនខ្វល់ខ្វាយប្រុសស្រីញញើតក្នុងករណីយកិច្ចតូចធំទាំងពួង អាចញុំាង

កិច្ចការនោះ ៗ ឲ្យសម្រេចស្រេចទៅបាន ដោយមិនទើសទាក់ជំពាក់រ៉ឹម រាំមឬស្អប់ស្អែងក្នុងកិច្ចនោះ ហេតុនោះ សមគ្គភាពទើបជាគុណត្រូវតែប្រាថ្នាទាំងក្នុងផ្លូវលោកទាំងក្នុងផ្លូវធម៌ បើមានសេចក្ដីអាចហើយ ខ្ចាចខ្ចី រឿងការៈធ្ងន់ កុំថាតែធ្ងន់ម្យ៉ាងឡើយ ទោះបីក្រីក្រលំបាកយ៉ាងណា ក៏គង់មិនផុតវិស័យសមគ្គភាពទៅបាន គង់អាចចាត់ធ្វើសម្រេច រួមសេចក្ដីជ័យជំនះមកទុកក្នុងកណ្ដាប់ដៃទាល់តែបានជាប្រាកដ ដូចបានបរិយាយមកដូច្នេះ ។

ច្បាប់មហាជេតិកានន្ទសួស្តិ៍

បទកាកគតិ

ហៃបាតម្ចាស់ បុត្រច្បងសង្ក្រ ព្រះជនកស្នេហា កូនអើយបាចាំ បណ្ដាំនេះណា ទុំពុកទុកជា ស្នងអង្គឯក្រោយ ។ នាយោមន្ត្រី ព្រះបាទនរបតី កូនកុំបាត្រោយ ចូរបាកត្តី កុំបីបាឲ្យ អប្បយសឯក្រោយ ព្រះជនកឡើយណា ។ បើបាមានច្បាប់ មានមារយាទគាប់ ផ្គត់ផ្គង់ ឥរិយា កេរ្តិ៍ក្រើន ចំរើនឧស្សាហ៍ ដោយព្រះចិន្តា អម្ចាស់សព្វថ្ងៃ ។ កូនអើយបើបា ស្រស់ឧស្សាហ៍ សព្វព្រះហឫទ័យ បាអើយរបស់ យីន យសបាក្រៃ ព្រះអង្គទ្រង់ថៃ-ត្រីត្រេកស្នេហ៍ស្នាល ។ បើបាឥត ច្បាប់ ឥតមារយាទគាប់ ឥតសព្វឥតសារ បាអើយដំនៀល លោក ជៀលសព្វកាល អប្បយសអៀនកល ជាលដល់ទុំពុក ។ កូនអើយ លោកផង សិងស្វែងបំណាន់ ឲ្យលុះទូរស្រុង យសយីនសម្បត្តិ ឲ្យ ខ្ពាត់ផែងទុក្ខ ប្រាជ្ញាសោយសុខ សម្បត្តិលោកិយ ។ នឹងចូលទៅជា មន្ត្រីសេនា ក្សត្រាធិបតី ជិតជួបគាល់ហៅ ទិត្យនៅប្រក្រតី ខ្វះ មានបារមី អម្ចាស់ករុណា ។ ខ្វះសោះសូន្យទេ ត្រមោចឯឯង អសារ សោះសា ខ្វះបាខយសហើយ ព្រងើយវិញ្ញាណ យសនោះប្រែជា វិ-នាសពីប្រាណ ។ ក៏ហេតុនោះនៃ កូនអើយម៉ែនក្រៃ ចិត្តជាប្រឆាំង មាន នោមស្អាតស្អាង មារយាទបើគ្មាន ស្មើឥតវិញ្ញាណ សោះសូន្យអសារ ។

អ្នកមានប្រាជ្ញា លោកយកចិត្តជា ខ្ញុំមខ្លួនតែងធារ វិញ្ញាណជាអាទិ៍
មារយាទជាទា ស្មារតីដេញផាល លោកទោសមោហា ៗ ហេតុនោះកូន
អើយ ចិត្តកូវជាត្រើយ ពំនាក់អាត្មា ចិត្តជាប្រធាន ប្រៀនប្រាណ
សុខសា- បាយបទចិត្តជា អម្ចាស់រូបហោង ៗ វៃហបុធម្មបាល បុត្រ
ប្បងសង្សារ ព្រះជនកស្នងត្រង់ ពីថ្ងៃនេះទៅ បានៅរៀនវង គំនិត
គាប់ហោង បំរើមហាក្សត្រ ៗ កូនអើយកាលបា ចូលគាល់ក្សត្រា
លោកប្រើប្រយ័ត្ន ស្រគត់ឥន្ទ្រិយ ដោយក្តីប្រតិបត្តិ កុំបាផ្លៀងចិត្ត ហាវ
ហានសោះសា ៗ កុំខ្វាចពេកពន់ កុំហ៊ានលើសលន់ តើពោលវាចា
កុំធ្វើដំកើង កន្ទ្រើងអាត្មា កុំធ្វើសោះសា ត្រឡាគំនាល់ ៗ ចូរបាតាំង
ចិត្ត ប្រកបសីលក្រិត្យ ប្បាសប្បាប់នូវធម៌ ប្រកបប្រាជ្ញ ពិចារណា
ស្គាល់ ព្រះក្រិត្យអម្បាល កាលគាន់វេរ ៗ កូនអើយបើបា សព្វព្រះ
ទ័យា នៃព្រះគន្ធ ពោះមានសុខុម នោះសមព្រះកូ- បាលបើកខ្សែនូវ
ប្រាយប្រាប់បាហោង ៗ កាលព្រះពជា ក្សាន្តខ្សឹបប្រាប់បា សព្វ
សេចក្តីផង ចូរបាលបណាក់ រួមរក្សាត្រង់ ក្តីសុខុមនោះហោង ទុក
ក្នុងទ័យា ៗ ហេតុព្រះអង្គសង្ឃ ស្នេហាទុកចិត្ត ឯកឯងតែបា ល្អិតអ្វី
បាស្រោល បណ្តាលវាចា ប្រាយប្រាប់ឲ្យជា សាធារណ៍ក្តីនោះ ៗ នឹង
ព្រួទ្ធទ័រ ដួតជាប់ព្រះកាណ៌ ក្រេវក្រោធសុះសោះ គ្មានព្រះទ័យា
ដោយនាទោសនោះ ត្រង់ត្រូវចំពោះ ដូចផលបាហោង ៗ ទោះមាន

កិច្ចការ ផ្ទះក្រោយគតការ គ្រៃគ្រសព្វផង មានព្រះតម្រាស់ ត្រាស់
ប្រើបាហោង ដោយព្រះបំណង ចំណង់ហឫទ័យ ។ ចូរបាទសព្វាហ៍
ដោយគុណប្រាជ្ញ ស្រស់សព្វថ្ងៃ ចូរបាគ្រវែន ចំរើនរឹងរែក ដោយ
ដួចហឫទ័យ អ្នកជាអម្ចាស់ ។ កិច្ចការកាលណា សោតសឹងប្រើបា
កាន់ព្រះតម្រាស់ បេញចែកភ្នាក់ងារ កាន់ការឲ្យច្បាស់ ដោយព្រះ
តម្រាស់ តំរិះឲ្យធ្វើ ។ កូនអើយបាបូរ ចាំព្រះបន្ទូល អម្ចាស់ប្រុង
ប្រើ បៀងជាក់ក្នុងចិត្ត ពិនិត្យឲ្យធ្វើ ដោយនូវអំពើ ការកុំប្រហែស ។
បាបេញទៅថា ប្រាប់អស់ភ្នាក់ងារ រៀនហ្វឹងពិសេស ចែកចូលកាន់
ការ ភ្នាក់ងារលៃបលេស កុំបាប្រហែស លុះលង់កំណត់ ។ អស់
លោកផងនោះ សឹងយោធាខ្ពោះ អាមាត្យព្រឹទ្ធព្រទ្ធ បាចែកកំណាន់
✓ ការកាន់ដោយបទ កុំបារន្ធត់ ជ្រែដោយធន្មា ។ ជើងជញ្ជីង ក្អកទៀង
សុះសឹង សាយសព្វយល់ប្រា- កដកាន់លើកឡើង ថ្កល់ថ្កើងលោ ផារ
ក្រវង់ស្នើគ្នា ពុំខុនពុំឆើយ ។ លោតែងឆារ ក្អកទៀងប្រការ ម្តេចមិញ
កូនអើយ បាយកប្រាជ្ញ ពិចារណាហើយ មធូរសួរឆ្លើយ ដោយក្តីកោត
ការ ។ ទោះយប់ទោះថ្ងៃ ពជកិច្ចការនៃ ក្សត្រាទ្រង់ធម៌ បន្ទូលត្រាស់
ប្រើ បាធ្វើសព្វសារ- ពើពីព្រះហា- ឫទ័យទើបទៀងហោង ។ បាយក
ប្រាជ្ញ បេះពិចារណា ពជកិច្ចការផង ញឹកៗប្រក្រតី កុំបីឲ្យធ្លង កុំ
កាន់រលង លើសលែងអាញ់ ។ មួយសោតថាបើ ព្រះអង្គប្រាប់ប្រើ

ប្រដាប់មាត៌ ចូកចាំងប្រាលប្រាប ពលកបសោភា ដាពដមាត៌ នៃ
មហាក្សត្រឆ្ពោះ ។ កុំបាបណ្ដាល ចិត្តចង់ត្រអាល ដើរទៅផ្លូវនោះ រី
ទោសទណ្ឌភ័យ កើតក្រៃចំពោះ ដល់បាឯងស្មោះ ហៅប្រមាទចក្រី ។
កុំបាសេពសម កាមគុណប្រទ្យំ ជាមួយអង្គជ- ស្វូរសត្វទ័យា ដោយ
នាប្រក្រតី កូនអើយកុំបី បាត្រាប់ព្រះអង្គ ។ តោះបីមាលា គ្រឿង
គ្រប់គន្ធា បុប្ផាភ្ញីផង ក្រពេះបួងចន្ទន៍ សុគន្ធប្រេនប្រេង ប្រដាប់
ព្រះអង្គ តែងទ្រង់សព្វថ្ងៃ ។ ពុំនោះព្រះពរ ពស្ត្រាបវរ ព្រះកូសា
ថ្ងៃ សែសយផ្តិតផ្តាស បេសមាសទៃ ខ្ចប់ព្រះអង្គ ស្អាប់ព្រះ
ផង្សា ។ គ្រឿងណាព្រះអង្គ បពិត្រតែងទ្រង់ កូនអើយនោះបា
ពុំគប្បីស្អាង រូបពងអាត្មា ប្រហែលក្សត្រា អម្ចាស់លើសត្រៃ ។
មួយកុំបាធ្វើ ប្លែកប្លែងអំពើ ក្រិត្យក្រមវិស័យ ជាក្រមក្រិត្យមហា-
ក្សត្រាជេស្ឋជ័យ អំពើនោះនៃ ពុំគាប់បាឡើយ ។ កុំពោលពាក្យធំ
ស្វូរសើចប្រទ្យំ អម្ចាស់ត្រាណត្រើយ កុំពើកជា ដែលមហាក្សត្រ
ឡើយ កុំសងពោលឆ្លើយ ត្រាប់ក្រងរំលេវល់ ។ មួយតោះព្រះអង្គ
ក្សត្រាស្ដេចគង់ នៅបរិពារពល ស្រីគ្គារស្រស់ស្រី មហេសីសួស្តី
សល់ ក្សាន្តហាទ័យដល់ ស្រើបស្រួលសប្បាយ ។ កុំបាធ្វើស្និទ្ធ
ស្នេហាបូលចិត្ត មេត្រីពេះពយ ទ៏ងកដទេត នារីទាំងឡាយ កុំសើច
ស្វូរសាយ លេងលេញទៅមក ។ តោះទៅស្ពានស្ងាត់ បូរបាប្រយ័ត្ន

ប្រយោជន៍ឲ្យល្អ កុំបាស្រដី ពាក្យពីរោះរក់ គលគិច្ចទៅមក លលោយ
លេះលាក់ ៗ វីព្រះពជទ្រព្យ ក្លាក់ផ្ការណ្ដាប់ ត្រូតត្រាជៀនជាក់
ទុកព្រះយ៉ាំងខ្ជាប អ្នកកាចលួចលាក់ កុំបារ៉ជាក់ រ៉សេរកយកឯង ៗ
កុំដេកដល់ថ្ងៃ ពេកពន់វិស័យ លើសលោភតម្លៃង ពុំគិតកិច្ចការ
ក្លាក់ផ្ការខ្លួនឯង យល់បាពុំកែង ការពាន់អាជ្ញា ៗ ស្រាស្រាល
បង្អាត ពាក្យពោលរិះទ ទោសទណ្ឌភយា ក់តែងបញ្ចុក ទោស
ទុក្ខអាត្មា កូនកុំសេពស្រា ស្រវឹងហើយគាល់ ៗ ទោះព្រះបក្រី
ចំញ៉មបក្ស័ អម្រឹតរង្គារ កុំបាបង្ហិទ បៀនបំណួទៅញល់ បារជ្រាម
ជ្រែងការ រក្សាគ្រប់គ្រង ៗ កែគ្រឹះគុភាំង តែនទិព្វទីនាំង បល្ល័ង្ក
រៀបរង ហត្ថអស្សា រថយានជង ទោះទូកសោតហោង កុំបារៀង
ស្និត ៗ កុំបាបណ្ដាល ចិត្តអន្ធពាល ថាស្តេចស្នេហ៍ស្និទ្ធ ករុណា
ឲ្យមាន អស់យានអញស្និត កុំបាទុកចិត្ត ទៀងស្និតឯងឆាយ ៗ
បើបាចូលគាល់ កុំបាផ្ទុះផ្ទាល់ អម្ចាស់ពណ្ណរាយ កុំទៀបពេកពន់
កុំលទ់លាកឆ្ងាយ កុំបារលេងណាយ ប្រឡំពាលា ៗ គាល់គយរំពៃ
ផ្ទោះព្រះនេត្រនៃ ទតយល់នោះណា កុំបាផ្ទៀងផ្ទង់ កែងកែកហត្ថា
កុំលលុកគ្នា លេងលើគំនាល់ ៗ កុំទុកចិត្តថា ព្រះបាទក្សត្រា
ទ្រង់ព្រះត្រាសាល សប្បាយទំនងអញ ស្រឡាញ់គោតការ កុំជាស្ដេច
ខ្ជាល់ ស្ដប់អញពេកក្រៃ ៗ ទោះបីព្រះអង្គ ក្សត្រាទ្រិសទ្រង់

ករុណាបានៃ ឲ្យទ្រព្យាករ បវរលើសក្រៃ សព្វព្រះហទ័យ ទិព្យទេព
ឱនបា ៗ កុំបាអួតអាង លើសលើខុនណាង មន្ត្រីយោធា ថាស្តេច
ស្រឡាញ់ តែអញឯងណា កុំអាងអាត្មា លើសលែងលោកធង ៗ
កុំបាប្រទូស្ត ស្រដីរឹងរូស ពោលពាក្យធ្គាំធ្គង ទឹងព្រះអង្គឥ- ស្សរពិ-
សេសហោង កុំបាឃ្លើសឃ្លង លែងលោកសម្លាយ ៗ រីពផ្ទារ
លោកដាក់ភ្លាក់ងារ រក្សាសព្វសាយ គួរប៉េកគួររាំង គួរទាំងគួរស្រាយ
កុំបាពាយងាយ ហាវហានចូលឯង ៗ កុំបាធ្វើស្និទ្ធ ស្នេហាទុកចិត្ត
បេញចូលឥតក្រែង កុំអាងអាត្មា ផ្សិតជាធំឯង យល់បាពុំក្រែង ក្រិត្យ
ព្រះរាជា ៗ រីកិច្ចក្រិត្យក្រម ក្សត្រាឧត្តម ពុំងាយណាបា ប្រដូច
ភ្លើងហោង អ្នកផងរក្សា បើបេះកាន់រ៉ា ជាឥតសង្ស័យ ៗ ល្គឹកអ៊ី
ប្រហែស ភ្លើងនោះលុះលែស ឆេះឡើងលើសក្រៃ រាលពេលអាត្មា
ដល់នាលុះក្ស័យ ទូវកើតគិតភ័យ ក្រៃក្រប្រមាណ ៗ រីពជត្រកូល
អម្បាលអម្បូរ ព្រះញាតិប្រធាន បុត្រាសោភី បុត្រីកល្យាណ ទោះ
ព្រះអង្គមាន ព្រះរាជករុណា ៗ ពុំនោះស្រុកធំ នគរសោតសម
ខេត្តខណ្ឌសីមា ទោះនាយធំរី សារថីពៅ ខ្ទន់កាន់រក្សា ចៅរដើង
ជំនិត ៗ សម្តេចក្សត្រា សព្វព្រះទ័យា នៃព្រះបពិត្រ នៅទ្រង់
ករុណា ដោយនាស្នេហ៍ស្និទ្ធ ទោះយសសម្បត្តិ សម្បូណ៌អ្វី ៗ ៗ

កូនអើយកាលណា៖ បានគាល់ចំពោះ ព្រះនេត្រចក្រី ចាព្ទព្រះសួរ
បន្ទូលពេរ៉ា ពេះពយស្រដី ត្ពោះព្រះករុណា ៗ ទំនើបពស្តុអ៊ី ជន
ជានពណ៌ពី· សេសសព្ទទ័យា ពុំគិតពុំស្តាយ បែកបាយបេញជា
ផ្ទាំងអ្នកណា សព្វព្រះទ័យនោះ ៗ កុំបាទូលទាស់ លើព្រះតម្រាស់
តម្រិះឯងស្មោះ កុំកេកលកិច្ច ឲ្យដាច់លាភនោះ កុំកេកលដោះ ឲ្យ
សោះសូន្យទេ ៗ កុំកាំងកុំក កុំពេពោលពា ត្រណាត់ចិត្តគេ កុំរក
ទំនាត បង់ឃ្លាតឃ្មៀងឃ្មេ ឲ្យដាច់លាភគេ វិនាសបង់បាត់ ៗ កូន
អើយធម្មតា អ្នកមានប្រាជ្ញា លោកប្រើប្រយ័ត្ន ស្រគត់ឥន្ទ្រិយ
ដោយក្តីប្រតិបត្តិ កុំជួសត្លោយមាត់ ពោលពាក្យឥតក្រែង ៗ កូន
អើយបើហ្នោះ លោកថាបាបនោះ បៀតបានបាឯង ពៀប្រែការកម្ម
បងចាំពុំក្រែង បាបដ្សៀតមាត់ឯង ទាស់ទែងទានគេ ៗ បំណោរទៅនៅ
នរកព្រំព្រៅ ទល់ទុក្ខឥតល្ហែ បាបបទបន្ទាន ជនជាន់ទានគេ
បាបបាកចិត្តគេ នោះរឹងបាបក្រៃ ៗ ឫស្សីល្ងូតលាស់ ដើមដុះខ្ពស់
ណាស់ ដុំដោមត្រៃឈ ញ៉ើអេស់អង្គុទន លំទោនរាតវៃ ដោយ
ខ្យល់បក់នៃ ប្រការម្តេចមិញ ៗ ពុំនោះដូចដូ ជាងដៀងត្រិះត្រូវ
បិតបោសកោសបេញ សម្រេចសម្រួល ទន់ស្រួលបានបាញ់ ប្រការ
ម្តេចមិញ ពាក្យពោលហ្នោះហោង ៗ ចូរប្រាក្រពើន ទប់ទល់ចំពើន
ដោយជានគន្ធង សម្តេចក្សត្រា ករុណាឯងហោង នៃអ្នកនោះផង

សុខសាន្តសោមនស្ស ៗ អរព្រះករុណា អរមួយដៀតបា ជ្រោម
ផ្ដែផ្ដិតម្រាស់ ដ៏លោកគុណគាប់ សួរសព្វគ្រៃត្រាស់ ផល់បរលោក
ច្បាស់ សោយសុខសួគ៌ា ៗ អំពើគុណគាប់ នេះហោងជាច្បាប់
ច្បាស់នៃអាត្មា ឧិងជាអាមាត្យ វរបុត្រក្សត្រា សព្វព្រះទ័យា យស
យឹនវេរបិត ៗ កូនអើយក្សត្រា កាលគង់ក្រឡា គំនាល់ផុំផិត ទ្រង់ព្រះ
ក្រសាល អម្បាលស្នេហ៍ស្និទ្ធ នោះសឹងពោលពិត ទូលទៅទៃ ៗ
កូនកុំថាហ្មោះ គាល់គយចំពោះ ព្រះនេត្រទិព្យថ្ងៃ គួរគប្បីថ្លៃ សំដែង
សម័យ បើពុំគួរនៃ ស្ងៀមត្រៃកូវជា ៗ ទោះមានសន្ទិះ អាថ៌អត្ថរកោះ
កុងព្រះទ័យា នូវចង់ជឹងដាន បុមានប្រាជ្ញា ប្រែព្រះកក្តា ភ្ញោះមក
ដណ្ដឹង ៗ កូនកុំបាលង់ ពេកពេញចិត្តផ្ដង់ ទូលដោយដំណឹង ដំណើរ
ដំរោកាល ប្រការផ្សេងៗ អាថ៌នោះឲ្យដឹង ច្បាស់ច្បាប់ធម៌ថា ៗ ពាក្យ
ពោលសារសត្យ ល័ក្ខណ៍លែបល្អិតក្កាត់ សួរសព្វរំពា ទូលជាទិទាន
ដោយដានកគាំ មោះនោះកុំបា សាំសិនប្រែនពេក ៗ បូរបា៖សព្វាប៌
បំរើបិតា មាតាតិរេក គុណគម្ភីរសា· គរមហាអនេក អនន្តតិរេក ដុង
ដោមខ្ពស់ត្រៃ ៗ អណ្ដាប់រៀមច្បង កោតកុំឃ្លើសឃ្លង វក្សាសព្វ
ថ្ងៃ អម្បាលអម្បូរ ត្រកូលហ៊ីនហៃ វត្តរមមូលមៃ ត្រើត្រែកស្នេហ៍-
ស្នង ៗ បូរបាខ្ញាសបាប វៀរអស់ផងពប ជីវិតសត្វផង វៀរកិច្ចកល
កាប អង់អាចឃ្លើសឃ្លង វៀរទោសទណ្ឌផង លះលែងគ្រឿងគ្រោធ ៗ

ចូរឧស្សាហ៍ ស្វះស្វែងប្រាជ្ញា រៀនរិះចំណោទ គម្ពីរធារធម៌ អស់
អាថ៌សុះសោត ក៏ចូលចំណោទ ឥតឯមានចួល ។ ចូរបាចាំចប់
គម្ពីរសោយស្រួញ- ស្រោះស្រោះយុគយល់ ទំនឹងទំនាយ ប្រះប្រាយឥតចួល
សុះសារពើកល កិច្ចក្ដីសាស្ត្រា ។ ចូរបេះផ្សំថ្នាំ កិច្ចកលកាយកម្ម
អាថ៌អាថ៌ពេតា ជាថ្នាំប្រាំសប្រោះ បុរសនានា ចូរឧស្សាហ៍
សស្ត្រោះញាតិផង ។ ទោះសារពើការ ជាងជៀងសព្វសារ- ពើពណ៌
ឥតខ្ចង់ ត្បូងត្រៃត្រាច់ ក្បូរក្បាច់គាពផង ចូរបាចាំចង ចិត្តបេះសុះ
សាយ ។ វិគុណប្រាជ្ញ ទោះគុណសាស្ត្រា គំនាប់គ្រឿងាយ ជា
យានបិតថេរ កើតកេរ្តិ៍សុះសាយ ទសទិសសម្លាយ រួចផុតស្ងួត ។
ចេះហោងកូនអើយ ប្រាជ្ញាជាត្រើយ តំងកក់អាត្មា ស្មាតើកុំជាប់ ភ្នាំង
ភ្លេចឡើយណា ចូរឧស្សាហ៍ ព្យាយាមលំនឹត ។ អ្នកចាស់ព្រឹទ្ធា
ស្រមណ៍ព្រាហ្មណ៍គណា- ចារ្យចាំស៊ីលសុទ្ធ ពហុស្សូតសព្វ ច្បាស់
ល្អប់ត្រៃទ្រព្ធ កិច្ចកម្មការគត់ ព្យាយាមកុំបង់ ។ អស់លោកនោះ
ហោង ចូរចារឹបាំង រួសរិះបម្រុង គោរពប្រតិ- បត្តិពិសេសផ្ចង់
ហាច័យត្រេកត្រង់ អរនុនសង្ឃ ។ ចូរបាចាំអែក គោជទ៍ពស្តុពិសេស
ពិសុទ្ធខាងខា បារីងអវៀ ដូចដៅយប្រាជ្ញា ចូរឧស្សាហ៍ បំរើកុំដាច់ ។
ទោះមានសទ្ធិះ កន្លាវែងរិះ កុំបាភ្នាំងភ្លេច ត្រង់ណាក៏ចូល ឆ្ងាយ

ធ្វល់គុំស្រេច លោកនឹងសម្រេច សម្រាលបាបហោង ។ ចូរបានុទនអង្គ
ជិតផ្ទួញទៅត្រង់ ស្រមណ៍ព្រាហ្មណ៍ព្រឹទ្ធជង ជណ្ដើងត្រង់កម្ម ទឹង
នាំរូបវង កម្មកើតចាំចង ជាតិជាវេរ ។ ម្ដេចហៅសុខសឹង ម្ដេច
ហៅតំទឹង ពំនាក់អាត្មា លោកិយកេ្យមក្សាន្ត លុះបានសួគ៌ា អំពើ
នោះណា ប្រការម្ដេចសោត ។ ម្ដេចហៅទៀតទាន ចាំសីលសមាទាន
លះលែងក្រវែក្រោធ ម្ដេចលោភទោសា មោហោសោះសោត ម្ដេច
ហៅអ្នកនោត កាន់វេរប្រាំ ។ វេរវៀរេបី សឹងកើតអំពី អង្គអាទិ៍
កាយកម្ម មនោវាចា វេរបោមចាំ ម្ដេចនឹងឲ្យនាំ បៀសចាករដោះ ។
ស្រមណ៍ព្រាហ្មណា- ចារ្យចាស់ព្រឹទ្ធា អស់លោកទាំងនោះ សឹងមាន
មេត្តា ករុណាអនុគ្រោះ ស្រាយអស់ហេតុនោះ សណ្ដាប់បាបហោង ។
កូនអើយកាលណោះ នាលោកអនុគ្រោះ អស់កន្លាជង ចូលបាវៀង
ជាក់ រូមក្សាគ្រង ធម៌នោះឯងហោង ខ្ញុំទូនអាត្មា ។ ចូរបាដំកល់
ចិត្តតែកុសល ត្រង់ត្រែកសទ្ធា ស្លូតស្មោះកំសត់ ខ្ញុំគិតកំព្រា ចូរ
បាទស្វាហ៍ ឲ្យទានកុំដាច់ ។ កុំបង់សីលា សីលសេពភាវនា កាន់
កុំបីភ្លេច កុំស្រោលស្រេបស្រែ ទានគេកុំផ្ដាច់ កុំរិះគលកិច្ច ចៃណែន
លោកផង ។ រាស្ដ្រទាសការកម្ម ក្សិណក្សយដោកជាំ ហ៊ីនហៃហួត
ហួង កូនអើយនោះបា រក្សារាំហោង កុំបាឲ្យគ្គង់ ធ្វើទុក្ខរានោះ ។ អ្នក

កាចរឹងរូស កុំបាប្រទូស្ត ប្រទះឈ្លោះឈ្មោះ កុំបាពោលពារ ខ្វៃ
ទាំងនោះ រាំនឹងស្នូរស្រោះ គន្ធឥតពាំទឹង ៗ ខ្ទេចអសារ បាជាអាចារ
សក្តធំពាក់ពាំង កុំបាបង្ហិន បង្កិនរាំទឹង ក្បាយខ្សែកកុំដឹង ពេក
ពេញទុក្ខទល់ ៗ ចូរបារក្សា ចិញ្ចឹមសន្ធគ្គា នៅទីងសុខសល់
ខេះហៅស្នេហ៍ស្នង ខេះហោងជាផល អាចនាំដល់ មោក្ខមាគ៌ា
សារ ៗ កូនអើយមួយណា ព្រះបាទក្សត្រា សម្តេចភូបាល សព្វព្រះ
ទ័យា ទ្រព្យណាត្រកាល គង់ទេក្ដូបរិបាល ព្រះអង្គឯងនៃ ៗ
ប្រើបារទៅយក នាំទ្រព្យនោះមក ដូចព្រះហទ័យ បាកុំពោរពារ
ទឹងអាថ្វៃថ្ងៃ ចូរបាផ្ញើមែ- ត្រីត្រេកចូលចិត្ត ៗ ទោះបីកម្រ ចូរបា
ណោមល ដោយខ្វះសុចរិត គេហោងទឹងភ្នាច អំណាចបពិត្រ មួយ
ភ្នាចចរិត បាបិទសេចក្តី ៗ កុំអាងអ្នកធំ ដើមដល់ទៀនទំ ពោល
ពាក្យអប្រិយ កុំអាងអាត្មា ផ្សិតជាមន្ត្រី កុំរាំតរកស៊ី បង្ហិនក្រសួងផង ៗ
ក្រសួងផងត្រដាក់ ផ្សិតបាខពាំនាក់ ទឹងអ្នកធំហោង ល្អិកធំកុំនៅ លំនៅ
ក្រសួងផង ក្រសួងរឹងក្ដៅហោង អង្គឥតអាស្រ័យ ៗ កូនអើយលោកថា
មញ្ញោមញ្ញា ពឹងគង្គានៃ លំនៅឯក្ង ពឹងភារព្រឹក្សព្រៃ ក្រសួងពាសខ្សែត
ខ្សែ ពឹងអ្នកធំជារ ៗ កូនអើយចូរបា រៀនរិះអញ្ញា- ស្រ័យសព្វប្រការ
ប្រុះប្រើយធំយល់ ដឹងកលដឹងការ ដឹងកិច្ចតែងជារ- ខាងក្រសួងមណ្ឌល ៗ

ឲ្យដឹងផ្លូវ ដឹងការទានទៅ វែកពានស្អប់ស្អល់ ឈ្លាសដឹងអំពើ បំរើកុំខ្វល់
ដឹងកិច្ចកម្មកល ការស្រែចំការ ៗ ចូរបាអាស្រ័យ ដោយខ្លួនវិស័យ
អំពើការងារ គួរគោកគួរទឹក គួរដឹកគោគ្នា គួរស្រែចំការ ការកាន់ដោយ
បទ ៗ ចូរបារំសាយ បារព្រាវតាំងឡាយ ទៅដោយកំណត់ កំណាន់
ការងារ សព្វប្រការគត់ ចូរបាផ្គង់ផ្គត់ ដណ្តឹងរកផង ៗ ទោះស្រែទោះ
ភ្លឺ ទោះគោក្របី ចំណាររបង ទោះបានទោះបង់ ទោះនង់សោតហោង
មើលកលការផង ដោយអាស្រ័យ ៗ ផ្លូវការងារ ស្រេចបាច់កាល
ណា អំពើទីទៃ នោះឲ្យគណនា ត្រួតត្រា ស្ទួយរៃ រៀនដោយវិស័យ
បុណ្ណភពជា ៗ បាមើលអាថ៌ក្តី ណាគួរគប្បី ដោយខ្នាតមាត្រា កុំបី
ខិតខំ តាមកំឡាំងរក យកដោយអាស្រ័យ ស្រួលចូលចិត្ត ៗ រីទ្រព្យ
ផង្វាយ កុំបាសាយកាយ បាត់បង់ពុំគិត ចូរបាត្រួតត្រា គណនាពិនិត្យ
ឲ្យអ្នកទុកចិត្ត រក្សាគ្រប់គ្រង ៗ ចំណេរបេរទៅ ទោះញាតិទោះផៅ
ខ្សត់អត់ឃ្លាខផង ចូរបាអនុគ្រោះ លំដោះស្ទួយគ្រង ចិញ្ចឹមរមែង
ដោយធម៌បុណ្ណ ៗ រីគុណអនុគ្រោះ គុណបុណ្យលំដោះ សុខទុក្ខ
ស្រេកឃ្លាន នោះហៅថាផល កុសលជាយាន នាំអាត្មាបាន ត្រីពិធ
សម្បត្តិ ៗ រាស្ត្រពាសការកម្ម ភួចកើតក្តីតាំ ភិតភ័យពេកក្តាត់ រឹះរេ
ពំនឹង ពាក់ពិងបាថ្វាត់ កុំបាស្ងៀមស្ងាត់ ក្រែក្រនឹងរក ៗ អាស្ទូរកំសត់

អាសូរទុគ៌ត អាសូរកំព្រា អាសូរត្រមោច ហ៊ានហោចឥតគ្នា នោះមកកាន់
បា ជាម្ដាយសត្វផង ។ ចូរបារមើល ក្ដីទាំងពីរ ឯណាធ្ងន់ធ្ងន់ បាគាត់
ដោយបទ ចូលចិត្តផង កុំបារំលង រំលងធម៌បុរាណ ។ មួយទោះក្សត្រា
ស្ដេចគង់នៅនា - ទីព្រះរាជស្ថាន ពពួកស្រីស្នំ ធីរជាក្រុមក្សាន្ត
កុំបាហៅហាន នាំក្ដីចូលទូល ។ អាថ៌នោះពុំគាប់ ពុំជួជាច្បាប់ នៃរាជ-
ត្រកូល ហៅក្ដីប្រមាទ ព្រះបាទឥស្សូរ ទោសនោះពុំយូរ ដួចដល់
បាណា ។ កុំពឹងសក្ដិបុណ្យ កុំពឹងមានគុណ កុំពឹងប្រាជ្ញា កុំពឹង
ជាចិត្ត រំងស្និទ្ធស្នេហា កុំពឹងករុណា អម្ចាស់ស្ងួនត្រង ។ កូនអើយ
លោកថា ពពួកតារា សហាស្សពាន់ផង ពុំស្មើព្រះចន្ទ្រ មួយស្បាន់
កន្ទង់ សហាស្សទូកផង ពុំស្មើរកេត្រា ។ លោកថាស្ទឹងធ្លារ សហស្ស
សហា ជន់ជោរមហិមា ត្រៃដែតត្រដាប ស្វាបសឹងគង្គា មោះពុំ
ស្មើមហា - សមុទ្រមួយប្រៅ ។ ទោះគណនាគុណ សោតសល់ពាន់
ធ្ងន់ អនេកទូទៅ ស្មើមួយអង្គា អាត្មានិត្យនៅ ទោសមួយចូលទៅ
គុណនោះបាត់ហោង ។ កូនអើយមួយណា ក្រិត្យក្រមទីងជា អាមាត្យ
ក្សត្រផង ក្រទីងរក្សា អាត្មាកន្ទង់ រំលងទោសទុក្ខផង ក៏យកិតអន្ត-
រាយ ។ កូនអើយអ្នកប្រាជ្ញ ផងពុំដែលអាច គិតក្ដីស្រស្រាយ លោក
ផ្ដត់ស្មារតី ឥតប៉ះសាយ ហេតុបទលោកណាយ ដំទៀលនិទ្ទា ។ អស់

អ្នកប្រាជ្ញផង លោកយកចិត្តបង់ ចាំបទគាថា អាថ៌ខាងទាន ខ្ញុំបាន
គាថា ឲ្យគាប់ឲ្យជាប់ ទើបខ្ញុំនាំគេ ។ លោកវៀរទោសភ័យ វៀរក្តី
ចៅក្រៃ ខុបទ្រព្យវៀរវេ វៀរពាក្យពាលា និន្ទាស្អប់គេ វៀរក្តីស្រាយស្រែ
មិនឲ្យមានហ្មង ។ កូនអើយព្រះត្រៃ ព្រះបាទបពិត្រ ក្រៅក្រកខ្នង
ត្រូវនឹងដឹងអាថ៌ សព្វសារពើផង ហេតុបទនោះហោង កុំបាប្រហែស ។
ចូរបាផ្គត់ចិត្ត ស្មារតីពិនិត្យ ត្រង់អាថ៌លេបលេស ញឹកៗ ប្រក្រតី
កុំបីប្រហែស ហឫទ័យពិសេស កុំឲ្យមានខ្ចាល់ ។ បាមើលអាថ៌ក្តី
កាលព្រះចក្រី ទ្រង់ព្រះក្រសាល ពេញៗស្រីគ្គារ បរិពារខៀវខ្វារ
កុំបាផ្គុរផ្គាល់ សាល់ទៀបពេកពន់ ។ មួយកុំបាឃ្លាត កាលទ្រង់អា-
ពាធ ជម្ងឺស្រាលធ្ងន់ កុំបាលាកលះ ពីព្រះបាទគន់ បាជួយគិត
គន់ ជម្ងឺម្តេចៗ ។ បាគន់ទឹកស្រង់ គន់ទឹកសម្រង់ សម្រាប់កុំ
ក្មេច រកពេទ្យផ្សំថ្នាំ មកចាំកុំដាច់ រកហោរសម្រេច សម្រាលព្រះ
គ្រោះ ។ បាជួយគិតគន់ គប្បីនិមន្ត ស្រមណ៍ផងចំពោះ ចំរើនមេត្តា
ផយាលំដោះ ព្រះជន្មព្រះគ្រោះ ទុក្ខទោសភយា ។ អម្ចាស់អផ្សុក
យកខ្លួនជាទុក្ខ ក្រៃវិញណាបា កុំគិតត្រង់ដេក ត្រង់ស្រេកឃ្លានណា
ចូរបារក្សា អម្ចាស់សព្វថ្ងៃ ។ ទោះព្រះទេពី ព្រះរាជបុត្រី បុត្រាថ្វា
ថ្ងៃ មានព្រះជម្ងឺ បាឈឺរវៃក្រៃ កុំឲ្យព្រះទ័យ ជាទុក្ខឡើយណា ។

v អម្ចាស់រូវផ្ទៃ[១] អ្នកផងអាស្រ័យ អម្ចប់នាយា ទេពីអម្ចាស់ រូមែក សាខា កជបុត្រជ្រា ពន្ធកផ្ទៃនោះ ៗ នរអ្នកណា ទ្រឹស្តិទ្រុស្ត មុស្សា បីកាន់កាច់ស្មោះ[២] ទោះត្រូវពន្ធក ទោះច្នកទោះស្មោះ ហៅមហាមិត្តទ្រុស្ត បានបាបអវិចិ ៗ នរអ្នកផង បីរក្សាគ្រង ព្រះផ្ទៃនោះម្ចី ប្រែកបបុប្ផា ផលាផលពី. សុខស៊ីកលាស់ខ្ចី មានផលនោះកែ ៗ មួយទោះព្រះអគ្គ បពិត្រនៅស្រង់ ស្រប់ព្រះបាទថ្ងៃ ពោះលើសិរសា លើខ្លួនបាទៃ កុំបាសង្ស័យ ជាអម្ចាស់ស្អប់ ៗ បាទុន សិរសា កបកើបាទា ដោយព្រះទ័យសត្វ កុំបាទុកចិត្ត ជាអម្ចាស់ស្អប់ កុំបាជុំបថប់ ដើមផល់អប្រិយ ៗ កុំជាតែម្ចាះ ក្រៅក្រលែងនោះ ផល់ ប៉ុន្មានគ្គី កុំបាអាចហ៊ាន ដើមគាន់ស្រដី ទូលពាស់ចក្រី ពុំគួរឡើយណា ៗ រឹជ្ញាផ្ទៃព្រៃផង វៀងលាកចំណាង ចំណាន់ប្រាជ្ញា ទូលទឹក ពេញក្អម ជូមលើសិរសា ករសម្មា បិតទូលទឹកនោះ ៗ មាន កាលបពាត ច្រៃឡផាំកាច់ វស្រែកយំចំពោះ លើកដៃសម្មា វន្ទាសត្វ នោះ ហើយពាក្យពីរោះ សរសើរងងសោក ៗ មានកាលបិតឈើ ម្ចុងព្រៃផ្ទះហើយធ្វើ គំរប់ការកោត ស្រាបាយកាហារ ព្រកាល សាច់សោត បូជាកាន់គោត វន្ទាសត្វថ្ងៃ ៗ ហេតុអ្វីដូច្នោះ ដ្បិត

---

១ រូ:ឥះជាពាក្យបុរាណ បានសេចក្ដីថា "ផ្ចិត ឬ បីផ្ចិត" ។ ២ បី ឥះ ... "ទោះបី ឬ បើ" ។

ចិត្តពាលខ្លះ ចង់បានលាភក្រៃ អំពើដាអាទិ៍ នេសាទដើរព្រៃ ចិត្តសាហ៊ៃ លាភលុះប្រាថ្នា ។ កូនអើយឥឡូវ សម្តេចព្រះភូ- បាលបុណ្យមហិមា បន្ទូលត្រាស់រក ខ្លះមកកាន់បា នូវកិច្ចកលប្រា- ការកម្មនោះហោង ។ ព្រះបាទឥស្សូរ ស្តេចជាកំពូល មកុដសព្វសត្វផងមានព្រះហឫទ័យ ផ្សាស្រែយក្តាត់ហោង បេលអាជីកន្ទង់ គប្បីករុណា ។

ហៃបាធម្មបាល បុត្រច្បងសង្សារ កូនអើយបើបា នៅជាមន្ត្រី ភក្តីក្សត្រា វេលចិត្តសុវត្ថិ- ម័ក្តិអម្ចាស់ ។ វេលចិត្តបាខ្ជាប់ ទៀងនៅដោយច្បាប់ នៃព្រះតម្រាស់ ត្រង់ណាអំពើ បាធ្វើឲ្យច្បាស់ ត្រង់ណាក្រណាស់ បាគិតឲ្យឆ្ងាយ ។ ទោះព្រះចំពោងចិន្តាត្រេកត្រង់ សុខុមកុំស្រាយ ចូរបារករិះ គ្រាប់គិះឲ្យឆ្ងាយឲ្យបានមកថ្វាយ ដូចព្រះទ័យា ។ អំពើក្រៅក្រិត្យ លោកវៃឆព- និត្យ សឹងជាងសឹងជា រិតួងព្រះទ័យ ក្រៃក្រមហិមា ហេតុនោះចូរបា គិះត្រង់នោះហោង ។ បាសព្វព្រះទ័យ អម្ចាស់សព្វថ្ងៃឆ្លុកទឹងសួនត្រង់ ដូចមហាមេឃា បង្អុរភ្លៀងផង ពីអាកាសកងចុះមកក្រៃក្រាស់ ។

ហៃបុត្រទាំងឡាយ ចូរស្តាប់អភិប្រាយ អាថ៌នេះឲ្យច្បាស់ច្បាប់កដសួស្តី មន្ត្រីអម្ចាស់ ចូរបាជាក់ជាស់ ខុកក្ខួទៃ ។ នូ

អ្នកណា នឹងចូលទៅជា រាជសេវកនៃ អ្នកនោះប្រែប្រាជ្ញ ជឹង អធ្យាស្រ័យ ក្នុងកិច្ចព្រះទ័យ ចំពូទៀងឲ្យច្បាស់ ។ អ្នកនោះនៅ បាន គ្រងាប្រទាន អនេកនៃក្រៃក្រាស់ សម្បត្តិសម្បូណ៌ ធានធន កាពេស្តុ យសយីនច្បាប់ច្បាស់ លោកិយប្រាកដ ។ រាជសួស្តី នៅជាមន្ត្រី គប្បីផ្គន់ផ្គត់ ផុតពុកថ្វាថ្វៃង សំដែងប្រាកដ ពូរចាំអស់ បទ ប្រការម៉្ហេះហោង ។

ច្បាប់រាជសួស្តី ព្រះបាទចក្រី រាជសម្ភារច្បាស់ច្បង ទ្រង់លើកៈ ទុកត ឲ្យនរជនជង សណ្តាប់ត្រាប់ត្រង ឯរំថប់ហើយ ។

ចប់ច្បាប់មហាទេពីរាជសួស្តី តែប៉ុណ្ណេះ ។

រឿងការច្បាប់ក្រឹត្យក្រម

របស់ព្រះគ្រូវិសុទ្ធិវង្ស ទិត វត្តសិរីសាគរ ស្រុកព្រែក ខេត្រព្រៃវែង

នេះនឹងថាថ្លែងតែងតាមចង់ លើកតាមទំនងជាកាព្យ ប្រាំពីរពាក្យ ពិតគិតប្អូនឃ្មា ចង់ជានិទានទុកប្រដៅ ៗ អស់ទាំងកុមារក្មេងតូចៗ ចិត្តឯងនៅខូចច្រើនខ្លាំងទៀត ស្រើបស្រាលដោយសារខ្លួនឆោតឆៅ មិនតាមប្រដៅគ្រូស្រក់ ៗ កាលណោះព្រះពុទ្ធសាស្នា កន្លងហើយណាបានពីរពាន់ បួនរយចិតសិបបីត្រូវត្រាន់ ឯខែគ្រប់គ្រាន់កន្លងគ្នា ៗ ថ្ងៃកន្លងបានម្ភៃពីរ នឹងគិតកាញ់ត្រូវក្នុងបច្ចុប្បន្ន ឆ្នាំមមីទោស័កក្នុងកម្ពុជ រដូវខែជេស្ឋប្រាំបីកើត ៗ គោនុនាមាអាត្មាភាព ចំរើនពរជ្រាបឈ្មោះកំណើត ទិតគិតពីព្រោះឃើញភ្ញាក់ព្រឺត ចិត្តកើតសង្វេគចេញបព្វជ្ជា ៗ សាមសិបប្រាយឆ្នាំជាកំណត់ នៅវត្តសិរីសាគរ ឃុំទំណ្ឌ ត្រែបកក្នុងតាមា រួមខែត្រព្រៃវែងស្រុកបាភ្នំ ៗ ខ្ញុំមានសិស្សកុមារច្រើន ស្រដីដាស់តឿនរំមិនទំបានជាគិតលើកល្បើកក្រឹត្យក្រម ឲ្យរៀនខិតខំកុំឲ្យធ្វេស ៗ ហៃអស់ពួកក្មេងកុមារ ចាំទុកកល់គ្នាកុំប្រហែស ប្រតិបត្តិតាមបែបយ៉ាងនេះ អ្នកកុំសន្ទុះនឹងបេះទាន ៗ ភ្ញាក់ឡើងពីព្រឹកនឹកបំណោះ ដែលខ្លួនរៀនចេះចាំប៉ុន្មាន ខំទន្ទេញឲ្យស្ទាត់មាត់កុំខាន ដ្បិតទើបនឹងបានរៀនថ្មីៗ ៗ ហើយឲ្យអ្នកផ្ទៀងរៀនអក្សរ អក្ខរឲ្យល្អរៀនសំដី នព្វន្តខ្ទរបិនឲ្យស្ទាត់ដៃ

លោកិយនេះគ្រាន់ប្រឡំគេ ៗ ហើយឲ្យអ្នកឆ្លៀតរៀនបាលី នោះទើប
គប្បីកុំទំនេរ មេសូត្រឲ្យស្ទាត់ចាំមាត់ទេ ដល់បាទៅប្រែថ្វាយអាចារ្យ ៗ
បើប្រែរួចហើយទៅដល់ស្ពាន កុំខ្ជិលប្រែះប្រាណពោះសាស្ត្រា ពីដៃ
ហើយដេកធ្មេចនិទ្រា មិនត្រួតត្រាការវិជ្ជាខ្លួន ៗ ចំណាំវិភត្តិបទបច្ច័យ
អាចារ្យប្រាប់ន័យចាំឲ្យមួន គោងការរំពូកមើលថែជួន បើជួនភ្លេចសព្ទ
សួរគ្នាឯង ៗ បាចូរប្រតិបត្តិសួរអាចារ្យ វិបត្តិអត្ថពឲ្យជាក់ស្តែង សូមទាន
ករុណាចូរសំដែង ថ្វាថ្លែងប្រោសប្រាប់តទៅទៀត ៗ អាចារ្យសំដែង
ប្រាប់សិស្សថា អក្ខរមោលាតាមដោយប្រៀត នឹងប្រែអក្សរតាមសាន្តត
រៀបរយតាមគេទទាំឲ្យជាក់ ៗ របៀបប្រែពាក្យក្នុងលោកិយ ប្រែឲ្យគប្បី
តាមអក្ខរៈ លោកយកប្រែក្របទឹងតួស្រៈ ជាពាក្យទីឃៈរស្សៈខ្លី ៗ ទីឃៈ
លោកប្រែពាក្យយ៉ាំងវែង រស្សៈនោះឯងប្រែពាក្យខ្លី ឯស្រៈមាននៅក្នុង
បាលី នោះមានប្រាំបីក្នុងអក្ខរ ៗ បើពាក្យណាសុទ្ធបាលីចំ លោកយក
មកផ្សំនឹងពាក្យប្រែ ដូចជាពាក្យថាអ្នករៀនស្នេហ៍ នោះត្រូវការមេព្រោះ
ហេតុកាម ៗ ពាក្យមួយលោកថាធ្វើគ្រូពេទ្យ ក្នុងអាណាខេត្តសត្វប្រែភ
ប្រាំ ពាក្យជាកិលេសវិសេសសាំ ព្រះគេជះចាំព្រះមហាថេរ ៗ យ៉ាំង
នេះយកស្រៈ (េ) មកប្រើ ដាក់តាមពាក្យស្មើដូចពាក្យខ្មែរ បាអានសំ
ទៀងឲ្យបន្ទើរ ជាពាក្យស្រៈ (ែ) វិញណាបា ៗ ផ្សិតពាក្យស្រៈ (ែ)
យ៉ាំងនេះនៃ នៅក្នុងបាលី គ្មានឡើយណា មានតែស្រៈ (េ) អក្ខរ

នេះលោកពោលថាប្រែជួស (ឫ) ។ ហេតុនោះបានលោកយកមកប្រែ
តាមបែបបទស្មើភាសាប្រែ យក (រ) នេះឯងតាំងស្រះ (ឫ) ចាំឲ្យជាប់ផៃ
ណាទៅណា ។ ឯរឿងបទស្រះឧទាហរណ៍ ដែលត្រូវអក្សរមេ-គកា
ខុសម្រាប់ប្រើក្នុងភាសា ក្រុងកម្ពុជាធិបតី ។ ចូរបាអានឲ្យប្រុងប្រយ័ត្ន
កុំឲ្យបង់បាត់បែរសេចក្តី អានកុំបំភ្លាត់បំភ្លៃស្តី តាមន័យពាក្យឃ្លោងឃ្លា
យាមុខ ។ ចូរបារាំងទាំងគួរខ្យល់ ប្រុងប្រយោគដល់ដោយទំនុក ប្រយ័ត្ន
កុំអានឲ្យទន្ទុក ផ្លូសទៅមុខហួសមិនត្រូវ ។ សេចក្តីពាក្យណាមើល
មិនចំ កុំថាបន្ទំរម្លងទៅ ចូរបាបង្អាក់ឈប់ចាំនៅ ទៅសួរលោកគ្រូសិន
សិមថ្លែង ។ កុំគិតចិត្តព្រើលខ្ទួចតែផ្តាស ទៅគិតរៀនខ្មាសនឹងគ្រូឯង
មិនហ៊ានទទឹងសួរទឹងសំដែង ថ្លែងសួរពីរឿងហេតុនានា ។ យ៉ាងនេះដូច
មានក្នុងបាលី បុគ្គលលោកស្តីតៗគ្នា ខ្មាសគ្រូបាធ្យាយគ្មានវិជ្ជា ខ្មាស
ករិយាពុំមានកូន ។ ខ្មាសមហាក្សត្រខាតយសយាន ខ្មាសធ្វើសីលទាន
គ្មានបុណ្យជូន ខ្មាសធ្វើការងារសោបស្ងាត់សូន្យ ខ្មាសញាតិបងប្អូនគ្មាន
ត្រៀវឡើង ។ ខ្មាសខ្ញុំកំដរខានប្រការ ខ្មាសស៊ីអាហារពោះផតស្តើង
ខ្មាសបុណ្យយសស័ក្តិពុំបានថ្កើង ខ្មាសពួកអ្នកយើងខានធ្វើបុណ្យ ។
ខ្មាសបាវភ្នាក់ងារគ្មានអាង ខ្មាសពាក្យមុសាលក់ខាតទុន ខ្មាសអន្តេ-
វាសិកខានដើរមុន ខ្មាសអ្នកមានគុណខានធ្វើគាប់ ។ ខ្មាសកូនខានស្តី
ប្រៀនប្រដៅ ខ្មាសអ្នកព្រានព្រៅថយអំណាច ខ្មាសពាលល្ងង់ខ្លៅ

មានគេថា ខ្លួសបណ្ឌិតប្រាជ្ញពេញពោលធំ ៗ ពាក្យចាស់ពីព្រេងតែងប្រឌិត មានមកមែនពិតដោយនិយម ពាក្យនេះមានមកពីបរមបុរាណចាស់ទុំជាដូច្នេះ ៗ ធម្មតាឯចិត្តគ្រូអាចារ្យ តាំងពីនមស្ការឲ្យសិស្សរៀន ពុំមានលាក់លៀមទុកចំណេះ ចង់ឲ្យសិស្សចេះសព្វសេចក្ដី ៗ មួយទៀតរឿងដែលនឹងសិក្សា ចំណេះវិជ្ជាក្នុងលោកិយ លោកថាប្រកបដោយអង្គបី នោះគឺស្មារតីនឹងប្រាជ្ញា ៗ ព្យាយាមជាទីតាំងបី ប្រែថាសេចក្ដីខំសង្វាត រីឯស្មារតីគឺសញ្ញា កំណត់កត់ត្រាការអ្វី ៗ ប្រាជ្ញារងនៃនាមបញ្ញត្តិ ជាអ្នកការកាត់សព្វសេចក្ដី ទៅខាងបរលោកឬលោ-កិយ កែខ្លួនឲ្យបានស្ថានល្អ ៗ បើបានគ្រប់ព្រមទាំងអង្គបី ប្រាជ្ញារៀនអ្វីសោតពុំក្រ សម្រិតក្នុងខ្លួនទាំងបីប-រិបូណ៌បានល្អជាអ្នកចេះ ៗ រីឯស្មារតីគឺចេតសិក ឲ្យចាំរឭកនឹកដម្រិះ កំណត់ចំណាំចាំចំណេះ បរិបូណ៌បានចេះស្រេចរីយា ៗ ទោះបីបើមានប្រាជ្ញច្រើន ថាបើចំរើនគោសង្ឃា កំជិលខ្ជិលគ្រែមហិមា ពុំអាចធ្វើជាអ្នកចេះបាន ៗ ថាហៃអស់អ្នកពួកខាក ចូរឲ្យចាំទុកក្នុងអង្គប្រាណ ខំសង្វាតព្យាយាមយកឲ្យបាន ទុកជាច្បាប់កាន់ក្រខ្លួន ៗ មួយទៀតឯអ្នករៀនព្រះត្រៃ-បិដកថ្នាំថ្ងៃតាមចំនួន លោកថាប្រកបដោយអង្គបួន នោះគឺ សុ. ចិ. បុ. លិ. ចាំ ៗ សុ. ប្រែថាឲ្យប្រឹងស្ដាប់គេ ចិ. គិតការញាំគ្នេរខ្ញុំចំណាំ បុ. ឲ្យសាកសួរតាមលំនាំ លិ. ឲ្យថែទាំកត់ឡើងទុក ៗ ធម្មតាអ្នករៀនរឿង

បាលី គឺព្រះត្រៃបិដកជាមុខ ចូរបាខំប្រឹងសរសេរទុក ក្រែងក្មេង
នៅមុខបានមើលស័ព្ទ ៗ ថាបើប្រែកបដោយអត្ថបួន បានគ្រប់ចំនួនដោយ
អណ្តាប់ សិក្សារៀនសូត្រក៏ចេះឆាប់ នឹងជាសណ្តាប់ប្រាជ្ញវោហារ ៗ
ថាបើបាឃ្លាតប្រាសចាកជួន ពីអត្ថគន្ថទួនបួនប្រការ នោះឯងពុំបាន
ជាអាចារ្យ រៀនដល់ចាស់ណាក៏ពុំចេះ ៗ ព្រះពុទ្ធដីកាព្រះអង្គត្រាស់
ទ្រង់ថ្លែងប្រកាសទុកដូច្នេះ កុមារអ្នកខំប្រឹងរេត្រកត្រេះ គិតរករៀនរះ
អស់វិជ្ជា ៗ ឯចំណេះសិល្បសាស្ត្រសព្វ បើបានចេះចប់គ្រប់ហើយណា
មិនបាច់នឹងព្រួយអត្តអាត្មា ទៅរកកាប់ឆ្កាក្តួរស្រែព្រៃ ៗ ថាបើនឹង
នៅទីស្ថានណា ខឹងមានឈ្មោះជាប្រាកដល្បី ពុំបាច់នឹងនឿយព្រួយ
ស្តាយដៃ ដើរតាមក្រោយគេទេណាទៅ ៗ ឬមួយនឹងទៅផ្គាប់ផ្គុន
ស្តេច នោះឯងមិនបាច់ទៅហាលក្តៅ ករុណាកាន់ទ្រង់ប្រោសប្រាណ
ទៅ ឲ្យយសស័ក្តិទៅជាអគ្គដ្ឋាន ៗ ទោះបីក្រខ្សត់អត់ញាតិផៅ គង់
តែគេហៅរកពប់អាន ស្រឡាញ់ទុកដូចជាសន្តាន គ្រាន់បានពឹងពាក់
គ្រាមានទុក្ខ ៗ ធម្មតាវិស័យរឿងចំណេះ បើបាបានចេះច្រើនគ្រប់មុខ
ទោះបីបើនឹងមានទោសទុក្ខ គង់តែបានសុខស្រួលក្សេមក្សាន្ត ៗ ចំណេះ
វិជ្ជាលោកចែងចាត់ ទុកជាសម្បត្តិសម្បូណ៌បាន ទោះបីក្រក្សត់អត់
ប៉ុន្មាន គង់តែបាបានគ្រាន់អាស្រ័យ ៗ សម្បត្តិនៅស្ថាននាលោកិយ
មាសប្រាក់ប្រែក្រតីនៅសព្វថ្ងៃ សឹងតែប្រែកបទៅដោយភ័យ បាត់បង់ទៀត

នៃជាអនិច្ចំ ។ រីឯសម្បត្តិគឺចំណេះ បើបានបានចេះដោយកំឡាំង ជាប់ វ៉ែនឹងដកបយារដើរ សឹងទៀនចិត្តតាំងដល់ខ្លួនស្លាប់ ។ ពុំដែលមាន អ្នកណាណា អាចធ្វើផ្លាឲ្យអន់អ័ប្ប ទោះបីដល់ភ្លើងប្រល័យកប្ប ក៏ពុំអាច ចាបឆេះអន្តរាយ ។ ចាំហែអស់ពួកកុមារ ចូរបានស្វាហាប់ខំខ្វល់ខ្វាយ សង្កេតកំណត់កុំឲ្យម៉ាយ តាមពាក្យបរិយាយយើងពណ៌នា ។ រីឯវិជ្ជា នាលោកិយ ប្រយោជន៍សិរីសួស្តីជាំ នឹងជួយឲ្យបានទ្រព្យនានា គេស្រួលក្នុងសុខាក្នុងលោកនេះ ។ រីឯវិជ្ជាគឺព្រះត្រៃ- បិដកថ្លាថ្លៃកុំសន្ទិះ ប្រយោជន៍តាំងនៅក្នុងលោកនេះ ដរាបដល់ទិសទិព្វបរលោក ។ ជា ស្បៀងជាប់ល្បៀងរូបអាត្មា នាំអង្គរូបាបាត់ទុក្ខសោក ទៅកាន់ខេមស្ថាន សិវមោក្ខ និព្វានស្ថានលោកជាអវសាន ។

ឥឡូវបញ្ចប់ស្ទុះចរចា អក្សរមាលាប៉ុណ្ណេះបាន និយាយអំពីគ្រង គ្រប់ប្រាណ ប្រដៅខ្លួនគេទៅទៀត ។ មនុស្សយើងត្រូវរៀនចំ- ណេះ ឲ្យបានចាំចេះមិនចន្លៀត បញ្ញាណាគេយើងកែច្នៀត ប្រៀត យកសេចក្ដីឲ្យឆ្ងាយស្លាប់ ។ គ្នាជាអ្នកល្ងង់ចូលមកសួរ អ្នកប្រាប់ឲ្យ គួរតាមសណ្ដាប់ ធម៌អាចារ្យណាត្រូវផ្ទៀងប្រាប់ សារសើព្វតាមធម៌តាម សេចក្ដី ។ នឹងមានកិត្តិសព្ទស្ងួរតំរេះ នឹងមានគេស្ញើចឈ្មោះខ្ពស់ត្រល្បី នឹង មានប្រាជ្ញាពីលោកិយ និងមានសិរីសួស្តីប្រាណ ។ យកចិត្តទុកដាក់ នឹងចំណេះ អ្នកកុំប្រហែសធ្វេសគិតខាន ខូចវេលាមួយដូចខាតច្រើន

ចាំត្រវែងណាអ្នកណា ៗ នឹងបានក្ដីច្បាស់សព្វសេចក្ដី ក្ដីដូចស្មើសែង សុរិយា ក្ដីច្បាស់ត្រចះនឹងនេត្រា ក្ដីថាដូចចិត្តឥតសង្ស័យ ៗ តែបាន រៀនច្រើនកើតចំណេះ តែចេះការច្រើនជាបច្ច័យ តែខំរៀនសូត្ររាល់ ថ្ងៃ ដូចថ្ងៃត្បូងពេជ្រលេចពន្លឺ ៗ បើមានចំណេះចេះវិជ្ជា បើនឹងស្ដីថា ច្រើនគេត្រូវ បើមានការគេបំភ្លឺ បើមានជម្ងឺជួយក៏ក្ដី ៗ បើបានចេះ ហើយនឹងមានឈ្មោះ សូរសព្ទពីរោះខ្ពស់ល្បី មានពាក្យសរសើរពី លោកិយ ដល់បរលោកក្ដីសុខក្សេមក្សាន្ត ៗ បើបានរៀនសូត្រខំឃ្មាត ខ្នះខ្នែងសង្វាតកុំឲ្យខាន ឲ្យខាតវេលាវិជ្ជាប្រាណ ចិត្តត្រែកកំសាន្តតាម ទំនើង ៗ កុំនិយាយគ្នាណាភាព ឲ្យខាតវិជ្ជារបស់យើង បើគេនិយាយ បាផ្ទើផ្ទើង កុំតតបឡើងជាប់សំដី ៗ ដោះឡើងដើរចេញទៅកេរៀន ចំណេះរបៀនតាមសេចក្ដី ដែលគ្រូការរៀនវិជ្ជាអ្វី តែជាប់សំដីខាន រៀនសូត្រ ៗ មួយទៀតកុំបារៀនចិត្តឈ្មោះ ប្រកែកទទោះរៀនឲ្យសូត សំដីគេលើសបាកុំស្រែក រូតរះបង់ឈ្នះឥតអំពើ ៗ រល់តែចិត្តគ្រូបាធ្យាយ ដំនឹអភិប្រាយរកស៊ីរើ ឃើញទោសហើយផ្លាលតាមដំណើរ អ្នកណា គេប្រើឲ្យឈ្មោះគ្នា ៗ ធម្មតាជាអ្នករៀនសិស្សសេក្ខ កុំរៀនកាចពេក ណាភាព គួរខ្លាចរំពាត់គួររាំងរក ចិត្តកាចនោះណាគួរទៀយណាយ ៗ មួយទៀតរឿងល្បែងលេងមិនសុខ ច្រើនតែមានទុក្ខបៀតបៀនកាយ លោកថាលេងច្រើនៗអន្តរាយ វិនាសខ្លាត់ខ្លាយសម្បត្តិទ្រព្យ ៗ

អ្នកអើយជម្ពូតាកើតជាមនុស្ស ឲ្យដឹងគាប់ខុសទើបនឹងគាប់ កុំរៀនធ្វើលើសលើសនឹងច្បាប់ ចូរស្ដាប់ពាក្យនេះចាំទុកទៅ ។ គំនិតសេក្ខសិស្សអ្នកនៅវត្ត ព្រោសព្រាណប្រតិបត្តិឲ្យត្រឹមត្រូវ កោតខ្លាចលោកគ្រូជានិម៉ែឪ ចូលទៅប្រតិបត្តិកុំឲ្យអាក់ ។ បារៀកម្មស្នាមូរបារី ប្រគេនហើយទឹករៀបស្រក្បែ វៃតាំងដាំទឹកក្ដៅត្រជាក់ ទុកដាក់របស់តាមរណ្ដាប់ ។ បើលោកះហៅប្រើការអ្វីៗ រៀបរួសដៃជាប្រញាប់ យកចិត្តទុកដាក់ធ្វើឲ្យឆាប់ លោកប្រាប់យើងធ្វើតាមព្រះវិន័យ ។ ផ្ដាប់គ្រូមិនសូវមានគ្រោះខ្លួន បើផ្ដាប់ឲ្យមួនកុំសង្ស័យ ខុសពីបើងលោកអភ័យ សំដៃចំណាំទុកឲ្យស៊ី ។

១ ឥឡូវបញ្ចប់រឿងនាគ នឹងរើកស្តែះទុកគេសេចក្ដី ពីគ្រឹមណោះទៅលើករឿងថ្មី ទុនានប្រុសស្រីគ្រប់កល់ខ្លួន ។ នឹងថ្លែងពីរូបយើងកល់គ្នា កើតកង្វិសាស្នាគិតឡូមូន បើមិនបង្វែតខ្លាចកែងខ្លួន សោះសូន្យមិនកើតឥតអំពើ ។ បំណាច់កើតទាន់កង្វិសាស្នា គួរគិតប្រាថ្នាកុំពាក្វី យកចិត្តទុកដាក់ក្នុងៈលើ វែកនឹងឥតអំពើបង់រូបកាយ ។ ទំនែស្ទងរករៀនធម៌បរមត្ថ ប្រឹងចិត្តប្រប័ត្នគិតឡូវឆ្ងាយ ជាកែយោងនេះនឹងអន្តរាយសុខ្ខសឹងតែស្រាយឥតទុំមសារ ។ ឥតមានអ្វីយកជាទីពឹង ពិតជាកុំដឹងស្លាប់ថ្ងៃណា ហេតុដូច្នេះខ្ញុំអរទិញ ដាអខគ្នាតាំងយៀងយ៉ាង ។ ហេតុដូច្នោះឯងប្រុសស្រី កើតកង្វិលោកឃើញទុំហ្វូត គេ្យស៊ីលទាន

ទំសង្កាត ចិត្តកុំប្រមាទដូចពណ៌នា ៗ មានមកក្នុងច្បាប់នេះស្រាប់ហើយ មិនមានខុសឡើយរៀងកល់ឃ្លា សំគាល់ចាំទុកទៅមុខជា ត្រៀងការទុក្ខ ការសត្រូវ ៗ អ្នកចំសំគាល់ធម៌សុខុម ធ្វើជាអារម្មណ៍ចាំទុកទៅ កល់រូបមុខជាមិនលែងត្រូវ ការស្លាប់នោះនៅកល់រូបពិត ៗ អ្នកអើយអ្នកចំត្រូតត្រៀងផ្ចាត់ កុំជាតែមាត់ស្រួចខ្ទរចិត្ត សព្វថ្ងៃចិត្តយើងគួរពិនិត្យ ផ្ចិតចិត្តបុណ្យបាបប្រឡំគ្នា ៗ ចិត្តណាវិលខូចបណ្ដេញចេញ កុំឲ្យវាទាញក្នុងរូបា វានាំឲ្យទុក្ខរូបវេទនា កើតទុក្ខកាលណាវាតែចោល ៗ រូបយើងសព្វថ្ងៃចិត្តធំណាស់ ធំជាច្បងស់ជាបង្គោល អាខ្លះជាក្មេងតែងដុតពេល អាខ្លះជាលដោលឲ្យវង្វេង ៗ អាខ្លះវាធ្វើឲ្យធុញថប់ បុណ្យសីលទានស្អប់គ្មានកោតក្រែង ខ្លះនាំបំផ្លាញប្អូនខ្លួនឯង ឲ្យធុញវង្វេងទីងកាមគុណ ៗ ខ្លះវាមាំលួចប្រពន្ធគេ អាខ្លះបង្វែរឲ្យលួចប្លន់ អាខ្លះកាប់ចាក់មិនគិតគន់ អាខ្លះលោភលន់បោកប្រាស់គេ ៗ ហៃអស់មហាជនទាំង-ឡាយអើយ បើដូច្នេះហើយចូរអ្នកគោរ អ្នកទុករក្សាមិនបានទេ លុះអ្នកវាយដេរបណ្ដេញចេញ ៗ វានៅវានាំបំផ្លាញរូប អ្នកអើយកុំទុកកុំស្រឡាញ់ ចាត់ចោលឲ្យឆ្ងាយពីខ្លួនចេញ តែអ្នកស្រឡាញ់ខូចខ្លួនហើយ ៗ ដែលនាំខ្លួនខូចពីព្រោះវាង អន្ទាយមិនដឹងខ្លួនសោះឡើយ នាំចាញលិចលង់មិនដឹងត្រើយ អ្នកអើយអ្នកគិតកុំឲ្យខាន ៗ អ្នកគិតតែល្អត្រូវត្រឹមត្រង់ លុះអ្នករឹងលើខ្លួនបាន ទៅណាយកទៅជាប់ទីងប្រាណ

ទើបបានគេស្រមគ្រាន់រចេ គ្រោះថ្នាក់ ។ តាមបន្ទូលព្រះអង្គទ្រង់ឲ្យ ទើបបាន
ទៅសោយសួគ៌ជៀសជាក់ កោតខ្លាចគោរពពុំឲ្យអាក់ កុំឲ្យមានថ្នាក់ការ
ថ្មស់ល្មោយ ។ បើជាប់ធម៌សីលទានទៅក គ្រាន់បានជាគ្នាយ៉ាតយោងជួយ
កប់អាទស្រឡាញ់ដូចខ្លួនមួយ សីលទានជាត្រួយស្ទើធីរិត ។ ឲ្យអ្នកគារ-
នាតែសព្វថ្ងៃ អកុសលចង្រៃគ្មានបានពិត បាក់បបខ្លួបខ្លាចអំណាចពិត
ដោយគ្រូសុចរិតខ្លាត់ទៅឯង ។ អ្នកកុំស្អប់ទើបសីលសិក្ខា លោកសង្ឃ
គាថាស្រ្តាវកោតក្រែង ដូងកែវកំណើតកុំចំរែង លោកតែងផុសលាង
រូបខ្លួនខ្មោ ។ ព្រះធម៌ថ្លៃថ្លាគ្មានស្អប់សត្វ អ្នកកុំលះកាត់ដោយមោហោ
ព្រះធម៌នាំសត្វចាកទុក្ខទោ កុំគិតរាលោភខ្លាចស្លាប់ ។ តែផុតលេត
ទៅកាលណា ទៅតាមវេរបុណ្យប្រាបធាប់ ធ្វើអ្វីបាននោះតាមចិត្តគាប់
ប្រាប់យមបាលធ្វើតាមកម្ម ។ ត្រូវដុតត្រូវស្ងោរត្រូវស្ទួចថ្ពក់ ត្រូវ
ដោលត្រូវគកាប់ចំញ្ញាំ ត្រូវទ្រង់រកាដែកតាមកម្ម តាមហេតុដែល
ចាំមានសាក្សី ។ ទោសខ្វះត្រូវបុកអង្រែដែក ល្អិតល្អោចខ្ទេចបែក
ដូចសំឡី ស្លាប់ហើយរស់វិញតែពល់ថ្ងៃ រងភ័យនរកវេទនាណាស់ ។
ស្រែកយំលេខ្លោចខ្លោចឈឺផ្សា តែព្រោះអាត្មាធ្វើកម្មក្រាស់ ប្រកាច់ដី
ដើរធ្វើទោសទាស ផ្តេសផ្តាសគេអ្វីចិត្តគ្មាន ។ យំខ្លួនញស្រែកហៅប្រពន្ធប្តី
កូនចៅបងប្អូនតាមមួយគ្មាន ហ្មុតខ្លះផ្គងមោយសារយ៉ាន មិន
មានអ្នកស៊ុលបាគណាស់ ។ ទំស្រែកអង្វរយមបាល ថាខ្ញុំកន្ទាលហើយ

លោកម្ចាស់ គេវៃគ្រួចដ៏ចងក់ចេះ ថាពុះអាពោះខ្ចួចអប្រិយ ៗ មិន
ឯងលួចប្លន់កាប់ចាក់គេ មិនមានទំនេរតែកល់ថ្ងៃ ប្រពន្ធកូនគេឯងគាប់ចៃ
លួចមិនប្រណី ព្រោះចិត្តធំ ៗ ប្រមាទមើលងាយគ្រូអាចារ្យ ផញ្ជឹងធ្ងន់ស្រាល
ថ្លឹងបន្ទំ ដេញបាញ់ម្រឹគបក្សីតូចធំ មិនមេត្តាពុំប្រណីឡើយ ៗ ផឹក
ស្រាស្រវឹងក្រហមភ្នែក ចិត្តត្រេកអាលក្រែកមិនមានស្បើយ គ្មានគិតធ្វើ
បុណ្យសីលទាន ឡើយ រៀនធម៌ឲ្យហើយទៅតាមស្ថាន ៗ រីយមបាលទាំង
ប្អូននាក់ តែងតែទាត់ធាក់ក្រាស់ប្រៃត្រាន កាន់លំពែងចាក់សុសសព្វ
ប្រាណ អ្នកខ្លះសោតបានទឹកទន់ដែង ៗ យកមកចាក់ស្រែចហុចឲ្យទៅ
ហើយកាន់ព្រួលពៅឈរកំហែង ថាហាំនេះស្រាបស់ឯង ដែលអាផ្ញាប់តែង
ផឹកពីមុន ៗ អញប្រែយ៉ាងល្អទុកសម្រាំង ក្បាលស្រាយ៉ាងខ្លាំងពីសាស៊ីន
ផឹកទៅអាវាក់បាត់ត្រែន មិនបាច់គេគ្នាន់គិតថ្លៃថ្នូរ ៗ អញឲ្យអានាងឯង
ផឹកចុះ ដោយចិត្តអញស្មោះមិនលក់ដូរ ឲ្យផឹកទទេគ្មានថ្លៃថ្នូរ ផ្សិតផ្ញាប់
ផឹកហូរពីដើមមក ៗ រីឯអស់ពួកសត្វនរក ក៏យកគិតជាទុក្ខតែពួនជ្រក
យមបាលគម្រាមដេញសង្រ្គក ដេរស្រែកគំហកកំហែងចាប់ ៗ បាន
ហើយបំផឹកទឹកទន់ដែង គិតទៅខ្លួនស្ទើរភ្លើងឆេះឆាប់ រលាករលួយ
រលាយស្លាប់ ប្រែប្រាណក្រឡាប់រស់ឡើងវិញ ៗ អាហារនៅក្នុងស្ថាន
នរក នោះមានតែលាមកខ្ទុះឈាមមិញ ហើយក្រខ្វិនបានស៊ីឲ្យពេញ
ពោះកើតទុក្ខម្ចាញទឹងភ្លើងក្តៅ ។ ឯណារ ស្រែកទឹកស្ងួតខះក ឃើញ

ទឹកថ្លាល្អរត់សំដៅ ស្មើរស្មុះស្មើរលោតរត់លឿនស្មៅ លុះបានដល់
ទៅត្បូងទឹកឡើង ៗ ពុំទាន់ទឹងបានដល់ក្នុងស្រះ រីឯទឹកនោះក្លាយ
ជាភ្លើង ធាយនេះជាលេកលដល់ថ្ងៃដើង ស្មុះរត់ក្រញ៉ាំងក្អែកសស្គុះ ៗ
ភ្លើងឆេះទៅពេលល្ងាយលោច របួតអស់អាចម៍ពីក្នុងពោះ ស្លាប់ហើយ
បណ្ដាលឡើងជារស់ ចំពោះមួយថ្ងៃមួយរយដង ៗ កើតកើតទឹងស្លាប់
ក្រឡាប់កើត រាប់ជាតិកំណើតច្រើនកន្ទង់ វេទនាដងទុក្ខរងទោសផង
ស្រែកយំពេញរងកម្មក្រាស់ ៗ សំដែងអំពីសត្វនរក ទឹងលើកស្ទះ
ទុកឲ្យលោកលះ ផ្សែតនៅមានច្រើនប្រការណាស់ ក្រឡាស់ថ្ងៃងពីលោ-
កិយវិញ ៗ លោកិយនេះត្រូវតែងរៀន ចំណោះរៀនទំទន្ទេញ ធម៌
យោមគ្គអត្ថប្រែចេញ ជាពាក្យខ្មែរវិញតាមគំបច្រើន ៗ មួយម៉ាត់ពីរម៉ាត់
ទុំខស្រួហ៍ តាំងចិត្តការខាទឹងចម្រើន ផលាទិសទ្ធិទឹងបានកើន បើ
មិនក្រវើនឥតអំពើ ៗ បេះតិបបេះច្រើនឲ្យជាក់ច្បាស់ កុំស្មូត្រផ្ដេស
ផ្ដាសថាពាក្យ បន្ទូបន្ទំជួចមម៉េ រេរើផ្ដេសផ្ដាសមិនច្បាស់គួ ៗ ឡើង
ក្ដល់ក្រង់ណាច្បាប់ប្រតិបត្តិ លោកណាបេះស្ទួតឲ្យស៊ើបសួរ ពិនិត្យសង្កេត
រៀងពល់គួ ចាំទុកទៅគួរទ័ងហានការ ៗ សេចក្ដីស្លាប់មានតែកល់គ្នា
ទុកេងគួរកត្រូវទំសាង កំណត់មានឈ្មោះនៅក្នុងក្រាំង ចាប់បានកើតចាំង
ពមិនលែង ៗ ជាអ្នកក្រទ្រូសការអាក្រក់ ចូលចាប់ការចងក់តគោតក្រង
សំពះបង់ដៃគ្មានយល់ឯង ចាប់បានមិនលែងឲ្យរួចទេ ៗ ទុកជាមាស

ប្រាក់ទាំងប៉ុន្មាន គេមិនទុកប្រាណនៅចំនេរ ពោលកូនពោលចៅពោល
ឪម៉ែ ពោលគេរ្តិ៍ ពោលស្រែទ្រព្យរបស់ ៗ អន្តរជាខ្ញុំធ្វើបុណ្យទាន ឧទ្ទិស
បញ្ជូនលោកឥតខ្ចោះ សូមបង្អង់ឲ្យរៀបកូនអស់ គេគ្មានស្រណោះ
ស្តាប់អ្នកទេ ៗ ចាំទុកអ្នកផងទាំងឡាយអើយ មរណៈនេះហើយមិន
ចំនេរ មានគល់តែរូបមិនតែគេ យើងក៏មានដែរមិនរំលង ៗ តាម
ព្រះពុទ្ធដីកាឲ្យការនោ រំឭកគាថាបីបទផង ឲ្យរឿយៗ ណាស់កុំរំលង
ទើបបានផលផងយ៉ាងនេះក្រិដ្ឋ ៗ អវេជ្ជាស្ទារ៉ៈ ថ្ងៃនេះស្អែក បរមស្វ៊ៈ
ខានស្អែកពិត ឲ្យចាំការនោរំពឹងគិត ថាអញប្រាកដជាទីងស្លាប់ ៗ
រំឭកឲ្យជាប់គល់វេលា កុំឲ្យឃ្លាតឃ្លាមិនត្រូវត្រាប់ ឲ្យលង់ចិត្តចុះទៅ
តាមច្បាប់ ទើបគាប់ដូចព្រះបន្ទូលថា ៗ សង្គ្រាមផ្លឹកកុំឲ្យភ្លេច ឲ្យ
បានសម្រេចធម៌អនិច្ចា រំពឹងឲ្យច្បាស់ផ្កាលផ្ទួន ថាអញត្រូវការស្លាប់
មិនលែង ៗ ការនោកុំភ្លេចគល់វេលា ឲ្យបានពិស្តារៈប្រែនយូរវែង
បន្ទឹកបង្ហាត់គំនិតឯង គួរស្បែងខ្លាចស្លាប់រូបវេទនា ៗ គេនត្រៃយទាំង
បីបទ ឲ្យតាំងតមាត់រៀនគល់ឃ្លា ថ្វាយបង្គំព្រះគល់វេលា ជាគ្រឿង
សស្ត្រាការសត្រូវ ៗ សំគាល់ធម៌ណាជាបរមត្ថ ប្រុង·ប្រៀបប្រយ័ត្ន
ចាំទុកទៅ គល់រូបមុខជាមិនលែងត្រូវ ការស្លាប់មានន៎ះនៅរូបទាំងអស់ ៗ
អាចារ្យឲ្យធម៌ក៏មិនបាន ព្រលឹងវិញ្ញាណមិនខ្ពស់សោះ ស្លូតមាត់ប្រហក
ត្រៀមផ្ដោះ លុះតែក៏ភ្លូខ្លួសទើបស្លាប់បាន ៗ អហោំគាំងចិត្តគិតឲ្យហើយ

អ្នកកុំបណ្ដោយឲ្យចាកស្ថាន សំណាងគិតៈច្រើនវានមិនបាន កុំខានចាំ តែចំពោះគេ ៗ កុំអួតកុំអាងសំណាងខ្លួន ក្រែងជួនជាខុសទៅទទេ វេទនាខ្វះខាតសព្វជាគេ គ័តគ្រោះទោះឃើញលំបាកក្រៃ ៗ មរណ-ទុក្ខនេះលំបាកណាស់ លុះដល់ប្រទះទើបបានក៏យ មិនដឹងជាក្រុជាឆ្ងាយ បើអ្នកនៅឆាយមិនដឹងគេកះ ៗ ស្លាប់ទៅប៉ុន្មានបាត់សូន្យឈ្លឹង គ្មានក្ដីដំណឹងនៅតែឈ្មោះ ធ្វើបុណ្យតែរូបដូចតល់ៗស ដុតគារបញ្ចុះជាបានហើយ ៗ ត្រង់ក្រែងឆ្ងាយគ្មានដំណឹង មិនមានវិលវិញមកប្រាប់ឡើយ ដុតគារបានទៅទុកព្រៃឆ្ងាយ អ្នកអើយគេធ្វើគបគុណទេ ៗ បើកូនស្រុះស្រួលដោយចិត្តស្មោះ ធ្វើបុណ្យចំពោះទៅឪម៉ែ តាមដោយសុចរិតបានខ្ពះវែរ បើចិត្តកាប្រែមិនត្រង់ស្មោះ ៗ អ្នកកុំពើងបានទៅដល់ កាគិតខ្វាយខ្វល់ទឹងរបស់ ចិត្តកាក៏ដឹងមិនត្រង់ស្មោះ ធ្វើព្រើនក្រែងអស់ក៏ខ្ទេច ៗ កាព្រៀងដំណើរដាក់ទៅឲ្យ របស់ខ្សត់-ខ្សោយហើងខ្ជិខ្ជា ប្រែសប់បានថ្នាំងកាំបិតព្រា ទ្រព្យណាឥតការដាក់ចុង ៗ ចិញ្ចឹមលបុជាសប្រែសប់ស្ទើង បង្រ្កូលដំកើងទុកបំរុង អាល័យសោកស្ដាយគិតដើមចុង ស្ទើរស្ទុតប្ររខ្លួនសូមទោឋង ៗ អាល័យខ្ញាំងណាសំមួយខែថាយ ចែកទ្រព្យប្រញាយគ្រប់ប្អូនបង បានតិចបានច្រើនកើតសៅហ្មង ប្អូនបងតាំងគ្នាកើតក្ដីក្ដាំ ៗ អ្នកអើយទំប្រើងចិញ្ចឹមកូន ប្រចិត្តប្រខ្វួននឹងតៀរកម្ម មិនឲ្យអត់ឃ្លានប្រឹងទ្រទ្រាំ ដល់ខ្លួន

ថែថមចាស់ជរា ។ រកកូនណាមួយគាស្លូតគ្មាន ប្រដៅទូន្មានមិនស្តាប់
ណា ប្រទូស្តរឹងរូសឈ្លោះឆ្លើយថា បុស្សាផ្ទួញផ្តាល់បង្គាប់វិញ ។
ស្រឡាញ់កូនស្មើរប្តូរជីវិត ទំអត់មិនហ៊ានបរិហារចេញ ទឹកភ្នែកស-
ស្រោកពុះពោរពេញ កូនចៅស្រឡាញ់មិនដូចចិត្ត ។ ម្ល៉ោះហើយ
ទើងខ្នាញ់ស្តីឲ្យរាក ឥតមានកូនណាដូចគំនិត រាប់ថាឯងចាស់មិនប្រព្រឹត្ត
ម្ល៉ោះហើយទើងចិត្តអាណិតខ្លួន ។ ទ្រព្យធនណាល្អមិនធ្វើបុណ្យ ផ្គត់ផ្គង់
បម្រើទុកឲ្យកូន បុណ្យទានមិនបានធ្វើម្តង ក្រែងកូនគ្មានស៊ីគ្មាន
ស្លៀកពាក់ ។ ទាល់តែស្លាប់ទៅវេទនា ឥតមានកូនណាជួយធុរៈ
ទ្រព្យរបស់ចែករាល់មាន មាសប្រាក់ គិតចុះណាអ្នកកុំសង្ស័យ ។ ស្លាប់
ទៅរំពឹងកូនធ្វើបុណ្យ ពិចារណាចុះផងទាំងប្រុសស្រី តែមិនប្រយ័ត្ន
ទៅអវីចី ធ្វើអ្វីធ្វើទៅតាមខ្លួនរស់ ។ រៀនធម៌ប្រតិបត្តិតាមសម្មា ព្រះ
អង្គទេសនាមិនដែលខុស រៀនសូត្រការនាទាន់ខ្លួនរស់ គួរគិតពិគ្រោះ
ទើងអ្នកប្រាជ្ញ ។ គេធ្វើបុណ្យឲ្យមិនទៀងណា ស្រេចនូវអាត្មាក្រែង
កោតខ្លាច កាន់សីលភាវនាកល់ព្រឹកល្ងាច នោះអាចប្រាកដទៀងជា
បាន ។ ដល់វេលាស្លាប់លះលែងជាតិ អះឡូលឃ្លាឃ្លាតមនុស្សលោក
ឋាន គេជះភាវនាធម៌សីលទាន នាំប្រាណហោះផ្សងទៅកុសល ។
ស្ថានសោះមែនមានប្រាជ្ញណ៍ប្រាសាទ ប្រសើរស្អាងស្អាតអស់ពីចិត្ត
សម្បត្តិទ្រព្យហូរចូលលែងគិត រាប់ពុំអស់ឥតមានខ្វះអ្វី ។ មានហ្វូង

នាងស្រីទេពកញ្ញា នៅជាប់ពីក្រោយស្រស់ស្រី ពីរពាន់សម្រាប់ជាប្រក្រតី មានត្បូងភ្លឺក្រែស្រាវ ៗ ដេញដំប្រគំគំប្រៀងថ្វាយ ឮស័ព្ទសូរ សាយពីរោះក្រៃ កល់ពេលវេហាអចិន្ត្រៃយ សព្វថ្ងៃគាប់ចិត្តល្អពន់ទៀត ៗ អស់ពួកស្រីស្នំក្រមការគាល់ ពយៈរៀងរូបកល់យ៉ាងឯកៗ ស្អាងខ្លួនកូល យាមតាមដោយទ្បែក ដោយពួកៈដោយប៉ែកចែកវេនគ្នា ៗ គ្មានអាក់ គ្មានអៀនគ្មានអន់ចិត្ត គ្មានប្រណែនគុំគន់នឹងគ្នា តាមតែសព្វព្រះហ-ឫទយា ទីដ៏រូបអ្នកណាឥតមន្ទិល ៗ សំដែងបែបនេះយ៉ាងថោកទាប បើតាមសភាពអំណាចសីល កាន់ខ្ជាប់ទំនៀមស្ត្រីកុំខ្ជិល រំកិលជាតិ កើនលឿនទៅមុខ ៗ បានដល់អរិយមគ្គក៏សឹងមាន សម្រេចទិញ្ញានស្អាន ក្សេមសុខ ប្រាសចាកអំពីសេចក្តីទុក្ខ ប្រយោជន៍ទៅមុខព្រោះតែសីល ៗ ហេតុនេះគួរអ្នកខំសង្វាត ចិត្តកុំប្រមាទជួបជាទិវ្យ ទំនៀមសព្វថ្ងៃកុំគិតខ្ជិល ទើបបានរំកិលជឿនជាតិទៅ ៗ តាំងចិត្តធ្វើឲ្យបរិសុទ្ធ ឲ្យទៀងហ្មត់ ចិត្តត្រង់ត្រឹមត្រូវ ប្រព្រឹត្តដើរតាមគន្លងផ្លូវ អរិយមគ្គត្រូវទើបបានខ្ពស់ ៗ អ្នកឯងកុំនឹកថាខ្លួននៅ ក្មេងទេត្រូវមិនទាន់ចាស់ ឈប់ចាំបន្តិចឲ្យចំ-ណាស់ សិនសឹមគិតប្រាសកេរៀនធម៌ ៗ កុំគិតក្នុងចិត្តស្រវឹងថា ខ្លួនអ្នកឯងណាទៅរូបល្អ ក្អេងក្អាងក្នុងចិត្តគិតស្មោះសារ អ្នកអរទើបរូបឥតកេតចាប់ ៗ ហើយអ្នកកុំអាលគិតថាខ្លួន ចំណាចចាំមួនមិនទាន់ស្លាប់ បន្តិចទៀតសិនសឹមរៀនច្បាប់ ធ្វើតាមសណ្តាប់គ្រូអាចារ្យ ៗ គិតគំនិត

នោះខុសមិនស្អាត ចាត់ជាប្រមាទក្នុងសង្ខារ សំដីយ៉ាងហ្នឹងមិនគួរថា
កុំអួតបំពាចាក់ពោលចេញ ៗ ផ្ទរស្ទាប់សព្វថ្ងៃទៅហូរហៃ មិនគិត
កាញ់គ្នារៀនខុសខ្ទួញ បង្ការប្រយ័ត្នខ្លួននោះមិញ ទៅវិញពន្លឺផ្ទរឲ្យ
យល់ ៗ ព្រលឹងថយចេញអស់វិញ្ញាណ រូបប្រាណចង្ក្រានដូចខ្មោស
គល់ កំពុងនៅពាលគ្មានគិតយល់ ធ្លាក់ដល់ផលមរណក្ស័យ ៗ ទើប
បានគិតឃើញភ័យគេផ្ទរ គេម៉ែគេឪព្រះគុណថ្លៃ គ្មានធម៌ស្ងូត្រផ្គុំផ្ទប
សព្វថ្ងៃ ទៀបក្ស័យដឹងខ្លួនជាតុកឡុង ៗ លុះដល់ពេលមកបៀតបៀន
កាយ ឈឺចុកសៀតសាយដាប់ដល់ចុង អាហារបាយទឹកពោះផ្ទុកហុង
ដាក់ចុះក្នុងមាត់លេបមិនបាន ៗ ដឹងខ្លួនជាក់ច្បាស់ជាខ្ទង់ក្ស័យ គិតភ័យ
ពេកក្រៃក្រៃពន់ប្រមាណ ប្រមើលមើលរូបកាយខ្លួនប្រាណ រំងារំខានចិត្តជា
ទុក្ខ ៗ ស្តាយកូនស្តាយចៅស្តាយប្រពន្ធ ស្តាយអស់ទ្រព្យធនវ៉ែវត្ត
ខ្វង់ត្រួតស្លូតស្លប់សញ្ជប់មុខ ពេតរ៉ងរឹតទុកកាន់តែខ្លាំង ៗ លុះដល់ទៀប
ហៀបផុតទឹងក្ស័យ គិតភ័យពេកក្រៃស្ងន់ស្មុគស្មាំង ស្មារតីក្តួចក្តីដល់
កំឡាំង ទើបគេរៀបក្រាំងសូត្រការកា ៗ ប្រាថ្នាបង់ឲ្យរដោះកម្ម តែ
គ្មានបានចាំបទត្រង់ណា វេលតែទឹងឈឺខ្លោចផ្សា ក្នុងអត្តាឃាតពន់ប្រ-
មាណ ៗ ធម៌រៀនចេះហើយគ្មានគេក្រា ដល់ភ័យប្រាកេធម៌គ្មាន មិន
គេក្សាទុកបម្រុងប្រាណ មិនចេះពប់ការពោលបង់ភ្លោះ ៗ ប្រៀបដូចបង
ប្អូនស្រឡាញ់គ្នា យូរទៅឃ្លាតឃ្លាមិនពប់សោះ មិនដែលហៅគេចំចេញ

ណោះ ពីព្រោះចិត្តលោភដូច្នេះឯង ៗ ដល់ក័យហៅគេបងប្អូនជួយ ប្អូន បែរមុខក្រោយមិនគិតក្រែង កាលណាគេនឹងស្រណោះឯង ក្រែងតែ មានព្រេងបុណ្យកុសល ៗ អំពីអតីតសាងមកច្រើន ជួយថែគ្រវេនទោះ មិនថា គ្មានគិតសន្សំមគ្គផល បណ្តារប្រយ័ត្នដល់ខ្លួនស្លាប់ ៗ អ្នក ស្លាប់ទៅមុននោះច្រើនណាស់ មិនដែលប្រទះវិលមកប្រាប់ ដំណើរ ដែលទៅឲ្យយើងស្តាប់ សារសព្ទឲ្យដឹងបែបយ៉ាងណា ៗ តែស្លាប់ទៅ បាត់ជ្រងំឈឹង មិនដែលវិលវិញមកប្រាប់ថា ទៅបានសុខទុក្ខយ៉ាងម្តេច ម្តា ឲ្យយើងកល់គ្នាបានដឹងផង ៗ

ក្រែងខ្ញុំលើកលោះខុសសេចក្តី មិនគួរគេរៀបបែបទំនង ខុសពាក្យ កុបកិនមិនប៉ុនឃ្លោង ខុសបែបគន្លងផ្លូវឆមិកាថ៍ ៗ ផ្សិតទើបនឹងរៀបរៀន លើកម្តង សេចក្តីច្រើនឆ្គងគ្រប់ប្រការ លោកណាចេះអាចសូមមេត្តា ជម្រង់ភាសាឲ្យពានផង ៗ កន្សែវពាក្យបំបប់សេចក្តី ល្មមគួរគប្បីស្តាប់ ហើយហោង អស់តាំងសន្តានគួរចាំចង់ សូរេចម៉្លេះផងចប់ឯរំ ៗ ៚

ចប់ច្បាប់ក្រិត្យក្រិន តែប៉ុណ្ណេះ ។

ប្រវត្តិពួកឧបាសិកា

ជាសាវិការបស់ព្រះពុទ្ធជាម្ចាស់

៥ នាងឧត្តរា — នន្ទមាតា ជាអ្នកក្រុងរាជគ្រឹះ បិតារបស់នាងឈ្មោះបុណ្ណៈ ដែលជាខ្ញុំនៅក្នុងផ្ទះរបស់សុមនសេដ្ឋី ។ ថ្ងៃមួយនោះជាថ្ងៃមហោស្រព សុមនសេដ្ឋីមិនព្រមឲ្យនាយបុណ្ណៈឈប់លេងមហោស្រពទេ បង្គាប់ឲ្យកាន់នង្គ័លទៅភ្ជួរស្រែ ចួនជាថ្ងៃនោះព្រះសារីបុត្រលោកចេញអំពីនិរោធសមាបត្តិ ឃើញឧបនិស្ស័យរបស់នាយបុណ្ណៈទើបលោកនិមន្តទៅជិតកន្លែងភ្ជួរស្រែនោះ នាយបុណ្ណៈគ្រាន់តែក្រឡេកឃើញព្រះថេរៈក៏កើតបីតិត្រេកអរ ទើបបេះឈើស្ទន់សម្រាប់ជម្រះធ្មេញ នឹងទឹកទៅប្រគេនលោក ហើយរំពឹងគិតក្នុងចិត្តថា កាលពីថ្ងៃមុនៗមក អញមកស្រែមិនដែលបានជួបប្រទះនឹងលោកម្ចាស់សោះ ទើបតែបានប្រទះក្នុងថ្ងៃនេះប្រហែលជាភ័ព្វសំណាងរបស់អញ ប្រសិនបើភរិយាយកបាយមកឲ្យអញហើយ បានជួបនឹងលោកនៅពាក់កណ្តាលផ្លូវ ចូរប្រគេនបាយនោះទៅលោកចុះ អញមុខជាបានផលបុណ្យជាច្រើនពុំខាន ។

គ្រានោះ ភរិយារបស់នាយបុណ្ណៈ កំពុងនាំបាយមកឲ្យប្តីស្រាប់តែបានជួបនឹងព្រះថេរៈនៅពាក់កណ្តាលផ្លូវ ទើបប្រគេនបាយនោះដល់ព្រះថេរៈដោយចិត្តសទ្ធាជ្រះថ្លា សមតាមគំនិតស្វាមីរបស់នាង ។ លុះនាងបាន

ប្រគេនចង្ហាន់ព្រះថេរៈហើយ ក៏វិលត្រឡប់ទៅផ្ទះចាត់ចែងដាំបាយជាថ្មី ហើយនាំយកទៅឲ្យស្វាមីទៀត បាននិយាយរឿងធ្វើទាននោះប្រាប់ស្វាមីសព្វគ្រប់ ឯនាយបុណ្ណៈក៏និយាយប្រាប់អំពីគំនិត គិតគូររបស់ខ្លួនឲ្យភរិយាស្តាប់ដែរ ស្វាមីភរិយាទាំងពីរក៏មានចិត្តសោមនស្សស្មើគ្នាទាំងពីរនាក់ ។

នាយបុណ្ណៈបរិភោគអាហាររួចហើយ ក៏ដេកលក់ទៅមួយស្របក់ ក្រោកឡើងឃើញមានពណ៌លឿងពេញទាំងស្រែ ក៏ស្មានថាជាផ្លែល្ពៅ តែការពិតនោះជាដុំមាសមានទំហំប៉ុនផ្លែល្ពៅ កើតឡើងដោយអំណាចបុញ្ញសម្បត្តិនៃខ្លួន ដែលបានបរិច្ចាគរួមគ្នាក្នុងថ្ងៃនោះ ទើបនាំសេចក្តីនោះក្រាបបង្គំទូលដល់ព្រះរាជា ព្រះរាជាទ្រង់ប្រាប់ឲ្យគេចាត់នាំយកមាសនោះមកហើយ ទ្រង់តាំងជាសេដ្ឋី ជាអ្នកមានស្តុកស្តម្ភបំផុតក្នុងស្រុកនោះ ។

លោកបុណ្ណសេដ្ឋី បានក្រាបបង្គំទូលអារាធនាព្រះពុទ្ធជាម្ចាស់ព្រមទាំងព្រះភិក្ខុសង្ឃទៅទទួលចង្ហាន់នៅផ្ទះរបស់ខ្លួន ហើយលោកសេ-ដ្ឋីអង្គាសដោយភោជនាហារយ៉ាងផ្ចិតផ្ចង់ជាវេលា ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានស្តាប់គាថាអនុមោទនា ហើយបានសម្រេចសោតាបត្តិផលទាំងប្តីទាំងប្រពន្ធទាំងពីរនាក់ ។

ឯធីតារបស់លោកបុណ្ណសេដ្ឋីនោះឈ្មោះនាងឧត្តរា ជាស្ត្រីមានសទ្ធាជ្រះថ្លាយ៉ាងខ្ជាប់ខ្ជួនក្នុងព្រះពុទ្ធសាសនា កាលបានចំរើនវ័យពេញ

ក្រមុំហើយ ទើបកដគហសេដ្ឋីជាចៅហ្វាយចាស់របស់បុណ្ណសេដ្ឋីកាល បានដំណឹងថា បុត្រីរបស់បុណ្ណសេដ្ឋីពេញក្រមុំហើយ ទើបចាត់ឲ្យមនុស្សទៅដណ្តឹង ឲ្យកូនប្រុសរបស់ខ្លួន ។ ដំបូងបុណ្ណសេដ្ឋីមានសេចក្តីរង្កៀសមិនព្រមឲ្យ ព្រោះត្រកូលកដគហសេដ្ឋី ជាមិច្ឆាទិដ្ឋិ នៅទីបំផុតបានព្រមព្រៀងគ្នាវិញ ដោយកដគហសេដ្ឋីឲ្យខសន្យាថា នឹងអនុញ្ញាតឲ្យកូនប្រសាស្រីនោះកាន់លទ្ធិសាសនា នឹងធ្វើបុណ្យទានផ្សេងៗតាមចិត្តបាន ទើបបុណ្ណសេដ្ឋីព្រមព្រៀងឲ្យរៀបមង្គលការផ្សំផ្គុំបុត្រីនឹងបុត្រកដគហសេដ្ឋីនោះ ។

នាងឧត្តរានៅរួបរួមជាមួយនឹងស្វាមី ដោយសេចក្តីសុខសប្បាយរហូតមក តែនាងចង់ដោះខ្លួនទៅរក្សាឧបោសថ ចំរើនកិច្ចវត្តតាមមុខក្រសួងរបស់ឧបាសិកា ទើបនាងទៅនិយាយជួលនាងសិរិមា ដែលជាស្រីពេស្យាមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងវេលានោះ ឲ្យមកនៅបំរើស្វាមីរបស់ខ្លួន ទើបនាងបានឱកាសទៅចំរើនធម្មបដិបត្តិ និងបំពេញកុសលកម្មក្នុងព្រះពុទ្ធសាសនា ។ ចំណែកឯនាងសិរិមា កាលបានមកនៅបំរើស្វាមីនាងឧត្តរាជាយូរថ្ងៃទៅ ក៏ភ្លេចខ្លួនកើតសេចក្តីប្រចណ្ឌនឹងនាងឧត្តរា ទើបចូលទៅប្រទូស្តរាយនាងឧត្តរា ឯពួកទាសីស្រីបំរើរបស់នាងឧត្តរា បានឃើញដូច្នោះ ក៏នាំគ្នាស្ទុះមកជួយការពារចៅហ្វាយរបស់ខ្លួន ហើយប្រឆាំងនឹងប្រទូស្តតបទៅវិញ តែនាងឧត្តរាបានហាមឃាត់កុំឲ្យធ្វើ ។ សេចក្តី

ប្រព្រឹត្តិល្អរបស់នាងឧត្តរាធ្វើឲ្យនាងសិរិមាដឹងខ្លួនថា ជាអ្នកធ្វើខុសហើយ សុំខមាទោស នាងឧត្តរាក៏ទទួលអត់ទោសឲ្យនៅចំពោះព្រះភក្ត្រព្រះបរមសាស្តា ។ អាស្រ័យហេតុដែលនាងឧត្តរាជាអ្នកស្ទាត់ជំនាញក្នុងការចំរើនឈាន ទើបព្រះបរមសាស្តាទ្រង់តាំងក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងជាងពួកឧបាសិកាដែលចំរើនឈាន ។

ចប់ប្រវត្តិសង្ខេបរបស់នាងឧត្តរាឧបាសិកា តែប៉ុណ្ណេះ ។

៦ សុប្បវាសា–កោលិយធីតា កើតក្នុងខត្តិយត្រកូល ក្នុងកោលិយនគរ មានព្រះនាមថា សុប្បវាសា កាលទ្រង់ព្រះចំរើនវ័យ បានអភិសេកសមរសនឹងសក្យកុមារ ១ អង្គ សម័យមួយបានស្តាប់ព្រះធម្មទេសនា របស់ព្រះបរមសាស្តា បានសម្រេចសោតាបត្តិផល តមកប្រសូតព្រះឱរស ១ អង្គ ទ្រង់តាំងនាមថា សីវលី (ដូចមានរឿងពិស្តារក្នុងប្រវត្តិព្រះសីវលិត្ថេរ ក្នុងអនុពុទ្ធប្រវត្តិ ៨០ អង្គ) ។

សម័យមួយព្រះនាងសុប្បវាសា បាននិមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រមុខឲ្យមកទទួលបិណ្ឌបាត្រក្នុងដំណាក់របស់ខ្លួន បានថ្វាយអាហារគោជនយ៉ាងផ្ចិតផ្ចង់ មានរសជាតិដ៏លើសលុបមានចំនួនជាច្រើនមុខផង ។ កាលព្រះបរមសាស្តា ទ្រង់សោយស្រេចហើយ ទើបទ្រង់អនុមោទនា បានទ្រង់សំដែងធម៌ ដល់ព្រះនាងសុប្បវាសា មានសេចក្តីថា ព្រះអរិយ-

សាវកទុកជាទាយកយ៉ាងឧត្តម តែងប្រគេនដោយគោរព ចាត់ជាវិធីឧត្តម ភោជនមានឱជារសដ៏ឧត្តម បានថ្វាយដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រមុខ ទុកជាបដិគ្គាហកដ៏ឧត្តម រមែងបានទទួលផលដ៏ឧត្តម ៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ។

ដោយអាស្រ័យហេតុនេះ ទើបព្រះបរមសាស្ដាទ្រង់តាំងព្រះនាងសុប្បវាសា-កោលិយធីតា ក្នុងឯតទគ្គដ្ឋាន ប្រសើរលើសលែងពួកឧបាសិកាដែលថ្វាយបង្ហាន់ដ៏ផ្ចិតផ្ចង់ ។

ចប់ប្រវត្តិសង្ខេបរបស់ព្រះនាងសុប្បវាសា-កោលិយធីតា តែប៉ុណ្ណេះ ។

រឿងព្រះបាទអសោក

(តមក)

រាជបុរោហិតក្រាបបង្គំទូលថា "បពិត្រព្រះសម្មតិទេព ! សូមព្រះអង្គនាំព្រះរាជកុមារទាំងអស់ទៅកាន់រាជសុវណ្ណឧទ្យានឯណោះ ខ្ញុំព្រះអង្គនឹងពិចារណាមើលទាយព្រះរាជកុមារទាំងអស់នោះ ក្នុងទីនោះ ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះរាជានុញ្ញាត ឲ្យនាំព្រះរាជកុមារទៅកាន់សួននោះហើយ ខណៈនោះ ព្រះរាជជននីបានត្រាស់នឹងអសោកកុមារថា "ម្នាលកូន ព្រះរាជាកំពុងទ្រង់ពិនិត្យមើលទំនាយព្រះរាជបុត្រទាំងឡាយរបស់ព្រះអង្គនៅក្នុងសុវណ្ណឧទ្យាន ព្រះអង្គស្តេចយាងទៅមុនហើយ ចូរឯងទៅទីនោះទៅ កូន" ។ អសោកកុមារតបថា "ស្តេចមិនទ្រង់ប្រោសប្រាណខ្ញុំទេ ព្រះអង្គនឹងមិនទតមកត្រង់ខ្ញុំឡើយ ខ្ញុំទៅក្នុងទីនោះតើមានប្រយោជន៍អ្វី?" ។ ព្រះមាតាត្រាស់ថា "បើទុកជាយ៉ាងណាក៏ត្រូវតែឯងទៅ" ។ អសោកកុមារទូលថា "បើដូច្នោះ ខ្ញុំទៅហើយ ព្រះមាតាឲ្យគេយកអាហារទៅឲ្យខ្ញុំផង" ។

គ្រានោះ អសោកកុមារបានលាព្រះមាតាហើយ ស្តេចចេញពីព្រះនគរបាដលិបុត្រ ទតឃើញរាធគុត្តកុមារជាបុត្រនៃសេនាបតីទី ១ នៅកណ្តាលផ្លូវ រាធគុត្តកុមារទូលសួរថា "ព្រះអង្គម្ចាស់ស្តេចយាងទៅណាហ្នឹង?" អសោកកុមារតបថា "ព្រះរាជបិតាទ្រង់ប្រជុំព្រះឱរស

ទាំងឡាយនៅទីសុវណ្ណឧទ្យាន ថ្ងៃនេះខ្ញុំក៏ទៅក្នុងទីនោះដែរ" ។ កាលនោះរាជបុត្រកុមារជិះលើកុញ្ជរចាស់ជរាមួយ ក៏ក្រាបទូលអសោករាជកុមារថា "ពេលនេះ ខ្ញុំព្រះអង្គក៏ទៅក្នុងទីនោះដែរ សូមព្រះអង្គម្ចាស់ទ្រង់លើកុញ្ជរនេះជាមួយនឹងខ្ញុំទៅ" ព្រោះដូច្នោះ អសោករាជកុមារទ្រង់ឡើងគង់លើដំរីជាមួយនឹងរាជបុត្រកុមារ ស្ដេចយាងទៅកាន់ព្រះរាជឧទ្យាននោះ លុះដល់ហើយក៏ចុះចាកកុញ្ជរយាត្រាទៅដោយព្រះបាទាចូលទៅ ប្រថាប់លើផែនពសុធានាទីជិតរាជកុមារទាំងឡាយ ។ ក៏ពួករាជកុមារទាំងនោះ នាំគ្នាសោយអាហារដ៏ឧត្ដមប្រសើរផ្សេងៗ គ្រប់យ៉ាង ឯអសោកកុមារនោះ សោយបាយបាយាសលាយដោយទឹកដោះគោដាក់ក្នុងភាជនដីហើយនឹងទឹកសុទ្ធជាធម្មតា ។

គ្រានោះ ព្រះរាជាមានព្រះបន្ទូលនឹងបុរោហិតថា "លោកអាចារ្យ ខ្ញុំសូមឲ្យលោកពិចារណាមើលពិនិត្យពិច័យព្រះរាជកុមារឲ្យជាក់ច្បាស់ថា អ្នកណាអាចនឹងបានជាស្ដេចគ្រប់គ្រងរាជអាណាចក្រ ក្នុងកាលជាអ-នាគតអំពីខ្ញុំទៅ?" ។

រាជបុរោហិត ទើបពិចារណាមើលលក្ខណៈព្រះរាជកុមារទាំងឡាយ រំពឹងក្នុងចិត្តថា "ប្រាកដជាអសោកកុមារនេះឯង នឹងបានជាព្រះរាជា ប្រសិនបើអញក្រាបទូលថា អសោកកុមារនឹងបានជាស្ដេច ព្រះអង្គមិនសព្វព្រះរាជហឫទ័យចំពោះកុមារនោះសោះឡើយ ក៏នឹងអន្ដរាយដល់

ជីវិតរបស់អាត្មាអញមិនខាន" លុះរំពឹងគិតដូច្នោះហើយ បុរោហិតទើបក្រាបទូលព្រះរាជាថា "សូមទេវៈ ខ្ញុំព្រះអង្គនឹងទាយដោយមិនចំពោះព្រះនាមព្រះកុមារអង្គណាមួយឡើយ ខ្ញុំទាយទៅតាមឫកពាថា "ជោគដួងជាតា រាជកុមារឯណា ដែលប្រើប្រាស់វត្ថុដ៏ឧត្តមប្រសើរជាងគេបំផុត រាជកុមារនោះនឹងបានជាស្តេច" ។

ព្រះរាជកុមារគ្រប់ព្រះអង្គ គិតស្មានតែក្នុងចិត្តរបស់ខ្លួនៗ មួយអង្គគិតថាអញមានពាហនៈប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញអង្គុយលើអាសនៈដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញបរិភោគអាហារដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គគិតថា អញប្រើប្រាស់ភាជនៈដ៏ប្រសើរ អញនឹងបានជាស្តេច, មួយអង្គទៀតគិតថា អញផឹកទឹកដ៏ប្រសើរ អញនឹងបានជាស្តេច ។ ឯអសោភករាជកុមារត្រិះរិះក្នុងចិត្តថា "អញនឹងត្រូវបានជាស្តេច ព្រោះកុញ្ជរជាពាហនៈដ៏ប្រសើរបំផុត ពសុធាជាអាសនៈដ៏ប្រសើរបំផុត បាយាសជាអាហារដ៏ប្រសើរបំផុត ភាជនៈដីជាវត្ថុដ៏ប្រសើរបំផុត ទឹកដោះគោជាព្រះស្ងោយដ៏ប្រសើរបំផុត ទឹកស្ទឹងជាបានៈដ៏ប្រសើរបំផុត ខ្លួនអញហ្នឹងឯងនឹងបានជាស្តេច ព្រោះត្រូវសមគ្រប់វត្ថុទាំងអស់នេះ" ។

កាលបុរោហិតក្រាបទូលទំនាយនេះស្រេចហើយ ព្រះរាជាក៏បញ្ជូនព្រះរាជកុមារទាំងអស់អង្គ ឲ្យស្តេចត្រឡប់មកព្រះនគរវិញ ។

រាជបុរោហិតបានចូលទៅគាល់ព្រះមាតារបស់អសោកកុមារ ហើយទូលព្រះនាងថា "ប្រាកដជាអសោកកុមារនឹងបានជាស្តេច" ។ ព្រះមាតាអសោកកុមារត្រាស់ថា "ចូរអ្នកបិទរឿងនេះឲ្យជិត កុំនិយាយប្រាប់អ្នកណាមួយសោះឡើយ បើមិនថ្ងៃណា គង់ថ្ងៃណាមួយ ព្រះករុណាជាម្ចាស់ជីវិត នឹងត្រាស់ហៅអ្នកទៅសួរដំណឹងនេះទៀតមិនខាន ហើយអ្នកនឹងត្រូវអន្តរាយដល់ជីវិត ព្រោះដូច្នោះ ត្រូវអ្នកចេញចាករដ្ឋសីមាមណ្ឌលនេះទៅលាក់ខ្លួនពួនកាត់នៅឲ្យឆ្ងាយផុតការណា រេត្តរបស់ព្រះអង្គ ដើម្បីនឹងរក្សាជីវិតរបស់អ្នក បើបានឮដំណឹងថាអសោកកុមារបានរាជសម្បត្តិហើយ សូមអ្នកត្រឡប់មកវិញក្នុងពេលនោះចុះ ។

គ្រាខាងក្រោយមក នគរតក្កសិលា កើតបះបោរក្បត់កាប់សម្លាប់គ្នាជាចលាចលវឹកវរ ព្រះបាទពិន្ទុសារៈទើបទ្រង់ចាត់ឲ្យអសោកកុមារទៅបង្ក្រាបរៀបចំទីនោះ ទ្រង់ត្រាស់ថា "ម្នាលកូន ឯងចូរទៅរៀបចំនគរតក្កសិលា" តែព្រះរាជាទ្រង់ព្រះរាជទានចំពោះតែកងទ័ពព្រមដោយចតុរង្គនីសេនា មិនបានព្រះរាជទានគ្រឿងសស្ត្រាវុធនឹងរថសង្គ្រាមឡើយ ។

ខណៈដែលអសោកកុមារបានទទួលព្រះរាជឱង្ការហើយលើករេហ៍ពលចេញចាកនគរបាដលីបុត្រ គ្រានោះពួកពលដែលជាប់តាមព្រះអង្គទៅ បានទូលអង្វរឃាត់ថា "ពួកយើងមិនមានសស្ត្រាវុធទេ យើងនឹងធ្វើចម្បាំងតយុទ្ធនឹងពួកខ្មាំងដូចម្តេចបាន ?" ។

អសោករាជឱរសមានព្រះបន្ទូលថា "ប្រសិនបើបុញ្ញានុភាពដែលបណ្ដាលឲ្យយើងខ្ញុំបានរាជសម្បត្តិមែន ខ្ញុំសូមឲ្យគ្រឿងសស្ត្រាវុធដែលយើងត្រូវការនោះកើតមានឡើងឯងៗ ក្នុងកាលឥឡូវនេះ" ។ ត្រាស់មិនទាន់ផុតពីព្រះឱស្ឋ ក៏ពួកភូមិទេវតាដែកយហាប្រថពីស្ទុះស្ទាចេញមកនាំយកគ្រឿងសស្ត្រាវុធកាលដៃមកថ្វាយ ។

គ្រានោះ ព្រះរាជឱរសព្រមដោយចតុរង្គសេនា ស្ដេចយាត្រាចូលកាន់ក្រុងតក្កសិលាជាទឡ្យារិកស្នួរស្នេង ពួកអ្នកនគរនោះ កាលបានឮដំណឹងថា អសោករាជកុមារយាងមកដល់ ក៏នាំគ្នារៀបអធិករណ៍នោះទៅឯង ត្រឡប់ជានាំគ្នារៀបចំតាក់តែងកំពែងបុរីស្អិតស្អាងផ្លូវប្រដាប់ទៅដោយគូទឹងស្លាមក្លោះដ៏ស្អាតល្អ ហើយនាំគ្នាយកភាជនៈដ៏ពេញទៅដោយគ្រឿងបណ្ណាការនឹងផ្កា ចេញមកទទួលព្រះរាជកុមារ ដើម្បីសំដែងសេចក្ដីចុះចូលនឹងព្រះអង្គ កាលទៅដល់ក្នុងទីចំពោះព្រះភក្ត្រ ចំនួនបន្ទាយកន្ទះយោជន៍ ក៏នាំគ្នាក្រែកបន្ទីសំឡេងដ៏ស្រទន់ពីរោះក្រាបទូលថា "ពួកខ្ញុំព្រះអង្គទាំងបានគិតជាសត្រូវខ្មាំងតតាំងនឹងស្ដេចក៏ទេ ពួកខ្ញុំព្រះអង្គទាំងគិតតតាំងជាខ្មាំងនឹងព្រះរាជឱរសក៏ទេដែរ តែពួកខ្ញុំព្រះអង្គប្រះប្រាតទល់នឹងអាមាត្យកំណាចឯណោះ" ថាហើយក៏នាំគ្នាហែហមពោមកេមអសោករាជកុមារ ថ្វាយគ្រឿងបណ្ណាការដោយសេចក្ដីគោរព ហើយស្ដេចយាងចូលទៅកាន់ក្រុងតក្កសិលាជាសុខសួស្ដី ដោយព្រះកិត្តិ-

យសយ៉ាងធំអស្ចារ្យ ។ អ្នកនគរទាំងនោះ ក៏ចុះចូលជារបៀបរៀបរយ សាន្តត្រានស្រួលបួលហើយ ទ្រង់ក៏ត្រឡប់ទៅកាន់នគរព្រះអង្គវិញ ។

ព្រះបាទពិន្ទុសារៈ បានបញ្ជូនអសោករាជកុមារឲ្យទៅបង្ក្រាបនគរខសៈម្តងទៀត ពួកអ្នកនគរនោះ ក៏បាក់បបខ្លបខ្លាចព្រះចេស្ដា ចុះចូលដោយអាការដូចគ្នានឹងរឿងមុន ហើយទ្រង់ត្រឡប់ទៅកាន់នគរព្រះអង្គវិញ ។ មានអ្នកចំបាប់ខ្លាំងពូកែពីរនាក់ ចូលមកសូមនៅអាស្រ័យបម្រើអសោករាជកុមារ ទ្រង់ប្រទានមុខការឲ្យត្រួតត្រាក្សាអាណាខេត្តរបស់ព្រះអង្គជាប់ដោយឡែក ។

ពេលនោះឯង ទេវតានឹងភូមិទេវតាទាំងឡាយដែលជាអ្នកគ្រប់គ្រងព្រះរាជធានីនោះ បានប្រកាសសេចក្ដីឲ្យប្រាកដដូច្នេះថា:

"ចូរអ្នកកល់គ្នាកុំបះបោរឡើយ ព្រោះអសោករាជកុមារនឹងបានជាស្ដេចចក្រពត្តិ ជាម្ចាស់នៃទ្វីបមួយ ក្នុងទ្វីបទាំងបួន មិនមានមនុស្សណាអាចហ៊ានតតាំងនឹងព្រះចេស្ដាបាន ព្រះអង្គនឹងពង្រីកអាណាខេត្តឲ្យដល់ទីបំផុតនៃផ្ទៃប្រថពី ទៅទល់នឹងច្រាំងមហាសមុទ្រទាំងបួនឲ្យតាំងនៅក្រោមអំណាចព្រះអង្គ" ។

ថ្ងៃមួយ ព្រះរៀមនៃអសោករាជកុមារ ព្រះនាមសុសិមៈ ស្ដេចត្រឡប់មក (អំពីការប្រពាតឧទ្យាន) ចូលទៅកាន់ក្រុងបាដលិបុត្រ ។

មានអគ្គមហាសេនាបតីម្នាក់ឈ្មោះខល្វាតកៈ[១] កំពុងដើរចេញទៅអំពីក្រុងទៅជួបនឹងសុសិមរាជកុមារនៅកណ្ដាលផ្លូវ សុសិមរាជកុមារឃើញក្បាលទំពែករលីងយ៉ាងផ្លូះផ្លាះ ទ្រង់តាំងព្រះរាជហឫទ័យនឹងសើចកំសាន្តលេងសប្បាយ ក៏វាយក្បាលអគ្គមហាសេនាបតីនោះនឹងព្រះហស្ត សេនាបតីនោះឃើញដូច្នោះហើយគិតថា :

"ថ្ងៃនេះ ព្រះអង្គម្ចាស់មិនទាន់បានរាជាភិសេកនៅឡើយ ហ៊ានទះក្បាលយើងទៅហើយ ក៏កាលបើបានរាជាភិសេកហើយសមជាស្ដេចនឹងកាត់ក្បាលយើងដោយព្រះខ័នមិនខាន" ។ ចាប់ដើមតាំងតែពីត្រឹមនោះមក ក៏អគ្គមហាសេនាបតីនោះ នាំរឿងកំហុសអាក្រក់របស់សុសិមរាជកុមារមកនិយាយបរិហារប្រាប់ពួកសេនាបតីទាំង ៥០០ នាក់ថា "សុសិមរាជ-កុមារមិនសមគួរជាស្ដេចសោយរាជ្យទេ ហោរាចារ្យបានទាយថា អសោក-រាជកុមារនឹងបានជាស្ដេចចក្រពត្តិ ជាធម្មិករាជព្រះអង្គគ្រប់គ្រងលើទ្វីបមួយក្នុងទ្វីបទាំងបួន ពួកយើងទាំងអស់គ្នាត្រូវលើកព្រះអង្គនោះឲ្យបានរាជបល្ល័ង្ក" ។

ខណៈនោះ ពួកអ្នកស្រុកក្នុងនគរតក្កសិលា កើតក្បត់បះបោរឡើងទៀត ដោយតាំងនៅក្រោមបង្គាប់សេនាបតីកាចអាក្រក់ ក៏ព្រះរាជាចាត់បញ្ជូនសុសិមរាជកុមារឲ្យទៅបង្ក្រាបសត្រូវក្នុងនគរនោះតែមិនអាច

១ ខល្វាតកៈ មានក្បាលទំពែករលីង ។

នឹងរម្ងាប់ឲ្យរៀបរយទៅបាន ។ ព្រះបាទពិន្ទុសារៈទ្រង់ជ្រាបដូច្នោះ ក៏ព្រួយព្រះរាជហឫទ័យខ្លាំងទៅជាប្រឈួន ទ្រង់ត្រាស់បង្គាប់ដល់ពួកសេនាបតីឲ្យប្រគល់រាជសម្បត្តិរបស់ព្រះអង្គទៅសុសិមរាជឱរស ហើយឲ្យអសោក-រាជកុមារទៅរម្ងាប់ពួកខ្មាំងនៅនគរតក្កសិលានោះទៀត. តែពួកសេនាបតីទាំងនោះ មានសេចក្ដីពេញចិត្តនឹងអសោករាជកុមារ ក៏ប្រើកលឧបាយយកល័ខលឿងមកលាបស្រឡាបដងខ្លួនអសោករាជកុមារ ហើយលាយល័ខលឿងទុំដាក់ក្នុងភាជនៈដើម្បីសំដែងឲ្យឃើញប្រាកដគ្រប់គ្នា ទើបទៅក្រាបទូលបំភាន់ព្រះរាជាថា "អសោករាជឱរសប្រឈួនជាទម្ងន់ណាស់ក្អកឈាមចេញមកពីព្រះឱស្ឋស្រស់ៗ មិនសមនឹងទ្រង់ចាត់ឲ្យទៅទទួលការនោះទេ" ។

ពេលនោះ ព្រះបាទពិន្ទុសារៈប្រឈួនរឹងរឹតតែចំរើនខ្លាំងឡើង មានព្រះកាយពលថយណាស់ហើយ ព្រះអង្គយល់ច្បាស់ថា មិនទ្រង់គង់ព្រះជន្មនៅបានតទៅទៀតទេ ក៏ពួកសេនាបតីឃើញដូច្នោះ. នាំគ្នាកាត់តែងអសោករាជកុមារ ដោយគ្រឿងរាជឥស្សរិយយសគ្រប់ប្រការ ហើយនាំស្ដេចទៅគាល់ព្រះរាជា ក្រាបទូលថា :

"យើងខ្ញុំសូមឲ្យព្រះអង្គតាំងអសោករាជកុមារឲ្យទ្រង់គ្រងរាជបល្ល័ង្កបណ្ដោះអាសន្នមុនសិន កាលបើព្រះសុសិមកុមារទើបត្រឡប់មកអំពីក្រុងតក្កសិលាហើយ យើងខ្ញុំនឹងប្រគល់រាជសម្បត្តិថ្វាយជាក្រោយ" ។

អសោកកាន់ទុក្ខសោកទើបផ្សងថា "បើដបល្ល័ង្កនឹងបានជារបស់ខ្ញុំដោយពិតមែនហើយ សូមឲ្យទេវតាបំពាក់មកុដកញ្ចលើក្បាលខ្ញុំចុះ" ។ ពួកទេវតាបានឮពាក្យនោះក៏ឆ្លើយតបមកព្រះអង្គវិញហើយ ទើបយកមកុដកញ្ចបំពាក់ព្រះសិរព្រះអង្គក្នុងខណៈនោះ ។ កាលឃើញសេចក្តីអស្ចារ្យរបស់អសោកកុមារដូច្នោះ ព្រះកជា ក៏ទ្រង់ព្រះក្រោធពិរោធខ្លាំង បណ្តាលឲ្យព្រះលោហិតស្រស់ៗ ពុះពោរហូរចេញមកតាមព្រះឱស្ឋព្រះអង្គ ហើយស្តេចទ្រង់សោយទិវង្គតក្នុងពេលនោះទៅ(១) ។

លុះព្រះបាទអសោកបានរាជសម្បត្តិហើយ បានតាំងរាធគុប្តៈឲ្យធ្វើជាអគ្គមហាសេនាបតីទី ១ របស់ព្រះអង្គ(២) ។

ពួកយក្សបាននាំគ្រឿងពលិការរាជាភិសេកប្រកាសឡើងទៅលើប្រថពីបានមួយយោជន៍ ចំណែកនាគក៏ប្រកាសចុះទៅខាងក្រោមប្រថពីបានមួយយោជន៍ដូចគ្នា ហេតុការណ៍ទាំងនេះ បណ្តាលឲ្យពួកគេប្រកបថា "ថ្ងៃនេះ រាជ្យនៃព្រះបាទវិន្ទុសារៈអស់ហើយ ព្រះបាទអសោកស្តេចឡើងប្រថាប់លើបល្ល័ង្ករាជ្យហើយ" ។

---

១ សៀវភៅពុទ្ធសាសនារបស់លោកញ៉ែ-ហ្វីលហ្វត៍ ដែលលោកម៉ៅ ប៊ុជអៃវ៉ាបា កាលក្នុងរាជព្រះបាទវិន្ទុសារៈជាបិតានោះ អសោកនៅជាឧបរាជនៅស្រុកអវន្តី តាំងព្រះដំណាក់នៅឧជ្ជេនី អសោកបានយកធីតាសេដ្ឋី ១ នៅស្រុកវិទិសា សព្វថ្ងៃនេះហៅភិលសាខ ជាព្រះជាយា ហើយបានព្រះរាជបុត្រ ១ ឈ្មោះមហេន្ទ្រ និងព្រះធីតា ១ ឈ្មោះសង្ឃមិត្រា ដែលទៅមុខទៅនឹងបានជាសាសនាចារ្យទៅក្នុងស្រុកសីឡុង (កោះលង្កា) ។ ២ មហាវង្សៈបានតាំងព្រះតិស្សរាជកុមារដែលជាប្អូនទោជាមួយនឹងព្រះអង្គឲ្យជាព្រះឧបរាជ ។

ព្រះសុសិមកជុរសេះកាលទ្រង់សណ្តាប់ថា ព្រះបិតាទិវង្គតហើយ អសោកកុមារបានមុទ្ធាភិសេកហើយដូច្នោះ ក៏ពិរោធខ្លាំង ស្តេចត្រឡប់ចូលទៅកាន់នគរបាដលិបុត្រដោយប្រញាប់ប្រញាល់ ។ ព្រះបាទអសោកទ្រង់ជ្រាបថា សុសិមៈត្រឡប់មក ក៏ចាត់ឲ្យអ្នករក្សាព្រះអង្គដាក់អ្នកចាំចាប់ម្នាក់ឲ្យឈរចាំនៅទ្វារទី ១ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី ២ ម្នាក់ទៀតឲ្យឈរចាំនៅទ្វារទី ៣ ជាមួយនឹងរាធគុប្តៈសេនាបតី, ចំណែកទ្វារខាងកើត ព្រះអង្គឯងស្តេចគង់ចាំនៅទីនោះនៅត្រង់ទីមុខទ្វារទិសខាងកើតនោះ ស្តេចបានឲ្យធ្វើរូបដំរីសអំពីឈើមួយឲ្យធ្វើរូបចម្លាក់ស្តេចអសោកជិះលើខ្នងនោះ ទីជុំវិញដំរីនោះបានឲ្យជីកគូធំ ១ ក្នុងទិសទាំងបួន ខាងក្នុងដាក់ពេញទៅដោយរងើកភ្លើង ហើយពីខាងក្រៅគ្របបិទបាំងដោយស្មៅនឹងសម្រាមដិតដិតល្អ រហូតទាល់តែភ្នែកមនុស្សធម្មតាមើលមិនយល់ ។

សុសិមកជុរសេះបរសំដៅទៅទ្វារទី ៣ ក៏រាធគុប្តសេនាបតីក្រាបទូលថា "ឥឡូវនេះ ព្រះបាទអសោកកំពុងទ្រង់គង់នៅទិសខាងកើត សូមព្រះអង្គយាងទៅតាមទ្វារទិសនោះចុះ ប្រសិនបើព្រះអង្គយាងទៅបានដូចសេចក្តីប្រាថ្នា ខ្ញុំព្រះអង្គសូមដើរតាមក្រោមម្លប់ព្រះបារមីផង ប្រសិនបើព្រះអង្គមិនអាចនឹងបង្ក្រាបព្រះបាទអសោកបានទេ ព្រះអង្គនឹងមិនអាចយាងចូលតាមទ្វារនេះបានទេ" ។

លុះព្រះសុសិមរាជកុមារទ្រង់ជ្រាបដូច្នោះ ក៏ស្ដេចយាងទៅកាន់ទ្វារទិសខាងកើត ទតឃើញដំរីនិងរូបចម្លាក់នោះហើយក៏ទំប្រឹងរុកកខ្លួនទ្រមចូលទៅ ដើម្បីនឹងឡើងលើដំរីហើយចាប់រូបចម្លាក់ព្រះបាទអសោកនោះ ក៏ធ្លាក់ចុះក្នុងរណ្ដៅភ្លើងដែលពេញទៅដោយរងើកភ្លើង ទ្រង់ក៏អស់ព្រះជន្មក្នុងទីនោះទៅ ។

កាលបើសុសិមកុមារអស់ព្រះជន្មហើយ យក្សជាបរិវាររបស់ព្រះអគ្គីឈ្មោះកញ្ច្រាយុត ព្រមដោយពួកពលជាច្រើនពាន់ បានចូលបួសក្នុងព្រះពុទ្ធសាសនាហើយបានសម្រេចមគ្គផលព្រះអរហត្តគ្រប់ៗ អង្គទៅ ។

ខាងក្រោយពីព្រះបាទអសោកស្ដេចទ្រង់រាជ្យ ពួកសេនាបតីក៏កើតសេចក្ដីមើលងាយដល់ព្រះអង្គ ទើបទ្រង់រិះរកហេតុឧបាយកលដោយការស្ងាត់ដើម្បីនឹងផ្ចាញ់ផ្ចាលអស់ពួកអ្នកទាំងនោះ ។ ពេលនោះ ទ្រង់ត្រាស់បង្គាប់ឲ្យពួកសេនាបតី កាប់ដើមឈើមានផ្លែនិងឈើមានផ្កាទាំងឡាយ យកមកស្រាស់ព័ទ្ធធ្វើជារបងនៃឈើមានបន្លាជាការផ្ទុយគ្នាយ៉ាងនេះ ។

ពួកសេនាបតី ទូលទទឹងទាស់ព្រះទ័យថា " តាំងតែពីដើមរហូតមកដល់ពេលនេះហើយ យើងដែលធ្លាប់តែគេថា ស្រាស់ព័ទ្ធរបងឈើមានផ្លែដោយឈើមានបន្លា មិនដែលធ្លាប់ អ្នកណាស្រាស់ព័ទ្ធឈើមានបន្លាដោយឈើមានផ្លែផ្កានោះសោះ " ។

ពួកសេនាបតី ទទឹងទាស់មិនគោរពតាមព្រះរាជឱង្ការរហូតដល់ ៣ លើក ។

គ្រានោះឯងព្រះបាទអសោក ទ្រង់ព្រះពិរោធដ៏លើសលុប ក៏ចាប់ព្រះខ័នឡើងប្រហារជីវិតពួកសេនាបតីទាំងប្រាំរយនាក់នោះទៅ ។

លំដាប់តមក ក្នុងរដូវផ្កាឈើ ដល់វេលាព្រឹក្សជាតិបញ្ចេញផ្កា រីកស្គុះស្គាយគ្រប់ដើម ក៏ព្រះបាទអសោកមានបានព្រះស្នំហោមហែម ជាបរិវារស្តេចយាងយាត្រាទៅក្រសាលក្នុងរាជឧទ្យាន នៅក្នុងឧទ្យាននោះ មានដើមឈើមួយដើមឈ្មោះអសោក កំពុងតែផ្កាមានក្លិនក្រអូប ឈ្ងុយឈ្ងប់ ទើបព្រះបាទអសោកទ្រង់សព្វព្រះរាជហឫទ័យនឹងដើមឈើនោះ ព្រោះឈើនោះមានឈ្មោះត្រូវនឹងនាមព្រះអង្គ ។ បានពោលមកហើយថា ព្រះសរីរាយវៈរបស់ព្រះបាទអសោកមានសម្ផស្សរ៉ឹងគ្រោតគ្រាត ហេតុនោះបានជាមិនពេញចិត្តនៃពួកស្រីព្រះស្នំដែលជាអ្នកត្រូវការដោយសម្ផស្ស លុះព្រះរាជាកំពុងផ្ទុំលក់នៅទីព្រះពន្លាក្នុងឧទ្យាននោះ ក៏ពួកស្រីព្រះស្នំដែលគាល់នៅខាងក្នុងនាំគ្នាត្រាច់ដើរលេងសប្បាយតាមអំពើចិត្តទៅក្នុងឧទ្យាន បានឃើញដើមអសោកនោះ ក៏បេះបោចផ្កា កាច់ទាំងមែកឈើនោះផង កាលព្រះរាជាទ្រង់តើនឡើង ចាកព្រះបន្ទំទតឃើញដូច្នោះ ទើបត្រាស់សួរថា "អ្នកណាធ្វើបំផ្លាញដើមឈើនុះអស់ ? រាជបរិពារក្រាបទូលថា " សូមទ្រង់ព្រះមេត្តា

ប្រោសពួកស្រីព្រះស្នំ ” ។ កាលព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ទើបទ្រង់ព្រះពិរោធខ្លាំង ត្រាស់ឲ្យចាប់ពួកស្រីព្រះស្នំរបស់ព្រះអង្គទាំងប្រាំរយ យកទៅដម្រៀបជុំវិញដើមឈើនោះហើយដុតភ្លើងទាំងរស់ស្លាប់ទាំងអស់គ្នាទៅ ។ ពួកអ្នកនគរទាំងអស់បានឃើញព្រះអង្គមានព្រះរាជហឫទ័យខ្លាំងដូច្នោះ ទើបនាំគ្នាហៅព្រះអង្គថា “ចណ្ឌាសោក (អសោកកាច)” ។

ខណៈនោះ រាជគ្រូជាសេនាបតីទី ១ ទើបទូលតឿនព្រះរាជាថា “សូមព្រះរាជតេជះមិនជាការសមគួរដល់ព្រះអង្គ ជាស្ដេចដែលទ្រង់ធ្វើកម្មដូច្នោះដោយផ្ទាល់នឹងព្រះហស្តព្រះអង្គឯង ព្រះអង្គគួរតាំងបុរសឲ្យមាននាទីជាអ្នកពិឃាតមនុស្ស ដែលព្រះអង្គបានដាក់ព្រះរាជអាជ្ញាហើយ ត្រូវពេជ្ឈឃាតនោះធ្វើតាមការពិភាក្សារបស់ព្រះអង្គ ។

ព្រះបាទអសោកក៏យល់ព្រមតាមពាក្យសូមនោះ ទើបមានព្រះឱង្ការបង្គាប់ឲ្យរកបុរសម្នាក់មានចិត្តក្លាហាន ដែលល្មមតាំងឲ្យធ្វើជាពេជ្ឈឃាតបាន ។

គ្រានោះ មានជាងដម្បាញម្នាក់ តាំងផ្ទះនៅក្នុងបច្ចន្តគ្រាមជិតជើងភ្នំ ជាងដម្បាញនោះមានកូនប្រុសមួយឈ្មោះ គិរិកៈ[១] មនុស្សនេះកាចជាទីបំផុត ក៏តែងធ្វើទុក្ខបុកម្នេញដល់ពោលក្ខាយឪពុកក៏ជាទិច្ច

១ គិរិកៈ ជាឈ្មោះរបស់មនុស្សអ្នកនៅភ្នំ ។

ក៏គាត់លប់នៅដៃក៏ផោតជង់ ក៏លាបថ្នាំពុលនៅលើស្មៅនិងស្លឹកឈើទាំង-ឡាយ ពួកសត្វដើរទៅប៉ះពាល់ថ្នាំនោះពុលស្លាប់វិនាសជាអនេក ។ ពួកអ្នកស្រុកទាំងអស់គេប្រកាសប្រាប់គ្នាថា បុរសនោះកាចណាស់ ហើយក្នុងស្រុកទាំងមូលគេតែងហៅគិរិកៈនោះថា "ចណ្ឌគិរិកៈ (គិរិកកាច[1])" ។

រាជបុរសបានទៅជួបនឹង គិរិកៈ ហើយនិយាយថា "អ្នកឯងហ៊ានធ្វើជាពេជ្ឈឃាតរបស់ស្តេចអសោកឬទេ ?" គិរិកៈឆ្លើយតបថា "ប្រសិនបើឲ្យខ្ញុំធ្វើទោសផ្ចាញ់ផ្ចាលមនុស្សខូចកាចក្នុងទ្វីបមួយទាំងមូល ក៏ខ្ញុំធ្វើបានដែរ មិនថាការសំខាន់អ្វីនឹងធ្វើជាពេជ្ឈឃាតទទួលការសម្រាប់ស្តេចអសោកមួយប៉ុណ្ណោះ" ។ រាជបុរសបានស្តាប់ពាក្យនោះហើយ ទើបត្រឡប់ទៅក្រាបទូលព្រះមហាក្សត្រិយ៍ ព្រះអង្គទ្រង់ឲ្យទៅនាំគិរិកៈនោះមក ។ រាជបុរសក៏ត្រឡប់ទៅដល់គិរិកៈវិញ និយាយប្រាប់ថា "មក គិរិកៈ ព្រះរាជាត្រាស់ឲ្យហៅអ្នកទៅ" ។

ចណ្ឌគិរិកៈ ដឹងដូច្នោះហើយ ក៏ម្នីម្នាទៅសូមអនុញ្ញាតអំពីមាតាបិតា តែមាតាបិតាមិនព្រមបើកឲ្យ, បានព្យាយាមហាមប្រាមឃាត់មិនឲ្យធ្វើក្នុងដំណែងនេះ ក៏ចណ្ឌគិរិកៈសម្លាប់មាតាបិតាទាំងពីរនោះទៅ ទើបស្ទុះចុះពីលើផ្ទះមក ខណៈនោះរាជបុរសសួរថា "ហេតុដូចម្តេច បាន

---

១ មហា.វង្ស: មិនមាននិយាយដល់រឿងរ៉ាវ គិរិកៈ នេះទេ ។

ជាយឺតយូរម្ល៉េះ?" បណ្ឌិតិកៈតបថា "ម៉ែឪខ្ញុំគាត់មិនព្រមអនុញ្ញាតឲ្យខ្ញុំមកសោះ តែខ្ញុំសម្លាប់គាត់ទាំងពីរនាក់នោះទៅហើយ ហេតុនេះបានជាខ្ញុំយឺតយូរបន្តិច" ។

បណ្ឌិតិកៈ និយាយរឿងរ៉ាវគ្រប់ប្រការឲ្យស្ដាប់ហើយ ទើបចូលទៅគាល់ស្ដេច លុះដល់ហើយក្រាបថ្វាយបង្គំទូលថា "សូមព្រះអង្គសាងគុកមួយទុកជាមន្ទីរយុត្តិធម៌ជារបៀបល្អយ៉ាងសំខាន់ឲ្យមានរូបភាពខាងក្រៅគួរជាទីសប្បាយរីករាយនៃចិត្តអ្នកផងទាំងពួង កាលបើសាងមន្ទីរនោះរួចហើយ សូមឲ្យឈ្មោះថា "គុកជាទីសុខសម្រាន្ត(១)" ។

គ្រានោះ បណ្ឌិតិក ទូលសូមពរព្រះរាជាថា "សូមទេជះព្រះអង្គប្រទានពរមួយដល់ខ្ញុំព្រះអង្គ គឺបើអ្នកណាមួយក៏ដោយតែចូលមកក្នុងមន្ទីរនេះ សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គថា មិនត្រូវឲ្យអ្នកនោះចេញទៅវិញជាដាច់ខាត" ។ ព្រះបាទអសោកក៏ទ្រង់ព្រោសប្រទានពរឲ្យតាមសេចក្ដីសូមដូច្នោះ ។

ខាងក្រោយពីនោះមក បណ្ឌិតិក បានចូលទៅក្នុងវត្តកុក្កុដារាម ក្នុងវត្តនោះ មានភិក្ខុមួយរូបកំពុងស្វាធ្យាយពាលបណ្ឌិតសូត្រថា:

"ពួកសត្វដែលចូលចិត្តនឹងទឹកក្ដៅនៅក្នុងខ្ទះ ត្រូវគេបុកកនោះគំទេចដោយអង្រែ ។ ពួកសត្វដែលចូលចិត្តគេបុកក្នុងត្បាល់ ត្រូវគេបំផ្លិចក្នុង

(1) prison-agréable ។

ខ្លះ ។ ពួកសត្វដែលនៅក្នុងនរកលេបដុំដែកដំបូល ហើយនាយនិរយ-
បាលបង្ហូរទឹកទង់ដែងក្ដៅទៅក្នុងមាត់(១)" ។ កាលបើបានឮសេចក្ដី
នៃព្រះសូត្រនោះហើយបណ្ឌិតរឹកៈទើបត្រិះរិះថា "តុកអញត្រូវឲ្យមានវិធី
រូបបនេះចុះ" ។

---

១ ពាលបណ្ឌិតសូត្រសំស្ក្រឹត សេចក្ដីប្រហែលគ្នានឹងទេវទូតសូត្របាលី ក្នុងគម្ពីរមជ្ឈិមនិ-
កាយ ។ ទេវទូតសូត្របាលីថា. . . . ពួកនិរយបាលសួរថា "ឯងត្រូវការអ្វី" សត្វនរកតប
ថា "ព្រះគុណអើយ ខ្ញុំឃ្លានណាស់ ។ ពួកនិរយបាលយកដែកស្រួចដ៏ក្ដៅកំពុងឆេះប្រាល
ផ្ដៅភ្លឺរន្ទាលចកទល់មាត់សត្វនរកនោះហើយ ញាត់ដុំទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅ
នៅក្នុងមាត់. . . ។ ពួកនិរយបាលនឹងសួរទៀត សត្វនរកតបថា "ព្រះគុណអើយ ស្រេក
ណាស់" ។ ពួកនិរយបាលយកដែកស្រួចដ៏ក្ដៅកំពុងឆេះប្រាលផ្ដៅភ្លឺរន្ទាលចកទល់មាត់សត្វ
នរកនោះ ហើយបង្ហូរទឹកទង់ដែងដែលភ្លើងកំពុងឆេះសន្ធោសន្ធៅទៅក្នុងមាត់ ។

(នៅមានត)

ពង្សាវតារក្រុងរ៉ូម

(តមកនិងចប់)

១- ទទួលយកសាសនាគ្រិស្តមកធ្វើទុកជាសាសនារបស់រ៉ូម ។

២- បានតាំងទីក្រុងឡើងជាថ្មី តាមព្រះនាមរបស់ទ្រង់ ហៅថា កុងស្តង់ទីណូប៉្លេ (Corstantinohle) ។

៣- ទ្រង់តាក់តែងរបបត្រួតត្រាស្រុកតាមរបៀបក្សត្រអាជ្ញាសិទ្ធិ-ករ ។

សាសនាគ្រិស្តបានផ្សាយចូលមកក្នុងក្រុងរ៉ូម តាំងអំពីសម័យនេ-រ៉ុងមុននោះទៅទៀត មុននឹងចូលមកដល់ក្រុងរ៉ូមនេះ សាសនានោះបានរាយភាយចេញទៅច្រើនរយៗ នៅប្រទេសក្រិកទាំងមូល ស្ទើរតែមានទាន់សាសនានោះយ៉ាងណាមុនហើយ ការផ្សាយសាសនាគ្រិស្តក្នុងស្រុកក្រិកទើបសម្រេចបានដោយស្រួល ព្រោះគោលធម៌សំខាន់ៗនឹងគំនិតគតិគួររបស់ក្រិក ប្រហែលនឹងសាសនាគ្រិស្តនេះដែរ ។ តែការផ្សាយសាសនានេះចូលមកក្រុងរ៉ូម បែរជាលំបាកយ៉ាងខ្លាំង ព្រោះក្រុងរ៉ូមសម័យដែលមានព្រះរាជាធិរាជនេះ ពួកព្រះរាជាធិរាជប្រកាន់ទ្រង់ជាខ្ពង់ខ្ពស់បំផុត តែឯសាសនាគ្រិស្តប្រដៅថាមានព្រះជាម្ចាស់ខ្ពង់ខ្ពស់ជាងព្រះរាជាធិរាជទៅទៀត ទើបពួកព្រះរាជាធិរាជក្រុងរ៉ូមបាន

ធ្វើទុក្ខទោសជាទម្ងន់ ដល់ពួកអ្នកផ្សាយសាសនានឹងពួកអ្នកកាន់សាសនា
នេះដូចជាចាប់ដុតទាំងរស់, វាយបោះដែកគោលឆ្កាង, ចាប់បញ្ចូលទៅ
ក្នុងទ្រុងឲ្យធ្វើជាអាហារសត្វព្រៃ, ឲ្យគោកាបរ័ធទាល់តែធ្លាយពោះវៀន,
ចាប់ឲ្យអង្គុយលើកៅអីដែកដែលដុតក្ដៅឆេះក្រហមព្រាល ៗ ទោស
ទាំងនេះត្រូវធ្វើក្នុងទីប្រជុំជន ពួកអ្នកដែលឈរមើលនាំគ្នាសប្បាយរីក
រាយដូចជាមើលល្ខោនសត្វ ៗ យើងបានដឹងខ្លះមកហើយថា ពួកគ្រិស្ត-
សាសនិកជនមានមានះខ្មីឃ្មាតក្នុងការផ្សាយសាសនាជាចំហុក បើកាន់
តែត្រូវគេធ្វើបាបខ្លាំងឡើង ក៏កាន់តែខំផ្សាយខ្លាំងឡើងដែរ ដរាបមក
ដល់សម័យផែនដីព្រះបាទកុងស្តង់តាំងនេះ ទើបសាសនានេះក្លាយទៅជា
សាសនាប្រចាំជាតិពេញម៉ាំង ដោយមហាក្សត្រអង្គនេះទ្រង់ឧបត្ថម្ភ ៗ

ការដែលព្រះបាទកុងស្តង់តាំង ទ្រង់ចាត់តាំងទីក្រុងនៃកជរាណា-
បក្រោមឡើងថ្មីនេះ ដោយៈហេតុផលច្រើនប្រការ ព្រោះប្រការទី ១
សត្រូវសំខាន់របស់ក្រុងរោម គឺពួកកុព្យនឹងពួកប៉ែរ្ស ទើបត្រូវតែបន្ទយ
ទីក្រុងឲ្យថយចូលមកជិតទន្លេដានូប (Danube) នឹងទន្លេអ៊ុយប្រាត (Eu-
phrate) ដើម្បីទទួលមុខសឹកទាន់ការ ៗ ប្រការទី ២ ព្រោះសាសនាចាស់
របស់ក្រុងរោមមានទេវរូបជាចំនួនច្រើនលើសលប់គណនា ដូចយើងបាន
ពោលពីខាងដើមមកហើយថា ការដើរកូលៈទៅក្រុងរោមនោះ នឹងបាន
ឃើញទេវរូបផ្សេងៗ ច្រើនជាងមនុស្សទៅទៀត ៗ កាលព្រះអង្គទទួល

លើកសាសនាគ្រិស្ទចូលមកជាសាសនាប្រចាំក្រុងរោមហើយ គេនៅតែទៀតសាងគុំឲ្យមានការរើរោះដាយប្រមាទទេវរូបចាស់ៗ អស់នោះបន្ទួសពេក ទើបទ្រង់ផ្លាស់ទីក្រុងជាថ្មី ៗ មួយវិញទៀត ក្រុងកុងស្តង់ទីនោប៉ូ ជាទីសមគួរជាងទីក្រុងរោមដោយប្រការទាំងពួង ពោលគឺជាស្រុកក្ដាប់គន្លឹះរបស់ទ្វីបអាស៊ី ហើយជាទីការពារសត្រូវបានជាចំណាប់ផងហើយ ជាកំពង់ជំនួញហ៊ាងល្អផង ៗ ព្រះបាទកុងស្តង់ទីនោប៉ូ ទ្រង់កសាងស្រុកនេះឡើងតាមបែបរោមទាំងអស់ ហើយទ្រង់នាំប្រជាជនអភិបាលយ៉ាងដែលមានត្រកូលខ្ពង់ខ្ពស់ទៅនៅ និងនាំប្រជាជនជិតខាងក្រុងរោមឲ្យទៅនៅក្រុងថ្មីនោះ ៗ ទ្រង់តាំងព្រះរាជបណ្ណាល័យដែលមានពាសពេញទៅដោយសៀវភៅ ដែលរឹបយកមកពីពួកក្រិក ហើយទ្រង់បង្គាប់ឲ្យប្រទេសអេស៊ីបបញ្ជូនស្បៀងទៅចិញ្ចឹមប្រជាជននៅក្រុងថ្មីនោះ ព្រោះពួកក្រស្តមិនទាន់បានត្រៀមខ្លួនធ្វើរបររកស៊ីជាមាំមួន ៗ

យើងបានពោលពីខាងដើមរួចមកហើយថា ព្រះបាទឌីយ៉ូក្លេទៀន ទ្រង់ព្យាយាមនឹងលើកដំកើងអំណាចមហាក្សត្រឲ្យខ្ពស់ត្រដែតឡើង តែធ្វើមិនសម្រេច ព្រោះប្រជាជនថ្នឹកស្ទួតស្រាប់នឹងរបៀបប្រជាធិបតេយ្យ
៦ និងសភាសេណាត់ និងសភាតំណាងរាស្ត្រ ជាវេលាយូរមកហើយ ៗ ការដំកើងអំណាចមហាក្សត្រឲ្យខ្ពស់បំផុតនេះ មិនមែនជាការធ្វើបានដោយងាយស្រួលទេ គ្រាតែមកដល់សម័យព្រះបាទកុងស្តង់ទីនោប៉ូ

ទើបទ្រង់ធ្វើការនេះបានសម្រេច គឺទ្រង់លុបសភាសេណាត់ និងសភា-រាស្ត្រចេញ ហើយទ្រង់រួបរួមអំណាចផែនដីតាំងមូលមកទុកក្នុងព្រះហស្ត បានដោយងាយ ៗ តាំងអំពីនោះមកក្រុងរោមទើបមានរបស់សំខាន់ ៣ យ៉ាង គឺព្រះរាជាធិរាជ, វជ្ជបាល, និងបណ្តារាស្ត្រ ៗ ព្រះបាទគុង-ស្តង់ទីនោប៍ គួររាប់ជាមហាក្សត្រអង្គ ១ របស់រោម ទ្រង់មានសភាពសមជាស្តេចពិត ៗ ទ្រង់ជាទីគោរពនៃប្រជាជនទូទៅ ទុកដូចជាព្រះ ១ ព្រះអង្គ ទ្រង់ពាក់មកុដមាស ហើយប្រជាជនយកកំទេចមាសរោយព្រះបាទវេលាក្រាបបង្គំទូលការអ្វីៗ គោងលុតជង្គង់ អស់ទាំងគ្រឿងក-ដូបភោគក៏តោងតែគោរពកប់អាន ទុកជារបស់ស័ក្តិសិទ្ធិដែរ ឯពួកអ្នករាជការក៏ទ្រង់តាំងឲ្យមានយសសក្តិតាមសមគួរ ហើយត្រូវមានគ្រឿងសំគាល់សម្រាប់ខ្លួនផង ៗ មានអ្នកប្រាជ្ញពង្សាវតាររ៉ូម៉ាំងម្នាក់ពោលទុកថា ពួកអ្នករាជការដែលពាក់គ្រឿងសំគាល់នេះមានចំនួនច្រើនជាងរុយក្នុងរដូវក្តៅទៅទៀត ៗ

តែព្រះបាទគុងស្តង់ទីនោប៍ទ្រង់ជ្រាបច្បាស់ នៅវេលាក្រោយថា បើអស់បុណ្យទ្រង់ទៅហើយ គង់តែមិនមានអ្នកឯណាមួយ អាចត្រួត្រាមហាអាណាចក្ររោមដូចជាព្រះអង្គ ដល់វេលាជិតក្ស័យព្រះជន្ម ទើបទ្រង់ចែកមហាអាណាចក្រនេះជា ៣ ភាគ ប្រគល់ឲ្យព្រះរាជបុត្រទាំង ៣ អង្គគ្រប់គ្រង ៗ

ស្រុកទេសក្តី កិច្ចការផ្ទាល់ខ្លួនក្តី បើបំបែកមតិគេឲ្យបែកគ្នាទៅហើយ
វែងតែឲ្យទោសច្រើនជាងគុណ បើជាត្រកូលធំៗ ដូចជាត្រកូលមហា-
សេដ្ឋីមានកូនច្រើន ហើយបែងមតិកបែកបន្តិចម្នាក់ៗទៅគ្រប់គ្នា មិនឲ្យ
មានអ្នកទទួលដំណែងជានាយកក្នុងត្រកូលហើយ ត្រកូលនោះទៀងតែទីង
អប្បទុនសាបសូន្យទៅជាមិនខាន ៗ ឯស្រុកទេសក៏មានទំនងដូចគ្នាដែរ
តាមពង្សាវតារស្រុកមានសំដែងឲ្យឃើញច្បាស់ថា ការបែងអាណាចក្រ
ឲ្យពួកកូនចៅក្សត្រគ្រងស្រុក មានអំណាចដាច់ស្រេចតែរៀងខ្លួនហើយ
មានតែនាំមកនូវសេចក្តីវិនាសសាបសូន្យជាទិច្ចមិនសូវដែលខាន ៗ
ហេតុនេះហើយ បានជាកាលព្រះបាទកុងស្តង់ទីនចូលក្ស័យព្រះជន្មទៅ
ហើយ ក៏កើតចម្បាំងក្នុងស្រុកឡើងយ៉ាងសំបើម អាណាចក្រក្រុងរោម
ក៏ជយឡាយចុះទៅ ឯពួកមនុស្សព្រៃ ក៏លុកលុយចូលតាំងលំនៅៗ
ក្នុងអាណាចក្រ ខាងផ្លូវសាសនាសោតទៀត ក៏កើតចលាចលវើក
ពោលគឺព្រះបាទស៊ុលលីយ៉ាន (Julien) ជាព្រះរាជនត្តារបស់ព្រះបាទកុង-
ស្តង់តាំងបានព្យាយាមបង្ខំឲ្យក្រុងរោមបែរមកកាន់លទ្ធិសាសនាចាស់វិញ
ហើយសេចក្តីព្យាយាមនេះក៏ធ្វើបានសម្រេច ព្រះបាទស៊ុលលីយ៉ានក៏ទិ-
វង្គតទៅ គ្មានអ្នកទទួលស៊ីរាជសម្បត្តិ ទើបពួកទាហានជ្រើសរើសក្សត្រ
សោយរាជ្យម្តងទៀត មានក្សត្រដែលតាំងឡើងតាមទំនងនេះតៗមកទៀត
ដល់តាមអន្តរា ចុងក្រោយបង្អស់ទ្រង់ព្រះនាម ថេអូដូស៍ (Théodose) ។

មហាក្សត្រអង្គនេះ ទ្រង់មានព្រះទ័យជ្រះថ្លានឹងសាសនាគ្រីស្ទៀនជាខ្លាំង ។ កាលគ្រាមុននេះយើងបានពោលមកហើយថា ពួកដែលនាំសាសនាគ្រីស្ទៀនមកផ្សាយក្នុងរ៉ូមនេះត្រូវទុក្ខទោសជាមុន តែមកដល់សម័យព្រះបាទថេអូដោស៍នេះ បែរជាចាប់ពួកអ្នកប្រឆាំងសាសនាគ្រីស្ទៀន យកទៅប្រហារជីវិតមុខគ្នាឲ្យស្លាប់ស្ងៀម ដូចជាទ្រង់ឲ្យសម្លាប់មនុស្សជាចំនួនដល់ ៧០០០ នាក់ ។ ការធ្វើទុក្ខទោសតាមទំនងនេះ ទុកជាពួកគ្រិស្តសាសនិកជនក៏មានចិត្តទោមនស្សជាច្រើនដែរ ដូចជាថ្ងៃ ១ ព្រះបាទថេអូដោស៍ ស្ដេចយាងចូលក្នុងវិហារក្រុងមីឡង់ ព្រះរាជាគណៈ (évêque) នៅវិហារនោះហាមឃាត់មិនឲ្យស្ដេចយាងចូលទៅ ហើយមានថេរដីកាឲ្យព្រះបាទថេអូដោស៍សុំខមាទោសចំពោះមុខប្រជាជន ។ ទ្រង់ក៏ព្រមប្រតិបត្តិតាម គ្រានេះជាគ្រាដំបូងក្នុងប្រវត្តិនៃសាសនាគ្រិស្តដែលមហាក្សត្រទ្រង់ស្ដាប់បង្គាប់គណសង្ឃក្នុងព្រះសាសនា ។

តាំងអំពីនោះ ពួកលោកសង្ឃបារាំងក៏ចាប់ផ្ដើមមានអំណាចក្នុងស្រុកទេស ហើយព្រះសង្ឃរាជនៅក្រុងរ៉ូម ជាអ្នកមានអំណាចខ្ពង់ខ្ពស់បំផុត ក្នុងសម័យកណ្ដាលតាមអាយុកាលនៃសាកលប្រវត្តិសាស្ត្រនេះ ។

តាមដោយពិត ព្រះបាទថេអូដោស៍ទ្រង់ប្រមូលក្រុងរ៉ូមមកទុកក្នុងព្រះហស្ត ទ្រង់ធ្វើក្រុងរ៉ូមឲ្យមានកំឡាំងរឹងប៉ឹងឡើងវិញបានទៀត លុះដល់ទ្រង់ទិវង្គតទៅ ទ្រង់បានបែងរាជអាណាចក្រជា ២ ភាគ គឺទិស

ខាងកើត ១ ភាគ ទិសខាងលិច ១ ភាគ ទ្រង់ប្រគល់ឲ្យព្រះរាជឱរស ២ អង្គ ទ្រង់គ្រប់គ្រង ១ ភាគមួយអង្គ ៗ ព្រះបាទថេអូដោស៊ីទិវង្គតក្នុង ពុទ្ធសករាជ ៩៣៨ (គ.ស.៣៩៥) ហើយការដែលទ្រង់បែងអាណាចក្រ ជា២ភាគ ក្នុងគ្រានេះជាបច្ច័យនាំឲ្យក្រុងរោមឈានមុខទៅកាន់សេចក្តី សាបសូន្យ លុះតមកទៀតមិនទាន់ដល់ ១០០ ឆ្នាំ រាជអាណាចក្រនៅ ចំណែកទិសខាងកើតក៏គ្មានឈ្មោះ ឯរាជអាណាចក្រនៅទិសខាងលិច ក៏តាំងនៅយូរបានតទៅទៀតបន្តិច តែមិនមានរឿងសំខាន់ ១ ដែលគួរ និយាយកើតឡើងទេ ហើយនៅទីបំផុតរាជអាណាចក្រនេះ ក៏ធ្លាក់ទៅ ក្រោមអំណាចរបស់ទួរគី កាលពីពុទ្ធសករាជ ១៩៩៦ (គ.ស.១៤៥៣)។

ចប់ពង្សាវតារពេទសម័យដើមដោយសង្ខេបតែប៉ុណ្ណេះ ។

ភូមិសាស្ត្រសង្ខេបនៃទ្វីបអូស្ត្រាលី

ទីតាំង — ទ្វីបអូស្ត្រាលីតាំងនៅទិសខាងត្បូងរវាង ១១⁰ និង ១៩⁰ និងតាំងនៅទិសខាងកើតរវាង ១១៣⁰ និង ១៥៣⁰ ហើយឃើញថា ទ្វីបនេះតាំងនៅក្នុងតំបន់ក្តៅពាក់កណ្តាល តំបន់ត្រជាក់ពាក់កណ្តាល ។

អាណាខេត្ត -- អាណាខេត្តទិសខាងជើងទល់នឹងសមុទ្រអា-ហ្វូរ៉ានឹងសមុទ្រទីម័រ ទិសខាងកើតទល់នឹងសមុទ្រគូរ៉ាល់នឹងមហា-សមុទ្រប៉ាស៊ីហ្វិក, ទិសខាងលិចនិងខាងលិចឆៀងខាងត្បូងទល់មហា-សមុទ្រឥណ្ឌា ទិសខាងត្បូងទល់នឹងសមុទ្រខាងត្បូង (Mer du sud) ។

ខ្នាត — បណ្តោយទ្វីបគិតពីទិសខាងកើតទៅដល់ទិសខាងលិច ប្រមាណ ៦៤១៦ គីឡូម៉ែត្រ ឯទទឹងប្រមាណ ៥១៨០ គីឡូម៉ែត្រ ទំហំទាំងមូលប្រមាណ ៧.៦៣៦,៤៦៨ គីឡូម៉ែត្រក្រឡា ហើយគទំហំកោះតាស្មានីមករួមផង ជាទំហំដីទាំងអស់ប្រមាណ ៧.៧០៤.៤៦៨ គីឡូម៉ែត្រក្រឡា ទ្វីបនេះទុកជាទ្វីបតូចបំផុត ។

មាត់ច្រាំងសមុទ្រ — វែង ១៩.៥៣៦ គីឡូម៉ែត្រលក្ខណៈច្រាំងសមុទ្រមានទំនងប្រហែលនឹងទ្វីបអាហ្វ្រិក មិនសូវមានឈូងលូកចូលទៅក្នុងទ្វីបច្រើនដូចជាទ្វីបឯទៀតទេ ។ តែអូស្ត្រាលីមានឈូងធំៗច្រើនជាទ្វីបអាហ្វ្រិក ឯឈូងសំខាន់ៗ គឺឈូងក្រង់បៃអូស្ត្រាលីយែន ឈូងកាប៉េនតារី, ឈូងកាមព្រិតស៍, ឈូងប៉រត៍ភីលិប ។ ឯជ្រោយដែលសំខាន់ៗ

គឺ ជ្រោយយ៉ក (នៅទិសខាងជើង), ជ្រោយបណារត៍ដូអេស្ត (នៅទិស
ខាងលិច), ជ្រោយព្រំ-វិលសុន (ទិសខាងត្បូង) ។

ផ្ទៃផែនដី — ទីដីកបទំនាបនិងដីកបខ្ពស់ក្នុងទ្វីបអូស្រ្តាលីមានខ្នាត
ប្រហែលៗគ្នា តាមមាត់ច្រាំងសមុទ្រជុំវិញទ្វីបជាដីកេះជាទីទំនាបចូលទៅ
ពីមាត់ច្រាំងចូលទៅក្នុងទ្វីបបន្តិចបន្តួច ផ្ទៃផែនដី គឺចាប់ផ្តើមខ្ពស់ឡើងៗ
ទៅជាទីខ្ពលខ្ពស់ (៣០០ម៉ែត្រ) ឯទីកបទំនាបខាងមហាសមុទ្រប៉ាស៊ី-
ហ្វិក ជាទីវៀវតូចចង្អៀតហើយចោតឡើងទៅទល់នឹងជួរភ្នំយ៉ាងធំវែង
ដែលតាំងនៅតាមមាត់ច្រាំងសមុទ្រហូតទៅតាំងពីឃ្វីនឡង់ហូតដល់
វិកតូរីយ៉ា ផុតពីជួរភ្នំអស់នោះទៅ ដីខ្ពស់ក៏សន្សឹមៗរាបទាបចុះទៅ
ត្រាតែកើតជាទីកបយ៉ាងធំទូលាយបំផុតក្នុងទ្វីប ។ ផ្ទៃដីដែលកបនេះក៏
ខ្ពស់ចោតឡើងទៀត ពាល់តែទៅជាទីកបខ្ពស់យ៉ាងធំសំបើម ផ្ទៃដីចំណែក
នេះគ្រាមានទឹកក្រៀងនឹងជ្រោះជ្រលងជងអូរជាទីបំផុត មានតែអាកាស
ស្ងួតក្រៀមខ្លះទៅ តំបន់ខ្លះជាសមុទ្រខ្សាច់ ។

ភ្នំ — នៅទិសខាងកើតមានភ្នំជាច្រើនដូចជាភ្នំអែលត៍, ភ្នំដេនហាម,
ភ្នំឡាំងសៃ, ភ្នំលីវែរប៉ូល, ភ្នំប៊ូម៉ៃ, ភ្នំប៊ូវេន, ភ្នំនូវែល អង់គ្លីតែរ៉ា
ដើម រួមហៅថា កាឌីយៀរអូស្រ្តាលីយ៉ែន ។

នៅទិសខាងត្បូង មានភ្នំស្តូនវ៉ែ, ភ្នំហ្វ្លីនដែរ, ភ្នំការ៉ែល... ។
ទិសខាងលិច មានភ្នំដាលីង, ទីនវិកតូរីយ៉ាជាដើម ។

នៅកណ្តាលទ្វីប មានភ្នំសម, ទីនម៉ុកដូនណែលជាដើម ។

កំពូលភ្នំដែលខ្ពស់បំផុតកំពស់ ២២០៥ម៉ែត្រ នៅជួរភ្នំករខ៊ៃយៀរ-អូស្ត្រាលីយ៉ែន ។

សមុទ្រខ្សាច់-នៅលើទឹដីកណ្តាលខ្ពស់ភាគខាងលិចមានសមុទ្រខ្សាច់ធំ ២ អន្លើ គឺក្រន់ដេសែរត៍ឌីសាប់ ១ ក្រន់ដេសែរត៍វិកតូរីយ៉ា ១ ហើយមានសមុទ្រខ្សាច់ខ្នាតតូច ១ ទៀតនៅទិសខាងជើង ។

ទន្លេសាប — ទន្លេសាបក្នុងទ្វីបនេះ ភាគច្រើនជាទន្លេសាបទឹកប្រៃ ហើយច្រើនតែជាទន្លេសាបរាក់ៗ មានទឹកតែក្នុងរដូវភ្លៀង ដល់រដូវប្រាំងហែងហួតអស់ទៅ ទន្លេសាបមានច្រើននៅអូស្ត្រាលីខាងលិច និងអូស្ត្រាលីខាងត្បូង ដែលសំខាន់គឺ ការលេក្សង់ដ្រ៍, អ៊ែយ៍, តូរ៉ង់, កាកណែរ, អាម៉ាដឺស៍, អូស្តាំងជាដើម ។

ទន្លេ — ទន្លេស្ទឹងដងអូរក្នុងទ្វីបអូស្ត្រាលីមានចំនួនតិចពេក ហើយច្រើនហែងហួតក្នុងរដូវប្រាំងផង មានផ្លូវទឹកជាច្រើនដែលហូរធ្លាក់ទៅក្នុងត្រពាំងបឹងនិងទន្លេសាប មិនសូវមានផ្លូវទឹកហូរធ្លាក់ទៅក្នុងសមុទ្រទេ ។ ការខ្វះខាតទឹកនេះមកពីហេតុ ២ ប្រការ ប្រការ ១ ភ្នំនៅទ្វីបនេះមិនសូវខ្ពស់ល្មមឲ្យមានហិមៈ ចាប់នៅកំពូលភ្នំបានគ្រាស់ៗ ប្រការ ១ ទៀតមិនសូវមានភ្លៀងធ្លាក់សព្វគ្រប់អន្លើ មានធ្លាក់ច្រើនតែតាមភ្នំដែល

នៅជិតៗ នឹងមាត់សមុទ្រខាងជើងដែលមានអាកាសក្តៅ នឹងតាមដងក្តំ កាមមាត់សមុទ្រខាងចំណែកមហាសមុទ្រប៉ាស៊ីហ្វិក ។

គ្រីនឡង់ដ៍ — មានទន្ទ្រហ្គ័នដែរ, តុមស៊ុង, ខ័យ៉ាម៉ងទិណា ។

នូវែល-គ្លូ-មានផ្ទុវរ៉ែបរិបូណ៌ជាងរដ្ឋឯទៀតៗ ស៊ឹងសំខាន់ គឺ ដារលិង, (ជាស្ទឹងដែលមានខ្សែវែងបំផុតក្នុងអូស្ត្រាលី ស្ទឹងឡាចឡង់, មៀររុមប៊ីតស៊ី ។

អូស្ត្រាលីខាងត្បូង មានទន្លេមៀរ៉េយហូរចេញទៅឈូងជីឡាវង់-កុងត្រ៍ ទន្លេនេះមិនសូវជ្រៅទេ ព្រោះមានល្បប់ដុះឡើងនៅមាត់ពាមសមុទ្រផង កប៉ាល់ចូលទៅពុំរួច ។

ដែនអូស្ត្រាលីខាងជើង - មានផ្លូវទឹកជាច្រើនដែរ តែជាស្ទឹងតូចៗ ដែលសំខាន់គឺស្ទឹងវិកតូរីយ៉ា នឹងកេប៉ែរ ។

ដែនអូស្ត្រាលីខាងលិច មានស្ទឹងមៀរគីសុង, អាសប៊ៀរតុងជាដើម ។

ខ្យល់អាកាស — នៅតំបន់ក្តៅទិសខាងជើងៗ មានអាកាសក្តៅប្រហែលៗ នឹងភ្លៀងស៊ុនៈនះដែរ ដល់មកដល់កណ្តាលទ្វីបកំដៅក៏អន់ពុះទៅដល់អាកាសត្រជាក់ម៉ិឌនៅតំបន់ទិសខាងត្បូង ។ នៅតំបន់ទឹកបក្តស់ មានអាកាសក្តៅច្រើន ព្រោះជាទីវាលស្រឡះ ទទួលកំដៅថ្ងៃពេញទី

ចណ្ហកម៉ៅនៅភាគខាងជើង ក្រៀនរាល់អាកាសរហូត១ឆ្នាំបាន ៨៥ ដឺក្រេ ហើយថយចុះទៅដល់ជាប់នៅសល់ត្រឹម ៥៥ ដឺក្រេនៅភាគខាងត្បូង ។

ក្នុងរដូវក្ដៅ មានខ្យល់សមុទ្របក់មកពីទិសខាងជើងនិងទិសខាងលិចឆៀងខាងជើង បាននាំភ្លៀងមកបង្អុរនៅភាគផែនដីខាងជើងទ្វីបជាចំនួនច្រើន ហើយមានខ្យល់បក់យកទឹកភ្លៀងពីទិសខាងកើតឆៀងខាងត្បូងមក បង្អុរចុះនៅភាគខាងកើត តែភ្លៀងធ្លាក់នៅក្នុងជាច្រើនជិតអស់ទៅមិនសូវមានធ្លាក់ភ្លៀងទៅដល់កណ្ដាលទ្វីប ទុកជាមានខ្យល់បក់ភ្លៀងចូលក្នុងតាមបរទឹងដីកបត្ថុសំពេលចូលទៅដល់កណ្ដាលទ្វីបបាន ប៉ុន្តែអាកាសដែលនៅនាកណ្ដាលទ្វីបនោះក្ដៅខ្លាំងពេកធ្វើឲ្យចំហាយទឹកដែលខ្យល់បក់ចូលមកនោះហែងហួតស្ងួតទៅបាន ។ ដល់រដូវរងានៅភាគខាងលិចនិងខាងត្បូង តែងបានទទួលទឹកភ្លៀងមកពីទិសខាងលិច ទើបមានភ្លៀងធ្លាក់ក្នុងរដូវនេះ ។ ឯភាគខាងជើងនិងភាគខាងកើតត្រឡប់ជាមិនសូវមានភ្លៀងធ្លាក់ទេ ។

ភ្លៀងធ្លាក់ច្រើនបំផុតនៅតំបន់ខាងជើង ហើយរះបាចបំផុតនៅផែនដីកណ្ដាលទ្វីប ។ នៅតំបន់ទិសខាងកើតឆៀងខាងត្បូងនៃនូវែល- កល្ និងទិសខាងកើតកែត្រូវយ៉ាមានភ្លៀងធ្លាក់រហូតពេញមួយឆ្នាំ ។

សម្បត្តិផែនដី — ១ ដំណាំដែលដុះល្អគណាស់ល្អនៅភាគខាងជើងនិងភាគខាងកើតលើដីកបជាទីទួលខ្ពស់ច្រើនតែជាទីវាលស្មៅនិងព្រៃ

ល្បារ ជាទីសមគួរដល់ការចិញ្ចឹមចៀមពពែ ឯព្រៃឈើមានដំទៃ្យច្រើន តែព្រៃឈើអ៊ុយជាការលិបទុស, ស្រល់, និងជាតិឈើដែលដុះតាមបង្កើះក្ន នៅភាគខាងកើតនិងភាគខាងត្បូងភាគខាងលិច មានតែដើមឈើតាបៗ ដោយច្រើន ។

ដំណាំដែលដាំច្រើន គឺស្រូវចៅ្រ, និងស្រូវជ្រៀវ, អំពៅ, ពោត, ដំឡូងបារាំង, ទំពាំងបាយជូរជាដើម ។

២ – លោហធាតុ – លោហធាតុសំខាន់របស់អូស្ត្រាលី គឺធ្យូងថ្ម, និងមាស លោហធាតុបន្ទាប់មកគឺប្រាក់, សំណ, ទង់ដែងនិងសំណប៉ាហាំង, ហ្វូសហ្វាត, សាំង្កស៊ី, នីកែល, ដែកជាដើម ។

៣ – សត្វ – ចៀមកែះនិងគោជាសត្វដែលចិញ្ចឹមច្រើនបំផុត ធ្វើឲ្យកើតជាជំនួញលក់ចេញយ៉ាងសំខាន់ឡើង ៣ យ៉ាងគឺរោមកែះ, សាច់គោ និងបឿរ ។

ក្នុង ព.ស. ២៤៧៧ មានចំនួនកែះ ១១៤,០៩៩,៤៩៦ គោ ១៣,៥១២,១៩៦ សេះ ១,៧៦៣,២២៥ ជ្រូក ១,០៤៦,៨៦៧ ។

ជំនួញលក់ចេញ – អូស្ត្រាលីជាប្រទេសដែលចំរើនខាងផ្នែកពាណិជ្ជកម្មច្រើន ធ្វើការលក់ដូរនឹងនានាប្រទេសនៅក្នុងលោក ជំនួញដ៏សំខាន់បំផុតនេះរបស់ប្រទេសនេះមាន ៣ យ៉ាង (ព.ស. ២៤៧៤) គឺរោមកែះ (៣២ លានលីវស្ទែរឡាំង) ស្រូវប៊ើ (១៤ លាន) មាស (១២

លាខ) ជំនួញសំខាន់បន្ទាប់មកគឺបៀរ, សាច់សត្វ, ស្បែកសត្វ, ម្សៅម៉ើ, ផ្លែឈើ, សំណ, ស្ករ, ប្រាក់, ស័ង្កសី ខ្លាញ់សត្វនិងឈើ ផ្សេងៗ ។

ប្រទេសដែលទិញជំនួញអូស្ត្រាលីច្រើន គឺអង់គ្លេស, ជប៉ុន, ចិន, បារាំងសែស, សហរដ្ឋអាមេរិក, និងអាល្លឺម៉ង់ ។ ឯប្រទេសដែលលក់ជំនួញឲ្យអូស្ត្រាលីច្រើន គឺអង់គ្លេស, សហរដ្ឋអាមេរិក, ឥណ្ឌា, ពួកកោះអាំងដេនេអៀឡង់ដេស, ជប៉ុននិងអាល្លឺម៉ង់ ។

ជំនួញលក់ចូល — ក្នុង ព.ស. ២៤៧៤ ជំនួញលក់ចូលដែលសំខាន់បំផុតមាន ៤ យ៉ាង គឺសំពត់អំបោះ, ប្រេងកាត, សំពត់ព្រែ, គ្រឿងថ្នាំនិងគ្រឿងស៊ីមី, គ្រឿងអគ្គិសនី ។ ជំនួញបន្ទាប់មកគឺធុង, បារី, ស៊ីកតែ, សៀវភៅ, គ្រឿងសរសេរ, ក្រដាស, ថ្នាំជក់, ដែក និងគ្រឿងម៉ាស៊ីន ។

ផ្លូវគមនាគមន៍ — ក្នុង ព.ស. ២៤៧៣ ផ្លូវរថភ្លើងដែលបើកប្រើហើយ មានខ្នាតវែង ៤៤,៥៦៨ គីឡូម៉ែត្រ របស់ឯកជនប្រមាណ ៦៩៧៦ គីឡូម៉ែត្រ មានផ្លូវថៃអ ១០២៦ គីឡូម៉ែត្រ ។ ផ្លូវអាកាសប្រៃសណីយ៍វែង ១២.៣៨៤ គីឡូម៉ែត្រ ។

ប្រជាជន — ជាជាតិអង់គ្លេសស្ទើរតែទាំងអស់ ចំនួនអ្នកស្រុកកាយមានតិចណាស់ (ប្រមាណ ១ សែននាក់) ។ ចំនួនប្រជាជនទាំងអស់ក្នុង ព.ស. ២៤៧៨ មាន ៦,៧២៤,០០០ នាក់ ច្រើនតែកាន់

សាសនាគ្រិស្ទកាយប្រូតែស្តង់ ហើយមានមនុស្សនៅច្រើនតែក្នុងដែនវិគតូរិយ៉ា និងនូវ៉ែល-កល្ល ។

របៀបរដ្ឋបាល— ទ្វីបអូស្ត្រាលីជាស្រុកចំណុះអង់គ្លេសតាំងមូល ទើបមានវិធីគ្រប់គ្រងទ្វីបនេះ ដូចជាប្រទេសតែមួយ ប្រទេសអូស្ត្រាលីប្រកបដោយរដ្ឋកូលូនី ៦ គឺរដ្ឋវិគតូរិយ៉ា ១ នូវ៉ែល-កល្ល ១ គ្វីនឡង់ ១ អូស្ត្រាលីខាងត្បូង ១ អូស្ត្រាលីខាងលិច ១ កោះតាស្មានី និងវែទ្រែ អូស្ត្រាលីខាងជើង ១ ។

កូលូនីទាំង៦នេះ កាលដាច់ដើមឡើងបំបែកការរដ្ឋបាលជាប្រទេសនីមួយៗដោយឡែកពីគ្នា តមកក្នុងព.ស. ២៤៤៤ រាជការអង់គ្លេស ចាត់បង្រួមជាប្រទេសតែមួយ ដើម្បីឲ្យបានស្រួលក្នុងការត្រួតត្រានិងសេចក្ដីចំរើនរបស់ប្រទេសដោយចាត់ឲ្យមានអ្នកសម្រេចរាជការ ជាដំណាងអង្គព្រះមហាក្សត្រអង់គ្លេសជាប្រមុខ ហើយជាអ្នកប្រើអំណាចត្រួតត្រាស្រុកទេសជាមួយនឹងគណៈរដ្ឋមន្ត្រី ។ ឯសភាការផែនដីដែលមានអំណាចចេញច្បាប់បាននោះ ប្រកបដោយសភាជាន់ខ្ពស់និងសភាដំណាងរាស្ត្រ សមាជិកក្នុងសភាជាន់ខ្ពស់មានចំនួន ៣៦ នាក់ (ក្នុងរដ្ឋនិមួយៗ មានចំនួន៦ នាក់) នៅក្នុងដំណែងម្នាក់ ៦ ឆ្នាំ ហើយមានការជ្រើសផ្លាស់សមាជិកចំនួនពាក់កណ្ដាលគ្រប់ ៗ បីឆ្នាំ ឯសមាជិកសភាដំណាងរាស្ត្រមានចំនួន ៧៦ នាក់ នៅក្នុងដំណែងកំណត់ ៣ ឆ្នាំ ។